ក្រុមជំនុំទំនៀមទម្លាប់
COMMISSION DES MŒURS & COUTUMES

ព្រះរាជបណ្ណាល័យកម្ពុជា

# KAMBUJASURIYÂ

# កម្ពុជសុរិយា

សៀវភៅទស្សនាវដ្តីចេញរាល់ខែ ពីព្រះរាជបណ្ណាល័យ

ឆ្នាំគំរប់ ១១

ខែ ៧, ៨, ៩, រួមគ្នា

កុង្សីយសេនាបតីបានអនុញ្ញាតហើយ

សម្តេចសង្ឃនាយកទាំងពីរគណៈយល់ព្រម




ភ្នំពេញ

ការផ្សាយរបស់ព្រះរាជបណ្ណាល័យ

ព. ស. ២៤៨២

គ. ស. ១៩៣៩

# បញ្ជីរឿង

ទំព័រ

១ — អំពីលោកស្លប៉េនហ៊ែរ និងព្រះពុទ្ធសាសនា(មានត) . . . . . . . . ៥

២ — ទឹកទន្លេសាប របស់ជីគិម-ហោក់ (តពីលេខ ១ ឆ្នាំទី ១១) . . . . . ១៥

៣ — វេយ្យាករណ៍សំស្ក្រឹត ភាគទី ៣ របស់ព្រះវិសុទ្ធិវង្ស ហ. តាត តពីខ្សែ ១០-១១ ឆ្នាំទី ១០) . . . . . . . . . . . . . . . . . . ៤៥

៤ — សិលាចារឹកនគរវត្ត និងបទានុក្រម . . . . . . . . . . . . . . ៥៧

៥ — រឿងព្រេង — ដំឡូង ៧ សន្តាន . . . . . . . . . . . . . . . ៩៩

## រូបក្រៅរឿង

ខែត្រសៀមរាប-វត្តអាទ្វា ព្រះពុទ្ធរូបធាតប្រាក់ . . . . . . . . . . . . ១

# TABLE DES MATIÈRES

Pages

1. Schopenhauer et le Bouddhisme.................... 5

2. L'eau du Tonlé-Sap (par KIM-HAK) ) suite............... 15

3. Grammaire de Sanskrit (par préas VISOTHIVONG H. TATH)

   (suite)........................................ 35

4. Les inscriptions D'Angkor-Vat (suite)................. 57

5. Conte populaires cambodgiens inédits:

   Les Sourds héréditaires............................ 99


HORS TEXTE:

Siem-Réap-Vat Athvéa, le statue du BOUDDHA sur

NÂGÂ............................................. 1



ខេត្តសៀមរាប-វត្តអាទ្វារ ព្រះពុទ្ធរូបនាគប្រក់

# អំពីរូបព្រះនាគប្រក់

នៅក្បែរស្ទឹងសៀមរាប មានវត្តខ្លះល្អមើលណាស់ ដោយមានបុរាណវត្ថុខ្មែរជាន់ដើម - ក្នុងចំណោមវត្តអស់នេះ មានវត្តមួយហៅថា វត្តអាត្វា នៅវត្តនេះមានព្រះពុទ្ធរូបនាគប្រក់មួយ ដែលគេបានកសាងមកក្នុងរវាង ព.ស. ១៥០០ — ១៦០០ ។ គេអាចពិនិត្យមើលព្រះពុទ្ធរូបនេះទុកជាកិច្ចការខាងចំឡាក់ខ្មែរមួយយ៉ាងល្អ ។ យើងគួរតែនិយាយប្រាប់គ្នាយើងឲ្យជួយថែទាំរក្សាទុកឲ្យល្អ កុំឲ្យខូចខាតបាត់បង់ទៅដោយអន្តរាយផ្សេង ៗ ។

# អំពីលោកស្លប៉ែនហឺរ និងព្រះពុទ្ធសាសនា

( មានត )

# អំពីលោកស្កូប៉េនហ៊ាវនឹងព្រះពុទ្ធសាសនា

## ប្រែចេញអំពីកាសែតពុទ្ធសាសនាត្រង់រឿងរបស់លោក

### "SCHOPENHAUER ET BUDDHISME"

កាលលោកស្កូប៉េនហ៊ាវ បានបោះពុម្ពសៀវភៅមួយដ៏សំខាន់របស់លោក កាលពីឆ្នាំ ១៨១៨ នោះ លោកនេះនៅមិនទាន់មានចំណេះចេះដឹងខាងសាសនធម៌របស់ព្រះសមណគោតមជាម្ចាស់នៅឡើយទេ ដ្បិតក្នុងវេលានោះនៅមិនទាន់មានការប្រកាសពុទ្ធសាសនា ដែលត្រឹមត្រូវពិត ៗ ក្នុងទ្វីបឱរុបទេ លុះឆ្នាំត ៗ មក ការសិក្សាព្រះពុទ្ធសាសនាកាន់តែចំរើនក្រាស់ឡើងជាលំដាប់ លោកនេះទើបចួបនឹងសេចក្ដីចំឡែកក្នុងចិត្តលោកថា ពាក្យប្រដៅខាងផ្លូវបរមត្ថរបស់លោកដើរប្រែប ៗ ស្របគ្នានឹងគោលដ៏សំខាន់របស់ពុទ្ធសាសនា ៗ ប្រសិនបើពាក្យដែលពោលមកនេះ ជាការត្រឹមត្រូវតាមដែលយើងជឿហើយ មុខគួរស្ងើចអំពីដំណើរនៃបុគ្គលទាំងពីរពន់ពេកដែលកើតឡើងក្នុងលោកនេះ មានលំនៅឆ្ងាយពីគ្នាណាស់ ទាំងក្នុងវេលាឃ្លាតពីគ្នាដល់ទៅពីរពាន់ឆ្នាំ តែបានស្រាវជ្រាវរកនឹងប្រកាសសេចក្ដីពិតបានស្របគ្នា ៗ

ហេតុនេះ បានជាលោកស្កូប៉េនហ៊ាវនោះ មានគេពោលដំណាលរឿងរបស់លោក ដែលមានសេចក្ដីទាក់ទងគ្នានឹងព្រះពុទ្ធសាសនាក្នុងទ្វីបឱរុបរហូតមក ៗ លោកនេះគេសន្មតថា ជាពុទ្ធបរិស័ទ្យដ៏សំខាន់ជាដំបូងរបស់

ជនជាតិអាល្លឺម៉ង់ ឯសេចក្ដីជាបរមត្ថធម៌របស់លោកនេះផ្សេងពីគ្នានឹងបរមត្ថធម៌របស់អ្នកប្រាជ្ញជាតិឯទៀតៗទាំងអស់ ។ សៀវភៅវណ្ណកម្មជាន់ឯក ភាគ ៤ របស់លោក ឈ្មោះ *Affirmation and Negation of Dirire for life*(១) អាចប្រៀបធៀបគ្នាបាននឹងអរិយសច្ច ខទី ១ នឹងខទី ៤ របស់ព្រះពុទ្ធសាសនា ។ ពាក្យប្រៀនប្រដៅរបស់លោកសំដែងថា ជីវិតទាំងពួងជារបស់មានទុក្ខ ព្រោះធ្លាក់នៅក្រោមអំណាចនៃសេចក្ដីចាស់ជរាគ្រាំគ្រានឹងសេចក្ដីស្លាប់ បើពោលដោយសង្ខេប គឺថា ជីវិតទាំងពួងក៏តង់ធ្លាក់ទៅនៅក្រោមអំណាចអនិច្ចំទាំងអស់ ។ ក្នុងគម្ពីរមជ្ឈិមនិកាយ យើងច្រើនជួបប្រទះសេចក្ដីដែលព្រះសម្មាសម្ពុទ្ធត្រាស់សួរព្រះសាវកថា យម្បនានិច្ចំ ទុក្ខំ វា តំ សុខំ វាតិ របស់ឯណាដែលមិនទៀង តើរបស់នោះជាទុក្ខឬសុខ ? (ព្រះសាវកទូលតប) ថា ទុក្ខំ ភន្តេ ជាទុក្ខព្រះអង្គ" ។ លោកស្កូប៉េនហ៊ែរពោលថា ជីវិតនឹងសេចក្ដីសុខនោះនៅដោយឡែកពីគ្នា ។

ពាក្យប្រដៅដែលពោលមកនេះ រមែងធ្វើឲ្យស្កូប៉េនហ៊ែរបាននាមសន្មតថា ជាមនុស្សឃើញលោកនេះជារបស់អាក្រក់ តាមយោបល់របស់មនុស្សក្នុងលោក ។ តាមទំនងនេះ យើងអាចបន្ទូលឲ្យឃើញធម្មជាតិប្រកបទៅដោយសេចក្ដីក្រៀមក្រំនៃទុក្ខវេទនានៃជីវិត ជម្ពូនាន

---

(១) ការជុះជាលកើតឡើងនឹងការដកចេញនូវភវតណ្ហា ។

របស់មហាមុនីទាំងពីរនោះ សិងមានសេចក្ដីបង្អុលផ្លូវសម្រាប់ចេញចាកទុក្ខដូចគ្នា ហេតុនេះយើងនឹងបន្ទោសពាក្យប្រដៅបែបនេះថា ជាលទ្ធិឲ្យផលអាក្រក់ដល់លោកដូចម្ដេចបាន ដូចជាពួកមនុស្សល្ងង់ខ្លៅចំពួកខ្លះពោលថា តម្រារោគសមុដ្ឋានរបស់ពេទ្យ ជាតម្រាសំឡឹងឃើញលោកជារបស់អាក្រក់ ដោយអាងថា ពណ៌នាឲ្យឃើញសភាវៈនៃរោគក្នុងកងកាយច្បាស់ពភស់ (នាំឲ្យនឿយណាយចិត្តឥតប្រយោជន៍) ។ តាមដោយពិតពាក្យប្រៀនប្រដៅរបស់ព្រះសម្មាសម្ពុទ្ធ របស់លោកស្កូប៉េនហាវ័រ រមែងប្រគល់ឲ្យនូវមគ្គគឺផ្លូវសម្រាប់ដកខ្លួនចេញចាកទុក្ខបានសម្រេច ខនេះមានសេចក្ដីប្រៀបដូចគ្រូពេទ្យ ដែលប្រាប់វិធីព្យាបាលរោគនឹងការសះជាចាករោគដូច្នោះដែរ ។

ព្រះពុទ្ធជាម្ចាស់ត្រាស់ទុកថា ព្រះនិព្វានកើតប្រាកដឡើង កាលបើតណ្ហារលត់អស់ទៅ ហ្នឹងហើយគឺទីបំផុតនៃទុក្ខទាំងពួង ។ លោកស្កូប៉េនហាវ័រពោលថា បុគ្គលរមែងផុតពីគំនរទុក្ខទៅបានក្នុងខណៈដែលខ្លួនបន្ទោបង់នូវតណ្ហាចេញបាន គឺសេចក្ដីប្រាថ្នាអន្ទះអន្ទែងដើម្បីចិញ្ចឹមជីវិតហ្នឹងឯង ។ អដ្ឋកថាចារ្យអង្គខ្លះបានធ្វើអត្ថាធិប្បាយថា បន្ទាប់អំពីមរណៈទៅ លោកដែលជាព្រះអរហន្តរមែងរលត់សាបសូន្យទៅ (មិនវិលកើតទេ) ។ ហ្នឹងហើយជាទីបំផុតនៃគតិភពរបស់លោក ។ លោកស្កូប៉េនហាវ័របានពោលសំដៅយកសេចក្ដីទទេ (គ្មានអ្វី) ថាជាព្រះនិព្វាន

ក្នុងព្រះពុទ្ធសាសនា ហើយថា ជាការចូលដល់ព្រហ្មគត ក្នុងសាសនាព្រាហ្មណ៍ ។ លោកនេះសរសេរទុកថា ការសម្រេចព្រះនិព្វានជាថ្នាក់បំផុតនោះគេនឹងប្រាកដថា ជាសភាវៈទទេដោយដាច់ខាត ។ នៅវេលានេះមិនទាន់មានអ្នកយល់ ឬក៏ចាប់យោបល់របស់លោកនៅឡើយ ។

អំពីពាក្យថា "អនត្តា" នោះ គួរប្រាកដថា ជាគោលធម៌ដ៏សំខាន់ ដែលជាទីបួរមួនៃធម៌ទាំងអស់ ក្នុងព្រះពុទ្ធសាសនា ព្រោះថា បណ្ដាបរមត្ថវិជ្ជាទាំងពួងរមែងវិលវល់នៅជុំវិញគោល គឺ អនត្តា, នេះឯង ។ មុខគួរស្ងើចដែលសង្កេតឃើញក្នុងសៀវភៅរបស់លោកស្កុប៉េនហឺរក៏មានប្រដៅប្រហែលៗគ្នាដែរ ។ របស់ដែលលោកស្កុប៉េនហឺរហៅថា របស់ដែលមាននៅក្នុងខ្លួនរបស់ខ្លួនក៏គឺ " សេចក្ដីប្រាថ្នាដើម្បីរស់នៅ " ហ្នឹងឯង ។ នៅទីនេះយើងមិនទាន់ប្រទះឃើញវិញ្ញាណដែលស្ថិតស្ថេរខ្ជាប់ខ្ជួននៅឡើយ គឺថា មិនទាន់មានអត្តាសោះឡើយ ។ ក្នុងព្រះពុទ្ធសាសនាក្ដី ពាក្យប្រដៅរបស់លោកស្កុប៉េនហឺរក្ដី យើងនឹងប្រទះឃើញសេចក្ដីដែលពោលទុកថា ការរួចផុតស្រឡះចាកទុក្ខរមែងមានតែមួយផ្លូវ គឺការផ្ដាច់តណ្ហាបោលចេញឲ្យអស់ ។ លោកនេះពោលទុកថា ខ្ញុំគួរពោលទុកឬទេថា សេចក្ដីប៉ុនប៉ងនៃជីវិតប្រកបដោយអត្ថតែមួយប៉ុណ្ណោះ គឺថា ចូរនាំគ្នារៀនដើម្បីទំលាយបង់នូវសេចក្ដីប្រាថ្នាក្នុងជីវិត ? ព្រោះថា

ការផ្តើមឡើងកាន់ទីដ៏ខ្ពង់ខ្ពស់ក្រៃលែង នេះបុគ្គលត្រូវតែប្រុងប្រៀបខ្លួន ដោយអាស្រ័យជីវិតនេះឯងដែរ ។

តែមើលទៅហាក់ដូចលោកស្ប៉េនហ៊ើរ មានសេចក្តីយល់ទាស់តាមយោបល់របស់លោក ក្នុងខណៈដែលលោកអធិប្បាយអំពីយោបល់របស់ខ្លួនថា "របស់ដែលមានជាប់ក្នុងខ្លួន" នោះនៅក្រៅគំនិតដែលទាក់ទងនឹងកាលវេលា ព្រោះរបស់ដែលនៅក្រៅកាលវេលារមែងនៅក្រៅសេចក្តីប្រែប្រួល សេចក្តីប្រែប្រួលដែលមានសភាពប្រាកដឡើងច្បាស់លាស់ ចំពោះក្នុងរយៈមានកំណត់កាលវេលា ។ ការប្រែប្រួលនៃ "សេចក្តីប្រាថ្នាក្នុងជីវិត" ក្នុងមួយខណៈៗនោះសំដៅដល់សេចក្តីប្រែប្រួល ដែលមានជាប់នៅក្នុងខ្លួន, ការបំណងនឹងមានជីវិតរស់នៅរមែងជាការអន្ទះអន្ទែងដោយសេចក្តីងងឹតល្ងង់ខ្លៅ គ្មានសតិបញ្ញាបេះដូងអ្វីឡើយ ដែលតាមផ្លូវព្រះពុទ្ធសាសនាហៅថា ភវតណ្ហា ព្រោះដរាបណា តណ្ហានេះមិនទាន់លែង ជីវិតក៏ត្រូវតែមាននៅដរាបនោះ ។ គំនរទុក្ខថ្មីក៏លូតលាស់ចំរើនឡើងអំពីជីវិតនោះ ខនេះឃើញសមតាមពាក្យដែលលោកស្ប៉េនហ៊ើរពោលទុកថា កាលបើប្រាថ្នានឹងមានជីវិតរស់នៅរមែងមានជីវិតទទេ ជាដរាប ការនឹកខ្លាចថា រអាចលែងផុតស៊ប់ចុះទៅដោយអំណាចសេចក្តីស្លាប់នោះជាសេចក្តីវង្វេងកាន់ច្រឡំយ៉ាងធំ ។

មិនមានអ្នកឯណា អាចកំណត់ដឹង ហើយចង្អុលប្រាប់អំពីសេចក្តីឥតខ្លឹមសារ ទីងសេចក្តីសោះសូន្យទទេនៃធម្មជាតិដ៏ពិតប្រាកដបានទេ តែសេចក្តីនេះមិនត្រូវដល់ព្រះសម្មាសម្ពុទ្ធជាម្ចាស់ផងទេ ឱកាសដែលមានអំណាចលើមូលហេតុនៃសេចក្តីទុក្ខនោះត្រូវអាស្រ័យការកំណត់ដឹងនូវមូលហេតុនេះឯង ។ ធម្មជាតិដ៏ពិតប្រាកដនៃជីវិតនោះ ជារបស់ផ្សាយចេញឲ្យឃើញច្បាស់បាន ដោយកម្លាំងហេតុផល ដែលជាគុណវិសេសដ៏ប្រសើរចំពោះខ្លួនរបស់មនុស្ស ។ បណ្តាសត្វតិរច្ឆានទាំងពួងត្រូវចង្ក្រាប់ទឹងកងនៃសង្សារវដ្ត ព្រោះថា ហេតុផលនឹងការយល់ត្រូវដោយផ្លូវចិត្ត មិនទាន់ប្រាកដច្បាស់ដល់ចិត្តវាឡើយ ។ មនុស្សជាសត្វចំពួកមួយប៉ុណ្ណោះ ដែលមានហេតុផលចំរើនលូតលាស់ឡើងខាងក្នុងសន្តានចិត្តរបស់គេបាន ។ ការពោលតាមពាក្យរបស់លោកស្ពែនហ៊ែរនោះ មានទុកសម្រាប់សាងគំនិតនឹកគិតទាំងឡាយ គំនិតដែលផុះផុះផាលឡើងដោយអំណាចពហុលីកតកម្ម នាំឲ្យមនុស្សមានឥស្សរភាពចំពោះរបស់ដែលនៅជុំវិញខ្លួន ។ ខនេះយើងអាចឃើញបាន កាលអ្នកបួសកំពុងធ្វើសមាធិ ឬអ្នកប្រាជ្ញសិល្បកំពុងគិតធ្វើវត្ថុអ្វីទៀត សេចក្តីប្រាជ្ញាក្នុងជីវិត ក៏មានសេចក្តីស្ងប់ស្ងាត់តទៅមួយខណៈនោះ ។

លោកស្ពែនហ៊ែរនឹងធម្មៈក្នុងពុទ្ធសាសនា មានពាក្យប្រដៅដូចគ្នាអំពីវិលកើតជាថ្មីនៃសត្វលោក តែលោកទាំងពីរពោលបដិសេធជំនឿថា

វិញ្ញាណតែងផ្លាស់ទៅកាន់កងថ្មី ។ ការជាប់ទាក់ទងគ្នានៃជីវិត មានបានដោយមិនបាច់ផ្លាស់ប្ដូរវិញ្ញាណ ។ ជីវិតរមែងកើតហើយកើតទៀតបានដោយអំណាចសេចក្ដីប្រាថ្នា (ក្នុងភវតណ្ហា) ។ សេចក្ដីឆ្លាតឆ្លៀវនិងហេតុផលដែលមាននៅក្នុងខ្លួនបុគ្គលនោះ រមែងធ្លាក់ទៅនៅក្រោមអំណាចសេចក្ដីប្រែប្រួល និងសេចក្ដីចាស់គ្រាំគ្រា របស់អស់នោះគ្រាន់តែជាលក្ខណៈផ្សេង ៗ នៃជីវិត ចំពោះបុគ្គលនីមួយ ៗ និងប្រកាន់ថាជា "របស់ដែលមាននៅក្នុងខ្លួនរបស់ខ្លួន" មិនបានទេ ។

លោកស្កូប៉េនហឺរ មិនមានពាក្យឆ្លើយប្រស្នាជាដើមហេតុ ។

(មានត)

# ទឹកទន្លេសាប

## របស់ប៊ី គិម-ហាក់ លេខានុការក្រសួងប្រៃសនីយ៍

## (ប៉ុស្ដខ្សែល្លួស) បានតែងនឹងរៀបរៀង

(តពីលេខ ១ ឆ្នាំទី ១១)

# ឈុតទី ៥

## ទុក្ខរបស់នាងម៉ាណ៉ា

នាងម៉ាណ៉ាឃើញប្ដីលង់ទឹក ប្រឹងរត់ឡើងលើគោក រត់តាមមាត់ច្រាំងស្រែកហៅប្ដី មិនឮឆ្លើយសោះ នាងក៏ស្រែកយំខ្លួន ៗ ថា ឱអ្នកម្ចាស់ប្អូនអើយ អ្នកហែលត្រឡប់មករកប្អូនវិញក៏ ម្ដេចឡើយបានជាអ្នកមកវិនាសខ្លួនបាត់ក្នុងទឹកសូន្យឈឹង បើប្រសិនណាជាបងស្លាប់ គួរស្លាប់នៅលើគោក ឲ្យបានប្អូនបីត្រកង ឃើញមុខផង ម្ចាស់អើយ ប្អូនតាំងពីថ្ងៃនេះទៅ សមជាកំព្រាគ្មានគ្នានៅកៀកកើយឡើយ ឱលោកទេវតាអើយ សូមលោកមេត្តាជួយជីវិតប្ដីខ្ញុំ ជួយឲ្យគាត់ហែលរួចដល់ត្រើយកុំខាន ឱទឹកអើយទឹក មិនគួរមកពង្រាត់សង្សារខ្ញុំសោះ ៗ

នាងម៉ាណ៉ាបោកខ្លួនទន្ទៀលសន្លប់នៅមាត់ទន្លេបាត់ស្មារតី សន្សើមចុះអាប់ត្រជាក់ជ្រួតជ្រាបដល់កាយនាងម៉ាណ៉ា ៗ ដឹងខ្លួនភ្ញាក់ឡើង ប្រឹងក្រោកតេះតះស្ទើរតែពុំរួច ស្រយុតស្រយាកញ័រអស់កាយដូចគេថ្ពប ដើរដម្រង់ទៅផ្ទះ ប្រាប់មាតាបិតាបងប្អូនពៀងណានទាំងអស់គ្នា ៗ ក៏ភ័យនាំឡោឡាស្រែកកងរំពងហៅគ្នា ខ្លះបានចែវ ខ្លះបានប្រវា ខ្លះបានបន្ទុះ អុចព្រោងព្រាត រត់យាំងប្រញាប់ ដើរចុះទូកស្រែកបង្កូកហៅចៅហាម ស័យពុំឮឆ្លើយ រកពុំឃើញសោះ ចាញ់បំណោះក៏វិលត្រឡប់មកភូមិវិញ ៗ

បានប្ដីប្រទោមល្អពេក គួរផ្ដេកផ្ដិត ទាស់តែកម្មមកផ្ដាច់ឲ្យព្រាត់ពីគ្នាមួយរំពេច ហេតុនេះហើយ បានជាព្រះសម្មាសម្ពុទ្ធទ្រង់ប្រដៅសត្វឲ្យខំគេចចេញពីវដ្ដសង្សារ ដែលជាទីជោរជន់ទូវទុក្ខ បង់ហោមស័យអើយមិនគួរចាកចោលប្អូនឲ្យនៅម្នាក់ឯងសោះ ស្រណោះអើយស្រណោះ ពេលដេកអ្នកដឹកដៃប្អូនចូលបន្ទប់ លើកប្អូនដាក់លើគ្រែ ថ្នមប្អូនមិនឲ្យអាក់អន់មួយកត្រី ដល់ព្រះសុរិយាស្មានអរុណោទ័យ អ្នកដាស់ប្អូននាំគ្នាត្រសង់ទៅលុបលាងកាយ ពេលបាយអ្នកពុំដែលភិសាចោលប្អូនឡើយៗ

នាងយំសស្រែងសស្រែក្នុងវេលាយប់នោះ ដល់មាតានាងភ្ញាក់ចាកនិទ្រាកាលណា ក៏ចូលទៅលួងលោមកូនថា កូនអើយ នាងកុំយំពេកធ្វើម្ដេចកូនសាងអាក្រក់ពីជាតិមុនមក ទើបជាតិនេះកូនលំបាកបែបហ្នឹងមិនតែរូបកូនឯងទេ គ្រប់រូបទាំងអស់ តែងព្រាត់ប្រាសកិរិយានឹងស្វាមីព្រាត់ស្លាប់ក៏មាន ព្រាត់ទាំងរស់ក៏មាន ណ្ហើយកាត់ចិត្តកាត់ថ្លើមចេញទៅចាំម្ដាយជូនកូនទៅរកតាអាចារ្យគាំសំណាក់ធម៌ មើលមើល តើប្ដីនាងស្លាប់ឬរស់ ៗ

នាងម៉ាល៉ាបានស្រាលទុក្ខបន្តិច ទៅយកធូបទៀនដាក់ជើងពានម្ដាយនាំដើរសំដៅទៅផ្ទះតាអាចារ្យគាំ ៗ ឃើញភ្ញៀវមកដល់ប្រឹងក្រោកកន្ទេលមកក្រាល ស្រែកហៅនាងម៉ុកជាកិរិយា ក្រមុំឲ្យយកប្រអប់ស្លាមកដាក់ សាកសួរកេកទាក់ទៅនាងបុប្ផាផាន់ទឹងនាងម៉ាល៉ា នាងបុប្ផាផាន់

ថ្ងៃនិទ្ទុករបស់កូនខ្ញុំស្រេចហើយ សូមឲ្យលោកតាអង្គុយធម៌តាមមើលចៅហេមស័យ តើស្លាប់ឬរស់នៅឡើយ តាគាំដឹងថា លោកមកដល់ ធ្វើទឹកមុខញញឹមស្ងួតថា ឱអាណិតនាងពេក ខ្ញុំនៅក្មេងស្រស់ស្រអាំ កុំភ័យចាំតាតាវនាតាមប្តីនាងមើល ប៉ុន្តែធម៌តាមិនថោកទេថ្លៃណាស់ សំណាក់ម្តង ១ គោងមានទៀន ៥ ធូប ៥ ផ្កា ៥ លាជកន្ទោង សំពត់សដប់ហត្ថ ប្រាក់គន្ធៈណៃន ។

ម៉ាល៉ា ចាស អស់ប៉ុន្មានក៏អស់ចុះ តែខ្ញុំគ្មានសំពត់សជាប់មកទេ ទឹងទៅរកទិញក៏បាន តែយូរពេក បើដាក់ប្រាក់ជួសបានឬទេ ។

តាគាំ អើ យកប្រាក់ដាក់ជួសសំពត់សរតែល្អណាស់ហើយ នាងទាំងពីរនាក់នៅចាំតាខាងក្រៅ តាទៅធ្វើនមស្សការថ្វាយបង្គំរលឹក គុណគ្រូអាចារ្យ គុណព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ រួចស្រេចតាគាំងចូលក្នុងបឋមជ្ឈាន បឋមជ្ឈានបានហើយ ចូលទុតិយជ្ឈាន ទុតិយជ្ឈានបានហើយ ចូលតតិយជ្ឈាន ឈានទៅរកមើលក្នុងស្ថាននរក ប្រេតអសុរកាយ ស្ថានសួគ៌ទាំង ៦ ជាន់ ឈានចូលទៅមើលក្នុងទឹក ក្រែងជួនឃើញចៅហេមស័យ ។

ម៉ាល៉ា តាមតែតាមេត្តាចុះ ។

តាគាំ កុំបារម្ភ ឈានតាពូកែណាស់ ។

តាគាំគាត់ស្លៀកស ពាក់ស ពានាស បើកទ្វារចូលទៅក្នុងបន្ទប់ តែនក្អែនមុខគ្រែព្រះធម៌ អុចធូបបីសរសៃរយ ៗ ធ្វើមាត់អួច ៗ ហាក់ដូចជាលួចជេរគេ ដល់បានមួយស្របក់ដោយគាត់ដេកពុំបានពីយប់មុន តាគាំកំលក់ស្រមុក ឃូ-ៗ ទាំងអង្គុយហើយយល់និមិត្តឃើញដូចជាសត្វក្រពើមួយ ពាំមនុស្សម្នាក់ហែលកាត់ទន្លេដល់ទៅ តាគាំភ័យណាស់ ភ្ញាក់ក្រញាងឡើងយកទឹកលុបមុខ មួបារីស្លឹកសង្កែមួយយ៉ាងធំជក់ ទើបចេញមកខាងក្រៅធ្វើអែះអែះ មើលទៅនាងម៉ាល៉ាហើយគ្រវីក្បាល ៗ

នាងម៉ាល៉ាសួរតាគាំថា ឃើញដូចម្ដេចខ្លះ ។

តាគាំថា ការនេះ តាពុំចង់និយាយទេ ក្រែងលោកើតទុក្ខ លោអើយប្ដីលោសព្វថ្ងៃនេះ នៅក្នុងពោះក្រពើស្លាប់បាត់ទៅហើយ ណ្ហើយកុំសោកស្ដាយអី ខំតែធ្វើបុណ្យឲ្យបានផ្សាយផលឲ្យគ្នាទៅ ធ្វើម្ដេចការស្លាប់ព្រាត់ប្រាសគ្នានេះគ្មានបុគ្គលណាចៀសរួចទេ ។

នាងម៉ាល៉ាឮតែថា ប្ដីស្លាប់ទៅហើយក៏បោកក្បាលទៅលើជញ្ជាំងផ្ទះ ព្រួសប្រគាំង ៗ ស្រែកទ្រហោយំទួញក្ដែង ៗ គួរឲ្យវេទនាដល់ត្រចៀកអ្នកស្ដាប់ពេកណាស់ នាងបុប្ផាផាន់ជាម្ដាយ ស្ទុះទៅត្រកងកូនទំនិយាយបញ្ចុះបញ្ចូលឲ្យគិតតាមផ្លូវធម៌ ម៉ាល៉ារឹងរិតតែស្រែកទ្រហោយំទៀតគ្មានស្រាក ដល់ក្បាលព្រលប់ស្ដ្រីទាំងពីរនាក់ត្រឡប់មកផ្ទះវិញ នាង

ម៉ាលា កោរសក់ស្លៀកស កាន់ទុក្ខប្ដីតាមលំអានអំពីបុរាណមក រក្សាសីល ធ្វើបុណ្យបរិច្ចាគទានឲ្យបានទៅប្ដីរៀងរាល់ទិវាគ្មានឈប់ ។

ចៅសុត្តា កាលណាបានដឹងថានាងម៉ាលាមេម៉ាយហើយនឹកត្រេកអរណាស់ថា ឱនាងម៉ាលាអើយ នាងបំជាគូព្រេងរបស់បងមែនពិត ហេតុនេះប្រុសណាមកគ្រងខ្លួននាងពុំបានយូរប៉ុន្មានទេ គង់តែបែកស្ថានគ្នា បើខ្លួនបងវិញ នឹងបានជួបជុំរហូតដល់ស្លាប់រៀងខ្លួន ម៉្លេះហើយបងសុំដណ្ដឹងម្ដងទៀត យកប្អូនឲ្យទាល់តែបាន ។

គិតស្រេចវេលាណា ចៅសុត្តាទៅក្រាបសំពះជំរាបមាតាបិតាខ្លួនតាមដំណើរអំពីរឿងនាងម៉ាលាថា ឱលោកឪពុកលោកម្ដាយដ៏ចម្រើនអើយ ខ្ញុំបាទមានកម្មក្រាស់ណាស់នឹងនាងម៉ាលា ចិត្តកូននៅតែស្រឡាញ់នាងនេះ គ្មានភ្លេចសោះ មេម៉ាយក៏ដោយ សូមលោកឪពុកលោកម្ដាយរៀបបណ្ណាការចូលដណ្ដឹងនាងនេះម្ដងទៀតឲ្យខ្ញុំកុំខាន បើមិនបាន ច្បាស់ជាជីវិតកូនសូន្យជាន់នឹងហើយ ។

លោកសេនាវិជ័យនឹងភរិយា អាណិតកូនខ្លោចចិត្ត ហៅពួកចាស់ ៗ បានដប់នាក់ឲ្យនាំបណ្ណាការ មានវត្ថុគ្រប់មុខដ៏មានដំឡៃឲ្យទៅនិយាយដណ្ដឹងនាងម៉ាលា ។

សីណា នឹងនាងបុប្ផាផាន់ កាលបានឃើញភ្ញៀវមកពេញផ្ទះត្រៀបត្រា យកទាំងរបស់មកពោរពេញ ក៏ទៅជាស្រឡាំងកាំង ប្ដីគេទៅកេកន្ទួល

មកក្រោល ប្រពន្ធទៅកន្ទ្រាក់ប្រអប់ស្លា នឹងកន្ទោរមកដាក់ ពួកចាស់ទុំនាំគ្នាសំពះជំរាបសួរ ឲ្យគួរសមតាមច្បាប់ហើយនិយាយថា យើងជាអ្នកបំរើរបស់លោកសេនាវិជ័យ លោកមានចិត្តចង់ចងស្ពានមេត្រីនឹងអ្នក ប្រើយើងមកឲ្យដណ្តឹងនាងម៉ាលា ឲ្យកូនលោកឈ្មោះសុគ្គា លោកបានមកដណ្តឹងម្តងហើយ តែមិនកើតដោយសេចក្តីទាក់ទាមគ្នា ឥឡូវនេះលោកសូមឲ្យអ្នកលៃលកឲ្យខានតែបាន នៃអ្នក លោកសេនាវិជ័យ លោកមានស័ក្តិដប់ពាន់ ប្រាក់លោកយ៉ាងតិចត្រឹមពីរហ៊ឺនណែន សម្បត្តិសម្បូណ៌ មនុស្សម្នាបរិវារលោកច្រើនរាប់ពុំអស់ទេ លោកមានកូនប្រុសតែមួយរូប កងក៏ល្អបំណោះក៏បាន ការអស់នេះមិនគួរយើងថ្លែងជំរាបទេ ពីព្រោះអ្នកក៏បានជ្រាបសព្វគ្រប់អស់ហើយ នាយសុគ្គាស្រឡាញ់កូនអ្នកនោះណាស់ មេម៉ាយក៏ដោយក៏មិនគិត បំណែកខ្លួនយើងវិញ បើមានកូនស្រីរូបឆោមល្អដូចកូនអ្នក យើងមិនបាច់ឲ្យអំពល់ច្រើនទេ លើកឲ្យនាយសុគ្គាមួយរំពេចដេកស៊ីតែបុណ្យកូនស្រីបានមួយអាយុ ទៅណាសុទ្ធតែគេសែង ជើងលែងជាន់ដីហើយ ប៉ុន្តែយើងគ្មានសំណាងផ្លូវបុណ្យពីជាតិមុនមក មានកូនសុទ្ធតែខ្មៅៗ ក្រញេស សក់ក្រញាញ់រួញក្រញេស ប្រុសខ្ទើមទាំងដិតផង ។

សីណា — បែរកែះប្រពន្ធនិយាយថា ម្តេចម៉ែមីនាង ទៀតហើយ កាលពីជាន់មុនបងបណ្តោយតាមចិត្តបានជាខូចពេលបង់សៀត

ទៅ ឥឡូវនេះបុណ្យយើងមកដល់ទៀតហើយ តើប្អូនចង់ទៅក្នុងភក់ល្បាប់ជាដែលហ្នឹង ឬចង់ខ្ពស់ដូចបងដែរ ឬអី ។

បុប្ផាផាន់ — ខ្ពស់ៗ ប្រយ័ត្នក្រែងធ្លាក់កប់ភក់ ។

សីណា — ទទៀតហើយ អ្នកទាំងអស់គ្នាស្តាប់ចុះ កាលជាន់មុន ខ្ញុំព្រមឲ្យនាយសគ្គា ម៉ែមីនាងគេប្រកែក ខ្ញុំក៏ព្រមតាមទាល់តែរហេមរហាមព្រាត់គ្នាអស់រលីង ស្រីតែមិនយកពាក្យប្រុស ច្បាស់ជារកសម្ពត់ស្លៀកគ្មានទេ ។

បុប្ផាផាន់ — សម្ពត់ខ្ញុំចុកហើបស្លៀកមិនអស់ ។

សីណា — អញចំជាកម្មក្រាស់បានប្រពន្ធមួយខុសគេខុសឯង មួយជាន់នេះអញប្រាប់ឲ្យស្រេច បើយកមីម៉ាល៉ាឲ្យនាយសគ្គាពុំបាន អញកោរក្បាលចូលវត្ត បួសជាលោកសង្ឃលែងសឹករហូត ។

បុប្ផាផាន់ — បើបងបួសជាលោកសង្ឃ ខ្ញុំបួសជាយាយជីដែរ ពេលឆាន់ៗ ជាមួយគ្នា ពេលសឹងយាយជីខ្ញុំច្បាស់ជាសឹងជាមួយទីង..... ហើយ ។

សីណា — នេះចំជាស្រីបំផ្លាញសាសនា ។

បុប្ផាផាន់ - ពាស - ខ្ញុំបំផ្លាញតែសាសនាបងឯង តែត្រង់ព្រះពុទ្ធ-សាសនា ខ្ញុំពុំហ៊ានបំផ្លាញទេ សូមបងកុំតូចចិត្តអ្វី ខ្ញុំចំអន់លេងទេតើ ខ្ញុំគិតការនេះរឿយៗមកហើយ កូនយើងមេម៉ាយទៅហើយគួរផ្សងស៊ំ-

ណោងក៏សនា ប្រជុំយឲ្យនាយសត្វាទៅចុះ ក្រែងជួនប្រកបដោយទូវ សីលាទិគុណ បុណ្យជួយ ៗ ក៏ឲ្យបានសុខសាន្តយូរអង្វែងទៅ ។

សីណា - អើល្មមតែគ្នាខឹងទៅហើយ បានប្រាប់ថាចំអន់...... ចំអន់ លេងទេ លេងនេះលេងអាក្រក់ ការប៉ុនក្តីមកធ្វើលេងកណ្តាលហ្វូង, លោកអ្នកទាំងអស់គ្នាមើលចុះ ប្រពន្ធខ្ញុំលេងអើយលេង ។

ការនេះ សូមលោកអ្នកអញ្ជើញទៅជំរាបលោកសេនាវិជ័យវិញចុះថា យើងខ្ញុំទាំងពីរនាក់ពប់អានស្រឡាញ់លោកណាស់ ទាំងកូនលោកក៏ យើងស្រឡាញ់ ចូលចិត្តចង់បានធ្វើជាកូនប្រសាដែរ តែយើងខ្ញុំពុំទាន់ បានសួរចិត្តកូនស្រីនៅឡើយ បើកថាយ៉ាងណា ៗ សឹមខ្ញុំជូនដំណឹងជា ក្រោយមិនខាន តែឲ្យលោកសង្ឃឹមថា ដប់បានទាំងដប់ ពីព្រោះទំមិន ដែលធំជាងនាល ផាលមិនធំលើសស្នែក ។

ពួកយាយ តា ចាស់ទុំ នាំគ្នាទៅជំរាបលោកសេនាវិជ័យសព្វគ្រប់ ប្រការ លោកសេនាវិជ័យត្រេកអរណាស់ ហៅកូនប្រពន្ធមកប្រាប់ ឯនាងបុប្ផាជាន់ ទឹងសីណា ដល់កៀវចុះបាត់ទៅ ក៏នាំគ្នាចូលបន្ទប់ នាងម៉ាលា ៗ កំពុងតែដេកភ្ញាក់ឡើងម៉ួម៉ាអង្គុយបត់ជើងចំពោះមុខឪពុក ម្តាយ ។

សីណា — នែកូនស្រីឪពុក ក្នុងខណៈនេះតោងកូនស្តាប់ពាក្យ ឪពុកឲ្យបានមែនទែន ខ្លួនកូនមេម៉ាយកំព្រាស្លាប់ប្តីជាការមិនល្អមើលទេ

ប្រុស ៗ ក៏ដឹងថា នាងនៅតែម្នាក់ឯង ក៏មើលងាយ មួយទៀត ទ្រព្យសម្បត្តិយើងសព្វថ្ងៃកាន់តែទន់ថយណាស់ទៅហើយ ឆ្នាំនេះស្រែចម្ការក៏ខានធ្វើ រវល់តែដេកដួតទឹកភ្នែក ឥឡូវនេះនាយសត្ថាមិនដាច់ចិត្តនឹងកូនសោះឡើយ គេបានយកជំនូនយ៉ាងសន្ធឹកពេញមួយកំណាត់ផ្ទះមកឲ្យកូន ឪពុកសូមអង្វរនាងកុំឲ្យប្រកែក ។

- ម៉ាលាបានឮហើយ ហាក់ដូចជាគេយកលំពែងមួយមកចាក់កណ្ដាលទ្រូងស្រែកយំថា ហេតុតែឯងមេម៉ាយ បានគេមើលងាយបែបហ្នឹង ប្ដីឯងស្លាប់មិនទាន់បានប៉ុន្មានខែ ក៏ហ៊ានមកឆាឆៅទៀត ចំជាមនុស្សព្រហើនថ្វីបើក៏មានប្រាក់ច្រើន អញមិនដែលខ្វីក៏ចាយកាលណា ។

លោកឪពុកអើយ មេម៉ាយឯទៀតច្រើនតែប្រុសបៀតបាន ឯមេម៉ាយខ្ញុំ ប្រុសជិតមិនបានទេ កុំថានាយសត្ថាមានបុណ្យសម្បត្តិចំណេះប៉ុណ្ណោះ មានច្រើនជាងណឹងដប់ភាគខ្ញុំក៏ពុំស្បិតផង ខ្ញុំសព្វថ្ងៃទឹកតែខ្មោចប្ដីខ្ញុំ សូមលោកឪពុកជ្រាប ។

សីណា — ព្រះអើយព្រះ មីនេះចំជាមេម៉ាយក្អឹង មិនមែនជាមេម៉ាយទឹក លូកមិនបានទេល្មួយ កាលពីដើមស្មានថា ក៏កូនឯងពិតៗឥឡូវទើបនឹងដឹងជាន់នេះ នែម៉ាលា ឯងហើយនឹងអញក៏ល្មមដែរ ប្រឹងបង្កើតប្រឹងចិញ្ចឹម តាំងពីតូចដល់មានប្ដីរហូតដល់មេម៉ាយទៀត និយាយការប៉ុណ្ណឹងឯងមិនខ្ចីស្ដាប់ យើងល្មមឈប់ហៅឪ ហៅកូនតទៅទៀត ។

ម៉ាលា — សូមទោសលោកឪពុក ការឯទៀតៗ កូនចេះតែស្តាប់ តែត្រង់រឿងនេះ កូនសូមចិត្តមួយគ្រា ។

សុីណា — មិនតែមួយគ្រាទេ ពីរគ្រាមកហើយ ឯងដឹងខ្លួនទេ ។

ម៉ាលា បាស មែនហើយ តែគឺរឿងដដែលៗ មនុស្សយើងគ្រប់រូបប្រាថ្នាសេចក្តីសុខ តែខ្យល់កំសនាបក់ជូនទុក្ខខ្លួនត្រូវតាមយថាកម្ម ខ្ញុំក៏ដឹងទុក្ខរបស់លោកឪ លោកម៉ែៗ កាន់តែខ្សត់ខ្សោយទ្រព្យសម្បត្តិ រីតតែបាស់ទៅទៀតផង ការចិញ្ចឹមជីវិតជានានៅលើខ្លួនកូន សុំទូលកញ្ចើលក់តបស្នងសងគុណមាតាបិតាវិញ ។

សុីណា — អើ ខានឯងរៀបកញ្ចះគេឯងបេះគ្រប់ ឯបុកពាថ្ងៃចូរ នៅតែលើផ្ទះផាត់ម្សៅ សិតសក់ គុបតែងកាយឲ្យតែប្តីស្រឡាញ់ គេហៅសុទ្ធតែលោកស្រីៗ ឯងមិនបង់ នេះចំជាពូជជ្រូក កុំថាឯងរកស៊ីមួយថ្ងៃបានពីរបីស្ទឹង បានដល់មួយណែន អញក៏មិនខ្វល់ស៊ីកំឡាំងឯងផង អញហើយនឹងឯង អស់ជាគ្នាត្រឹមណឹងហើយ ។

បុប្ផាផាន់ កូនម៉ែ នាងកុំប្រកែកក្រែងបែកការធំ តោងកូនអាសូរទ្រង់ម្តាយផង សព្វថ្ងៃម្តាយចំបែងចិត្តណាស់ បានកូនមួយអក័ព្យអ៊ូម៉េះ ការដែលស្មានថាត្រូវ ទៅជាខុសទទេ ។

ម៉ាលា ខ្ញុំបានដំរាបម៉ែសឹងតែរាល់ថ្ងៃថា កូនលែងយកប្តីទៀតហើយៗ

បុប្ផាផាន់ បើកូនឯងប្រកែក ម៉ែក៏យឲ្យបែកខ្ទង ។

សីណា — រកយកម្ដងទៅ រកយផ្ដាំ រួចបណ្ដេញកំឲ្យចុះពីផ្ទះឲ្យ ដាច់ តែសំពត់អាវបន្តិចកុំឲ្យរកផង ។

ម៉ាលា — ហេតុដូចម្ដេចបានជាកយបណ្ដេញខ្ញុំៗពួកគេតែងនិយាយ ថាក្រមុំដណ្ដឹងម្ដាយ មេម៉ាយដណ្ដឹងចិត្ត ។

សីណា — ច្បាប់នេះមិនដឹងរបស់ស្រុកណាទេ រីឯច្បាប់ស្រុកនេះ គេថា ក្រមុំដណ្ដឹងម្ដាយ មេម៉ាយស្រេចនៅលើឪពុក ។

នាងម៉ាលា ទុញទាល់គំនិតខ្លាចក្រែងមាតាបិតាកយនាំឲ្យអាស្រូវ ប៉ាក់យ អង្គុយតែយំមិនបរិភោគបាយទឹកចំនួន ៣ ថ្ងៃស្គមស្គាំងខ្លួនប្រាណ ទន់ល្វន់ល្វាយអស់ ។

នាងបុប្ផាផាន់ឃើញកូនមិននិយាយពីរឿងនោះទៀតស្មានថា កូន ព្រមតាម ក៏ទៅដំកបលោកសេនាវិជ័យ ឲ្យគាត់ចែងសង់ពេងក្នុងថ្ងៃបន្ទូ ក្រោយនេះ ទីងរៀបមង្គលការកូនឲ្យទាន់ក្ដៅចិត្ត ការនេះទុកយូរមិនបាន ទេ លោកសេនាវិជ័យមុខញញឹម ចូលទៅហៅចៅសត្ដាឲ្យមកសំពះសួរ នាងបុប្ផាផាន់ៗឃើញកូនប្រុសហើយក៏ថ្លែងប្រាប់ថា នៃកូនប្រុសម្ដាយ គឺសំណាងកូនទីងមីនាងម៉ាលា បានកសាងជាមួយគ្នាក្រាស់ក្រែលណាស់ ពីអតីតមក ម្ដាយគ្រាន់តែសួរចិត្តកបន្តិច មុខកឡើងញញឹមហើយគឿន ឲ្យរៀបចំកំឲ្យឆាប់ផង ។

សគ្កា — យីមែនប្អូនអីម៉ែ ។

បុប្ផាផាន់ — អ្នកណានិយាយលេង ។

សគ្កា — សូមលោកម៉ែមេត្តាប្រាប់ប្អូនផងថា ខ្ញុំបាទរលឹកណាស់ មិនយូរប៉ុន្មានទេគង់តែបានឃើញមុខគ្នាហើយ ។

បុប្ផាផាន់ — មិនអីទេចាំម្តាយប្រាប់ឲ្យ ។

រួចហើយគឺលោកសេនាវិជ័យត្រឡប់មកផ្ទះអាត្មាវិញ ។

លោកសេនាវិជ័យប្រើមនុស្សប្រមាណ៣០នាក់ទៅកាប់ឬស្សី ដេរស្លឹក យកមកធ្វើប្រក់រោងក្រសាល ចំនួន ៤ ខ្នងវែង ១ រៀបតុបតែងចងផ្កា នឹងស្លឹកឈើសម្រាប់ទទួលភ្ញៀវ ចាត់មនុស្សឲ្យទៅរកជួលភ្លេងពិន-សៀម-យួន-ចាម-ក្លូឡា ចំនួន ៤ វង់ ទិញជ្រូក ៣០ គោ ១០ មាន់ ១ រយ ទា ១ រយ ស្រាស ៥០ ទុទិន ស្រាត្នោត ៥ ពាង នឹងគ្រឿងគ្រប់យ៉ាង ចាត់ឲ្យអ្នកផ្ទះទៅមហាយកគ្រឿងមាសប្រាក់-ពេជ្រសំពត់អាវហូលព្រែ យ៉ាងថ្លៃៗ ទៅជូននាងម៉ាលា ៗ ទទួលយកដោយមុខក្រៀមក្រំ គ្មានសប្បាយក្នុងចិត្តសោះ នឹកគិតតែទៅហោមស័យមួយ ។

ដល់ថ្ងៃស្រួតមន្ត វេលាម៉ោងប្រាំពីរយប់ ញាតិសាលោហិតបងប្អូនជិតឆ្ងាយមកជួបជុំ ផឹកស្រាស៊ីលៀងសើចលេងក្អាកក្អាយ ខ្លះច្រៀង ខ្លះទះដៃ ពួកភ្លេងប្រឹងក្រឡៃខាត់បទតាមសម័យថ្មី ឮសូររងំយ៉ាងស្រ-ងាត់ នាំឲ្យពួកក្រមុំកំលោះយំចង់បានគូស្រករឲ្យឆាប់ដូចគេ ឲ្យពួកគោះ

ម៉ាយនឹងមេម៉ាយខ្វល់ខ្វាយ ចិត្តនឹកដល់គ្រាក្រកំសត់នឹងប្តីប្រពន្ធ មានតាតាស់ម្នាក់ស្រវឹងស្រាស្រែកច្រៀងថា :

ស្តាយអើយស្តាយខ្លួនកាន់តែចាស់ សាច់ស្វិតជ្រីវណាស់ទៅហើយណា ឃើញពួកក្មេង ៗ រូបសង្ហា កើតចិត្តប្រាថ្នាចង់ពិសម័យ ៗ ស្តាយអើយស្តាយមាសស្ងួនខ្លួនល្អ គួរបើតែកង៏ឲ្យពេញដៃ ធោមអូនល្អឆើតយ៉ាងវិល័យ មាសថ្លៃគួរបងផ្ញើជីវ៉ា ៗ ជីវិតបងមួយបងគ្មានស្តាយ ឲ្យបានរួមកាយចួបក្រ្តា យូរក្តីពាប់ក្តីរៀមពុំថា សូមអូនមេត្តាណាព្រលឹង ៗ ព្រលប់យប់យូរណាស់ទៅហើយ មាសអើយខ្ញុំបងសែនណែនតឹង បងរឹងសញ្ជប់រងសញ្ជឹង ខ្ទឹងមើលផ្លូវកែវកន្និដ្ឋា ៗ បើប្អូនមាសស្ងួនមិនប្រណី ស្រស់ស្រីឲ្យរៀមរងទុក្ខា សមបងនឹងសាបសូន្យជីវ៉ា ដោយសារស្នាដៃស្រីពុំខាន ៗ

ក្នុងវេលាដែលជនទាំងឡាយ កំពុងសប្បាយពាសពេញពេញ នាងម៉ាលីសឹងតែសង្រេងសង្រៃងទឹកអាល័យដល់ប្តីថា បងហេមស័យម្ចាស់ប្អូនអើយ តាំងពីថ្ងៃនេះទៅហើយសមប្អូនបានឃើញមុខបងហូត មានមារមកចង់ជ្រៀត នាំឲ្យប្អូនរឹតតែទុក្ខក្រំទៅទៀត ម្ល៉េះហើយជីវិតប្អូននឹងសូន្យក្នុងយប់នេះពុំខានទេ ៗ

គិតតែប៉ុណ្ណោះ នាងម៉ាលីចូលទៅក្នុងបន្ទប់ទាញដៃប្អូនស្រីជីដូនមួយ ឈ្មោះនាងហ៊ាន់យ៉ា គេឲ្យជូនទៅមាត់ទន្លេមួយភ្លែត ៗ

មេឃងងឹតសូន្យឈឹង ពពកពាសពេញលុបបាត់អស់ពន្លឺព្រះតារាទាំងឡាយ សត្វរៃយំរ៉ៃនៅក្នុងគុម្ពស្មៅ ស្លឹកឈើដែលស្រពោនស្រពន់ក្នុងវេលាថ្ងៃ រើបរីកឡើងដោយអំណាចយប់ត្រជាក់ នាងម៉ាល៉ា ប្រឹងដើរយ៉ាងលឿនកុំឲ្យអ្នកផងទាំងពួងឃើញ ដល់ទៅកន្លែងដែលប្ដីនាំនាងទៅងូតទឹក នាងគក់ទ្រូងស្រែកយំថា ឱបងហេមស័យអើយ ទីនេះហើយដែលប្អូននឹងបងនាំគ្នាមកប្រឡែងលេងសើចហ៊ោកញ្ជ្រៀវ ទីនេះហើយដែលយើងទិពសន្យា ទីនេះហើយដែលជីវិតបងមកវិនាសសូន្យ ទីនេះហើយដែលជីវិតប្អូននឹងវិនាសតាមបងឥឡូវនេះ ៗ ឱសត្វរៃ ៗ ឯងអើ ក៏សប្បាយណាស់ យំលេងលាន់ព្រៃទ្រហឹង មិនដូចខ្លួនអញ ៗ កើតទុក្ខស្មើរតែធ្លាយទ្រូងជា ១០ ភាគទៅហើយ ព្រះគង្គាអើយលោកយកប្ដីខ្ញុំទៅណាបាត់ទៅ បពិត្រអារក្សទេវតា អ្នកតាជិតខាង សូមអ្នកជាករុណាសាក្សីរបស់ខ្ញុំ ៗ មានចិត្តស្រឡាញ់ឪពុកម្ដាយខ្ញុំ ប្ដីខ្ញុំ ដូចខ្ញុំស្រឡាញ់រូបខ្ញុំដែរ តែវេលានេះខ្ញុំមានទុក្ខធ្ងន់ធន់ពុំបាន ដូចមានភ្នំមួយមកសង្កត់លើដើមទ្រូង ខ្ញុំទ្រាំរស់នៅតទៅទៀតពុំបានទេ សូមលោកមើលថែរក្សាមាតាបិតាឲ្យខ្ញុំផង ហើយជាតិក្រោយខ្ញុំសូមឲ្យជួបតែបងហេមស័យប្ដីកំសត់របស់ខ្ញុំ នៃ មីអូនហាន់យ៉ា សូមអូនត្រឡប់ទៅផ្ទះវិញចុះ យកសំបុត្រមួយនេះទៅជូនលោកឪពុកលោកម្ដាយបងផង បងបានឃើញ

មុខប្អូនហើយ ជាតែប៉ុណ្ណោះ នាងម៉ាល៉ាលោតទំលាក់ខ្លួនប្រុងទៅក្នុងទន្លេទឹកកំពុងតែហូរ ។

នាងហ្វាន់យ៉ាឃើញដូច្នោះហើយ តក់ស្លុតភិតភ័យរត់ទៅស្រែកប្រាប់ពួកចាស់ទុំដែលកំពុងសើចលេងក្អាកក្អាយក្នុងពេងការ ប្រឹងស្រាយសំបុត្រពីក្រមាហុចទៅឲ្យឪពុកម្ដាយនាងម៉ាល៉ា ចៅសីណា – ហែកសំបុត្រមើលឃើញសេចក្ដីថា :

ទម្ងន់អ្វីពុំស្មើនឹងទម្ងន់គុណមាតាបិតា ទុក្ខអ្វីពុំស្មើទុក្ខព្រាត់ប្រាសសង្សារ កម្លាំងអ្វីមិនក្លាលើសកម្លាំងកាមគុណ គ្រឿងសស្ត្រាវុធទាំងឡាយអាចកាត់ផ្ដាច់បានតែវត្ថុរឹង ។ ឯចិត្តវិញមុតលើសសស្ត្រាវុធនានា ហេតុនេះកូនសូមលាលោកឪពុកលោកម្ដាយសិនហើយ ។

ជនទាំងអស់គ្នាស្រែកចោឡោស្ទុះរត់ទៅមាត់កំពង់កន្ត្រាក់ទូកអុំផ្ទាត់ថ្វែងពេញទន្លេ ស្រែកហៅនាងម៉ាល៉ា ។

លោកសេនាវិជ័យ ចៅសីណា នាងបុប្ផាផាន់ ទឹកភ្នែកហៀរល្ហែងតាមជើងកំពង់ ស្រែកហៅ កូនអើយកូន ម្ដេចនាងគ្មានអាល័យយើងសោះ កូនទៅណាទៅ ពៅមកអាយក៏អាណិតមាតាបិតាផង ។

នាំគ្នារកមួយយប់ទាល់ភ្លឺ ក៏ពុំឃើញដានស្នាមនាងម៉ាល៉ាឡើយ ។

ចៅសត្ថាដឹងថា នាងម៉ាល៉ាទៅលោតទឹកសម្លាប់ខ្លួនដូច្នោះហើយ ក៏សន្លប់បាត់ស្មារតី ដល់ដឹងខ្លួនឡើងវិញ ប្រឹងដើរទេត្រាគយគន់មើលប្រ-

ពន្លកក៏ពុំឃើញ ដើរតាំងពីព្រលឹមទល់ព្រលប់យំសស្រែកពុំឈប់ឈរ ដល់មកដើមគគីរមួយយ៉ាងធំ ចៅសត្វាអង្គុយផ្អែកទៅលើដើមឈើនោះ ហើយដកដង្ហើមធំគិតរំពឹងក្នុងខ្លួនថា ឱអាត្មាអញអើយមិនគួរបែបនេះទេ កាលជាតិមុនច្បាស់ជាអញពង្រាត់សត្វ ទើបបានជាតិនេះអញមកបែកពីនាងម៉ាលាស្រី មិនទាន់បានប៉ះពាល់កាយគ្នាបន្តិចសោះ មកព្រាត់ពីគ្នាស្រស់ៗអញមិនអស់ចិត្តទេ កម្មអ្វីអាក្រក់ដល់ម្ល៉េះ នៅរស់បានប្រយោជន៍អ្វី ប្រាសស្រីស្មើស្រោតកណ្ដាលវាល គួរអញប្រហារជីវិតឲ្យស្លាប់តាមគ្នាទៅ រស់នៅក៏អាម៉ាស់មុខទុក្ខធ្ងន់ណាស់ដែរ ។

មើលឃើញដុំដែកមួយស្រួចនៅជិតដៃ ចៅសត្វាចាប់យកនូវដុំដែកនោះ ប្រឹងប្រគោងឡើងដើមគគីរ សរសេរលើសំបកឈើនោះតាំងអំពីគល់រហូតដល់ចុង សេចក្ដីថា:

"កាមគុណសម្រាប់សត្វលោក"

ឡើងផុតចុងឈើ សរសេររួចសេចក្ដីនេះកាលណាចៅសត្វាធ្លេចក្អែកលោតបោកខ្លួនពីលើធ្លាក់មកដល់ដីក៏ស្លាប់មួយរំពេចទៅ ។

លោកសេនាវិជ័យ ដល់បាត់កូនទាល់ល្ងាចពុំឃើញវិលមកផ្ទះវិញ សង្ស័យក្នុងចិត្តណាស់ទើបប្រើកូនក្មួយឲ្យជួយរកមើល ដើរស៊ើបសួរគ្រប់ភូមិគ្រប់ផ្ទះ មិនបានប្រទះឃើញសោះ ចូលទៅរកមើលក្នុងព្រៃបឹងបួរ

ស្ទុសានដល់ទៅដើមគគីរធំនោះ ឃើញតោសត្វស្លាប់ស្តូកនៅលើដី សត្វស្រមោចតោមពេញជុំជិត ឈាមហូរហៀរមកតាមមាត់នឹងច្រមុះ ឆ្អឹងបាក់ខ្ទេចខ្ទី អ្នកទាំងអស់គ្នាបានដឹងថា តោសត្វលោតទំលាក់ពីលើដើមឈើ ពួកកូនក្មួយលោកសេនាជ័យគិតភ័យតក្កមា រត់ទៅជំរាបនាយចៅហ្វាយលោកសេនាជ័យ ចៅសំណា នាងបុប្ផា ផាន់បានដឹងថា តោសត្វសម្លាប់ខ្លួនតាមនាងម៉ាលា ដូច្នោះហើយ ព្រលឹងអ្នកអស់នោះដូចជាលេតបាត់អស់ស្ងួនព្រឹង រូបក៏រត់ទៅកាន់ដើមឈើនោះ មើលទៅឃើញខ្មោចកូនលោកសេនាជ័យស្ទុះទៅឱបខ្មោចដាក់លើទ្រូងបោកខ្លួនយំទន្ទៀលនៅដីក្រឡេកមើលដើមគគីរឃើញអក្សរឆ្លាក់នៅលើសំបកឈើថា “កាមគុណសម្លាប់សត្វលោក” លោកសេនាជ័យចង្អុលប្រាប់មនុស្សម្នាដែលតាមមកឲ្យមើលសេចក្តីនោះ អ្នកទាំងអស់គ្នាមើលហើយគ្រវីក្បាល ជកដង្ហើមធំយំអាណិតអាសូរដល់សំដី គួរយកជាច្បាប់ពិចារណានូវទោសដែលកើតឡើងពីកាមគុណ, ដោយអំណាចស្រឡាញ់កូនពេក លោកសេនាជ័យប្រឹងលើកខ្មោចតោសត្វដាក់លើស្មាលីយកមកផ្ទះខ្លួនឯង មិនឲ្យអ្នកណាជួយ ធ្វើមឈូសមណ្ឌបរំលេចភ្ជិតទមាស និមន្តលោកសូត្រធម៌ដំកល់សពទុកចំនួនប្រាំពីរថ្ងៃ ទើបរំកិលសពយកទៅបូជារើសធាតុធ្វើបុណ្យយ៉ាងមហាឧឡារិក ចំណាយទ្រព្យឲ្យទានអស់ចំនួនជាងពាក់កណ្តាល

ពួកអ្នកកំសត់ទុគ្គតនៅស្រុកអង្គរទាំងប៉ុន្មានសឹងបានសប្បាយ ខ្លះរួចខ្លួនពីសេចក្តីក្រដោយបានទទួលទានអំពីលោកសេនាវិជ័យបរិច្ចាគឲ្យ ។

ចៅស័ណការនឹងបុប្ផាផាន់អង្គុយឱបក្បាលជង្គង់យំទឹកភ្នែកហូរហៀរជោទិច្ចស្តាយកូន ស្តាយកេរ្តិ៍ឈ្មោះ ប្រពន្ធបន្ទោសប្តី ថាមកពីប្តី បានជាកូនសម្លាប់ខ្លួន ចៅស័ណការកែដោះខ្លួនថា មកពីនាងបុប្ផាផាន់ទៅដំកបលោកសេនាវិជ័យឲ្យរៀបការឲ្យឆាប់ទៅ ទើបបាននាងម៉ាណ៉ាឈឺចិត្តបែបនេះ ជនទាំងពីរនាក់ប្រកែកប្រកាន់លើកទោសដាក់គ្នាទៅវិញទៅមក កើតទុក្ខសោកសៅក្តៅចិត្តខ្លួនប្រាណក៏កាន់តែរឹងរៃស្គមស្គាំង នេះដោយអំណាចតណ្ហាប្រាថ្នាខ្ពស់ពេក ទើបគោកយ៉ាកធ្លាក់ខ្លួនដល់ទីហ្នឹង ។

(មានតទៅទៀត)

# វេយ្យាករណ៍សំស្ក្រឹត
# របស់ព្រះវិសុទ្ធិវង្ស ហ. តាត
# (គ)

# ប៉ែកព្យញ្ជនជាតាសិក្ស

(៣៤) កំណើតដើមនៃទីបំផុតរបស់សព្ទសំស្ក្រឹតមួយ ៗ មិនដែលមានតួ ញ៑ ឡើយ, ឯតួ ង៑ នឹង ណ៑ ក៏កម្រមាន, ដែលមានច្រើនតែតួ ន៑ នឹង ម៑ ។ តួទាំង ២ នេះ រមែងតភ្ជាប់ដោយងាយស្រួលទៅនឹងព្យញ្ជនជាបន្ទាប់ខាងចុង ប៉ុន្តែតួ ម៑ ងាយស្រួលណាស់ជាងតួ ន៑ ។

(៣៥) តួ ន៑ នៅទីបំផុតនៃសព្ទមួយ ៗ ដែលមានព្យាង្គបន្ទាប់ខាងដើមជា ស្វរប្រហ្ស្វ, កាលបើមានស្វរណាមួយនៅខាងចុង, ត្រូវដំរួតគ្នាជាពីរតួ ។. តស្មិន៑ ឯវ ទេឝេ > តស្មិន្នេវ ទេឝេ तस्मिन्नेव देशे "ក្នុងប្រទេសនោះឯង"; ឧទ្យន៑ អាទិត្យះ > ឧទ្យន្នាទិត្យះ उद्यन्नादित्यः "ព្រះអាទិត្យរះឡើង" ។

(៣៦) តួ ន៑ កាលបើមានព្យញ្ជនជាតាលវ្យ, មូធ៌ន្យ ឬ ទន្ត្យ ដែលជាអឃោឞ ណាមួយនៅខាងចុង, ត្រូវផ្លាស់ជា អនុស្វារ ហើយត្រូវបន្ថែមព្យញ្ជនជា ឩឞ្មន៑ ឝ៑, ឞ៑, ស៑ ណាមួយដែលមានស្ថានត្រូវគ្នានឹងអឃោឞខាងចុង ភ្ជាប់មកនឹង អនុស្វារ ។. ធមាន៑ ចរតិ > ធមាំឝ៑ ចរតិ ឬ ធមាំឝ្ចរតិ धमांश्चरति "(គេ) ប្រព្រឹត្ត នូវធម៌ទាំងឡាយ"; វ្ឫក្សាន៑

ឆិន្ទតិ > រុក្ខំ ឆិន្ទតិ ឬ រុក្ខញ្ឆិន្ទតិ รุกฺขญฺฉินฺทติ "(គេ) កាត់នូវឈើទាំងឡាយ"; អត្ថំ ដីកយតិ > អត្ថំ ដីកយតិ ឬ អត្ថណ្ឌីកយតិ อตฺถณฺฑีกยติ "(គេ) អធិប្បាយនូវសេចក្ដី ឬ នូវប្រយោជន៍ទាំងឡាយ"; សត្រុំ តុទតិ > សត្រុំ តុទតិ ឬ សត្រុន្តុទតិ ศตฺรุนฺตุทติ "(គេ) ចាក់នូវសត្រូវទាំងឡាយ" ។ល។

(៣៧) តួ ំ កាលបើមានព្យញ្ជនជាតាលុជដែលជា ឃោសៈ ឬតួ ឃ្ម ជ នៅខាងចុង, នោះត្រូវផ្លាស់ជា ញ, ឯតួ ជ ខាងចុងត្រូវផ្លាស់ជា ញ (មើលលេខ ៣២ ត្រង់ ៣) ។. មន្ត្រំ ជបតិ > មន្ត្រញ្ជបតិ ឬ មន្ត្រញ្ញបតិ มนฺตญฺญปติ "(គេ) សូត្រនូវមន្ត្រទាំងឡាយ"; ធម្មំ ជានាតិ > ធម្មញ្ជានាតិ ឬ ធម្មញ្ញានាតិ ธมฺมญฺญานาติ "(គេ) ដឹងនូវធម៌ទាំងឡាយ"; ធម្មំ ឆាស្តិ > ធម្មញ្ឆាស្តិ ឬ ធម្មញ្ញាស្តិ ธมฺมญฺญาสฺติ "(គ្រូ) ប្រដៅនូវច្បាប់ទាំងឡាយ"; តានំ ឈានំ អនុវ្រជតិ > តាញ្ឈានមនុវ្រជតិ ตาญฺฌานมนุพฺพชติ "(គេ) ដើរតាម នូវទន្សាយទាំងឡាយ" ។ល។

(បើមាន ឃប្ម ឯទៀតក្រៅពី ជ នៅខាងចុង នោះតួ ំ ត្រូវទុកឲ្យគង់នៅដដែល គេអាចបន្ថែម មូលព្យញ្ជន ជាអឃោស១ តួ ដែល

មានស្ថានត្រូវគ្នានឹងព្យញ្ជនៈខាងចុង ភ្ជាប់មកនឹងគូ ន៑ ។. អឝ្វាន៑ ស្យតិ > អឝ្វាន្ត៑ ស្យតិ अश्वान्त् स्यति "(គេ) ចង នូវសេះទាំងឡាយ"; ពុទ្ធាន៑ ស្មរតិ > ពុទ្ធាន្ត៑ ស្មរតិ बुद्धान्त् स्मरति "(គេ) រលឹក នូវព្រះពុទ្ធទាំងឡាយ") ។

(៣៨) គូ ន៑ ឬ ម៑ កាលបើមាន ល៑ នៅខាងចុង, ត្រូវថែមគូ ល៑ ១ អំពីខាងមុខនៃគូ ន៑ ឬ ម៑ ឯគូ ន៑ នឹង ម៑ នោះបើតាមទម្លាប់ដែលតែងធ្វើមក គឺត្រូវធ្វើគូ ន៑ ជា អនុនាសិក ឬ ជា អនុស្វារ, គូ ម៑ ជា អនុស្វារ ។. គោគាន៑ លភតិ > គោគាँល្លភតិ गोगाँल्लभति ឬ គោគាំល្លភតិ गोगांल्लभति "(គេ) បាន នូវគោគទាំងឡាយ"; តម៑ លាភម៑ > តំល្លាភម៑ ឬ តំ លាភម៑ तं लाभम् "នូវលាភនោះ" ។

(៣៩) គូ ម៑ ដែលត្រូវតែនៅដដែលមិនត្រូវផ្លាស់ទៅជាអ្វីនោះ បានតែនៅទីបំផុតបណ្តាចម្លាក់ឯង ឬមានស្រៈនៅខាងចុង ។. តម៑ អឝ្វម៑ > តមឝ្វម៑ तमश्वम् "នូវសេះនោះ"; តម៑ ឦឝ្វរម៑ > តមីឝ្វរម៑ तमीश्वरम् "នូវព្រះឥស្វរនោះ"; តម៑ ឫឞិម៑ > តម្ឫឞិម៑ तमृषिम् "នូវឫស៊ីនោះ"; តម៑ ឯវ > តមេវ तमेव "នោះឯង" ។ល។

កាលបើមានព្យញ្ជនៈនៅខាងចុង តួ ម៑ ខាងដើមត្រូវធ្វើជា អនុស្វារ ១ តម៑ ក្សត្រិយម៑ > តំ ក្សត្រិយម៑ តំ ខត្តិយម្ "នូវក្សត្រិយ៍នោះ"; តម៑ គណម៑ > តំ គណម៑ តំ គណម្ "នូវពួកនោះ"; តម៑ ចន្ទ្រម៑ > តំ ចន្ទ្រម៑ តំ ចន្ទម្ "នូវព្រះចន្ទ្រនោះ"; តម៑ ឈសម៑ > តំ ឈសម៑ តំ ឈសម្ "នូវត្រីធំនោះ"; តម៑ ពិម្ពម៑ > តំ ពិម្ពម៑ តំ ពិម្ពម្ "នូវស៊ុតនោះ"; តម៑ តរុម៑ > តំ តរុម៑ តំ តរុម្ "នូវឈើនោះ"; តម៑ ធ្យានិកម៑ > តំ ធ្យានិកម៑ តំ ឈានិកម្ "នូវយោគីអ្នកបានធ្យាននោះ"; តម៑ នីឌម៑ > តំ នីឌម៑ តំ នីឌម្ "នូវសំបុកនោះ"; តម៑ បិតរម៑ > តំ បិតរម៑ តំ បិតរម្ "នូវបិតានោះ"; តម៑ ពន្ធុម៑ > តំ ពន្ធុម៑ តំ ពន្ធុម្ "នូវផៅពង្សនោះ"; តម៑ រាជានម៑ > តំ រាជានម៑ តំ រាជានម្ "នូវស្តេចនោះ"; តម៑ លោកម៑ > តំ លោកម៑ តំ លោកម្ "នូវលោកនោះ" (មើលលេខ ៣៨); តម៑ វ្ឫក្សម៑ > តំ វ្ឫក្សម៑ តំ វក្ខម្ "នូវឈើនោះ"; តម៑ ឝឝាង្កម៑ > តំ ឝឝាង្កម៑ តំ សសង្កម្ "នូវព្រះចន្ទ្រនោះ"; តម៑ សិន្ធុម៑ > តំ សិន្ធុម៑ តំ សិន្ធុម្ "នូវទន្លេនោះ"; តម៑ ហោតារម៑ > តំ ហោតារម៑ តំ ហោតារម្ "នូវព្រាហ្មណ៍អ្នកសូត្របូជានោះ" ។ល។

(តួ ម៑ ដែលមានរបៀបធ្វើដោយច្រើនដូចខាងលើនេះ ក៏ពិតមែនហើយ (ដោយវិធីផ្សេងៗ) ប៉ុន្តែគប្បីចូលចិត្តថា តួ ម៑ នេះ នៅមានវិធី

ផ្លាស់ប្តូរផ្សេងៗទៅទៀត គឺថាកាលណាមានព្យញ្ជនជាកណ្ឋ្យ-វគ្គ, តាល-វ្យ-វគ្គ, មូធន្យ-វគ្គ, ទន្ត្យ-វគ្គ, ឱដ្ឋ្យ-វគ្គ ណាមួយនៅខាងចុង, គូ ម៑ ត្រូវផ្លាស់ជា នាសិក្យ គឺជាព្យញ្ជនទីបំផុតនៃវគ្គនោះៗ ឧ. តម៑ ក្សេត្រ-យម៑ > តង្ក្សេត្រយម៑ तङ्क्षत्रियम्; តម៑ គណម៑ > តង្គណម៑ तङ्गणम्; តម៑ ចន្ទ្រម៑ > តញ្ចន្ទ្រម៑ तञ्चन्द्रम्; តម៑ ឌិម្ពម៑ > តណ្ឌិម្ពម៑ तण्डिम्बम्; តម៑ តរុម៑ > តន្តរុម៑ तन्तरुम्; តម៑ បិតរម៑ > តម្បិតរម៑ तम्पितरम् ។ល។

គូ ម៑ ដែលផ្លាស់បានតែជាអនុស្វារម្យ៉ាងនោះ ចំពោះតែមានព្យញ្ជនជាអធិស្វរ ហើយនិង ឧប្ម័ន នៅខាងចុង ដូចជា សំ ម៑ បុព្វបទ ដែលភ្ជាប់ចំពោះនឹងរូបសព្ទទាំងឡាយផ្សេងៗ: សំយម संयम, សំរក្សណ संरक्षण, សំលាប संलाप, សំវត្សរ संवत्सर, សំឝយ संशय, សំ-សារ संसार, សំហារ संहार ។ល។ បើព្យញ្ជនខាងចុងក្រៅពីអធិស្វរនិងឧប្ម័ន, គូ ម៑ គួរផ្លាស់ឲ្យសមគួរដល់ព្យញ្ជនក្នុងវគ្គនោះៗ ដូចសព្ទទាំងឡាយ គឺ សំករ, សំជយ, សំធិ, សំពន្ធ ។ល។ អាចផ្លាស់បានទៅជា សង្ករ सङ्कर, សញ្ជយ सञ्जय, សន្ធិ सन्धि, សម្ពន្ធ सम्बन्ध ។ល។

# បែកវ្យញ្ជនអវគ៌ ស និង រ

(៤០) តួ ស៑ នឹងតួ រ៑, ឥតមានបែកអំពីគ្នាទេ, កាលបើនៅទីបំផុតបង្អស់ គឺថាមិនមានស្វរ ឬ វ្យញ្ជននៅខាងចុងទេ, ត្រូវផ្លាស់ជាវិសគ៌ (មើលលេខ ១៣): ១. អស្វស៑ តរតិ ឬ តរត្យស្វះ तरत्यश्वः "សេះលោតឆ្លង"; អគ្និស៑ តបតិ ឬ តបត្យគ្និះ तपत्यग्निः "ភ្លើងឲ្យក្ដៅ"; អស្វៃស៑ តរតិ ឬ តរត្យស្វៃះ तरत्यश्वैः "(គេ) ឆ្លងដោយសារសេះទាំងឡាយ" ៗ ២. បុនរ៑ ឯតិ ឬ ឯតិ បុនះ एति पुनः "(គេ) មកទៀត ឬ មកវិញ"; បិតុរ៑ ធនម៑ ឬ ធនំ បិតុះ धनं पितुः "ទ្រព្យរបស់បិតា"; អាហុរ៑ ឫឞយះ ឬ ឫឞយ អាហុះ ऋषय आहुः "ឫស៊ីទាំងឡាយ ពោលហើយ" ៗ

(៤១) តួ ស៑ នៅទីបំផុតនៃសព្ទ, កាលបើមានវ្យញ្ជនជា ទន្ត្យអឃោស នៅខាងចុង, ត្រូវទុកឲ្យនៅជាប្រក្រតីដដែល ព្រោះជាវ្យញ្ជនមានស្ថានត្រូវគ្នា ឧ. អស្វស៑ តរតិ > អស្វស្តរតិ अश्वस्तरति "សេះឆ្លងទៅ"; អគ្និស៑ តបតិ > អគ្និស្តបតិ अग्निस्तपति "ភ្លើងឲ្យក្ដៅ"; អស្វៃស៑ តរតិ > អស្វៃស្តរតិ अश्वैस्तरति "(គេ) ឆ្លង ដោយសារសេះទាំងឡាយ" ៗល ៗ

កាលបើមានព្យញ្ជនអឃោសឯទៀតនៅខាងចុង, ត្រូវផ្លាស់ដូច្នេះ:

១ បើមានព្យញ្ជនក្នុងវគ្គជា តាលព្យ ឬ មូទ្ធន្យ ជាអឃោស នៅខាងចុង, នោះតួ ស៑ ខាងដើមត្រូវផ្លាស់ជា ឝ៑ ឬ ឞ៑ តាមសមគួរដល់ស្ថានរបស់ព្យញ្ជនខាងចុង ឧ. អឝ្វស៑ ចរតិ > អឝ្វឝ៑ ចរតិ ឬ អឝ្វឝ្ចរតិ अश्वश्चरति "សេះដើរ"; ឫឞិស៑ ដីកយតិ > ឫឞិឞ៑ ដីកយតិ ឬ ឫ-ឞិឞ្ដីកយតិ ऋषिष्टीकयति "ឫសី ពោលអធិប្បាយ" ។ល។

២ បើមានព្យញ្ជនក្នុងវគ្គជា កណ្ឋ្យ ឬ ឱឞ្ឋ្យ ជាអឃោស នៅខាងចុង, នោះតួ ស៑ ខាងដើម ត្រូវផ្លាស់ជា វិសគ៌ (មើលលេខ ១៣) ឧ. បុរុឞស៑ ករោតិ > បុរុឞះ ករោតិ पुरुषः करोति "បុរស ធ្វើ (នូវការ-ងារ)"; អឝ្វស៑ ខាទតិ > អឝ្វះ ខាទតិ अश्वः खादति "សេះស៊ីនូវស្មៅ.)"; អគ្និស៑ បតតិ > អគ្និះ បតតិ अग्निः पतति "ភ្លើងធ្លាក់ចុះ" ។ល។

៣. បើមានព្យញ្ជនជាឧឞ្មន ឝ៑, ឞ៑, ស៑, ទាំងបីតួនេះណាមួយ នៅខាងចុង, នោះតួ ស៑ ខាងដើម ត្រូវផ្លាស់ជាវិសគ៌. ឧ. ទេវស៑ ឝិវស៑ សគណស៑ > ទេវះ ឝិវះ សគណះ देवः शिवः सगणः "ទេវតាឈ្មោះឝិវ ព្រមទាំងគណះ"; ទេវាស៑ ឞដ៑ > ទេវាះ ឞដ៑ देवाः षट्

“ទេវតាទាំងឡាយ ៦ នាក់”; ឃោសស៑ សូយន្តេ > ឃោសាះ សូយន្តេ ឃោសា សូយន្តេ “សំឡេងទាំងឡាយ ដែលគេលឺ” ។ល។

(៤២) កាលណាតួ ស៑ នៅទីបំផុតនៃសព្ទ មានឃោសវ័តនៅខាងចុង, ត្រូវសំដែងអំពីតួ ស៑ នោះឯង ដែលមានអក្សរបន្ទាប់ខាងដើមជាស្រៈ អ ឬ អា ឬ ជាស្រៈឯទៀត ដូចជា អស៑, អាស៑, ឥស៑, ឦស៑, ឧស៑, ឩស៑, ឯស៑, ឱស៑, ឳស៑,

១. អស៑ នៅទីបំផុតនៃសព្ទមួយ, កាលបើមានឃោសវ័តនៅខាងចុង, ត្រូវផ្លាស់ទៅជា ឱ ។. អស្សស៑ ធាវតិ > អស្សោ ធាវតិ អស្សោ ធាវតិ “សេះបោល”; បិតរស៑ មុត្តាស៑ > បិតរោ មុត្តាះ បិតរោ មុត្តា “បិតាទាំងឡាយ ផុតបង់ហើយ”; រោគស៑ រុជតិ > រោគោ រុជតិ រោគោ រុជតិ “រោគ ចាក់ដោត” ។ល។ (មើលខាងដើមត្រង់លេខ ២៤-២៥ អំពីស្រៈសន្ធិ ដែលមានសំដែងពីឃោសវ័តខាងចុងជាស្រៈ) ។

២. អា សិ នៅទីបំផុតនៃសព្ទមួយ ៗ, កាលបើមានយោបរ័តនៅខាងចុង, ត្រូវលុប សិ ចេញ ទុកឲ្យនៅតែតួ អា, បើយោបរ័តខាងចុងនោះជាស្រៈ, តួ អា ខាងដើម ត្រូវទុកឲ្យដាច់ពីគ្នា មិនត្រូវបង្រួមបួលជាមួយគ្នាឡើយ ។. អស្សាសិ ធាវន្តិ > អស្សា ធាវន្តិ អស្សា ធាវន្តិ “សេះទាំងឡាយ បោល”; មុត្តាសិ វុត្តាសិ > មុត្តា វុត្តាះ មុត្តា វុត្តាះ “ឈើទាំងឡាយ ឆាប់ហើយ” ។ល។ អស្សាសិ អទន្តិ > អស្សា អទន្តិ អស្សា អទន្តិ “សេះទាំងឡាយ ស៊ី ( នូវស្មៅ )”; ជនាសិ អាហុសិ > ជនា អាហុះ ជនា អាហុះ “ជនទាំងឡាយ ពោលហើយ”; អស្សាសិ គច្ឆន្តិ > អស្សា គច្ឆន្តិ អស្សា គច្ឆន្តិ “សេះទាំងឡាយ ដើរទៅ” ។ល។

៣. តួ សិ នៅទីបំផុតដែលមានព្យញ្ជនៈខាងដើមជាស្រៈដទៃក្រៅពី អ, អា ដូចយ៉ាង ឥសិ, ឦសិ ជាដើម, កាលបើមានយោបរ័តនៅខាងចុង, ត្រូវផ្លាស់ជា រ៍ ។. អគ្គិសិ ឧបតិ > អគ្គិរោបតិ អគ្គិរោបតិ “ភ្លើង ឆេះ”; អគ្គិសិ ទហតិ > អគ្គិទ៌ហតិ អគ្គិទ៌ហតិ “ភ្លើង ឆេះ”; ឥត្ថីសិ នយតិ > ឥត្ថីន៌យតិ ឥត្ថីន៌យតិ “គេ នាំទៅនូវស្ត្រីទាំងឡាយ”; រត្តិសិ អាគច្ឆតិ > រត្តិរាគច្ឆតិ រត្តិរាគច្ឆតិ

"សត្រូវ មក"; វធូស៑ គច្ឆតិ > វធូគ៌ច្ឆតិ वधूर्गच्छति "ស្រី មានគូ-ស្រករ ដើរទៅ"; ឫសេស៑ ធម៌ោ អស្តិ > ឫសេធ៌ម្មោ' ស្តិ ऋषेर्धर्मोऽस्ति "ធម៌របស់ឫសី មាន"; អគ្នេស៑ គច្ឆតិ > អគ្នេគ៌ច្ឆតិ अग्नेर्गच्छति "(គេ) ទៅ ដោយសេះទាំងឡាយ"; គោស៑ ឩធស៑ > គោរូធះ गोरूधः "ដោះនៃមេគោ"; គៅស៑ ទុហ្យតេ > គៅទ៌ុហ្យតេ गौर्दुह्यते "មេគោដែលគេរូត (ទឹកដោះ)" ។ល។

បើឃោសវ័តខាងចុងជាតួ រ៑, នោះតួ រ៑ ខាងដើមត្រូវលុបចោលចេញ ហើយត្រូវធ្វើស្វរខាងដើមដែលជា ហ្រស្វ ឲ្យទៅជា ទីឃ៌ វៀរលែងតែស្វរខាងដើមជា ទីឃ៌ស្រាប់ ឬ ជា ទ្វិមាត្រាស្វរ ។ ឧ. មុនិរ៑ រោចតិ > មុនី រោចតិ मुनी रोचति "អ្នកប្រាជ្ញ រុងរឿង"; អគ្និរ៑ រោហតិ > អគ្នី រោហតិ अग्नी रोहति "ភ្លើង ឆាបឆេះឡើង"; ស្ត្រីរ៑ រក្សតិ > ស្ត្រី រក្សតិ स्त्री रक्षति "(គេ) រក្សា នូវស្ត្រីទាំងឡាយ"; បិតុរ៑ រថស៑ > បិតូ រថះ पितू रथः "រថ របស់បិតា"; វធូស៑ រោទិតិ > វធូ រោទិតិ वधू रोदिति "ស្ត្រីមានគូស្រករ យំ"; មុនេរ៑ រោចនម៑ > មុនេ រោចនម៑ मुने रोचनम् "អ្នកប្រាជ្ញមានសេចក្តីរុងរឿង" ។ល។

(៤៣) តួ រ៏ នៅទីបំផុតនៃសព្ទ ដែលត្រូវនៅតែជា រ៏ ដ-ដែលនោះ បានតែមានស្រៈ ឬ ព្យញ្ជនៈឃោសតែនៅខាងចុង (មើលលេខ ៤០) ឧ. បុនរ៏ ឯតិ > បុនរេតិ पुनरेति "(គេ) មកទៀត"; បិតុរ៏ ឧទ្យានម៏ > បិតុរុទ្យានម៏ पितुरुद्यानम् "ឧទ្យាន របស់បិតា"; បុនរ៏ ភរតិ > បុនភ៌រតិ पुनर्भरति "(គេ) នាំទៅទៀត" ។ល។ ក្រៅពីនោះ តួ រ៏ ត្រូវធ្វើដូចជាតួ ស៏ ដែលជាទីបំផុតនៃសព្ទដែរ:

១ បើមានព្យញ្ជនអឃោស ជា តាលវ្យ, មូធ៌ន្យ ឬ ទន្ត្យ ណាមួយនៅខាងចុង, តួ រ ខាងដើម ត្រូវផ្លាស់ជា ឧស្ម័ន ឝ៏, ឞ៏, ឬ ស៏ ណាមួយ ឲ្យត្រូវគ្នានឹងស្ថានរបស់ព្យញ្ជនអឃោសខាងចុង; បើមានព្យញ្ជនអឃោស ជាកណ្ឋ្យ, ឱឞ្ឋ្យ ឬជា ឧស្ម័នទាំង ៣ តួ ណាមួយនៅខាងចុង, តួ រ៏ ខាងដើម ត្រូវផ្លាស់ជា វិសគ៌ (មើលលេខ ៤១): បុនរ៏ ចរតិ > បុនឝ្ចរតិ पुनश्चरति; បុនរ៏ ដីកយតិ > បុនឞ្ដីកយតិ पुनष्टीकयति ; បុនរ៏ តរតិ > បុនស្តរតិ पुनस्तरति ។ល។ បុនរ៏ ខាទតិ > បុនះ ខាទតិ पुनः खादति; បុនរ៏ បតតិ > បុនះ បតតិ पुनः पतति ; បុនរ៏ ឝ្ឫណោតិ > បុនះ ឝ្ឫណោតិ पुनः शृणोति "(គេ) ស្តាប់ទៀត"; បុនរ៏ ស្ឫជ្យតេ > បុនះ ស្ឫជ្យតេ पुनः सृज्यते ។ល។

២. បើមានតួ ្រ ទៅខាងចុង, ត្រូវធ្វើដូចវិធីខាងដើម (មើលលេខ ៤២ ត្រង់សេចក្ដីខាងចុង): បិតុរ៑ រហស្យម៑ > បិតូ រហស្យម៑ "पितू रहस्यम् "ការសម្ងាត់របស់បិតា"; ប្រាតរ៑ ពេហតិ អាទិត្យស៑ > ប្រាតា ពេហត្យាទិត្យៈ प्राता रादित्यः " ព្រះអាទិត្យរះឡើងអំពីព្រឹក" ។ល។

(ក្នុងវ្យញ្ជនសន្ធិនេះ គ្រូបង្រៀនគប្បីតែងធ្វើជាប្រយោគខ្លី ៗ ចំនួន ២ សព្ទ គឺនាមសព្ទ ១ កិរិយាសព្ទ ១ ឬ ៣ សព្ទក៏បាន ឲ្យប្លែកអំពីឧទាហរណ៍ក្នុងខាងលើ ដាក់ឲ្យសិស្សរៀនផ្លាស់វ្យញ្ជនទីងគ្នា ៗ គប្បីធ្វើរឿយ ៗ ដរាបដល់សិស្សចូលចិត្តស៊ប់ អាចផ្លាស់ប្ដូរទីងតដោយត្រឹមត្រូវខ្លួនឯងបាន ។

វិធីដែលតែងជាប្រយោគខ្លី ៗ នោះ មិនចាំបាច់ធ្វើឲ្យមានសេចក្ដីតគ្នាជាលំដាប់ហូរហែពីប្រយោគ ១ ទៅ ១ ទេ ធ្វើឲ្យកើតតែជាប្រយោគ ៗ ឡើង សេចក្ដីផ្សេងពីគ្នាដូចម្ដេចក៏បាន) ។

## អន្តរសន្ធិ

(៤៤) វិធីធ្វើក្នុង ពាក្យសន្ធិ ខាងដើម ដូចគ្នានឹង អន្តរសន្ធិនេះដែរ វៀរលែងតែត្រង់វិធីធ្វើ ២-៣ កន្លែងនេះចេញ គឺ ទ្វិមាត្រាស្វរ ឯ, ឰ, ឱ, ឳ កាលណាបើមាន ប្រត្យយ ដែលមានអក្សរត្តួដើមជាស្វរ

ឬជាតួ យ៑, នោះត្រូវយក ឯ ធ្វើជា អយ៑. ឰ ជា អាយ៑, ឱ ជា អវ៑, ឳ ជា អាវ៑ ។ នេ + អន > នយន नयन; នៃ + អក > នាយក नायक; គោ + អតិ > គវតិ गवति; គោ + យ > គវ្យ गव्य, នៅ + អម៑ > នាវម៑ नावम् ។

(៤៨) ព្យញ្ជនទាំងឡាយដែលជាទីបំផុតនៃធាតុ, កាលណាបើមាន ប្រត្យយ ឬ វិភត្តិ ដែលមានអក្សរតួដើមជា ស្វរ, ជា នាសិក្យ ឬជា អន្តស្ថ នៅខាងចុង, នោះត្រូវទុកឲ្យនៅដូចដែលមិនត្រូវផ្លាស់ឡើយ; បើ ខាងចុងនោះជាព្យញ្ជនឯទៀតក្រៅពីព្យញ្ជនដែលបានពោលហើយ, ត្រូវ ធ្វើដូចវិធីក្នុង ពាក្យសន្ធិ ។ ធាតុ អទ៑ "ស៊ី" : អទ៑ + អនីយ > អទនីយ अदनीय; អទ៑ + មិ > អទ្មិ अद्मि; អទ៑ + យ + តេ > អទ្យតេ अद्यते (ប៉ុន្តែត្រង់ អទ៑ + សិ > អត្សិ अत्सि; អទ៑ + តិ > អត្តិ अत्ति); ធាតុ ស្វប៑ "ដេកលក់" : ស្វប៑ + ឥ + តិ > ស្វបិតិ स्वपिति ស្វប៑ + ន > ស្វប្ន स्वप्न; ស្វប៑ + យ + តេ > ស្វាប្យតេ स्वाप्यते; ធាតុ វច៑ "ពោល" : វច៑ + អន > វចន वचन; វច៑ + មិ > វច្មិ, वच्मि; វច៑ + យ > វាច្យ वाच्य (ប៉ុន្តែត្រង់ វច៑ + សិ > វក្សិ वत्ति; វច៑ + តិ > វក្តិ वक्ति មើលលេខ ៤៦ (ត្រង់ ១), វៀរលែងតែ តួ ទ៑ ដែលជាទីបំផុតនៃធាតុ, កាលណាបើមានប្រត្យយ ធ៑ នៅខាងចុង

ត្រូវផ្លាស់ ទ៑ ជា ន៑ ។. ធាតុ ឆិទ៑ "កាត់, ដាច់": ឆិទ៑ + ន > ឆិន្ន छिन्न "ដែលដាច់ហើយ"; ធាតុ ភិទ៑ "ទំលាយ, ធ្លាយ": ភិទ៑ + ន > ភិន្ន भिन्न "ដែលធ្លាយហើយ". ។

(៤៦) ព្យញ្ជនៈជា តាលវ្យ អឃោសៈ ឬ ឃោសវ័ត, កាលណាបើមានស្វរ, អធិស្វរ ឬ ព្យញ្ជនៈជា នាសិក្យ នៅខាងចុង, ត្រូវទុកឲ្យនៅដូចដែល (មើលលេខ ៤៥); ប៉ុន្តែបើមានព្យញ្ជនៈជា សំស្សត ឬជា ទន្ត្យ នៅខាងចុង, នោះត្រូវផ្លាស់ជា កណ្ឋ្យ ឬជា មូធន្យ ជា អឃោសៈ ឬ ឃោសវ័ត តាមសភាពនៃព្យញ្ជនៈដែលភ្ជាប់តមកពីខាងមុខ:

១. តួ ច៑ ត្រូវផ្លាស់ជា ក៑ ឬ គ៑. ។. ធាតុ វច៑ "ពោល": វច៑ + តិ > វក្តិ वक्ति "(គេ) ពោល"; វច៑ + សិ > វក្សិ वक्षि "(ឯង) ពោល"; វច៑ + ធិ > វគ្ធិ वग्धि "(ឯង) ចូរពោល" ។

២. តួ ឝ៑ ត្រូវផ្លាស់ជា ក៑ ចំពោះតែមានតួ ស៑ នៅខាងចុង, កាលណាបើមានព្យញ្ជនៈឯទៀតនៅខាងចុង ត្រូវផ្លាស់ជា ឞ៑. ។. ធាតុ វិឝ៑ "ចូល": វិឝ៑ + ស្យតិ > វេក៑ ស្យតិ > វេក្ស្យតិ वेक्ष्यति "(គេ) នឹងចូលទៅ" វិឝ៑ + ត > វិឞ៑ ដ > វិឞ្ដ विष्ट "(គេ) ចូលទៅហើយ"; ទ្ឫឝ៑ ឬ ទ្ឫឝ៑ "ឃើញ" + ត > ទ្ឫឞ៑ ដ > ទ្ឫឞ្ដ दृष्ट "ដែល (គេ) ឃើញហើយ" ។

៣. តួ ជ៑ ត្រូវធ្វើដូចជាតួ ប៑ ទឹង ភ៑ ដែរ ។. ធាតុ រជ៑ “ជ្រលក់” + ត > រត្ត रक्त “ដែល (គេ) ជ្រលក់ហើយ”; រាជ៑ “សោយរាជ្យ” + ត > រាជ៑ ឋ > រាដ្ឋ राष्ट्र “ដែន” ។

(៤៧) តួ ហ៑ កាលបើមាន ស៑ នៅខាងចុង, ត្រូវផ្លាស់ធ្វើជា ក៑ ហើយតួគិចិលខាងដើម ត្រូវត្រឡប់ធ្វើជាធ្នូទិត. ឧ. ធាតុ ទុហ៑ “រូត” + ស្យតិ > ធោក៑ ឞ្យតិ > ធោក្ឞ្យតិ धोक्ष्यति “(គេ) ទឹងរូត” ។

ម្យ៉ាងទៀត តួ ហ៑ បើមាន ត៑ នៅខាងចុង, ត្រូវធ្វើដោយវិធី ២ យ៉ាង :

១ ហ៑ ត្រូវធ្វើជា គ៑ ហើយត្រូវផ្លាស់ ត៑ ជា ធ៑ ឧ. ធាតុ ទុហ៑ + ត > ទុគ៑ ធ > ទុគ្ធ दुग्ध .

២. ហ៑ ត្រូវលុបចេញ ហើយធ្វើស្រៈបន្ទាប់ខាងដើមដែលជា ហ្រស្វ ឲ្យជា ទីឃ ហើយត្រូវផ្លាស់ ត៑ ទន្ត្យ ជា ឍ៑ មូធន្យ ឧ. ធាតុ លិហ៑ “លិឍ” + ត > លីឍ लीढ “លិឍហើយ”; លិហ៑ + តុម៑ > លេឍុម៑ लेढुम् “ដើម្បីលិឍ”, (ឥ ធ្វើជា ឯ); វហ៑ “នាំទៅ” + តុម៑ > វោឍុម៑ वोढुम् “ដើម្បីនាំទៅ” (អ ធ្វើជា ឱ) ។

(៤៨) ត៑, ប៑ អឃោស ជាអក្សរតួដើមរបស់ ប្រត្យយ ទឹង វិភត្តិទាំងឡាយ, កាលបើមានវ្យញ្ជនជា ធ្នូទិតឃោសវ័ត នៅខាងដើម, ត្រូវផ្លាស់ទៅជា ធ្នូទិតឃោសវ័ត ឲ្យត្រូវតាមស្ថានរបស់ខ្លួនដើម ហើយត្រូវ

ផ្លាស់ព្យញ្ជនខាងដើមដែលជាធនិតឃោសវ័ត ឲ្យទៅជាសិថិលឃោសវ័តវិញ ។. ធាតុ លភ៑ "បាន" + ត > លទ្ធ लब्ध "ដែល (គេ) បានហើយ"; លភ៑ + ត្វា > លទ្ធ្វា लब्ध्वा "បានហើយ"; ពុធ៑ "ភ្ញាក់, ត្រាស់ដឹង" + ត > ពុទ្ធ बुद्ध "ត្រាស់ដឹងហើយ"; ពុធ៑ + ត្វា > ពុទ្ធ្វា बुद्ध्वा "ត្រាស់ដឹងហើយ"; រុធ៑ "ឃាត់" + ត > រុទ្ធ रुद्ध "ឃាត់ហើយ"; រុធ៑ + តុម៑ > រោទ្ធុម៑ रोद्धुम् "ដើម្បីឃាត់" ។ល។

(៤៩) ព្យញ្ជនជា ឩស្ម មុទ្ធន្យ ស៑ កាលបើមានព្យញ្ជនជាទន្ត្យអឃោសភ្ជាប់មកពីខាងមុខ, ត្រូវធ្វើឲ្យទៅជាមុទ្ធន្យដូចគ្នា ។. ធាតុ ឥស៑ "ប្រាថ្នា" + ត > ឥដ្ឋ इष्ट; ទ្វិស៑ "ស្អប់" + ត > ទ្វិដ្ឋ द्विष्ट; ទ្វិស៑ + តុម៑ > ទ្វេដ្ឋុម៑ द्वेष्टुम् ។ល។

១. បើមាន ធ៑ នៅខាងចុង, គួ ស៑ ខាងដើម ត្រូវផ្លាស់ជា ឌ៑ ហើយគួ ធ៑ ខាងចុង ត្រូវផ្លាស់ជា ឍ៑ ។. ទ្វិស៑ + ធិ > ទ្វិឌ៑ ឍិ > ទ្វិឌ្ឍិ द्विड्ढि

២. បើមាន ស៑ នៅខាងចុង, គួ ស៑ ខាងដើម ត្រូវផ្លាស់ជា ក៑ ហើយគួ ស៑ ខាងចុងត្រូវផ្លាស់ជា ឞ៑ (មើលលេខ ៥០) ។. ទ្វិស៑ + ស្យតិ > ទ្វេក៑ ឞ្យតិ > ទ្វេក្ឞ្យតិ द्वेक्ष्यति "(គេ) នឹងស្អប់" ។

(៥០) ព្យញ្ជនៈជាឧបទន្ត្យ ស៑ កាលបើមានស្រៈឯទៀតក្រៅពី អ៑ អា នៅភ្ជាប់ខាងដើម ឬ មាន ក៑ ទឹង រ៑ នៅភ្ជាប់ខាងដើម, ឬ ដម្រួតពីខាងលើ, ត្រូវផ្លាស់ទៅជា ឞ៑ ឧ. ហវិស៑ "កិរិយាបូជា" តតិយាឯកវចន ហវិឞា हविषा, សប្តមីឯកវចន ហវិឞុ हविषु ។ល។ ធាតុ ស្វប៑ "ដេកលក់" ប្រកបដោយ សុ អក្សរខាងដើម ធ្វើជា សុ-ឞុប្ត सु-षुप्त "(គេ) ដេកលក់ហើយ"; បិតឫ + សុ > បិតឫឞុ पितृषु "កូនបិតាទាំងឡាយ"; វិឝ៑ "ជនពួជវៃឝ្យ" + សុ > វិក្ឞុ विक्षु; ធាតុ ករ៑ "ធ្វើ" + សម៑ > អកាឞ៌ម៑ अकार्षम् "(ខ្ញុំ) បានធ្វើហើយ"; ធាតុ ស្ថា "ស្ថិតនៅ" ប្រកបដោយ តិ អក្សរខាងដើម ធ្វើជា តិឞ្ឋតិ तिष्ठति "គេ ស្ថិតនៅ" ។ល។

ប៉ុន្តែគួ ស៑ នេះ, កាលបើមាន រ៑ នៅជាបន្ទាប់ខាងចុង ឬ នៅពីខាងក្រោម, ត្រូវទុកឲ្យនៅដដែល ឧ. ឧស្រ उस्र "ក្រហម"; តិស្រស៑ तिस्रस् "បី" ។

(៥១) គួ ន៑ មិនចាំបាច់មាន ច៑ ទឹង ជ៑ នៅខាងចុងទេ ពោះបើនៅខាងដើម ក៏គង់ត្រូវផ្លាស់ទៅជា ញ ដែរ ឧ. ធាតុ យាច៑ "សូម"

+ នា > យាច៑ ញា > យាច្ញា याच्ञा "កិរិយាសូម" ; ធាតុ យជ៑ "បូជា" + ន > យជ៑ ញ > យជ្ញ यज्ञ "កិរិយាបូជា" ។

(៤២) គូ ម៑ នឹង ន៑ កាលបើមានព្យញ្ជនជា ខ្ច័ន ណាមួយនៅខាងចុង, ត្រូវផ្លាស់ជា អនុស្វារ. ឧ. ធាតុ រម៑ "ត្រេកអរ" + ស្យ + តេ > រំស្យតេ रंस्यते "(គេ) នឹងត្រេកអរ"; ធាតុ ហន៑ "បៀតបៀន, សម្លាប់" + សិ > ហំសិ हंसि "(ឯង) បៀតបៀន ឬសម្លាប់" ។ល។

(៤៣) ក្នុងរូបសព្ទមួយ ៗ បើមានព្យញ្ជននាសិក្យទន្ត្យ ន៑ នៅខាងចុង ហើយមានស្វរ ឫ, ឫ្ ឬអធិស្វរ រ៑ ឬខ្ច័ន ឞ៑ នៅខាងដើម, ត្រូវផ្លាស់ ន៑ ជា ណ៑ ឧ. ករ៑ + អន > ករណ करण "កិរិយាធ្វើ"; កឞ៌ + អន > កឞ៌ណ कर्षण "កិរិយាភ្ជួរ"; ភូឞ៑ + អន > ភូឞណ भूषण "កិរិយាប្រដាប់"; តប៌ + អន > តប៌ណ तर्पण "កិរិយាធ្វើឲ្យឆ្អែត"; បិតរ៑ ឬ បិត្ឫ "បិតា" + នាម៑ > បិត្ឫណាម៑ पितॄणाम् "នៃបិតាទាំងឡាយ" ។ល។

តួ ន នេះ បើទុកជាមាន ឫ, ឬ, ឭ ឬ ឮ ណាមួយនៅខាងដើម ក៏ដោយ គង់មិនត្រូវផ្លាស់ទៅជា ណ ទេ ត្រូវទុកឲ្យនៅជាតួ ន ដដែលនោះ ដោយហេតុដូចមានខាងក្រោយនេះ:

១. តួ ន ដែលនៅទីបំផុតបណ្ដាច់នៃរូបសព្ទមួយ ជា មូលព្យញ្ជន ដែលគ្រាន់តែជាតួប្រកប, នោះមិនត្រូវផ្លាស់ប្ដូរឲ្យទៅជាអ្វីឡើយ ឧ. បិត្ឫន៑ पितॄन् “នូវបិតាទាំងឡាយ”; ឃោឞាន៑ घोषान् “នូវសំឡេងគឹកកងទាំងឡាយ”; អរីន៑ अरीन् “នូវសត្រូវទាំងឡាយ” ។ល។

២. ន ដែលជ្រួតពីលើ ត, ថ, ទ, ធ, ក៏មិនត្រូវផ្លាស់ជា ណ ឡើយ ឧ. ប្រ. + អន្ត > ប្រាន្ត प्रान्त, “ទីបំផុត, ក្បែរ”; គ្រន្ថ ग्रन्थ “កិរិយាបង, ដោតក្រង”; រន្ធន रन्धन “សេចក្ដីនាស, ការបំផ្លាញ” ។ល។

៣. កាលបើមានព្យញ្ជនជាតាលព្យ ច, ឆ, ជ, ឈ, ញ, ឝ ឬជាមូធន្យ ដ, ឋ, ឌ, ឍ, ណ, (លើកតែតួ ឞ ១ ចេញ) ឬជាទន្ត្យ ត, ថ, ទ, ធ, ន, ស, ល ព្យញ្ជនទាំង

នេះណាមួយ នៅក្នុងចន្លោះនៃព្យញ្ជនមូធន្យ ឫ, ឬ, រ, ឞ ហើយ ទឹងតួ ន នោះតួ ន ត្រូវទុកឲ្យនៅដដែល ។ ឧ. រាជានម៌ राजानम् "ទូលស្ដេច", រជនី रजनी "យប់", រសនា रशना "ខ្សែក្រវាត់"; ទ្វិស្ដេន द्विष्टेन "ដោយអំពើដែលគេស្អប់ហើយ"; ក្ឫបណេន कृपणेन "ដោយគ្រឿងប្រដាប់"; កត៌ + អន > កត៌ន कर्तन "កិរិយាកាត់"- រត្ន रत्न "កែវ"; រសេន रसेन "ដោយរស"; រថេន रथेन "ដោយរថ" ។ល។

(ក្នុងអន្ដរសន្ធិនេះ គ្រូបង្រៀនគប្បីដកស្រង់យកសព្ទដែលប្លែក ៗ ពីសព្ទដែលដាក់ជាឧទាហរណ៍ក្នុងខាងលើនេះ មកដាក់ជាឧទាហរណ៍ បង្ហាត់ឲ្យសិស្សរៀនធ្វើរឿយៗ ដរាបដល់សិស្សបានចូលចិត្តស៊ប់អាចផ្លាស់ប្ដូរអក្សរដោយខ្លួនឯងផងចុះ) ។

សន្ធិវិធី ចប់ដោយសង្ខេប ។

# សិលាចារិកនគរវត្ត

និង

# បទានុក្រម

លេខ ៣៧

Nº 39 (**B**)

(១) នេះគីរោះត្រីពីត្វសុប្វរិត្វសាទ្វាំមហាវីបុលអាតុល អត្តិវេកឯករ (២) គតាប្រមោជជោតិបង្គុប្វរត្នវិឆពិទ្វអាបិន្តិណិ បិតិមនោជពៃរោជសុ (៣) គន្វរបវិរសរសោម្មនស្យាភិលង្កត្តិ កសិត្តសោត្តរបវិរបុទុំម្មា (៤) ភាប្រកាសៃសុម្បៀសុមុហុត្តម ហោត្តុំសំម្មន្វអសទារីកសុប្វរី (៥) តរាប្វាសត្យាអទ្វីស្នាណ ប្រនិជាន្មន្ស្បៀឱកញ្ញាសេនាបរទេស្យ ន្វជុំ (៦) ទារគ្រឹកញ្ញកេ សរមានបំត្រកាតតំម្លាសាទ្វាំប្រាប្នាព្រម្មនឹងគ្នាលា (ប្រ) (៧) ពន្វបេញប្ចូលយោកផលអន្វីសងតំម្រងសុមាត្ត្យឱ្នាតសង្វា (ត) (៨) សាងព្រះមាស ២ អង្គ ផ្វងយោកសំម្ត្តមានតំម្លៀប្រព្រៃ កាតជាព្យ (៩) តាន ២ ហើយហ្យប្រាកឲ្យជាទានតស្យកំម្រតែង សង្យជោងបីញ្ជូង (១០) ៧ នោះម្តោង លុះធ្វើបុន្យឯក្រោយ្យ សោតបុះព្រះមាស្យអង្គ ១ ព្រះ (១១) ប្រាកអង្គ ១ បំម្យូស្យ ខ្ញុំ ៥ អ្នកឲ្យរ្វៃបជាព្រៀអ្សីត្តបីបិរ (១២) ពាលល្មៀ ហើ្យកាត ព្យតាន ១ ទង ១ លើកក្វនឲ្យជាទានៈ (១៣) លោះតំម្លឹង

៥ ឲ្យមានព្រហ្ម ២ ប្រាកស្មាមានជញ្ជិង ៥ ជាសុរេប្ញ (១៤) ហាង លុះទ្រង់ព្រះក្រុណាឲ្យយស្បស្តុក្កតាហ្លើងជាព្រះឃ្លាងនោះ ប្ល (១៥) ស្ប ២ តួង បុះព្រះមាស្សអង្គ ២ ព្រះប្រាកអង្គ ២ ព្យួតាន ១ ទង ១ (១៦) ឆ្លងជាសុរ៉េប្ញ នែះកាលជាព្រះឃ្លាងហោង ០ លុះបានជា (១៧) កាស្បាសោតប្លស្ស ២ តួង បំម្ប្សក្រុន្ទ្រុយបំម្ប្សស្ប្លៀ (១៨) ទ្រូនធម្មជាសំម្មើរ ៧ អង្គ ហ្លើងឱ្យសំម្បាតជាភិក្ខុសោត ១០ អង្គ (១៩) បុះព្រះមាសអង្គ ១ ព្រះទ្ទង់ហ៊្យហអង្គ ១ ព្រះប្តាអង្គ ១ ព្រះប្រាកអង្គ ១ (២០) ព្យួតាន ៤ ទ្ទង ២ នេះកាលជាកោស្បាហោង ០ លុះទ្រង់ព្រះក្រុណា (២១) បិញ្ញ្រមជាក្រលាហោមសោតប្លសម៉្តង បំប្លសក្រូនឆ្លោង ៦ តួង បំ (២២) ប្លសក្រូនកន្តាល ៤ តួង បំប្លសក្រូនបន្ទុបនោះម៉្តង នែះហោងនូ (២៣) គុននា ២ គ្រាសំម្នាងកុសលផលបុន្យ ឱកញ្ញាសេនាបរទេស្សបាន (២៤) ធ្វើកាលនូជាខ្ញុំទ្រង់ព្រះក្រុណាពិសេស្សបោហង ០ លុះអំណាស្សនិ (២៥) ដឱកញ្ញាទៅហ្សេ ឯក្រោយនោះជុំទាវ

កញ្ញាកេសរមានបិត្រគីត (២៦) កាត្តញុកាត្តរីទីខ្ទីយអាប្ទូមោក
វត្តាប្បលើកខ្មោចឱកញ្ញានូទាត (២៧) ទ្និបដ្ឋមហាគេរ សង្សឹក
៤ ត្រៃយ ៤ សំម្រាប្ប៉ កន្ទេល ៤ ចេ្យម្ទ ៤ (២៨) ខ្ទេយ ៤
គ្រៀងបាយ ៤ ប៉ិងស្លា ៤ កោកទឹក ៤ ក្លស ២ ឲ្យទានកាល
(២៩) ឥ្យមុន្ត្រប្រិសង់ទ្រិងបាងស្ទួលនោះជាសុវេប្ទូហោង ០ លុះ
គលសព្ទា (៣០) ម្ទស្តុស្លូស្តិ៍គ្រិយសព្ទាមង្គលពហុលបេស្តា
ដៃយ្យាតីវេក ១៦ (៣១) ២២ នក្សត្រ ឆ្នាំម្នរោង ខែមាឃ ៨
កើត ថ្ងៃ ១ ពារសាណ្ណាមុគ្គតិស (៣២) ជុំនុំម្ទសំតែបព្រះសុ
មង្គលមហាសយ៉ិរាជបុពីត្រ នូសំតែបព្រះវេរជេ (៣៣) ដ្ឋមហា
សយរាជបុពីត្រ នូសំតែបព្រះជេដ្ឋសត្តាម្ហាសយ៉ិរាជបុពីត្រ នូសំ
តែ (៣៤) បព្រះរាជសត្តាម្ហាសយ៉ិរាជបុពីត្រ នូសំតែបព្រះអន
ធិព្វបក្ខម្ហាសយ៉ិរាជ (៣៥) បុពីត្រ នូសំតែបព្រះបញ្ញាពីទូវម្ហា
សយ៉ិរាជបុពីត្រ នូសំតែបព្រះធម្មសីលាបាម្មិម្ហា (៣៦) សយ៉ិ
រាជបុពីត្រ នូសំតែបព្រះសត្តវង្សម្ហាសយ៉ិរាជបុពីត្រ នូសំតែបព្រះ
ពុទ្ធវង្សាម្ហាសយ៉ (៣៧) រាជបុពីត្រ នូសំតែបព្រះបញ្ញារីវៃស្សបុ

ពីត្រ នូព្រះសង្ឃរបាឡីបូពីត្រ នូព្រះសត្ថាបាឡីបុពី (៣៨) ត្រ នូព្រះត្រៃយបាឡីបុពីត្រ នូភិក្ខុបេរសំម្មោរផោងប្រេទ ឯគ្រហស សោតមា (៣៩) នឱកញ្ញាសេនាធិរាត្យ នូឱកញ្ញាទេសនាយុក នូបៅឱងនូអកហ្មឺនស្មេបងរក្ស (៤០) នូជ្យហុតនូតសកូនព្រពន្ធឱ កញ្ញាឯងទំអំម្បាលនោះស្បៀងជាសាកសីពេជ្រាន (៤១) ឡៃជុំទារ កញ្ញាកេសរមានបិត្រកាត់តំម្លាសាទ្ធាធ្វើអំពេកុសលផលបុគ្ស (៤២) ជុំម្តោះជូនទៅឱកញ្ញាសេនាបរទេស ព្រះមាសអង្គ ១ ទំម្ងនតំម្លឹង ១០ ព្រះប្រា (៤៣) កអង្គ ១ ទំម្ងន ៦ តំម្លឹង ស្លឹង ៦ ផ្កាន ៥ ទុង ២ ទុងសប្បុករ ៨ ខ្ញីយអាបប្រោស (៤៤) ខ្ញុំម្ម ១១ អាឡៃមេនុង ១ អាឡៃមេមូល ១ អាសុក្ខមេខ្យៃ ១ អាពៅ ១ (៤៥) អាឯក ១ មេពេញ ១ អារីតមេជ្យៃ ១ តសទំនែះស្បៀងជាស្រែបុគ្សឡៃរក្សាជុំ (៤៦) ម្ចាវកញ្ញាកេសរ លុះ អំណោស្បទឹងអ្នកជុំម្ចាវទៅហើ្យ (ឡៀប) ជាព្រៃជ្រោះស្រែលុះ ប្រាំម្បីទីសត (៤៧) តបីបីរពោលល្បេ ក្រេងបោងផ្តនកូនក្មួយ ឯនា ៗ ម្យម្ពោកយោកតសទំបំម្រោស (៤៨) នែះជាខ្ញុំ ព្រះ

ត្រសប្បអំម្បារខ្សែបកំម្បីប្រោសអ្នកនោះល្មៀ ហើយអ្នកនោះទៅបញ្ចូននូវ (៤៩) កសព្វ ៗ ជាត្តកុំនេតហោង ៚ ហើយនាប្រោសខ្ញុំម្មទុំ ១១ គំម្ពុរព្ភនាកាល (៥០) ផ្ញើបុគ្យជាប្រប្តិម្មតសជុំគុម្មសយ៉ៃយ្យនាបុប្ផាវិសុប្តូនាព្រះអភិធម្មព្រះសូ្យ (៥១) តព្រះវិស្បែថ្ងៃបីជាសុរេច្ច តំម្នាបទ្រាព្យសំម្រាប្បប្បូជាធម្មិទេស្នា តសកំម្រែតៃ (៥២) ឯសយ៉ទ្រឹងសយ៉ៃយ្យនានោះសង្ស៊ីក ៨ សំម្រាប្បប្រែតាប្ប៉ជាតើម្មគីត្រៃបីរ (៥៣) មសីត្ត ស្លោកបាទ្ន សំអាត្តទូប្រិត្តតែក បំម្លែកទូបង្សជ្ជូង ទូកុំម្បី (៥៤) ត្រកោរ គ្ជូរទូជេងអាធារស្មារទូកុំម្បីខ្លីទូត្រងទឹក ពន្លឹកទូក្សោ (៤៥) យ តៀ្យទូសាទ្ទាមានទុំកុំម្បីតព្រា តើងទុំ បន្សម្មទូអន្លងធាកពន្លាកក្វី (៥៦) តពេជ្រសំម្រាបទូអងរុសខ្មោសប្រាសជ្រឹទឹកតែកភ្លែង ស្បឹងតំម្កើងជាស្នាទា (៥៧) ណ្ណមានទុំកន្ទេល ៨ សំម្រាប្បប្រែតាប្បតស្បទ្រាព្យទុំអំម្បាលនែះ (៥៨) សឹង្ស ៨ មេម្បូ ៗ ហោង ម្បូសោត្តគ៉ាកាលផ្ញើបុគ្យផ្លង្សព្រះ (៥៩) កន្លាះខែនោះសឹងតារមាត្តិកាទេស្នាជាតើម្ម គឺធម្មិគុរុព្ភបប្ប៉តសព្រះមាត្តគុនម្លា (៦០) ល្ប នាថ្ងៃស្បូត

មន្ត្រីនោះហោង លុះកន្លោងរំលងអំពីរ្យប្រៃសុម្បែព្រិក្សព្រហា (៦១) ម្តាម្តព្រះភ្សុនទ្បែតារប្រពៃ្យហៀ្យធ្បែ ទេព្វមោកទេស្វាតិសទេស ជាតប (៦២) ប៉្បគុំម្រិត្តនិងសវិយ្យនាសាទ្ទាគុនតា ២ គ្រាតិសប្រាកស្នាទាំនមានទុំរត្តិត្រើ (៦៣) ជុំពូរត្រូវជាប្រាក ៣៤ បីញ៉ីងនិងស្លឹង ១០ គុំម្រិត្តនាកាលធ្វើបុន្យឆ្លងព្រះក (៦៤) ន្លាះវិនោះហោង ហៀងក្រៀនោះសោតឡីមុន្ត្រីអ្នកយេងហ្លោង ទៅ (៦៥) ធ្វើបុន្យពូនភ្នំម្នខ្សែបសំម្រែបនូភ្នំមព័ន្ធ តិស កូនព្រពន្ធសង្ខាតប្រាប្នាអន្ទី (៦៦) បាព្រម្ទនឹងគ្នាយលជាកុំ ម្នើតនែះព្វំទៀងរៀងប៉ប្លូលគ្នាសាទ្ទាធ្វើបុន្យឡី (៦៧) មុន្ត្រីអ្នក យេងប្អូនព្រះអង្គទ្រុងបង្ហានមត្តក៉ភេត ស្អិតតែលស្នានឱកញ្ញា ម (៦៨) តាខ្សែជីវីតសាមុតន្ធូនាស្រុកក្អែកទុំម្នះនោះ បំម្ប្សស្ទុំ ៥ អ្នកសំម្នាកព្រះសា (៦៩) ស្នាជាផលអន្ទីសងតុំម្រិងជូន ទៅឱកញ្ញាហើ្យសាទ្ទាស្តាប្បព្រះអភីធម្មប្លាជាត រា (៧០) ប្ប បាទប្ថៃប្បី សាងភ្នំរំត្នាតារឆ្លងសឹងព្រះមាត្តិកាប្បីថ្ងៃព្រពៃ្យត្នប្រាក ស្នា (៧១) ទានបិញ្ចិង ១ តំម្លិង ៤ ស្លិង ៥ នោះជា

សុរេប្ចហោង ។ ភន្តេភគវា បុ (៧២) ពីត្រព្រះតមានបុត្រៀ ហេតុតេជតេជះត្បោះខ្ញុំមមានបិត្រកាតតុំ (៧៣) ម្លាសាទ្ធាផ្ញើ អំម្តេកុសលផលបុត្យតិសទុំអម្បាលនែះសំនែះជូនទៅ (៧៤) ឱ កញ្ញាសេនាបរទេស សូមឲ្យវិសេសតួបក្តីប្រាជ្ញាបាន (៧៥) ប្រ សព្វនិងគ្នាសព្វ ៗ ផាតកុំនេត្រ តរាប្បលុះបាគត (៧៦) ល ប្រាជ្ញាអារហោតបតីសំម្ពីទាញានបានប្វ (៧៧) លនិព្វាណផា បងតិសហោង ។

*លេខ ៣៨*

Nº 40 (C)

៙(១) សព្វមសស្តស្តីគ្រិសព្វគ្រិមង្គលាពហុលព្រះដៃ យ្យាត្បៀសាទ្ធាតិរេក ព្ទ ០ គា ១៦២៣ ស្ករ នែះ ត...មសៃញ នៃទ្វារទស រោជមាឃមៃ ទិពារប្ញៃព្រះហាស្បតី ០ ពិតេម្មនែះ ឯងគា ត្បៀគាឋាព្រះបាទ្បី លើកសរសេរពុទ្ធី បទមុះហ្វេព្រហ្ម គិត្ត ០ (២) អញខ្ញុំមហ្យប្បុត្ភា ព្រះភគ្គវាសព្វៀជ្ញ ស្ថិតត្រាស យល . . . . . . . . . . . . . . .ស្តែបគុងគិតឆ្ពួញមារនៃ ០ បទុំម

ក្រពុំមស្អាត ឲ្យព្រះបាទសព្វេជ្ញថ្លៃ លុតលើកទស្សករក្រែ ផ្ទង
ប្រពៃតាកសិរស៊ី ០ ខ្ញុំមក្រាប់ក្រោមព្រះបាទ អត្តីវាទវិរវគ្គី
គិតឲ្យទៅព្រះត្រៃ រត្នត្រៃយត្រីក្កាល្ហ ០ រុងរឿងបាលុំ (៣)
ពេជ្ញ ព្យុបិត្រស្រែបរិច្ឆា ឆ្លាកឆ្លៅវជាភ្ញីផ្កា បរប្បូរប្បូនទន្តប្ប-
ហ៍ត ០ តាមឬប្បងស្បៀងត្រប៉ូព្រាណ្ណ លួតស្វាយ៉ុផ្ទះប្រវាត្ត
កេតផ្ស...ពោធិសត្វ ព្រះគុងស្អិតឈ្មោះមារផោង ០ ឲ្យព្រះ
សាខ្យម្មី នោព្រះត្រីអារសោតហោង ត្រស្បូធម្មិទាំសត្វផោង ក្នុង
គន្លងកាល្ប (៤) នែះនា ០ ខ្ញុំមក្រាបក្រោមព្រះបាទ អត្តីវាទ
វិរវគ្គា ប្រណំព្រះសាស្តា បញ្ចពុទ្ធារត្នត្រៃ ០ តេជះអញខ្ញុំឲ្យ
ទសករកាយឥសប្រាទ្យែ ផ្ទឹមផ្ទងគំម្បងថ្លៃ បិត្រម្ហូលអៀនែ
ប្រាជ្ញា ០ គីត្តឲ្យព្រះបេត្តី បុណ្ណាម្មីត្រៃត្រឹង្សា សាងទុកព្រះ
កេស្សា ឥសទេព្វតាឲ្យបង្គំម្ម ០ ឲ្យព្រះប្រត្តីមា មា(៥)ស
នោនាស្អាណអស្រ៊ំម ព្រះត្រៃសណ៍ាគំ ជាពុំន្អកនៃសត្វ
ផោង ០ ឲ្យព្រះពុទ្ធរូប្ប ព្រះសធូបបៃត្តីហោង ឲ្យគ្រុបព្រះ
ឆ្មីផោង ព្រះសាធត្តូងព្រះគោឞា ០ តេជះអញខ្ញុំឲ្យ ស្បួង

កាបកាយកប្បហាត្ថា លុតលើកឥភរអង្គា ថ្វាយវន្ទាស្វូរេប
ហោង ០ ថ្វាយហើយខ្ញុំទូលផ្តឹង សូមឡើត (៦) ឯឥសអារ
ផោង ជាត្តិសរញាណហោង កុំកម្បាំងភ្លាំងភ្លេចល្បើ ០ កេត
បានប្រាំម្ពិលឆ្នាំ ប្រាជ្ញាចាំមហើយបេះធ្លើយ ឥសអយើងធម៌គ្រុប
ហើយ ត្រៃបីឯករត្នមត្យេទេ ០ ឥត្ថខុស្សផ្គោងតលតិប ថ្លែង
ពាកពេជ្រស្រែបឯងឯ ទោះធ្លើទោនិងគេ តោះប្រឹស្នាអ្វីគ្រ
ទាំលសាល្យ ០ សូម្បេះបបត្រៃ (៧) ភេទ សើលសាលសេត់
អ្វិតទេសទាល ធុតធាប្ប័ជាឥសបាយ៉េ ត្វបព្រះបរមេស្វរនៃ ០
សូមទ័នព្រះគ្រឹអាយ៉ុ មានបរិពារច្រើនក្រាសក្រៃ ជារាយពាន់-
ហ្មឺណនៃ ល្អប្រពៃត្បៀប្រាជ្ញា ០ សេព្វជីន្ទគ្រិទោបួស ភ្លើង-
ផលផ្លស្បល្អពៃថ្លា សំនាក់ព្រះសាស្នា បានព្រះពុទ្ធទំនាយទុក្ខ ០
ព្រះគ្រឹអាយ៉ើងរាជ្យ (៨) ថា អ្នកនេះនាត្រស៉្យឯមុក្ខ ជាព្រះពុទ្ធ
ស្មៀសុក្ខ ត្រស៉្យធម៌ទុក្ខតាំម្នូសត្វនៃ ០ ខ្ញុំស្ញូមនោះរើងម្ហោក
ជាពន្លកសព្វេជ្រថ្លៃ អង្គខ្ញុំនេះឯងនៃ តៀទាម្មហោរវិជេយន្ទ ០
រឺតាងជាកន្សៀ ឈ្មោះពិរនៃមឹងវិបែនស្ងួន រុបធោម្មទនអែនអន

យលស្នាកសម្បវត្តគ៏ ០ លះព្រះបាទ្ធរាជ្ជា ឲ្យសក្តាទិវៃ្យ
ទិ្ន (៩) ជៀនួនស្នាធិព្វតិ្យ ហើ្យឲ្យធិ្យព្រៀក្តិហោង ០ តល
ទៅធ្យើប្ស្យងឃ្មុំ ហ្នាហ្មឹនធិឯកឯងហោង លុះជាយម្នារាជដោង
នោះឯងហោងសាងត្រឹស្សូរ ០ ឯមិងបែននោះនា យសសក្ខ
តាតៅ្យគុំន្ស៊ូរ ឈ្មោះនោះយលបរប្បូរ ជាជុំទារទេព្វសុពណ្ណ៎ ០
រ្យអ្នកនែះទំព្យរ តៅ្យរមិលយលឥសបយ៉្ស ជាតនែះព្ឋ (១០)
ទ្ស៊ូទារ កេតទុក្ខព្រាតជាទាយាត ០ ជាតនែះពុំបរប្បូរ ប្រាស
ពុំមូលប្រែនឃ្លាឃ្លាត ទោះកើតសព្វ ៗ ជាត កុំត្រាឃ្លាតតល
តេបលើ្យ ០ វិបាកនែះដោងគ្នា មោកប្រើនគ្រាពុំត្រាស្បើយ
អំម្ពិជាតនែះហើ្យ ខ្ញុំវៀរត្រងវិបាកប្រាន្ទ ០ ទោះលែងជាតនែះ
ទោវ វិលមោកនៅកើតរួមស្នាណ្ណា ត្រងទុ (១១) ក្ខអស្ស៊ូវ
ប្រាន កុំត្រាមានភិតភៃរ្យ ០ កាលអ៊្យិតនិងព្រះពន្ធ សោក
លេសលួនទូនឥន្ទ្រី ហើ្យក្អព្រះបាយតិ្យ ទុក្ខជាតនិបីនិងកូន ០
រ្យកូនទំពិ្យរអង្គ អាពុកផ្ទូងធ្វើបុន្យជូន ប្រិក្អបម្តាយនិងកូន
អ្នកឥម្មឳងនោម្យស្នាណ ០ ហើ្យសាងព្រះបាកបែក បាក

ជំញែកបែកអង្គប្រាណ ខ្ចាតខ្ចាយ (១២) អន្តរធាន បាក
តសប្រាណជាកំទាត ០ ឯខ្លះបាកស្បូង ព្រះកេសដោងធ្លាក
បិញបាត ព្រះបាទជាកុំទាត ព្រះហ័សបាត់តាប់ខ្ចាតខ្ចាយ ០
ខំពោករើស្បបម្ចូល បោះឃ្លាប្បបូលម្ចូលវប្បការ បើតមាស្បតិស
ទុំហ្លៀ ជាពន្លាយស្លមានទ្រង់ ០ វិបាប័តសទុំហ្លៀ (១៣)
មរុយហ្លាយ ៣០ ព្រះអង្គ សាងព្រះបទពិរផ្លូង គួរគ្រុបអង្គរប
តួបទុំ ០ ហៀប្បូសឆ្លោងហាយតិ្យ ព្រះសាងឬទ្ធិតោះឆ្លោងផ្តុំម
ឆ្លោងវិ្វបទុំតួបទុំ ជាឱតំម្មផ្លូសស្រែបហោង ០ ស្រតីវ្រែតនូ
នែះ ពុំរៀបរិះពិ្យតេមដោង ធ្វៀបុត្យតោះប្រើនហោង ប្បស្ប
ប្រាំម្មតោងនិងនែះនា ០ កាលបុះព្រះមា (១៤) សម្ចូល សាង
ត្រីស្បូរតោះម្ប្យគ្រា សីទ្ធព្រះសីហាំងតា បុះព្រះមាសប្រាកប្រើន
ដោង ០ ធ្វើបុត្យពិមុន្តនា សងសាលាវិហារហោង បំម្ប្លស
កូនគ្រុបដោង ប្រោសខ្ញុំហោងបញ្ចុះសីម្មា ០ និងគិតតៀ្យ-
ស្មាទាន បាំមពុំបានបទ្ធប្រើនគ្រា ខ្សែទានខ្លះបានត្រា តៀ្យ
គន្ធាគិត្តជាប៉ុង្យ ០ ស្រតិ្យតៀ្យបាំកាត (១៥) ពុំរៀបរាប់ពី
តេមផ្លូង បើគិតឲ្យទានសយ៉ៈ តោះប្រើនហ្នាស់បាំម្មពុំបាន ០

តៀបគិតធ្វើបុស្បា និងគន្ធាប្រើទូសព្វស្ពាន និងហាំមនោះពុំ បាន បទ្ទៀបស្ពានប្រើនត្អូងនា ។ ស្ងួតព្យនែះទៅហៀប ស្ងួត បងហៀបបុះទៅវល្បា ស្ងួតរូបតិសនែះនា ស្ងួតសិម្មនូមសំម្រែប ហោង ។

១ (១៦) នែះបទព្វជុំងលេលា លើកតៀបកាព្យា ជាល្បាទំ ហ្ស ។ លាតិសហោភទោសម្បុំទ្វាយ លាភៀអន្តរាយ ព្រាត ព្រាឃប្រាសគ្នា ។ ខ្ញុំក្រាប្បទូលព្រះពុទ្ធា ព្រះហៀបខ្ញុំលា ត្រូងនាទុកសោក ។ ខ្ញុំលាត្រូងកុំណើត្របោក កេត្រមោក តិសលោក សើបតៀលសន្តាន ។ ខ្ញុំលាសព្វជា (១៧) ត វៀរស្ពាន ក្តិអាស្រូវប្រាន កុំមានលើបនា ។ ខ្ញុំលាត្រូងតិត ប្រាជ្ញា ធ្វូលខ្លោវមោហា ខ្ពាសគេអៀនប្រៀន ។ ខ្ញុំលាត្រូង តិតរបៀន បួលជុំនុំស្ងៀម ពុំបេិះឆ្លៀបា ។ ខ្ញុំលាពិសភ្យាធ រោគ្គា ប្រាសបុត្រភិយ្យា ស្លាប់ទបាសប្រាន ។ ខ្ញុំលាវិបាក បូរាន៍ ជាទុកក្នុងប្រាន ស្រែក (១៨) ឃ្លាននោះដោង ។ ខ្ញុំ លាតិសបាប់ពៀរហោង ចិត្តរាព្យដោង ប្អូនកុំទៅស្មៀ ។

ខ្ញុំលាត្រូវគុំនិតផ្តោយ លាខ្ជិលកុំស្មៀ ហៀស្នាត្បិតេប ០ ខ្ញុំលាពុំបេះកលកិប សើល្យសាល្យការស្រេបុ្ក ពាកពេជ្រនោះឆា ០ ខ្ញុំលាត្រូវឥតប្រាជ្ញា ពុំបេះភាសា ស្រត្បិនិង (១៩) គ្យេ ០ ខ្ញុំលាត្រូវខ្សូត្រខ្លួនទេ ត្រមោបឯងឯង ឥតប្រៀងឆ្វា ០ ខ្ញុំលាឥតទ្រាព្យភោគ្គតា ទាស្សិទាស្សា ពុំមានតលម្នក ០ ខ្ញុំលាត្រូវបិត្រប្រត្តិយ៉ាក ស្រត្តិឱ្យអាក អនអៀនបិត្រគ្យេ ០ ខ្ញុំលាត្រូវពាកស្រោលស្រេ ស្រុត្បិត្តូបគ្យេ មមេិហត្តុតឆា ០ ខ្ញុំ (២០) លាត្រូវឆោតភាសា ស្រត្បិទៅថា ពព្លៀហឥតកាយ៉្យ ០ ខ្ញុំលាត្រូវខ្លោវអនុពាល ស្រត្បិសារធារ ឥតគ្យេយោកពាក ០ ខ្ញុំលាត្រូវឆាត្តុកយាក្យ ទូរយសត្បិបាក ពុំព្រេិស្សសាញ្យ ០ ខ្ញុំលាត្រូវល្អូង្សភិប្រាយ ធូលធ្ញញ្យាមា្យផ្ដែរោឥតកាយ៉្យ ០ ខ្ញុំលាស្នាត្បិ (២១) សារធារ ស្រត្បិកិបកាយ៉្យ ពុំបាំនោះហោង ០ ខ្ញុំលាពុំគោលស្សូរសង់ ស្រត្បិពាកឆ្គង ពុំត្រូវបិត្រគ្យេ ០ ខ្ញុំលាគ្យេស្អូបសព្វតេ៉ ត្រូវឆាខ្មាសគ្យេ ខ្ញុំលានោះហោង ០ ខ្ញុំលាឥសសេរីវាដោង ពៀរព្រេង

បុំណ្ណាង្យ កុំយលល្បើសា ០ ខ្ញុំហោតិស្សក្តិមោហា វង្វេង
ឃ្លាតឃ្លា ភ្លេចភ្លាំង (២២) ប្រមាទ ០ ខ្ញុំលានោះសព្វ ៗ
ជាត ស្រតិ្យប្រមាទ ពិឃាដ្ឋសត្វផោង ០ ខ្ញុំលាសាព្វើក្តិ
ឆ្គោង គិតខុសរលង ទើព្វយេញឯក្រោយ ០ ខ្ញុំលាត្រងក្តិ
ទុំលោយ គិត្តខុសហ្យេក្រោយ ទេព្វយេញក្តិគាប៊្យ ០ ខ្ញុំលា
ត្រងតាំអាភាព្វ រស្សនោពុំស្លាប់ ជាទុក្ខមកឯង ០ ខ្ញុំលា
ត្រងតាំ (២៣) វង្វេង ស្រតិ្យតិតក្រែង បារំក្រោយស្បើ ០
ខ្ញុំលាជាតនេះយេញហ្យេ គិត្រយលតិត្រ្តយ ពុំន្នកល្បើសា ០
ខ្ញុំលាត្រងក្តិមោហា ប្រមាទម្សេបា គ្រូបាធ្យាយផោង ០ ខ្ញុំលា
ត្រងក្តិឆ្គាំម្មឆ្គោង ប្រមាទសឃិះផោង ព្រះពុទ្ធព្រះធម៌ ០ ខ្ញុំ
លាត្រងក្តិសាហាវ ស្រតិឱ្យខ្វាល អនអៀនព្រះទៃ ០ (២៤)
ខ្ញុំលាពុំប្រក្កបន្សៀ នោអំម្ចាស់ប្លៀយ ប្រពៃទ្រង់ធម្ម ១ ខ្ញុំលា
ត្រងបិត្រសហារ សាហាវតិត្យ៉ាយ៉ឹ្យ បន្ទួនក្របាន ០ ខ្ញុំលា
មនុស្សនារៀនប្រាន ស្រតីបងខាន្ត ព្យេះញ្យុងបិប្ចូ ០ ខ្ញុំលា
ត្រងក្តិអស្រៀវ ស្រតីបិប្ចូ តែះតៀលប្រមាទ ០ ខ្ញុំលានោះ

សព្វៗជាត្ត សារៈពុំបងឃ្លាត ប (២៥) ឯខានលាភយស
០ ខ្ញុំលាត្រងនាហៅដ្ឋឡស្ស យសស្ពុក្ខរបស្ស ក្លាតក្លាយបាត
បង ០ ខ្ញុំលាត្រងគ្យេញុះញុង បងខានបំណាង បងខុស
ឃ្លាតឃ្លា ០ ខ្ញុំលាត្រងភ្យែវេរា ត្រមោះបកុំព្រា ឥតគ្នាតាម
ក្រោយ ០ ខ្ញុំលាត្រងខ្លាបកុំស្មោ្យ ភិតភ្យែប្រែក្រោយ គ្នុត្តើក្យ
បុំប្រប្ប័ ០ ខ្ញុំលាត្រងអ៊ែ (២៦) យុក្តិបប្ប ភិតញ្ញារបុំប្រប្ប័
វន្ធត្តឥស្សអង្គ ០ ខ្ញុំលាគ្យេហោមផាក្កង្យ ភិតភៃហ្វិន្យហ្វង
ឥតគ្នាជួយហោង ០ ខ្ញុំលាសព្វៗជាតឆោង កេតជាសែនគ្នុង
លាត្រងសត្រូវ ០ ខ្ញុំលាក្បាលទ្វែកស្នុកស្លូវ ជើងស្នុកអាស្រូវ
ធ្មេញបាក់ខ្វាក់ប្លង ០ ខ្ញុំលាវេរាស្រែងឃ្លុង ដំបោរឥសអង្គ
(២៧) ជាទុក្ខអ៊ិតស្បើយ ០ ខ្ញុំលាកេតហ្លិងឥត្តត្រឿ ប្រឿ
អាក្រកហ្បេ ក្លិនក្តាស្បស្អែះឆោង ០ ខ្ញុំលាឥសទុំនោះហោង
សាព្ទុំផ្តាំផ្តោង ហោរអកុសល ០ ខ្ញុំលានោះកុំត្រាយល
ព្យិជាតនែះតល រៀងទោះឯមុក្ខ ០ ខ្ញុំលាភិយ្យាអាក្រក នោ
ស្ពានអ៊ិត្តសុក្ខ ជាទុក្ខឯង (២៨) ហោង ០ ខ្ញុំលាបេហ

មានទ្រព្យផោង អក្រកនោះហោង កុំត្រាយលលៀ ០ ខ្ញុំលា សព្វជាតហៀ ត្រង់ទុក្ខឥតស្បៀយ កុំត្រាំ'សលហោង ០ ខ្ញុំ លាស្រែបសព្វគ្រប់ផោង កេតសព្វជាតហោង កុំត្រាយលលៀ ០ ខ្ញុំលានែះជាបងហៀ បាប្បពៀរទុកៀ កុំមានលៀ (២៩) ណា ០ ខ្ញុំលាអើរភៀអើរ កេតហ្លៀងកាល្ហា ថ្លៃល្អហាស្រែបផោង ០ ប៉ើកេតខុសនិងបំណុង លាត្រង់នោះហោង កុំកេតមោក លៀ ០៙

បទតើមនែះក្តី ហោរកាគ្គិត តោយបាទ្បិហា លើកជា សំនួម ខ្ញុំមសូមប្រាជ្ញា សូ (៣០) មបិត្រសារទ្ធា កាត់អំ ម្នោយទាន ០ អញខ្ញុំនែះនៀ តាមតើមឈ្មោះវៀ វៀរ ភៀបូរាគ សូមបានត្រ៊សត្រែប សារព្វជ្ញតាញាណ សូម បាននិព្វាណ ឆ្នាំឥសសត្វផោង ០ ជាតមុក្ខប្រើនក្រៃ កេត ជាអសខ្មៀ ឆ្នាំខ្មៀកាល្បហោង ខ្ញុំសូមប្រាថ្នា សាទ្ធា ទានផោ (៣១) ង តាមតោយគន្លង ព្រះសីអារមែត្រី ០ ទោះគៀប្រាថ្នា សុំឥសអង្គា សែងបញ្ជូនទ្រី ស្លូតប្លែម បែះត្នុង ពុងពោះឈោមឬ្ន ភ្នែកឆ្អើងខ្ញុំគ្តៀ ឲ្យទានគៀ

ហោង ០ ខ្ញុំសូមប្រាថ្នា ត្រិកអរសាទ្ធា បិត្តាស្មោះផោង គួប
ព្រះជាធរ ឲ្យមានប្រេត្តហោង ផ្សី (៣២) សេបឈាម្ពផោង
ឥសឥតសំណួល ០ ខ្ញុំសូមប្រាថ្នា ឲ្យមានកាល្អា ទេព្តា
ជួយយល សូមឥសឥន្ទព្រិហ្ម ជ្រោមជ្រែងប្រេនយល កេតកោ
លាហាល ជួយបំពេញមាន ០ ទេព្តាទុំលាក់ ព្រះខាន្ទ
យលជាក ស្ត្រងជាប្រធាន យោកព្រះខាន្ទនោះ អារ៍សេប
ឲ្យ (៣៣) មាន ប្រេតធ្យៀតឃ្លាន ឆ្អេតប្រាននោះ
ហោង ០ ខ្ញុំសូមប្រាថ្នា ទូលព្រះភគ្គវា ត្រាស់ធម្មិកន្លង
ខ្ញុំសូមគួបព្រះ សីអាយ៉ឹងងហោង វិយ្យាធិកផោង នោះ
ស្យែទេព្វបាន ០ ខ្ញុំថ្វ្យបទុំម្នា សំតែបភគ្គវា ស្រោប
ស្រងប្រោសប្រាន ខ្ញុំកានបុត្តា វិត្ថ្នាស្រែបបាន ឱប្ប
(៣៤) ធាបួសប្រាន សូតក្នាមវាជ្ជហោង ០ ខ្ញុំបួសនែះស្យែ
សិម្នាក់ព្រះត្រៃ សណ្តាំគុំផោង ខ្ញុំសូមឲ្យត្បិង កំនេត
សត្វហោង តាម្មតៀគន្លង ស្យែព្រះពុទ្ធត្រាស់ ០ ជាត
នែះឆ្ងាយ ពុំមានពត្រាយ ជាកជៀងស្តែងឆ្លាស ខ្ញុំ

សូមជាតក្រៀយ រៀងតួបព្រះត្រាស់ ប្រាជ្ញាបុឝ្យប្បាស ឥត
អ្នក (៣៥) ផ្ទឹមផោង ០ ខ្ញុំសូមប្រាជ្ញា បើះផ្ទៀប្រឹស្នា
តោះស្រាយសារស្នួង តួបព្រះទាគ្គសេន ផ្ទៀប្រឹស្នាផោង
ទូក្រុងមាលីនហោង តោះឥតជុំពាក់ ០ ទោះផ្ទៀប្រឹស្នា
សាពៀប្រាជ្ញា ទ្រាព្យធនយស្សសក កុំម្បីមានក្រហ ទោរភោគ
គលអ្នក ទៀត្តម្ហកពុំនាក្ស (៣៦) ជាកំម្លងល្បឿ ០ សូមកើត
ម្ហកឯង តោ្យផលពីព្រែង បូរានជាត្រែយ សិងបូលម្ហកជួយ
ពុំឲ្យព្រួយល្បឿ គឺតត្រងគាហ្បៀ ទេត្តាបំពេញ ០ ខ្ញុំសូមប្រាជ្ញា
ជាតក្រោយមោកគា កុំត្រាកុំនែញ សូមបិត្រខ្ញុំជា សាទ្ធាបំពេញ
គ្បៀសូមអ្បិមិញ ឲ្យទានឥតលុស្ប ០ (៣៧) ម្បសូមប្រាជ្ញា
តួបព្រះកាលជា ផ្ទេញដែបរស្ប ផ្ទៀប្រឹជ្ញាផោង គន្ទីយក្ខនិរ
ភ្យស ប្រាជ្ញាស្រែបស្រស្ប តោ្យបាម្មីប្លៃ ០ ហ្បៀពិនោះស្រែប
ការ៍អាយុស្បស្ដេច រ៉ូបជាប្រពៃ គាំទុត្តិយគ្គ័ សំណោក្បទូជ្រៃ
ជាបរិពារនៃ ក្រួញក្រាខ្លប័ខ្លប ០ (៣៨) រៀងមោកពីនោះ
បាប៍ស្ដេចម្បឈ្មោះ អភ៌ិគិរាជ ហ្បៀឈ្មះស្ដេចម្ប ឈ្មោះវិរាជ

រាជ ព្រះនិកឯងអាប ហោរិម្នាជយក្សា ០ នែះស្រតិ្យកាត់ ពុំបានរៀបរាប់ ពិតេមម្ចុកតា៉ បើស្រតីតស្ប ប្រើនប្ញាស្ប សព្វគ្រា បង្ហើយបានជា ឱប្បរាជ (៣៩) ឯងឯ ០ ខ្ញុំសូម អំនត បិត្រល្អស្រគត ត្វបព្រះតមេ ព្រះវរបិត្តា ឲ្យល្បំង តិតធ្វើ ព្រះអង្គអតគ្យេ ឆទស្បឆ្នាំគត ០ ខ្ញុំសូមប្រាជ្ញា ត្វបព្រះកាល្នា កើតជាមហោសុថ្ម ឈ្មោះតិស្បអា (៤ ) [បារ៉ា ផ្កាល] ផ្កាញកែវ្វត្ត ប្រាជ្ញាប្រើនក្តាត ឈ្នោះព្រះបុលណ្យ ០ ខ្ញុំសូមឲ្យបាន កាត់អំម្នោយទាន ដូចព្រះមុះហ្នា ព្រះវែសន្តរ នោនាងមេទ្រី ឲ្យទានជាលិ ក្រស្នានោះហោង ០ នាងបែន នោះនែ កេត្រជាកន្សែ តាមតេតតេ្យងោង ដូចនាងបញ្ញ.... ត្វបអំម្រាងោង ទ្វនាងមេទ្រី ០ ស៊ិ្យងតាមសព្វជា (៤១) ត កេតពុំតេលឃ្លាត របបញ្ចតន្ត្រី ហើយល្អតតង្វឹម ឆោមឆាយ ឆ្សើ ខ្លាបទំសុមាត្យ តតអ្នកតេតតល ០ ខ្ញុំសូមសព្វជាត កេតកុំត្រាឃ្លាត ទិខ្សៃមន្ទួល ទោះទោរកេតស្សគ៌ ខ្ញុំសូម ឲ្យយល ទោះកេតក្រវល នោអាយកេត្រងោង ០ ជាតនែះ(៤២)

ខ្ញុំឃ្លាត ខ្ញុំសូមសព្វជាត កុំឃ្លាតតលម្តង ទោះកើតជាសត្វ ជាមនុសក្តិហោង ខ្ញុំសូមកើតផោង តូបខ្ញុំប្រាថ្នា ០ ខ្ញុំសូម បោងផ្តណ ញាតផៅតសកូន សំលេញភិយ្យ៉ា បោងរសនាង បែន សូមកេតមូលគ្នា ខ្ជនខ្ញុំនែះនា៉ សូស្បពោរឥមឧង ០ ខ្ញុំសូមមានម្ចាជ ឬទ្ធិអំម្ចា (៤៣) ជ អនុភាព្តតោយបង ខ្ញុំ សូមសើលជុប ធុតតូបព្រះអង្គ ព្រះឥសូរស្តេចទ្រង ជុបនាង ភគ្គវត្យ ០ សូមម្ចាជព្ធាយ តូបកាលព្រះនរា្យ បុះបាកអំព្យ សួគ៌មោកកើតជា ព្រាម្ហទេព្វខ្ញិ ផ្ចួញឥសតិរដ្ឋ អាសុរលុង្កា ០ ខ្ញុំសូមម្យ៉ុនិ តូបព្រះបាទ្ធក្រិ គ្រីវក្រិនា ផ្ពោះទៅកៃលាស្ស (៤៤) ព្រះឥសូរា បានតូបប្រាថ្នា បិត្តាបោតបង ០ បាន សើលសាសស្រេប វិលមោកជាស្តេប តូបបិត្របំណាង អ្នក បានមេឃ្សូវ ប្រាប្អូនព្រះអង្គ អត្តិសេកបានទ្រង ស្មោយរាជ ម្សៃទ្ឆ្នាំ ០ ខ្ញុំសូមកុំល្ងំ អនុភាព្វបែងខ្លាំង សើលសា សធុតបាំម្ន ដូចព្រះហនុមាន បូរាននាឡ្យ (៤៥) កេត មោកជាកុំ ល្ងំព្រះរាម្ហទេព ០ សូមមានសំភារ បម្ហយត្រ

កាល បើះសើលសាសសេត្ត បើះការសង្គ្រាម ត្លូបព្រះរាម្មទេព្វ
សើលធ្លូវឯងឯក ផតអ្នកស្មើដោង ០ លែងជាតនែះទោ បើ
វិលមោកនោ កើតផ្ទៃស្ដេចហោង បានត្លូបបៅកេត មាលា
ហោះផ្សង ទៅស្នូគ្គំឡាហោង (៤៦) ជាកូនព្រះឥន្ទ្រ ០ ហៀ
មោកជាស្ដេច សាងនគរៈស្រប នោខាងគិរិន ព្រះពិស្សនុកាយ៉ៀ
វិលហ្លៀងទៅវិញ អ្នកកេតឯងមិញ សោយរាជនោអាយ ០
ខ្ញុំសូមសំម្លឹង ពិរោះប្លេកផ្សឹង ឮខ្លួវខ្ញុំប្លាយ ពាកត្លូបករវិក ក្រលួប
ព្រិហសាយ ប្រាជ្ញាពគ្រាយ បើះត្លៃ (៤៧) ឯឥតខ្វាះ ០
ខ្ញុំសូមទ្រាព្យធន មាសប្រាករត្នតន កែវម្នីជោតជ្រិះ ខៀនព្រៃ
កាសា បែមព្រិហពេញផ្ទិះ ព្វកផ្គាទមនះ ត្លូបជោតិកសេស្នី ០
ខ្ញុំសូមបរពារ ឥសគ្រីគ្រិង្គារ៉ ត្រកាលប្រិមប្រី រុបល្អលេស
លទ ទនភ្លនមានគ្រិយ សំម្បូរខៀវភ្ញី ត្លូបផ្កាស្លាកេត ០
សូម (៤៨) បើះញតគុណា ធុតធាប់លើសលន មែនបបត្រៃ
ភេទ សន្លបគ្រុបអង្គ មិរសុងព្រះនេត្រ ខ្សលតិបសង្បែត
គ្រានរស្សជីវី ០ សាបាយត្រកាល ក្រឯមពិស្ដារ ត្រិកគ្រុប

បត្រ្ទី ព្រីហព្រួបកាម្មា បិន្ទាស្លូគ្គ៌គ្រិ៍ ភ្លិកភ្លេបស្មាត៌្យ ប្រឹង ប៉្រែងពុំបាន ០ ស្នេហាគ្រុបគ្រាន ជារុ (៤៩) យជាពន្ធ ពុំគឹតភ្ញាកប្រាន លុះតែតលស្រាយ នោះនៃទេិព្យបាន តះហ្លេិ ងប៉្រែប្រាន ពុំបាតសាបាយ ០ សូមខ្ញុំប្រុសគ្រិ្យ ជារុយពន្ធក្តិ ប្រេិនក្រែពត្រាយ វប្ប្យនោម្មស៊ុ្យងល្អ សិងបេិះភិប្រាយ ស្រិត តោះស្រាយ ព្យិរោះឥត្លផ្គោង ០ សូមសែះតំម្រ្យ គោក្របីក្តិ (៥០) ល្អខ្លាំងកន្លោង រទេះកូបអាន គ្រែយានមាសដោង ទូកសា៉ម្លួងហោង តោយតែយាត្រា ០ ល្អគ្រុបប្រតាប បរិពារ ស្រេបស្រាប កាន្ទុះគ្រឿងគ្រុប្បគ្នា សម្រាប្បតំហែ ត្យោតែ យាត្រា តួបកុតផលា លេលាស័កសែង ០ សូមបានប្រាសាធ ប្រិាប្លួនល្អស្អាត (៥១) បិតមាសព្រាសទែង គាងឃ្វាយឆេត ធុាយពត្រាយយលស្ដេង តាំមប្យ្វងឆ្លះបែង ល្អគ្រុប្បប្រកាយ្យៀ ០ មានផ្សួរជុំវិញ បីជានឆ្លាកពេញ រូំបគ្រុប្បពិស្ដារ មាន ជានិរាយ សៀ្យងក្ល្យគ្រុប្បទ្វារ នាគ្យលេិកពពាណំ បាំម្ន ជើងតេរកាប្ចូ ០ ទោះនឹងមានផ្ទុះ បិ (៥២) ល្អស្រលះ

សឹងមានមុក្ខគេប ទទិងរោងជ្រែក បង្គនផ្សូរស្រេប រាំង ជុំខាន្ទកាប់ រោងតំរៀសែះ ॥ ០ ། មានបន្ទធាយ្យា មុន្ទប្ប សាលា ធ្វិងស្តាំមសិងស្រោះ ផ្សូរតាំមសិងផ្កា បាំប៉ាបានបែះ ក្លឿឡត្បូបក្រៃបែះ ព្យិតោរត្រែរបហោង ០

(៥៣) ឆ្នាំមមីពេញបុម្មីខែហាផល្គុនតោះ បានជាតុក ញ្ញស្សរិត្រ្យាធិរាជ្ជ លុះតលឆ្នាំវក្ខពេញបុម្មី ខែពីសាក្សតោះ បានជាបោហ៊្យាប៉ុំក្លស្ស ៤

*លេខ ៣៩*

**№ 41 (B)**

(១) សព្វមស្តុស្ដិស្រីសព្វមង្គលពហុលបេស្តាដៃយ្យា (២) តិរេក ១៦៦៩ សក្កបោះនក្សត្រខែមាគ្សិរ ១៣ ( (៣) កត្រថ្ងៃព្រះហ័ស្សតីពារសាណ្ណ៍ មន្តិតស្សដុំនុំសំគេបព្រះ (៤) រាជសិលាបាយ៉្យមហាសយិរាជបុពីត្រ ន្វសំគេបព្រះសុមង្គលម (៥) បាសយិរាជបុពិត្រ ន្វតស្សសំគេបព្រះគ្រូ ភិក្ខុបេរសំម្ភេរ ដោ (៦) ឯប្រែឡជាប្រធានថ្លៃនែរ្ហកឧកញ្ញាវង្សាអគ្គរាជន្វអ្នក ប្អូម្នាវ (៧) ស្រីវត្តកេសរមានបិត្រកាតតំម្លាសាទ្ធាំបានហ្វៀងម្អក

ធ្វើបុនឡ (៨) ទាន និមន្ត្រអ្នកព្រះសឃ៍ទ្រង់ប៉ាំស្កួលអនិពាន្ធ លើព្រះពានតាកា (៩) លអ្នកឱកញ៉ាវង្សអគ្គរាជន្ធជាហោរញ៉ា មន្ត្រីសង្គ្រាមនោះ (១០) ព្រះបាទអ្នកជាអំចស្សស្តេចលេលា យាត្រាមកអំពីក្រុងទេព្វព្រះ (១១) មបានគរមកតលស្រុក បន្ទាយរ៉ែ ទើប្បព្រះបាទអ្នកជាអំចស្ស (១២) ត្រស្សប្រើហោពញា មន្ត្រីសង្គ្រាមមកមុនតលបន្ទាយលុង្វែកប្ជ្ឈ (១៣) នឹងសំតេចព្រះរាជបុត្រាត្តបទ្រង់ព្រះនាមជាសំតេចព្រះកែវហ្វ៉ា នាកាល (១៤) ឆ្នាំមសាញខែមាឃ ពិបាកខ្សត្តទ្រគតឥតទ្រព្វធន ធានពុំមាន (១៥) លើ្សហើ្សទើប្បប្ជូមទារិរត្នកញ៉ាជាម្ដាយមឹង បង្កើតន្ធនាងសរ (១៦) ជាក្លួយប្ជើសំពតហូល ១ ឪ ១ ទោហោពញ៉ាន្ធបន្ទាយលង្វែក (១៧) ហើ្សស្រីតរូតទៅតាមគ្រួតលស្រុកសំរោងសែនបានប្ជួបនឹងសំតេច្ជព្រះ (១៨) អនុជខ្សត្រីន្ធសំតេចព្រះរាជបុត្រាន្ធសំតេចព្រះរាជបុត្រីន្ធសំតេច (១៩) ភគ្គីយោន្ធសំតេចព្រះភគ្គនិយា ហើយបានឃើញម្ដាយមឹងនៅ (២០) ឥស្សរសេបញ្ជាតទ្វំ ៧ សន្តាន ទើប្បបានតន្តិងយក

នាងពៅ (២១) ជាប្រពន្ធ ឯនាងពៅនោះ មានទ្រព្យធនខ្ញុំ កុំត់ច្រើនទើបប្រឹលទៅ (២២) បន្ទាយ ហៀសំតេចព្រះរាជបុត្រា ធំទ្រង់ព្រះនាមសំតេចព្រះ (២៣) ស្រីធម្មរាជាឲ្យទានបោពញា ជាឧកញាសុរិន្ទ្រាធិបតី ឲ្យទាន (២៤) នាងពៅជាប្អូនទាវស្រី រត្នកេសរ ទេវិប្បសំតេចព្រះវររាជបីត្តាធិរាជប (២៥) រំម្មនាដ្ឋ ព្រះបាទបរំម្មបុពិត្រយកទៅបីញ្ចមជាឧកញាវង្សាអគ្គរាជពីឆ្នាំមរ (២៦) កា លុះតលឆ្នាំមជូត ទើប្បសំតេចព្រះបាទបរំម្មនាដ្ឋព្រះ បាទបរំម្មបុពិត្រអ្នក (២៧) ជាអំបស្សត្រស័្យប្រើឧកញាវង្សា អគ្គរាជនូនាយពលគ្រឹលនូតស្សក្កូទ (២៨) ក្តយលើកទាប្ប័ បិញទៅប្រាប្បវាហោរកុំនាបស្រុករលាប្បអៀរ ស្រុក (២៩) បរប្បូរ ស្រុកខ្លង ស្រុកក្រង ស្រុកក្រគ នោះវាហោរកុំនាបបាកប្អូប្បខ្ល (៣០) ប្បខ្លាបតៀនូព្រះអំនាបព្រះបាទអ្នកជាអំបស្សនោះបាន បរប្បូរ (៣១) ស្រុកខ្មែរខ្សានសាបាយ ទូលាយតស្សអនា ប្រជារាស្ត្រនោង (៣២) នូឆ្នាំញ . . . បបរប្បូរបូលបិញ ទៅវិញ ទៅមុក លុះតលថ្ងៃសុក (៣៣) ៣ រោជខែអាសាធឆ្នាំមហោះ

ន . . . . . ទិព្វសំពតព្រះបាទព្រះ (៣៤) ដៃរជេស្ឋាធិរាជ
រាមាធិប្បតិបរមនាថព្រះបាទបរមបពិត្រអ្នកជា (៣៥) អំបស្ស
ត្រាស្សប្រើឱកញ្ញាវង្សាអ . . . . . . ជាមេកងទ័ព (៣៦) ហើយ
បើកព្រះអំនាបព្រះរាជទាន . . . . . . . . . ស្ស ហើយក្រាប្ប
លាបិ (៣៧) ញទោនិងជុំ . . . . . . តាវ្យពលគ្រីវលនូតិស្ស
កូនក្មួយ (៣៨) លិកទ័ព្វបិញទៀតតាំធ្លាងនិងសំពត
ព្រះមហាឧត្រីជាបុត្រីអ្នក (៣៩) សំពតព្រះកែវហ៊្វានោះមាន
ធ្លាងឈ្មោះសំពតព្រះមហាឧត្រីតេញប៉ (៤០) ករតក្លាត
ក្លាយតោយនូតេជះអំនាបព្រះបាទអ្នកជាអំបស្សហើយបាន (៤១)
តៅព្រ្នកគំនិតប្រាជ្ញាឱកញ្ញាវង្សាអគ្គរាជត្រិះរិះគិតតាកតែងលែ
(៤២) ងមេទ័ព្វមេកងតាមស្ពាតរង្កាតសព្វផ្ទប្រឹកប្អកបាប្បបាន
ខ្ញុំសំពត (៤៣) ព្រះមហាឧត្រីនូតិស្សទ្រាំព្ទរបស្សរដោងប្រើន
តាំបូលទោក្រាប្ប (៤៤) ប៉្វបង្គំប៉្វតូតិស្សខ្ញុំនូតិស្សរបស្ស
ទ្រាំព្ទនោះទិព្វសំពតព្រះបាទ (៤៥) បរមនាថព្រះបាទបរម
បពិត្រអ្នកជាអំបស្សត្រស្សព្រះរាជឧង្ការមធូរហ្វ (៤៦) រតីព្រះ

ឱស្សទិព្វពីសេស្សប្លៃឲ្យព្រះនាងទេពកញ្ញាវង្សាអគ្គរាជជា (៤៧) ឱ កញ្ញាតេជោ ធីស្រុកកំពង់ស្វាយ នោះទេពកញ្ញាអង្វរព្រះរាជប្រាទៀ (៤៨) ប្លៃទិព្វពីសេស្សពុំទទួលសៀ ហើយទើប្បព្រះរាជទានបើក ឲ្យទេពកញ្ញាធី (៤៩) ពានមាស្សឲ្យបាំក្លស្ស ៤ ទើប្បទេពកញ្ញា ក្រាបបង្គំលាព្រះបាទសំតេច (៥០) បរមក្សត្រព្រះបាទបរមបពិត្រ បិញមុកផ្ញើបុនព្រះពានបំបួស្សបុមទារ (៥១) ត្នកញ្ញាជា ម្ដាយមឹងបង្កើតឲ្យបុមទារស្រីរត្នកេសរជាប្រពន្ធនាងកឹម (៥២) ជាខ្មែរត្នយស្រី ២ ស៊ាកបួស្សជានាងជីផ្ញើបុនប្ញៃ ១ នឹមន្ត្រីអ្នក ព្រះស (៥៣) យ៉ីទ្រង់បំស្នូលអនិច្ចាបុមទារត្នកញ្ញាជាម្ដាយ មឹងទ្រង់ ២ សយ៉ីរាជ (៥៤) ៥ អង្គភិក្ខុ ១១ អង្គ ហើយនឹ មន្ត្រីអ្នកព្រះសយ៉ីទ្រង់បំស្នូលអនិច្ចាឱក (៥៥) ញាវង្សា អគ្គរាជឯងទ្រង់ ១ សយ៉ីរាជអង្គ ១ ភិក្ខុ ៧ អង្គហើយ (៥៦) នឹ មន្ត្រីទ្រង់បំស្នូលអនិច្ចាបុមទារស្រីរត្នកេសរជាប្រពន្ធទ្រង់ ១ ស (៥៧) យ៉ីរាជ ២ អង្គ ភិក្ខុ ៦ អង្គ ឯតំណោះប្រគេនស យ៉ីរាជទុំទ្រង់ (៥៨) ១ សឹងអង្គ ១ តំលឹង ១ ឯភិក្ខុសឹង

ប្រគេនស្លឹង ៨ ទំលោះទូរគ្រឿ (៥៩) អង្គហើយតាំរឆ្លង
នោះអ្នកព្រះសឃ៊ទ្រីទ្វង ២ សឃ៊រាជ ៣ អង្គសិ (៦០) ងប្រ
គេនអង្គ ១ តំលិង ១ ឯភិក្ខុនោះសិងប្រគេនអង្គ ១ បាទ ២ (៦១)
ឩមន្ត្រីអ្នកសំម្មេរសូតធម៌គឺយោកអង្គ ២ ប្រគេនបាទ ១ ឯ (៦២)
ឥស្សអ្នកសំម្មេរទំប៉ាំស្លូលអនិច្ចាទំតាំរនោះត្រូវសំម្មេរ ៧០ សិ
(៦៣) ងប្រគេនអង្គ ១ ស្លឹង ១ ហើយឩមន្ត្រីមហាសឃ៊រាជសិលា
បាយ៌ទេស្នា (៦៤) ព្រះមហាជាតកាន ១ លើកអ្នកគុងកូនប្រុស្ស
អាយុស្សឆ្នាំ ៨ បូជា (៦៥) ព្រះធម្មហើយបូជាប្រាក់បាទ ៣ ទេិប្ប
លោះត្វអ្នកគុងកូនប្រុស្សតំ (៦៦) លិង ៧ ហើយនិមន្ត្រីមហា
សឃ៊រាជបញ្ញាលិក្ខិតទេស្នាអនិសង្សព្រះ (៦៧) នូអនិសង្ស
ផ្នួស បូជាប្រាក់តំលិង ៣ ស្លឹង ៣ នូបង់ប៉ាកស្លាឈាស័កក្លា
(៦៨) ត ១ បងលំទុង ១ ប្រគេនសំពតស្ទូ ១ នូស្បៃ
កាសាទូងម្ទូ ១ ឡូដ្ឋ (៦៩) លអ្នកលេងបាទ ៧ គិតបូក
ឥស្សតំណោបត្រូវជាប្រាក់ជំង ៣ ឪជាទា (៧០) ន ឲកញ្ញា
វង្សាអគ្គរាជតំជាកូន អ្នកឲកញ្ញាក្រលាហោមសេនាបរទេស
(៧១) នូអ្នកបមទាវិកញ្ញាកេសរជាមាត្តាបិត្តាឲកញ្ញាវង្សាអគ្គ

រាជនូវ (៧២) មទារគ្រឹះគ្នាកេសរនូវអ្នកហឹងអ្នកព្រំមនូវអ្នកគុង មានបិត្របិ្ញសាទ្ធាសា (៧៣) ឯកុសលទាំនេះជូនទោមាគ្គ បិត្តានូវញាតិកាទាំ ៧ សន្តានត់មានធម្មិសប្បុរ (៧៤) ស្ម ហើយ សូមបានអាយុស្សវែងបាន ៥០០០ វស្សា កប្បនូវប្រាជ្ញានូវទ្រព្យ សំ (៧៥) ម្យ៉ាគត្តបជោគ្គិកសេស្ទិហើយសូមបានជាព្រះមហា បរម្មបក្កពត្តិរាជ (៧៦) ស្មោះស្មេរក្ខខេម្រមខ្វាន់សាបប្បត់រាប្បលុះ បានបូលទិញ្ជានហោង

*លេខ ៤០*

No 41 (A)

(១) នែះនឹងពាណ្យាសរសេដ្ឋព្រះមហាឥន្ទ្រ.......

(២) នែនឹងព ....................

(៣) អ្នកឯកជ្ជៀ ....................

No 41 (B)

(១) សមុហានូវអ្នកព្រះឱត្តលជេតនូវអ្នក.........

(២) អ្នកពុទ្ធជាកម្មនូវអ្នកសម្តេចមោកនូវអ្នកព្រះធម្មអរិយ បេរិនូវបេរ......................

លេខ ៣៧

*N. 39 (B)*

(៣) អនីសងតម្រងសុមាត្តៀ សំ.ខ. អានិសង្ស.ជម្រង់-ស្នូបតិ ។ តាមទម្លាប់ប្រើសព្វថ្ងៃ ស្នូបតីជាស្មារតី ។

(១៤) ឲ្យយស្សស្តុក្កតាះហ្លិងជាព្រះឃ្លាង សំ. ខ. ឲ្យយសសក្កាឡើងជាព្រះឃ្លាំង ។ ព្រះឃ្លាំង គឺជាចាន់ហ្វានក្រុមព្រះឃ្លាំង ឆារជា កោសាធិបតី ។

(១៦) ឆ្លុងជាសុវេប្ប ខ. ឆ្លងជាសូរេច ។

(១៧) ជាកោស្សា ឆារ. ជាកោសា គឺជាកោសាធិបតី ដំណែងអធិបតីក្រសួងឃ្លាំង ។

(១៧) បំម្ប្រស្សខ្លៃ ខ. បំបួសថ្លៃ (គឺបំបួសសាច់ថ្លៃដូច យ៉ាងបងថ្លៃប្អូនថ្លៃ ដែលគេហៅថា ថ្លៃ) ។

(១៨) កូនធម្មិជាសំម្ញេរ ម. សំ. កូនធមិជាសាមណេរ ។

(១៩) ព្រះប្កាអង្គ ១ ខ. ព្រះផ្កាអង្គ ១ = (គឺព្រះដែល គេធ្វើពីផ្កា) ។

(២៤) លុះអំណាស្ស ខ. លុះអណាស់ ឬលុះអំណិស ។ លុះអំណាស់ គឺលុះអស់ ។ លុះអំណិសគឺលុះគស ។

(២៩) និមុន្ត្រប្រសង់ទ្រង់បាងស្កុល *ម. ១. និមន្តព្រះសង្ឃទ្រង់បង្សុកូល ។*

(៣៤) ព្រះអនធិព្វបក្ខុមហោសឃរាជ *(ឆារ) ព្រះឥន្ទ្រទិព្វចក្ខុមហាសង្ឃរាជ ។*

(៥៣) មសិត្តស្លោកបាទ្ធ *សំ. និសិទន៍ (សំពត់ក្រាលអង្គុយ) ស្លោកបាត្រ ។*

(៥៩) ធម្មិគុរព្តបប្បតិសព្រះមាត្តគុនម្ហាល្បៃ *ម. ១. ធម្មគោរពចប់អស់ព្រះមាតុគុណ មហាលៃយ ។*

(៦១) តាម្មព្រះអ្រុនឡៃ *១. ម. តាមព្រះអរុណោទ័យ = តាមពេលអរុណរះ ។*

(៦៣) មានទ្វំរត្តិគ្រិជុំព្យូរ *សំ. ១. មានទាំងតើគ្រឹជម្ពូ ។ តើគ្រឹជម្ពូនេះដូចម្តេច? គិតមិនយល់ ។*

(៦៥) ភ្នំព័ន្ធ *១. ភ្នំពាន់ ។*

(៦៧) បង្ហានមត្តកភេត *១. ម. បង្ហាន់មតកភត្ត = ភត្តដែលគេឧទ្ទិសផលអ្នកស្លាប់ទៅ ។*

(៧២) ហេតុតេជតេជះត្បោះខ្ញុំម្មមាគបិត្រ *១. ហេតុតេជតេជៈបរខ្ញុំមានចិត្ត ។*

'លេខ ៣៨

N. 40 (C)

(១) លើកសរសេរពុទ្ធ ខ. លើកសរសើរពុទ្ធ ។

(២) ថ្វាយបុប្ផា ម. ថ្វាយបុប្ផ = ថ្វាយបុផា គឺថ្វាយផ្កា ។

" លុតលើកទស្សករ ម. លុតលើកទសករគឺលុតជង្គង់ លើកម្រាមដៃ ១០ ។

" រត្នត្រៃយត្រិកាល សំ. រត្នត្រ័យត្រីកាល ។

(៣) បាល្ងំពេជ្ជ សំ. បល្ល័ង្កពេជ្រ ។

" ព្យីបិត្រស្រែបរិបតា សំ. ពិចិត្រស្រេចរបនា ។

" ព្រះសាខ្យម្នី ម. ព្រះសាក្យមុនីឬសក្យមុនី ។

(៤) តិសប្រាទៃយ ខ. សំ. អស់ហ្ឫទ័យ ។

(៥) ព្រះត្រៃសណាំគំ សំ. ព្រះត្រៃសរណគមន៍ ។

ស្បងកាបកាយកប្បហត្ថា សំ. ម. ខ. សព្ពបង្កិដ – កាយកបហត្ថា (ប្រែថាដោយសេចក្ដីថាដៃរបស់ខ្លួនកាន់ទូវផ្កាសព្ពបង្កិដ) សព្ពបង្កិដ = បង្កិដ ៧ ស្រទាប់ ។ ខ្មែរហៅ ស្បង្កិដ ។ ម. សត្ដបង្កិដ្ឋ ។ ជាឈ្មោះឈើក ១ យ៉ាងសំបុរក្រហមផ្កាមូល ។ ។

(៦) ជាត្តិសរញ្ញាណ *ម. ជាតិសរញ្ញាណ ឬ ជាតិសរ-ណញ្ញាណ = ញាណគ្រឿងរលឹកបានទូវជាតិមុន ៗ ។*

" តិសអយ្យិធម្ម *ខ. សំ. អស់-អាថិធម៌ ។ ឬ ម្យ៉ាងទៀត អស់អរ្យធម៌ ។*

" ត្រៃបីដិករត្ថមត្យទេ *ខ. ត្រៃបិដក-រត់មាត់ទេ ( គឺចាំរត់មាត់ទទេ មិនចាប់មើលក្បួន ) ។*

" ប្លឹងពាកពេជ្ជ *(ម. ក្លាយ) ថ្លែង-ពាក្យពេចន៍ ។ ពេចន៍ គឺ វចន សរសេរថ្លែងជា ពេចន៍ ។*

" តោះប្រស្នាអ្វីគ្រទាំលសាល្យ *ដោះប្រស្នាអ្វីក្រពាល់សល់?*

(៧) សើលសាសសេត៌ *សំ. សិល្បសាស្រ្តសេដ្ឋ ។*

" តិសបាយ្យិ *សំ. អស្ចារ្យ ។*

" សេព្វជិន្នត្រិ *សំ. សេពជិនត្រៃ ។*

(៨) ផើងម្ហោក *ខ. រៀងមក ។*

" តោយតាម្មេហោរជៃយគ្គន្ន *ខ. ដោយនាមែយហៅ ដៃយខន្ធ ។*

" មឹងបែទស្មូន *(ឈ្មោះ) មឹងបែនសុន ឬមឹងប៉ែនសុន ។*

" ជាជុំទារទេព្វសុពណ្ណ៌ (ឈ្មោះ) ជាចមទាវទេពសុ-ពណ៌ ។

(៩) ជៀនន្ទស្នាធិព្វត្យ (ឈ្មោះ) ដៃយនទូសេនាធិបតី ។

(១០) កេតទុក្ខព្រាតជាទាយាត ១. ម. កើតទុក្ខព្រាត់ជាទាយាទ ។ ទាយាទ ប្រែថា ជាអ្នកទទួល . . . ។

(១១) ភិតភៃរ្យ សំ. ភីតភៃរី ៗ ភៃរី ប្រែថា អ្នកមានពៀរ ។ ម. ពើរ ។

" ទុក្ខជាតនិបិនិងកូន ១. ទុកជាតុនីបីនឹងកូន ។

(១២) ពោះប្លាប្បបូលមូលព្រប្បកាយ ១. ម. ពោះភ្លាប់ ចូលមូលរូបកាយ ។

(១៤) តៀគគ្នាគិត្តផាបុង្ស ១. ដោយគណនាគិតបារេង ។

(១៥) សួតបងហោយបុះទៅល្បា ១. សូត្របង្ហើយចុះ ទៅល្បា ។ ល្បា = ពាក្យលា គឺពាក្យដែលលាកុំឲ្យជួបទឹងសេចក្ដីអាក្រក់ ជាដើម ដូចពាក្យកាព្យក្នុងទំនេះលេខ ៣៨ ត្រង់លេខប្រចាំ ១៦ ដល់ ២៩ ហៅថា ល្បា ។

(១៥) សួតបងហៀបុះទៅល្បា ១. សូត្របង្ហើយចុះទៅ ល្បា ។ ល្បាឬបុា ប្រែថា "លំដាប់" គឺលំដាប់រឿងកាវ ដូចពាក្យថា

ប្រាក្រត = លំដាប់ក្រិត ។ មកពីពាក្យមគធៈ បក្ត, សំ. បក៌ ។ ខ្មែរប្រែក្លាយជាល្បាប្រក្ត ។

(១៦) ពូជុំងលេណ ម. កូដគ្គលេណ ប្រែថាលំនាំដំណើរនាគ) ។

(១៧) ប្រាសបុត្រភិយ្យ៉ា សំ. ប្រាសបុត្រកវ្យា, ម. ករិយា ។

" ខ្ញបាសប្រាំន សំ. ខុបាសប្រាណ ។ ខុបាស ប្រែថា សេចក្ដីបៀតបៀន – សេចក្ដីវិនាសអន្ដរាយ ។

(១៩) ឥតប្រៀងគ្នា ១. ឥតប្រៀនគ្នា ។ លំដាប់វង្សគ្នារៀងមក បានដឹងមនុស្សដែលជាញាតិផងគ្នាហៅថា ប្រៀន ។ ហៅថា មិត្រសំឡាញ់គ្នា ។

" ប្រត្តិយ៉ាក សំ. ប្រត្យ័គ្យ (ម. បច្ចក្ខ) ច្បាស់, ប្រាកដ, ឬដូយគ្នាម្នាក់នឹងម្នាក់ទៀត ដូចសទឹងខ្មៅ ។

" គ្លកយាក្យ ១. (ឬសៀម) គកយ៉ាក គឺគោកយ៉ាក ឬ គុកយ៉ាក ។

" ពុំព្រើស្សសាប្យ ១. ពុំព្រើសសប្បាយ ។ ព្រើស = រីករាយ ឬរុងរឿង - ត្រចះត្រចង់ ។

(២១) ពុំគោល ១. ពុំនោល គឺពោល ។

(២២) ពិឃាដ្ឋសត្វដោង ម. ១. ពិឃាដ ឬពិឃាតសត្វផង ។

(២៤) សាហ៉ារ មកពីពាក្យមគធៈថា "សាហស" គន្ថ៍ទីនេះត្រូវប្រែថា សាហាវ-កាច ។ គន្ថ៍ខ្លះប្រែថា រហ័ស-រួសរាន់, កំហែង-ធ្វើដោយអំណាច-កំលាំងក៏មាន ។

(២៥) ហៅជ្ជិឡូស្ស ១. ហៅចូស់ ។

" កុំស្មោយ ១. កុំសោយ (គឺជាអ្នកខ្សោយ) ។

" តុត្តិក្យប៉ុប្រប្ប៉ ១. គតើកចំប្រប់ ឬគតិកចំប្រប់ ។

(២៦) ជាកុង្ស ១. ជាគន ។

" ភិតភ្យៃហ្លិនហ្លង ១. ភីតភ័យហ៊ីនហ៊ន ។

(២៧) ប្រេ្យអាក្រិកហ្មេ្យ កើនក្តាស្សផ្ទេះដោង ១. រូបអាក្រក់ហើយ កូនក្តាស (ក្រដាស) ផ្ទេះផង ។

(២៩) បាប្បពៀរទុពៀ ម. ១. បាបពៀរទុក្ខកើយ ។

(៣១) សែបបញ្ចូតត្រិ ១. ម. សាប់-បញ្ចូតទ្រិយ ។

(៣៣) ខុំកានបុត្ត្រា ១. ម. ខ្ញុំកាន់បុត្ត្រា ។

(៣៤) ឱប្បធាប្ហូសប្រ៉ាន ម. សំ. ឧបជ្ឈាយ៍បួសព្រាណ

" ស្យូតក្មាមភាជ ១. ម. ស្សូត្រកម្មវាច ។ គឺស្សូត្រកម្មវាចា ។

(៣៥) បេះដៀប្រឹស្នា *ខ. សំ. បេះដើយ - ប្រឹស្នា ។ សំស្រ្កឹតសុទ្ធជា បុស្នា តាមទម្លាប់ប្រែជាប្រស្នា ។*

" ទ្រព្យធនយស្សក *សំ. ទ្រព្យធនយសស័ក្តិ ។*

(៣៦) ជាកិម្លងល្បើ *ខ. ជាកំលាំងល្ហើយ ។*

" គឹតត្រងណាហៀ *ខ. គិតត្រង់ណាហើយ ។*

" ឲ្យទានឥតលុស្ស *ខ. ឲ្យទានឥតលោះ ។*

(៣៧) និរត្យស *សំ. និរព្យស (ប្រែថា អស់ព្យស-ឥតព្យស-អស់ពុតកំណាច) ។*

(៣៨) អភ្ជិគិរាជ *(ឈ្មោះ) អគ្គីរាជ ។*

(៣៩) តួបព្រះគោមេ *(ឈ្មោះ) ដូចព្រះគោមេយ៍ (ម.គេមិយ) ។*

" ឲ្យល្បិងឥតធ្វើ *ខ. ឲ្យល្បងឥតធ្វើ ។*

" ឆទស្សឆ្នាំគត *ម. ខ. ឆទស - ឆ្នាំគត់ (គឺ ១៦ ឆ្នាំគត់) ។*

" មហោសុប្ធិ *ម. មហោសថ ។*

" ផ្កាញក្រៀវត្ត *(ឈ្មោះ) ផ្កាញ់ - គេរ័ដ ។*

(៤១) ធូបអំម្រាផោង (ឈ្មោះ) ធូប-អមរា-ផង ។

(៤៣) ព្រះរាមទេវក្ញុំ (ឈ្មោះ) ព្រះរាមទេព-ខ្ញុំ ។ រាម ទេពនេះគឺព្រះរាម ។

" ត្រីវិក្រិតា (ឈ្មោះ) ត្រីវិក្រម-ណា (គឺព្រះត្រីវិក្រមាទិត្យ) ។

(៤៤) មេហ្សរ៍ ១. មេហ្ស ។ ទេវី-មហេសី ។ របស់ក្សត្រហៅថា មេហ្ស ។

(៤៦) បាទធូបទៅកេត — មាលា (ឈ្មោះ) បាទដូចទៅ កេតុមាលាព្រះនាមស្តេចខ្មែរ ១ អង្គក្នុងសម័យអង្គរ ។

(៤៨) ញតគុណ?

" មិរសុងព្រះនេត្រ ១. មឹសុងព្រះនេត្រ គឺងងឹតសុងព្រះ នេត្រ ។

" ខ្យលតិបសង្ស្រត ១. ម. ខ្យល់តិច-សង្ស្រត ។ សង្ស្រត គឺសំសីត ប្រែថាត្រជាក់ ជាអាការរបស់មនុស្សទៀបស្លាប់ ។ គឺខ្យល់តិច ត្រជាក់ខ្លួន ដោយតេជោធាតុថយ ។

(៤៩) ជារុយជាពន្ធ ១. ជារយេ ជាពាន់ ។

(៥០) តួបកុតផលា?

(៥១) ចាំម្ជើងតេរកាប្ល ១. ចាំជើងដើរគាត់ គឺចាំជើងដំណើរគាត់ ។

(៥១) មានផ្សូរជុំវិញ ១. គឺមានកំផែងជុំវិញ ។

(៥២) បង្គនផ្សូរ ១. បង្គន់ ជាឈ្មោះរបស់ដែលគេបាំងកុំឲ្យមើល ដូចយ៉ាងដែលហៅថា ឡប់ឡៃ ។ ផ្សូរគឺកំផែង ឬ កំពែង ។

" មុន្ទប្បសាលា ម. មណ្ឌប-សាលា ។

(៥៣) ពោហ៊ាំបាំក្សស្ប ៤ ១. ពៅហ្វាបាំងក្សស ៤ ។

# រឿងព្រេង-ដំឡូង ៧ សន្តាន

និយាយរឿង ១ មានបុរសប្តីប្រពន្ធនាំគ្នាទៅសួរបងប្អូននៅភូមិព្រៃសណ្តែក ដើរៗទៅប្រទះនឹងអាដំឡូង ៧ សន្តានកំពុងតែទឹមគោភ្ជួរស្រែ បុរសប្តីប្រពន្ធនោះសួរថា អ្នកអើយអ្នក ផ្លូវណាកាត់ត្រង់ទៅលើភូមិព្រៃសណ្តែក ដ្បិតខ្ញុំខានមកយូរឆ្នាំហើយ មិនដឹងជាផ្លូវណាកាត់ទៅឲ្យត្រង់ៗ នោះអាដំឡូង ៧ សន្តានស្រាប់តែខឹងឆ្លើយថា គោអញ ១ នឹមនេះសុទ្ធតែកូនក្រោលបង្គោលស្នឹង អាក្របម ១ នេះម្តាយក្មេកគាត់ចែក ឯអាស្នែងកន្ទុកឪអញគាត់ឲ្យ អញមិនលួចគោរបស់អាណាយកមកទឹមទេ ។

ឯបុរសប្តីប្រពន្ធដែលសួរផ្លូវនោះឮហើយនិយាយគ្នាថា អ្នកនេះយើងសួរផ្លូវគាត់ៗនិយាយពីគោ ហើយស្តីកំពេះកំរើយឲ្យឯងផង ន្ហើយ គេហ៎ យើងកុំខ្វល់សួរវាយូរ ធាប់គង់តែនឹងទៅដល់ផ្ទះបងប្អូនមិនខាន ហើយក៏បណ្តើរគ្នាហួសទៅ ឯអាដំឡូង ៧ សន្តាននោះក៏ទំភ្ជួរស្រែមិនឈប់ ដល់ពេលជិតថ្ងៃត្រង់មេដំឡូងជាប្រពន្ធក៏ទូលបាយទៅឲ្យប្តីបរិភោគ លុះដល់ដាក់ល្អីបាយនៅក្រោមម្លប់ឈើនៅក្តីស្រែ ប្តីនោះលុះបានឃើញប្រពន្ធយកបាយមកឲ្យក៏ឈប់លែងភ្ជួរស្រែ បរិភោគបាយនិយាយទាំងខឹងប្រាប់ប្រពន្ធថា មានបុរសប្តីប្រពន្ធបណ្តើរគ្នាមកពីណា ហើយប្រកាន់ថា អញលួចគោវា ឯគោ ១ នឹមនេះប្រាកដជាម៉ែឪឯងអញចែកមក មេប្រពន្ធឃើញមាត់ប្តីនិយាយហាបៗ ទឹកស្មានថាស្តីឲ្យខ្លួន ស្រាប់តែខឹង

ហើយឆ្លើយតបទៅវិញថា អញគិតថាប្ដីមកក្បែរស្រែទាល់ថ្ងៃចំប្រញាប់ប្រញាល់ខ្លួលបាយមកឲ្យស៊ី ឥឡូវទៅជាថា ឯងមានប្រុសមានសហាយ អញសហាយនឹងឈ្មោះអាណា គាត់រកមុខឲ្យឃើញ ប្ដីមិនតែពមបាយអស់មួយល្អីប្រពន្ធថាអ្វីក៏មិនព្រមផង លុះប្ដីបរិភោគរួចមេប្រពន្ធកន្ត្រាក់យកល្អី ប្ដីសួរថា ឯងមានការអ្វីឯផ្ទះបានជាប្រញាប់ម្ល៉េះ មេប្រពន្ធថាអញមុខជាប្រាប់ម៉ែឪអញមិនខាន ហើយកណ្ដៀតល្អីត្រឡប់ទៅដល់ផ្ទះជួបនឹងម្ដាយនិយាយទាំងទឹងមុខក្រហមប្រាប់ម្ដាយថា កូនប្រសាម៉ែឯងក៏ល្អ ហើយខ្ញុំខ្លួលបាយទៅឲ្យស៊ីដាក់ល្អីស្មើរតែមិនទាន់ ក៏ស្ដីឲ្យខ្ញុំថា មានប្រុសមានសហាយ ។

ឯចំណែកម្ដាយនោះខឹងញ័រឡើងថា ហ៏ឯងដូចេះទេតើបានជាមុខក្រហម អញថាកូនថាទៅចាំផ្ទះឲ្យវ៉ា ឥឡូវក៏ថា ឯងលួចចាំក៏យកទៅជូរជូង មេអន្ទោនឯងក្រោយៗ កុំនិយាយដូចេះមិនត្រូវទេ ស្បូវតែចាំ ១ ធ្នុក ក៏អញមិនលួចយកផង បើទុកជាអញយកមែន ម្ដាយនឹងកូនមិនត្រូវហ៊ាន ឯងពោលឲ្យអញខ្មាសគេ ចាំឪហ៏ឯងមកអញប្រាប់ឲ្យដេវក៏យប្រដៅហ៏ឯងមិនខាន ។

លុះយូរបន្តិចប្ដីមកពីកាប់បង្គោលធ្វើរបងបញ្ចាំមិនឲ្យគោក្របីចូលស៊ីស្រណាបសំឡូង ប្រពន្ធនិយាយប្រាប់ប្ដីថា កូនស្រីឃើងក៏ទៅជូនបាយប្ដី ខ្ញុំចាំផ្ទះឲ្យវ៉ា ៗ មកវិញក៏ថា ខ្ញុំជាម្ដាយលួចចាំក៏ជូរជូង ខ្ញុំខឹងណាស់ ។

ប្ដីស្ដាប់មិនត្រូវខឹងនឹងប្រពន្ធដែរថា មេចោរក្រហែងប្រចណ្ឌអញអីម្ល៉េះ អញមិនស្លៀកពាក់តែងខ្លួនដើរលេងចង់ស្រីឯណា អញទៅកាប់ឈើធ្វើបង្គោលរបងទេតើ អញអត់តែម្ដងនេះទេ ក្រោយៗបើហងឯងនៅតែស្ដីប្រចណ្ឌអញទៀត មុខជាអញធាក់ឲ្យដួលទាំងដំហរមិនខាន ហាមប្រពន្ធហើយបរិភោគបាយរួច ទៅចងសន្ទូចបានត្រីត្រឡប់មកផ្ទះវិញ វេលាថ្ងៃល្ងាចប្រពន្ធក៏ធ្វើត្រីស្ង សាំងឲ្យប្ដីបរិភោគខ្លះ រំលែកទុកព្រឹកខ្លះ ដើម្បីនឹងធ្វើសម្រាប់យកទៅប្រគេនលោកគ្រូឯវត្ត នឹងកូនប្រុសតូចម្នាក់ឲ្យ នៅរៀនអក្សរជាមួយនឹងលោកបងនោះ ។

លុះព្រឹកឡើងម្ដាយនោះដាំបាយដួសដាក់មានម្ហូបពីល្ងាចស្រាប់ទូលយកទៅដល់កុដិប្រគេនលោកគ្រូ ហើយនិយាយថា ខ្ញុំករុណារលឹកលោកគ្រូណាស់ មួយទៀត ប្អូនតូចនោះតើរៀនអក្សរគ្រាន់បើឬទេ លោកគ្រូនោះមានពុទ្ធដីកាថា ចំរើនពរញោម អាត្មាសព្វថ្ងៃនេះកំពុងស្រឡាញ់សីលផ្ទសណាស់អាត្មាមិនសឹកទេ ម្ដាយក៏ហៅកូនតូចដែលនៅបំរើបងនោះថា អានាងលាលោកបងទៅផ្ទះនឹងម្ដាយបានមួយថ្ងៃពីរថ្ងៃសិន ដ្បិតឪឯងរលឹកណាស់ អាកូនតូចឆ្លើយប្រាប់ម្ដាយថា ត្រីងៀតលោកបងនៅពីរកន្ទុយទុកក្នុងកុដិ ពេលល្ងាចខ្ញុំយកពីរចំរៀកដុតស៊ីបាយដែលសល់ពីលោកឆាន់ពេលព្រឹកនោះ ។

ឯលោកសង្ឃដែលគង់នៅជិតកុដិប៉ុន្មាន ៗ បានឮម្ដាយលោកនឹងកូននិយាយតែដោយខ្លួន មិនទទួលសំរុកគ្នាដូច្នោះ លោកទាំងអស់ទប់ពុំបានក៏សើចទ្រហឹងអឹងអាប់ ឯមិកានោះក៏សំពះលា លោកកូនត្រឡប់មកដល់ផ្ទះវិញហើយលុតជង្គង់ជូនបុណ្យប្ដីថា ខ្ញុំជូនបុណ្យអ្នកផង ប្ដីឆ្លើយថា អើអញឃើញបាយសំឡខអាំង ព្យួរទុកនៅសរសៃក អញស៊ីអស់ទៅហើយ ប្រពន្ធក៏មើលមុខប្ដី ៗ មើលមុខប្រពន្ធ ប៉ប្រិចភ្នែកមក ៗ ឆ្ងើងហើយតែដោយខ្លួន លុះយូរបន្តិច ស្រាប់តែប្អូនស្រីបង្កើតខាងប្ដីនៅភូមិដទៃឆ្ងាយមកដល់បានផ្លែពងមួយផ្លែនឹងស្លឹកប្រស់ស្វាមួយ សំណុំមកផ្ញើបងហើយនិយាយសួរបងថា បងបានក្ដួរពេស់ដកស្ទូងបានស្រែប៉ុន្មានហើយ នោះបងទាំងប្ដីប្រពន្ធឆ្លើយប្រាប់ទៅប្អូនស្រីវិញថា អើហ៎ងល្អមទុកដាក់ឲ្យពាំមានប្ដីទៅចុះ តែហ៎ងមើលកុំឲ្យតែបេះលេងបៀផឹកស្រាជក់អាភៀន ៗ

នោះមេប្អូនស្ដាប់មិនឮទៀត និយាយឆ្លើយប្រាប់ទៅបងទាំងពីរនាក់ថា ខ្ញុំស្ដាយត្រឡាចខ្លួនមួយទ្រើងណាស់ កំពុងតែផ្កាក្របតូច ៗ ស្រាប់តែមេជ្រូកពាំទៅឈ្ងីសគលផាបង៉ាបអស់ បងទាំងពីរនាក់ថា អើហ៎ងល្អមទៅផ្ទះក៏ទៅចុះល្ងាចណាស់ហើយក្រែងកូនពាំយំរក ប្អូនស្រីនោះក៏ត្រឡប់មកផ្ទះវិញ ។

( រឿងជំឡង់ ៣ សន្ដានចប់តែប៉ុណ្ណោះ )

ឧកញ៉ាអក្ខរៈលេខា ( ណុប ) តែង ។

# បញ្ជីរឿង


១ — វិធីការសំអាត ព្រះវិសុទ្ធវង្ស (ហ. តាត) រៀបរៀង . . . . . . . . . . ១១១

២ — អំពីលោកស្លូប៉េនហ៊ើរ នឹងព្រះពុទ្ធសាសនា (តនឹងចប់) . . . . . . . . . . ១២១

៣ — រឿងកាកី ព្រះរាជនិពន្ធ ព្រះបាទសម្ដេចព្រះហរិរក្សរាមាឥស្សរាធិបតី ព្រះបរមកោដ្ឋ (តទី ២) . . . . . . . . . . . . . . . . . . . . ១៣១

៤ — កេរ៍គោបទេស ភាគទី ១ «ការបង់មិត្រ» (ត) . . . . . . . . . . . . . . . . ១៥៩

៥ — ធម្មទេសនា ព្រះឧបាហ្វូត វត្តលង្កា . . . . . . . . . . . . . . . . . . ១៦១


## រូបក្រៅរឿង


វិចិត្រសៀមរាប-បន្ទាយសំរែ នេះរូបហោជាង (មើលរឿងទំព័រ) . . . . . ១០៧



គណៈកម្មការទំនៀមទម្លាប់

COMMISSION DES MŒURS & COUTUMES

# TABLE DES MATIÈRES

Pages

1. La Propreté (par le Vénérable H. TATH)................. 111

2. Schopenhour et le Bouddhisme (suite et fin)............. 121

3. La légende de Kaki (par S. M. ANG-DUONG ROI du Cambodge)...................................... 131

4. Hétopadésa 1re partie (suite)........................... 153

5. La Religion Bouddhique comparée à d'autres religions (par MOHA HUOT)................................ 161

HORS TEXTE:

Siem-Réap-Bantei Samrê, le fronton du monument Brahmanique...................................... 107



ខេត្រសៀមរាបពន្ទាយសំរែ នេះរូបហោជាង ( មើលរឿងទំព័រ ១០៩ )

## អំពីប្រាសាទមួយនៅបន្ទាយសំរែ

ក្រសួងថែរក្សាបុរាណវត្ថុនៃឥណ្ឌូស៊ីន កំពុងជួសជុលប្រាសាទបែបព្រាហ្មណ៍មួយយ៉ាងល្អ នៅបន្ទាយសំរែ ដែលនៅត្រង់ផ្លូវទៅភ្នំគូលែន បំងាយ ១១ គីឡូម៉ែត្រ ពីបរិវេណផ្លូវធំ ។

ប្រាសាទនេះ គេបានសាងមកក្នុង ព. ស. ១៥០០ ដល់ ១៦០០ ។ ដែលមានរូបបោះពុម្ពនៅខាងមុខនេះ គឺរូបហោជាងប្រាសាទបុរាណនោះ មើលឃើញរូបព្រះសិវៈ ទ្រង់ដាក់ព្រះនាងបារ្វតីលើភ្លៅ ទ្រង់គង់លើគោនន្ទិ ។

## វិធីការសំអាត

ព្រះវិសុទ្ធិវង្ស ហ. តាត រៀបរៀង

# ការសំអាត

(ព្រះវិសុទ្ធិវង្ស ពាត រៀបរៀង)

អស់លោកអ្នកទាំងឡាយ គួរឧស្សាហ៍សំអាតទីលំនៅ, សំអាតគ្រឿងប្រើប្រាស់, សំអាតគ្រឿងស្លៀកពាក់, សំអាតគ្រឿងផឹកនិងភោជន, សំអាតរូបកាយឲ្យស្អាតឲ្យផូរផង់ល្អ ៗ ព្រោះថាកាលបើទីលំនៅជាដើមមិនស្អាតល្អហើយ នឹងជាហេតុនាំបណ្ដាលឲ្យរូបកាយរបស់យើងដែលអាស្រ័យនូវគ្រឿងមិនស្អាតមានរោគផ្សេង ៗ ៗ កាលបើរូបកាយមានរោគហើយ ចិត្តដែលអាស្រ័យនៅខាងក្នុងរូបកាយ ធ្វើម្ដេចនឹងប្រព្រឹត្តទៅដោយស្រួលបាន, កាលបើចិត្តប្រព្រឹត្តទៅមិនស្រួលហើយ គំនិតប្រាជ្ញាដែលអាស្រ័យនៅនឹងចិត្ត ធ្វើម្ដេចនឹងដុះដាលចំរើនភ្លឺស្វាងឡើងបាន,កាលបើគំនិតប្រាជ្ញាមិនចំរើនមិនភ្លឺស្វាងហើយ ប្រយោជន៍ដែលយើងត្រូវការចង់បានក្នុងបច្ចុប្បន្ននេះនឹងក្នុងខាងមុខ ធ្វើម្ដេចនឹងសំរេចប្រយោជន៍បាន ៗ កាលបើយ៉ាងនេះគួរតែចូលចិត្តថា បណ្ដារោគទាំងអស់សុទ្ធតែជាតួសត្រូវឬជាមេចោរជាអ្នកបំផ្លាញនូវប្រយោជន៍ នៃអស់យើងពល់គ្នា ព្រោះសេចក្ដីពិតថាអ្នកណាមួយទោះបីមានបុណ្យស័ក្ដិក្ដី មានទ្រព្យសម្បត្តិច្រើនក្ដី មានប្រាជ្ញាច្រើនក្ដី មានកំលាំងច្រើនក្ដី កាលបើរោគចូលមកអាស្រ័យនៅក្នុងរូបកាយបានហើយ បុណ្យស័ក្ដិជាដើម

របស់អ្នកនោះ ក៏ត្រឡប់ទៅជាឥតអានុភាព ប្រើការមិនកើតទាំងអស់, ព្រោះបាលបាញ់អំណាចនៃរោគដែលចូលមកលុកលុយក្នុងរូបកាយ ។

ហេតុដូច្នេះគួរតែយើងខំៗ សម្រាប់សំអាតទីលំនៅជាដើម ដើម្បីនឹងរាំងបិទផ្លូវកុំឲ្យរោគកើតឡើងបាន ។ ពិតមែនជាមានពុទ្ធភាសិត ១ កន្លែងសំដែងថា “រូបំ រោគនិទ្ធំ” រូបជាសំបុកនៅនៃរោគ ឬជាទីអាស្រ័យនៅនៃរោគ ។ ដែលព្រះអង្គសំដែងដូច្នេះ ចំពោះត្រង់កន្លែងដែលរោគចូលទៅអាស្រ័យនៅក្នុងរូបកាយ បើឥតរូបកាយក៏ឥតមានរោគ; តែមានរូបកាយហើយក៏ឈ្មោះថា មានទីសំរាកនៅនៃរោគ ។ ឯរោគសមុដ្ឋាន គឺហេតុដែលបណ្ដាលឲ្យរោគកើតឡើង ព្រះអង្គមិនបានសំដែងចំពោះត្រង់ពាក្យថា “រូបំ រោគនិទ្ធំ” នេះទេ, រោគសមុដ្ឋាននោះ ព្រះអង្គមានសំដែងទុកក្នុងសូត្រឯទៀតដោយប្រែមានគិរីមានន្ទសូត្រជាដើម ។

ឯទីកន្លែងដែលស្មោកគ្រោកក៏រាប់ថាជាសមុដ្ឋាននៃរោគ មិនមែនមានតែក្នុងដំរាកនៃពេទ្យសព្វថ្ងៃនេះឡើយ ក្នុងពុទ្ធភាសិតក៏មានសំដែងប្រាប់ថាឲ្យសំអាត ដើម្បីនឹងកំចាត់បង់នូវទោសមានរោគក្ដៅជាដើម ដូចសេចក្ដីដែលនឹងមានសំដែងទៅខាងមុខ ។

## ការសំអាតដែលយើងត្រូវធ្វើនោះដូច្នេះ

១ ការសំអាតទីលំនៅ  ត្រូវសំអាតទីខាងក្រោមផ្ទះឬទីខាងផ្ទះ ដោយជុំវិញកុំឲ្យមានសំរាមទឹកកក់ជ្រាំ  កុំឲ្យមានក្លិនស្អុយជាទីស្មោកគ្រោកឡើយ ។ ទីខាងក្នុងផ្ទះត្រូវបោសសំអាតកុំឲ្យមានសំរាមទីងធូលី កុំឲ្យស្តោះទឹកមាត់ ឬខាកដាក់លើក្តារក្រាល ឬក្នុងចន្លោះក្តារដែលចន្លៀត ឬក៏លើផ្ទៃដីឬឥដ្ឋខាងក្នុងផ្ទះ ត្រូវឲ្យស្តោះដាក់តែក្នុងទីដែលគួរស្តោះ ឬក្នុងប្រដាប់សំរាប់ស្តោះមានកន្ធោរជាដើម ។ កុំឲ្យមានសំបុកពីងពាងឬមែងភ្ញើងព័ទ្ធព័ន្ធទូរជញ្ជាំងឬពិតានដម្បូលផ្ទះ ។ ទីកន្ទ្រីងសំរាប់អង្គុយឬសំរាប់អាស្រ័យដំណេក ត្រូវបោសទីងជូតសំអាតឲ្យស្អាត ។ គ្រឿងដេកគឺគ្រែទីងកំរាលត្រូវខំសប្តាហ៍គោះជូតសំអាតកុំឲ្យមានធង់ធូលីជាប់ប្រឡាក់, កំ-រាលដេកទីងស្រោមខ្នើយក៏ត្រូវបោកគក់ដុសលាងឲ្យរឿយ ៗ កុំឲ្យជាប់ប្រឡាក់ដោយញើសក្អួល ។

២ ការសំអាតគ្រឿងប្រើប្រាស់ក្នុងផ្ទះ: របស់សំរាប់ប្រើប្រាស់មានតុទីងកៅអីជាដើម ត្រូវខំសប្តាហ៍ជូតសំអាតកុំឲ្យមានធូលីរុំឡើយ ។ បើមានកន្ធោរសំរាប់ស្តោះទឹកមាត់ ត្រូវសំអាតកុំឲ្យដក់ទឹកមាត់ឬជាប់ប្រ-ឡាក់កាន់ទឹកមាត់ក្រាស់ក្នុងកន្ធោរនោះ ព្រោះទឹកមាត់តែហួសវេលាទីងមានក្លិនអាក្រក់ ។ គ្រឿងប្រដាប់សំរាប់ដាក់គ្រឿងផឹកមានប៉ាន់តែទីងផ្តិលឬកែវទឹកជាដើម ត្រូវរកសំពត់ដែលស្អាតល្អសំរាប់ជូត កុំយកសំ-

ពត់ឬកន្សែងដែលសំរាប់ជូតមុខជូតដៃ ឬជូតញើសទៅជូតគ្រឿងប្រដាប់ដឹកនោះឡើយ ។ គ្រឿងប្រដាប់សំរាប់ដាក់ភោជនាហារ មានចាននឹងស្លាបព្រាជាដើម ក៏ត្រូវសំអាតដូចគ្នា ។

៣ ការសំអាតគ្រឿងផឹកនឹងភោជន: ទឹកដែលសំរាប់ផឹកត្រូវសំអាត គឺត្រង់កុំឲ្យមានធូលី បើដាក់ទឹកផឹកនឹងអ្វីត្រូវឲ្យមានគ្របបិទឲ្យជិត ត្រូវដំកល់ទុកដោយឡែកផ្សេងអំពីទឹកសម្រាប់ងូតសម្រាប់លាង ។ គ្រឿងភោជនមានបាយសំឡជាដើមក៏ត្រូវសំអាតដូចគ្នា បើដាក់បាយសំឡឬម្ហូបអ្វី ៗ នឹងភាជន៍ត្រូវឲ្យមានគ្របបិទឲ្យជិតកុំឲ្យសត្វល្អិតមានរុយជាដើមចូលបានឡើយ ។

៤ ការសំអាតគ្រឿងស្លៀកពាក់ គ្រឿងស្លៀកពាក់ទាំងអស់មានសំពត់ខោនឹងអាវជាដើម ត្រូវឧស្សាហ៍បោកគក់ដុសលាងឲ្យរឿយ ៗ កុំឲ្យប្រឡាក់ដោយញើសក្អែលនឹងធូលី ឬកុំឲ្យមានក្លិនឆ្អេះឆ្អាបជូរផ្អូមឡើយ ព្រោះគ្រឿងស្លៀកពាក់កាលបើមិនស្អាតហើយ ជាហេតុនាំឲ្យស្អុះស្អាប់ឲ្យស្អៀបរមាស់បណ្ដាលឲ្យកើតជារោគមានកមរមាស់ជាដើម ។

៥ ការសំអាតរូបកាយ រូបកាយបើប្រឡាក់ដោយញើសក្អែល ត្រូវងូតទឹកដំរះដុសលាងឲ្យស្អាត (វៀរលែងតែពេលកំពុងធ្វើការងារ) វេលាចូលទៅក្នុងទីកន្លែង ត្រូវលាងជើងជូតឲ្យស្អាតហើយសឹមចូលទៅ វៀរលែងតែជើងស្អាតស្រាប់ ។ បើសក់ដុះវែងត្រូវកាត់កោរចេញ ។

បើក្រចកដៃជើងដុះវែង ត្រូវកាត់ចេញឲ្យស្អាតឲ្យត្រឹមនឹងសាច់ ។ វេលាបរិភោគរួចហើយត្រូវសំអាតមាត់នឹងធ្មេញឲ្យស្អាត គឺយកឈើស-ម្រាប់ចាក់ធ្មេញមកចាក់កកាយចេញនូវកំទេចបាយ ឬត្រីសាច់ដែលចូលទៅជាប់ជ្រៀតជ្រែកតាមចន្លោះគៀនធ្មេញកុំឲ្យសល់នៅ. រួចដុសលាងដោយច្រាស់ឲ្យស្អាតល្អ ដើម្បីនឹងរក្សាធ្មេញកុំឲ្យមានរោគមានដង្កូវស៊ីជាដើមផង, កុំឲ្យមានក្លិនស្អុយផ្សាយចេញពីមាត់ផង, ឯធ្មេញនេះក្រៅពីពេលបរិភោគអាហារ មានពេលកំណត់ឲ្យដុសលាងសំអាតពីរដង គឺវេលារៀបអាស្រ័យដំណេកក្នុងវេលាយប់មួយ ពេលក្រោកពីដេកមួយ ។

ការសំអាតមានប៉ុណ្ណេះជាដើម កាលបើបានប្រព្រឹត្តធ្វើហើយនឹងនាំឲ្យមានអានិសង្សដូច្នេះ :

១ នឹងបានកំចាត់បង់នូវរោគផ្សេង ៗ

២ នឹងមានគំនិតប្រាជ្ញាភ្លឺល្អ ។

សេចក្ដីដែលពណ៌នាអំពីការសំអាតដូចខាងលើនេះ មិនមែនមានតែក្នុងដំណើរសំអាតក្នុងបច្ចុប្បន្ននេះឡើយ ច្បាប់ក្នុងព្រះពុទ្ធសាសនាក៏មានសំដែងទុកមកដោយច្រើន ៗ ក្នុងគម្ពីរវិន័យបិដក ប៉ែកខាងខន្ធក-វិន័យមានសេចក្ដីជាពុទ្ធប្បញ្ញត្តិនឹងពុទ្ធានុញ្ញាតមានដូច្នេះជាដើម ឲ្យបោសសំអាតទីសេនាសនៈកុំឲ្យមានសំបុកពីងពាងនឹងមែងភ្លើងជាដើម ៗ កុំឲ្យ

ទុកសក់វែង ៗ កុំឲ្យទុកក្រចកវែង ៗ កុំឲ្យស្តោះទឹកមាត់ដាក់កន្លែងដែលសំអាត ត្រូវលាងជើងជូតឲ្យស្អាតសិមជាន់លើកំរាល ៗ

ម្យ៉ាងទៀត ព្រះអង្គសំដែងថា អ្នកដែលមិនសំអាតធ្មេញ នឹងត្រូវបាននូវទោស ៥ យ៉ាងគឺៈ ១ កើតពេកកង់ក្អែក ៗ ២ ស្អុយមាត់ ៗ ៣ សរសៃសំរាប់ទទួលរសអាហារមិនស្អាតល្អ ៗ ៤ ប្រមាត់នឹងស្លេស្មមិនទប់ក្រសោបអាហារដែលបរិភោគទៅ ៗ ៥ នាំបណ្តាលឲ្យស្អើមមួមិនឲ្យឃ្លានអាហារបរិភោគមិនសូវបាន ៗ

អ្នកដែលសំអាតធ្មេញ នឹងត្រូវបាននូវអានិសង្ស ៥ យ៉ាង គឺ ១ មានក្អែកក្លិនស្រឡះល្អ ៗ ២ មិនស្អុយមាត់ ៗ ៣ សរសៃសំរាប់ទទួលរសអាហារស្អាតល្អ ៗ ៤ ប្រមាត់នឹងស្លេស្មទទួលទប់ក្រសោបអាហារដែលបរិភោគទៅ ៗ ៥ នាំបណ្តាលឲ្យឃ្លានចូលចិត្តបរិភោគអាហារ ៗ

ម្យ៉ាងទៀត កង្គម្ពីរវិសុទ្ធិមគ្គត្រង់សមាធិនិទ្ទេស មានសេចក្តីសំដែងអំពីអប្បនាកោសល្ល ១០ យ៉ាង ត្រង់អប្បនាកោសល្លទី ១ ឈ្មោះ វត្ថុវិសទកិរិយា សេចក្តីថា ធ្វើវត្ថុខាងក្នុងនឹងខាងក្រៅឲ្យស្អាត ៗ ធ្វើវត្ថុខាងក្នុងឲ្យស្អាតគឺធ្វើរូបកាយឲ្យស្អាត មានកាត់ក្រចក កោរសក់ នឹងដំរះដុសលាងខ្លួនមិនឲ្យមានញើសនឹងក្អែលជាដើម ៗ ធ្វើវត្ថុខាងក្រៅឲ្យស្អាត គឺសំអាតគ្រឿងស្លៀកពាក់នឹងទីដេករីអង្គុយជាដើមឲ្យស្អាត

បាត ។ បើវត្ថុខាងក្នុងនិងខាងក្រៅស្អាតល្អហើយ ៗ ទៅអន្គយចំរើនព្រះកម្មដ្ឋាន ចិត្តនិងចេតសិកក៏ប្រព្រឹត្តទៅដោយស្រួល កាលបើចិត្តនិងចេតសិកស្រួលហើយ ញាណគឺប្រាជ្ញាដែលអាស្រ័យនៅនឹងចិត្តក៏ភ្លឺស្វាងរុងរឿងល្អ ឧបមាដូចជាពន្លឺប្រទីបគឺចង្កៀងគោម កាលបើតួប្រទីបស្អាត ប្រេងក៏ល្អ ប្រឆេះក៏ល្អ លំដួងក៏ស្អាតល្អ ពន្លឺប្រទីបនោះក៏ភ្លឺរុងរឿងឡើងបាន ។ កាលបើវត្ថុខាងក្នុងនិងខាងក្រៅមិនស្អាតល្អហើយ ញាណគឺប្រាជ្ញាក៏មិនភ្លឺស្វាងរុងរឿងឡើងបានដូចជាពន្លឺប្រទីប, កាលបើតួប្រទីបជាដើមមិនស្អាតល្អហើយ ពន្លឺនោះក៏មិនភ្លឺស្វាងរុងរឿងឡើងបាន ។

ការសំអាតដែលមានក្នុងច្បាប់ព្រះពុទ្ធសាសនាច្រើនប្រការណាស់ តែដែលនាំយកមកអធិប្បាយក្នុងទីនេះជាសេចក្តីសង្ខេប ។

សូមអស់លោកទាំងឡាយ ឧស្សាហ៍សំអាតដូចខាងលើនេះនឹងបានត្រូវតាមដំពក្នុងបច្ចុប្បន្ននេះផង ត្រូវតាមច្បាប់ក្នុងព្រះពុទ្ធសាសនាផង មិនគ្រាន់តែបានត្រូវប៉ុណ្ណោះឡើយ នឹងបានទាំងប្រយោជន៍ផ្សេងៗផង មានកំចាត់បង់នូវរោគចេញអំពីកាយជាដើម កាលបើកាយឥតមានរោគហើយ ឈ្មោះថាបានលាភដ៏ឧត្តម សមដូចពុទ្ធភាសិត “អារោគ្យាបរមាលាភា” មានលាភអ្វីក៏មិនឧត្តមស្មើនឹងគ្មានរោគ ។ ព្រោះសេចក្តីថា អ្នកដែលឥតរោគអាចនឹងទទួលនូវលាភគ្រប់យ៉ាងបាន ឯអ្នកដែលមាន

ពេគសូម្បីលាភឯណាមួយកើតចំពោះមុខ ក៏មិនអាចទទួលយកបាន បើទុកជាទទួលយកមកបានក៏ហៅតែទឹងបាន ទឹងអាចសោយសេចក្ដីសុខព្រោះលាភនោះពុំបានឡើយ ព្រោះខ្លួនអ្នកមានពេគកេសេចក្ដីសុខគ្មាន ៗ

សេចក្ដីទាំងប៉ុន្មាន ដែលបាននាំយកមកអធិប្បាយក្នុងខាងលើនេះជាសេចក្ដីសង្ខេបគ្រប់អរទ្ធីទាំងអស់ព្រោះមិនមានពេលល្មមនឹងអធិប្បាយឲ្យពិស្ដារទៅបាន ក៏សន្មតថាចប់តែប៉ុណ្ណោះ ៗ

# អំពីលោកស្លូប៉េនហ៊ើរ

និង

# ព្រះពុទ្ធសាសនា (តនឹងបប់)

គឺការផ្ដើមកើតឡើងនៃវត្ថុទាំងពួង ដូចជាព្រះជាម្ចាស់នៃយើងដែរ ៗ ការដែលគិតស្រាវជ្រាវរកបែបនោះ នៅក្រៅវិស័យគំនិតរបស់ពួកអ្នកប្រាជ្ញ អ្នកស្វែងរកតែសេចក្ដីពិត ៗ មួយវិញទៀត លោកស្កុប៉េនហារមានពាក្យខ្លួនដូចជាព្រះពុទ្ធជាម្ចាស់ដែរ ថាព្រះជាម្ចាស់សួគ៌នោះមិនមែនជាអ្នកកសាងលោកនេះឡើងទេ លោកនេះតែងកើតឡើងឯងជាលំដាប់ ៗ គឺធាត់ធំចំរើនឡើងឯងគ្រប់ៗខណៈ ៗ លោកអ្នកប្រាជ្ញនោះសរសេរទុកថា "លោកនិងមនុស្សកើតឡើងដោយខ្លួនឯង គឺដោយអំណាចសេចក្ដីប្រាថ្នារបស់ខ្លួន" ៗ ក្នុងគំនិតរបស់លោកមិនដែលមានគំនិតស្របទៅតាមកិច្ចការរបស់ព្រះម្ចាស់ជាអ្នកសាងលោក ឬសាងសព្វសត្វក្នុងលោកនេះឡើយ គ្រាន់តែយល់ថាជាសភាពស័ក្តិសិទ្ធិដែលផ្សាយចេញទូទៅ គឺ "សភាវៈសូន្យទទេ" តាមលទ្ធិដែលប្រកាន់ថា គ្រប់យ៉ាងគ្រប់ប្រការចេញអំពីរបស់ជាមួយគ្នា ៗ

ការយល់ថា "ព្រះជាម្ចាស់" នោះ សំដៅដល់អ្នកសាង អ្នកចេះដឹងទូទៅ អ្នកមានមហិទ្ធានុភាព អ្នកទ្រង់នូវយុត្តិធម៌ អ្នកមានមេត្តាករុណា គឺជាអ្នកមានអំណាចនិងប្រាជ្ញាដ៏ខ្ពង់ខ្ពស់បំផុត ៗ សេចក្ដីអស់នេះសឹងចង្អុលសំដៅដល់បុគ្គល មិនអាចសំដៅជម្រៅទៅដល់សភាពស័ក្តិសិទ្ធិទូទៅទេ ការដែលហៅលោកថាជាព្រះម្ចាស់ ដូចជាលោកនោសាពេលនោះ មិនបានសេចក្ដីដូចម្ដេចសោះឡើយ ៗ លោកស្កុ-

ប៉េនហ៊ើរពោលថា គ្រាន់តែនិយាយឲ្យមានសំដីភាសាសម្បូរឡើង ដោយពាក្យប្ញ៉ិតពេក សម្រាប់បន្ថែមផលពាក្យថា "លោក" ប៉ុណ្ណោះ ។

ពាក្យប្រដៅទូន្មានរបស់លោកស្ប៉េនហ៊ើរ ត្រូវគ្នានឹងព្រះពុទ្ធជាម្ចាស់ជាច្រើនដូចបានពោលមកនេះ តែមតិរបស់លោកមិនស្របគ្នានឹងព្រះធម៌របស់យើង ទុកជាសារធម៌ដ៏សំខាន់របស់ពុទ្ធសាសនាក៏សង្គ្រោះចូលពុំបានដែរ គឺអំពីរឿងប្រែប្រួលផ្លាស់ប្តូរ ឬការហ្វឹកហ្វឺននិស្ស័យសន្តានរបស់មនុស្សដូចជាលោកស្ប៉េនហ៊ើរទូន្មានថា មនុស្សយើងរមែងមាននិស្ស័យប្រចាំមកពីកំណើត នឹងកែប្រែមិនកើត នៅនឹងដដែលរហូតដល់ស្លាប់ គឺការប្រែនិស្ស័យសន្តានដែលជាឫសគល់ដើមនោះ ប្រព្រឹត្តទៅមិនបានឡើយ ។

អំពីការឃាត់ខាំងដំណើរចិត្តនោះ លោកស្ប៉េនហ៊ើរយល់ទាស់ ឬបដិសេធធម្មចរិយា នឹងសីលធម៌ទាំងឡាយ ព្រោះលោកនេះទូន្មានថា មិនមានធម្មចរិយាណាមួយដែលមានដំឡៃនឹងមានកំឡាំង អាចកែប្រែមនុស្សដែលមិនមានសីលធម៌ឲ្យមានសីលធម៌ឡើងបានទេ ដូចជាមនុស្សមិនមាននិស្ស័យខាងក្បាច់រចនា ទុកជាមានគម្រាក្បួនក្បាច់រចនានៅនឹងដៃក៏មិនអាចធ្វើអ្នកនោះឲ្យទៅជាអ្នករចនាបានឡើយ ។ សេចក្តីទូន្មានក្តី ធម្មចរិយាក្តី គ្រាន់តែជួយជ្រោមជ្រែងចំណេះក្នុងខ្លួនឲ្យប្រាកដស្តែងចេញមកប៉ុណ្ណោះ តែមិនអាចផ្លាស់និស្ស័យសន្តានដើមបានឡើយ ។ អ្នក

ដែលកើតមកមាននិស្ស័យសន្ដានជាមនុស្សពាល ក៏នៅតែមាននិស្ស័យពាលរហូតដល់ស្លាប់ ទុកជាមានធម្មចរិយាជាគ្រឿងជួយប្រែនិស្ស័យបានក៏ដោយ និស្ស័យពាលដែលមានក្នុងសន្ដានចិត្តក៏គង់ទ្រង់នៅដដែល ៗ ពួកអ្នកលួចឆក់អាចក្លាយទៅជាអ្នកជំនួញយ៉ាងពូកែ តែថាការសម្រេចខាងផ្លូវជំនួញនោះ គេតោងតាំងអាស្រ័យនៅលើបែបភាពចោរកម្មដ៏ទាន់សម័យនុ៎ះឯង ៗ

សេចក្ដីដែលលោកស្ប៉េនហ៊ែរបានពោលមកហើយនេះ ទុកជាយើងមិនមានសេចក្ដីយល់ព្រមតាមយោបល់របស់លោកក៏ដោយ តែត្រូវសំឡឹងឲ្យដល់សេចក្ដីពិតថា "ទំនើងសីលធម៌និងធម្មចរិយាមិនអាចដឹកនាំបុគ្គលទៅកាន់សេចក្ដីត្រាស់ដឹងបានទេ គឺមិនអាចញ៉ាំងបុគ្គលឲ្យបានសម្រេចព្រះនិព្វានបានឡើយ" ៗ មនុស្សយើងអាចរក្សាសីលតែមួយយ៉ាងបានរហូតទៅ តែនៅតែមិនអាចឲ្យរួចផុតពីទុក្ខទាំងពួងបានឡើយ ៗ បុគ្គលរក្សាសីលដើម្បីឲ្យមានជីវិតនៅក្នុងលោកតាមទំនងគន្លងធម៌ដែលល្អ តែមិនអាចធ្វើព្រះនិព្វានឲ្យប្រាកដបានឡើយ ៗ វិមុត្តិឬការរួចផុតស្រឡះជារបស់មិនមែនត្រូវដើរទៅតាមផ្លូវត្រង់ឬផ្លូវវៀចទេ ព្រោះព្រះនិព្វាននោះមិនមែននៅខាងមុខយើងឡើយ គឺនៅជុំវិញខ្លួនយើងនេះទេ តើ ៗ យើងមិនបានគុណវិសេសអ្វីអំពីការកើតទៀតនោះឡើយ ការដែល

យើងបានដល់នូវវិមុត្តិបាននោះ លុះតែយើងឃើញច្បាស់លាស់ដោយចិត្តរបស់ខ្លួន គឺវិបស្សនាញាណ ។

ឯវិបស្សនានេះ ជាធម្មជាតិជ្រាលជ្រៅសំខាន់ណាស់ ហេតុនេះ បានជាពួកភិក្ខុនាំគ្នាធ្វើសមាធិនិងពួកលទ្ធិសេនស៊ុ(១) នាំគ្នាបំរើនវិបស្សនានេះជាទីប្រជុំរួមផ្សំកណ្ដាលដែលពួកនិកាយផ្សេង ៗ ទាំងមហាយាននិងហីនយាន ដើរផ្លូវជាមួយគ្នា សូម្បីក្នុងលទ្ធិស៊ិនស៊ុ(២) របស់យីពុន ក៏ជួបនិងសេចក្ដីពិតក្នុងពេលប្រតិបត្តិដូចគ្នាដែរ ។ ពួកស៊ិនស៊ុនេះសំឡឹងតែកំឡាំងខាងក្រៅ ដើម្បីដាស់ចិត្តខាងក្នុង ។ ឯពួកសេនស៊ុស្វែងរកក្នុងខ្លួនគេឯង ។ បើដូច្នេះតើយើងអាចវិនិច្ឆ័យបានថា ពួកណាខុស ពួកណាត្រូវ មិនមានអ្នកណាដឹងបានថា កិរិយាជ្រះស្រឡះនៃចិត្តនោះបង្កើតពន្លឺមានរស្មី រមែងកើតអំពីសេចក្ដីព្យាយាមរបស់បុគ្គល ឬកើតអំពីអំណាចខាងក្រៅខ្លួន ។

កិរិយាជ្រះស្រឡះនៃចិត្តអាចមានបានគ្រប់ ៗ ខណៈ គឺក្នុងខណៈដែលកំពុងធ្វើសមាធិ និងខណៈដែលមានហេតុការណ៍ខាងក្រៅមកបណ្ដាលឲ្យកើតឡើងតាមធម្មតាដូចជារឿងដែលយើងធ្លាប់ប្រទះមកថា មានភិក្ខុមួយរូបមានសេចក្ដីយល់ច្បាស់អំពីអនិច្ចលក្ខណៈដោយខ្លួនឯង ដោយ

---

១ សេនស៊ុ (Zenshu) មហាយាននិកាយ ៖ ក្នុងស្រុកយីពុន ។ ២ ស៊ិនស៊ុ (Shinshu) មហាយាននិកាយ ៖ ក្នុងស្រុកយីពុនដែរ ។

ហេតុប្អូនជាខ្លួនបានឃើញធ្មេញរបស់ស្រីម្នាក់សើចប៉ុណ្ណោះ ខនេះជារឿងមិនមានគោលសម្រាប់ប្រតិបត្តិទេ គ្រាន់តែនាំយកមកពោលទុកជាឧទាហរណ៍ប៉ុណ្ណោះ តែហេតុការដូច្នេះ នឹងប្រកាន់ទុកជាគោលនៃការចំរើនវិបស្សនាមិនបានឡើយ ព្រោះបុគ្គលយើងកម្រនឹងស្វែងរកព្រះនិព្វានឃើញដោយការធ្វើធ្មេញនោះទេ តែកិច្ចការចំពួកខ្លះដែលកើតឡើងតាមទំនងនេះរមែងមានរឿយ ៗ ។

ក្នុងគម្ពីរអង្គុត្តរនិកាយដែលសំដែងពីធម៌ប្រាំបួន ៗ មានសេចក្តីពាក់ទងនឹងវិបស្សនាខមួយថា ការចំរើនវិបស្សនាត្រឹមតែមួយខណៈប៉ុមួយស្របក់ រមែងមានគុណានិសង្ស ច្រើនជាងការឲ្យទានជាងការរៀនបរិយត្តិធម៌ ជាងការសមាទានសីល តែវិបស្សនាញាណដែលយល់ច្បាស់ថា សង្ខារមិនទៀង ត្រឹមមួយខណៈប៉ុណ្ណោះ មានអានិសង្សច្រើនជាងការចំរើនមេត្តាភាវនាទៅទៀត ការឃើញច្បាស់យ៉ាងជ្រះស្រឡះនឹងការដល់នូវព្រះនិព្វានអាចកើតឡើងបាន ដោយអាការចំរើនអនិច្ចលក្ខណៈនេះឯង ។

ក្នុងគោលប្រតិបត្តិរបស់លោកស្កូប៉េនហ៊ែរ ក៏ច្រើនតែពោលថែមហើយថែមទៀតអំពីការចំរើនវិបស្សនានេះជានិច្ចដែរ ព្រោះវិមុត្តិគឺការរួចផុតអំពីគំនរទុក្ខនោះ មនុស្សយើងនឹងបានសំរេចបានដោយការដឹងច្បាស់តាមសេចក្តីពិត អំពីដំណើរជីវិតរបស់ខ្លួនដែរ ដែលជាចំណោះ

បេះសម្លាប់បង់នូវសេចក្ដីប្រាថ្នាអន្ទះអន្ទែងក្នុងជីវិត ទើបញុំាងបុគ្គលនោះឲ្យបានសម្រេចនូវឧត្តមសុខជាផលកំរៃ ។

ក្នុងដំណើរនៃសីលធម៌នេះ លោកស្ហប៉េនហឺក៏បាននិយាយទុកដោយល្អិតដែរ លោកធ្វើគោលចារិកក្នុងក្បួនច្បាប់របស់លោកសុទ្ធសឹងជាប់ទាក់ទងនឹងចិត្ត ដែលប្រកបដោយមេត្តាករុណាដល់សត្វទាំងឡាយដោយមានសភាពស្មើគ្នាទាំងអស់ ។ មេត្តាចិត្តបែបនេះ ត្រូវគ្នានឹងមេត្តាចិត្តរបស់ជនពួកមួយដែលប្រកាន់តាមលទ្ធិ "វេទាន្តៈ" ។

ចំណែកខាងពុទ្ធសាសនា មិនមានបំណងនឹងអធិប្បាយដូច្នោះទេ ព្រោះដឹងស្រាប់ហើយថា មេត្តានិងករុណារមែងកើតឡើងជាមួយគ្នាដូចជា "Tuning-Fork(១)" ដែលឃ្លាតចុះឃ្លាតឡើងពីមួយទៅមួយតាមទំនងដូចគ្នា តែការត្រូវការសេចក្ដីករុណា ដើម្បីទុកជាបទស្ថាននៃសីលធម៌ដ៏ប្រពៃនេះ ធ្វើឲ្យលោកស្ហប៉េនហឺយល់ព្រមតាមយោបល់ របស់ពួកពុទ្ធបរិស័ទ ដែលមានចិត្តផ្សាយដល់សត្វលោកទាំងពួងយ៉ាងគ្រប់គ្រាន់ ។

លោកស្ហប៉េនហឺមានមុទិតាចិត្តដល់សត្វទាំងឡាយ ចិត្តបែបនេះក្នុងសម័យរបស់លោក រកបានដោយក្រ ក្នុងទ្វីបអឺរ៉ុប ។ លោកអច្ឆរិយបុរសនេះ មានគេកេរឿងថា លោកជាមនុស្សមើលងាយប្រមាទ

---

១ គ្រឿងតន្ត្រីមួយយ៉ាងរបស់ពួកអឺរ៉ុបដែលយើងមិនធ្លាប់ឃើញ ។

ដល់គេតមនុស្ស បានជាលើកសិទ្ធិរបស់សត្វតិរច្ឆានមកប្រៀបផ្ទឹមនឹងមនុស្សដោយមានភេទៈតបតដំណាងរបស់វាជានិច្ច ។ សេចក្តីរៀបរៀងតែងជាក្បួនរបស់លោកពេញទៅដោយសេចក្តីមេត្តាករុណាដល់សព្វសត្វទាំងអស់ ដែលវិលកើតវិលស្លាប់ក្នុងសង្សារវដ្តនេះ មានសេចក្តីមួយបទដែលបានសរសេរទុកនោះដូច្នេះ :

> ប្រសិនបើខ្លួនខ្ញុំជាព្រះម្ចាស់សួគ៌ ជាអ្នកកសាងពិភពលោក
> នេះហើយ សេចក្តីទុក្ខលំបាកនៃសត្វទាំងពួងដែលកំពុងតែ
> រងទុក្ខវេទនានៅវេលានេះ នឹងធ្វើឲ្យហទយវត្ថុដួងចិត្តរបស់ខ្ញុំ
> ឲ្យប្រេះឆ្លាយដោយពិតមិនខាន ។

សេចក្តីអស់នេះ សឹងជាសេចក្តីច្បាស់លាស់ព្រោះលៀនចេញមកអំពីដួងចិត្តរបស់លោក តែដោយហេតុលោកជាជនជាតិឥទុរុប ទើបប្រឹងតែទំនុកបម្រុងគំនិតរបស់លោក ឲ្យប្រព្រឹត្តទៅតាមអំណាចហេតុផលនឹងតក្កវិទ្យា ។ ហេតុនេះ បានជាក្នុងសៀវភៅរបស់លោកជាច្រើន ដែលមានសេចក្តីមិនស្របគ្នា ទំនើសគ្នាឯងលាយច្របល់ផង ខនេះសំដែងឲ្យឃើញការធ្វើរបស់លោក ស្រេចតែអំណាចគំនិតរបស់ខ្លួនយ៉ាងច្បាស់លាស់ ៗ ការយល់ច្បាស់ (តាមពិត) ធ្វើឲ្យលោកបានដឹងថាបុគ្គលគោងតែទទួលផលកម្មរបស់ខ្លួនៗតែតាមតក្កវិទ្យាពោលថា កម្មគ្រប់យ៉ាងជាផលនៃចេតនាដើមតាមលក្ខណៈដែលមិនអាចប្រែប្រួលបានប៉ុណ្ណោះ ៗ

ការដែលលោកស្ប៉េនហ៊ឺលោកព្យាយាមអធិប្បាយអំពីជីវិតថាជាវិធីមួយ ដែលវិលទៅតាមហេតុនិងផល គឺជាប្រព្រឹត្តទៅតាមបញ្ញត្តិរបស់ហេតុ នេះជាការខុសឆ្គាត់យ៉ាងធំរបស់លោក ព្រោះជីវិតមិនមែនប្រព្រឹត្តទៅតាមបញ្ញត្តិធម្មជាតិទេ តែជីវិតជាតួបញ្ញត្តិខ្លួនឯង ជីវិតជារបស់ប្រាកដនៅក្នុងលក្ខណៈនៃបញ្ញត្តិ ជីវិតមានអំណាចដាច់ស្រេចជាបំផុត ជីវិតនេះអាចសំដែងឲ្យយើងឃើញរូបឆោមខាងក្រៅ បានគ្រប់ៗយ៉ាង អ្នកដែលអធិប្បាយអំពីជីវិតថានៅក្រោមអំណាចធម្មជាតិនិងក្រោមបញ្ញត្តិនៃធម្មជាតិនោះជាសេចក្តីបូលបិត្តខុសទាំងស្រុង ។

# រឿង កាកី

## ព្រះរាជនិពន្ធ ព្រះបាទសម្ដេចព្រះហរិរក្សរាមាឥស្សរាធិបតី

## ព្រះបរមកោដ្ឋ

*តាមច្បាប់របស់ព្រះអង្គម្ចាស់ក្សត្រីមាលិកា*

( ភ ទី ២ )

៙ បទកាកគតិ ក្រុងគ្រុឌបក្សី ប្រែប្រាណកាខ្លា រូបរូទេ-វបុត្រ ពិសុទ្ធសោភា ឲបអង្គកែវកា-កីកិតនាកី ៗ នៃបទិតក្រសោប ផ្ទួញផិតអង្គឲប អង្អែលឥន្ទ្រិយ ថើបថៃកាយា កក្ដាកាកី ក្ដួចកើតមេត្រី កាគសេតណ្ហា ៗ នាងកាកីជំ-លឿងលបលួចសំ-ឡក់លរតិរយា ការក៏ទះទាត់ ច្រានផាត់គ្រុឌា ទើបមានវាចា ផ្ទាស់ផ្ទើយទៅថ្កាន ៗ ថាទុព្រះអង្គ ពុំគួរត្រេកត្រង់ រួមសេដិតដាន ទើងអង្គអញខ្ញុំ យល់ពុំសមប្រាណ ដ្បិតខ្ញុំនៅមាន ស្វាមីមិត្រហើយ ៗ គួរប្ដីព្រះអង្គ ព្រះទ័យពុំត្រង់ នឹងម្ចាស់ខ្ញុំឡើយ លបលួចយកខ្ញុំ មកផ្ដុំផ្ដើមខ្ទើយ ឱព្រះអង្គអើយ ពុំគិតក្សត្រា ៗ បំណាច់ចាប់ចិត្ត ជាមិត្រស្នេហ៍ស្និទ្ធ សំឡាញ់ផងគ្នា ព្រះអង្គធ្វើបាន ពុំមានមេត្តា ព្រះទ័យព្រះមហា-ក្សត្រក្បាន្តដល់តិច ៗ ចង់បើខ្ញុំដោយ យូរទៅឯក្រោយ ស្រាប់តែទើងគេច យកស្រីស្នួតា ឯណាល្អលេច ម៉្លោះហើយទើងក្ដេច ពោលខ្ញុំបង់សៀត ៗ បើម៉្លោះសមខ្ញុំ នឹងមានទុក្ខធំ ទូងត្រួតបង្អៀត ថែមទាំងដំនៀល គេដៀលផ្ទួនទៀត ថាស្រីស្រៀបឆ្ងៀត មានប្ដីត្រុឌា ៗ ហើយគេទើងដៀល ដំណាលដំនៀល ដល់ព្រះរាជា ជាស្ដេចស្ទើងស្ទះ លាកលះលីលា ទៅលួចកិរិយា គេមកសិព្ទលី ៗ ក្រុងគ្រុឌឆ្លើយថា បងជើងហើយណា ប្អូនជាមហេសី ស្ដេចទុកជាច្បង កន្លងលែងស្រី ហើយព្រះចក្រី ស្រឡាញ់អស់អញ ៗ ទោះបីបើក្ស-ត្រាទ្រង់ជ្រាបថ្លាក់

ក្រោធក្រៃគ្នាន់ខ្នាញ់ បងពុំខ្លាចឡើយ ប្អូនអើយព្រឹកមិញ បើដោយ
ស្រឡាញ់ ប្អូនមាសប្រសើរ ៗ តែគិតក្តៅកោះ បើកុំប៉ុណ្ណោះ កន្ត្រាក់
យកយើរ ពីមុខអ្នកស្តេច បងផ្តាច់មិនស្បើរ ពារពារហោះហើរ មករួម
ស្នេហ៍ស្នង ៗ ប៉ុន្តែការកើត ខ្លាចមានទាំងពីរ ទាំងប្អូនទាំងបង បានជា
បងឈប់ លុះយប់ទើបផ្គង នាំប្អូនមកត្រង់ ទីទេនសៃយាស ៗ
ប្អូនអើយមាសថ្លៃ មាសថាខ្លាចក្រែង ពាក្យពោលទាំងផ្តាស គេ
ដៀលដល់បង ថាបងនាំមាស ហើរហោះរបោស មកស្ថានសួគ៌ា ៗ
នាកាលអញបង យកប្អូនស្នេហ៍ស្នង នោះគ្មាននរណា យល់ជាបង
យក មាសមកស្នេហា ប្អូនអើយកុំប្រា-រម្ភការព្រាណ ៗ អំបាលស្រីសួគ៌
គំនាប់គំនួរ ស្រៀបស្រស់កល្យាណ ម្តេចបងពុំប៉ង ចិត្តបងចង់បាន
បានជាបងគ្មាន ស្រីស្រស់កញ្ញា ៗ ឯអង្គកាកី ចិត្តចង់មេត្រី ពត
សេតណ្ហា ធ្វើពោលពាក្យពើ ថាយើសួគ៌ា គ្មានស្រីមួយជា ត្រូវចិត្ត
ប្តី ៗ អំបាលស្រីសួគ៌ គំនាប់គំនួរ ម្តេចមិនមេត្រី ចុះអ្វីខ្ញុំជា មនុស្ស
នាផែនដី កាលណាឡើយត- ស្បូរសព្វទីយា ៗ សព្វតែព្រះឧស្ស
ព្រះអង្គថាប្រោស លើសលែងនានា ព្រះបន្ទូលផ្អែម ល្ហិមល្ហែម
ណាស់សា ព្រះអើយខ្ញុំមហា- សង្ស័យកន្លង ៗ ទើបគ្រុឧលោមថា
មែនហើយស្ងួនភ្ងា អស់ស្រីសួគ៌ផង ល្អល្អះមែនពិត ឯកឥតមាន

ហ្មង ប៉ុន្តែអញបង ពុំត្រូវហឫទ័យ ។ ប្អូនអើយកុំប្រ-(១) រម្កេរៀមក្រែងក្រ-
លាប់លែងដោះដៃ បងពោលពាក្យពិត ពិនិត្យពេកក្រៃ កុំស្ងួនសង្ស័យ
សន្ទិះសង្កា ។ ហើយត្រូវចូលជិត ចូលចង់ទៃបទិទ្រ ទៃបនឹងស្នេហា
ឯកែវកាកី ក្សត្រីសោភា សំងំអង្គា អង្គុយផ្ញួញជិត ។ តែមាត់នាងថា
ចុះឲអនិច្ចា ពុំអាសូរចិត្ត ដ្បិតបេលឯកឯង កំហែងប្រតិព័ទ្ធ ធ្វើបំបាត់
មាត់ ពុំឱ្យឆ្លើយបាន ។ ត្រូវឱបក្រសោប ត្រកងអង្គឱប អង្អែលអស់
ប្រាណ មូលមេចចនថើប សំរើបសម្រាន ផ្ទុំផ្ទឹមផ្ទាល់មាន ចិត្ត
ចង់មេត្រី ។ រួមរ័តរសរូប ក្រអែបក្រអូប ផ្សាយផ្សព្វឥន្ទ្រិយ ស្រើប
ស្រួលចូលចិត្ត ជួញជិតប្រតី·ពន្ទ័ពេញបីតី សុខសេពចំណង់ ។ ត្រូវ
ក្លេបនាគា អាហារភោគ្គា ជាចំអែតអង្គ នាងក្លេបមហាក្សត្រ ព្រហ្ម-
ទត្តទ្រើសទ្រង់ ត្រូវក្លេបឃោះបង់ ហេមពាន្តខ្ជូវទ័ ។ នាងក្លេបអស់
ល្បែង ខុទ្យានតែងលេង កំសាន្តឥន្ទ្រិយ ត្រូវក្លេបផ្ទៀលផ្ទាត់ ផ្គាត់
ស្រះស្រី នាងក្លេបបុរី សួស្តិទ្ធភពស្ថាន ។ ត្រូវបានកាកី ពាសេស
លែងស្រី ពិដោរអស់ប្រាណ សេពសុខមនោរម្យ ផ្ទឹមផ្ទុំសម្រាន
សំរើបសប្រាណ ឥតឯមានហ្មង ។ សេពសុខស្កប់ស្កល់ ទៀងទៀប
ទៅដល់ ទឹងបានកន្ទង ត្រឹមត្រូវយោមា បក្សាសូរសង រងាវរំពង
រំពេសុរិយា ។

---

១ ដែលត្រូវជា ប្រា តែក្នុងទីនេះត្រូវការឲ្យសម្ព័ន្ធនឹងពាក្យខាងក្រោយ គឺ ក្រ ។

១ បទព្រហ្មគីតកាល ត្រឹះស្នេហ៍ស្នាលទឹងកែវកា- កិកាយគប គន្ធា- សេរិះនេះស្មេះបង្អង់ ៗ ចាប់ចង់ទំនងទី- ធានទៅពីក្សត្រទ្រើស ទ្រង់ រាជវឌ្ឍកាលកើតក- ង្គុលកែវកោលាហល ៗ ដោយបុទ្ធិរាជត្រុឡា បណ្ដាលជាព្យុះពេញ្រមសល់ លុះស្ងាត់បាត់ព្យុះខ្យល់ ស្ដេចចូលដល់ វែនមណី ៗ ពុំឃើញវរជាយា នៅក្រលាបន្ទំទី ទៀងទើបព្រះភូមី ស្ទុតព្រះទ័យព្រះរាជា ៗ ស្ដេចគន់ស្ដេចគិតឆ្ងល់ បទពុំយល់វរជាយា ដណ្ដឹងស្នំស្នេហា នាងទៅណាបាត់ពុំយល់ ៗ អស់ស្រីសិងស្នាំងកាំង ភ័យភិតភាំងកេរះល់ តែកេនាងនិរមល សព្វមន្ទីរមណ្ឌលា ៗ បាត់ សោះបាត់សូន្យសល់ រកពុំយល់វរជីតា មកទូលមហាក្សត្រា ស្ដេច រឹងភាំងរឹងភិតក្រៃ ៗ ស្ទុតស្ញប់ផប់ព្រះភក្ត្រ អន់អួលអាក់ក្នុងព្រះទ័យ ក្ដួលក្ដៅឧកក្រៃ គិតអាល័យអាលោះលន់ ៗ ទ្រង់ព្រះកន្សែងសោក សែនអាម៉ោកស្ដាយពេកពន់ ព្រះផ្អូកព្រះប្អូនគន់(១) ទ្ទួញទន្ទឹងទន្ទេញ ថា ៗ ឱមាសមិត្រកល្យាណ បងកេគ្មានស្រីឯណា ឲ្យដូចកែវកេនិជ្ជា ក្ខិនក្រអូបក្រអែបឯង ៗ ឱស្ដាយកក្រៃសោភ័ណ ហាក់ព្រះបន្ទូលត្របះ រិបង ស្នួនសមជាស្ដេចស្ដែង ឯកក្សត្រិស្រីកល្យាណ ៗ ស្ដាយបេះ

---

១ គន់ មកពីពាក្យថា រគន តែអ្នកតែងកាព្យត្រូវការពាក្យតែ ១ ម៉ាត់ កាត់យកតែត្រឹម គន់ មកប្រើក៏មាន ចួនកាលយកតែសំឡេងអក្សរដើម ១ ម៉ាត់ គឺរគន់ មកប្រើក៏មាន ចួនកាលគិតយកទាំង រគន់ ក៏មាន ។

ផែងចរចា ស្តាយប្រាជ្ញាបេះរិះធ្យាន ដឹងអត់ដឹងខុនប្រាណ ដឹងសម
គួរសមគាប់ការ ៗ ស្តាយសមជាមហេសី ដំលើសស្រីស្រស់ស្រីស្គារ
ស្តាយបេះដូងសព្វសារ ពេការពុំមានផ្ទៃធ្វល់ ៗ បំរុងស្រីបំរើ ចិត្តស្មោះ
ស្មើគ្មានកិច្ចកល់ ដឹងទោសដឹងទុក្ខខល់ អស់ស្រីស្នំស្និទ្ធទាំងឡាយ ៗ
បងរកបងរិះគ្រប់- ពុំប្រសព្វប្រសើរកាយ ឲ្យដូចប្អូនពោមពាយ ស្រីសំ-
ល្អិតសំឡាញ់បង ៗ ឥឡូវប្អូនប្រែប្រាស ព្រាត់ទិសសៀមហើយ
ហោង សៀមរកនារីស្នង ពុំដូចមាសមិត្រភ្ងាស្រី ៗ ខ្ញុំប្អូនធ្លាប់ផ្ដុំផ្ដិម
ទៀបខ្ទិមលើខែនទី ពុំដែលពុំជាច់ពី អង្គអញបង់បាត់ចេះណា ៗ
ខ្ញុំប្អូនធ្លាប់គង់ជិត នៅនែបរិទ្រទឹងរៀមព៉ា ក្រសាលសុខទ័យា ម្តេច
ឡើយប្រាសទិសទៅ ៗ ខ្ញុំបងធ្លាប់យល់កក្រ្ត ប្អូនវរលក្ខណ៍គង់
គាល់ហៅ បំរើសព្វថ្ងៃនៅ ឥឡូវបាត់បង់បងធ្លាយ ៗ ខ្ញុំធ្លាប់ស្រីធំគន្ធា
ទឹងរៀមព៉ាក្បាន្តសប្បាយ និទុក្ខសុខស្កល់កាយ រួមភិរម្យរសទាំងទ្វី ៗ
ខ្ញុំប្អូនថ្ងៃត្រកាល កំពុងពាលពេញពិសី ពុំគួរឡើយប្អូនស្រី ប្រាស
ចាកពីប្រសើរសុខ ៗ ខ្ញុំប្អូនទៅស្ថានណា ជាសុខាឬខល់ទុក្ខ ឬកាល
កើតកលិយុគ ក្រែងក្រុងត្រុឌយក្សនាគផង ៗ មកយកពៅពិសី ទៅ
បែតិស្ថាលស្នេហ៍ស្នង ខ្ញុំប្អូនអើយបើបង ដឹងជាស្ថិតនៅស្ថានណា ៗ
បងទឹងតាមដោយដាន ត្រាតែបានយល់កញ្ញា ឥឡូវកែកេនិដ្ឋា ឥត
ដំណឹងដំណួចឡើយ ៗ ខ្ញុំមាសមិត្រព្រលឹង អស់ខ្ទឹងប្អូនម៉្ងុះហើយ

ទុក្ខបងពុំត្រាស្បើយ គ្មានល្ហែល្ហើយរាប់រាល់ថ្ងៃ ៗ ស្តេចសោកអគ្គជាយា អន់អួលអាណោតណាស់នៃ ជាទុក្ខរៃងទុក្ខក្រៃ ក្រៃលែងលើសទុក្ខនានា ៗ វេលាធ្លាប់ផ្ទំលក់ ផ្ទំពុំសុខសែនសោកា ក្មេចទាំងស្រស់គន្ធា តាំងតែទួញតែទុក្ខទៅ ៗ ពេលសោយក្រយាស្ងោយ ក្មេចសេពសោយតែសោកសៅ ព្រះអង្គព្រះអួលក្តៅ ក្នុងព្រះទ័យតែងទុក្ខទល់ ៗ ក្មេចក្លាំងទាំងក្រសាល អស់អំបាលស្នំនិមល ទាំងល្បែងលេងសុខសល់ តាំងតែទួញតែទុក្ខា ៗ ទើបត្រាស់ឲ្យរកហោរ គន្ធទៅជួបចិន្តា ហើយប្រាប់ពីជាយា ឃាត់អំពីប្រាសាទស្ថាន ៗ គន្ធនដឹងហេតុហើយ ទើបទូលឡើយថាសូមទាន កាលព្រះមហាក្សត្រក្សាន្ត ទ្រង់ស្កានឹងមាណពនោះ ៗ ទូលព្រះបង្គំយល់ អ្នកនិមលនៅទ្វារផ្ទោះ មើលមកមាណពនោះ ឯមាណពធ្វៀងនេត្រា ។ ញញឹមមើលទៅត្រង់ ទូលព្រះបង្គំក្រោធា តាងទ្រង់ព្រះករុណា ពិសេសស្មើស៊ីសាច់បាន ៗ តែខំអត់កំហឹង គិតជញ្ជឹងយល់សូមទាន បើសិនជាប្រុសប្រាណ នៅនាឧត្ត'យើងអាយ ៗ ម្តេចមិនថ្វាយបង្គំ បើអ្នកអម្ចង់ស្ថានឆ្ងាយ ខ្លាំងដើរម្តេចអន្សាយ ឆាប់ដល់ទៅដល់មកទ្វា ៗ យល់ប្លែកនឹងមាណព នៅពិភពភូមិផែនដី ខ្លាចក្រែងក្រុងត្រៃ- ភពរឹងបុទ្ធិក្មេងបួមអគ្គ ៗ មកលេងហើយក្បួនលាក់ ព្រះអង្គអគ្គទេពីពង្ស ទៅសេពសោសាច់ស- ម្រាស់ទម្លាញ់នៅសម្ពលី ៗ ទូលព្រះបង្គំនេះ យល់ផ្តេរណាយសេចក្តី សូមទានល្អងធូលី

ព្រះបាទចាំប្រាំពីរថ្ងៃ ៗ យល់ជាមកពុំខាន យើងនឹងបានគន់រំពៃ ឲ្យ
ជាក់បើច្នេះនៃ តាមដោយដិតគន់ដឹងថ្វាត់ ៗ ហើយធ្វើកលឲ្យបាន ដូន
កល្យាណមកម្យរ័ដ្ឋ គន្ធ័នទូលមហាក្សត្រ ព្រះអង្គអគ្រាន់បានស្បើយ ៗ
ទើបស្តេចត្រាស់ទៅផង ថាហៃបងគន្ធ័នអើយ បើមែនដូច្នោះហើយ ឲបង
អើយអញអរក្រៃ ៗ ច្នោះបងទៅឲ្យឆាប់ នឹងក្រលាប់វិលវិងវៃ ចូរគន់គិត
គារក័យ វៃរៀសរំងកាយ ៗ ដង្ហិតទៅក្នុងការក្រៃ ទឹកម្រជូរក៏ធ្លាយ
គន្ធ័នសោកក្រាបថ្វាយ វរវន្ទាព្រះបមបៅ ៗ ឯក្សត្របរបូលថ្កាន ក្នុង
កដស្តានតែងសោកសៅ ជាទុក្ខក្តាត់ក្តួលក្តៅ នឹងតែវកាក៏កល្យាណ ៗ
ដំណាលដំណើរនេះ យើងទុកស្ទុះឈប់ទិទាន នឹងថ្វាថ្ងៃងដោយដាន
ក្រុងក្រុឌត្រុងតែវកាក៏ ៗ ស្នេហ៍ស្នងស្នេហ៍ស្នាលស្និទ្ធ ចូលចាប់ចិត្តបង
បែគី ចំណង់សោមេត្រី សិងសោមនស្សទាំងទ្វេហា ៗ

◎ បទព្រទង់កុជង្គលីលា ដំណើរពណ៌នា ត្រុឌនឹងកាក៏ ៗ សេព
សមបន្ទំលើទី លុះព្រះសូរ្យសី បាត់បង់ផ្រុងក្នុ ៗ បក្សីតើនពីបន្ទំ
លោមនាងឧត្តម ត្រេកត្រាស់ទៅថា ៗ ប្អូនមាសវរកំសោភា បង
នឹងយាត្រា នាំប្អូនទៅ ៗ លេងដោយផ្រុងព្រោយព្រៃព្រៅ មើល
ក្នុំហើយទៅ ស្រះស្រង់ផលសៃ ៗ ត្រាស់ស្រេចទើបស្តេចវេនតែយ
បីបមស្រីថ្ងៃ ចរចេញចាកទី ៗ ហើរហោះចំពោះគិរី សូមេរុជាទី
កំសាន្តទ័យា ៗ រៀបរាប់ប្រាយប្រាប់ទៅថា ប្អូនអើយបព្វតា សូមេរុ

វង្កួល ៗ នាងអើយនេះហើយកំពូល ខ្ពង់ខ្ពស់បណ្តូល បណ្តាប់គួរ
ស្រែង ៗ ត្រសេតអណ្តែតឯកឯង ត្រដួចបញ្ចែង បញ្ចាំងសឹងមណី ៗ
បព្វតាថ្ងៃថ្វារង្សី ដូចសែងសូរិយ៍ សន្ធោសន្ធៅ ៗ ថ្មទឹមថ្មាព្រាលផ្គៅ
ព្រាលផ្គួនតាប់នៅ តាប់ទឹងថ្មទឹល ៗ មណីរតន៍សសុទ្ធស្រស់ស្រិល
ពព្រាតពព្រិល ប្រពាឡរតន៍កាយ ៗ ថ្មពេជ្រឆ្នុះលេចពិតាយ ពៃទូរ្យ
ពណ្ណកាយ ពព្រាកបុប្ផុស្ស ៗ សត្តរតន៍នព្វរតន៍ស្រិលស្រស់ ភ្លឺផ្ទេក
ទាំងអស់ ទាំងឯមុក្តា ៗ ស្វាយព្រាលពពាលសថ្វា លៀងអនរតនា
បៃតងខៀវខ្ចៅ ៗ ព្រាតប្រុះផ្ទាស់ឆ្ពុះឆ្អិនឆ្អៅ ឆ្អឹនឆ្អិតសន្ធៅ សន្ធោរស្មើ ៗ
ទតស្រេចទើបស្តេចបក្សី ហិចហើរហោះខ្ញី ដល់សត្តបរិភណ្ឌ ៗ ព្រាប់
ឲ្យមើលដោយក្តុំខណ្ឌ ទាំងប្រាំពីរជាន់ ស្បូមេរុពជ ៗ ប្អូនភ្ជាមើលក៏
ត្រដាច ត្រដឹងគួរខ្លាច ស្តិមស្តែបវរ ៗ ចន្លោះត្រង់ណោះសាគរ ឈ្មោះ
សីទន្តរ តាក់ជ្រោពេកក្រៃ ៗ ទឹកល្អិតហៅឥតសរសៃ ធ្លាក់អ្វីដល់ញ
ទឹកសឹងលិចលង់ ៗ ព្រាយព្រាប់ស្រេចស្រាប់ពអង្គ កាក់ទៅត្រង់
សមុទ្រផលសៃ ៗ ដល់ស្រេចទើបស្តេចវេនតៃយ បង្ហាញទៅញ
សមុទ្រគង្គា ៗ ប្អូនពៅនេះហៅផលសា ឈ្មោះលោណមហា សមុទ្រ
ទឹកប្រៃ ៗ ធំឆ្ងាយទូលាយពេកក្រៃ ប្អូនអើយរំពៃ មើលមានមច្ឆា ៗ
ធំ ៗ នោះសមកនក់ តូច ៗ ហ្វូងកា ក្រាស់ក្រៃកកូង ៗ ឯធំប៉ុនភ្នំដាម្តង
កៀងគ្នាក្រសង ហែបហែលដេញគ្នា ៗ ប្រែប្រឹងសំឡឹងរេក លេច

លើគង្គា មើលហាក់ត្រើយត្រាន ។ សន្ធឹកដំទឹកប្រឹងប្រាណ ហែបហែល
លលាន លលេលលាំ ។ ខ្វះសោតលោលោតទៅពាំ ចំណីទន្ទ្រាំ ទន្ទេង
ទៅមក ។ ខ្នារខ្នរខ្វាយខ្វរលេក មច្ឆាតូចជ្រែក ខ្វបខ្វាចប្រួញប្រាណ ។
ប្អូនមាសវាសមើលមាន ទ្វីបបួនជាស្ថាន មនុស្សលោកនៅនិត្យ ។ ទ្វីប
នោះមានកោះប្រកិត ពីរពាន់ដុះជិត ជាតិជាបរិវារ ។ ប្រាប់គ្រប់សាយ
សព្វប្រការ ស្រេចនាំនាងនាថ ទៅភ្នំហេមពាន្ត ។ ដល់ហើយគ្រុឌធ្ងើយ
ប្រាប់ថ្កាន ហៃប្អូនកល្យាណ មាសមើលគិរី ។ ហេមពាន្តជាស្ថានទួលទី
មើលអ៊ីប្អូនស្រី ធារធំស្កឹមស្កៃ ។ ប្អូនពៅមើលទៅនាព្រៃ ជាជួរល្អក្រៃ
ឥតឯគណនា ។ មើលមានជាស្ថានគុហា ស្រះស្រង់គង្គា ឈ្មោះអនោ-
តាត្ត ។ ទឹកស្រះថ្លាជ្រះជ្រៅស្អាត ក្នុងនោះគ្មានជាតិ ត្រែងចកឈើ
ស្មៅ(១) ។ ហូរបែកបួនបែកវិលនៅ បីជុំហួសទៅ តាំងបួនទិសទី ។ វេន-
តៃយពនៃនារី ចុះស្រង់ស្រះស្រី ក្រសាលសប្បាយ ។ និរទុក្ខជា
សុខស្កល់កាយ កាកីធោមធាយ ក្សេមក្សាន្តទ័យា ។ ស្រង់ស្រេច
ទើបស្តេចបក្សា បីបមកែវកា- កីកាយកល្យាណ ។ ប្រាប់ឲ្យមើលដោយ
ភ្នំមាន ព្រៃព្រះហេមពាន្ត ច្រើនក្រៃគណនា ។ ដុះជិតប្រកិតវៀងគ្នា
រៀបរាយជួររ៉ា ផ្លែផ្កាយោនយោង ។ ក្រអែបក្លិនក្លែបសព្វឋាន
ក្រអូបផលមាន រសរែងពីសា ។ មាសថ្លៃពៅមើលអ៊ី អុញ

---

● ព្យាប់ខ្វះដា ត្រឹចកឈើស្មៅ ។

ហ៊្សុសត្វក៏ កៀងគូរឈ្មោលញី ៗ ដូចបងត្រកងប្អូនស្រី នៃបរនៅឥន្ទ្រីយ
ពុំឲ្យឃ្លាតឃ្លា ៗ ប្អូនគន់គួរគន់ពញ ពញាក់រោក រោកទំនៅ ៗ ប្អូន
ភ្នាមើលកំប៉ោ ចចាតហើរទៅ ហើរទាបហើយយំ ៗ មាសស្ទៅ
មើលឯស្រគំ ស្រកា(១) ហើរទំ ហើរទៅខ្ទប់ខ្ទាំង ៗ ប្អូនអើយនោះហើយ
ក្រសាំង ក្រសាសំកាំង សំកុលកន្ទុយ ៗ ប្អូនមាសរាំងសមើលគុយ
មើលគូកហើរព្រុយ ហើរព្រាតរៀងកាយ ៗ ប្អូនពៅមើលទៅប្រពាយ
ប្រពេចប្រញាយ ប្រញាប់ទំផ្កាស ៗ ប្អូនថ្ងៃពៃមើលទាស មើល
ទៀវទំជ្រាស ជៀវជ្រើមជប់ជ្រក ៗ ប្អូនគន់គួរគន់មើលធ្លក មើល
ថ្នុំហើរមក ហើរមើរិលរង់ ៗ ទេវីស្រស់ស្រីមើលខ្ទុង មើលខ្វែងរេង
រោសទន្សែម ៗ ស្រីស្រស់មើលអស់ទទិម ទទាទំផ្លឹម ទំផ្លុំប់គ្វក់ ៗ
ស្រីស្រស់មើលអស់ម្រឹគា ម្រឹគីនានា ច្រើនណាស់ក្រាស់ក្រៃ ៗ សី-
ហាក្ងៀវក្លានិភ័យ និរកិតជាញជ័យ នៅទីងសីហោ ៗ សិង្ហសេះគជ
កៃះគោតគោ លៀងកាខ្លាគោ កៀរគាល់ឈ្មោលញី ៗ នរសិង្ហនៅ
ទីងនរសីហ៍ មាសមើលតាមរី នៅទីងតាមក ៗ រេនតៃយពហ៍នៃជាយា
ទតសព្វបព្វតា ដលសៃព្រៃស្ពាន ៗ ហើយហោះហាក់ព្យុះលុះបាន
ដល់ទីពិមាន សិម្ពលីព្រឹក្សព្រៃ ៗ គ្រុឌសុខនិទ្ទុក្ខភោកក្រៃ កាកម្យូល
មៃ-ត្រីត្រកបិន្ទា ៗ

---

(១) ដែរត្រូវហៅថា សាលិកា តែក្នុងទីនេះ ដើម្បីឲ្យស្រាត់ភ្លូនឹងពាក្យខាងដើមផង ៗ

១ បទព្រហ្មគីតគន់ កាលសុបណ្ណពជបក្សា នឹងកាកីជាយា
រួមភិរម្យសុខសម្រាន ៗ លុះគ្រប់សត្តទិវា ក្រុងគ្រុឌាគន់គិតឈ្យាន
ថាកាលអញលួចបាន កែវកាកីមកស្នេហា ៗ បានប្រាំពីរថ្ងៃគត់
បួបកំណត់ទៅលេងស្កា បើអញពុំយាត្រា សមគេគន់គិតសង្ស័យ ៗ
គិតស្រេចលួងលោមថា ហៃកែវកាកីថ្ងើមថ្ងៃ ឥឡូវបួបប្អូនថ្ងៃ
បងតែងតែទៅលេងស្កា ៗ ចូរនាងនៅណាហៅ បងហោទៅតែពេលា
រសៀលព្រះសុរិយា នោះបងមកបងមិនខាន ៗ កាកីស្តាប់គ្រុឌា
ទើបវន្ទាទៀងទូលថ្កាន ថាបពិត្រព្រះមាន គុណគួរគន់គិតប្រណី ៗ
កាកីនៅកន្ទុង តែឯកឯងអង្គជាស្រី ធ្លាប់មានព្រះបក្រី
គ្រាន់ជាពីរនាក់ទិត្យនៅ ៗ មិនគប្បីឃ្លាឃ្លាត ពីព្រះបាទព្រះបងទៅ
ប្អូនអន់ប្អូនអួលក្តៅ ក្រប្រយ័ត្នប្រយោជន៍ប្រាណ ៗ ប្អូនខ្លាចអស់ខ្មោចព្រៃ
ស្តេរស្តិតព្វទូវទីស្ថាន ទាំងយក្សយង់សាមាន្យ ពិទ្យាធរវីងឫទ្ធិរុង ៗ
មានឫទ្ធិមានជយោ ពាលពលោពាលាពង្ស ពុះពាពះពើបអង្គ
ខ្ញុំម្ចាស់អើយមករួមស្ថាន ៗ ខ្លាចខ្លួនជាតិជាស្រី គប្បីតើម្តេចបាន
បើគេមករួមស្ថាន សមកាកីរឹងដូរកែ ៗ ប្រុសមួយពីរពោលបង់
មករួមអង្គប្រុសដទៃ ពីរអង្គពុំប្រពៃ ម្តេចថែមប្រុសមួយទៀតផង ៗ
ជាបីប្រាណប្រុសគត់ ខុសកំណត់ច្បាប់កន្លង ដូច្នេះសូមព្រះបង
ព្រះបាទកុំចរលីលា ៗ នាងទូលនាងទួញយំ ក្រាបប្រណម្យប្រទៀលនា

ព្រះបាទព្រះបក្សា សោកឥតអាក់ឥតឯស្បើយ ។ គ្រុឌស្ដាប់អស់សំដី លោមទេវីឲ្យល្ហៃល្ហើយ ទុក្ខទៀងទើបធ្ងាស់ធ្ងើយ កាន់កែវកេ ភីថ្មើមថ្ងៃ ។ ប្អូនអើយបើបងពុំ លីលាសមគេគិតខ្នៃ ថាបងលួចប្អូនថ្ងៃ ត្រកាលកាយមកស្នេហ៍ស្នង ៖ បងទៅមាសកុំគិត កុំព្រួយចិត្តណាមាសបង បងបេះអាគមចង ទ្វារប្រាសាទជាប់ក្ដាំងក្ដាត់ ។ ទោះទាំងទេពទេវា យក្សពិទ្យាធរសិល្បសិទ្ធ អាក្ខោខ្មោបរិងឫទ្ធ ពុំទម្លុះទម្លាយបាន ។ នាងទៅណានាងណា កុំសោកាឡើយកល្យាណ កុំទល់ទុក្ខពុំក្សាន្ត កុំអាលោះអាល័យឡើយ ។ បងទៅៗពុំយូរ តែព្រះសុរិយាល្ងាចហើយ បងវិលមកម៉ាសអើយ ចូរនាងទៅណាទាងណា ។ ប្រាប់ហើយគ្រុឌត្រកងលោមស្នេហ៍ស្នងស្រេចយាត្រា ដល់ក្រៅទ្វារប្រាង្គណ៍ប្រា- សាទសេពបងទ្វារជាប់ក្ដាត់ ។ ហើយប្រែប្រាណវិញជា គ្រុឌបក្សាសហាស័ឫទ្ធិស្ទុះចេញពីស្ថានស្ថិត ហៀរហោះហាហួសដួចដល់ ។ ដើមជ្រៃហើយចូលចាប់ ប្រែក្រឡាប់កាយឲ្យយល់ ជាមាណពដូចកល ដូចកាលមុននៅនាជ្រៃ ។ ក្រុងគ្រុឌប្រែកាឡា ស្រេចយាត្រាឆ្ពោះទៅឮ ប្រា-សាទមហាក្សត្រថ្ងៃ ដល់ស្រេចហើយចរបូលថ្កាន ។ ឯអគ្គមហាក្សត្រាយល់គ្រុឌាទើបស្ដេចមាន ព្រះស្បូរបន្ទូលថ្កាន ទឹងក្រងគ្រុឌសោះសង្ស័យ ។ តែក្នុងព្រះទ័យ ក្រេវក្រោធាពន់ពេកក្រៃ គ្រុឌសោតសិងសង្ស័យ ទឹកអៀសអគ្គអាត្មា ។ ព្រះបាទព្រហ្មទត្ត ស្ដេចទ្រង់អត់

ព្រះក្រោធា ហើយត្រាស់ឲ្យយកស្កា មកក្រសាលដូចសព្វដង ៗ លន់
លុះព្រះសុរិយេ ទន់ទាបជ្រេគ្រុឌទ្រើសឃ្នង ទឹកកាកីកន្ទុង ហើយលុត
លាព្រះបមពៅ ៗ យាត្រាត្រង់ព្រៃជ្រៃ គន្ធនៃវៀងសំដៅ លបលាក់
ដើរតាមទៅ មើលដំណើរនៃគ្រុឌា ៗ ដើរដល់ដើមព្រៃជ្រៃ ប្រែប្រាណ
វិលវិញជា ក្រុងគ្រុឌកងបក្សា គន្ធនសោតនិម្មិតអង្គ ៗ ជាស្រមើលទំ
នា ពេមគ្រុឌាគ្រុឌឫទ្ធិរុង សុះហោះហើរពុំផ្សង សំដៅដល់ដើមសិម្ពលី ៗ
ក្រុងគ្រុឌពុំដឹងខ្លួន គន្ធនពួនលើស្ទ្រិយ ឃ្លាតតែហៀរហោះខ្វី លុះ
មណ្ឌលមន្ទីរស្ថាន ដល់ស្រេចគ្រុឌគិតគន់ ស្រាយនូវមន្តបង្ខារបាន
ហើយចរចូលទៅឋាន កែវកាកីស្រីសោភា ៗ បក្សាសោកស្នេហ៍ស្នាល
នាងត្រអាលទឹងគ្រុឌា សេពសុខសោតនិទ្រា ទាំងពីរពិតឥតអំពល់ ៗ

១ បទកាកគតី រឿងរ៉ុងរង្សី សែងសុរិយោយល់ បំព្រាងស្វាង
ជ្រះ ស្រលះមណ្ឌល គ្រុឌទឹងនិរមល តើនពីបន្ទំ ៗ សំណោះសំណាល
ក្រុងគ្រុឌត្រអាល លានាងឧត្តម ទឹងចរចេញទៅ រកនូវអស់ចំ-ណី
នៅព្រៃភ្នំ ព្រឹក្សាស្រះស្រី ៗ គ្រុឌលានាងកា-កីចេញដល់ទ្វារ សេព
មន្តតាប់ខ្ចី បង្ខារស្រេចហោះ ផ្លេកផ្លោះទន្ទី ដូចដល់ទួលទី ព្រៃព្រះ
ហេមពាន្ត ៗ កាលក្រោយគ្រុឌទៅ គន្ធនោះនៅ ឯក្រោយប្រែប្រាណ
ជាគន្ធព្វា នាងកាកីបាន យល់គន្ធនទពន រូតរូសមកដល់ ៗ នាងទឹក
ថៃថា នេះសមព្រះមហា ក្សត្រក្សាន្តថ្កើងថ្កល់ ប្រើមករកអញ គួរ

អញធ្វើកល ឲ្យគន្ធ័នយល់ ជាអញព្រួយចិត្ត ៗ គិតស្រេចនាងថា ឱះឱ ក័ព្វជា ថ្ងៃនេះពេកក្តាត់ ជួបបងគន្ធ័ន ប្អូនគ្រាន់ស្បើយចិត្ត បងអើយ ចក្រវត្តិ ម៉េះទុក្ខកន្ទួង ៗ បងអើយបងស្ងួះ បងរៃស្នួងរូតរះ ស្រែកប្អូនហោង បងមកឯងប្ត ស្តេចប្រើប្រាណបង បងជឹងទំនង ឬគេប្រាប់ប្រាយ ៗ គន្ធ័នឆ្លើយថា ខ្ញុំបាទលីលា លួចមកពីនាយ មិនមានគេដឹង ដំណឹង សព្វសាយ ខ្ញុំនិម្មិតកាយ ដែកកោមគ្រុឌា ៗ ឯមហាក្សត្រថ្ងៃ ពុំ ព្រួយព្រះទ័យ នឹងអ្នកទេណា ខ្ញុំបាទអាណិត មានចិត្តមេត្តា ខែង ខំយាត្រា មកមិនគិតក្រែង ៗ ជាហេតុបុណ្យខ្ញុំ បាទបានសាងសុំ អំ-ពីព្រឹទ្ធព្រេង នាំមកពេបពះ ប្រទះអ្នកឯង អណោសត់តថ្លែង ឥត បើថ្លែងបាន ៗ នាងស្តាប់ពាក្យកៀស ពាក្យកលបញ្ចៀស បញ្ចូលចង់ ប្រាណ ថាតាសអរហោង ដោយបងគិតធ្យាន សមបុណ្យបុរាណ មែន ពិតកន្ទួង ៗ បានបងឯងក្បូរ គ្រាន់បានជាផ្លូវ នាំអាចិទំនង ទៅទូលក្សត្រា ដោយនាហេតុផង សមអានឹងបង នឹងបានគុណគាប់ ៗ នាងធ្វើជាស្មោះ គន្ធ័នព្រួញបោះ វៃវងឆ្លើយឆាប់ សង្វាតតាមមក ស្រែកសើរស្ងាប់ ស្រាប់ តែក្រឡាប់ គ្មានគុណសោះសា ៗ សង្ឃឹមបានដល់ ទឹងបានដូចកល ដូចចិត្តប្រាថ្នា ឥឡូវអ្នកបេះ វិលវៀះវងថា ឲ្យមហាក្សត្រា សងគុណឯ នាយ ៗ ឯអ្នកបុណ្យស្ពល់ ទៀងទើបពុំយល់ គុណគេខ្វល់ខ្វាយ សង្វាត តាមដិត ពុំគិតក្រងាយ គួរអ្នកនៅអាយ ជឹងគុណាតិចរ៉ា ៗ នាងស្តាប់

ពាក្យកើច ឲនអស់សំណើច សំណោះថ្លែងថា ឲឯប្អូនស្រី មានអ្វីថ្លៃថ្លា ឲ្យគាប់គួរជា ស្ហាន់បងមក ៗ គន្ធ័នឆ្លើយឆ្លៀត ឆ្លើយឆ្លាសទៅទៀត អញណែមើលហ្ន៊ តែធនធានគ្មាន គង់មានទ្រព្យល្អ អ្នកពុំនឹករ ឲ្យឯងពុំជា ៗ ទើបនាងឆ្លើយថ្កាន បងអើយប្អូនមាន តែខ្លួនទេណា នឹងនៅជាខ្ញុំ ក្រែងពុំប្រាថ្នា ហេតុនោះបានជា ប្អូនថាពុំមាន ៗ គន្ធ័នសើចសង ញញឹមឆ្លើយស្នង ថាបាទសូមទាន តែត្រង់ណោះឯង គិតក្រែងបើបាន អរលើសធនធាន អ្វី ៗ ជាម្តង ៗ នាងឆ្លើយដោយស្មោះ ថាបើប៉ុណ្ណោះ បានទេណាបង ប្អូនខ្លាចបងចង់ បានត្រង់ទ្រព្យផង នោះនឹងរកសង្ឃ គុណគាប់ក្រែក្រី ៗ គន្ធ័នឮឈ្មោះ ព្រួចចិត្តចាប់ពោះ ចាប់ចងមេត្រី ខិតខាងចូលជិត នែបនិត្យកាយី ឱបអង្គកាកី មេបមួលថើបថៃ ៗ នាងព្រួចព្រើសចិត្ត ចងចាប់ប្រតិព័ទ្ធ គឺមោះប៉ុន្តែ ការកេរ្តិ៍ខ្មាសស្រី ថាយ៉ាមើលនៃ អញពុំស្និទ្ធស្នេហ៍ ប្រុសអ្វីដូច្នោះ ៗ អញស្មានជាស្មោះ ថាទៅប៉ុណ្ណោះ ស្រាប់តែវិលវេះ ប្រលោមប្រលែងអញឯងអញទេ ហ៊ានប្រួសម្តេចម្ល៉េះ អញពុំដែលយល់ ៗ មាត់តែជជែកប្រកួតប្រកែក ដោយមាយាកល ឯប្រាណប្រុសព្រម ល្មក់ល្មមមណ្ឌល ពុំគិតអំពល់ អំពើក្រែងក្រ ៗ គន្ធ័នអរក្តាត់ យល់នាងចូលចិត្តប្រែប្រាណប្រែប្រ— លោមល្ងង់កាកី មេត្រីត្រេកត្រ— កងកប៉ប-ប្រាសបានថើបថៃ ៗ កកៀកកាន់ជន[១] នានែបបានប— ទុំទិមមួល

---

១ ឋិន ម. (សំ. ស្តន) ដោះ ។

មេ — ជុនជម្ពូត្រែកត្រែ — កាលក៏ស្និទ្ធស្នេ — ហាហើយឥតឯ មោះ
មានសង្កា ៗ គន្ធ័នស្នេហ៍ស្និទ្ធ កាកីបាប់ចិត្ត ភគសេតណ្ហា គន្ធ័ន
ក្សេមក្សាន្ត ពុំមានភ័យា នាងក្មេចគ្រុឡា សង្ក្រាប្ដោងថ្មី ៗ រួមរស
កាមេ លុះព្រះសុរិយា ជុតជុំងគិរី គន្ធ័នរះឈ្មាន ប្រែប្រាណ
វិន្ទ្ទ លបលាក់ឥន្ទ្រិយ ខូបខ្ចាបប្រញ្ញប្រាណ ៗ ឯក្រុងគ្រុឡា បេះ
បានផលា ហើយវិលវិញថ្កាន ប្រាសាទមណ្ឌល តែដល់ព្រឹកឈ្មាន ទៅ
ទៀតពុំលង់ លុះដល់មួយថ្ងៃ ៗ ពុំដឹងគន្ធព្វ មកម៉ែត្រសម្គត ទីងទាង
នាងញ ប្រាសាទមណ្ឌល លុះដល់ចូបថ្ងៃ ប្រាំពីរវេនតែយ លានាង
កល្យាណ ៗ ទីងទៅលេងស្កា ស្រេចគ្រុឡលីលា ចរចេញចាក
ស្ថាន គន្ធ័នដឹងជាក់ លបលាក់ប្រញ្ញប្រាណ ប្រញ្ញប្រែបចូលបាន ជិត
រង្គគ្រុឡា ៗ ទំផ្កាប់គ្រុឡហើយ គ្រុឡហោះព្រងើយ ដល់ដើមព្រឹក្សា
និគ្រោធគ្រុឡប្លែង អង្គឯងចេញជា មាណពហើយយា — ត្រាត្រាច់ត្រង់
ញ ៗ ចុងពេងម្សៀតន៍ ព្រះបាទព្រហ្មទត្ត យល់ក្រុងវេនតែយ ត្រាស់
ហៅលេងស្កា ទីងមហាក្សត្រថ្ងៃ លង់លុះដល់ថ្ងៃ សៀលសុរិយា ៗ

១ បទអង្គកូដង្គលីលា គ្រុឡលាក្សត្រា ចុះចរឆាប់ក្រែ ៗ ដូច
ដល់មណ្ឌលព្រះថ្ងៃ ហិចហើរវិលវៃ ដូចដល់ពិមាន ៗ ក្រោយ
គ្រុឡលាផុតទៅថ្កាន ព្រះមហាក្សត្រក្សាន្ត យល់គន្ធព្វ ៗ ដល់
ស្រេចទើបស្ដេចត្រាស់ថា បងចរលើលា ទៅរកកាកី ៗ ញុំាង

ដឹងដំណឹងប្ដី គន្ធីនទូលខ្ញុំ ថាទូលព្រះបង្គំ ។ ស្វែងសុះលាក
លះដំបន់ ទៅឃើញនាម- ណ្ឌលទាល់សិម្ពលី ។ សត្វគ្រុឌពាំម្រែត
ក្សត្រី ទៅសេពវៃគី រួមសេមណ្ឌល ។ ទូលបង្គំនាំមើលគល
ឯអ្នកនាងយល់ ដណ្ដឹងមកខ្ញុំ ។ ទូលបង្គំប្រុងស្រដី បន្ទូលសេច.
ក្ដី ចង់ដឹងកិរិយា ។ ជាទុក្ខប្ដីសុខម្ដេចម្ដា គិតមហាក្សត្រា ប្ដី
សោះសូន្យហើយ ។ ឃើញជាក់ជាអ្នកក្ដើយ ពុំគិតសោកឡើយ
ពាព្រឹមពព្រាយ ។ ចូលជិតហាក់ស្និទ្ធនិយាយ ផ្ដើកលអាយនាយ
នឹងទូលបង្គំ ។ យល់ប្លែកចំឡែកលែបលន់ ពាលើសខ្នាតស៊ិន ពុំ
គោតពុំក្រែង ។ ឲ្យការបរបាចាយបែង ទូលបង្គំស្វែង ក្នុងចិត្ត
ថាឃើ ។ អ្នកនេះដល់ម៉ោះមិញតើ ឯងម៉ោះថាបើ វិលមកប៉ុរី ។
ទំនងជាល្អងធូលី ព្រះបាទពុំភី រម្យរួមស្នេហ៍ស្នង ។ ដ្បិតគ្រុឌ
ពាំម្រែត់ទៅគ្រង រួមសេកទ្វង ជាពីរអង្គហើយ ។ ហើយចប្រាប់
ទម្លាប់មុនឡើយ មហេសីត្រាណត្រើយ ពុំដែលដូច្នេះ ។ គិតយល់
ដូចកលទូលនេះ បានជាហ៊ានម៉ោះ លលែងទាល់ស៊ិន ។ ពុំបាន
ទូលថ្កានជាមុន ផល់ស៊ិនក្រលុន ពុំបេប្រោសប្រាណ ។ ព្រះបាទ
នរនាថក្សត្រក្សាន្ដ ស្ដាប់គន្ធីនបាន ទូលទើបក្សត្រថៃ ។ ត្រាស់
កាន់គន្ធីនថាហៃ បងកុំសង្ស័យ កុំគិតភ័យា ។ អញគិតពុំយកទោសា
កុំបីបងបា- រម្ភរះខ្វាចឡើយ ។ សោកថ្វីមេស្រែកត្រើយ ពាម៉ោះ

អស់ហើយ នរណាទឹងកប់ ៗ លើបឹងឯងហោងបងស្រាប់ អញ
ពុំក្រឡាប់ យកគុណជាទោស ៗ ម្តេចៗ គង់គេបោលប្រោស
ប្រែងប្រែសន្តោស ពុំគិតល្មោះល្មេះ ៗ ខឹងថ្វីសេចក្តីប៉ុណ្ណេះ ទោះ
លើសពីនេះ អញក៏ពុំខឹង ៗ បូរបងត្រិះត្រងដញ្ញឹង ធ្វើកលម្តេចនឹង
បានមកវិញណា ៗ កុំឲ្យដូចដោយចិត្តា ពង្រាត់ពីគ្នា គ្រាន់
មើលមុខលេង ៗ គន្ធីនស្រែកទូលថ្លែង ទូលបង្គំឈ្លោង ដោយ
កលប្រាជ្ញា ៗ យើងតាំងទម្រាំទិក ប្រាំពីរគ្រា វិលមកពុំខាន ៗ
បើកលីលាដល់ស្ថាន ទូលបង្គំធ្យាន គិតយល់ទឹងផ្សំ ៗ ចំរៀង
ច្រូចច្រៀងដេញដំ ពិណពេញពាក្យពាំ- នោលទឹកកាលគ្រង ៗ
ឲ្យជួនកាព្យកលកន្លង កន្ទួបទំនង ទំនុកទំនើប ៗ កន្ទួបពាក្យ
ពេចន៍ពីពើប ពះពាសំរើប សំរាលតណ្ហា ៗ នឹងអ្នកនាងជាក់នៅ
ខា នៃដើមកា កកកលកិច្ចកាយ ៗ បើគ្រូឧត្តមអតិប្រាយ យល់
ជាទឹងស្តាយ គំនិតគំនាប់ ៗ អន់អៀនកង្កៀនស្ម័រស្ងាប់ ហើយ
ទឹងក្រឡាប់ ទៅយកអ្នកមក ៗ ថ្វាយវិញដោយខ្ញាញ់តាល់ក
ទឹងល្មេចក្លោកយ៍ ពុំបានជាម្តង ៗ សូមទានយល់បានដូចប៉ង តាម
ដោយទំនង ហានថាជាបាន ៗ ឯក្សត្រព្រហ្មទត្តក្សេមក្សាន្ត ពុ

គន្ធ័នធ្យាន ត្រេកត្រូវព្រះទ័យ ។ ទ្រង់អរសាទរពេកក្រៃ បន្ទូល
ថាហៃ គន្ធ័នអើយបង ។ ត្រិះត្រូវត្រង់ផ្លូវទំនង គង់បានដូចប៉ង
យើងគិតប្រាថ្នា ។ ថាស្រេចទើបស្តេចលីលា ចរចូលក្រលា- បន្ទំ
សុខសាយ ។ លុះគ្រប់ជួបចប់ដល់ថ្ងៃ ប្រាំពីររវេនតៃយ លានាង
រួបហើយ ។ ស្ទុះហោះផ្លេកផ្លោះព្រាងើយ ឆ្លាស់ឆ្លងដល់ត្រើយ
ជម្ពូទ្វីបស្រេច ។ ចុះដល់មណ្ឌលដែរគេច ក្លាយមួយរំពេច ជាអង្គ
មនុស្សា ។ ដើរដល់មណ្ឌលអាសនា ស្តេចឲ្យយកស្លា លេងនឹង
សុប័ណ្ណ ។ ព្រះអង្គទតត្រង់គន្ធ័ន ក្រឡេកស្រពាន់ ជាហេតុឲ្យយល់ ។

# ហិតោបទេស ភាគទី ១

## «ការបងមិត្រ»

ឧកញ៉ាទេពពិទូរ ក្រសេម គ្ដួរបនបណ្ឌិត

ប្រែនិងរៀបរៀង (ត)

បបកជម្ពូកបានស្តាប់ក្អែកនាំទិទានមកប្រៀបធៀប ក៏ខឹង ហើយនិយាយថា “កាលប្រើសបានប្រទះស្និទ្ធស្នាលនឹងអ្នកក្នុងថ្ងៃដំបូងនោះ ក៏មិនទាន់ដឹងចិត្តដឹងនិស្ស័យគ្នានៅឡើយ ហេតុម្តេចអ្នកនឹងប្រើសទើបស្រឡាញ់ជិតដិតគ្នារៀងរបមកបាន ?”

៧១ ធម្មតាទីណា ខ្សត់អ្នកប្រាជ្ញ ទីនោះទោះមានអ្នកចេះដឹងអ្វីត្រឹមបន្តិចបន្តួច ក៏មានគេលើកគេសរសើរ (ប្រៀបដូច) ក្នុងទីដែលខ្សត់ព្រឹក្សជាតិធំ ត្រឹមតែដើមថ្ងន់រហុង ក៏ឡើងបានឈ្មោះថាជាឈើធំ ។

៧២ អ្នកនេះជាពួកយើង ឬពួកដទៃ ? នេះជាសំដីរបស់អ្នកដែលមានចិត្តចង្អៀត, សម្រាប់អ្នកចិត្តទូលាយរមែងគាន់ថា “អ្នកនៅលើពសុធាទាំងអស់ជាពួកជាមួយគ្នា” ។

កាលប្រើសនេះមកបានជាមិត្រនឹងខ្ញុំ អ្នកឯងក៏ជាមិត្រសំឡាញ់នឹងខ្ញុំដែរ” ។

ប្រើសបញ្ចប់សេចក្តីថា នឹងដដែកគ្នាទៅរកអ្វីទៀត ? សុំឲ្យយើងទាំង ៣ នៅជាសុខសមាគមជាមួយគ្នាចុះ ព្រោះ –

៧៣ អ្នកណា ក៏មិនមែនជាមិត្ររបស់អ្នកណា, អ្នកណាក៏មិនមែនជាសត្រូវរបស់អ្នកណា, ដែលនឹងកើតជាមិត្រគ្នាឡើង ឬកើតជាសត្រូវគ្នាឡើង មកពីសេចក្តីប្រព្រឹត្ត” ។

ស្អែក (ក៏គោងព្រម) ថា "បើដូច្នោះក៏តាមចិត្ត" លុះព្រឹកឡើងសត្វទាំងពីរក៏ស្វែងរកអាហារក្នុងទីដែលខ្លួនគាប់ចិត្ត រៀងខ្លួន; នាថ្ងៃមួយ ចចកនិយាយនឹងប្រើសបែបជាប្រាប់សេចក្តីអាថ៌កំបាំងថា "សំឡាញ់អើយ, ក្នុងព្រៃនេះ មួយកន្លែងនោះមានស្រែស្រូវយ៉ាងល្អ, ខ្ញុំនឹងនាំអ្នកទៅបង្ហាញ ៗ កាលចចកនាំផ្លូវដូច្នោះហើយ ប្រើសក៏ចូលទៅស៊ីស្រូវក្នុងស្រែនោះតែរាល់ថ្ងៃ; លុះកន្លងមក ២-៣ ថ្ងៃ ក្សេត្របតី (ម្ចាស់ស្រែ) មកទាន់ឃើញប្រើស ទើបធ្វើអន្ទាក់ដាក់ លុះព្រឹកឡើងប្រើសក៏ចូលទៅស៊ីស្រូវដូចសព្វដង ក៏ត្រូវអន្ទាក់ដែលគេដាក់ ទើបរំពឹងថា "អ្នកដែលនឹងជួយដោះឲ្យរួចពីអន្ទាក់នាយព្រាន ដ៏បីដូចជាអន្ទាក់ព្រះកាលនេះ ក្រៅអំពីមិត្រសំឡាញ់ គ្មានអ្នកណាជួយបាន" កាលប្រើសកំពុងរិតក្កដូច្នេះ ចចកជម្ពុកក៏ដើរចូលទៅជិតនឹកអំណរថា "អើ! ឧបាយកលរបស់យើងសម្រេចមកប៉ុណ្ណេះហើយ, សេចក្តីប្រាថ្នារបស់យើងគង់នឹងសម្រេចបរិបូណ៌; ព្រោះកាលនាយព្រានពន្លះយកសាច់ប្រើស យើងក៏នឹងបានឆ្អឹងនឹងសាច់ឈាមដែលជាប់នៅឆ្អឹងជារបស់សំណល់នោះជាប្រាកដ" ឯប្រើសកាលឃើញចចកក៏ត្រេកអរស្រែកហៅថា "ជម្ពុកសំឡាញ់! ជួយខាំបណ្តាច់អន្ទាក់នេះឲ្យខ្ញុំរួចទៅផង ព្រោះ-

៧៤ ក្នុងកាលវិបត្តិ នឹងឃើញចិត្តមិត្រ សម័យកើតសឹក
ជុំជិត នឹងឃើញចិត្តទាហាន វេលាឲ្យក្តីទ្រព្យបាន នឹង

ឃើញចិត្តអ្នកមានចិត្តស្អាតស្អន ក្នុងយាមសម្បត្តិអន្តរធាន នឹងឃើញចិត្តភរិយា ក្នុងពេលអនាថា នឹងឃើញចិត្តញាតិ ៗ

៧៥ អ្នកណាមិនលះបង់ចោលមិត្តក្នុងវេលាសុខសប្បាយ នឹងក្នុងវេលាបានទុក្ខព្រួយ ក្នុងវេលាអត់អាហារ ក្នុងវេលាចលាចល ដិតដោយតាមទៅដល់ទ្វារព្រះរាជវាំង នឹងប៉ាធា អ្នកនោះរាប់ថាជាមិត្តស្មោះ ។

ចំណែកជម្ពុកពិចារណា ទៀងធ្នងមើលអន្ទាក់សត្វគ្រប់ហើយដឹងថា ប្រើសនេះជាប់អន្ទាក់ខ្ជាប់មែនទែនហើយទើបនិយាយថា សំឡាញ់ប្រើសអើយ ! ខ្សែអន្ទាក់នេះធ្វើដោយសរសៃសត្វ ថ្ងៃនេះក៏ជាថ្ងៃកត្តារកការ ( ថ្ងៃសីល ) នឹងឲ្យខ្ញុំយកធ្មេញទៅប៉ះពាល់អន្ទាក់នោះដូចម្ដេចបាន? សំឡាញ់អើយ ! ចូរប្រឹក្សារកឧបាយយ៉ាងដទៃវិញ រឿងនេះសូមឲ្យបន្អង់ដល់ស្អែកចុះ សំឡាញ់នឹងឲ្យជួយដោយស្ថានណា ខ្ញុំនឹងចាត់ការជួយដោយស្ថាននោះ, ថាហើយក៏គេចទៅពួនចាំក្នុងគុម្ពោតឈើដែលមានព្រៃឈើស្ដើងៗ សិងនៅក្បែរនោះ ។

នឹងនិយាយអំពីក្អែក លុះវេលាល្ងាចមិនឃើញប្រើសត្រឡប់មកក៏ហើរចេញទៅតាមរក ប្រទះប្រើសត្រូវអន្ទាក់ដូចពោលហើយ ទើបចូលទៅសួរថា "អេះសំឡាញ់ ! នេះហេតុម្ដេចក៏ដូច្នេះ?

ប្រើសត្វបថា "ផលដែលមិនជឿពាក្យមិត្រ; លោកទើបថា –

៧៦ អ្នកណាមិនស្តាប់ពាក្យដាស់តឿនរបស់មិត្រ អ្នកប៉ុនប៉ងអនុគ្រោះ សេចក្តីវិបត្តិនឹង នឹងចូលមកជិតអ្នកនោះ; អ្នកនោះនឹងបានជាទីត្រេកអររបស់សត្រូវ ៗ ក្អែកសួរថា " ក៏ឥឡូវនេះចចកវាទៅណាទៅ ?"

ប្រើសត្វបថា "ឈរនៅក្នុងព្រៃស៊ីទ្រុំទ្រុះហ្ន៎! វាចាំតែស៊ីសាច់ខ្ញុំ ៗ ក្អែករំលឹកសេចក្តីក្រោយថា "សំឡាញ់! ខ្ញុំក៏បានតឿនអ្នកហើយ ព្រោះ

៧៧ (សំឡេងថា) ខ្ញុំមិនប្រាថ្នានឹងគិតអាក្រក់អ្វីឡើយ ប៉ុណ្ណោះនូវមិនទាន់មានទម្ងន់នឹងឲ្យចុះចិត្តជឿបាន; ដែរពិត ទោះបីអ្នកមានចំណេះពេញខ្លួន ក៏គង់បានទទួលទុក្ខភ័យអំពីអ្នកមានពុតព្យសន៍ជាធម្មតា ៗ

៧៨ អ្នកដែលមានអាយុដល់កំណត់មរណៈ ឥតមានធុំក្លិនទៀននៃប្រទីបដែលរលត់ ឥតឮសំដីតឿនក្រើនរបស់មិត្រ មិនឃើញផ្កាយអរុន្ធតី[១] ឡើយ ៗ

៧៩ មិត្រដែលនៅមុខសរសើរ កំបាំងមុខនិន្ទា ត្រូវតែចៀស

---

១ គេប្រែថាផ្កាយព្រឹក ៗ ផ្កាយប្រចាំកំណើតទេវតា ?

វាងឲ្យឆ្ងាយ, គេនោះទុកដូចជាឆ្នាំងថ្នាំពិស មានទឹកដោះអណ្ដែតទៅមាត់ឆ្នាំង" ។

លំដាប់នោះក្អែកដកដង្ហើមធំហើយថា អាសញ្ញាតិ អប្បលក្ខណ៍ បញ្ឆោតមិត្រឯង! កំណើតអាសត្វអាក្រក់ វាទឹងធ្វើអ្វីបាន? ព្រោះ —

៨០ ក្នុងលោកនេះ អ្នកដែលស្លាប់ចិត្តព្រោះពាក្យផ្អែមល្ហែម, អ្នកដែលធ្លាក់ទៅក្នុងអំណាច ព្រោះការលំទគលំឱន, អ្នកមកសុំពឹងដោយមានសង្ឃឹមទឹងទុកចិត្ត, អំបាលនេះ ទោះអ្នកណាក៏គង់តែគេបញ្ឆោតបាន ។

៨១ បពិត្រព្រះមេពសុធា ព្រះគុណអើយ! សត្វបាបប្រព្រឹត្តទុច្ចរិតណាមក ក្នុងអ្នកមានសន្ដានចិត្តបរិសុទ្ធ មានករុណាធ្វើឧបការៈដល់វា ដោយមិនមានសេចក្ដីសន្ទិះសង្ស័យ ម្ដេចព្រះមេទទួលទ្រទ្រង់ឲ្យវាដើរជាន់ទៅមកបាន?

៨២ ឈ្មោះថាទុជ៌ន មិនគួរអ្នកណាទឹងគប់ជាមិត្រ ឬសូម្បីតែស្និទ្ធផង; រងើកភ្លើង កាលភ្លើងនៅមាន ត្រូវដៃក៏ក្ដៅពង, រលត់ហើយត្រូវដៃក៏ប្រឡាក់ខ្មៅ ។

និស្ស័យទុជ៌ន :

៨៣ ធ្វើកិរិយាលំឱនលំទុនទៀបបាទជើងពីខាងមុខក្រឡាស់ មកខាំសាច់ពីខាងក្រោយ , និយាយពីរោះផ្អែមល្ហែម តែបានឱកាសក៏សំពងថែមភ្លាម ឥតមានទប់ចិត្ត ប្រៀបដូចកន្ទួបអាល រមែងឲ្យទោសគ្រប់ជ្រុង ។

៨៤ មួយទៀត ទុជ៌នច្រើននិយាយផ្អែមល្ហែម តែខនោះមិនជាមូលល្មមឲ្យចុះចិត្តជឿតែម្តង (គឺ) គេមានទឹកឃ្មុំជាប់នៅចុងអណ្តាត មានទឹកពិសកំណាបត្រាំនៅក្នុងដួងចិត្ត ។

# ធម្មទេសនា

## របស់ព្រះមហាហួត វត្តលង្កា ជា

## បម្រើព្រះសិរីសម្មតិវង្ស ចាងហ្វាងសាលាបាលីបរិយត្តិជាន់ខ្ពស់

## សំដែងនៅកណ្ដាលទីសន្និបាត ក្នុងខែត្រស្វាយរៀង

*កាលនៅថ្ងៃ ២៨ យូពាំងដល់ ១០ សូមេត*

*ឆ្នាំ ១៩៣៨*

# របៀបធម៌ទេសនា

ដែលពជការលោកកុងស៊ុយសេនាបតីបានចាត់ឲ្យទៅសំដែងក្នុងទីប្រ-ជុំ ១៣ កន្លែង ក្នុងខែត្រស្វាយរៀង ។

តាំងពីថ្ងៃទី ២៨ យូកាំងដល់ថ្ងៃ ១០ សូយេត ឆ្នាំ ១៩៣៨ :

១) សំដែងពីកំណើតសាសនា (ពាក្យប្រៀនប្រដៅ) ដែលកើតឡើងក្នុងលោកនេះ មានគតិជាពីរយ៉ាងគឺ :

ក) កើតឡើងដោយគំនិតរបស់អ្នកដែលតាំងផ្ដើមនោះប្រាថ្នាកសេចក្ដីសុខឲ្យដល់មនុស្សជាតិដូចគ្នា ។ ព្រោះថាពួកមនុស្សនេះ ទោះជាគ្មានស្នែងស្រួចដូចគោ-ក្របី, គ្មានក្រចកចង្កូមមុតដូចខ្លា ឬខ្លាំងដូចដំរីទឹងរមាស, គ្មានពិសកំណាចកាចដូចពស់ គឺថាគ្មានវត្ថុអ្វីដែលពូកែគួរខ្លាចនៅជាប់នឹងកាយក៏ពិតមែន តែមនុស្សនេះមានពុតកំណាចអាក្រក់លើសពីពិសកំណាចទៅទៀត ។ នៅកណ្ដាលពួកមនុស្សឥតធម៌ឥតច្បាប់ បានទុក្ខលំបាកអាចដល់ស្លាប់ លើសពីការនៅកណ្ដាលហ្វូងខ្លា-ដំរីឬសត្វសាហាវដទៃទៅទៀត ។ ហេតុនោះបានជាមានអ្នកប្រាជ្ញមួយៗ គិតស្វែងរកឧបាយនឹងដឹកនាំមនុស្សឲ្យបានសុខ ទូន្មានប្រៀនប្រដៅបង្កើតឡើងជាច្បាប់នាំឲ្យមនុស្សកាន់តាម ហាមមិនឲ្យធ្វើអំពើអាក្រក់ដល់គ្នីគ្នា ឲ្យខំប្រព្រឹត្តល្អដល់គ្នាទៅវិញទៅមក ។ មានមនុស្សជឿនិយមកាន់តាមច្រើនឡើង ៗ ពាក្យប្រៀនប្រដៅនេះហៅថាសាសនា ។ សាសនា

យ៉ាងនេះឈ្មោះថាកើតឡើងដោយគំនិតដើមល្អៗតែគំនិតអ្នកតាំងសាសនាមួយៗនោះផ្សេងគ្នាដោយប្រាជ្ញា គឺអ្នកណាមានប្រាជ្ញាតិច ក៏តែសេចក្តីសុខមកឲ្យនានាមនុស្សបានតិច អ្នកមានប្រាជ្ញាច្រើន ក៏តែសេចក្តីសុខប្រាប់មនុស្សបានច្រើនៗ ហេតុនោះគួរជឿថាសាសនាមួយៗក្នុងពួកនេះ សុទ្ធតែមានល្អគ្រប់តែសាសនា ចាញ់ឈ្នះគ្នាតែត្រង់ល្អតិច-ច្រើនជាងគ្នាប៉ុណ្ណោះៗ

ខ) សាសនាមួយបែបទៀត កើតឡើងដោយគំនិតអ្នកតាំងមិនបរិសុទ្ធ ប្រាជ្ញានឹងយកសាសនាជាកំឡាំងហើយធ្វើអំពើអាក្រក់អ្វីមួយ ឬដើម្បីនឹងចិញ្ចឹមជីវិតក៏សឹងមាន ព្រោះគេឃើញថាមនុស្សដែលមានគំនិតតិច រមែងលោភច្រើន ហើយច្រើនជឿប្រកាន់ផ្សេងៗ គេក៏ឧបាយអ្វីផ្សេងៗ មកជម្រាបឲ្យត្រូវនឹងអ្នកត្រូវការនោះ ហើយទើបគេគិតទាញយកប្រយោជន៍អំពីអ្នកជឿប្រកាន់តាមនោះ សាសនានេះឈ្មោះថាកើតដោយគំនិតអាក្រក់ៗ

ក្រៅអំពីសាសនាតាំងពីរខាងលើនេះ នៅមានសាសនាមួយបែបទៀត សន្និដ្ឋានថា កើតឡើងដោយគំនិតមនុស្សទើកស្រមៃស្មានយកច្រើនប្រឌិតយករបស់ដែលចាប់មិនបាន ស្មានមិនត្រូវ ដូចឃើញអ្វី ឬឮអ្វីប្លែកសម្បើម ក៏ស្មានថាប្រហែលជាមានអ្វីវិសេសអស្ចារ្យនៅក្នុងទី

នោះ ៗ ហើយក៏បបួលគ្នាគោរពបូជា ក៏កើតឡើងជាសាសនាមួយឡើងទៀត ៗ

ន័យមួយទៀត សម្បីសាសនាដែលកើតឡើងដោយគំនិតអ្នកដើមល្អនោះសោត អាចក្លាយទៅជាអាក្រក់វិញក៏សឹងមាន ព្រោះក្លាយដោយគំនិតរបស់ពួកសាវក គឺអ្នកដែលទទួលកាន់ការត ៗ មកនោះ យល់សេចក្ដីមិនដល់ ទើងយល់សេចក្ដីហួស ឬដែកកោនសាសនាតែខ្លួន ចំណែកចិត្តនោះនៅតែមិនលះបង់សេចក្ដីអាក្រក់ គិតយកសុខចំពោះខ្លួន ប្រែនជាងសុខធំ ជាសុខសាធារណ៍ដល់អ្នកដទៃ ដែលនាំឲ្យចំរើនដល់ជាតិប្រទេសជាដើម ជាការឃ្លៀងឃ្លាតអំពីបំណងរបស់អ្នកមុនដំបូងបំផុត ៗ ហេតុនោះគួរយល់ថាការកាន់សាសនាមួយ ៗនោះ មិនមែនសុទ្ធតែបានសុខទាំងអស់នោះទេ គួរគិតពិចារណាឲ្យឃើញហេតុផលល្អិតល្អន់ ទើបជាការល្អ កុំឲ្យប្រើវិធីមូលលេបនោះ នាំឲ្យទាស់ដល់ខ្លួន ព្រោះថាបើយើងជាអ្នកចង់សុខ ហើយធ្លាក់ខ្លួនទៅជាឈ្លើយ. របស់សាសនានុ៎ម ឬលើពួកអ្នកដែលដឹកនាំអាក្រក់ហើយ យើងនឹងក្លាយខ្លួនទៅជាចំណី ទៅជាបរិវារឬជួបគេថាទៅគ្រាន់តែបង្គ្រប់ បានឲ្យគេជាកំឡាំងឲ្យគេប៉ុណ្ណោះ ៗ គួរនឹកដល់រឿងកន្លងមកដែលដំណាលអំពីអ្នកលិចសំពៅម្នាក់ បានផែនក្ដារ១ ផ្ទាំងកាន់ហែលមកដល់ត្រើយ ហើយរកសំពត់ស្លៀកពាក់គ្មាន ក៏យកស្លឹកឈើខ្ទាស់ស្លៀក

ដើរមកសូមបាយអ្នកស្រុកទទួលទាន ៗ អ្នកស្រុកសំគាល់ថាជាអរ-ហន្តវិសេស ក៏នាំគ្នាគោរពបូជាដោយលាភសក្ការ ឯអ្នកនោះយល់ឃើញថាខ្លួនដែលសម្បូរដោយគ្រឿងសក្ការនេះ ព្រោះដោយសារតែសំ-លៀកស្លឹកឈើនេះ ហើយក៏ទំនេរនៅស្លៀកតែស្លឹកឈើ ទោះគេយកសំពត់ទៅឲ្យក៏មិនព្រមស្លៀក សំដែងពុតថាជាអ្នកប្រាថ្នាតិច តាំងការប្រៀនប្រដៅអ្នកស្រុកតាមតែនឹកឃើញ កើតបានជាលទ្ធិ ១ ឡើង ៗ រឿងភិក្ខុទេវទត្តប្រាថ្នាចង់ធំ ហើយទៅសូមការគ្រប់គ្រងគណសង្ឃអំពីព្រះពុទ្ធ លុះមិនបានសមដូចសេចក្ដីប្រាថ្នា ហើយរិះគិតបង្កើតវត្ថុ៥ប្រ-ការឲ្យតឹងជាងព្រះពុទ្ធ ដើម្បីបញ្ឆោតពួកអ្នកល្ងង់ឲ្យគាន់តាំងជឿថាខ្លួនប្រ-ព្រឹត្តតឹងវិសេសជាងព្រះសម្ពុទ្ធនេះ ក៏ក្លាយទៅជាលទ្ធិសាសនាមួយដោយឡែកទៀត ៗ ការកាន់សាសនាគួរពិនិត្យឲ្យឃើញសមហេតុសមផលកុំយកអាការកិរិយាក្រៅជាប្រមាណ ដូចឃើញថាគេមានហើយ. គេធំហើយ គេសុទ្ធតែចេះ សុទ្ធតែត្រូវនោះ ដូចពាក្យលោកថា: "ជើង ៤ ជួនមានភ្លាត់ ទោះចេះស្ទាត់ តែងអ្វីភ្លាំង" គួរនឹកដល់រឿងជាតកដែលសំណាលអំពីពោធិសត្វនិងពួកអ្នកជំនួញនេះ ព្រមចិត្តគ្នាបររទេះកាត់ទីវាលខ្សាច់ធំ គង់ពេលយប់ ដោយគាត់យកអ្នកស្គាល់ផ្កាយ ឲ្យជាមគ្គនាយកនាំផ្លូវ លុះរទេះបរទៅដល់ពាក់កណ្ដាលយប់ នឹងដល់ពាក់កណ្ដាលផ្លូវហើយ អ្នកនាំផ្លូវនោះដេកលក់ នាំរទេះវិលក្រោយ

វិញ, ទម្រាំតែដឹងថាត្រឡប់ក្រោយវិញ ក៏ជិតភ្លឺណាស់ទៅហើយ ៗ នៅចំកណ្ដាលវាលខ្សាច់ ឆ្ងាយអំពីទីមាត់ព្រៃទាំងសងខាង ដែលជាហេតុនាំគ្នាក្ដៅស្លាប់ក្នុងពេលព្រះអាទិត្យរះឡើង. តែខ្លួនប្អូនពេលនោះ បានព្រះពោធិសត្វមានប្រាជ្ញា ជួយប្រាប់ឧបាយឲ្យយករទេះមកព័ទ្ធដំកង់ជុំវិញ ហើយយកសំពត់បេញមកត្រដាងជាបាំងបាំងនឹងរកកន្ទេងជីកអណ្ដូងប្រយោជន៍ឲ្យបានទឹកសម្រាប់ប្រើប្រាស់ ការពារក្ដៅទីងស្រេក ៗ រឿងនេះជាគតិឲ្យឃើញថា កុំឲ្យទុកចិត្តគេបេះគេគ្រាន់បើ គេជាលោកគ្រូគប់កន្ទេងពេក តែក៏មិនមែនហាមមិនឲ្យជឿសោះនោះទេ គ្រាន់តែហាមថាជឿអ្វីឲ្យមានវិះគិតផង ទើបល្អ ៗ

ការយកចិត្តទុកដាក់ប្រតិបត្តិតាមពាក្យប្រៀនប្រដៅ ដែលហៅថា សាសនាល្អនោះ រមែងបានសេចក្ដីសុខ ៗ ការកាន់តាមសាសនាហើយត្រឡប់បានទុក្ខនោះ ទាស់មកពីធ្លាក់ខ្លួនទៅលើសាសនាប៉ុម ទឹកជឿប្រកាន់តាមសេចក្ដីដឹកនាំរបស់សមណព្រាហ្មណ៍ ដែលមានគំនិតទុច្ចរិត ។ ឬក៏ដោយហេតុដែលធ្វើតាមមិនដល់កម្រិត ទឹងហួសកម្រិតធម៌ដែលគេកំណត់ឲ្យធ្វើ រឿងនេះគួរគិតដូចអាហារ ដែលបរិភោគ ៗ ធម្មតាអាហារទាំងអស់កុំឲ្យចូលចិត្តថា សុទ្ធតែទទួលទានឲ្យរស់ខ្លួននោះ មានឲ្យស្លាប់ខ្លួនវិញក៏សឹងមានដែរ ៗ ដូចម្ដេចដែលបរិភោគត្រឡប់ជាស្លាប់ខ្លួននោះ? ៗ ដូចបរិភោគម្លួល, បរិភោគអាហារបុម, អាហារដែល

បណ្ដាលឲ្យកើតពេកពួកនេះ បើទុកជាមិនដល់ស្លាប់ ក៏គង់បានទុក្ខវេទនាក្បែរស្លាប់មិនខាន នេះឯងដូចគ្នានឹងការកាន់សាសនាត្រូវល្អ តែកាន់ជួរថយខ្ជិលខ្ជាឬតឹងរ៉ឹងហួសហេតុ នឹងកាន់សាសនាប៉ុម ឬសាសនាដែលមានមនុស្សខ្ទប់ប៉ុមខ្លួនអែបនែបនៅខាងក្នុង នេះហើយ ការកាន់សាសនាដែលត្រឡប់បានផលផ្ទុយ គឺត្រឡប់ផ្ទុយទុក្ខជំនួសសុខ ៗ អស់លោកទាំងឡាយគួរតែគំនិតគិតជាថ្មីឡើងវិញ ការកាន់សាសនាហើយមិនបានសុខចំរើនសមដូចសេចក្ដីប្រាថ្នានោះ ក្រែងមានបើយើងកាន់ខុសអ្វីហើយទេដឹង បានជាមិនបានផលសមបំណងយ៉ាងនេះ ៗ គួរគិតថា សូម្បីតែការស្ទូងដណ្ដាំ ទោះជាមានបន្លែត្រីអ្វីសព្វគ្រប់ គង់មានខ្វះស្លមិនបានការ មិនមានរសជាតិ មិនឆ្ងាញ់ បរិភោគមិនកើត នេះមកពីផ្សំគ្រឿងមិនត្រូវ ៗ ការដាំបាយក៏មានខុសទំនងដូចគ្នា ដាំឲ្យនៅឲ្យជ្រាយហួសឲ្យខ្លោចឬទាំងនៅទាំងជ្រាយ ទាំងខ្លោច តើនឹងទទួលទានកើតឬទេ? មួយទៀតដូចនាឡិកា ដែលយឺតពេក លឿនពេកឬឈប់ មិនដើរ មិនទៀងទាត់ តាមកំណត់ពេលវេលា យ៉ាងនេះតើនឹងអាស្រ័យយកជាគ្រឿងប្រាប់កាលវេលាបានឬទេ? បើយ៉ាងហ្នឹងគួរនឹងបោលទៅឬគួររើខ្ចាត់ផ្សុលណាងជាក់ប្រែការរៀបចំឲ្យត្រូវខ្ជាប់ឡើងវិញ? ឧបមាមួយទៀតការកាន់ធម៌មានគតិដូចឧបកែវដំបូក កាន់ខ្ជិលខ្ជាក៏ធ្លាក់បែក កាន់ប្រយ័ត្នជ្រុលឧបកែតាំងពេកក៏បែកដូចគ្នា ៗ

ព្រះពុទ្ធសាសនារបស់យើង ឈ្មោះថាកើតឡើងដោយសេចក្ដីបរិសុទ្ធ ព្រោះព្រះសម្ពុទ្ធដែលជាអ្នកតាំងសាសនានេះឡើង ព្រះអង្គជាជាតិក្សត្រិយ៍ បានសោយរាជសម្បត្តិយ៉ាងសុខសប្បាយ ហើយទ្រង់លះរាជសម្បត្តិចោល ចេញទៅសាងព្រះផ្នួស ទ្រង់ខំធ្វើទុក្ករកិរិយាជាការធ្វើតាមសាសនាដទៃ ៗ ដែលមានក្នុងសម័យនោះ ដើម្បីពិសោធល្បងឲ្យដឹងលទ្ធិសាសនាទាំងនោះ អស់វេលា ៦ ឆ្នាំ ទើបទ្រង់ត្រឡប់ធ្វើតាមព្រះសតិបញ្ញារបស់ព្រះអង្គ ក៏បានត្រាស់ជាព្រះសម្មាសម្ពុទ្ធឡើងក្នុងលោក ។ ពុទ្ធសាសនាយើងនេះ ឥតមានការរង្វៀសថា ម្ចាស់សាសនានេះ ជាជាតិថោកទាប ព្រោះព្រះអង្គជាក្សត្រិយ៍ ។ ឥតមានរង្វៀសថា ព្រះអង្គជាអ្នកក្រីក្រ តាំងសាសនាដោយប្រាថ្នាទីពឹងចិញ្ចឹមជីវិតនោះ ព្រោះព្រះអង្គបានសោយរាជ្យ ។ ឥតមានរង្វៀសថា ក្រែងព្រះអង្គប្រដៅមិនត្រូវ មិនត្រឹមស្មើនឹងសាសនាដទៃនោះ ព្រោះព្រះអង្គពិនិត្យល្បងមើលលទ្ធិសាសនាដទៃ ដោយការធ្វើទុក្ករកិរិយាអស់ ៦ ឆ្នាំហើយ ។ ធម៌ដែលព្រះពុទ្ធទ្រង់សំដែងទាំងប៉ុន្មាន ឈ្មោះថាព្រះអង្គបានពិនិត្យស្រិតស្អាតល្អសព្វគ្រប់ហើយ ប្រៀបដូចជាងមាសបានដេញមន្ទិលមាសចេញស្អាតហើយ ទើបចេនាជាប្រដាប់ប្រដាសន្ធាវៀរកជាដើម ។ ព្រះបរមសាស្ដារបស់យើង ឈ្មោះថាមានព្រះប្រាជ្ញាបរិសុទ្ធខ្ពស់បំផុតពិត ព្រោះព្រះអង្គប្រដៅសាសនាក្នុងវេន ៤៥ វស្សា ធ្វើការ

មិនមានស្មោក ទោះជាមានពាលគិតបៀតបៀនខ្លះ ក៏ព្រះអង្គមិនដែលមានគ្រោះថ្នាក់អ្វី ប្រសិនបើព្រះអង្គមិនឆ្លាត សំដែងធម៌មិនត្រូវ ហើយទ្រង់ប្រកាសសាសនាក្នុងកណ្ដាលពួកសាសនាដទៃ ដែលជាការជួបជាប្រណាំងប្រជែងនឹងសាសនារបស់គេ ជាហេតុនាំឲ្យគេទាស់ចិត្តគិតព្យាបាទយ៉ាងនេះ ម៉្លេះសមជាព្រះអង្គគង់ត្រូវគេធ្វើអន្តរាយអ្វីខ្លះមិនខានទៅហើយ ។ មួយទៀត ពុទ្ធសាសនានេះ ក៏ឈ្មោះថាមានមកយូរឆ្នាំកប់ប្រមាណជាងពីរពាន់ប្លាយឆ្នាំហើយ ប្រសិនបើធម៌នោះមិនពិតមិនត្រឹមត្រូវ ប្រហែលជាពុទ្ធសាសនានេះមិនគង់អាយុមកដល់យើងសព្វថ្ងៃនេះទេ តែពុទ្ធសាសនាមានតំលៃ ចំពោះអ្នកកាន់មានប្រាជ្ញាចេះពិចារណាពិនិត្យឲ្យចូលចិត្តសេចក្ដីនៃធម៌ឲ្យជាក់ច្បាស់ ប្រៀបដូចពេជ្រ-មាស មានតំលៃចំពោះអ្នកស្គាល់ប្រយោជន៍ចេះប្រើ បើមិនស្គាល់ទេ ឬធ្លាក់ទៅលើពួកដែលឥតពិចារណាហើយ ក៏មិនខុសអំពីពាក្យលោកថា "ស្វាបានកែវ" ប៉ុណ្ណោះទេ ហេតុនេះហើយ បានជាមានពួកដែលមិនស្គាល់តំលៃ ពុទ្ធ-សាសនាច្រើនតិះដៀលថា ពុទ្ធសាសនាឥតផលប្រយោជន៍ គិតធ្លាក់ចោលពុទ្ធសាសនា បែរគំនិតទៅជាមនុស្សទំនេរឯងៗ ឬទៅចូលកាន់លទ្ធិដទៃដែលជារបស់អសារឥតការសោះ ក៏សឹងមាន សូមឲ្យមានគំនិតថា មុនដែលចោលពុទ្ធសាសនា គួរសង្កេតឲ្យស្រស់ដឹងសិន ក្រែងចុះក្នុងពាក្យលោកថា "បាក់អង្ករយកអង្កាម" វិញទេដឹង គួរនាំគិតថា ពុទ្ធសាស-

នានេះ បើយើងផុសខាត់ពិចារណាណាស់ ក៏រឹតតែជ្រះថ្លាណាស់ ព្រោះខាងក្នុងសាសនានេះបរិសុទ្ធល្អបំផុត ឥតមានមន្ទិលដែលនាំអ្នកកាន់តាមឲ្យវិនាសឡើយ ។

២) សេចក្តីប្លែករបស់ពុទ្ធសាសនានឹងសាសនាដទៃ គួរជ្រាបថា សាសនាក្នុងលោកនេះ ពិតមែនជាមានច្រើន មានលទ្ធិផ្សេង ៗ គ្នា តែក៏មិនមែនហួសវិស័យដែលយើងនឹងកំណត់មិនបាននោះទេ មានលទ្ធិប្លែកគ្នាតែពីរបីយ៉ាងប៉ុណ្ណោះ គឺពួកមួយអាងកម្ម (អាងយកអំពើដែលសត្វធ្វើនោះជាហេតុឲ្យសុខឲ្យទុក្ខ) ។ ពួកមួយអាងយកវត្ថុខាងក្រៅប្រកាន់ថាសត្វដែលបានសុខក្តី ទុក្ខក្តី មកអំពីអ្នកវិសេសណាមួយចាំឲ្យ ។ មួយពួកទៀតបដិសេធទាំងកម្មទាំងអ្វី ៗ ខាងក្រៅទាំងអស់ ជឿប្រកាន់ថាស្រេចតែនឹងទទួលចួន ដូចការប្រព្រឹត្តអំពើអាក្រក់ណាមួយ កុំឲ្យតែគេដឹងគេចាប់បាន ក៏រួចខ្លួនគ្មានបាបអ្វីទេ ។ ពួកទី ១ ធ្វើអំពើអ្វី ៗ ប្រយ័ត្នតែកាយ-វាចា-ចិត្តមិនឲ្យទាស់ ប្រព្រឹត្តធ្វើតែកាយ-វាចា-ចិត្តឲ្យសុចរិត ។ ពួកទី ២ ធ្វើអ្វីៗ ដោយកាយ-វាចា-ចិត្តហើយ ក៏មិនគិតដល់កម្ម គិតប្រុងប្រយ័ត្នកុំឲ្យទាស់នឹងរបស់ខាងក្រៅប្រព្រឹត្តផ្គាប់ចិត្តបួងសួងបន់ស្រន់ចំពោះរបស់សក្តិសិទ្ធិដែលខ្លួនជឿប្រកាន់ថាជាអ្នកចាំឲ្យសុខឲ្យទុក្ខ ។ ពួកទី ៣ លែងគិតអ្វីទាំងអស់ប្រើតែប្រាជ្ញាប្រុងគេចវៀះ កុំឲ្យតែគេចាប់បានប៉ុណ្ណោះ ។

ចំណែកព្រះពុទ្ធជាម្ចាស់របស់យើងទ្រង់អាងយកកម្មជាធម៌ទ្រង់ប្រដៅឲ្យប្រុងកាយ - វាចា - ចិត្តឲ្យស្អាត លះបង់ទុច្ចរិត ប្រព្រឹត្តសុចរិត ព្រោះជាសុខ ទុក្ខទាំងពួង ស្រេចហើយតែនឹងធ្វើ បើធ្វើល្អ ក៏បានល្អ ធ្វើអាក្រក់ក៏បានអាក្រក់ មិនមានអ្នកណាមួយឲ្យសុខឲ្យទុក្ខដល់គ្នាបានទេ បើទុកជាអ្នកក្រៅគេឲ្យសុខឲ្យទុក្ខក្តី ក៏អាស្រ័យមកអំពីអំពើល្អ អាក្រក់របស់ខ្លួនដែរ ៗ ការដែលធ្វើល្អហើយមិនបានសុខសមបំណងនោះត្រូវប្តូរចិត្តថាមកអំពីខ្លួនធ្វើទាស់ទេ ដូចអធិប្បាយមកហើយអំពីខាងដើម, ហេតុនោះ បើយើងជាអ្នកកាន់ពុទ្ធសាសនាពិតគួរយើងគិតប្រកាន់តែកម្មឲ្យមាំ កុំអាងវត្ថុខាងក្រៅ ដូចអាងគេអ្នកវិសេស អ្នកមានបុណ្យពេកនោះ ជាការហួសហេតុហើយ ត្រូវខំតែធ្វើឲ្យត្រូវតាមព្រះដំបូន្មានព្រះសម្ពុទ្ធឲ្យសព្វគ្រប់ចុះ សេចក្តីសុខកាយសប្បាយចិត្តប្រាកដជានឹងបានដូចសេចក្តីប្រាថ្នាមិនខានឡើយ ៗ

៣) ពាក្យប្រៀនប្រដៅក្នុងសាសនាទាំងអស់ គួរយើងកំណត់ទុកថាពួកខ្លះប្រដៅឲ្យស្គាល់តែប្រយោជន៍បច្ចុប្បន្នប៉ុណ្ណោះ ខ្លះក៏ប្រដៅឲ្យស្គាល់ទាំងប្រយោជន៍បច្ចុប្បន្ននឹងអនាគត ខ្លះក៏ប្រដៅឲ្យស្គាល់រហូតដល់បរមត្ថប្រយោជន៍ គឺប្រយោជន៍ខ្ពស់បំផុត ដែលជាសុខទៀងទាត់ឥតប្រែប្រួល (ប្រយោជន៍ព្រះនិព្វាន) ៗ ន័យមួយទៀត ពួកខ្លះប្រដៅបានចំពោះតែត្រឹមកុំឲ្យធ្វើអាក្រក់ ខ្លះប្រដៅឲ្យធ្វើល្អដែលជាកិច្ចឲ្យ

រក្សាល្អបានចំពោះតែកាយនឹងវាចាប៉ុណ្ណោះ ខ្វះក៏ប្រើឲ្យបេះដុសខាត់ចិត្តឲ្យស្អាតថែមទៀត ។ ក្រៅអំពីព្រះពុទ្ធសាសនាហើយ ឃើញថាប្រើប្រយោជន៍មិនបានគ្រប់ទាំង ៣ នោះទេ ទាំងប្រើមិនបានគ្រប់ទាំងកាយ-វាចា-ចិត្តនោះទេ ។

៤) ការកាន់សាសនាមានប្រយោជន៍អ្វី? ត្រង់នេះគួរជ្រាបផងរបស់ដែលយើងត្រូវរៀននឹងត្រូវធ្វើជាមុនសិន ។ របស់ដែលត្រូវរៀនត្រូវធ្វើក្នុងលោកនេះសោត ពិតមែនជាមានច្រើនរាប់ស្ទើរមិនអស់ តែក៏ច្រើនចំពោះតែមុខការទេ បើនឹងទាញយកមកដាក់ក្នុងខ្លួនយើងហើយក៏នឹងឃើញថា យើងដែលនឹងខំរៀនខំធ្វើទាំងអម្បាលម៉ាន ប្រយោជន៍តែនឹងចិញ្ចឹមជីវិត នឹងរក្សាខ្លួនឲ្យល្អប៉ុណ្ណោះ ។ វិជ្ជា: លេខ-អក្សរ-ត្បាញ-រវៃ-ជំនួញ- នឹងគ្រឿងយន្តជាដើម ជាវិជ្ជាសម្រាប់ចិញ្ចឹមជីវិត ។ វិជ្ជាដែលគិតធ្វើដូចម្ដេចក្នុងពេលដែលយើងមានប្រាក់ចាយ មានបាយទទួលទានហើយឲ្យបានសុខផងនោះ នេះជាវិជ្ជារក្សាខ្លួន សំដៅយកចរិយា (សេចក្ដីប្រព្រឹត្ដិ) ។ មនុស្សដែលកើតក្នុងត្រកូលខ្ពស់ត្រ-កូលអ្នកមានស្ដុកស្ដម្ភ មានវិជ្ជាសម្រាប់ចិញ្ចឹមជីវិតហើយ នៅតែមិនបានសុខនោះ មកតែពីគ្មានចរិយា គឺវិជ្ជារក្សាខ្លួននេះ ត្រូវតែយកចិត្តទុកដាក់វិជ្ជានេះជាងវិជ្ជាចិញ្ចឹមជីវិតទៅទៀត ។ ព្រោះវិជ្ជារក្សាខ្លួននេះជាមេលើវិជ្ជាទាំងអស់ ។ គួរជ្រាបថា ខ្លួនយើងនេះចែកជាពីរចំណែកគឺ

រូបកាយ ១ នាមកាយ ១ ៗ ធាតុទាំង ៤ គឺ ដី-ទឹក-ភ្លើង-ខ្យល់ (បានដល់សាច់សរសៃ, សក់, ធ្អឹង, ឈាម, ខ្យល់ដង្ហើមចេញចូល និងរបស់ក្ដៅជាដើម ដែលកើតឡើងបានជារូបកាយនេះ) ១ ចំណែក; របស់ដែលមានតែឈ្មោះ ដូចវេទនា (ការទទួលសុខ-ទុក្ខ-ឧបេក្ខា); សញ្ញា (សេចក្ដីកត់សំគាល់ចាំបាន), សង្ខារ (ការតាក់តែងឲ្យកើតឲ្យមានឡើង), វិញ្ញាណ (ការទទួលដឹងការល្អ-អាក្រក់) ដែលជាប៉ែករួមចូលខាងចិត្តនេះ ១ ចំណែក ៗ វិជ្ជាចិញ្ចឹមជីវិតសម្រាប់ទំនុកបំរុងរូបកាយនេះ ឲ្យស្រស់ឲ្យរស់ឲ្យតាំងនៅ ៗ បរិយាវិជ្ជារក្សាខ្លួន សម្រាប់ទំនុកបំរុងនាមកាយឲ្យស្រស់ឲ្យសុខ រួមសេចក្ដីឲ្យខ្លីគឺវិជ្ជាឲ្យសុខកាយ និងវិជ្ជាឲ្យសប្បាយដល់ចិត្ត ៗ វិជ្ជាឲ្យសុខកាយនេះ ជាភារៈលើយើងករែកខ្លួនឯងចុះ សាសនាទទួលប្រាប់តែវិជ្ជារក្សាខ្លួនប៉ុណ្ណោះ ព្រោះវិជ្ជានេះក្រហើយជាវិជ្ជាជួយគាំទ្រវិជ្ជាដទៃទាំងអស់ ៗ បរិយា គឺវិជ្ជាខាងសេចក្ដីប្រព្រឹត្តខ្លួនឲ្យបានសុខនេះ ក្នុងព្រះពុទ្ធសាសនាយើង សម្បូរបំផុតឥតខ្វះ មិនបាច់យើងទៅអាស្រ័យសាសនាដទៃទេ ៗ គួរចាំទុកថា បរិយាក្នុងពុទ្ធសាសនានេះ បើរៀនបានហើយប្រព្រឹត្តតាមបានត្រឹមត្រូវហើយ សេចក្ដីសុខកាយសប្បាយចិត្តក៏នឹងបានព្រម ដោយហេតុវិជ្ជានេះជាកំឡាំងជួយជោរគំនិតយើងឲ្យកើតសេចក្ដីឧស្សាហ៍ខំស្វែងរកហេតុដែលឲ្យយើងបានស្រួលទាំងកាយទាំងចិត្ត គឺមិនឲ្យយើង

ក្មេងគិតលក់គំនិតគិតតែ ១ ផ្លូវ ៗ កុំឲ្យគិតតែវិជ្ជាប្រដៅខ្លួន មិនរកវិជ្ជារក្សាជីវិតផង ឬគិតតែវិជ្ជារក្សាជីវិតក្មេងគិតរកវិជ្ជារក្សាខ្លួនផង ៗ ហេតុនោះបើយើងប្រាថ្នាដើរឲ្យទាន់ជាតិគេជុំវិញខ្លួនយើងនោះ ត្រូវយើងកុំលក់គំនិតដូចកិច្ចដែលធ្លាប់ធ្វើមកហើយនោះ ត្រូវយើងរើគំនិតគិតឡើងជាថ្មីថា យើងខំរៀនវិជ្ជាចិញ្ចឹមជីវិតអ្វីមួយ ៗ ឲ្យបេះស្មាត់ប្រាកដ ហើយខំរៀនវិជ្ជាប្រដៅខ្លួនឲ្យបេះមែនទែន ខំប្រព្រឹត្តឲ្យបានល្អទាំងកាយវាចាចិត្តតាមគន្លងច្បាប់ដែលព្រះសម្ពុទ្ធទ្រង់ប្រោសប្រទានទុកមក ៗ ត្រង់ដែលយើងខំធ្វើបានយ៉ាងនេះ ប្រាកដជាបានសុខ ត្រង់បានសុខនេះហើយត្រូវចូលចិត្តថា ហ្នឹងហើយដែលហៅថាបានបុណ្យ ព្រោះពាក្យថាបុណ្យ ក៏សំដៅយកសេចក្ដីសុខកាយសុខចិត្តទាំងពីរនេះ ៗ ការតាំងសាសនាប្រយោជន៍ឲ្យបានបុណ្យគឺឲ្យបានសុខទាំងពីរផ្លូវ ដែលលោកហៅថា កាយិកសុខ (សុខខាងកាយ) ចេតសិកសុខ (សុខខាងគំនិត) ដូចអធិប្បាយមកនេះឯង ៗ

៤) ពុទ្ធសាសនា ប្រែថាដូចម្ដេច? ការដែលគេតាំងសាសនាឡើងមួយ ៗ សុទ្ធតែគេប្រកាសឈ្មោះ ប្រាប់ឈ្មោះអ្នកតាំងដើមក៏មាន យកសេចក្ដីបំណងរបស់អ្នកតាំងផ្ដើមឡើងតើគេប្រាថ្នាឲ្យអ្នកកាន់តាមបានប្រយោជន៍អ្វីនោះជាឈ្មោះក៏មាន ដូចសាសនាមោហម័ទ ឬ ហៅថាឥស្លាម សាសនាយេស៊ូឬកាតូលិក សាសនាអចេល អាជីវក បរិញ្ញា-

ដក និគ្រន្ថ អន្យតិរ្ថិយ តាបស ឥសី ជដិល ព្រាហ្មណ៍ជាដើម សា-
សនាពួកនេះសុទ្ធតែប្រកាសថា សាសនាគេនោះកំចាត់សេចក្ដីអាក្រក់
ប្រាជ្ញាតិច វៀរបាបជុំវិញ ឥតធម៌អាក្រក់សំញុំជាដើម តែនឹងបានល្អ
ដូចគេថាមែនឬទេនោះ មិនបាច់និយាយដល់ ត្រូវយើងគិតចំពោះតែ
សាសនាដែលយើងកាន់នេះចុះ ដើម្បីឲ្យដឹងថា ព្រះបរមសាស្ដារបស់
យើងទ្រង់មានព្រះបំណងអ្វីនឹងគេដែរ បានជាទ្រង់តាំងសាសនានេះ
ឡើង ។ ត្រង់នេះ ត្រូវយើងដឹងឈ្មោះជាពីរន័យ គឺគេហៅថា ពុទ្ធ-
សាសនាក៏មាន ដូចណាគេហៅថាសាសនាព្រះសក្យមុនីក៏មាន ពាក្យ
ថា សក្យមុនី ប្រែថាអ្នកប្រាជ្ញស្ដេចសក្យ ឯពាក្យថា ពុទ្ធសាសនា នោះក៏
ជាឈ្មោះប្រាប់បំណងដល់ការតាំងសាសនានេះដូចជាសាសនាដទៃដែល
គេប្រាប់បំណងសាសនារបស់គេដែរ ព្រោះពុទ្ធសាសនានេះ ប្រែ
ថាពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធ ក៏ពាក្យថា ពុទ្ធ នេះ មិនមែនជាព្រះ
នាមដ៏កំណើត ដែលព្រះវរមាតាបិតាថ្វាយនោះទេ មិនមែនជានាមជាតិ
ដូចជាពាក្យសក្យនោះទេ ជាគុណនេមិត្តកនាម គឺព្រះនាមដែលគេថ្វាយ
តាមគុណសម្បត្តិដែលមានក្នុងព្រះអង្គ ព្រោះសព្ទថាពុទ្ធនោះ ប្រែថា
ភ្ញាក់ដូចគ្នានឹងពាក្យភ្ញាក់ពីដេកលក់ តែក្នុងទីនេះសំដៅយកភ្ញាក់ពីសេចក្ដី
ល្ងង់ងងឹតដែលមិនដឹងអ្វី ដូចជាការមិនដឹងរបស់អ្នកដេកលក់នោះ សូម្បី
ពាក្យធម្មតាក៏គេតែងនិយាយថា អ្នកដែលនេះ ជាមនុស្សភ្ញាក់កំណើត

មនុស្សបើកភ្នែក មនុស្សមានធុលីតិចក្នុងភ្នែក ឯអ្នកល្ងង់វិញគេតែងនិយាយថា មនុស្សលក់គំនិត មនុស្សខ្វាក់ភ្នែក មនុស្សធុលីពេញភ្នែក ។ ព្រះសម្ពុទ្ធព្រះអង្គជាអ្នកប្រាជ្ញបំផុត ព្រះអង្គបានភ្ញាក់រំពើងកលក់គឺអវិជ្ជា បានជាគេថ្វាយព្រះនាមថា ព្រះពុទ្ធ គឺព្រះអង្គហ្នឹងឯងដែលជាបុគ្គលភ្ញាក់កំណើតកើតគំនិតមែន ព្រះអង្គទ្រង់យល់ហេតុនាំឲ្យចំរើនហេតុនាំឲ្យវិនាសទាំងក្នុងលោកនេះទាំងលោកខាងមុខពិតប្រាកដ ហេតុនោះគួរជ្រាបថា ពុទ្ធសាសនានេះគឺពាក្យប្រៀនប្រដៅរបស់អ្នកដែលភ្ញាក់កំណើតកើតគំនិតគឺរបស់បុគ្គលដែលជាអ្នកប្រាជ្ញពិត ៗ ឬថាពាក្យប្រៀនប្រដៅបំណងឲ្យអ្នកកាន់តាម បានភ្ញាក់កំណើតកើតគំនិតបានរះដឹងនឹងគេឡើង កុំឲ្យនៅលក់គំនិតឥតកំណើត ឲ្យរះឲ្យដឹងខ្លួនឲ្យស្គាល់ការគ្រប់សព្វដែលនាំឲ្យចំរើនដល់ខ្លួននឹងញាតិដែលនៅរួមគ្នា ។ ធម្មតាអ្នកដែលគេទុកថាបានភ្ញាក់កំណើតកើតគំនិតនោះ ជាមនុស្សរះមានអធ្យាស្រ័យល្អ រះជួយសង្គ្រោះគ្នាមិនបៀតបៀនគ្នា ធ្វើខ្លួននឹងអ្នកដទៃឲ្យសុខកាយសុខចិត្តក្នុងបច្ចុប្បន្ននេះ ទាំងមិនឲ្យខាសមិនឲ្យកើតទោសទៅអនាគតផង ។

៦) ពុទ្ធសាសនា ប្រដៅឲ្យភ្ញាក់គំនិតនោះតើ ប្រដៅអ្វីខ្លះ?

ផ្លូវដែលឲ្យកើតសុគតិ ទុគ្គតិ មាន ៣ គឺកើតអំពីកាយ ១ ផ្លូវ អំពីវាចា ១ ផ្លូវ អំពីចិត្ត ១ ផ្លូវ ហើយត្រូវប្រុងប្រយ័ត្នទ្វារទាំង ៣ នេះ ជា ៣ ផ្លូវ

ទៅទៀត គឺប្រយ័ត្នកុំប្រព្រឹត្តកាយ វាចា ចិត្តឲ្យអាក្រក់ដល់គ្នីគ្នា គឺកុំធ្វើបាបគ្នា កុំធ្វើអាក្រក់ កុំបៀតបៀនគ្នាគ្រប់យ៉ាង ព្រោះថាបើយើងនៅរួមគ្នាហើយ ប្រើកាយ វាចា ចិត្តអាក្រក់ដល់គ្នាទៅវិញទៅមក ព្រោះតែយើងចង់សុខតែឯងយ៉ាងនេះ អំពើពាលនេះហើយដែលនាំឲ្យវិនាសទាំងអស់គ្នា ព្យាយាមកុំធ្វើអាក្រក់ដល់គ្នានេះ ១ ផ្លូវ ។ ត្រូវឲ្យមានកាយវាចា ចិត្តស្លូតត្រង់ដល់គ្នា ឲ្យមានគំនិតគិតសង្គ្រោះគ្នា ជួយទំនុកបម្រុងគ្នាឲ្យបានសុខបានចំរើន ឲ្យមានមេត្តាករុណាអាណិតអាសូរដល់គ្នាទៅវិញទៅមក កុំឲ្យល្អតែកាយបែរទៅសំដីអាក្រក់ ឬល្អតែសំដីតែចិត្តអា-ក្រក់នោះមិនហៅថាល្អទេ ការដែលប្រព្រឹត្តកាយវាចាចិត្តឲ្យល្អដល់គ្នីគ្នានេះ ជាហេតុឲ្យបានចំរើន ១ ផ្លូវ ។ រួចហើយត្រូវប្រយ័ត្នសេចក្តីអា-ក្រក់ដែលកើតឡើងចំពោះចិត្ត ដែលនាំឲ្យបំផ្លាញខ្លួនក្តី បំផ្លាញដល់គ្នីគ្នាក្តី ខំទប់ខំអត់សង្កត់ប្រឹងដុសខាត់ចិត្តឲ្យស្អាតផូរផង់ល្អដល់គ្នីគ្នានេះ១ផ្លូវទៀត ។ ន័យមួយទៀត ពាក្យថាបាប ជាអាក្រក់នោះតើអ្វីខ្លះ ដែលថាល្អនោះតើត្រង់ណាខ្លះ ។ យឺត, ប្រហែស, ខ្ជិលច្រអូស, ល្ងង់ជាដើម ហៅថា អាក្រក់ ។ រហ័ស, ប្រឹងប្រយ័ត្ន, ឧស្សាហ៍, បេះដឹងជាដើមហៅថា ល្អ ។ ត្រូវកុំធ្វើអាក្រក់គ្រប់យ៉ាង ឲ្យធ្វើតែល្អគ្រប់យ៉ាងនឹងកុំឲ្យប្រយ័ត្នតែត្រង់

មិនធ្វើអាក្រក់ដល់គ្នីគ្នាប៉ុណ្ណោះ ហើយឥតមានការជួយសង្គ្រោះគ្នា ឥតមានវក្យាអធ្យាស្រ័យគ្នានោះក៏មិនឈ្មោះថា នាំខ្លួនទឹងជាតិឲ្យភ្ញាក់កំណើតកើតគំនិតឡើយ ។ បំណងពុទ្ធសាសនាប្រាថ្នាប្រដៅឲ្យយល់ផ្លូវ ៣ នេះឯង ។ អ្នកកាន់ពុទ្ធសាសនាពិតនោះ ត្រូវព្យាយាមធ្វើឲ្យបានទាំង ៣ ផ្លូវនេះ ទើបឈ្មោះថាធ្វើត្រូវតាមបំណងរបស់ព្រះបរមគ្រូរបស់យើងមែនៗ

ក្រៅអំពីព្រះឱវាទនេះហើយ ព្រះពុទ្ធជាម្ចាស់ត្រាស់សំដែងបញ្ជាក់ថា ធ្វើជាអ្នកមានគំនិតដែលហៅថា បណ្ឌិតនោះត្រូវធ្វើប្រយោជន៍បច្ចុប្បន្ននេះ នឹងប្រយោជន៍អនាគត គឺមិនត្រូវគិតតែប្រយោជន៍បច្ចុប្បន្នសុទ្ធ ហើយបោលប្រយោជន៍អនាគត ឬគិតតែប្រយោជន៍អនាគត ហើយមិនគិតប្រយោជន៍បច្ចុប្បន្នផងនោះក៏មិនល្អទេ ។ មានមនុស្សជាច្រើនដែលគិតតែប្រយោជន៍មួយៗ គឺគិតយកតែប្រយោជន៍បច្ចុប្បន្នសុទ្ធ ទោះបីអាក្រក់ល្អយ៉ាងណាក៏មិនរវល់ គិតឲ្យតែរួចខ្លួនមួយក្នុងបច្ចុប្បន្នក៏សឹងមានមួយពួកទៀតនោះប្រព្រឹត្តតែទៅមុខសុទ្ធ មិនរវល់គិតខាងអាយសោះ ដូចដំណើរដើរមើលហួសតែទៅមុខ ទាល់ចំពប់ជើងដួលក៏មិនរវល់ គឺគិតយកតែប្រយោជន៍អនាគតសុទ្ធ ត្រង់ប្រយោជន៍បច្ចុប្បន្ននេះបង់ខូចវិនាសយ៉ាងណាក៏មិនរវល់ ដូចគេថាគិតតែដីស្ថានសួគ៌ ដីក្នុងស្ថានអាយនេះ មិន

ល់សោះ បង់ខូចវិនាសទៅយ៉ាងណា ក៏មិនយកចិត្តទុកដាក់សោះ ការគិតតែឯនាយសុទ្ធ ពេលឯណាយនេះ សង្ស័យក្រែងមិនបានសមបំណងទេដឹង ព្រោះមានពាក្យចាស់លោកប្រដៅថា «ក្តីពីមនុស្សលោកទើបរួចដល់សួគ៌ានាយ» បើបច្ចុប្បន្ននេះនឹងត្រូវខូចទៅហើយ តើនឹងមិនខូចទៅឯនាយទៀតឬ? ការនេះបើសង្កេតពិចារណាឲ្យល្អិតទៅ ក៏នឹងឃើញថាមែន ព្រោះមនុស្សទុគ៌តខ្សត់ទ្រព្យសម្បត្តិយសសក្តិសតិបញ្ញាក្នុងបច្ចុប្បន្ននេះហើយ មុខជានឹងអកតញ្ញូនូវការធ្វើការក្រោយស៊ីលជាដើមហើយ ព្រោះសេចក្តីក្រត្របសង្កត់ឃាត់ឧបនិស្ស័យទៅមុខត្រង់ផ្លូវ ហេតុនោះគួរខំធ្វើតាមព្រះឱវាទនេះចុះ គឺត្រូវធ្វើដូចម្តេចឲ្យបានប្រយោជន៍ទាំងបច្ចុប្បន្ន ទាំងអនាគតកុំគិតតែប្រយោជន៍មួយ ៗ ទើបហៅថា បណ្ឌិតបាន ។

ព្រះពុទ្ធសាសនាយើង ជាសាសនាបំភ្លឺប្រយោជន៍គ្រប់យ៉ាង ល្អបំផុត តែផលយើងយកប្រយោជន៍មិនបាននេះ មកតែពីមិនរៀន មិនយកចិត្តទុកដាក់សង្កេតពិចារណា បានថា បានសាសនាយ៉ាងល្អហើយត្រឡប់ជាអសារឥតការទៅវិញយ៉ាងនេះ ហេតុនោះគួរអ្នកកាន់ពុទ្ធសាសនាទាំងឡាយខំរៀន ជួយទំនុកបម្រុងការរៀន កុំទំនេរនឹងការរៀន ព្រោះការរៀនច្រើនដឹងច្រើន ទើបយោគខ្លួនបាន មិនកាន់ច្រឡំខុសជាត្រូវ ទាំងមិនមានអ្នកណាអាចបោកបញ្ឆោតដឹកនាំទៅផ្តេសផ្តាសបានផង ។

ក្នុងទីបំផុតនេះសូមឲ្យអស់លោកទាំងឡាយ តាំងព្យាយាមធ្វើប្រយោជន៍ដល់ខ្លួន នឹងប្រយោជន៍ដល់គ្នីគ្នា កុំគិតតែប្រយោជន៍ខ្លួន ចោលប្រយោជន៍អ្នកដទៃ ឬគិតតែប្រយោជន៍អ្នកដទៃ ចោលប្រយោជន៍ខ្លួននោះ ព្រោះថាប្រយោជន៍ទាំងពីរខាងនេះទាក់ទងរកគ្នា បើគិតសុខតែខ្លួន មិនគិតសុខអ្នកដទៃផងនោះខ្លួនឈ្មោះថាមិនបានសុខទេ ឬគិតតែសុខគេ សុខរបស់ខ្លួនមិនគិតសោះនោះ ក៏មិនបានសុខដូចគ្នាដែរ ។

វត្តលង្ការាម ក្រុងភ្នំពេញ

នៅថ្ងៃទី ៦ អ៊ីតឆ្នាំ ១៩៣៨

ព្រះមហាហ្លួត

# បញ្ជីរឿង


ទំព័រ

១ — ចម្រៀងរបស់ពួកយុវសាលា . . . . . . . . . . . . . . . . . . ១៨៨

២ — សេចក្ដីសង្ខេបក្នុងសៀវភៅរបស់លោកសង់ម៉ារគិសរីវីយែរ . . . . . . . . ១៨៩

៣ — សំភាសកថា និយាយពីគូសំភាស ៤ ពួក . . . . . . . . . . . . . ១៩៣

៤ — ប្រជុំពាក្យកាព្យ ភាគ ទី ៣ (ត) . . . . . . . . . . . . . . . ២០៣

៥ — វេយ្យាករណ៍សំស្រ្កឹត ព្រះវិសុទ្ធិវង្ស ហ. ពាត . . . . . . . . . . . ២២១

៦ — ធម្មទេសនា ព្រះសមុហ៍ពោធិបញ្ញា (បាន) . . . . . . . . . . . . ២៤៣

៧ — រឿងព្រេង — បុរសដក់ក្ដាម . . . . . . . . . . . . . . . . . ២៥៧

៨ — លទ្ធិទំនៀមទម្លាប់ខ្មែរ ក្បួនកុមារជន់ . . . . . . . . . . . . . . ២៦៥


## រូបក្រៅរឿង


យុវសាលាមួយ ក្បែរវត្តដំណាក់ ខែត្រសៀមរាប . . . . . . . . . ១៨៧



គណៈកម្មការទំនៀមទម្លាប់

COMMISSION DES MŒURS & COUTUMES

# TABLE DES MATIÈRES


Pages

1. Chant Yuvasaliste .......................... 188

2. L'extrait du livre de Mr JEAN MARQUIS RIVIÈRE .......... 189

3. Les 4 catégories de mariage .......................... 193

4. Recueil des poèmes cambodgiens 3e partie (suite) ....... 203

5. Grammaire de Sanscrit (suite) .......................... 221

6. Conseils Bouddhiques (par le Vénérable Ban) ............ 243

7. Conte populaire cambodgien inédit:

   L'aventure d'un pêcheur de crabes .................... 257

8. Mœurs et Coutumes cambodgiennes:

   Méthode pour guérir les enfants malades .............. 265

HORS TEXTE:

Une auberge de jeunesse cambodgienne "YUVASALA"

à Siemréap .................................. 187



យុវសាលាមួយ ក្បែរវត្តដំណាក់ ខេត្តសៀមរាប

# ចម្រៀងយុវសាលា

យុវសាលាដ៏ឧត្តម ដែលជាសមាគមរៀបចំថ្មី
នៅកម្ពុជរដ្ឋបុរី សម្រាប់ប្រុសស្រីមិនកំណត់ ៗ
សមាគមនេះបានកើតឡើង នាំឲ្យថ្កុំថ្កើងពិតប្រាកដ
សង្គ្រោះពួកជនអ្នកក្រខ្សត់ ឲ្យស្គាល់បែបបទស្រុកនានា ៗ
ទាំងធ្វើដួងចិត្តជនប្រុសស្រី ឲ្យមានមេត្រីរាប់រកគ្នា
បានសុខក្សេមក្សាន្តរាល់វេលា មិនឲ្យនិន្ទាព្យាបាទបាន ៗ
ទាំងបាននាំពួកយុវជន ដែលបានគយគន់មើលសព្វស្ថាន
ជំនួញជួញប្រែទាំងប៉ុន្មាន ទើបរីកកាយបានបែកប្រាជ្ញា ៗ
ទីណាដែលមានសមុទ្រភ្នំ ព្រៃតូចព្រៃធំតាមធម្មតា
មានសត្វបក្សីនិងបក្សា យំឆ្លើយឆ្លងគ្នាកងរំពង ៗ
ឮហើយឃើញហើយកើតគំនិត អាចត្រិះរិះគិតរកដើមទង
មិនឲ្យឃ្លៀងឃ្លាតខុសគន្លង ទំនងឲ្យកើតប្រយោជន៍ធំ ៗ
រួបរួមសេចក្តីខ្ញុំទៅថា យុវសាលាគួរអភិរម្យ
ជាជនឲ្យកើតសមាគម តាមលោកនិយមសម័យនេះ
ទាំងបានចំរើនកំឡាំងខ្លួន សតិមាំមួនកើតជម្រះ
ប្រាជ្ញាឆ្លៀវឆ្លាសអង់អាចបេះ ចំណោះសេដ្ឋកិច្ចសម្រេចអើយ ៗ

# សេចក្តីសង្ខេបក្នុងសៀវភៅ
# របស់លោកសង់ម៉ារគិសរីវីយែរ

លោកសង់ម៉ារគិសរីវីយែរ (Jean Marguis Rivière) ជាអ្នកប្រាជ្ញជាតិបារាំងសែសមួយដែលយកចិត្តទុកដាក់ នឹងបរមត្ថវិជ្ជា នឹងការសាសនា នៅស្រុកកិគ្គ ព្រមទាំងព្រះពុទ្ធសាសនាផង ។

ក្នុងសៀវភៅដែលឈ្មោះថា "ពារាណសី" (Bénarès) ដែលជាទីក្រុងចាស់ដ៏ស័ក្តិសិទ្ធិនៃស្រុកឥណ្ឌាតាំងនៅមាត់ទន្លេគង្គា ។ លោកអ្នកតែងរឿងបានសរសេរប្រវត្តិរបស់លោកសង្ឃទីបេត៍ ១ អង្គទុកនៅក្នុងសៀវភៅនោះ ។ កាលលោកសង់ម៉ារគិសបានធ្វើដំណើរទៅកាន់ស្រុកឥណ្ឌា នឹងស្រុកទីបេត៍ ដើម្បីឲ្យបានយល់ច្បាស់អំពីគំនិតខាងការសាសនា នឹងខាងបរមត្ថវិជ្ជា ដែលមាននៅក្នុងគម្ពីរសំស្ក្រឹតបាលីនឹងគម្ពីរទីបេតាំង ។ ដោយហេតុតែរឿងដែលលោកសរសេរទុកនោះមានសេចក្តីច្បាស់ ហើយជួយឧបត្ថម្ភពួកអ្នកមើលជាជាតិបារាំងសែសឲ្យបានយល់បរមត្ថវិជ្ជា នឹងចិត្តគំនិតនៃស្រុកឥណ្ឌាបានច្បាស់លាស់ឡើងផង ។

សេចក្តីខាងក្រោមនេះយើងដកស្រង់យកសេចក្តីក្នុងសៀវភៅពារាណសីនោះ ដែលជាគ្រឿងជុះពន្យល់ឲ្យភ្លឺច្បាស់អំពីគំនិតពុទ្ធសាសនា ល្មមជាគ្រឿងប្រដាប់សតិបញ្ញារបស់អ្នកមើលជាជនជាតិខ្មែរគ្រប់គ្នា ។

មានមន្ត្រីជាតិនិយមម្នាក់ចូលចិត្តនិយាយសរសើរការបម្រាំង ដែលគេបានទៅសម្លាប់បច្ចាមិត្តរបស់គាត់ចេញបាន ក្នុងពេលដែលមានបម្រាំងសាសនាមួយ ទើបមានភិក្ខុជរា ១ រូបក្នុងព្រះពុទ្ធសាសនាឆ្លើយតបទៅមន្ត្រីនោះថា :

ដោយសេចក្តីពិត ជម្ពូបក្រទេះមានកង់កាំច្រើនស្មុគស្មាញ ហើយផ្លូវក៏លំបាកណាស់ផង បើអ្នកបណ្តោយឲ្យចិត្តគំនិតដឹកនាំអ្នក អ្នកគង់តែស្លាប់បង្គាប់ចិត្ត ប៉ុន្តែអវិជ្ជា អ្នកពាំងឲ្យមិនបានយល់ផ្លូវដែលដឹកនាំទៅកាន់ទីក្សេមក្សាន្តសោះ (គឺអ្នកដឹកនាំខាងផ្លូវចិត្ត) ។ អ្នកឯងត្រូវការតែសេចក្តីតាស់តែងអយុត្តិធម៌នឹងសេចក្តីទុក្ខលំបាក ដែលនាំឲ្យកើតចលាចលដល់សន្តិភាពនឹងសេចក្តីសុខក្នុងលោក ។ ហេតុអ្វី ទើបគេចង់តែកំចាយសេចក្តីតាស់តែងនឹងអាឃាតព្យាបាទឲ្យជ្រួតជ្រាបទៅក្នុងសាច់ឈាមម្ល៉េះ? កម្មល្អតែងឲ្យផលល្អ កម្មអាក្រក់តែងឲ្យផលអាក្រក់ កម្មអស់នេះហើយដែលអ្នកពល់គ្នា ត្រូវតែទទួលមានទំនងដូចជាកង់តែងនឹងវិលមកត្រូវនៅលើខ្លួនអ្នកវិញមិនខាន ត្រូវនឹងទំនៀមដែលអ្នកស្រុកយើងគាយតែងពោលថា កាំត្រាចកាំភ្លើង នឹងសេចក្តីសុខទុក្ខតែងវិលវល់ត្រឡប់ផ្លាប់ផ្លារ ត្រូវទៅលើសត្វគ្រប់រូប ។ យើងបានដែលជូនដំបូន្មានដ៏ល្អនឹងចំណេះវិជ្ជាពុទ្ធសាសនាដល់អ្នកឯង ឯអ្នកត្រឡប់ទៅបំផ្លាញកំណាប់ទ្រព្យសម្បត្តិខេះបេញអស់ [illegible] ចូលបក្រគប់សត្វ

អ្នក បាបធម៌ដ៏លាមកដូច លោភៈ ទោសៈ មោហៈ នឹងចូលមកអ្នក គម្រាមកំញើញអ្នក ឥតកោតញញើតអ្នកបន្តិចឡើយ ។

ក្នុងការស្វះស្វែងរកឥស្សរភាពក្នុងលោកនេះ ស្រេចតែសេចក្ដីប្រព្រឹត្តទៅតាម យុគតាមសម័យ នឹងពុះពារបំពានពុំបានឡើយ ។ អ្នកកុំលុបលាងមើលងាយគំនិតប្រកបដោយសទ្ធិភាព កុំបោះបង់យោបល់ប្រកបដោយសទ្ធិភាព គិតតែពុះពារបំពានរំលោភលើអ្នកដទៃដោយសេចក្ដីលោភរបស់ខ្លួន ។

មុនលោកសង្ឃទីបេតាំងមរណភាពទៅ នៅស្រុកពាកណសីនោះ លោកបានទូន្មានសិស្សរបស់លោកថា ចូរប្រយ័ត្ន ចូរប្រយ័ត្នឲ្យមាំមួនណាអ្នកណា (ចូរប្រកបព្រមដោយសេចក្ដីមិនប្រមាទ ) មានមនុស្សជាច្រើនដែលលះបង់ចោលនូវសេចក្ដីសុខហើយ បែរជាទៅទិញឬដូរយកសេចក្ដីទុក្ខមកវិញ (នេះត្រូវនឹងពាក្យទំនៀមខ្មែរថា បាក់អង្ករយកអង្កាម ) ការយកឈ្នះសត្រូវបច្ចាមិត្ត ត្រូវតែធ្វើបច្ចាមិត្តឲ្យក្លាយ ទៅជាមិត្តមេត្រីដោយចិត្តស្មោះត្រង់របស់អ្នក ហើយទាំងពួកបិសាចឬពួកមារនឹងក្លាយទៅជាអ្នកអារក្ខាថែរក្សាឲ្យសេចក្ដីសុខទៅវិញ ចូរអ្នកចៀសវាងការបន់ស្រន់ពួកទេវតាដែលមានឫទ្ធិអំណាច ព្រោះជាអំពើដ៏ថោកទាបឥតប្រយោជន៍ ហើយជាការបន្ទោកបន្ទាបទេវតាអស់នោះផង ហេតុនេះ ត្រូវតែអ្នកធ្វើខ្លួនឲ្យភ្ជាប់ខ្លួនម៉ឺងម៉ាត់ទៀងត្រង់សុចរិត ពួកទេវតានឹងរាប់អានអ្នកមិន

ខាន ចូរអ្នកកុំនាំយកលទ្ធិទំនៀម ឬពិធីកម្មទៅប្រើឲ្យខុសផ្លូវ ឬទាស់នឹងទំនងគន្លងធម៌ឡើយ ចូរអ្នកគោរពសេចក្ដីបរិសុទ្ធដែលមាននៅក្នុងចិត្ត ចូរអ្នកដឹងថា វិធីនេះហើយទុកជាវិថីបទជាន់ខ្ពស់ ៗ ជាងវិថីបទដទៃ ៗ ទាំងអស់ ៗ ចូរអ្នកប្រគល់សេចក្ដីមេត្រីចិត្តដល់សព្វសត្វទាំងឡាយ ចូរស្រឡាញ់រាប់អានអស់សព្វសត្វដូចស្រឡាញ់ខ្លួនរបស់អ្នកដែរ ៗ ចូរអ្នកលះបង់សេចក្ដីកំណាញ់យល់តែប្រយោជន៍ខ្លួន ដែលនាំឲ្យអន្តរាយដល់សព្វសត្វ កុំប្រកាន់ខ្លួនឆ្មើងឆ្មៃថាខ្លួនជាអ្នកប្រតិបត្តិត្រឹមត្រូវតាមច្បាប់សាសនា ព្រោះអំពើនេះហើយជាអំពើឆ្មើងឆ្មៃរបស់ខ្លួនមនុស្សធម្មតាក្នុងលោក . . . . អំពើអស់នេះជាគ្រឿងបំពេញតណ្ហារបស់សត្វ មិនមែននាំឲ្យកើតសេចក្ដីចំរើនអ្វីទេ ៗ ត្រូវតែស្គាល់ដល់ដើមកំណើតរបស់សព្វសត្វ ទើបជួយនាំផ្លូវសត្វលោកទៅកាន់ស្ថានដ៏ចំរើនបាន បើមិនដូច្នោះទេ មិនខុសនឹងមនុស្សខ្វាក់ ដឹកដៃមនុស្សខ្វាក់ផងគ្នាសោះឡើយ ៗ

សំភាសគាថា

---

# និយាយអំពីគូសំភាស ៤ ពួក
# ដែលជាពាក្យទំនុំទំនៀម ប្រៀបធៀប
# នឹងគូសំភាស ៤ ពួក ដែលជាពុទ្ធភាសិត

---

មហាថែម ក្រុមជំនុំប្រែព្រះត្រៃបិដក
ក្រសួងពុទ្ធសាសនបណ្ឌិត្យ រៀបរៀង

ក្រុងភ្នំពេញ

ព. ស. ២៤៨១

---

សំភាសកថា

១. ឆាងគូនឹងអ្នក

២. មេខាតលក្ខណ៍គូនឹងអាកំបាក់អន្សា

៣. ជំទាវគូនឹងឧកញ៉ា

៤. ស្រីទេពកញ្ញាគូនឹងមហាក្សត្រ

កាលបើយើងពិចារណាមើលពាក្យទំនុំទំនៀមខាងលើនេះ ទើងឃើញថា បណ្ដាបុរសស្ត្រីដែលជាប្ដីប្រពន្ធគ្នាក្នុងលោកនេះ ចំពោះស្ត្រីល្អរមែងមកជាគូនឹងបុរសល្អ ស្ត្រីមិនល្អរមែងមកជាគូនឹងបុរសមិនល្អ ឬស្ត្រីថោកទាបមកជាគូនឹងបុរសថោកទាបដែរ សុទ្ធតែមានទំនងដូច្នេះជាដរាប ប៉ុន្តែបើយើងពិនិត្យមើលដោយសព្វគ្រប់ទៅគង់ឃើញថាមិនមែនដូច្នោះគ្រប់ ៗ គូទេ រមែងមានច្ឆូកគ្នាខ្លះជាធម្មតា គឺស្វាមីភរិយាគូណាដែលអ្នកផងមើលទៅឃើញមិនសមសួនគ្នាគឺមិនសមគ្នាដោយរូបពណ៌សម្បុរៈទ្រព្យធន កិរិយាឫកពាជាដើម ឬយ៉ាងណានីមួយក៏មាន មានចួនកាល ប្ដីកាច ប្រពន្ធស្លូត ឬប្រពន្ធកាច ប្ដីស្លូតក៏មាន ចួនកាល ប្ដីឆ្លាត ប្រពន្ធល្ងង់ ឬប្ដីល្ងង់ ប្រពន្ធឆ្លាតក៏មាន ហេតុនេះ ទើបឃើញថាបណ្ដាបុរសស្ត្រីជាស្វាមីភរិយាគ្នានៅវេលានេះ មិនមែនគត់គូសមសួនគ្នាទាំងអស់ ដូចពាក្យទំនៀមដែលលោកចងក្រងទុកនោះទេ មានចួនកាល នាង

ធ្លាក់ទៅជាគូនឹងអាកំបាក់អន្ទ្យា ឬស្ទុះឡើងជាគូនឹងលោកឲកញ្ញា" ឬជាគូនឹងក្សត្រាក៏សឹងមាន ប៉ុន្តែស្វាមីភរិយាគូណាដែលមិនសមស្មួនគ្នា មិនសូវឃើញមានច្រើនដេរដាស ច្រើនតែអ្នកផងមើលទៅឃើញសម ៗ គ្នា ទុកជាដំបូងឃើញពាស់ក្អែក លុះនៅរួមជាមួយគ្នាយូរទៅ ៗ ស្រាប់តែឃើញសមគ្នាទៅវិញក៏មាន ៗ មួយវិញទៀត បើយើងសង្កេតមើលដោយសព្វគ្រប់ទៅ នឹងឃើញថា ស្វាមីភរិយាគូណាដែលមិនសមស្មួនគ្នា ច្រើននៅរួបរួមជាមួយគ្នាមិនបានស្ថិតស្ថេរ ច្រើនតែមិនបាននៅរួមសុខ-ទុក្ខរហូតដល់ស្លាប់រៀងខ្លួនទៅទេ ច្រើនមានរឿងទាស់ទែងខ្វែងគំនិតគ្នា ហើយលះលែងគ្នាទៅក៏មាន ទើបអស់លោកចាស់ទុំបង្ក្រងទុកជាក្បួនច្បាប់សម្រាប់ជនជាន់ក្រោយរហូតមកមិនបាត់សាបសូន្យទៅវិញនោះ ព្រោះប្រកបដោយសេចក្ដីពិត តាមទម្លាប់ធម៌អ្នកស្រុកយើងនេះ ទុកជាឃ្លៀងឃ្លាតខ្លះ ក៏មានចំនួនតិចតួចដែរ បានជាមានអ្នកផងចាំចងទុកជាប់រហូតមកដល់ជំនាន់យើងសព្វថ្ងៃនេះ ។

ឯសេចក្ដីអធិប្បាយនៃពាក្យទំនៀមខាងលើនេះ ខ្ញុំមិនដែលឃើញសេចក្ដីអធិប្បាយក្នុងក្បួនច្បាប់ដទៃឬសេចក្ដីពន្យល់អំពីអ្នកដទៃទេ ក្នុងទីនេះ ខ្ញុំសូមពន្យល់ជាសេចក្ដីខ្លី ៗ តាមមតិរបស់ខ្ញុំដូច្នេះ:

ពាក្យថា "នាងគូនឹងអ្នក" នេះលោកសំដៅយកស្វាមីភរិយាគូណាដែលមានឋានៈយ៉ាងកណ្ដាល មានវង្សត្រកូលមិនខ្ពស់ពេកមិនទាបពេក

មានរបររកស៊ីយ៉ាងកណ្ដាល ទុកជាធ្វើស្រែចំការច្បារដំណាំ, ជំនួញជួញប្រែ ឬកិច្ចការអ្វី ក៏មិនមានធនធានស្ដុកស្ដម្ភទៅជាសេដ្ឋីគហបតី ល្មមតែស៊ីចាយសប្បាយចិត្ត មិនជំពាក់បំណុលគេ មានសេចក្ដីប្រព្រឹត្តរៀបរយតាមសណ្ដាប់ធ្នាប់របស់អ្នកស្រុក ស្វាមីភរិយាគូនេះ គួរពោលថា «នាងគូទឹងអ្នក» ។

ពាក្យថា "មេខាតលក្ខណ៍គូទឹងអាកំបាក់អន្សានេះ" លោកគង់សំ-ដៅយកមនុស្សជាន់ទាប គឺទាបទាំងពូជពង្ស ទាបទាំងសេចក្ដីប្រព្រឹត្ត ទាបទាំងធនធាន ទាបទាំងគំនិតគិតគូរ ទីងបំណេះចេះដឹង ហើយមានហេតុទាស់ទែងគ្នាមិនសូវស្រាក ចួនកាលប្រពន្ធជេរប្ដី ៗជេរប្រពន្ធ វាយដំប្រំធាក់គ្នាជាទិច្ច ឥតមានការអៀនខ្មាសអ្នកផងបន្តិច ស្រែកជេរប្រទេចគ្នាទ្រហឹងអឹងកង ឥតមានក្រែងចិត្តញាតិមិត្រជិតខាងសោះ ចួនកាលលែងលះគ្នាទៅក៏មាន ចួនកាលលែងគ្នាហើយត្រឡប់ជាគ្នាវិញក៏មាន ហេតុនេះហើយ ទើបលោកពោលថា "មេខាតលក្ខណ៍គូទឹងអាកំបាក់អន្សា" ។

ពាក្យថា "ជំទាវគូទឹងឧកញ៉ា" នោះលោកគង់សំដៅយកគូស្វាមីភរិយាជាន់ខ្ពស់ ដែលមានវង្សត្រកូលខ្ពស់ មានកិរិយាបុកពាថ្លៃថ្នូរ សមជាអំបូរមន្ត្រីជាន់ខ្ពស់ មានសំដីល្អប្រកបដោយសេចក្ដីពិត មានសេចក្ដីប្រព្រឹត្តល្អ គួរអ្នកផងគោរពរាប់អាន មិនគប់មនុស្សពាល មាន

ធម៌ល្អនៅក្នុងខ្លួន មិនឆ្មើងឆ្មៃដំឡើងឫកខ្ពស់ មើលងាយអ្នកដទៃ ប្រកបដោយគុណសម្បត្តិ គួរជាបែបបញ្ញាប់សម្រាប់អ្នកផង ទើបលោកសរសើរចូលក្នុងបទនេះ បើបុរសស្ត្រីណា មានត្រកូលខ្ពង់ខ្ពស់ទាំងគូ តែជាមនុស្សមូទូរប្រលោះបោះ ឥតមានសណ្ដាប់ល្អសោះ ប្រព្រឹត្តអំពើថោកទាបដោយកាយ វាចា ចិត្ត ឥតអៀនខ្មាស ដូចជនពាល បុរសស្ត្រីគូនេះ មិនត្រូវរាប់បញ្ចូលក្នុងបទនេះឡើយ បើបុរសស្ត្រីណា ទោះបីមិនមានត្រកូលឧត្តុង្គឧត្តម មិនមែនជាអ្នកមានបុណ្យស័ក្តិ តែជាអ្នកមានសេចក្ដីប្រព្រឹត្តរាបសាល្អ ទាំងមានចំណេះល្អ បានធ្វើការឡើងថ្នាក់យសស័ក្ដិជាមន្ត្រី ឯកិរិយាក៏តាំងខ្លួនឱ្យសមស្មូនតាមយសស័ក្តិរបស់ស្វាមី ស្វាមីកិរិយាគូនេះក៏គួររាប់បញ្ចូលក្នុងពាក្យថា "ដំទាវគូនឹងចេកញី" ដែរ ៗ

ពាក្យថា ស្រីទេពកញ្ញាគូនឹងមហាក្សត្រ នេះសំដៅយកស្វាមីកិរិយាជាក្សត្រទាំងគូ ឬស្វាមីជាក្សត្រ តែកិរិយាជាកូនមន្ត្រីឬជាកូនរាស្ត្រធម្មតាក៏ដោយ តែមានកិរិយាមារយាទថ្លៃថ្នូរ សមជាគូនឹងមហាក្សត្របាន ក៏រាប់បញ្ចូលក្នុងបទនេះដែរ ៗ មួយវិញទៀត បណ្ដាគូស្វាមីកិរិយាជារាជវង្សានុវង្សរហូតដល់មហាក្សត្រដែលទ្រង់រាជ្យជាទីបំផុត ដែលមានសេចក្ដីប្រព្រឹត្តិសមស័ក្ដិជាក្សត្រ គួរជាទីគោរពកោតក្រែងនៃអាណាប្រជាជន ក៏សរសើរក្នុងពាក្យថា "ស្រីទេពកញ្ញាគូនឹងមហាក្សត្រ" ទាំងអស់ ៗ

សេចក្តីអធិប្បាយដែលបានពណ៌នាមកដោយសង្ខេបនេះ ទុកជាមានខុសភ្លាត់ឬតក់ត្រង់កន្លែងណា សូមប្រគល់ការវិនិច្ឆ័យដ៏ត្រឹមត្រូវនៅលើលោក-អ្នកមើលទាំងអស់ ៗ ឯពាក្យទំនុំទំនៀមទាំង ៤ បទដែលបានកំណត់ទុកនៅខាងដើមនេះ បើស្រង់យកទៅប្រៀបធៀបនឹងព្រះពុទ្ធដីកាដែលព្រះបរមសាស្តាទ្រង់សំដែងទុកក្នុងសុត្តន្តបិដក គម្ពីរអង្គុត្តរ-និកាយចតុក្កនិបាត នោះឃើញមានចំណែកបែកចេញជា ៤ គូដូចគ្នា ប៉ុន្តែចាត់របៀបមិនស្របគ្នាដូចពាក្យទំនៀមទាំង ៤ បទនោះទេ ឯសេចក្តីក្នុងគម្ពីរនោះមានរឿងដំណាលថា:

សម័យមួយ ព្រះដ៏មានព្រះភាគទ្រង់ពុទ្ធដំណើរទៅកាន់ផ្លូវឆ្ងាយនៅចន្លោះក្រុងមធុរានឹងស្រុកវេរញ្ជា វេលានោះ ទ្រង់ចូលទៅឈប់សម្រាកព្រះអង្គក្រោមម្លប់ឈើ ១ ដើម ៗ

កាលណោះ មានពួកគហបតីនិងគហបតានី (ស្វាមីភរិយា) ដែលនៅត្រង់ចន្លោះនៃស្រុកទាំងពីរនោះ បាននាំគ្នាចូលទៅគាល់ព្រះដ៏មានបុណ្យថ្វាយបង្គំព្រះអង្គហើយអង្គុយក្នុងទីសមគួរ ៗ ទើបព្រះបរមគ្រូទ្រង់មានព្រះពុទ្ធដីកាទៅនឹងបុរសស្ត្រីអស់នោះថា ម្នាលអ្នកទាំងឡាយ សំវាស (ការនៅរួមរួមគ្នាជាប្តីប្រពន្ធ) នេះមាន ៤ គឺ ឆវោ ឆវេន សទ្ធិំ សំវសតិ បុរសខ្មោច (បុរសដូជាតិ) នៅរួមជាមួយនឹងស្រីខ្មោច (ស្រីដូ-ជាតិ) ១ ឆវោ ទេវិយា សទ្ធិំ សំវសតិ បុរសខ្មោចនៅរួមជាមួយនឹង

ស្រីទេវតា ១ ទេវោ ឆវាយ សទ្ធឹ សំវសតិ បុរសទេវតានៅរួមជាមួយនឹងស្រីខ្មោច ១ ទេវោ ទេវិយា សទ្ធឹ សំវសតិ បុរសទេវតានៅរួមជាមួយនឹងស្រីទេវតា ១ (ត្រូវជា ៤ គូ) ។

## សេចក្ដីអធិប្បាយ :

បុរសស្ត្រីដែលជាស្វាមីភរិយាគូណា ធ្វើតែអំពើបាណាតិបាតលួចទ្រព្យអ្នកដទៃ ប្រព្រឹត្តខុសក្នុងកាម ពោលពាក្យកុហក ផឹកសុរាមេរ័យ ជាអ្នកទ្រុស្តសីល មានចិត្តកំណាញ់ស្វិតស្វាញ ជេរប្រទេចពួកសមណព្រាហ្មណ៍អ្នកមានសីល ស្វាមីភរិយាគូនេះឈ្មោះថា បុរសខ្មោចនៅរួមជាមួយនឹងស្រីខ្មោច (ឬនិយាយខ្លីៗថា ខ្មោចគូនឹងខ្មោច គូនេះត្រូវនឹងពាក្យទំនៀមថា មេខាតលក្ខណ៍គូនឹងអាកំបាក់អន្សា) ។

បើស្វាមីជាអ្នកប្រព្រឹត្តអាក្រក់ គឺសម្លាប់សត្វ បំបាត់ទ្រព្យគេ ផឹកស្រាលេងល្បែងជាដើម ប៉ុន្តែភរិយាជាស្ត្រីត្រឹមត្រូវ វៀរចាកការសម្លាប់សត្វ បំបាត់ទ្រព្យគេ មិនប្រព្រឹត្តខុសក្នុងកាម មិនពោលពាក្យកុហក មិនផឹកទឹកស្រវឹង ជាស្រីមានសីល មានធម៌ល្អនៅក្នុងខ្លួន មានចិត្តទូលាយ មិនស្វិតស្វាញ មិនជេរប្រទេចពួកសមណព្រាហ្មណ៍អ្នកមានសីល ស្វាមីភរិយាគូនេះ ឈ្មោះថា បុរសខ្មោចនៅរួមជាមួយនឹងស្រីទេវតា (ឬនិយាយខ្លីៗថា ខ្មោចគូនឹងទេវតា) ។

បើស្វាមីជាអ្នកប្រព្រឹត្តល្អ គឺវៀរចាកការសម្លាប់សត្វ បំបាត់ទ្រព្យគេជាដើម តែភរិយាប្រព្រឹត្តអាក្រក់ ធ្វើអំពើបាណាតិបាត អទិន្នាទាន កាមេសុមិច្ឆាចារជាដើម ស្វាមីភរិយាគូនេះ ហៅថា បុរសទេព្ដានៅរួមជាមួយនឹងស្រីខ្មោច ( ឬនិយាយខ្លីៗ ថា ទេព្ដាគូនឹងខ្មោច ) ។

បើស្វាមីភរិយាទាំងគូ ជាអ្នកប្រព្រឹត្តល្អ មិនសម្លាប់សត្វ មិនលួចទ្រព្យគេ មិនប្រព្រឹត្តរំលងចិត្តគ្នា ជាអ្នកមានសីល មានធម៌ល្អនៅក្នុងខ្លួន មានអធ្យាស្រ័យទូលាយពេញចិត្តបរិច្ចាគទានជាដើម នេះហៅថា បុរសទេព្ដានៅរួមជាមួយនឹងស្រីទេព្ដា (ឬនិយាយខ្លីៗ ថា ទេព្ដាជាគូនឹងទេព្ដា ត្រូវនឹងពាក្យទំនៀមថា ក្សត្រាគូនឹងក្សត្រី ទុកជាពាក្យថា នាងគូនឹងអ្នក, ដំទាវគូនឹងឲកញ៉ា ក៏គួរសង្គ្រោះក្នុងបទនេះដែរ ។

ព្រះពុទ្ធភាសិតដែលពណ៌នាមកដោយសង្ខេបនេះ កាលបើប្រៀបធៀបនឹងពាក្យទំនុំទំនៀមនឹងឃើញមានទំនងដូចខាងក្រោមនេះ :

## ព្រះពុទ្ធភាសិត:

១. ខ្មោចគូនឹងខ្មោច

២. ខ្មោចគូនឹងទេព្ដា

៣. ទេព្ដាគូនឹងខ្មោច

៤. ទេព្ដាគូនឹងទេព្ដា

## ពាក្យទំនុំទំនៀមៈ

១ . នាងគូទនឹងអ្នក

២ . មេខាតលក្ខណ៍គូទនឹងអាកំបាក់អន្ទ្រ

៣ . ជំទាវគុទនឹងឲកញ្ញ៉ោ

៤ . ស្រីទេពកញ្ញាគូទនឹងមហាក្សត្រ

ចប់សង្ខាសកថាដោយសង្ខេបតែប៉ុណ្ណោះ ។

ប្រជុំពាក្យកាព្យ

# ភាគទី ៣

## របស់ពួកស្ត្រីនិងស្តេចក្សត្រិ

## ផ្សេងវោហារគ្នា

# ពាក្យនាំ

ខ្ញុំបានប្រារព្ធឃើញថា ពាក្យកាព្យជាន់មុន មានពួកដែលតែងយ៉ាងល្អគួររក្សាបំរុងទុក ខ្ញុំមានបំណងនឹងចុះពុម្ពមកយូរហើយ តែពុំទាន់បានចុះពុម្ព ព្រោះមានធុរៈឯទៀតច្រើន គ្មានវេលានឹងរើសពាក្យ ៗ

ការដែលនឹងចុះពុម្ពពាក្យកាព្យនោះលំបាកជាងរឿងឯទៀត ដោយ ពាក្យកាព្យសំរាប់ប្រៀនក៏មាន ពាក្យកាព្យជារឿងនិរាសក៏មាន ជាពាក្យកាព្យសង្វាសក៏មាន បើនឹងចុះពុម្ពមានតែរៀបឲ្យជាពួក ៗ ដោយលំដាប់តាមសម័យដែលតែងនោះ ដូចបានពណ៌នាមកក្នុងពាក្យនាំប្រជុំកាព្យភាគទី ១ មករួចហើយ ពាក្យកាព្យទាំងនេះឲ្យឈ្មោះថា "ប្រជុំពាក្យកាព្យ"

ព្រះអង្គម្ចាស់ក្សត្រីមាលិកា

ទុក្ខខ្ញុំជាតិនេះលើសអស់ស្រី  ក្សត្រីមិនជាជាងប៉ុន្មាន
ក្សត្រីធ្លាប់ក្សេមធ្លាប់ស្រាកស្រាន្ត  ម្ដេចលោកពប់អានថាមានទុក្ខ ៗ
ទុក្ខខ្ញុំទុក្ខរស់ទុក្ខរងកម្ម  ពប់ខែពប់ឆ្នាំតែតក្ក
រស់នៅជាមនុស្សមិនពេញមុខ  នេះទើបហៅទុក្ខជាងក្សត្រី ៗ
ក្សត្រីកើតទុក្ខ ៗ សល់សែន  ទុក្ខមែនប៉ុនតែទុក្ខនោះខ្លី
ទុក្ខខ្ញុំដល់អស់ផុតផែនដី  ដល់ណាលោកក្ដីមិនអស់ទុក្ខ ៗ
តែងសារតបសារព្រះទ្រង់បុទ្ធ  ដ្បិតព្រះបពិត្រគិតវេទនា
ដើរទៅខ្ញុំម្ចាស់ឯនាយថា  ទ្រង់ព្រះចិន្ដាស្មោះពិសម័យ ៗ
ខ្ញុំម្ចាស់គិតសព្វហើយគិតគ្នេរ  ពុំឃើញពិតទេណាក្សត្រថ្ងៃ
ហាក់ដូចពេហារកែបវៃណ  មោះក្ដង់ព្រះទ័យមិនដូចថា ៗ
គិតគ្រប់រឹងក្រំដំណាំចិត្ត  ព្រោះដ្បិតឆោតជឿព្រះពចា
បានជាគិតខុសលុះអសារ  អាសូរទុករែងចំរែង ៗ
កាលដើមព្រះទ័យព្រះទសពល  សង្កេតមិនយល់ថាជាកូន
បានជាគិតខុសព្រោះកម្មព្រេង  នាំឲ្យវង្វេងអសារចិត្ត ៗ
កាលមុនខ្ញុំម្ចាស់តាំងចិត្តថា  ប្រសិនមានទារបច្ចាមិត្រ
ចូលជាសត្រូវទីងបពិត្រ  ជីវិតខ្ញុំម្ចាស់តាំងស្ដេចបាន ៗ
សារស្ទួរវេទពីបាទបង  ដឹងទំនងដែតែទុក្ខពុំសុខឡើយ
គិតព្រះរៀមព្រះរួមកាយទុកម្ដើយ  កាលណាឡើយទឹងស្បើយពីទុក ៗ

ពុំសារបៀមមធុរសូរពីរោះ    ស្រយុតទន់អស់ឥន្ទ្រីយទីស្នេហា
រីឯតែទុក្ខមានតែទីតូបចិន្តា    សូមទេពជួយជីវិតអាណិតខ្ញុំ ។
បើបៀមកែអ្នកបានសារសន្សំពិត    ទេវបុទ្ធិពិតឲ្យបានប្រាណកំរម្យ
បើបៀមកែអ្នកជាគូកម្មបន្ទំ    សូមកុំឲ្យខ្ញុំមានចិត្តគិតមេត្រី ។
សារស័ព្ទប្រាប់ពីទុក្ខពីក្តីស្នេហ៍    មែនឬទេឲ្យតែជឿព្រះហឫទ័យ
បើពិតជាមេត្តាដូចសារថ្លៃ    សមទិស្ស័យដែលបានសារប្រើនជាតិ ។
នាំឲ្យយើងទាំងពីរពិតជាមិត្តមូល    បានជួបចូលមូលមេត្រីបដិបត្តិ
សែនអំពល់ខ្វល់ចិត្តគិតអនាថ    ជួបហើយឃ្លាតគឹកកម្មប្រចាំកាយ ។
អនិច្ចាចិត្តអើយសែនចម្លែង    ថ្វាថ្ងៃក្រាបទូលព្រះបរមស្ងួន
គ្រានេះប្រថុយជន្មជីវិត    មិនគិតក្រែងមនុស្សគេនិន្ទា ។
បើមិនយល់ជាព្រះទ័យស្នេហ៍    ប្អូនមិនគិតគ្រោះថ្នាក់កាយា
ព្រោះជឿហរិវង្សទ្រង់មេត្តា    បានជាកនិដ្ឋាប្រថុយប្រាណ ។
បើទ្រង់បានជ្រាបស័ព្ទអក្សរ    សូមលាយព្រះករតបប្រទាន
ឲ្យបានអនុជដឹងដើមដាន    ដោយពិតពណ៌ដ៏មានពីព្រះទ័យ ។

ព្រះអង្គម្ចាស់ក្សត្រី ល. ឥ.

១ អក្ខរាសារស័ព្ទតាប់និទាន    ពីខ្លួនខ្ញុំមានទុក្ខវេទនា
ពុំដែលហៅលោះមួយវេលា    ក្តៅក្តូទ័យាដូចអគ្គី ។
សព្វថ្ងៃសម្តេចព្រះចក្រី    មិនមានប្រណីត្រើដល់ទី

ខំអត់សង្កត់ក្នុងឥតទ្រើយ　　ទឹកកម្មអំពីជាតិមុនមាន ៗ
វិស័យកើតក្នុងបុថុជ្ជន　　ចិត្តមនុស្សលោកលន់ផ្ទើបំពាន
បំបែកញុះញង់ឲ្យហេតុមាន　　ខ្ញុំតាំងប្រណិធានពុំក្រោធា ៗ
សព្វថ្ងៃយកព្រះជាទីពឹង　　ពំនឹងតែគុណព្រះពុទ្ធា
នូវគុណទេវ័នជាន់សួគ៌ា　　គុណមហាក្សត្រាគ្រងក្រុងក្រៃ ៗ
ខ្ញុំនឹកព្រះគុណមិនមានលោះ　　ក្នុងពោះខ្ញុំតាំងចិត្តប្រាស្រ័យ
ផ្ញើកាយជីវិតលើក្សត្រថ្លៃ　　ជាខ្ញុំចមត្រៃតរៀងទៅ ៗ
ឥឡូវឃើញជាក់ប្រាកដណាស់　　ឧបមាដូចផ្ទះគ្មានម្ចាស់នៅ
សមនឹងអន្តរាយវិនាសទៅ　　រំពឹងឲ្យជ្រៅគួរអនិច្ចា ៗ
ទ្រាំរងទុក្ខម្នេញពេញទាំងខ្លួន　　ជាច្រើនឆ្នាំជួនមកហើយណា
មិនដែលរំដោះអស់ទុក្ខា　　ដូចភ្នំសុមេរ៉ុសង្កត់ប្រាណ ៗ
សព្វថ្ងៃខ្លួនអើយដូចមច្ឆា　　ពាក់ពឹងផលសាជាទីឋាន
បើទឹករីងហួតស្ងួតអស់ព្រាណ　　ម្រាងអើយនឹងមានជន្មជីវ៉ា ៗ
ជីវិតនេះពិតគង់ប្រល័យ　　បើក្ស័យទុកឈ្មោះក្នុងពសុធា
ឲ្យល្បីសាយសព្វនគរ　　ពុំបង់សត្យាសេចក្ដីសត្យ ៗ

ព្រះនាងខមស្រីទេពឧប្សរ

ខ្ញុនអើយកើតមកក្នុងសាសនា រងតែវេទនាពន់ពេកក្រៃ
ខ្មាសមនុស្សក្នុងដែនដែនកពាក្រៃ សព្វថ្ងៃមើលមុខគេមិនត្រង់ ៗ
ខំអត់សង្កត់ក្នុងចិន្តា ឡើងគាល់កាលណាស្មារតីប្រុង
គន់មើលចរិតក្សត្រចមពង្ស ជាទ្រង់មេត្តាប្អស់ហើយ ៗ
ពិនិត្យគន់ទៅនៅតែគួរ ថែមមួដិតជងប៉ងគ្មានស្បើយ
ចាប់ទោសថ្ងៃណាមិនដឹងឡើយ ខ្ញុនអើយគង់ត្រូវទៀតមិនខាន ៗ

ព្រះនាងចមស្រីទេពអប្សរ

ពាក្យកាព្យស្តីក្នុងព្រះបរមរាជវាំង លើកតតបគ្នាទៅវិញទៅមកជា សេចក្តីកំសាន្តលេងសប្បាយ :

១ យប់យូរព្រះចន្ទ្រាបស្រទន់ ជំនោរះជោរជន់ព្រះពាយផាត់
តារាះរៀងដោយសង្កាត់ ហោមពេមចន្ទ្រជិតជាបរិវារ ៗ

អ្នកម្នាងផយ៉ម

១ ផ្កាយសេះរះក្រោមផ្កាយកូនមាន់ រះរៀងដោយជាន់ដោយជួរគ្នា
ផ្កាយដូងទេរះច្បាស់ភ្លឺថ្លា ទាំងផ្កាយគជសារះកបផង ៗ

ព្រះអគ្គម្ចាស់ក្សត្រីស្រីអ៊ុក

១ ឯផ្កាយត្រពើបែរសិរសា ចូលរូងនិទ្រាទៅហើយហោង
ផ្កាយកូនមាន់លិចទោជាមួង ផ្កាយយាមរះដួងទៀបបន្ទ្រា ៗ

អ្នកម្នាងគិយ៉ម

ម្ដេចឡើយរះក្រោមពោះអណ្ដើក   ឬព្រះលោកបើកឲ្យអស្ចារ្យ
ឬគ្មានមណ្ឌលឋានត្រឹះឋា   អាកាសព្យោមាទូលាយក្រៃ ។

## ព្រះអង្គម្ចាស់ក្សត្រីស្រអ៊ុក

១ សែនទុក្ខទោមនស្សអស់សង្ឃឹម លន្ទោពលន្ទ៉មលន្ទន់ចិត្ត
ឃ្លាតអន្ដឆ្ងាយទ្រង់មេត្តាស្និទ្ធ   ឯកោទុគតឯកាកាយ ។
ទុក្ខធំក្រៃណែនសែនសង្វេគ   ព្រួយគិតពន់ពេកអម្ចាស់ថ្លៃ
ស្ដេចចេញចាកចោលវាំងវៀងជ័យ   ខ្ញុំមហាអាល័យព្រះបក្ខាព ។
ទឹកដល់ក្ដីក្ដៅក៏ក្ដៅសែន   ទឹកដល់ក្ដីណែនក៏ណែនផ្សា
ទឹកពីកាលសោកក៏សោកា   ទឹកដល់កាលគ្រាប្រាសប្រណី ។
អម្ចាស់ផែនដីថ្លៃកែវអើយ   ស្ដេចយាងទៅហើយចាកភាព
ខ្ញុំសែនទុក្ខក្រំជាំទុក   ទឹកព្រះពជាស្ទើរក្ស័យប្រាណ ។

អ្នកមាតាផយ៉ម

បទយំយាម

# ព្រះករុណាព្រះបាទសម្តេច
# ព្រះនរោត្តម ជាអម្ចាស់ផែនដី
# ក្រុងកម្ពុជា

## បទទី ១

១ អំម្ចាស់ខ្ញុំអើយ    យប់ហើយម្ចាស់ថ្លៃ
ស្តេចផ្ទាប់គន់ៗ    ព្រះទៃនវេទនា ៗ
ឥឡូវម្តេចបាត់    ស្ងប់ស្ងាត់ឱង្ការ
ពេលខ្ញុំភជការ    កំព្រាពេកក្រៃ ៗ
អំម្ចាស់ឧត្តម    យើងខ្ញុំអាល័យ
ព្រេកម្ចាស់ថ្លៃ    រាល់ថ្ងៃខ្លោចផ្សា ៗ
ព្រះអង្គស្តេចទៅ    គង់នៅឋានណា
ចាតុភជិកា    ឬតាវតឹង្ស ៗ
និម្មានរតី    សួគ៌ស្រីត្រៃត្រឹង្ស
ម្ចាស់អើយខ្ញុំប្រឹង    ធ្វើបុណ្យថ្វាយទៅ ៗ

ព្រះអង្គស្តេចឃ្លាត សម្បត្តិខានទៅ
ចោលខ្ញុំម្ចាស់នៅ សោកសៅខ្លោចផ្សា ។
ព្រះចមនគរិន្ទ មិនទ្រង់មេត្តា
គ្រប់ខ្ញុំកជការ តែងតាំងបារមី ។
ធ្លាប់បានសុខគ្រប់ សុខសព្វប្រក្រតី
ព្រះចមបុរី ប្រណីករុណា ។
យើងខ្ញុំឥតទីពឹង វង្វេងខ្លោចផ្សា
គរគក់ទព ជាអាចិន្ត្រៃយ ។
ចិត្តគិតអាល័យ ម្ចាស់ថ្លៃខ្ញុំអើយ
សោកសៅពុំស្បើយ ស្តាយគិតមិនភ្លេច ។

## បទទី ២

១ អំម្ចាស់ឧត្តម យើងខ្ញុំអាល័យ
អគ្រាត្រស្វាត់ក្រៃ ម្ចាស់ថ្លៃធ្លាប់ស្គាល់ ។
យើងខ្ញុំទ្រូតព័ត លើរ័តន៍មណ្ឌល
ធ្លាប់តែងឡើងគាល់ រៀងរាល់វេលា ។
ម្តេចឡើយស្តេចបាត់ សូន្យស្វាត់អសារ

យើងខ្ញុំនោ	យើញតែកន្ទេង ។
យើងខ្ញុំធ្លាប់គាល់	ពល់កត្រីតែង
គន្ធ្រីយបន្ទេង	ព្រះបាទនរបត ។
ឥឡូវស្ដេចទៅ	ស្ថិតនៅសួគ៌ស្រី
ពោលត្បូងគន្ធ្រីយ	ពោលព្រះម្ចាស់ស្ងំ ។
ព្រះអង្គស្ដេចបាត់	ស្ងប់ស្ងាត់ដែនធំ
ពោលទីបន្ទំ	ពោលខ្ញុំកដការ ។

បទទី ៣

១ អំម្ចាស់ខ្ញុំអើយ	ព្រឹកហើយម្ចាស់ខ្ញុំ
ធ្លាប់តើនបន្ទំ	យើងខ្ញុំបំរើ ។
បំរុងប្រតិបត្តិ	ចមក្សត្រប្រសើរ
ភ្នាក់នោរសោរតើ	បំរើផ្គូផ្គង ។
ពេលស្រប់ព្រះកក្រ	ត្រជាក់ថ្វាយផង
ពល់ពេលតែងទ្រង់	គង់ក្ងនវាំង ។
យើងខ្ញុំបំរើ	តែងដើរកិលការ
ពេលសោយភោជនា	ស្រិង្គារលើកថ្វាយ ។

ឥឡូវព្រះអង្គ　　ស្ដេចបង់យាតឆ្ងាយ
ពោលយើងនៅអាយ　　ទាំងឡាយកំព្រា ៗ
ព្រះគុណកែវអើយ　　ស្ដេចហើយតែថា
ស្ដេចស្ថិតស្ថានណា　　ស្ថាននោះសុខហោង ៗ
ព្រះបមម្កុជវង្ស　　ទ្រង់កាត់បាបផង
កាត់គ្រប់បំណាង　　ឆ្លងទៅនិព្វាន ៗ
ទ្រង់សាងសីលសុទ្ធ　　តាមពុទ្ធទ្ធនាន
ស្អាងផលឲ្យមាន　　ស្អាងវត្តព្រះកែវ ៗ

## បទទី ៤

១ អំម្ចាស់ថ្លៃខ្ញុំ　　ធ្លាប់ជុំធ្លាប់ស្រស់
ខ្ញុំម្ចាស់ធ្លាប់ផ្គង់　　ប្រាណប្រុងថ្វាត់ថ្វាយ ៗ
ថ្ងៃត្រង់ធ្លាប់សោយ　　ក្រស្វាយទាំងឡាយ
សៀលស្បៀសាយណ្ហ៍　　ធ្លាប់ថ្វាយទឹកស្រង់ ៗ
អស់ពួកយើងខ្ញុំ　　បង្គំប្រញប្រុង
អជ្រាត្រព្រះអង្គ　　ធ្លាប់ទ្រង់សុគល ៗ
ពេលប់ធ្លាប់គង់　　ត្រិះទ្រង់យោបល់
សរពើកិច្ចកល　　ដំកល់សាសនា ៗ

ពេលព្រឹកម៉ោងបី ចេញស្ដុកផការ
ដោះទុក្ខប្រជា ជនផងសព្វសាយ ៗ
ព្រះអង្គស្ដេចថ្វាត់ សម្បត្តិទាំងឡាយ
ចោលទុកនៅអាយ រៀងកាយត្រៀបត្រា ៗ
នៅតែដំណែល ដែលទ្រង់ចេតនា
បាត់ព្រះចេស្តា ព្រះមហាចមពៅ ៗ
ស្ដេចគង់វង្វេង យើងខ្ញុំកក់ក្ដៅ
ព្រះអង្គស្ដេចទៅ យើងនៅខ្លោចផ្សា ៗ
ព្រះចមម្កុដភព ធ្លាប់ទ្រង់ករុណា
ស្ដេចទៅស្ថានណា តាមហែមិនដល់ ៗ
ធ្លាប់តែងថ្វាយថ្វាត់ ចមក្សត្រថ្កើងថ្កល់
ឥឡូវពុំយល់ អំម្ចាស់ថ្លៃឡើយ ៗ
ព្រះចមក្រុងក្រៃ ម្ចាស់ថ្លៃខ្ញុំអើយ
ព្រះអង្គជាត្រើយ ត្រយម្លប់យើងខ្ញុំ ៗ
ម្លប់មួយឲ្យមាន ម្លប់មួយឲ្យធំ
ម្លប់មួយជាព្រហ្ម អស់ខ្ញុំភផការ ៗ
ព្រះចមហរិវង្ស ធ្លាប់គង់ព្រះពន្លា

ព្រះទីនាំងមេខល្ងា　　អំម្ចាស់កែវអើយ ។
យើងធ្លាប់ប្រតិបត្តិ　　គ្មានខាតខានឡើយ
ស្តេចយាងបាត់ហើយ　　គ្មានស្បើយក្រៀមក្រំ ។
ប្រាណព្រួយគ្មានល្ហែ　　ទុក្ខតែគប់ក្រុម
ម្ចាស់អើយឲ្យខ្ញុំ　　បំរើលោកណា ។
អំម្ចាស់ស្តេចទៅ　　យើងនៅកំព្រា
ដូចសត្វព្រាត់មាតា　　វេទនាពន់ពេកក្រៃ ។
វិមានចក្រពត្តិ　　នារីរ័តន៍សោភា
ទក្សិណទិសា　　ទេពវិជ្ជ័យ ។
ព្រះមហាមន្ទីរ　　វិមានអាកាស
ចន្ទឆាយ៉ាប្រពៃ　　មុខដាប់ឧត្តម ។
ព្រះបរិត្តវិមាន　　សម្រានភិរម្យ
កេងគង់សាសម　　កេងរ័តន៍អស្សុព្រា ។
ព្រះទីន័ងតុស្តី　　កោដទីកល្បា
បញ្ញង់រតនា　　ឧកាសសោភ័ណ ។
ធ្លាប់គាល់ធ្លាប់គង់　　ធ្លាប់ទ្រង់ករុណា
អស់ខ្ញុំពដការ　　សុខសព្វប្រក្រតី ។
ព្រះអគ្គជាឆ័ត្រ　　មេស្រណ្តបុរី

ពុំនោះសោកនៃ ដូចម្លប់ពោធិ៍មាស ។
បើកបាំងត្រៃឈ សុខក្រៃគ្រប់ក្រស្ត
ទុក្ខភ័យវិនាស ដោយបុណ្យបារមី ។
ព្រះម្កុដកែវខ្ញុំ នៅចាំថ្មី ។
ធ្លាប់ទ្រង់ប្រណី សុខក្រៃពេកក្តាត់ ។
អំម្ចាស់លើត្បូង ទ្រង់ខ្ញុំក្រំក្រែ
ដោយអំម្ចាស់ថ្ងៃ ស្តេចចាកម្យេរដ្ឋ ។
សោយវិលាលៃ ពោលវៀនដៃថ្វាត់
ស្តេចសូន្យបង់បាត់ ពុំយល់ព្រះអង្គ ។
១ ព្រះម្លប់ពោធិ៍មាសថ្ងៃ អំម្ចាស់សិរីយើងខ្ញុំអើយ
ស្តេចយាងទៅបាត់ហើយ ព្រះជាគ្រើយម្លប់យើងខ្ញុំ ។
ស្តេចទៅស្ថិតស្ថានណា ពោលបណ្តាខ្ញុំគ្រប់ក្រម
ពោលទុកស្ងាត់ផែនដី ពោលបរមនិវេសរ៍ង ។
ពោលស្នួនដំណាក់ច័ន្ទ ទែនសោភ័ណព្រះទីន័ង
ស្មុគច័ត្រែគន់បល្ល័ង្ក សឹងទ្រង់គាំងកែងនៅឡើយ ។
យើងខ្ញុំសែនសោកស្តាយ ក្តុលក្តុងកាយពុំល្ហែល្ហើយ
ព្រះគុណធួនខ្ញុំអើយ កាលណាឡើយទឹងបានយល់ ។
ឃើញតែទីដំណែល ដែលទ្រង់ស្ពានសព្វកុសល

ទឹងព្រះរាជមណ្ឌល យើងខ្ញុំយល់ស្រណោះក្រៃ ៗ
ទុក្ខធំក្រៃសព្វសាច់ ដូចទឹងផ្ដាច់ជីពជន្មក្ស័យ
ពេកនឹកអាល័យ អំម្ចាស់ថ្ងៃពល់វេលា ៗ
ខ្ញុំម្ចាស់ធ្លាប់បំរើ គាល់គក់ជើងតបាទា
ធ្លាប់ផាត់រូតសន្ទិយា ចាត់ចែងការសេវតើថ្វាយ ៗ
ធ្លាប់បោសទីបន្ទំ ថ្វាយស្ដេចផ្ទំកិរិយាកាយ
ពេលតើនទ្រង់ព្រះឆាយ យើងខ្ញុំថ្វាយគ្រឿងគន្ធា ៗ
ពេលស្រង់គន្ធរស ធ្លាប់ខាត់ដុសព្រះបាទា
ពេលសោយព្រះក្រយា ស្នំស្រិង្គារគាល់ជៀងកាយ ៗ
មានទុក្ខធ្លាប់ជ្រែកបុណ្យ ដោយព្រះគុណបានសប្បាយ
មានទោសផងទាំងឡាយ បានសោយដោយបារមី ៗ
សម្ដេចព្រះចមក្រុង ភ្លឺគ្រងផ្ទែរាជបុរី
ដូចច័ន្ទពេញបូណ៌មី សព្វមន្ត្រីរាជសេនា ៗ
ធ្លាប់ថ្នមរាជបុត្រី ធ្លាប់ប្រណីរាជបុត្រា
ម្ដេចឡើយកាត់ស្នេហា ពុំមេត្តាខ្ញុំទាំងឡាយ ៗ
ម្ចាស់អើយព្រះរាជបុត្រ ស្ពានសីលសុទ្ធបង្គំថ្វាយ
ស្ដេចទៅគង់សួគ៌ិនាយ សុខព្រះកាយបានសម្រាន ៗ

អ្នកមាតាជំយ៉មតែង

# វេយ្យាករណ៍សំស្ក្រឹតភាគទី ៣

## របស់ព្រះវិសុទ្ធិវង្ស (ធ)

ភាគទី ៣

# នាមវិធី

ក្នុងនាមវិធីនេះ មានសេចក្ដីត្រូវគ្នាដោយច្រើននឹងរបៀបសេចក្ដីក្នុងវេយ្យាករណ៍បារាំង (អ្នកសិក្សាមានសេចក្ដីត្រូវការចង់ដឹងដោយសព្វគ្រប់ ប្អូរមើលក្នុងសៀវភៅរក្ខាយនូបត្ថម្ភកភាគទី ១ ត្រង់នាមនិទ្ទេស តាំងពីលេខ ៣៤ ជាដើមទៅ) ។ ក្នុងនាមវិធីនេះ នឹងពោលដោយសង្ខេប ចំពោះសេចក្ដីណាដែលមានប្រយោជន៍ខាងពោលមិនបាន នឹងសេចក្ដីដែលប្លែកខុសពីរបៀបក្នុងបារាំង ដូចសេចក្ដីតទៅនេះ:

## លិង្គ

(៤៨) នាមសព្ទ មាន លិង្គ ៣ គឺ បុំលិង្គ "ភេទប្រុស" ១, ស្ត្រីលិង្គ "ភេទស្រី" ១, នបុំសកលិង្គ "មិនមែនភេទប្រុសមិនមែនភេទស្ត្រី" ១ ។

## វិបន

(៤៩) មាន វិបន ៣ គឺ ឯកវិបន ១ ទ្វិវិបន ១ ពហុវិបន ១ ។

វចនដែលប្រាប់ចំនួនតែមួយ ហៅថា ឯកវចន សម្រាប់ប្រើចំពោះអ្វីៗ ដែលមានតែមួយ ដូចពាក្យថា ឬភូមៈ បុរុឞះ "ប្រុស" គឺប្រុស ១ នាក់; វុត្តៈ វ្ឫក្សះ "ដើមឈើ" គឺឈើ ១ ដើម ។ល។ វចនដែលប្រាប់ចំនួនតែពីរ ហៅថា ទ្វិវចន សម្រាប់ប្រើចំពោះអ្វីៗ ដែលមានត្រឹមតែពីរ ឬដែលជាគូ ដូចពាក្យថា ឃ្ញុត្តៅ ហស្តៅ "ដៃទាំងពីរ"; ឡុត្តៅ អក្សី "ភ្នែកទាំងពីរ"; ឡុដ្ឋៅ អឝ្វៅ "សេះទាំងពីរ" ។ល។ វចនដែលប្រាប់ចំនួនច្រើនហៅថា ពហុវចន សម្រាប់ប្រើចំពោះអ្វីៗ ដែលមានចំនួនច្រើនតាំងពី ៣ ឡើងទៅ ដូចពាក្យថា ឬភូបាៈ បុរុឞាះ "ប្រុសទាំងឡាយ" គឺប្រុសច្រើននាក់; វុត្តាៈ វ្ឫក្សាះ "ឈើទាំងឡាយ" គឺឈើច្រើនដើម ។ល។

នាមសព្ទទាំងអស់ ត្រូវប្រើវចន ៣ យ៉ាងនេះជាគ្រឿងសំគាល់ តែដែលនឹងសង្កេតឲ្យស្គាល់វចនទាំង ៣ យ៉ាងនោះ ត្រូវកំណត់តាមវិភត្តិនាមដែលប្រកបភ្ជាប់នៅទីបំផុតខាងចុងនៃនាមសព្ទ, ទើបនឹងអាចដឹងថា ជា ឯកវចន, ទ្វិវចន ឬ ពហុវចន បាន ។

# វិភត្តិ

(៨៦) វិភត្តិ មាន ៧ ឈ្មោះ គឺ ប្រថមា, ទុតិយា, តតិយា, ចតុត្ថី, បញ្ចមី, ឆដ្ឋី, សត្តមី[1] ថែម សម្ពោធន[2] (បា. អាលបន) ១ មកទៀតបន្ថែមជា ៨ តែសម្ពោធននេះលោកមិនរាប់បញ្ចូលថាជាវិភត្តិទេ ព្រោះជាប្រថមាវិភត្តិនោះឯង គ្រាន់តែមានវិធីប្រើប្លែកគ្នាប៉ុណ្ណោះ ។

## ពាក្យប្រែរបស់វិភត្តិ

វិភត្តិទាំងនេះ សឹងមានពាក្យសម្រាប់ប្រែច្រើនយ៉ាងផ្សេងៗគ្នា, មានអត្ថផ្សេងគ្នា, ប្រព្រឹត្តទៅតាមទំនងសេចក្តី ឥតមានច្រឡំគ្នាឡើយ មានទំនងល្អមអាចឲ្យកំណត់សំគាល់បាន ដូចសេចក្តីតទៅនេះ:

១. **ប្រថមាវិភត្តិ** ជាវិភត្តិសំដែងនូវសេចក្តីជាបទប្រធាន ជាអ្នកសម្រេចនូវអំពើខ្លួនឯង ឬ ប្រើគេឲ្យសម្រេចនូវអំពើ ប្រែថា "រី ..."

---

១ វិភត្តិទាំង ៧ នេះ, បើប្រែមកជាភាសាខ្មែរថា វិភត្តិទី ១, ទី ២, ទី ៣, ទី ៤, ទី ៥, ទី ៦, ទី ៧, (បើតាមរបៀបវេយ្យាករណ៍សំស្ក្រឹតរបស់អ្នកប្រាជ្ញបារាំងសែស គេហៅឈ្មោះវិភត្តិទាំង ៧ នេះ តាមភាសាបារាំងសែស: វិភត្តិទី ១ ថា NOMINATIF, ទី ២ ថា ACCUSATIF, ទី ៣ INSTRUMENTAL, ទី ៤ DATIF, ទី ៥ ABLATIF, ទី ៦ GÉNITIF, ទី ៧ LOCATIF) ។ ២ ប្រែថា ញុំាងអ្នកឯទៀតឲ្យភ្ញាក់, ឲ្យដឹង គឺ ហៅគេឲ្យដឹងខ្លួន (បារាំងថា VOCATIF) ។

ឧទាហរណ៍:

ព្រាហ្មណោ គេហំ ចជិត្វា វនំ គច្ឆតិ *ព្រាហ្មណោ គេហំ ចជិត្វា វនំ គច្ឆតិ* "*ព្រាហ្មណ៍ លះបង់ នូវផ្ទះ (របស់ខ្លួន) ទៅ កាន់ព្រៃ*", សូតោ អស្សំ រថំ វាហយតិ *សូតោ អស្សំ រថំ វាហយតិ* "*សារថី ញ៉ាំងសេះ ឲ្យនាំទៅ នូវរថ*" ។ល។

២. ទុតិយា-វិភត្តិ *ជាវិភត្តិសំដែងនូវសេចក្ដីជាអំពើដែលគេត្រូវធ្វើ, ប្រែថា "នូវ ..."; ជាដំណើរ ឬ ជាទីទៅដល់, ប្រែថា "កាន់ ..."; ជាអ្នកទទួលសម្រេចនូវអំពើដែលគេប្រើឲ្យធ្វើ, ប្រែថា "ញ៉ាំង ..."; ជាទីប្រព្រឹត្តទៅរបស់ហេតុ, ប្រែថា "អស់ ..."; ជាទីទទួលពាក្យដែលគេនិយាយចំពោះខ្លួន, ប្រែថា "នឹង ឬ ចំពោះ ..."; ជាកិរិយាវិសេសន គឺធ្វើកិរិយាឲ្យមានសេចក្ដីប្លែក ឬធ្វើឲ្យមានអាការដូចជាវិសេសននៃកិរិយា សព្ទតែងគ្មានពាក្យប្រែរបស់វិភត្តិឡើយ ។*

ឧទាហរណ៍:

ធម្មំ ទេសេតិ ភិក្ខុ *ធម្មំ ទេសេតិ ភិក្ខុ* "*ភិក្ខុ សំដែង នូវធម៌*"; នគរំ គតោ *នគរំ គតោ* "*(គេ) ទៅហើយ កាន់នគរ*"; សិស្សេ វិជ្ជំ សិក្ខាបយតិ *សិស្សេ វិជ្ជំ សិក្ខាបយតិ*, "*(អាចារ្យ) ញ៉ាំងសិស្សទាំង-*

ឡាយឲ្យសិក្សា នូវវិទ្យា"; តីណិមាសានិគាមេ វសតិ ត្រីនិ មាសានិ គ្រាមេ វសតិ "(គេ) នៅ ក្នុងស្រុក អស់ ៣ ខែ", យោជនំ គច្ឆតិ យោជនំ គច្ឆតិ "(គេ) ទៅ អស់មួយយោជន៍"; ភគវន្តំ ឯតទវោច ភគវន្តមេតទវោចត៑ "(គេ) បានពោលហើយ នូវពាក្យនេះ នឹងព្រះដ៏មានព្រះភាគ"; កោសំ គច្ឆតិ ក្រោឝំ គច្ឆតិ "(គេ) ទៅ ហើស្ង", សុខំ សយតិ សុខំ ឝយតេ "(គេ) ដេក សប្បាយ", ពហុំ ភុញ្ជតិ ពហុំ ភក្ស្យតិ "(គេ) ស៊ី ច្រើន" ។ល។

៣- តតិយា-វិភត្តិ ជាវិភត្តិសំដែងនូវសេចក្ដី ជាគ្រឿងសម្រេចនូវអំពើ, ប្រែថា "ដោយ..."; ជាផ្លូវ ឬ ជាទំនង, ប្រែថា "ដោយនូវ..., ដោយសារ..." ឬ "តាម..."; ជាអ្នកសម្រេចនូវអំពើខ្លួនឯង ក្នុងប្រយោគជាកម្មវាចក ឬ ភាវវាចក, ប្រែថា "គឺ... ឬ ដែល..."; ជាហេតុ, ប្រែថា "ហេតុ..., ព្រោះ... ឬ ព្រោះតែ..."; ជាអាការហាក់ដូចជាបទវិសេសនរបស់បទដែលមានវិភត្តិផ្សេងគ្នា, ប្រែថា "មាន..."; ជាគ្រឿងប្រកបជាមួយ, ប្រែថា "ដោយ... ឬ នឹង..." (ត្រង់ទីបំផុតនេះច្រើនប្រកបជាមួយនឹងសហ ឬ សទ្ធឹ) ។

## ឧទាហរណ៍ៈ

ทณฺเฑน สปฺปํ ตาฬยติ *ទណ្ឌេន សប្បំ តាឡេតិ "(គេ) វាយ នូវពស់ ដោយដំបង"*; รสฺมินา วิโรจติ จนฺโท: *រស្មិនា វិរោចតិ ចន្ទ្រៈ "ព្រះចន្ទ្រ រុងរឿង ដោយរស្មី"*; อาหาเรน ชีวติ *អាហារេន ជីវតិ "(សត្វលោក) រស់នៅ ដោយសារអាហារ"*; มคฺเคน จรติ *មគ្គេន ចរតិ "(គេ) ដើរទៅ តាមផ្លូវ"*; อยํ ธมฺโม วิญฺญูหิ น ครหิตพฺโพ: *អយំ ធម្មោ វិញ្ញូហិ ន គរហិតព្វោះ "ធម៌ នេះ គឺអ្នកមិនត្រូវតិះដៀលឡើយ"*; น ปุเนวํ ตยา กาตพฺพํ *ន បុនេវំ តយា កាតព្វំ "គឺអ្នកមិនត្រូវធ្វើយ៉ាងនេះទៀតឡើយ"*; ขุทาย ทุกฺขํ ปาปุณาติ สร: *ក្សុធា ទុក្ខំ ប្រាប្តោតិ សរៈ "វាដល់ នូវសេចក្តីលំបាក ព្រោះសេចក្តីស្រេកឃ្លាន"*; มนสา เจ ปสนฺเนน ภาสติ วา กโรติ วา *មនសា ចេ បសន្នេន ភាសតិ វា ករោតិ វា "បើ (បុគ្គល) មានចិត្ត ជ្រះថ្លាហើយ ពោលក្តី ធ្វើក្តី"*; ราชา ปุตฺเตหิ สห นิสินฺโน: *រាជា បុត្តេហិ សហ និសិន្នោះ "ព្រះរាជា គង់មួយអន្លើ ដោយបុត្រទាំងឡាយ" ឬថា "ព្រះរាជា គង់ ជាមួយនឹងបុត្រទាំងឡាយ" ។ ល ។*

៤ ចតុត្ថី-វិភត្តិ *ជាវិភត្តិសំដែងនូវសេចក្តី ជាទីឲ្យ ឬ ជាទីទទួលនូវអំណោយ, ប្រែថា "ដល់...."; ជាទីពឹង, ជាទីផ្ញើ*

ឬ ជាទីបញ្ចូន, ប្រែថា "ដើម្បី... ឬ បំរុង..."; ជាទីត្រូវគេប្រទូស្ត, គេបៀតបៀន ប្រែថា "ចំពោះ... ឬ ទឹង..." ។

## ឧទាហរណ៍:

ទលិទ្ទាយ ធនំ ទទាតិ ទលិទ្ទាយ[១] ធនំ ទទាតិ "(គេ) ឲ្យ នូវទ្រព្យ ដល់អ្នកទ័លក្រ[១]"; ភិក្ខុស្ស អាវាសំ ករោតិ ភិក្ខុស្ស[២] អាវាសំ ករោតិ "(គេ) កសាង នូវអាវាស ដើម្បី[២] ឬ បំរុង[២] ភិក្ខុទាំងឡាយ"; ន ទលិទ្ទាយ ទុព្ភយាមិ ន ទលិទ្ទាយ[៣] ទុព្ភយាមិ "(បុគ្គល) មិនគប្បីប្រទូស្ត ចំពោះ[៣] ឬ ទឹងអ្នកទ័លក្រ[៣]ឡើយ" ។ល។

៤- បញ្ចមី-វិភត្តិ ជាវិភត្តិសំដែងនូវសេចក្តី ជាដែនចេញ ឬជាដែនដែលគេត្រូវវៀរលែង, ប្រែថា "អំពី... ឬចាក...", ពុំនោះប្រែថា "ដល់..." ដូចចតុត្ថី-វិភត្តិ (នេះ តែងប្រើប្រកបជាមួយនឹងរូបធាតុដែលប្រែថា "ខ្លាច", ថា "ហាមឃាត់" ជាដើម, ពុំនោះប្រកបនឹងនិបាតសព្ទ ដែលប្រែថា "ចាប់ដើម ឬ តាំងតែ", ថា "វៀរ" ដូច្នេះជាដើម); ជាដែនប្រៀបធៀបឲ្យដឹងថាលើសឬថយជាងគ្នា, ប្រែថា "ជាង..."; ជាមូលហេតុ គឺជាដើមហេតុ, ប្រែថា "ហេតុ... ឬ ព្រោះ..." ។

## ឧទាហរណ៍ៈ

लुब्धकाद्बिभेति លុព្ធកាទ៑ ពិភេតិ "(ឯង) ខ្លាច អំពីព្រានព្រៃ"; मरणाद्भयम् មរណាទ៑ ភយម៑ "ភ័យ អំពីសេចក្ដីស្លាប់"; इयं कन्या मरणात्पितुर्गृहे तस्थौ ឥយំ កន្យា មរណាត៑ បិតុរ៑ គ្ឫហេ តស្ថៅ "នាងកញ្ញា នេះ ស្ថិតនៅ ក្នុងផ្ទះ នៃបិតា រហូត ដល់ស្លាប់"; कुमारकालात्प्रस्थाय កុមារកាលាត៑ ប្រស្ថាយ "តាំងតែ អំពីក្មេងតូច"; इन्द्रान्महत्तरः ឥន្ទ្រាន៑ មហត្តរះ "(គេ) ធំក្រាន់បើ ជាងព្រះឥន្ទ្រ"; अविद्याप्रत्ययात्संस्काराः អវិទ្យាប្រត្យយាត៑ សំស្ការះ "សំស្ការ (សង្ខារ) ទាំងឡាយ (កើតមានព្រម) ព្រោះអវិទ្យា (អវិជ្ជា) ជាបច្ច័យ" ។ល។

៦- ឆដ្ឋី-វិភត្តិ ជាវិភត្តិសំដែងនូវសេចក្ដី ជាគ្រឿងជាប់ ដោយម្ចាស់របស់, ប្រែថា "នៃ... ឬ របស់..."; ជាទីទទួល អំណោយ, ប្រែថា "ដល់..." ដូចជាចតុត្ថី-វិភត្តិ; ជាអំពើដែលគេ ត្រូវធ្វើ, ប្រែថា "នូវ..." ដូចទុតិយាវិភត្តិ (តែត្រង់នេះប្រកបចំពោះ តែនឹងក្ឫតនាម) ។ល។

## ឧទាហរណ៍:

वृक्षस्य फलानि វ្ឫក្សស្យ ផលានិ "ផ្លែទាំងឡាយ នៃឈើ"; पितुः पुत्राः បិតុះ បុត្រាះ "កូនទាំងឡាយ របស់បិតា"; पितुर्ददाति पुत्रः បិតុរ៑ ទទាតិ បុត្រះ "កូន ជូន (នូវអាហារ) ដល់ បិតា"; धनस्य परित्यागः ធនស្យ បរិត្យាគះ "កិរិយាបរិច្ចាគ នូវទ្រព្យ" ។ល។

៧. *សប្តមី-វិភត្តិ* ជាវិភត្តិសំដែងនូវសេចក្តី ជាទីកន្លែងដែលអាស្រ័យនៅ, ប្រែថា "ក្នុង..."; ជាទីកន្លែងដែលទៅដល់ ប្រែថា "កាន់..." មានទំនងដូច ទុតិយាវិភត្តិ (តែនេះមានប្រើម្តង ៗ ក្នុងកាលដែលប្រកបនឹងរូបធាតុជាសកម្ម); ជាកាល, ជាពេល, ប្រែថា "ក្នុង..."; ជាទីបំរុង, ជាទីទ្រ, ប្រែថា "លើ..., ឰដ៏..., ត្រង់..., នា...; ជាទីជិត, ជាទីប្រប, ប្រែថា "ជិត... ឬ ទៀប..." ។ល។

## ឧទាហរណ៍:

गृहे वसति គ្ឫហេ វសតិ "(គេ) នៅ ក្នុងផ្ទះ"; जले मत्स्या वसन्ति ជលេ មត្ស្យា វសន្តិ "ត្រីទាំងឡាយ នៅ ក្នុងទឹក"; देवेषु गच्छति ទេវេឞុ គច្ឆតិ "(គេ) ទៅ កាន់ស្ថាននៃទេវតាទាំងឡាយ";

តស្មិំ សមយេ អញ្ញតរោ យតិ ពារាណសីនគរេ វសតិ តស្មិំ សមយេ ភិក្ខុ យតិ ពារាណសី-នគរេ វសតិ "ក្នុងសម័យនោះ ភិក្ខុមានសេចក្ដីព្យាយាម (យតិ) ១ រូប បាននៅហើយក្នុងក្រុងពារាណសី"; អថ ភគវា និសីទតិ អាសនេ ភគវា និសីទតិ "ព្រះដ៏មានព្រះភាគ បានគង់ហើយ លើអាសន"; រុក្ខស្ស មូលេ និសីទតិ រុក្ខស្ស មូលេ សីទតិ "(ភិក្ខុ) អង្គុយ ទៀបគល់ នៃឈើ"; ភគវា សាវត្ថិំ វិហរតិ ជេតវនេ សាវត្ថិំ វិហរតិ ជេតវនេ" (ព្រះដ៏មានព្រះភាគ) គង់នៅក្នុងវត្តជេតពន ជិតក្រុងសាវត្ថី" ។ល។

៨ — សម្ពោធន ជាប្រថមាវិភត្តិ មានទំនងសេចក្ដីដោយឡែកផ្សេង, ជាពាក្យសម្រាប់ហៅអ្នកឯទៀតឲ្យភ្ញាក់, ឲ្យដឹងខ្លួន គឺ ស្រែកហៅ ឬ ពោលចំពោះ, ប្រែថា "បពិត្រ..., ម្នាល..., នែ..., ហៃ..." តាមគួរដល់សេចក្ដីខ្ពស់ទាប ឬ សេចក្ដីគោរពនិងមិនគោរព ។ តាមទម្លាប់ភាសាខ្មែរ ត្រូវប្រែថា" បពិត្រ.. ជាពាក្យគោរព; ត្រូវប្រែថា "ម្នាល, នែ, ហៃ" ជាពាក្យមិនគោរព ។

នាមសព្ទ កាលដែលប្រកបដោយប្រថមាវិភត្តិត្រូវ សម្ពោធន ខ្លះ កាលប្រែចំពោះតែសព្ទមួយៗ ដូច ទេវ, រាជ ដូច្នេះជាដើម ក៏មាន,

ចួនកាលប្រែឲ្យមានន័យតាមសព្ទដូច ហៃ, ហៃណា, ភោសិ ជាដើម ឲ្យនៅពីខាងដើមនាមសព្ទនោះក៏មាន ។

## ឧទាហរណ៍ៈ

**ជយតុ ភវាន្មហារាជ** ជយតុ ភវាន៑ មហារាជ១ "បពិត្រមហារាជ សូមព្រះអង្គដ៏ចំរើន ទ្រង់ឈ្នះ"; **ធម៌ វោ ភិក្ខវោ ទេសេមិ** ធម៌ វោ ភិក្ខវោ២ ទេសេមិ" ម្នាលភិក្ខុទាំងឡាយ តថាគត នឹងសំដែង នូវធម៌ ដល់អ្នកទាំងឡាយ"; **មា ត្វំ បុត្រ បាបម្** មា ត្វំ បុត្រ៣ បាបម៑ "នែកូន (ឯង) ចូរកុំធ្វើ នូវបាប" ។ល។

(វិភត្តិ ដែលមានពាក្យប្រែផ្សេងៗគ្នា ដូចបានពោលដោយសង្ខេបខាងលើនេះ គឺពោលតាមរបៀបរៀនប្រែពីសំស្ក្រឹតបកជាភាសាខ្មែរ ឲ្យស្របគ្នានឹងរបៀបរៀនប្រែបាឡី ព្រោះសំស្ក្រឹតនឹងបាឡីមានទំនងដូចគ្នា, តែកាលបើប្រែពីសំស្ក្រឹត រៀបរៀងជាសេចក្ដីសម្រាយឬសំដីដែលគេនិយាយគ្នាសព្វថ្ងៃក៏ដោយ គេអាចកាត់ពាក្យប្រែរបស់វិភត្តិដូចពាក្យថា រី, នូវ, កាន់, ញុំាង ជាដើម ចោលចេញខ្លះ ទុកឲ្យនៅខ្លះ តាមសមគួរដល់ទម្លាប់ភាសាខ្មែរ, ដូចមានសេចក្ដីពន្យល់ក្នុងសៀវភៅកច្ចាយនូបត្ថម្ភក ភាគ ១ ត្រង់ទំព័រ ៨៧ ដោយសព្វគ្រប់ (ស្រាប់) ។

## ការាន្ត

(៥៧) អក្សរជាទីបំផុត គឺស្រៈក្តី ព្យញ្ជនៈក្តី ដែលមានក្នុងទីបំផុត នៃនាមសព្ទ ហៅថា ការាន្ត (< ការ + អន្ត) ។ នាមសព្ទទាំងឡាយ បើចែកតាមការាន្តជាគោលដើម មានពីរយ៉ាង គឺនាមសព្ទជា ស្រៈការាន្ត ១ ជា ព្យញ្ជនការាន្ត ១ ; នាមសព្ទដែលមានស្រៈជាទីបំផុត ហៅថា ស្រៈការាន្ត, ដែលមានព្យញ្ជនៈជាទីបំផុត ហៅថា ព្យញ្ជនការាន្ត ។

## ស្រៈការាន្ត

ស្រៈជាទីបំផុតនៃនាមសព្ទនោះ មានប្រាំយ៉ាង គឺ

១ – នាមសព្ទ ជា អ-ការាន្ត (បុំលិង្គ និង នបុំសកលិង្គ)

២ – " ជា អា-ការាន្ត (ស្ត្រីលិង្គ)

៣ – " ជា ឦ, ឩ ការាន្ត (ស្ត្រីលិង្គ)

៤ – " ជា ឥ, ឧ ការាន្ត (បុំលិង្គ, ស្ត្រីលិង្គ, នបុំសកលិង្គ)

៥ – នាមសព្ទដែលមាន[illegible] ជា ឦ, ឧ, ឩ, ឪ ការាន្ត ។

ចួនកាលប្រើឲ្យមានន័យតាមសព្ទដូច ហេ, ហលា, ភោសិ ជាដើម ឲ្យនៅពីខាងដើមនាមសព្ទនោះក៏មាន ។

## ឧទាហរណ៍ៈ

**ជយតុ ភវាន្មហារាជ** *ជយតុ ភវំ មហារាជ*[១] "បពិត្រ[១] មហារាជ សូមព្រះអង្គដ៏ចំរើន ទ្រង់ឈ្នះ"; **ធម្មំ វោ ភិក្ខវេ ទេសេស្សាមិ** *ធម៌ វោ ភិក្ខវេ[២] ទេស្សាមិ* "ម្នាលភិក្ខុទាំងឡាយ តថាគត នឹងសំដែងនូវធម៌ ដល់អ្នកទាំងឡាយ"; **មា ត្វំ បុត្ត បាបម្** *មា ត្វំ បុត្ត[៣] បា-បំ* "នែកូន[៣] (ឯង) ចូរកុំធ្វើ នូវបាប" ។ល។

(វិភត្តិ ដែលមានពាក្យប្រែផ្សេង ៗ គ្នា ដូចបានពោលដោយសង្ខេបខាងលើនេះ គឺពោលតាមរបៀបរៀនប្រែពីសំស្រ្កឹតមកជាភាសាខ្មែរ ឲ្យសមគ្នានឹងរបៀបរៀនប្រែបាឡី ព្រោះសំស្រ្កឹតនឹងបាឡីមានទំនងដូចគ្នា, តែកាលបើប្រែពីសំស្រ្កឹត រៀបរៀងជាសេចក្ដីសម្រាយ ឬសំដីដែលគេនិយាយគ្នាសព្វថ្ងៃក៏ដោយ គេអាចកាត់ពាក្យប្រែរបស់វិភត្តិដូចពាក្យថា រី, នូវ, កាន់, ញ៉ាំង ជាដើម ចោលចេញខ្លះ ទុកឲ្យនៅខ្លះ តាមសមគួរដល់ទម្លាប់ភាសាខ្មែរ, ដូចមានសេចក្ដីពន្យល់ក្នុងសៀវភៅកច្ចាយនរូបត្ថម្ភក ភាគ ១ ត្រង់ទំព័រ ៨៧ ដោយសព្វគ្រប់ (ស្រាប់) ។

## ការាន្ត

(៤៧) អក្សរជាទីបំផុត គឺស្រៈក្តី ព្យញ្ជនៈក្តី ដែលមាននៅទីបំផុតនៃនាមសព្ទ ហៅថា ការាន្ត (< ការ + អន្ត) ។ នាមសព្ទទាំងឡាយ បើចែកតាមការាន្តជាគោលដើម មានពីរយ៉ាង គឺនាមសព្ទជា ស្រៈការាន្ត ១ ជា ព្យញ្ជនការាន្ត ១ ; នាមសព្ទដែលមានស្រៈជាទីបំផុត ហៅថា ស្រៈការាន្ត, ដែលមានព្យញ្ជនៈជាទីបំផុត ហៅថា ព្យញ្ជនការាន្ត ។

## ស្រៈការាន្ត

ស្រៈជាទីបំផុតនៃនាមសព្ទនោះ មានប្រាំយ៉ាង គឺ

១ – នាមសព្ទ ជា អ-ការាន្ត (បុំលិង្គ នឹង នបុំសកលិង្គ)

២ – " ជា អា-ការាន្ត (ឥត្ថីលិង្គ)

៣ – " ជា ឦ, ឥ ការាន្ត (ឥត្ថីលិង្គ)

៤ – " ជា ឥ, ឧ ការាន្ត (បុំលិង្គ, ឥត្ថីលិង្គ, នបុំសកលិង្គ)

៥ – នាមសព្ទដែលមានស្រៈក្រៅ ១ ជា ឦ, ឩ, ឫ, ឱ, ឪ ការាន្ត ។

## វ្យញ្ជនការន្ត

វ្យញ្ជនជាទីបំផុតនៃនាមសព្ទ មានច្រើនយ៉ាង គឺ

១ – ធាតុ-នាមសព្ទ[១] មានការន្តផ្សេងៗគ្នា

២ – នាមសព្ទ ជា អន៑-ការន្ត

៣ – ” ជា ឥន៑-ការន្ត

៤ – ” ជា អន្ត៑-ការន្ត

៥ – ” ជា អស៑, ឥស៑, ឧស៑-ការន្ត.

៦ – ” ជា យស៑ និង ឦយស៑-ការន្ត

៧ – ” ជា វស៑-ការន្ត

៨ – ” ជា អរ៑-ការន្ត

## របៀបវិភត្តិ

(៥៨) វិភត្តិទាំងឡាយ, ក្នុងវិធីបំបែកនាមសព្ទដែលមានការន្តផ្សេងៗគ្នានេះ, ឃើញថាមានរបៀបផ្សេងៗ ប្លែកអំពីគ្នា ដោយលើសលុបពេកណាស់ ស្ទើរតែនឹងរកបែបចំណាំឲ្យទៀងទាត់ពុំបាន, ប៉ុន្តែបានពិនិត្យមើលរបៀបវិភត្តិ ដែលភ្ជាប់នឹងនាមសព្ទជា វ្យញ្ជនការន្ត ស្ទើរតែទាំងអស់ទៅ, ក៏អាចកំណត់ទុកថាជាវិភត្តិមានរបៀបទៀងទាត់បាន;

---

១ មើលលេខ ៦៥ ។

ចំណែកខាងវិភត្តិដែលភ្ជាប់នឹងនាមសព្ទជា ស្វរការន្ត នោះ ផ្សេងឆ្ងាយ ចេញពីវិភត្តិដែលភ្ជាប់នឹងនាមសព្ទជា ព្យញ្ជនការន្ត ដោយច្រើន ៗ

## របៀបវិភត្តិ ដែលសំរាប់ភ្ជាប់នឹងនាមសព្ទជា ព្យញ្ជនការន្ត

| | ឯកវចន | ទ្វិវចន | ពហុវចន |
|---|---|---|---|
| | បុំ. ស្ត្រី. នបុំ. | បុំ. ស្ត្រី នបុំ. | បុំ. ស្ត្រី. នបុំ. |
| ប្រថមា | ស៑ ០ (១) | អៅ; ឦ | អស៑; ឥ, |
| ទ្វិតីយា | ម៑; អម៑ ០ | អៅ; ឦ | អស៑; ឥ, |
| ត្រិតីយា | អា | ភ្យាម៑ | ភិស៑ |
| ចតុថ៌ី | ឯ | ភ្យាម៑ | ភ្យស៑ |
| បញ្ចមី | អស៑ | ភ្យាម៑ | ភ្យស៑ |
| ឆដ្ឋី | អស៑ | អោស៑ | អាម៑ |
| សប្តមី | ឥ | អោស៑ | សុ |
| សម្ពោធន | ០ | អៅ | អស៑ |

នាមសព្ទដែលជា ស្វរការន្ត មានការន្តទៀងទាត់ គេអាចកំណត់បានដោយងាយ, តែវិភត្តិដែលសម្រាប់ភ្ជាប់នឹងនាមសព្ទជាស្វរ-

១ គ្រឿងសំគាល់ ០ នេះ ហៅថា សូន្យ សំគាល់ថាមិនមានវិភត្តិទេ ។

ការកន្តនោះផ្សេង ៗ ខុសពីគ្នា ហើយប្រែប្រួលណាស់ មិនងាយនឹងកំណត់ឲ្យទៀងទាត់បានឡើយ; ឯចំណែកនាមសព្ទជា ព្យញ្ជនការកន្តមានការកន្តប្រែប្រួលផ្សេង ៗ មិនទៀងទាត់ឡើយ, តែចំណែកវិភត្តិដែលសម្រាប់ភ្ជាប់នឹងនាមសព្ទជាព្យញ្ជនការកន្តនោះ ទៀងទាត់មិនសូវប្រែ-ប្រួល គេអាចកំណត់បានដោយងាយ ដូចគំរូខាងលើនេះ ។

## វិធីបំបែកនាមសព្ទជាស្វរការកន្ត

### (៤៩) ១. នាមសព្ទ ជា អ-ការកន្ត.

देव ទេវ, បុំ. "ទេវតា"

| | ឯក. | | ទ្វិ. | | ពហុ. | |
|---|---|---|---|---|---|---|
| ប្រ. | देवस् | ទេវ-ស៑ | देवौ | ទេវៅ | देवास् | ទេវាស៑ |
| ទ្វិ. | देवम् | ទេវ-ម៑ | देवौ | ទេវៅ | देवान् | ទេវាន៑ |
| ត្ឫ. | देवेन | ទេវេន | देवाभ्याम् | ទេវាភ្យាម៑ | देवैस् | ទេវៃស៑ |
| ច. | देवाय | ទេវាយ | देवाभ्याम् | ទេវាភ្យាម៑ | देवेभ्यस् | ទេវេភ្យស៑ |
| ប. | देवात् | ទេវាត៑ | देवाभ्याम् | ទេវាភ្យាម៑ | देवेभ्यस् | ទេវេភ្យស៑ |
| ឆ. | देवस्य | ទេវស្យ | देवयोस् | ទេវយោស៑ | देवानाम् | ទេវានាម៑ |
| ស. | देवे | ទេវេ | देवयोस् | ទេវយោស៑ | देवेषु | ទេវេឞុ |
| សម្ពោ. | देव | ទេវ | देवौ | ទេវៅ | देवास् | ទេវាស៑ |

# សព្ទជាអការាន្ត បុំលិង្គ មានប៉ុណ្ណោះជាដើម ត្រូវបំបែកដូច ទៅ

| | | |
|---|---|---|
| अंश | អំស | ស្មា |
| अमर | អមរ | ទេវតា |
| आचार्य | អាចារ្យ | អាចារ្យ |
| इन्द्र | ឥន្ទ្រ | ព្រះឥន្ទ្រ |
| कुमार | កុមារ | ក្មេងប្រុស |
| गज | គជ | ដំរី |
| ग्राम | គ្រាម | ស្រុក |
| चन्द्र | ចន្ទ្រ | ព្រះចន្ទ្រ |
| झष | ឈស | ត្រី |
| त्याग | ត្យាគ | ការលះបង់,បំណាយ |
| द्रुम | ទ្រុម | ដើមឈើ |
| धर्म | ធម៌ | ធម៌ |
| नरक | នរក | នរក |
| पादप | បាទប | ដើមឈើ |
| पुरुष | បុរុស | បុរស |
| प्रदेश | ប្រទេស | ប្រទេស |
| भाग | ភាគ | ចំណែក |
| मर्कट | មក៌ដ | ស្វា |
| मस्तक | មស្តក | ក្បាល,លលាក្បាល |
| मृग | ម្រឹគ | ម្រឹគ |
| राग | រាគ | រាគ |
| लोपाश | លោបាស | ចចក |
| व्याघ्र | វ្យាឃ្រ | ខ្លាធំ |
| शब्द | សព្ទ | សំឡេង |
| शिष्य | សិស្យ | សិស្ស |
| श्येन | ស្យេន | សត្វខ្លែង |
| सुत | សុត | កូន |
| स्वर्ग | ស្វគ៌ | ឋានសួគ៌ |
| हंस | ហំស | សត្វហង្ស |
| हर्ष | ហរ្ស | សេចក្តីរីករាយ,សប្បាយ |

# จิตฺต ចិត្ត, នបុំ. "ចិត្ត"

| | ឯក. | | ទ្វេ. | | ពហុ. | |
|---|---|---|---|---|---|---|
| ប. | จิตฺตมฺ | ចិត្តម៑ | จิตฺเต | ចិត្តេ | จิตฺตานิ | ចិត្តានិ |
| ទុ. | จิตฺตมฺ | ចិត្តម៑ | จิตฺเต | ចិត្តេ | จิตฺตานิ | ចិត្តានិ |
| តតិ. | จิตฺเตน | ចិត្តេន | จิตฺตาภฺยามฺ | ចិត្តាភ្យាម៑ | จิตฺไตสฺ | ចិត្តៃស៑ |
| ច. | จิตฺตาย | ចិត្តាយ | จิตฺตาภฺยามฺ | ចិត្តាភ្យាម៑ | จิตฺเตภฺยสฺ | ចិត្តេភ្យស៑ |
| បំ. | จิตฺตาตฺ | ចិត្តាត៑ | จิตฺตาภฺยามฺ | ចិត្តាភ្យាម៑ | จิตฺเตภฺยสฺ | ចិត្តេភ្យស៑ |
| ឆ. | จิตฺตสฺย | ចិត្តស្យ | จิตฺตโยสฺ | ចិត្តយោស៑ | จิตฺตานามฺ | ចិត្តានាម៑ |
| ស. | จิตฺเต | ចិត្តេ | จิตฺตโยสฺ | ចិត្តយោស៑ | จิตฺเตษุ | ចិត្តេឞុ |
| សម្ពោ. | จิตฺต | ចិត្ត | จิตฺเต | ចិត្តេ | จิตฺตานิ | ចិត្តានិ |

## សព្វជាអការន្ត នបុំសកលិង្គ មានបុំណ្ណោះជាដើម ត្រូវបំបែកដូច ចិត្ត

| | | | | | |
|---|---|---|---|---|---|
| อกฺษร | អក្សរ | អក្សរ, ព្យញ្ជ | ฤณ | ឫណ | បំណុល |
| อคฺร | អគ្គ | អរយ: | กาพฺย | កាវ្យ | ពាក្យ |
| อาลสฺย | អាលស្យ | សេចក្ដីខ្ជិល | เกฺษตฺร | ក្សេត្រ | ស្រែ |
| อินฺทฺริย | ឥន្ទ្រិយ | ឥន្ទ្រិយ | คฺฤห | គ្ឫហ | ផ្ទះ |
| อุทก | ឧទក | ទឹក | จกฺร | ចក្រ | កង់ |

| | | | | | |
|---|---|---|---|---|---|
| ជល | ជល | ទឹក | ពិល | ពិល | រន្ធ, រូង |
| ត្ឫណ | ត្ឫណ | ស្មៅ | យន្ត្រ | យន្ត្រ | យន្ត្រ |
| ទ្វារ | ទ្វារ | ទ្វារ | រាឞ្ដ្រ | រាឞ្ដ្រ | ដែន; រាស្ត្រ |
| នយន | នយន | ភ្នែក | លក្សណ | លក្សណ | លក្ខណៈ |
| បាត្រ | បាត្រ | បាត្រ | ឝរីរ | ឝរីរ | សរីរៈ |
| ផល | ផល | ផល, ផ្លែ | ស្ថាន | ស្ថាន | ទី, កន្លែង |

ការផ្ទៀបវិភត្តិៈ វិភត្តិមានរបៀបទៀងទាត់ ដែលបានដាក់ទុក ត្រង់លេខ ៩៨ បានផ្ទៀបមកនឹងវិភត្តិដែលភ្ជាប់នឹងនាមសព្ទជាអការាន្ត ឃើញថាមានត្រូវគ្នាខ្លះ ដូចតទៅនេះ:

ត្រង់បុំលិង្គ ឯកវចនៈ ប. អស៑ (=អ+ស៑); ទុ. អម៑ (=អ+ម៑); ស. ឯ (=អ+ឥ)

ទ្វិវចន : ប. ទុ. សម្ពោ. អៅ.

ត្រង់នបុំសកលិង្គ
ពហុវចន : ប. សម្ពោ. អាំសិ (=អ+អំសិ)
ឯកវចន : ស. ដូចជាត្រង់បុំលិង្គ
ទ្វិវចន : ប. ទុ. សម្ពោ. ឯ (=អ+ឦ)

ឯវិភត្តិក្រៅពីនោះ ប្លែកពីវិភត្តិដែលមានរបៀបទៀងទាត់ ឆ្ងាយបែកពីគ្នាខ្លះ ស្រដៀងគ្នាខ្លះ ។

## (៦០) ២. នាមសព្ទ ជា អា-ការន្ត

កថា កថា, ស្ត្រី. "សំដី, រឿងរ៉ាវ"

| | ឯក. | | ទ្វិ. | | ពហុ. | |
|---|---|---|---|---|---|---|
| ប្រ. | កថា | កថា | កថេ | កថេ | កថាស៑ | កថាស៑ |
| ទ្វិ. | កថាម៑ | កថាម៑ | កថេ | កថេ | កថាស៑ | កថាស៑ |
| ត្ឫ. | កថយា | កថយា | កថាភ្យាម៑ | កថាភ្យាម៑ | កថាភិស៑ | កថាភិស៑ |
| ច. | កថាយៃ | កថាយៃ | កថាភ្យាម៑ | កថាភ្យាម៑ | កថាភ្យស៑ | កថាភ្យស៑ |
| ប. | កថាយាស៑ | កថាយាស៑ | កថាភ្យាម៑ | កថាភ្យាម៑ | កថាភ្យស៑ | កថាភ្យស៑ |
| ឆ. | កថាយាស៑ | កថាយាស៑ | កថយោស៑ | កថយោស៑ | កថានាម៑ | កថានាម៑ |
| ស. | កថាយាម៑ | កថាយាម៑ | កថយោស៑ | កថយោស៑ | កថាសុ | កថាសុ |
| សម្ពោ. | កថេ | កថេ | កថេ | កថេ | កថាស៑ | កថាស៑ |

## សព្ទជាអា-ការន្ត ស្ត្រីលិង្គ មានប៉ុណ្ណេះជាដើម ត្រូវបំបែកដូច កថា

អង្គនា អង្គនា ស្ត្រី.

អាកាង្ក្សា អាកាង្ក្សា សេចក្ដីប្រាថ្នា, បំណង

អាឝង្កា អាឝង្កា សេចក្ដីរង្កៀស

ករុណា ករុណា សេចក្ដីអាណិត

គង្គា គង្គា ទន្លេគង្គា; ទឹក

គ្រីវា គ្រីវា ក

| | | |
|---|---|---|
| चिन्ता | *ចិន្តា* | សេចក្តីគិត, គំនិត |
| जरा | *ជរា* | ជរា, សេចក្តីគ្រាំគ្រា |
| टीका | *ដីកា* | សេចក្តីអធិប្បាយ |
| तारा | *តារា* | ផ្កាយ |
| सेना | *សេនា* | ពួកចម្បាំង |
| दया | *ទយា* | សេចក្តីអាណិត, អាសូរ |
| निशा | *និសា* | យប់ |
| प्रज्ञा | *ប្រជ្ញា* | ប្រាជ្ញា |
| भार्या | *ភារ្យា* | ប្រពន្ធ |
| माला | *មាលា* | កម្រងផ្កា |
| रुजा | *រុជា* | កិរិយាចាក់ដោត, ជម្ងឺ |
| लज्जा | *លជ្ជា* | សេចក្តីខ្មាស |
| विद्या | *វិទ្យា* | ចំណេះ, វិជ្ជា |
| शाला | *សាលា* | សាលា |
| संज्ञा | *សំជ្ញា* | សញ្ញា |
| होरा | *ហោរា* | ម៉ោង; ការទាយតាមនក្សត្រ |

# ធម្មទេសនា

របស់

ព្រះសមុហ៍ សមាធិបញ្ញា ( បាន )

វត្តសារាវ័ន

ជាបំរើរបស់ព្រះពោធិវាំង ស្តីទីសង្ឃនាយក

សំដែងនៅកណ្តាលទីសន្និបាត

ក្នុងខែត្រស្វាយរៀង

កាលនៅថ្ងៃ ២៨ យូវាំងដល់ ១០ សូយេត

ឆ្នាំ១៩៣៨

ឧដ្ឋានវតោ សតិមតោ សុចិកម្មស្ស
និសម្មការិនោ សញ្ញតស្ស ច
ធម្មជីវិនោ អប្បមត្តស្ស យសោភិវឌ្ឍតីតិ ។

# អារម្ភកថា

ពាក្យប្រារព្ធខាងដើម មុននឹងសំដែងធម្មទេសនានេះ សូមពន្យល់ដល់អស់លោក-អ្នកជាសប្បុរស ដែលបាននិមន្តមកនិងអញ្ជើញមកក្នុងទីនេះ ឲ្យបានជ្រាបសេចក្ដីជាមុនថា បណ្ដាសត្វក្នុងភាជនៈលោកទាំងមូល មិនមានអ្នកណាមួយប្រាថ្នាចង់បានសេចក្ដីទុក្ខទាល់ក្រលំបាកថោកទាបជាអ្នកមិនមានយសសក្តិបំណេះវិជ្ជា គឺសេចក្ដីចេះដឹងនិងប្រយោជន៍ក្នុងបច្ចុប្បន្ននេះនិងបរលោកនិងប្រយោជន៍យ៉ាងក្រៃលែង គឺព្រះនិព្វានដែលជាអមតស្ថាននេះសោះឡើយ សុទ្ធតែជាអ្នកប្រាថ្នាចង់បានសេចក្ដីចំរើនគ្រប់យ៉ាងដូចគ្នាទាំងអស់ តែថាអ្នកខ្លះប្រាថ្នាទៅបានសម្រេចដូចសេចក្ដីប្រាថ្នា អ្នកខ្លះប្រាថ្នាទៅមិនបានសម្រេចដូចសេចក្ដីប្រាថ្នា មកពីទំនាស់ធម៌ណាបានជាឲ្យផលមិនស្មើគ្នា ហេតុនេះសាធុជនទាំងឡាយត្រូវជ្រាបសេចក្ដីនេះថា .

អ្នកដែលប្រាថ្នាសេចក្ដីចំរើនគ្រប់យ៉ាង ហើយបានដូចសេចក្ដីប្រាថ្នានោះ គឺគេធ្វើតាមពាក្យប្រៀនប្រដៅរបស់ព្រះដែលទ្រង់ត្រាស់សំដែង

មកដោយប្រពៃ អ្នកដែលប្រាថ្នាសេចក្តីចំរើនគ្រប់យ៉ាងហើយមិនបានដូចសេចក្តីប្រាថ្នាមកពីមិនធ្វើតាមពាក្យប្រៀនប្រដៅ របស់ព្រះសាស្តាទេសនាទុកមក ។

អធិប្បាយថា អ្នកធ្វើតាមពាក្យប្រៀនប្រដៅរបស់ព្រះពិជិតមារ ហើយបានសម្រេចដូចសេចក្តីប្រាថ្នា លុះតែប្រកបដោយធម៌៧ប្រការតាមបាឡីអដ្ឋកថាធម្មបទដែលបានកំណត់ទុកមកខាងដើមនេះថា យសសក្តិ ភោគសម្បត្តិសេចក្តីកប់អាន សេចក្តីសរសើររមែងចំរើនដល់អ្នកដែលមានព្យាយាមជាហេតុក្រោកឡើងមិនខ្ជិលច្រអូស ១ អ្នកមានស្មារតី ១ អ្នកមានការងារស្អាត ១ អ្នកចេះពិចារណាហើយទើបធ្វើ ១ អ្នកសង្រួម ១ អ្នកចិញ្ចឹមជីវិតដោយធម៌ ១ អ្នកមិនប្រមាទ ១ គាថានេះហើយដែលជាពុទ្ធភាសិតសំដែងទុកមកឲ្យយើងពល់គ្នាប្រតិបត្តិតាមនឹងបានសេចក្តីសុខសេចក្តីចំរើនក្នុងលោកនេះនិងលោកខាងមុខ ។

សូមស្រង់យកគាថាដែលបានពោលមករួចហើយនឹងអធិប្បាយជាបទមាតិកាមួយម្តង ៗឲ្យបានជាសេចក្តីពិស្តារថា :

ទី ១ ឧដ្ឋានវតោ ការដែលព្យាយាមជាហេតុក្រោកឡើងមិនធុញថប់ព្រោះប្រសប់ធ្វើការងារគ្រប់យ៉ាង មិនអាងដល់កាលវេលាថា :

ត្រជាក់ណាស់ហើយមិនធ្វើការងារ ១ ក្តៅណាស់ហើយមិនធ្វើការងារ ១ ល្ងាចណាស់ហើយមិនធ្វើការងារ ១ ព្រឹកណាស់ហើយមិនធ្វើការ

ស្រា ១ ឃ្មានណាស់ហើយមិនធ្វើការស្រា ១ ស្រែកណាស់ហើយមិនធ្វើការ ស្រា ១ បុគ្គលណាមួយដែលមានព្យាយាម វៀរចាកទោស ៦ យ៉ាងដូចបាន ពណ៌នាមកហើយនេះ រមែងចំរើនទ្រព្យពីរប្រការ គឺទ្រព្យក្នុងបច្ចុប្បន្ន នេះ ១ ទ្រព្យក្នុងបរលោក ១ ទ្រព្យក្នុងបច្ចុប្បន្ន ២ យ៉ាងគឺ សវិញ្ញាណក ទ្រព្យ ១ អវិញ្ញាណកទ្រព្យ ១ ឯសវិញ្ញាណកទ្រព្យបានខាងទ្រព្យដែល មានវិញ្ញាណ គឺៈ ខ្ញុំប្រុសស្រីគោក្របីដំរីសេះជាដើម ១ ។

អវិញ្ញាណកទ្រព្យបានខាងទ្រព្យមិនមានវិញ្ញាណ គឺមាសប្រាក់ ស្រែចម្ការច្បារដំណាំជាដើម ១ នេះហើយដែលជាទ្រព្យក្នុងបច្ចុប្បន្ន ឯ ទ្រព្យក្នុងបរលោកនោះ គឺ អរិយទ្រព្យទាំង ៧ ប្រការមានសទ្ធាធំ ជា ដើម មានបញ្ញាធំ ជាទីបំផុត អ្នកដែលមានព្យាយាមជាហេតុក្រោក ឡើងមិនអាងដល់កាលវេលាដូចបានពោលហើយនេះ កុំសូម្បីឡើយ ដលមនុស្ស សូម្បីតែសត្វតិរច្ឆានក៏គង់បានសម្បត្តិដូចសេចក្តីប្រាថ្នា ដូចវត្តនិទានដែលមានក្នុងគម្ពីរសារត្ថសង្គហផ្លូក ១ ដែលជាស្នាដៃរបស់ ព្រះនន្ទាចារ្យលោកបានទុកមកថាៈ

អតីតេ កាលេ ក្នុងកាលដែលកន្លងទៅហើយ ព្រះសម្មាសម្ពុទ្ធ ជាម្ចាស់នៃយើង កាលដែលព្រះអង្គយោនយកព្រះជាតិជាកំប្រុកបានធ្វើ សំបុកកូនទៀបឆ្នេរសមុទ្រ សម័យមួយមានភ្លៀងបង្អុរ ចុះមកក៏អណ្តែត សំបុកព្រមទាំងកូនលិចទៅក្នុងទឹកសមុទ្រនោះ មហាសត្វក៏មានព្យាយាម

បាចទឹកសមុទ្រអស់ការៈ ៧ ថ្ងៃ - ហេតុតែសេចក្ដីព្យាយាមនៃមហាសត្វមិនធុញថប់ ក៏បង្កើតជាអស្ចារ្យ ក្ដៅដល់អាសនៈព្រះឥន្ទ្រាធិរាជ ៗ ក៏ចុះមកស្រង់យកកូនឲ្យដល់មហាសត្វ រឿងនេះសំដែងដោយសង្ខេប ។

វត្ថុនិទានមួយទៀត ដែលមានក្នុងចូឡកសេដ្ឋីជាតកក្នុងបឋមវគ្គនៃគម្ពីរឯកនិបាត លោកសំដែងថា មានបុរសកំសត់មួយនាក់ជាកូនក្មួយនៃចូឡកសេដ្ឋី ជាអ្នកមានព្យាយាមល្អ បានឮពាក្យចូឡកសេដ្ឋីជាចៅ-ហ្វាយនាយនិយាយថា កណ្ដុរស្លាប់នេះ បើអ្នកឯណាមានព្យាយាមល្អរើសយកទៅលក់នឹងញុំាងទ្រព្យសម្បត្តិឲ្យកើតឡើង នឹងបានជាអ្នកមានទ្រព្យច្រើនក្នុងនគរនេះ ឯបុរសកំសត់ក៏រើសយកកណ្ដុរស្លាប់នោះទៅលក់ឲ្យជនអ្នកចិញ្ចឹមឆ្មាជាដើម ហើយប្រកបការជំនួញជើងទឹកជើងគោកមិនយូរប៉ុន្មានកំណត់បាន ៤ ខែ ក៏បានទ្រព្យមួយសែនកហាបណៈ សេដ្ឋីជាម្ចាស់មានសេចក្ដីត្រេកអរពេញចិត្ត ហើយបានឲ្យកូនស្រីរបស់ខ្លួនជាប្រពន្ធនៃបុរសនោះ ៗ ក៏បានជាសេដ្ឋីធំមានទ្រព្យច្រើន ចាប់ដើមតាំងពីថ្ងៃនោះទៅ ដោយផលដែលបានប្រកបការងារមិនខ្ជិលច្រអូសនោះឯង ។

ឯសម្បត្តិក្នុងបរលោកវិញ លោកសំដែងអាទិនិទានថា ដូចជាព្រះថេរអង្គ ១ ឈ្មោះមហាល្លកមហាតិស្ស លោកមានព្យាយាមល្អមិនខ្ជិលច្រអូសនឹងបំពេញព្រះកម្មដ្ឋាន វេលាដែលសេចក្ដីខ្ជិលនឹងងងុយមកគ្របសង្កត់លោក ៗ ក៏យកចំបើងមកជ្រលក់ទឹកដាក់លើសិរសា ដើរចុះទៅក្នុង

ទឹកប្រមាណត្រឹមកដើម្បីឃាត់នូវសេចក្ដីខ្ជិលទន់ទន្ទុយនោះ ខំព្យាយាមកន្ទង់ទៅបាន ១២ ឆ្នាំក៏បានសំរេចព្រះអរហត្តផល ល្បីខ្ចរទៅក្នុងជម្ពូទ្វីបជាអស្ចារ្យដោយផលានិសង្សដែលព្យាយាមល្អនោះឯង ។

ទី ២– សតិមតោ ប្រែថា មានស្មារតី ឬ ចាំការដែលបានធ្វើទាំងពាក្យដែលពោលហើយសូម្បីអន្លង់បាន អធិប្បាយថា បុរសបុគ្គលឯណាដែលមានចំណេះវិជ្ជា គឺអក្សរលេខនព្វន្តគុណហារជាដើម ឬប្រកបការងារមានក្បួនស្រែកាប់ចម្ការជួញប្រែជាដើម ជាវិជ្ជាលោកិយក្ដី ឬបានរៀនសូត្រធម៌វិន័យបរិយត្តិជាដើម ជាលោកុត្តរក្ដី បើមានសតិដំកល់មាំចាំអស់កាលជានិច្ចមិនភ្លេចស្មារតីហើយ វិជ្ជាលោកិយក្ដី លោកុត្តរក្ដី រមែងសំរេចដល់បុរសបុគ្គលនោះមិនខាន ។

ទី ៣– សុចិកម្មស្ស ប្រែថា ការងារស្អាត ៗ នោះលោកសំដៅយកត្រង់ស្អាតដោយកាយ ស្អាតដោយវាចា ស្អាតដោយចិត្ត ស្អាតដោយកាយ គឺកាយមិនសម្លាប់សត្វ ១ មិនលួចទ្រព្យគេ ១ មិនកន្ទង់បរណី គឺប្រពន្ធកូនអ្នកដទៃ ១ នេះហើយដែលស្អាតដោយកាយ ស្អាតដោយវាចា មិននិយាយកុហក ១ មិននិយាយញុះញង់ ១ មិននិយាយចាក់ដោត ១ មិននិយាយពាក្យគ្មានប្រយោជន៍ ១ នេះហើយដែលស្អាតដោយវាចា ស្អាតដោយចិត្ត គឺ មិនសំឡឹងចង់បានរបស់ទ្រព្យគេ ១ មិនចងចិត្តប្រទុស្សរ៉ាយគេ ១ ឃើញតាមគន្លងធម៌ ១ នេះហើយដែលស្អាតដោយ

ចិត្ត បុរសបុគ្គលឯណា ដែលបានប្រកបការងារស្អាតដោយកាយ-វាចា-ចិត្ត ដូចបានសំដែងមកហើយនេះ យសសក្តិកោតសម្បត្តិសេចក្តីរាប់អានញាតិមិត្តសំឡាញ់ជាលោកិយត្ថ លោកុត្តរត្ថ រមែងឲ្យផលដល់បុរសបុគ្គលនោះពុំដែលដាច់ឡើយ ។

ទី ៤– និសម្មការីនោ អ្នកដែលចេះពិចារណាមុនហើយទើបធ្វើ អធិប្បាយថា អ្នកដែលមានប្រាជ្ញា មុននឹងប្រកបការងារត្រូវឲ្យស្គាល់ហេតុដូចជាស្គាល់ថា នេះជាហេតុនៃសេចក្តីសុខ នេះជាហេតុនៃសេចក្តីទុក្ខ ជាអ្នកស្គាល់ផលដូចជាស្គាល់ថាសេចក្តីសុខ-ទុក្ខ ជាផលកើតឡើងអំពីហេតុរបស់នេះៗ ជាអ្នកស្គាល់ខ្លួនថា យើងនេះមានជាតិត្រកូលយសសក្តិសម្បត្តិបរិវារ សេចក្តីចេះដឹងនឹងគុណធម៌ដែលមានក្នុងខ្លួន ត្រឹមតែជាន់នេះៗ ហើយប្រព្រឹត្តខ្លួនឲ្យសមគួរដល់ជាន់របស់ខ្លួនដែលមាននៅ ជាអ្នកស្គាល់ប្រមាណក្នុងការដែលស្វែងរកគ្រឿងចិញ្ចឹមជីវិត ដោយផ្លូវប្រពៃ នឹងស្គាល់ប្រមាណក្នុងការបរិភោគតែល្មមសមគួរ ជាអ្នកស្គាល់ប្រមាណកាលវេលា ដែលសមគួរនឹងប្រកបកិច្ចការនោះៗ ជាអ្នកស្គាល់ប្រជុំជន នឹងកិរិយាដែលត្រូវប្រព្រឹត្តក្នុងទីប្រជុំជននោះ ៗ ថាពួកនេះកាលចូលទៅរកត្រូវធ្វើកិរិយាយ៉ាងនេះៗ ត្រូវនិយាយយ៉ាងនេះៗ ជាអ្នកស្គាល់បុគ្គល ថាអ្នកនេះជាមនុស្សល្អគួរសេពគប់ អ្នកនេះជាមនុស្សមិនល្អមិនគួរសេពគប់ អ្នកឯណាដែលចេះពិចារណារកហេតុផលជាដើម ដូច

ពណ៌នាមកហើយនេះ សេចក្ដីចំរើនរមែងកើតឡើងដល់អ្នកនោះ ដូចជាគ្រូពេទ្យដែលអាចស្គាល់សមុដ្ឋាននៃរោគ ដែលតាំងឡើងអំពីហេតុនោះៗ ហើយទើបផ្សំថ្នាំ ដំរូវត្រូវនឹងរោគដែលខ្លួនស្គាល់នោះ រោគនោះក៏បានរម្ងាប់បង់ទៅយ៉ាងណាមិញ អ្នកដែលចេះពិចារណាមុនហើយ ទើបប្រកបការងារជាខាងក្រោយ ការងារនោះរមែងចំរើនដល់អ្នកនោះមិនខានឡើយ ដូចគ្នានឹងគ្រូពេទ្យនោះឯង ។

ទី៤- សញ្ញតស្ស អ្នកសង្រួមប្រខ្ចប់អំពើអាក្រក់ ចំណែកខាងកិច្ចត្រូវសង្រួមក្នុងសីល ៤ គឺ ១- បាតិមោក្ខសំវរៈ សង្រួមក្នុងព្រះបាតិ-មោក្ខ វៀរចាកទោសដែលទ្រង់ហាម ធ្វើតាមច្បាប់ដែលទ្រង់អនុញ្ញាត គឺសិក្ខាបទ ២២៧ ។

២- ឥន្ទ្រិយសំវរៈ សង្រួមឥន្ទ្រិយ ៦ គឺ ភ្នែក ត្រចៀក ច្រមុះ អណ្ដាត កាយ ចិត្ត មិនឲ្យស្អប់មិនឲ្យស្រឡាញ់ក្នុងវេលាឃើញរូបស្ដាប់សំឡេងធុំក្លិនស្របរស កាយពាល់ត្រូវដឹងធម្មារម្មណ៍ដោយចិត្ត ។

៣- អាជីវបារិសុទ្ធិ ចិញ្ចឹមជីវិតដោយផ្លូវប្រពៃ គឺ វៀរចាកអ-នេសនៈ ២៦ ។

៤- បច្ចយប្បច្ចវេក្ខណៈ ពិចារណាមុនទើបបរិភោគបច្ច័យ ៤ គឺចីវរ បិណ្ឌបាត សេនាសនៈ គិលានភេសជ្ជ មិនបរិភោគដោយតណ្ហា ។

ចំណែកខាងគ្រហស្ថគប្បីសង្រួមដោយអវយវមានកាយជាដើម ដូចភាសិតក្នុងគម្ពីរខុទ្ទកនិកាយធម្មបទថា:

កាយប្បកោបំ រក្ខេយ្យ កាយេន សំវុតោ សិយា
កាយទុច្ចរិតំ ហិត្វា កាយេន សុចរិតំ ចរេ ។

បុគ្គលគប្បីរក្សានូវកិរិយាកំរើកនៃកាយ គឺញុំាងកាយមិនឲ្យកំរើកឡើង បុគ្គលគប្បីសង្រួមបិទឃាត់ហាម នូវអំពើអាក្រក់ដោយកាយ បុគ្គលគប្បីលះបង់នូវសេចក្តីប្រព្រឹត្តអាក្រក់ដោយកាយ បុគ្គលគប្បីប្រព្រឹត្តឲ្យបរិសុទ្ធល្អដោយកាយ គឺរៀរលែងកាយទុច្ចរិត ។

វចីបកោបំ រក្ខេយ្យ វាចាយ សំវុតោ សិយា
វចីទុច្ចរិតំ ហិត្វា វាចាយ សុចរិតំ ចរេ ។

បុគ្គលគាប្បីរក្សានូវកិរិយាកំរើកឡើងនៃវាចា គឺថាមិនប្រព្រឹត្តញុំាងពាក្យសំដីដែលអាក្រក់ឲ្យកំរើកកើតឡើងបាន បុគ្គលគប្បីសង្រួមឃាត់ហាមនូវពាក្យពោលអាក្រក់ បុគ្គលគប្បីលះបង់នូវកិរិយាប្រព្រឹត្តអាក្រក់មិនល្អដោយវាចា ហើយគប្បីប្រព្រឹត្តឲ្យជាសុចរិតបរិសុទ្ធល្អដោយវាចា គឺរៀរលែងវចីទុច្ចរិត ។

មនោបកោបំ រក្ខេយ្យ មនសា សំវុតោ សិយា
មនោទុច្ចរិតំ ហិត្វា មនសា សុចរិតំ ចរេ

បុគ្គលគប្បីរក្សានូវកិរិយាកំរើកនៃចិត្ត គឺថាញុំាងចិត្តមិនឲ្យកំរើកឡើង កាន់យកនូវអារម្មណ៍ខុសមិនល្អ បុគ្គលគប្បីសង្រួមបិទឃាត់ហាមនូវសេចក្តីរិះគិតខុសដោយចិត្ត បុគ្គលគប្បីលះបង់នូវសេចក្តីប្រព្រឹត្តអាក្រក់មិនល្អដោយចិត្ត ហើយប្រព្រឹត្តឲ្យជាសុចរិតល្អដោយចិត្តកាន់យកនូវអារម្មណ៍ត្រូវប្រពៃ គឺថាប្រព្រឹត្តវៀរចាកមនោទុច្ចរិត ។

នរជនជាតិឯណាមួយ បើបានសង្រួមដោយកាយវាចាចិត្ត ដូចបានសំដែងមកហើយនេះ យសសក្តិ ភោគសម្បត្តិ បរិវារសម្បត្តិ សេចក្តីរាប់អានក្តី ញាតិមិត្តស្រឡាញ់ក្តី ដែលជាលោកិយ និងលោកុត្តរក្តី ក៏រមែងកើតឡើងដល់នរជនជាតិនោះមិនលែងឡើយ ។

ទី ៦ — ធម្មជីវិនោ អ្នកចិញ្ចឹមជីវិតដោយផ្លូវធម៌ អធិប្បាយថា ជនអ្នកគប់គ្រងរក្សាផ្ទះ ត្រូវវៀរចាកជំនួញទាំងឡាយ ៥ ប្រការ គឺ ១- សត្ថវណិជ្ជា លក់គ្រឿងប្រហារ ២- សត្តវណិជ្ជា លក់មនុស្ស ៣- មំសវណិជ្ជា លក់សត្វរស់ដែលគេនឹងសម្លាប់យកសាច់លក់ ៤- មជ្ជវណិជ្ជា លក់ទឹកស្រវឹង ៥- វិសវណិជ្ជា លក់ថ្នាំពិស ការវៀរ

លក់ដូររបស់ ៥ យ៉ាងនេះ ហើយទើបព្យាយាមធ្វើស្រែកាប់ចំការរក្សាគោ ជាដើម ឈ្មោះថាចិញ្ចឹមជីវិតរស់នៅដោយធម៌ ។

ចំណែកអ្នកបួសត្រូវវៀរចាកវេជ្ជកម្ម ទូតកម្មជាដើម ដែលព្រះទ្រង់ហាមប្រាមមិនឲ្យធ្វើ ជាអំពើសៅហ្មងដល់ព្រហ្មចារ្យ ត្រូវខំឧស្សាហ៍បិណ្ឌបាតសង្កាត់សន្តោសដោយបច្ច័យ ៤ តាមមានតាមបាន ឈ្មោះថា ចិញ្ចឹមជីវិតរស់នៅដោយធម៌ ។

ទី ៧- អប្បមត្តស្ស អ្នកមិនប្រមាទ អធិប្បាយថា អ្នកមិនប្រហែសធ្វេសប្រមិនបណ្តែតបណ្តោយក្នុងការកុសលឯណា ដែលខ្លួនធ្វើហើយក៏ឲ្យគិតដល់កុសលនោះរឿយ ៗ កុំឲ្យដាច់ ១ កុសលឯណាដែលមិនទាន់បានធ្វើប្រុងប្រៀបចំធ្វើឡើងដោយឆាប់ប្រញាប់ កុំគិតបង្អែបង្អង់ថាចាំស្អែកខានស្អែកខែនេះខែនោះឆ្នាំនេះឆ្នាំនោះ កុំគិតថានៅក្រោយទៀតចាំមានមុនសិនចាំធ្វើ ការដែលមិនគិតបង្អែបង្អង់យ៉ាងនេះហៅថាសេចក្តីមិនប្រមាទ ម្យ៉ាងទៀត ចេះរៀបចំការងារយកកស ថាដូចជាដូរធ្វើស្រែក៏ប្រុងប្រៀបធ្វើស្រែ ដូរធ្វើចំការក៏ប្រុងប្រៀបធ្វើចំការ ពេលដែលត្រូវលក់ដូរក៏ត្រូវចេះរៃលេកថារបស់នេះលក់ទៅមានចំណេញ របស់នេះលក់ទៅមិនមានចំណេញ របស់នេះគួរលក់ របស់នេះមិនគួរលក់ របស់នេះគួរសំចៃ របស់នេះមិនគួរសំចៃ ការដែលចេះរៀបចំមិនឲ្យខូចពេលយ៉ាងនេះហៅថាសេចក្តីមិនប្រមាទ ៗ នេះជាហេតុឲ្យកើតមានសិល្បសាស្ត្រ ៗ មានហើយជាហេតុ

ឲ្យមានទ្រព្យ ។ មានហើយជាហេតុឲ្យមានមិត្ត ។ មានហើយជាហេតុឲ្យមានសុខ ។ មានហើយជាហេតុឲ្យមានបុណ្យ ។ មានហើយជាហេតុឲ្យបានដល់នូវព្រះនិព្វាន សេចក្តីដែលមិនប្រមាទជាគ្រឿងញុំាងសម្បត្តិទាំងឡាយនេះឲ្យកើតឡើងដូចបានពោលមកហើយ សប្បុរសទាំងឡាយគប្បីប្រតិបត្តិតាមធម៌ ៧ ប្រការដូចបានអធិប្បាយមកនេះចុះនឹងបានសេចក្តីសុខសេចក្តីចំរើនក្នុងលោកនេះនឹងលោកខាងមុខ ធម៌ឯណាប្រព្រឹត្តទៅខុសត្រង់គ្នានឹងធម៌ ៧ ប្រការដូចបានពោលមកហើយ គឺ ១– អ្នកខ្ជិលច្រអូសមិនធ្វើការងារគោរពដល់កាលវេលា ២– អ្នកមិនមានសតិ គឺភ្លេចភ្លាំងស្មារតី ៣– អ្នកមានការងារមិនស្អាត គឺមិនពិនិត្យពិចៃ ៤– អ្នកមិនចេះពិចារណា ហើយទើបធ្វើគឺមិនចេះរៀបចំ ៥– អ្នកមិនសង្រួម គឺមិនបិទអំពើអាក្រក់ ៦– ចិញ្ចឹមជីវិតមិនប្រកបដោយធម៌ គឺរស់នៅមិនត្រឹមត្រូវ ៧– អ្នកប្រមាទ គឺប្រហែសធ្វេសប្តូបណ្តែតបណ្តោយ ធម៌ ៧ ប្រការនេះកើតមានដល់បុគ្គលឯណាហើយ សេចក្តីវិនាសធំកើតដល់បុគ្គលនោះ ដូចមានភាសិតសំដែងថា បុគ្គលខ្ជិលមានសិល្បសាស្ត្រមកពីណា បុគ្គលគ្មានសិល្បសាស្ត្រហើយមានទ្រព្យមកពីណា បុគ្គលគ្មានទ្រព្យហើយមានមិត្តមកពីណា បុគ្គលគ្មានមិត្តហើយមានសេចក្តីសុខមកពីណា បុគ្គលគ្មានសេចក្តីសុខហើយមានបុណ្យមកពីណា បុគ្គលគ្មានបុណ្យហើយធ្វើដូចម្តេចឡើយនឹងបានព្រះនិព្វាន ។

សប្បុរសទាំងឡាយចូរលះបង់ធម៌ ៧ ប្រការនេះចេញឲ្យផុតស្រឡះ ហើយគប្បីកាន់យកធម៌ ៧ ប្រការខាងដើម នឹងបានសេចក្ដីសុខសេចក្ដីចំរើនគ្រប់ប្រការ ដូចបានពណ៌នាមកដោយសង្ខេប ។

ព្រះសមុហសមាធិបញ្ញា

( ញាន )

បំរើព្រះពោធិភាំង ស្ដីទីសង្ឃនាយក

គណៈមហានិកាយ

# រឿងព្រេង - បុរសជីកក្ដាម

និទានរឿង ១ មានចិនប្ដីប្រពន្ធមានកូនប្រុស ១ កូននោះអាយុបាន ១២ ឆ្នាំ មាតាក៏ស្លាប់ទៅនៅតែឪពុកពោះម៉ាយ ឪពុកក៏ធ្វើរបរលក់ដូរតែពីរនាក់ទាំងកូនលក់ក៏មិនដាច់រិតតែក្រទៅ ៗ នោះបានជាឪពុកក៏អនិច្ចកម្មទៅទៀត កូននៅតែម្នាក់ឯងរក្សាផ្ទះសំបែង ឪពុកស្លាប់ទៅបាន ៤ ថ្ងៃក៏មកតាមយល់សុបិនប្រាប់ថា កូនឯងក្រលំបាកណាស់ យើងជាឪពុកគ្មានរបស់អ្វីទាំងឲ្យទេ ដូច្នេះឲ្យកូនទៅជីកក្ដាមនៅក្រោមខ្ទមអ្នកតា នៅទិសខាងត្បូងសាលផ្ទះយើងយកទៅលក់ចិញ្ចឹមជីវិតរៀងរាល់ថ្ងៃតទៅចុះ បើវេលាព្រឹកថ្ងៃរះឡើងកាលណា ឲ្យកូនទៅជីកយករាល់ថ្ងៃកុំខាន ។

កូននោះភ្ញាក់ឡើងក៏ច្បាស់ចាំជាក់នូវនិមិត្តសព្វគ្រប់ ហើយក៏ចាប់យកចបដើរដម្រង់ទៅខ្ទមអ្នកតា ជីកទៅឃើញសត្វក្ដាមមួយប្រាកដមែន រួចយកក្ដាមនោះទៅលក់ឲ្យអ្នកផ្សារ ៗ ក៏ទិញយក បុរសនោះបានប្រាក់ហើយត្រឡប់មកផ្ទះវិញ ។

ថ្ងៃក្រោយវេលាព្រឹកទៅជីកក្ដាមនៅទីកន្លែងដដែលនោះ បានក្ដាមមួយក៏យកទៅលក់ឲ្យអ្នកផ្សារទៀត គេក៏ទិញយក បុរសនោះត្រឡប់មកផ្ទះ រឿងនេះឈប់ស្ងះទុកសិន ។

ទីនពណ៌នាពីមហាសេដ្ឋី ៗ នោះមានកូនស្រីក្រមុំច្រើន កូនស្រីបងទាំងប៉ុន្មានមហាសេដ្ឋីរៀបឲ្យមានប្ដីទាំងអស់ នៅតែកូនស្រីម្នាក់ឈ្មោះ

នាងពៅ គឺកូនពៅប្រកែកមិនព្រមយកប្ដី មហាសេដ្ឋីជាឪពុកម្ដាយបង្ខំឲ្យមានប្ដីក៏មិនព្រមយក ។

ឯបុរសនោះ ថ្ងៃក្រោយទៅជីកក្ដាមនៅទីកន្លែងដដែលទៀត បាន ១ ហើយកាន់យកទៅលក់ នោះនាងពៅកូនក្រមុំមហាសេដ្ឋី បានឃើញក៏ហៅមកសួរថា អ្នកកំឡោះយួរក្ដាមទៅណា បុរសនោះតបថា ខ្ញុំយកទៅលក់ នាងពៅក៏ទិញយក ហើយនាងនោះប្រាប់ថា ពីថ្ងៃនេះតទៅបើអ្នកបានក្ដាមកុំលក់ឲ្យអ្នកឯណា អ្នកយកមកលក់ឲ្យខ្ញុំរាល់ថ្ងៃកុំខាន ដោយនាងនោះមានចិត្តប្រតិព័ទ្ធនឹងបុរសនោះណាស់ តែអ្នកនោះមិនដឹងខ្លួន បុរសនោះបានប្រាប់ហើយត្រឡប់មកផ្ទះវិញ ថ្ងៃក្រោយបុរសនោះទៅជីកក្ដាមនៅទីកន្លែងដដែលបានទៀត រួយកលក់ឲ្យតែនាងពៅរាល់ថ្ងៃ នាងនោះទទួលទិញយកមិនដែលខាន ហើយនាងពៅមានចិត្តរឹងរឹតស្រឡាញ់បុរសនោះខ្លាំងឡើង ក៏ធ្វើបុកពារកិរិយាឲ្យបុរសនោះដឹង បុរសនោះក៏ដឹងជាក់ថា នាងនេះស្រឡាញ់អញប្រាកដ ក៏គិតរាណាថា ខ្លួនអញសព្វថ្ងៃក្រីក្រលំបាកណាស់ហើយកំព្រាផង មិនហ៊ាននិយាយថាដូចម្ដេចឡើយ ។

ចំណែកបងស្រីប៉ុន្មាននាក់ បានឃើញនាងពៅជាប្អូនធ្វើបុកពារកិរិយាស្រឡាញ់បុរសលក់ក្ដាមនោះពន់ពេក ក៏នាំគ្នាទៅតបមហាសេដ្ឋីជាមាតាបិតាថា នាងពៅជាប្អូនធ្វើបុកពារស្រឡាញ់បុរសលក់ក្ដាមនោះ

ក្រៃពេក បុរសនោះបើបានក្អមហើយយកមកលក់ឲ្យតែនាងពៅ ៗ ទទួលទិញយករាល់ថ្ងៃ រួចធ្វើបុកពារកិរិយាស្រឡាញ់បុរសនោះណាស់ ខ្ញុំទាំងអស់គ្នានិយាយទូន្មានដូចម្តេចក៏មិនស្តាប់តាម រឹងរឹតតែធ្វើខ្លាំងឡើង សេដ្ឋីជាមាតាបិតាបានស្តាប់ដូច្នោះក្រៃឡោតខឹងឡើង ឲ្យហៅនាងពៅមកជេរបន្ទោសត្មះតិះដៀលថា ហាងនេះជាមនុស្សរឹងទទឹងចិត្តមាតាបិតា អញឲ្យមានប្តីនឹងមនុស្សដែលគេមានទ្រព្យសម្បត្តិ ហាងឯងប្រកែកមិនព្រមយក ឥឡូវហាងស្រឡាញ់អាមនុស្សក្រសត់លក់តែក្អមវិញ ហាងឯងនេះអាក្រក់ណាស់ ចុះចេញពីផ្ទះអញឲ្យឆាប់ទៅយកអាកំសត់លក់ក្អមនោះចុះ តាំងពីថ្ងៃនេះតទៅហាងឯងកុំមកឡើងផ្ទះអញ សូម្បីតែចូលក្នុងភូមិក៏ចូលមិនបាន អញកាត់ចោលហើយ បំណែកមាតាកាត់ចិត្តមិនដាច់នឹងកូនពៅក៏លបវេចរបស់ដែលមានដំឡៃស្រាលៗ ឲ្យនាងពៅជាកូន នាងពៅក៏សំពះលាមាតា យកបង្វេចដែលមាតាឲ្យចុះចេញពីផ្ទះសំដៅទៅផ្ទះបុរសដែលលក់ក្អម និយាយប្រាប់រឿងពីបិតាខឹងបណ្តេញសព្វគ្រប់ បុរសនោះបានស្តាប់ហើយឆ្លើយតបថា ខ្លួនខ្ញុំសព្វថ្ងៃក្រីក្រជាទីបំផុត ហើយកំព្រាតែម្នាក់ឯងផង នាងត្រឡប់ទៅវិញចុះ ខ្ញុំមិនហ៊ានទទួលយកនាងទេ ខ្ញុំខ្លាចលោកមហាសេដ្ឋីជាបិតានាងចាប់ទោសយកខ្ញុំទៅសំឡាប់ នាងពៅតបថា ខ្ញុំមិនទៅវិញទេ ស៊ូស្លាប់នឹងអ្នកហើយ ហើយបុរសនោះឆ្លើយថា យើងគិតដូចម្តេច នាងពៅឆ្លើយថាបើអ្នកគិតឃើញយ៉ាងណា ខ្ញុំទទួលតាមៗ

ទើបបុរសនោះនាំនាងពៅចេញចោលផ្ទះទៅនៅខេត្តក្រៅ ហើយធ្វើផ្ទះនៅជាមួយគ្នា លុះព្រឹកឡើងមកដកក្តាមនៅទីដដែលយកទៅលក់ដូចថ្ងៃមុនទៀត បានប្រាក់ហើយទិញវត្ថុផ្សេងៗមកផ្ញើប្រពន្ធ ប្រព្រឹត្តធ្វើយ៉ាងនេះជាច្រើនថ្ងៃ នាងពៅនោះហេតុតែស្រីគ្រប់លក្ខណ៍ ក៏បម្រើប្រតិបត្តិប្តីមិនឲ្យទាស់ចិត្ត វេលាយប់ចូលដំណេក នាងពៅនិយាយនឹងប្តីថា ខ្ញុំសូមចិត្តអ្នកឲ្យអាណិតខ្ញុំតាំងពីថ្ងៃនេះតទៅអ្នកកុំទៅដកក្តាមទៀតឡើយ កាសប្រាក់យើងមានច្រើនហើយ បើអ្នកចង់ទិញរបស់អ្វីៗ តាមចិត្តអ្នកទិញចុះ ប្តីមិនព្រមតាម ។

លុះព្រឹកឡើងប្តីកាន់បបទៅដកក្តាមទៀត ប្រពន្ធបានឃើញដូច្នោះ ក៏លបដើរតាមទៅមើលឲ្យឃើញច្បាស់ទឹកទ្វៃងមិនឲ្យប្តីដឹង នាងនោះឃើញច្បាស់ហើយក៏ត្រឡប់មកផ្ទះវិញ ចំណែកប្តីដកក្តាមបានហើយ យកទៅលក់រួចទិញម្ហូបចំណីមកផ្ញើប្រពន្ធ ។

ថ្ងៃក្រោយប្តីទៅកាប់ឧសក្នុងព្រៃឆ្ងាយ នាងពៅបានឃើញប្តីទៅរកឧសក៏កាន់បបទៅដកដីរំលើងនូវទឹកទ្វៃងដែលប្តីដកក្តាមនោះអស់រួចត្រឡប់មកផ្ទះហើយដាំបាយធ្វើម្ហូបចំណីទុកឲ្យប្តីបរិភោគ ថ្ងៃល្ងាចត្រជាក់ប្តីមកពីព្រៃក៏បរិភោគបាយជាមួយគ្នា ។

លុះព្រឹកឡើងប្តីកាន់បបទៅដកក្តាមទៀតឃើញទឹកទ្វៃងដ៏នោះធ្លុះធ្លាយរលើងខ្ចាត់ខ្ចាយអស់ហើយបានឃើញសម្បកក្តាម១ធំបែកស្លុតស្អាត

ដូចជាហាលថ្ងៃយូរហើយ អ្នកនោះក៏កាន់សំបកក្តាមយកមកទុកក្រោមផ្ទះ មិនបានប្រាប់ភរិយាឲ្យដឹង ភរិយាក៏មិនសួរប្តីថាដូចម្តេចឡើយ ដល់វេលាយប់ចូលដំណេកនាងនៅកាន់ប្រាក់របូតពីដៃធ្លាក់១ណែនទៅក្រោមផ្ទះ ធ្លាក់ទៅលើសំបកក្តាមធំនោះ នាងនៅក៏មិនឲ្យប្តីដឹង ហើយគិតថា ចាំព្រឹកឡើងភ្លឺច្បាស់សិមចុះទៅយកប្រាក់មកទុកវិញ លុះព្រឹកភ្លឺស្រឡះក៏ចុះពីផ្ទះទៅ យក ១ ណែនដែលធ្លាក់ស្រាប់តែឃើញប្រាក់ណែនពេញសំបកក្តាម នាងនៅអរណាស់យកមកឲ្យប្តីៗសួរថា នាងបានប្រាក់ពីណាច្រើនម្ល៉េះ នាងនៅជំរាបប្តីថា កាលពីយប់មិញខ្ញុំកាន់ប្រាក់ដើម្បីនឹងយកទៅទុកខាងក្នុង ក៏របូតពីដៃ១ណែនធ្លាក់ទៅក្រោមផ្ទះខ្ញុំពុំបានចុះទៅយក ពីព្រោះគិតឃើញថា ផ្ទះនៅឆ្ងាយពីគេគ្មាននរណាដឹងឃើញ ថាចាំព្រឹកភ្លឺច្បាស់សិមចុះទៅយកមកទុក លុះព្រឹកឡើងខ្ញុំចុះទៅយកស្រាប់តែឃើញប្រាក់ណែនពេញសំបកក្តាមខ្ញុំក៏យកមកជូនអ្នក ប្តីមានចិត្តអំណរពន់ប្រមាណ ហើយនិយាយប្រាប់ប្រពន្ធថា ពីថ្ងៃនេះតទៅបងឈប់ដឹកក្តាមហើយ ប្រពន្ធឆ្លើយថា ខ្ញុំអរណាស់ អ្នកទាំងពីរប្តីប្រពន្ធវេលាយប់កាលណា នាំគ្នាទំលាក់ប្រាក់ទៅលើសំបកក្តាមធំ ព្រឹកឡើងចុះទៅមើលឃើញប្រាក់ពេញសំបកក្តាមក៏យកមកទុករៀងរាល់ថ្ងៃ បើទំលាក់ប្រាក់រៀល ព្រឹកឡើងឃើញប្រាក់រៀល បើទំលាក់ប្រាក់ណែន ព្រឹកឡើងឃើញប្រាក់ណែន បើទំលាក់គ្រឿងមាសពេជ្រ ព្រឹកឡើង

ឃើញគ្រឿងមាសពេជ្រពេញសំបកក្ដាម អ្នកទាំងពីរប្រព្រឹត្តធ្វើយ៉ាងនេះ ចំនួន ១ ឆ្នាំ ប្រាក់ទឹងគ្រឿងប្រដាប់មានច្រើនណាស់កប់មិនអស់ ទើបប្រឹក្សាគ្នាថា ប្រាក់យើងមានច្រើនម៉្លេះ យើងបានអ៊ុំទឹងទុកប្រាក់គ្រឿងប្រដាប់ទាំងអស់នេះ ហើយនាំគ្នាយកប្រាក់ទឹងគ្រឿងមាសពេជ្រទាំងអស់ទៅជីកដីកប់ទុកច្រើនអន្លើ ៗ

ក្រោយនោះមកអ្នកទាំងពីរប្ដីប្រពន្ធនាំគ្នាទៅសួរមហាសេដ្ឋី ជាមាតាបិតា លុះដល់បងស្រីទាំងអស់បានឃើញផងថា មេចោរចៅស្រីឯងនាំអាប្ដីកំសត់លក់តែក្ដាមមករកអី ហានឯងបានខ្ពុប្បទេ លោកឪពុកបណ្ដេញគាត់ចោលហើយសូម្បីតែក្នុងភូមិក៏ចូលមិនបាន មេចៅស្រីឯងចេញពីភូមិឲ្យឆាប់ នាងតៅឆ្លើយថា បងទាំងអស់កុំមើលងាយខ្ញុំ ៗមកនេះដើម្បីសួរមាតាបិតា ព្រោះលោកមានគុណលើខ្ញុំ ៗ មិនសុំទ្រព្យសម្បត្តិលោកទេ សម្បត្តិបងឯងទាំងអស់ក៏ខ្ញុំមិនសុំ ខ្ញុំមើលទៅទ្រព្យសម្បត្តិបងទាំងអស់មានប៉ុណ្ណេះ ខ្ញុំមិនកោតមិនព្រឺឡើយ សូម្បីតែស្មើទឹងកែមជើងខ្ញុំក៏មិនស្មើផង ៗ

បងទាំងអស់ខឹងណាស់ជេរប្រទេចផ្សេង ៗថា ហានឯងនេះអួតណាស់ អញមិនជឿទេ នាងតៅថា បើមិនជឿតាំងភ្នាល់គ្នាចុះ បងទាំងនោះថា ភ្នាល់ដូចម្ដេច នាងតៅថា ឲ្យបងទាំងអស់កប់ប្រាក់ខ្ញុំមើលឲ្យអស់ក្នុង១ថ្ងៃ បើកប់អស់ខ្ញុំឲ្យវៃតកកល់គ្នា បើកប់មិនអស់ខ្ញុំមិនឲ្យ មួយទៀត កុំថាឡើយកប់១ថ្ងៃ ប្រសិនណាជាកប់ពីរថ្ងៃបីថ្ងៃក៏មិនអស់ បងទាំងនោះឆ្លើយថា

អញព្រមទៅកប់ តែបើឯងកុហកអញៗពយហានឯងសំឡាប់ នាងពៅប្រាប់ថា តាមចិត្ត ហើយក៏នាំគ្នាទៅកប់ប្រាក់នាងពៅ ចាប់កប់តាំងពីព្រឹកទាល់ល្ងាចក៏មិនអស់ នាំគ្នាត្រឡប់មកផ្ទះវិញរួចដំពបសេដ្ឋីជាមាតាបិតាថា នាងពៅជាប្អូនពអួតថា ខ្លួនពមានប្រាក់ច្រើន ខ្ញុំទាំងអស់គ្នាមិនជឿ ហើយពថា បើមិនជឿទេ ឲ្យទៅមើលឯផ្ទះចុះ ខ្ញុំទាំងអស់ក៏ទៅមើលឃើញពមានប្រាក់ច្រើនមែន ក៏តាំងភ្នាល់នឹងពៗថា បើខ្ញុំទាំងអស់គ្នាកប់ប្រាក់ពក្នុង ១ ថ្ងៃអស់ ពឲ្យខ្ញុំយកចែកគ្នាចុះ បើកប់មិនអស់ពមិនឲ្យ នោះខ្ញុំទាំងអស់គ្នាចាប់កប់តាំងពីព្រឹកទាល់ល្ងាចក៏មិនអស់ប្រាក់ ត្រឡប់មកដំពបលោកជាមាតាបិតាតាមរឿង ៗ មហាសេដ្ឋីបានស្តាប់ក៏ចាត់ក្រម-ការឲ្យទៅមើលប្រាក់នាងពៅឲ្យជាក់ច្បាស់ នាងពៅក៏នាំឲ្យមើលគ្រប់កន្លែង ក្រមការទាំងនោះបានឃើញប្រាក់នាងពៅមានច្រើនប្រាកដមែន ហើយត្រឡប់មកដំពបមហាសេដ្ឋីសព្វគ្រប់ មហាសេដ្ឋីបានជ្រាបមានចិត្តអំណរណាស់ក៏ចាត់បំរើឲ្យទៅហៅនាងពៅនឹងកូនប្រសាមកប្រាប់ថា កូនឯងមកនៅជាមួយនឹងមាតាបិតាវិញចុះ ទើបមហាសេដ្ឋីបង្គាប់ក្រមការឲ្យគេណ្ឋារទេះក្របីគោច្រើនទៅដឹកជញ្ជូនប្រាក់ នឹងទ្រព្យសម្បត្តិនាងពៅយកមកទាំងអស់ ក៏ឲ្យជញ្ជូនដាក់លើផ្ទះពាសពេញល្វែង មហាសេដ្ឋី

បានឃើញប្រាក់នាងពៅច្រើនមែន មានចិត្តអំណរពន់ប្រមាណក៏សរសើរថា កូនអញនេះពេញជាមានបុណ្យ អំណើះតទៅកូនទាំងពីរនឹងបានធ្វើជាសេដ្ឋីដំណតវង្សពុំខាន ដែលបិតាខឹងបណ្ដេញកូននោះអ្នកកុំប្រកាន់ខឹងនឹងបិតា នាងពៅនឹងប្ដីក៏នៅផ្ទះជាមួយនឹងមាតាបិតាដូចពីដើម ចំណែកបងស្រីទាំងប៉ុន្មានក៏កោតខ្លាចនាងពៅនឹងប្អូនថ្លៃនោះណាស់ លុះមហាសេដ្ឋីជាបិតាមរណភាពទៅវេលាណា នោះប្ដីនាងពៅនឹងភរិយាក៏បានធ្វើជាសេដ្ឋីជំនួសបិតាតទៅ ។

(ចប់តែប៉ុណ្ណេះ)

ឧកញ៉ាប្រាជ្ញាធិបតី ជាងហ្វាង (យិន) តែង ។

# ក្បួនកុមារដង់

ក្បួនកុមារជន់

# មើលអំពីហេតុដែលក្មេងឈឺ ជាត្រូវអ្វីធ្វើ និងសំដែងពីរបៀបសែន

កាលមានមនុស្សឈឺឡើង តែមិនដឹងជាឈឺដោយហេតុខ្មោចអ្វីធ្វើឲ្យឈឺ ៗ គេតែងបើកក្បួនកុមារជន់នេះមើល ត្រូវលើខ្មោចអ្វីធ្វើ គេក៏រៀបសែនទៅតាមបែបបទដែលលោកបង្គាប់ទុកក្បួននោះ តែកាលនឹងមើលគប្បីចាំឈ្មោះថ្ងៃដែលចាប់ឈឺឡើង ទើបមើលបាន ៗ ក្បួននេះជាភាគ ១ ក្នុងក្បួនទាំងឡាយដែលសម្រាប់មើលជម្ងឺ កាលណាមើលហើយ ទៀងជាប្រទះឃើញពាក្យទំនាយថាត្រូវខ្មោចនេះ ខ្មោចនោះ ធ្វើជាពុំខាន ៗ ហេតុនេះយើងនឹងជឿស៊ប់ស្មោះទៅតាមក្បួននេះតែម្ដង ក៏មិនទំនងដែរ ព្រោះសមុដ្ឋាននៃរោគមាន កើតអំពីហេតុដទៃ មានត្រជាក់ពេកក្ដៅពេកជាដើម ក៏មានដែរ កាលមើលតាមក្បួននេះមិនគប់ហើយ ក៏ត្រូវប្រែប្រួលមើលដោយវិធីដទៃតទៅ ៗ

## វិធីមើលតាមក្បួននេះ

១ ទោះថ្កាត់ថ្ងៃអាទិត្យ ត្រូវខ្មោចនៅលើកំពូលដំបូក រុក្ខទេវតា អារក្សនៅដើមឈើធំ ៗ ក្នុងទិសបូព៌ាឲ្យទោសធ្វើឲ្យឈឺ ដំបូងឡើងឈឺក្បាល ក្ដៅខ្លួន ក្រៀមមុខ-មាត់ ចង់តែផឹកទឹក ពុំនឹកឃ្លានភោជនាហារ ៗ

ឲ្យធ្វើពែបែន ៣ រួតមួយ កន្ទោង ៤ ដាក់បាយខ្មៅ បាយក្រហម ទឹកសួនរូបទេវតា ១ រូបស្វា ១ ឲ្យយកស្លឹកស្វាឈ្មោលទ្រាប់រូបអំបាលនេះ ដាក់ក្នុងពែ រូបអុជទៀនធូបបូជាដោយមន្តនេះ ។

ឱំ ពុជយក្ខទេវតា សព្វេ សហា បរិវារេហិ ឯហិ ៗ អាគច្ឆន្តុ ភុញ្ជន្តុ ស្វាហាយ ៣ ដង ។ រួចហើយលើកជូនទៅទិសបូព៌ា ៣ ថ្ងៃសះហោង ។

១ ពោះថ្កាត់ថ្ងៃចន្ទ ត្រូវខ្មោចក្នុងទឹកនៅទិសបស្ចិមធ្វើឲ្យឈឺផ្ទៃ-ឈឺជើង ឈឺដៃ ត្រូវដាក់ក្រហាយក្នុងខ្លួន ។ ឲ្យធ្វើពែបែន ៥ រួត ប្រដាប់ដោយឆត្រ-ទង់ក្រដាស ដាក់បាយម្ហូបចំណី ស្រា ទឹកឃ្មុំទឹកសួនរូបព្រះអង្គារ ១ រូបនាគង្ហឹងព្រះធរណី ១ ឲ្យយកស្លឹកបេកទ្រាប់រូបអំបាលនេះ រូបអុជទៀនធូបសែនបូជាដោយមន្តនេះ ។

ឱំ ភជា ធរណីទេវតា សព្វេ សហា បរិវារេហិ ឯហិ ៗ អាគច្ឆន្តុ ភុញ្ជន្តុ ស្វាហាយ បីដង ។ រួចជូនទៅទិសបស្ចិម ៣ ថ្ងៃសះហោង ។

១ ពោះថ្កាត់ថ្ងៃអង្គារ មានបើដើរទៅពានលើទេពតានៅទិសឧត្តរ ធ្វើឲ្យឈឺក្បាលក្អក ក្តៅក្រហាយ ចង់តែផឹកទឹក ពុំទឹកនាទឹងបរិភោគបាយចំណី ។ ឲ្យធ្វើពែបែន ៣ រួត ១ ដាក់បាយម្ហូបចំណី ស៊ុតមាន់

ស្រា ទឹកសូនរូបស្រី ១ រូបបិសាច ១ រូបពាលី ១ រូបក្របី ១ ឲ្យ យកស្លឹកស្វាឈ្មោលត្រាប់រូបអំបាលនេះ រួចអុជទៀនធូបសែនបូជាដោយ មន្តនេះ ៗ

ឱ ក្រុមទេវតា មណីយក្ខសុណី

កុមារី ឯហិ ៗ អាគច្ឆន្តុ កុញ្ជន្តុ ស្វាហាយ

បីដង ៗ រួចជូនទៅទិសឧត្តរ, ៣ ថ្ងៃសះហោង ៗ

◎ ទោះជាត់ថ្ងៃពុធ ត្រូវខ្មោចយក្សធ្វើឲ្យឈឺដៃ. ឈឺជើង, ឈឺខ្នង ទឹកភ្លក ភ្លុត ស្លុតក ៗ ឲ្យធ្វើពែង ៣ រួត ១ ដាក់បាយ សំឡប្រហើរ សំឡម្ជូរ ទឹកបន្លែម, ទឹកឲ្យសូនរូបប្រេត ១ យក្ស ១, ដំរី ១, ក្របី ១, ឲ្យយកស្លឹកអំពៅត្រាប់រូបអំបាលនេះ រួចអុជទៀន ធូបសែនបូជាដោយមន្តនេះ ៗ

ឱ ប្រេតិយក្សទេវតា សព្វេ សហា បរិវារេហិ ឯហិ ៗ អាគច្ឆន្តុ កុញ្ជន្តុ ស្វាហាយ បីដង ៗ រួចជូនទៅទិសទក្សិណ ៣ ថ្ងៃសះហោង ៗ

◎ ទោះជាត់ថ្ងៃព្រហស្បតិ៍ ត្រូវទេវតាក្លាំងមឿងនៅទិសនិរតី ធ្វើ ឲ្យឈឺក្តៅក្រហាយ ឈឺក្បាល តឹងទ្រូង តឹងដើមក ដេកពុំសុខ បេះតែ ស្លាប, ពុំទឹកនាទឹកបរិភោគភោជនាហារ ៗ ឲ្យធ្វើពែង ៣ រួត ១

ដាក់បាយម្ហូបចំណីនឹងអំពៅផ្កាស្រស់ នឹងឲ្យសូនរូបទេវតា ១ ព្រាហ្មណ៍ ១ ពិទ្យាធរ ១ រូបស្តេចជិះដំរី ១ រួចអុជទៀនធូបសែនបូជាដោយមន្តនេះ ៗ

ឱំ ទេវតា ឥន្ទកជា ចណីកុមារី ឯហិ ៗ អាគច្ឆន្តុ ភុញ្ជន្តុ ស្វាហាយ បីដង ៗ រួចជូនទៅទិសនិរតី, ៣ ថ្ងៃសះហោង ៗ

ទោះផ្កាត់ថ្ងៃសុក្រ ត្រូវខ្មោចពុធយក្ខទៅដំបូក-ដើមឈើធំ នៅទិសពាយព្យ ធ្វើឲ្យឈឺអន្ទះអន្ទែងសោប់សល់ ចាប់ចុកជើង-ដៃ នឹងឈឺពោះ ឈឺទ្រូង ៗ ឲ្យធ្វើតែបែង ៧ រូត ១ កន្ទោង ២, ដាក់បាយម្ហូប ស្រា នឹងលាជ ទឹកឃ្មុំ អំពៅ, ផ្កា ៗ ឲ្យសូនរូបយក្ខកាន់ដំបង ១ កិន្នរី ១ កិន្នរ ១ រូបនាគរាជ ១ រួចអុជទៀនធូបសែនបូជាដោយមន្តនេះ ៗ

ឱំ ភូមទេវតា សព្វេ សហា បរិវារេហិ ឯហិ ៗ អាគច្ឆន្តុ ភុញ្ជន្តុ ស្វាហាយ បីដង ៗ រួចឲ្យជូនទៅទិសពាយព្យ ៣ ថ្ងៃសះហោង ៗ

ទោះផ្កាត់ថ្ងៃសៅរ៍ ត្រូវខ្មោចយក្ខកាន់ដំបងសិលា ខ្មោចគេកាប់ទៅទិសពាយព្យ ធ្វើឲ្យឈឺអ្នកក្តៅក្រហាយ នឹងឈឺអស់សព៌ាង្គកាយ ៗ ឲ្យធ្វើតែបែង ៧ រូត ១ កន្ទោង ៣, ដាក់បាយម្ហូបចំណី នឹងឲ្យសូន

រូបខ្មោចបិសាច ១ រូបយក្ខិនីឈ្មោះអស្សមុខី ១ រូបកពណាសូរ ១ ឲ្យយកស្លឹកស្លាឈ្មោល ទឹងស្លឹកក្រូចឆ្មារព្រាប់រូបអំបាលនេះ អុជទៀនធូបសែនបូជាដោយមន្តនេះ ។

ឱ្ម ពុធយក្ខបិសាច កជក្ខតទេវតា សពេ្វ សហា បរិវារេហិ ឯហិ ៗ អាគច្ឆន្តុ គុញ្ឆន្តុ ស្វាហាយ បីដង ។ រួចឲ្យជូនទៅទិសពាយព្យ, ៣ ថ្ងៃសះហោង ។

នៅមានពាក្យសូត្រសែន ១ យ៉ាងទៀត មិនចំពោះថ្ងៃណាដូចខាងលើនេះទេ ឈឺថ្ងៃណាក៏ដោយ ប្រើសូត្រសែនពាក្យនេះបានទាំងអស់ ប្តូរទឹងសូត្រសែនឲ្យចាស់ក្តី ក្មេងក្តី បានទាំងអស់ ។

ឱ្ម គ្រោះបរ ឱ្មគ្រោះមរណ៍ គ្រោះដោក គ្រោះថាំ គ្រោះខែ គ្រោះឆ្នាំ គ្រោះលក្ខណាអន្ធរាក់ណើតអ្នកនោះឯងហោង អំពីព្រះម្រឹត្យូវរាជឲ្យថ្កាត់; ឫសិទ្ធិស័ក្តិព្រះពុទ្ធមន្ត ទើបអញ្ជើញស្តេចទេវរាជទាំងឡាយដ៏គង់នៅកំលុងទិសត្រៀសាណ - បូព៌ - អគ្នេយ៍ - ទក្សិណ - និរតី បស្ចិម - ពាយព្យ - ឧត្តរ, អញ្ជើញស្តេចមកយកក្រយាបូជា ពោះថ្កាត់នានាពេតាឲ្យបាត់ ចូរពីងចេញថ្កាត់កាន់ស្ថានលំនៅពីងវិញហោង ។

ឱ្ម នមោ ពុទ្ធស្ស នមោ ធម្មស្ស នមោ សង្ឃស្ស សេយ្យថីទំ ហុលោ ហុលោ ស្វាហាយ ។ ឱ្ម អង្គកាយអញ ស្រាយពន្ធនំ ទើបអញស្មោះ

អញ្ជើញទាំងបាបគ្រោះ ទាំងពន្រាយស្រាយហើយ សូមស្រាយជម្ងឺចេញហោង កុំឲ្យឈឺក្បាលត្បូង ឈឺទ្រូងឈឺស្មា ឈឺជើង ឈឺដៃសរសៃកោគឡើយ , សូមទោសសូមលា កុំអ្នកប្រកួត ទោះឈឺចាក់ឈឺច្បាក់សាច់ស្លួតជោតរមួលរមួត សូមពឹងរំដោះជំងឺឲ្យជា , ទោះថ្កាត់នានាកោតឲ្យបាត់, ចូរពឹងចេញថ្កាត់ ដោយទូរលំនៅទីទៃ ៗ, ឱ នមោពុទ្ធស្ស ឱ នមោ ធម្មស្ស ឱ នមោ សង្ឃស្ស សេយ្យថីទំ ហុលោហុលោ ស្វាហាយ ៗ ឱ អង្គកាយអញអញ្ជើញយាត្រាជូនពៃហើយណាអញ្ជើញទៅហោង ហើយយកជម្ងឺនោះទៅផង ដឹកស៊ីហើយហោងទៅឋានទីទៃនានា រលកធា ៗ បែកជាផ្កាត្រែង យល់អ្នកសង្វៀន ជូនពៃទៅហោង ៗ

(ចប់)

ក្រុមជំនុំទំនៀមទម្លាប់
COMMISSION DES MŒURS & COUTUMES

ព្រះរាជបណ្ណាល័យកម្ពុជា

# KAMBUJASURIYÂ

# កម្ពុជសុរិយា

## សៀវភៅទស្សនាវដ្ដីចេញរាល់ខែ ពីព្រះរាជបណ្ណាល័យ

ឆ្នាំគំរប់ ១១

ខ្សែ ១០, ១១, ១២, រួមគ្នា

កុង្សីយសេនាបតីបានអនុញ្ញាតហើយ
សម្ដេចសង្ឃនាយកទាំងពីរគណៈយល់ព្រម

ភ្នំពេញ
ការផ្សាយរបស់ព្រះរាជបណ្ណាល័យ
ព. ស. ២៤៨២
គ. ស. ១៩៣៩

# បញ្ជីរឿង


ទំព័រ

១ — កិត្តិគុណនិងការងារជាថ្មីនៃរបស់លោកគ្រូព្រះសពព្រះឧត្តមមុនី (អ៊ុម-ស៊ូរ)... ៣

២ — ដំណឹងផ្សេងៗ ........................ ៩

៣ — ទឹកទន្លេសាប របស់ជីគីម-ហាក់ លេខានុការក្រសួងប្រៃសនីយ៍ តែងនិង រៀបរៀង ........................ ១៩

៤ — វេយ្យាករណ៍ សំស្ក្រឹត របស់លោកគ្រូព្រះវិសុទ្ធិវង្ស (ត) .......... ៤៣

៥ — ធម្មទេសនា របស់ព្រះវិនយធម្ម (អ៊ូច) .............. ៩៥

៦ — ហិតោបទេស ភាគទី ១ (ត) ................ ១០៧

៧ — រឿងព្រេងខ្មែរៈ បុរស កាស ៣១ .............. ១១៧

៨ — លទ្ធិទំនៀមទម្លាប់ខ្មែរៈ សែនក្ឡោបមេបាចាស់ទុំ .............. ១២៣


## រូបក្រៅរឿង


នេះរូបលោកគ្រូព្រះសពព្រះឧត្តមមុនី (អ៊ុម-ស៊ូរ) .............. ១

# TABLE DES MATIERES

Pages

1. L'œuvre du Vénérable Préas Uttamamuni (Oum-Sou)....... 3

2. Informations diverses.............................. 9

3. L'eau du Tonlésap par Kim-Hak (suite et fin)........... 15

4. Grammaire sanscrite par le Vénérable Visuddhivong (suite). 43

5. Dhammadésanâ par le Vénérable Ouch................. 95

6. Hitopadésa 1e partie (suite)............................ 107

7. Contes populaires Cambodgiens inédits

   L'homme aux 30 sapèques.............................. 117

8. Mœurs et coutumes Cambodgiennes:

   Offrandes faites aux ancêtres à la suite des maladies causées par la discorde entre parents.................. 123

HORS TEXTE:

Portrait du Vénérable Préas Uttamamuni (Oum-Sou)..... 1



ព្រះឧត្តមមុនី អ៊ុម-ស៊ួរ ១៨៨០-១៩៣៩

# កិត្តិគុណនិងការងារជាថ្វីដៃរបស់
# លោកគ្រូព្រះឧត្តមមុនី
# អ៊ុម — ស៊ូរ

[stamp]

លោកគ្រូព្រះសពព្រះឧត្តមមុនី (អ៊ុម-ស៊ូរ) ជាអ្នកប្រាជ្ញធំមួយនៅក្នុងស្រុកខ្មែរ ប៉ែកខាងព្រះអភិធម្ម មានកេរ្តិ៍ឈ្មោះល្បីខ្ទរទៅក្នុងស្រុកខ្មែរ ហូតដល់តាមប្រទេសខ្លះផង ។ លោកគ្រូព្រះសពនេះជាមេកំឡាំងមួយយ៉ាងធំចំបង ក្នុងការរៀបចំធម្មវិន័យនិងដឹកនាំពុទ្ធសាសនិកជនជាតិខ្មែរឲ្យប្រតិបត្តិត្រឹមត្រូវតាមទំនងគន្លងធម៌ជាដំណតមកពីលោកគ្រូព្រះសពព្រះមហាវិមលធម្ម ព្រះនាមថោង ដែលជាគ្រូរបស់លោកគ្រូព្រះសពនេះ ។ បណ្ដាគ្រហស្ថនិងបព្វជិត ដែលបានប្រគល់កាយថ្វាយខ្លួនជាសិស្សគណរៀនសូត្រនៅក្នុងសំណាក់លោកក្ដី មករកផ្ទៀងផ្ទាត់ធម៌អាថ៌ក្នុងសំណាក់លោកក្ដី សឹងមានមកស្ទើរតែគ្រប់ខេត្តគ្រប់ស្រុក ក្នុងកំឡុងក្រុងកម្ពុជា ក្នុងកាលដែលលោកនៅមានព្រះជន្មនៅឡើយ ។

បើពោលតាំងពីលោកបានមកធ្វើជាអាចារ្យ ប្រចាំនៅព្រះរាជ-បណ្ណាល័យ ៗ ទុកស្មើបានទីប្រឹក្សានិងកំឡាំងយ៉ាងធំនាំឲ្យចំរើនក្បួនខ្នាតនានាជាអនេក គឺសៀវភៅផ្សេងៗដែលលោកគ្រូព្រះសពបានប្រែនិងរៀបរៀងតាំងប៉ុន្មាន ដែលយើងបានស្រង់យកមកចុះផ្សាយនៅខាងចុងសេចក្ដី

រំពុកគុណនេះ ៗ ឥឡូវនេះ ពួកមិត្តនៃព្រះរាជបណ្ណាល័យបានទទួលវិប្បយោគយ៉ាងធំគ្របសង្កត់លើដួងចិត្តរាល់គ្នា ដោយហេតុលោកគ្រូព្រះឧត្តមមុនី អ៊ុម-ស៊ូរ ត្រូវបោះបង់ពួកយើងទៅកាន់សុគតិភពហើយ ដោយមិនមានអ្វីមួយរាំងទប់ទល់ឲ្យលោកគង់នៅតទៅទៀតបាន តាំងពីថ្ងៃ ២២ ស៊ូយេតឆ្នាំ ១៩៣៩ វេលាម៉ោងពីរយប់ ៗ បណ្ដាញាតិមិត្តសាច់សាលោហិត សិស្សគណនិងពុទ្ធសាសនិកជនទាំងឡាយក្នុងកំឡុងក្រុងកម្ពុជា សឹងមានចិត្តសោកស្ដាយអាឡោះអាល័យក្រៃពេកណាស់ ក្នុងខណៈដែលបានទទួលដំណឹងដែលនាំឲ្យរំភើបចិត្តជាពន្លឹកនេះ តែអនិច្ចា? បណ្ដាសត្វនិងសង្ខារទាំងឡាយ ដែលកើតមកក្នុងលោកនេះ តែងធ្វើដំណើរទៅកាន់ចុងផ្លូវ គឺមរណៈគ្រប់រូបគ្រប់នាម មិនថាមនុស្សទេវតា ឥន្ទ្រ ព្រហ្ម យម យក្ខណាមួយឡើយ សូម្បីព្រះសម្មាសម្ពុទ្ធជាម្ចាស់ជាកំពូលនៃទេវតានិងមនុស្សទាំងឡាយ ព្រះអង្គគង់តែស្ដេចចូលព្រះបរិនិព្វានទៅទីបំផុតនៃព្រះជន្មាយុដែរ ៕

យើងសូមថ្លែងសារសព្ទពីការងារជាថ្វីដៃរបស់លោក និងគុណ-សម្បត្តិរបស់លោកដែលមើលឃើញច្បាស់លាស់ ក្នុងខណៈដែលលោកនៅមានព្រះជន្មនៅឡើយ គឺតាំងអំពីពេលដែលរាជការចាត់ការរៀបចំប្រែព្រះត្រៃបិដកជាអក្សរខ្មែរមានទាំងបាលីទាំងសម្រាយ ដោយវិធីចាត់តាំងក្រុមជំនុំមួយក្រុមសម្រាប់ប្រែនិងផ្ទៀងផ្ទាត់បោះពុម្ព លោកគ្រូព្រះ

សពនេះជាមេកំឡាំងមួយក្នុងការរៀបចំការងារដ៏ប្រសើរនេះ ឥតមានគិតនឿយហត់ឬបង់ខាតអ្វីឡើយ ហេតុនេះហើយ ទើបកើតការយល់ថា លោកគ្រូព្រះសពនេះ ជាអ្នកប្រាជ្ញធំមួយដែលមានចិត្តឈឺឆ្អាលនឹងព្រះពុទ្ធសាសនាជាបំផុត ទើបតាំងលោកធ្វើជាអធិបតីនៃក្រុមជំនុំព្រះត្រៃបិដក ។ តាំងអំពីលោកបានមកកាន់កាប់ការដ៏ប្រសើរនេះកាលណា លោកខំខ្វល់ខ្វាយប្រឹងប្រែងរៀបចំធ្វើដោយពិនិត្យផ្ចិតផ្ចង់ហ្មត់ចត់ ពិតមែនតែលោករមែងមានជម្ងឺប្រចាំសង្ខារពងកាយមិនស្រួលខានក៏នៅតែយកព្រះទ័យទុកដាក់ចាត់ការឲ្យការប្រែនឹងបោះពុម្ពបានចំរើនកើនឡើងឥតអាក់ថែមទាំងឆ្លៀតពេលសរសេរសៀវភៅដទៃទៀតផង ដូចមានតឹកតាងឲ្យយើងមើលឃើញស្រាប់គឺនៅមានសល់សំណុំរឿងមួយដែលលោកសរសេរមិនទាន់ចប់សព្វគ្រប់ ស្រាប់តែអាពាធជាទម្ងន់ចូលមកលុកលុយករដ្ឋកាយយ៉ាងខ្លាំង ទើបបង្អង់ការងារជាថ្មីដែលបង្ហើយរបស់លោករហូតដល់ថ្ងៃសុគត ។ សំណុំរឿងនេះជាបរមត្ថធម៌សុទ្ធ ៗ មិនទាន់មានឈ្មោះដូចម្ដេចទេ តែដែលឲ្យឈ្មោះថា «អវសានកិច្ច» ជាខាងក្រោយនេះ ព្រោះជាកិច្ចបង្ហើយដែលជាស្នាដៃក្រោយបង្អស់របស់លោក ។ សៀវភៅនេះនឹងបោះពុម្ពចែកជាធម្មទាន នៅឱកាសបូជាសពលោក ។ ដែលពោលមកនេះ ល្មមសំដែងឲ្យឃើញការងារជាថ្មីដែលនឹងសេចក្ដីព្យាយាមដ៏ម៉ឺងម៉ាត់ឥតទម្រន់សោះឡើយ ។

ក្រៅពីកិច្ចការដែលពោលពណ៌នាមកនេះ នៅមានកិច្ចការម៉្យាងទៀត ដែលលោកត្រូវទទួលធ្វើប្រចាំរៀងរាល់ឆ្នាំ គឺធ្វើជាមេប្រយោគត្រួតប្រយោគកូនសិស្សសាលាបាលីជាន់ខ្ពស់ ដែលប្រឡងចេញ ឬប្រឡងចូល ហើយនៅឆ្នាំបំផុតនេះ លោកទទួលធ្វើជាសមាជិកកិត្តិយសនៃពុទ្ធិកសមាគម កម្ពុជរដ្ឋ ។

គុណសម្បត្តិនិងគុណធម៌ របស់លោកគ្រូព្រះសពព្រះឧត្តមមុនី អ៊ុម-ស៊ូរ ដែលបានសរសេរមកនេះមិនទាន់ជាចប់សព្វគ្រប់ទេ គ្រាន់តែសូមថ្លែងថា ដោយហេតុលោកមានគុណសម្បត្តិ-គុណធម៌-ចំណេះវិជ្ជាដ៏ប្រសើរព្រមទាំងព្រេងសំណាងរបស់លោកផងទើបបណ្ដាលឲ្យពុទ្ធសាសនិកជនទាំងឡាយក្នុងកម្ពុជរដ្ឋនេះ នាំគ្នាឈូឆរមកធ្វើបុណ្យឧទ្ទិសផលប្រគេនដល់លោក តាំងពីថ្ងៃសុគតដរាបមក តាមកំណត់ដាក់សពលោកទុកធ្វើបុណ្យអស់ ១ វស្សា ( ៣ខែ ) មិនមានថ្ងៃណាមួយចន្លោះទំនេរឥតមានធ្វើបុណ្យឧទ្ទិសផលនៅចំពោះមុខសពលោកនោះទេ ដោយមានពួកទាយកទាយិកាជាពួកជាក្រុមពីស្រុក, ភូមិ, ឃុំនានាទាំងឆ្ងាយទាំងជិតនាំគ្នាមកធ្វើបុណ្យទក្ខិណានុប្បទានតែរៀងរាល់ថ្ងៃឥតមានទំនេរថ្ងៃណាមួយឡើយ មានចួនកាលដល់ទៅដណ្ដើមថ្ងៃធ្វើបុណ្យក៏មានខ្លះដែរ ។ ឯពួកសប្បុរសបុរសិស្សគណរបស់លោកដែលនៅស្រុកឆ្ងាយពេកមិនអាចនាំគ្នាមកធ្វើបុណ្យផ្ទាប់នៅចំពោះមុខសពបាន ក៏នាំគ្នាធ្វើបុណ្យឧទ្ទិសផល

នៅទំនោះទៅក៏មាន ដូចមានសេចក្ដីចុះផ្សាយក្នុងកាសែតនគរវត្តស្រាប់ ៗ

តាមសេចក្ដីដែលយើងសរសេរមកនេះ ឃើញថាលោកគ្រូព្រះសព្រះឧត្តមមុនី អ៊ុម-ស៊ូរ ក្រៅពីការងារជាថ្វីដៃរបស់លោក ៗ នៅមានគុណសម្បត្តិដទៃទៀតជាច្រើនប្រការ ដូចជាការប្រកាន់សិក្ខាវិន័យយ៉ាងម៉ឺងម៉ាត់ មានចិត្តប្រកបដោយមេត្តាករុណា នៅឧកាសឲ្យធម្មទានដល់សិស្សានុសិស្ស លោកតែងប្រើសំដីពីរោះទន់ផ្អែមជាទីចាប់ចិត្ត វេលានឹងពោលធម៌ឬពន្យល់ពីធម៌អាថ៌ប្រស្នាអ្វីមួយ លោកតែងសំដែងដោយសំដីពីរោះគ្រោះក្សាយច្បាស់លាស់ ធ្វើឲ្យអ្នកស្ដាប់យល់សេចក្ដីបានដោយងាយ ទុកជាអាថ៌ប្រស្នាជ្រៅ ៗ លោកក៏អាចពន្យល់ឲ្យពាក់ងាយយល់ដែរ ទើបធ្វើឲ្យពុទ្ធសាសនិកជនទាំងគ្រហស្ថ ទាំងបព្វជិត ដែលបានចូលទៅសេពគប់សមាគមនឹងលោកសឹងស្ញុំគ្រប់ចិត្តគោរពរាប់អានជាច្រើន មានចំនួនតិចទេ ដែលមិនពេញចិត្ត ដែលជារបស់ធម្មតាឥតនរណាចៀសរួចក្នុងលោកនេះ ៗ

ឯក្បួនច្បាប់ព្រះពុទ្ធសាសនា ដែលកើតឡើងដោយថ្វីដៃរបស់លោកមានជាច្រើនអនេក តែក្នុងទីនេះយើងគ្រាន់តែស្រង់យកចំពោះឈ្មោះសៀវភៅដែលជាស្នាដៃរបស់លោកប៉ុណ្ណោះ ដើម្បីសំដែងផលនៃការងារជាថ្វីដៃរបស់លោក គឺ ១- សុភាសិតប្បកាសិនី ២- អភិធម្មត្ថសង្គហ:

ប្រែ ៣- គិហិវិន័យសង្ខេប ៤- មាតាបិតុឧបដ្ឋានកថា ៥· ទសបារមីកថា ៦· សាមណេរវិន័យ ៧- គិហិវិន័យពិស្តារ ៨· រតនប្បភា ៩- មរណានុស្សតិកម្មដ្ឋាន ១០- មិលិន្ទបញ្ហា ខ្សែ ១-២ ។ ក្រៅពីនេះលោកជួយរៀងផ្ទាត់តម្រែតម្រង់រឿងការផ្សេង ៗ ដែលអ្នកដទៃតែងក៏មានចំនួនជាច្រើនដែរ ហើយជួយតែងរឿងចុះក្នុងទស្សនាវដ្តី កម្ពុជសុរិយាក្នុងឆ្នាំមុន ៗ នេះក៏មានច្រើនរឿងណាស់ដែរ ។

ឯបំណាច់ដែលលោកបានទទួល គឺព្រះករុណាជាម្ចាស់ជីវិតលើត្បូង ទ្រង់ប្រទានសមណសក្តិ ទីពជាគណៈ កិត្តិយស ( ព្រះឧត្តមមុនី ) ហើយបានទទួលគ្រឿងឥស្សរិយយសម៉ៃដយផ្សេង ៗ ទៀតជាច្រើននៃក្រុងកម្ពុជានេះ និងគ្រឿងឥស្សរិយយសពីព្រះចៅក្រុងហ្វូងព្រះបាទប្រទេសឡាវ ៗ លោកបានទទួលដំណែងនាទី ជាចាងហ្វាងរងនៃក្រុមជំនុំព្រះត្រៃបិដក ក្រសួងពុទ្ធសាសនបណ្ឌិត្យ, ជាអាចារ្យនៃព្រះរាជបណ្ណាល័យ, ជាមេប្រយោគត្រួតប្រយោគកូនសិស្សនៅសាលាបាលីជាន់ខ្ពស់ , ជាសមាជិកកិត្តិយសនៃពុទ្ធិកសមាគមកម្ពុជរដ្ឋ ។

ចប់កិត្តិគុណនឹងការងារជាថ្មីដែរបស់លោកគ្រូ

ព្រះសពព្រះឧត្តមមុនី ( អ៊ុម - ស៊ូរ )

ដោយសង្ខេបតែប៉ុណ្ណោះ ។

## ដំណឹងផ្សេង ៗ

### អំពីអានុភាពនៃពុទ្ធសាសនាគ្របលើពួកអ្នកប្រាជ្ញជាតិឧរុប

មានអ្នកប្រាជ្ញជាតិអង់គ្លេសម្នាក់ ជាអ្នកមានកេរ្តិ៍ឈ្មោះល្បីល្បាញនៅក្នុងប្រទេសរបស់លោករហូតមកដល់មហានគរបារាំងសែស ៗ បណ្ដាសៀវភៅរបស់លោកស្ទើរតែទាំងអស់ បានត្រូវប្រែចេញពីភាសាអង់គ្លេសមកជាភាសាបារាំងសែស ដោយលោកនោះជាអ្នកមានគំនិតដ៏ជ្រាលជ្រៅក្នុងសម័យជំនាន់យើងនេះ ៗ បណ្ដាបុគ្គលដែលបានមើលសៀវភៅរបស់លោក ដែលមានធ្វើសេចក្ដីអធិប្បាយពន្យល់ដល់ពួកអ្នកមើលជាតិបារាំងសែសសរុបរួមសេចក្ដីថា លោកអាល់ដូស៍ ហ៊ុក្សលី មានចំណេះចេះដឹងខាងពុទ្ធសាសនាច្រើន លោកនេះយល់ថា ព្រះពុទ្ធសាសនាជាហេតុដឹកនាំមនុស្សឲ្យមានបែបផែននៃជីវិតប្រព្រឹត្តទៅបានស្រួល មិនឲ្យមនុស្សទាំងឡាយធ្វើជាខ្ញុំបម្រើនៃតណ្ហាតទៅទៀត មិនត្រូវមានចិត្តជាប់ជំពាក់នឹងទ្រព្យសម្បត្តិអ្វីមួយក្នុងលោកនេះឡើយ ហើយកែប្រែផ្លាស់ប្ដូរអាការៈលក្ខណៈឲ្យទៅជាបុគ្គលគ្មានកំព គឺទីបំផុតនៃការរំលត់ទុក្ខ ៗ ការដែលផ្លាស់ប្រែសភាពទាំងស្រុងដូច្នេះ មានសេចក្ដីប្រៀបដូចជាវិជ្ជាពេទ្យដែលមានសេចក្ដីពន្យល់អំពីវិធីបង្ការរោគដឹកនាំមនុស្សឲ្យចៀសពង

ពីជម្ងឺឈឺចាប់កំចាត់បង់នូវសេចក្ដីទុក្ខវេទនាគ្រប់ប្រការ ។ ទុកជាទ្រង់ខំប្រឹងប្រែងដល់ម៉្លោះ ក៏នៅតែមិនអាចបានដើងល័ព្ធដោយគ្រប់គ្រាន់បរិបូណ៌ឡើយ (គឺជាព្រះជាម្ចាស់ទ្រង់ខំប្រឹងប្រោសសត្វឲ្យបានសម្រេចមគ្គផលនៅតែមិនទាន់បានសម្រេចមគ្គផលសព្វគ្រប់) ។

ពុទ្ធសាសនានឹងមានសេចក្ដីចំរើនកើនឡើង ជាលំដាប់ទៅនោះលុះតែអាស្រ័យសេចក្ដីយុត្តិធម៌ នឹងសេចក្ដីស្ម័គ្រចិត្តរបស់បណ្ដាជនទូទៅ ។ លោកអ្នកប្រាជ្ញនេះ បានល្បងយកវិជ្ជាខាងពុទ្ធសាសនាទៅបញ្ចូលក្នុងផ្លូវវិទ្យាសាស្ត្រសព្វថ្ងៃនេះ ដម្រូវទៅតាមនិស្ស័យសន្ដានចិត្តអ្នកស្រុកឥរុប ដើម្បីធ្វើឲ្យគំនិតរបស់យើងកាន់តែរីកធំទូលាយឡើង នឹងដើម្បីធ្វើឲ្យសកលពិភពមានឥស្សរភាពផុតស្រឡះពីគ្រឿងកង្វល់ នាំឲ្យរវល់ឥតប្រយោជន៍ ។

ហេតុនេះ ទើបឃើញថា លោកអ្នកប្រាជ្ញអង់គ្លេសនោះជាអ្នកមានចំណេះខាងបរមត្ថវិជ្ជាយ៉ាងគ្រប់គ្រាន់បរិបូណ៌ ហើយប្រាថ្នាចង់ឲ្យបណ្ដាអ្នកមើលសៀវភៅរបស់លោក អាចនឹងរកគោលសំខាន់ៗ ក្នុងសៀវភៅនោះជាប្រយោជន៍ឲ្យកើតសន្តិភាពក្នុងសកលលោកនេះ ។

*

* *

# អំពីរូបចម្លាក់នៅខេត្តឆាន់ស៊ី ស្រុកចិន

ព្រះរាជបណ្ណាល័យបានទទួលធម្មទានមួយ គឺទស្សនាវដ្ដីភូមិសាស្ត្រ ដែលគេបោះផ្សាយនៅប្រទេសអាមេរិក មានរូបថតល្អៗជាចំនួនច្រើន ៗ កាសែតខែមារ្យ ឆ្នាំ ១៩៣៨ នោះ មានរឿងរ៉ាវដែលមានប្រយោជន៍ច្រើនដល់ពួកយើងជាអ្នកកាន់ព្រះពុទ្ធសាសនា ដ្បិតនៅក្នុងខុមន្គមួយនៅខាងជើងនៃខេត្តឆាន់ស៊ី (ស្រុកចិននោះ) មានរូបល្អដ៏វិចិត្រដែលគេសាងទុកមកប្រហែលក្នុងព្រះពុទ្ធសករាជ ៩៩៥ ៗ រូបអស់នោះជាក្បាច់ចម្លាក់ដែលកើតឡើងដោយស្នាដៃពួកចិនអ្នកកាន់ពុទ្ធសាសនាមានសទ្ធាជ្រះថ្លាមាំ ដោយសាសនានេះមានអានុភាពច្រើន ពុទ្ធសាសនាបង្កើតឲ្យមានបែបក្បាច់សិល្បកម្មនិងអក្សរសាស្ត្រដល់ប្រទេសនោះជាច្រើន ៗ នៅគុហាខ្លះ មានរូបចម្លាក់ធ្វើជាដំណាងព្រះសម្ពុទ្ធនិងព្រះពោធិសត្វជាចំនួនច្រើន និងរូបនាងទេពអប្សរមានពណ៌ផ្សេងៗ ល្អមើលណាស់ ៗ គេមើលឃើញមានរូបសេះកណ្ឋកៈខណៈលាព្រះមហាសត្វជាម្ចាស់ មានរូបដំណាងព្រះពុទ្ធអនាគតជាច្រើន សុទ្ធតែធំៗលើសព្រះពុទ្ធរូបធម្មតាជាទ្វេភាគ ហើយមានព្រះពុទ្ធរូបដ៏វិចិត្រមួយអង្គទ្រង់ស្ដែងប្រទានអភ័យ (គ្រាប្រទានអភ័យ) ៗ នៅជុំវិញគុហាទាំងនោះមានរូបលោកសង្ឃចិនពាក់មួកខ្មៅរណ្ដកំណាត់ក្រហម ៗ

លំអនៃក្បាច់ចម្លាក់ដែលគេឆ្លាក់នៅដើមជញ្ជាំងនិងពិតានសុទ្ធតែជារបស់ពិបាកឆ្លាក់ ប៉ុន្តែពួកជាងនៅតែឆ្លាក់កើត នៅផ្ទាំងជញ្ជាំងនីមួយៗ រាប់ចំនួនរូបចម្លាក់ច្រើនជាង ៦០០ រូបទៅទៀត ។

✲

✲ ✲

## អំពីកំណើតជាន់ទាបនិងជាន់ខ្ពស់

នេះជាឈ្មោះរឿងមួយដែលមានចុះផ្សាយក្នុងទស្សនាវដ្ដី ពុទ្ធសាសនាមហាពោធិជាសេចក្ដីអធិប្បាយរបស់ភិក្ខុនារទៈ ស្រុកលង្កា ដែលយើងបានប្រែសៀវភៅរបស់លោកមកជាភាសាខ្មែរ បានបោះពុម្ពផ្សាយហើយ ហើយមានរឿងខ្លះ ដែលនាំឲ្យសប្បាយរីករាយដល់អ្នកមើលនៅស្រុកខ្មែរយើងនេះ ។

លោកអ្នកតែងរឿងនេះតាំងប្រស្នាថា មនុស្សយើងអាចមានកំណើតជាន់ទាបបានដែរឬទេ? ឆ្លើយថា អាចមានបាន ។ សភាពដែលកើតប្រាកដឡើងឲ្យមើលឃើញច្បាស់ ដូចជាទេវតា មនុស្ស ឬសត្វតិរច្ឆាន ដែលកើតឡើង ហើយមានរូបរាងប្រាកដនោះ ដោយអំណាចកំឡាំងកម្មរបស់ខ្លួន ។

សត្វលោកទាំងអស់នោះ ប្រៀបដូចជាក្រសែភ្លើងអគ្គិស្សនី ប្រាកដរូបចេញមកជាសភាពមានកំដៅ មានពន្លឺ និងមានរញ្ជួយ អស់នេះសឹង

មានអំណាចដាច់ដោយឡែកពីគ្នាតែរៀងខ្លួន ឯកំឡាំងរបស់កម្មក៏មានទំនងដូចគ្នាដែរ តែងបណ្ដាលឲ្យកើតទៅជាទេវតា ជាមនុស្ស ឬសត្វតិរច្ឆានបានដែរ ដោយមិនមានអ្វីមួយមកជួយជ្រោមជ្រែងទៅវិញទៅមកឡើយ ។

មិនត្រូវពោលថា មនុស្សនឹងក្លាយទៅជាសត្វតិរច្ឆានក៏បាន ឬថា សត្វតិរច្ឆានប្រែត្រឡប់មកជាមនុស្សវិញក៏បាន ត្រូវតែនិយាយថា កំឡាំងកម្មនោះអាចប្រែត្រឡប់ឲ្យទៅកើតជាមនុស្ស ឬទៅជាសត្វតិរច្ឆានដូច្នេះវិញទើបត្រូវ ។

ឥឡូវនេះយើងសាងសន្សំកម្មថ្មីឡើងជានិច្ចជានិរន្តរ៍ ទើបយើងមកដល់ជាតិនេះមិនដូចជាតិជាអតីតទេ ដល់ទៅអនាគតទៀតក៏មិនដូចជាតិយើងនៅសព្វថ្ងៃនេះដែរ ។ កាលយើងរលត់ផុតចិត្តពីភពនេះទៅ តែងទៅចាប់កំណើតជាថ្មីទៀត ។ ប្រសិនបើបុគ្គលដែលស្លាប់នោះមានសន្តានចិត្តថោកទាបដោយអំណាចកម្មអាក្រក់ នឹងដឹកនាំទៅកាន់កំណើតថ្មីមួយទៀត ឲ្យល្មមសមនឹងសន្តានចិត្តជាន់ទាបនុ៎ះដែរ ។ អ្នកដែលមិនប្រកាន់ថា កម្មទាំងពួងដែលកន្លងមកហើយនោះជាកម្មឥតផល គឺថាកម្មទាំងនុ៎ះនៅរង់ចាំឱកាសនឹងឲ្យផលហើយដឹកនាំបុគ្គលនោះឲ្យទៅចាប់កំណើតថ្មីដែលថ្លៃថ្នូរ ហេតុនេះ មនុស្សយើងទើបត្រូវតែកើតទៀត នឹងក្លាយទៅជាសត្វតិរច្ឆាន ឬជាមនុស្ស ស្រេចតែកម្មរបស់ខ្លួន ។

ឯកឧត្តមសាយ

# របស់បីគឹម-ហាក់ លេខានុការក្រសួងប្រៃសនីយ៍

តែងនឹងរៀបរៀង

(តនឹងចប់)

# ឈុតទី ៦

## នាងម៉ាល៉ា នឹងហៅហោមស័យបានជួបគ្នាវិញ

សេចក្ដីទុក្ខដែលកើតឡើងក្នុងសន្ដានចិត្តសត្វ មិនបានស្ថិតស្ថេរ ចិរកាលយូរប៉ុន្មានទេ ជួនកាលកើតឡើងមួយភ្លែតខ្លាត់អស់ទៅវិញក៏មាន ជួនកាលនៅកាន់ខែកាន់ឆ្នាំ តែគង់រលាយអស់ទៅដែរ, ក្នុងឱកាសដែលទុក្ខចេញទៅ សេចក្ដីសុខកើតឡើងនាំឲ្យកើតសេចក្ដីរីករាយត្រេកអរ ៗ អ្វីមិនស្មើនឹងត្រេកអររបស់សត្វដែលបានជួបឃើញមុខសង្សារបែកឃ្លាតពីគ្នាយូរ ជួនកាលបណ្ដាលឲ្យយំយែកដោយត្រេកអរពេក សត្វខ្លះស្ទុះទៅឱបថើបគ្នានៅមុខបណ្ដាជនភ្លេចគិតសេចក្ដីអៀនខ្មាស ៗ

ហេតុតែផលពីអតីតរបស់នាងម៉ាល៉ា នឹងហៅហោមស័យពីព្រេងនាយនាំឲ្យបានជួបគ្នាវិញ ក្នុងវេលាដែលនាងម៉ាល៉ាលោតទឹកប៉ងនឹងសម្លាប់ខ្លួននោះ បណ្ដាលឲ្យនាងម៉ុះអផ្សុកតែក្កតប្រម៉ល់អំពល់ទុក្ខ បបួលហៅហោមស័យឲ្យទៅអុំទូកលេងក្នុងទន្លេ នាងម៉ុះនិយាយអង្វរហៅហោមស័យថា បងអើយតាំងពីយើងបានជួបគ្នាមិនដែលមានសេចក្ដីព្រួយបារម្ភអ្វីសោះ ចិត្តយើងតាំងពីនោក់ហាក់ដូចជាគេវេញត្របាញ់ចូលគ្នាមិនដែលខុសហ៊ានអ្វីឡើយ ប្អូនស្រឡាញ់បងជាងខ្លួនប្អូនទៅទៀត បើប្រសិនណាជាប្ដីខ្ញុំត្រឡប់មកវិញ ខ្ញុំនឹងរកឧបាយកលនិយាយឲ្យខាងតែបានបងនៅជាមួយនឹងខ្ញុំបានយូរទៅទៀត ៗ

ហោមស័យ - យ៉ី កុំធ្វើបែបនេះប្អូនអើយ បងសងគុណប្អូនក៏យូរមកណាស់ហើយ ល្មមកាន់តែជិតអស់ណាស់ដែរ ។

ម៉ុះ - នៅច្រើនណាស់ ថ្ងៃនេះពិតតែមានខ្យល់ជំនោរមកពីទិសខាងត្បូង ខ្លួនខ្ញុំក្តៅក្រហាយពេកណាស់ មិនដឹងដូចម្តេចទេ សូមបងមេត្តាជូនប្អូនអុំទូកលេងតាមទន្លេ នាំគ្នាច្រៀងលេងកំសាន្ត ដល់កណ្តាលអធ្រាត្រសឹមយើងត្រឡប់មកផ្ទះវិញ មិនអីទេនៅទីនេះស្ងាត់ណាស់ មានតែយើងពីរនាក់ទេ ធ្វើអ្វីធ្វើបានតាមចិត្ត ។

ហោមស័យ - កុំព្រួយ ចូរប្អូនរៀបខ្លួនឲ្យយ៉ាងឆាប់ បងជូនទៅលេងមិនខាន ។

នាងម៉ុះស្តាប់ហើយក៏ត្រេកអរពេកណាស់ តែងខ្លួនស្លៀកសម្ពត់ហូល ពាក់អាវព្រែ បង់ក្រមាស៊ីយ៉ាងញ៉ាំញ៉ី ដឹកដៃចៅហោមស័យចុះទៅកាន់ទូក ចៅហោមស័យអ្នកអុំ នាងម៉ុះអ្នកច្រៀងផ្តោះផ្តងឲ្យចៅហោមស័យៗ ច្រៀងឆ្លើយតបគ្នាទៅវិញទៅម ។

ម៉ុះ - ប្អូនជិះទូកទៅតាមទន្លេ ចិត្តគ្នេគ្នាន់គិតដល់រៀមក៏ ធោមបងកងផ្ចើតគួរស្នេហា ស្រីណាឃើញហើយសែនប៉ីតិ ។

ហោមស័យ - បងប្រឹងអុំទូកឲ្យប្អូនជិះ ចិត្តបងរេរះដល់សេចក្តីព្រាត់ប្រាសពីនាងម៉ាលាស្រី រៀមស្តីគួរស្តាប់ណាមាសបង ។

ម៉ិះ- ទឹកអើយទឹកហូរម្តេចគ្មានហត់ ពាក្យប្រុសសន្មតពុំដែលត្រង់ ពីដើមកៀកកើយបីត្រកង ឥឡូវអ្នកបងចង់ដោះដៃ ៗ

ហោមស័យ-ទឹកអើយទឹកហូរទៅខាងលិច ខ្លួនរៀមពុំភ្លេចឆោម ស្រស់ស្រី ចិត្តប្អូនល្អណាស់គួរប្រាណី មេត្រីរក្សាគ្នាតទៅ ៗ

ម៉ិះ- បងអើយស្តាប់លោកបោកលើច្រាំង ត្រសូរក្តាំងៗក្នុងយប់ជ្រៅ ណ្ហើយចុះល្មមយើងត្រឡប់ទៅ ឯទីលំនៅយើងវិញណា៎ ៗ

ហោមស័យ- ព្រះពាយបោកផាត់ព្រះគង្គា បងរងរងាញ័រកាយា កម្មអីកម្មាបគួរអនិច្ចា មកព្រាត់សង្សារស្រីសម្លាញ់ ៗ

ចៅហោមស័យ កាត់ទឹកបំបែរក្បាលទូកត្រឡប់មកផ្ទះវិញ ដល់ទូក ងាកក្បាលបន្តិច ខ្លួននាងម៉ាល៉ាអណ្តែតមកប៉ះត្រូវទូកស្ទើរតែក្លុកចូលទឹក នាងម៉ិះភ័យស្រែកថាក្រពើ ៗ កល់ទូក ចៅហោមស័យ ពិនិត្យមើលទៅ ឃើញរូបស្រ្តី ក៏ប្រឹងរួសរាន់ស្រង់ទាញពីទឹកមកដាក់លើទូក អុំស្រូត យ៉ាងរហ័សសំដៅទៅផ្ទះអាត្មា នាំគ្នាសែងទៅដាក់លើគ្រែ អុជចង្កៀង ហើយឃើញស្គាល់ជាក់ជានាងម៉ាល៉ា ប្រពន្ធខ្លួន ក្នុងវេលានោះចៅ ហោមស័យ ហាក់ដូចជាគ្មានបេះដូងស្រែកថា នៃប្អូនសំឡាញ់ ម្តេចមក អណ្តែតតាមទឹកដូច្នេះ ស្ទាបដង្ហើមមើលឃើញនៅខ្យល់ចេញចូលតិច ៗ ខ្លួននៅក្តៅ ចៅហោមស័យ ប្រឹងរូតរឹតគក់ច្របាច់ដុតភ្លើងកំដៅនាង

ម៉ាលា ៗ ដឹងខ្លួនមើលឃើញប្ដីក៏ចេញទឹកភ្នែកព្រោក ៗ តែរកនិយាយពុំរួច លុះចំនួនប្រហែលជាង ១ ម៉ោង នាងម៉ាលានិយាយផងយំផងឱបកប្ដី ស្រដីសាកសួរហេតុតាំងពីដើមរៀងមក ៗ

ចៅហេមស័យប្រាប់ថា កាលដែលទឹកហូរខ្លាំង បងប្រឹងហែលដំរង់ ប្រាំងពុំរួចឡើយ អស់កម្លាំងពេកណាស់ បងបណ្ដែតខ្លួនតាមខ្សែទឹក ហូរហូតមកដល់ទីនេះស្ទើរតែនឹងដាច់ខ្យល់ បាននាងម៉ុះដែលអង្គុយនៅខាងនោះ គាត់ជួយស្រោចស្រង់យកជីវិតបង បងសង្ស័យណាស់ ហេតុម្ដេចបានជាប្អូនលង់ទឹកដូចបងដែរ ៗ

នាងម៉ាលា- ឱបងអើយណាក់ចុំងថ្ងៃ កាលដែលបងលិចបាត់ទៅក្នុងទឹក ប្អូនស្រែកទ្រហោយំឲ្យគេជួយ តែគ្មានអ្នកណាមួយឮសោះ ខ្ញុំទៅប្រាប់បងប្អូនទាំងអស់គ្នា គេប្រឹងផ្អើលឆោឡោរកមួយរំពេច តែពុំបានឃើញបងសោះ ចំនួនបីបួនថ្ងៃក៏គ្មានដំណឹងអ្វី ខ្ញុំអត់បាយក្រហាយទឹក ដេកពុំលក់បក់ពុំល្ហើយដោយសេចក្ដីស្រឡាញ់បង ខ្ញុំទៅរកលោកអាចារ្យតាំសមណ:ធម៌ឲ្យ លោកអាចារ្យនោះប្រាប់ខ្ញុំថា ឃើញសត្វក្រពើមួយលេបរូបបងទាំងមូលទៅក្នុងពោះវា ខ្ញុំរឹតតែសង្រេងសាង្រែទាំងថ្ងៃទាំងយប់ រឿងនេះមិនស្ងាត់បាត់ក៏ឮទៅដល់នាយសត្វា ជាកូនលោកសេនាវិជ័យ វាអរពេកណាស់ គិតថាមួយជាន់នេះច្បាស់ជា

បានខ្ញុំធ្វើកិរិយាមិនខាន ពារៀបបណ្ណាការមកដណ្ដឹងខ្ញុំៗ ប្រកែកៗ ក៏មិនឈ្នះលោកឪពុកម្ដាយខ្ញុំ គាត់កំហែងបង្ខំខ្ញុំ បើចេះតែប្រកែកសមគាត់វាយប្រំដាក់ ដល់យប់ម្សិលមិញនេះ គេរៀបការខ្ញុំនឹងចៅសត្វា ចិត្តខ្ញុំគ្មានចង់ឲ្យប្រុសណាមកកន្ទុំខ្លួនក្រៅអំពីបង ខ្ញុំលបលួចរត់មកមាត់ទន្លេកន្លែងដែលបងបែកពីប្អូនៗ ក៏លោតទឹកប្រាថ្នាឲ្យសាបសូន្យជីវិត ឲ្យបានជួបនឹងបងទៅអនាគតជាតិទៀត ដោយអំណាចយើងបានកសាងជាមួយគ្នាច្រើនណាស់ មិនចាំបាច់ដល់ជាតិក្រោយឡើយ យើងបានជួបគ្នាតាំងពីថ្ងៃនេះតទៅទៀត ។

ចៅហែមស័យគន់មើលមុខប្រពន្ធ អាណិតពេកណាស់ហើយនិយាយថា នេះចំជាបុណ្យយើងមានអំពីមុនមក យើលោកតាអាចារ្យគាំចំជាមហាព្រីលមិនគួរយកធម៌មកមើលទាយស្លាប់រស់ដូច្នេះសោះ មិនអីទេ ចាំបងត្រឡប់ទៅវិញ ទៅធ្វើបាបអាចារ្យនេះឲ្យពេញទី នេះគ្រោះជា បើគ្រោះកាចសមជាប្អូនឯងស្លាប់ទទេ ដោយសារតែជឿតាគាំ ។

ចៅហែមស័យ ថ្ងូងទុក្ខសោកប្រាប់ប្រពន្ធសព្វគ្រប់ ទើបងាកទៅនិយាយសើចនឹងនាងម្ទិះថា ម្នាលប្អូន នេះគឺប្រពន្ធកំសត់កម្មរបស់បងជួបគ្នាបានមួយវស្សាបែកបាក់គ្នាមក ។

ម្ទិះ– “បងចិញ្ចើមធ្វើមុខក្រញូវ” ចាស ខ្ញុំដឹងហើយ នេះចំជាធ្វើគុណបានទុក្ខវិញ ។

ហេមស័យ – បងឲ្យសុខប្អូនឯងយូរមកហើយ ។

ម៉ាលា – អ្នកបងឲ្យសុខអីដល់នាងនេះ ។

ហេមស័យ – បងតបគុណគាត់ ។

ម៉ាលា – តបគុណបែបណាខ្លះ ។

ហេមស័យ – គ្រប់បែបគ្រប់ធុន ។

ម៉ាលាដោយចិត្តប្រចណ្ឌប្ដី ក្រែងប្ដីមិនស្រឡាញ់ខ្លួនប្រឹងនិយាយផងយំផងថា បែបអីខ្លះសូមបងប្រាប់ប្អូនផង ។

ហេមស័យ – នែប្អូន នាងនេះនៅតែឯង ប្ដីទៅរកស៊ីធ្វើការឯស្រុកឆ្ងាយណាស់ ខ្លួនជាស្រីនៅទីស្ងាត់គ្មានមនុស្សម្នាក់សោះ គាត់ឃើញបងគាត់អរអើយអរ ពឹងបងឲ្យនៅកំដរបន្តិច ចាំប្ដីមកដល់ៗ កាលណា បងនឹងលាគាត់ត្រឡប់ទៅវិញ ។

ម៉ាលា – អ្នកបងកំដរគាត់បុះខ្ញុំក៏គ្មានថាអ្វីទេ ។ ពីព្រោះគាត់មានគុណលើយើងណាស់ តែថាប្រុសនឹងស្រីដែលនៅស្ងាត់តែពីរនាក់ហើយច្បាស់ជាអ្វីៗពុំខាន (១) ។

ហេមស័យ- បើប្រុសឯទៀតថា ប្រុសបងខានបានទាំងអស់ ។

ម្ទុះ- ក្រែងតែស្រីគេ ឯស្រីខ្ញុំកុំថាប្រុសតែមួយ ប្រុសដល់មួយរយនៅជិតខ្លួនខ្ញុំក៏មិនត្រូវការ ។

ម៉ាលា - ឯស្រីខ្ញុំត្រូវការតែប្ដីរបស់ខ្ញុំ ក្រៅពីនោះខ្ពើមណាស់ មិនដែលមានប្រុសនឹងស្រីនៅតែពីរនាក់ចំនួនបីខែ អ្នកថាគ្មានធ្វើអីគ្នា ស្ងាត់យ៉ាងហ្នឹងស្រួលយ៉ាងឯកច្ឆន្ទ ចង់ធ្វើម៉ានបានធ្វើណឹង ។

ម៉ិះ - យី ម្ដេចអ្នកឯងពោលពាក្យយ៉ាងហ្នឹង អ្នកឯងស្មានថាយើងជាស្រីផ្កាមាសឬអី នែ ប្ដីអ្នកឯងមកនៅបំរើខ្ញុំចំនួនបីខែមកហើយ គឺគាត់ដឹងគុណខ្ញុំៗ ទុកគាត់ដូចជាបាវបាតជើងខ្ញុំ អ្នកឯងដឹងទេ ។

ម៉ាលា - ពិតហើយ បាវតែថ្ងៃៗទេ តែយប់ប្ដីខ្ញុំធ្វើជាម្ចាស់ត្រួតពីលើអ្នកឯងវិញហើយមិនខាន ។

ម៉ិះ - នែអ្នក យប់ៗឲ្យប្ដីអ្នកឯងដេកក្រោមផ្ទះ ខ្ញុំដេកលើផ្ទះកាំងទ្វារយ៉ាងជិត ។

ម៉ាលា - អើ មែនហើយតែដល់កណ្ដាលអធ្រាត្រអ្នកឯងចុះទៅដេកក្រោម ប្ដីខ្ញុំមកដេកពីលើវិញ ។

ថាហើយក៏ស្ទុះចូលទៅប្រានទ្វារបន្ទប់មើលទៅក្រែសព្វគ្រប់ហើយស្រែកថា នំមើលចុះ លោកអើយលោក ខ្នើយពីរទន្ទឹមគ្នា ខោអាវសារុងប្ដីខ្ញុំនៅពាក់ចុងក្រែទាំងអស់ នៅតែគេអួតថាមិនត្រូវការនឹងគ្នាទៀត ។

ម៉ិះ - យី ខ្នើយមួយនោះសម្រាប់ប្ដីខ្ញុំទេតើ ខោអាវសារុងប្ដីអ្នកឯងខ្ញុំយកមកទុកខាងក្នុងឲ្យ ក្រែងគេលួច យើនេះចំជាក្រពើវង្វេងបឹង ។

ម៉ាលី - ប្រាកដហើយ ទាំងរូបប្តីខ្ញុំក៏អ្នកឯងយកទៅទុកខាងក្នុងដែរ ក្រែងស្រីៗលួច ។

មុំ - ធ្លាប់អ្នកឯងយកប្តីគេទៅទុកក្នុងបន្ទប់ខ្លួន មាន់ណាខ្ពតមាន់ហ៊ឹងពង ពិបាកណាស់ ម៉ោៗ ទៅយកដីក្រឡាមកគៀតកៀក ។

ម៉ាលី - យី អ្នកឯងមិនទាន់ដឹង ដីក្ដៅនេះស្អិតផ្អែមខះកញ្ជ្រីខ្លួន ។

ចៅហោមស័យ ឃើញស្រីទាំងពីរនាក់ឈ្លោះប្រកែកគ្នាខ្លាំងៗដូច្នោះហើយ ស្ទុះទៅដឹកដៃនាងម៉ាលីចុះទៅដី នាំដើរទៅក្រៅភូមិ និយាយអង្វរចិត្តប្រពន្ធកុំឲ្យប្រកាន់ប្រកួត ធ្វើដូចម្តេចជាធម្មតារបស់មនុស្សលោក ។

ម៉ាលី - នេះបំជាស្រឡាញ់បងចិត្តមិនគួរមកក្បត់ខ្ញុំដូច្នេះសោះ ឯងប្រឹងស្រឡាញ់គេស៊ូប្តូរជីវិត ឯគេវិញគេធ្វើព្រងើយកន្តើយមកដេកប្រៀនប្រែងលាក់ខ្លួនពួនមុខក្នុងព្រៃស្ងាត់ជាមួយបងនឹងស្រីសាមាណ្យនេះ ។

ហោមស័យ - បងដឹងអស់ហើយតែបងមានចិត្តអាណិតនាងនេះណាស់ពីព្រោះគេមានគុណលើយើងទាំងពីរ ។

ម៉ាលី - ឯគុណនោះត្រូវទុកទៅវេលាក្រោយ គួរណាស់ត្រឡប់ទៅស្រុកវិញប្រាប់ឲ្យខ្ញុំដឹងថា បងមានជីវិតនៅឡើយ មិនគួរឲ្យគេមួយស្រុកកើតទុក្ខហើយមកស្រណុកតែម្នាក់ឯង នេះបំជាមនុស្សឥតបើគិត កុំអីចៅសត្វាមិនហ៊ានមើលងាយខ្ញុំៗក៏មិនបានលោតទឹកសម្លាប់ខ្លួនបែបនេះ

ទេ ឱសមលោកឪពុកម៉ែបងប្អូនទាំងអស់គាត់សោកសង្រេងយ៉ាងណាទៅហ្ន៎ ។

ហេមស័យ — បងបានជាខុសទៅហើយ មួយទៀត នៃនាងម៉ូរ៉ះនេះវាចេះមន្តវិជ្ជាការធ្វើស្នេហ៍ជាក់បង ប្រុសណាបានប្រទះវាម្តងហើយម្តងទៀត ។

ម៉ាលា — នេះចំជាស្នេហ៍ពូកែមែន ឯស្នេហ៍មកតែពីស្និទ្ធ បើចិត្តវាមិនជិត ស្នេហ៍ណាក៏ជាក់មិនត្រូវ ។

ហេមស័យ — អើប្អូនឯងតែងមាត់មាត់ចេះតែថា ៗ ទៅ បងចេះតែទទួលពាញ់ជានិច្ច ប្តីនាងម៉ូរ៉ះវាធ្វើមេចោរធំណាស់សព្វថ្ងៃនេះវាកំពុងតែលុកលុយប្លន់ឯព្រំប្រទល់ដែនសៀម វាបានរបស់មកកប់ក្នុងដីភូមិនេះច្រើនណាស់ ប្រពន្ធវាប្រាប់កន្លែងបងអស់ហើយ ។

ម៉ាលា — ឱពុទ្ធោកម្មអើយ នាងនេះប្តីវាធ្វើមេចោរ ថែមទាំងវាធ្វើចោរលួចប្តីគេទៀត ខ្ញុំអត់មិនបានទេ ខ្ញុំស្រែកជេរកណ្តាលយប់ឥឡូវហ្នឹង ។

ហេមស័យលើកប្រពន្ធបីថើបដាក់ដៃបិទមាត់ប្អូនថាកុំនិយាយឮពេក កុំឲ្យនាងម៉ូរ៉ះឮ ក្រែងបែកការ ចាំដល់ពីរបីថ្ងៃទៀត បងនឹងនាំប្អូនត្រឡប់ទៅស្រុកវិញមិនខានឡើយ ។

ទៅហេមស័យក៏នាំនាងម៉ាលាឡើងមកដេកលើផ្ទះវិញ ។

នាងម៉ូះអង្គុយកើតទុក្ខ ដកដង្ហើមធំយូរៗ ជូតទឹកភ្នែកនៅកៀនសសរ ធ្វើម៉ឺះៗមកគិតគ្នាន់ក្នាញ់ថា មេនេះរូបល្អបែបហ្នឹង បានជាប្តីក៏នឹកគ្មានឈប់មួយវេលា តែងសរសើរប្រពន្ធក៏ប្រាប់អញរាល់ៗយប់ មិនអីទេ យ៉ាងយូរណាស់ត្រឹមបីថ្ងៃទៀត អញរកឧបាយកលសម្លាប់មេហោរមុខក្រាស់នេះឲ្យទាល់តែបាន ។

ដល់ម៉ោងមួយយប់សន្សើមធ្លាក់ត្រជាក់ចុះអន្ទា នាងម៉ូះទៅជាក្តៅអន្ទះអន្ទែងដេកពុំលក់ លបមើលឃើញចៅហេមស័យ ដេកជាមួយនឹងប្រពន្ធ ទ្រូងនាងម៉ូះស្ទើរតែបែកជា ១០ភាគ ស្ទើរនឹងស្ទុះទៅប្រហារជីវិតនាងម៉ាលាឲ្យស្លាប់ទៅក្នុងយប់នោះ ប្រឹងខំលេបភ្នែកសង្កត់ចិត្ត លុះដល់ព្រឹកឡើងនាងម៉ូះធ្វើឫកញញឹកញញ័ក់ញញាំញញើ មុខរីកប៉ប្រិមនិយាយឲ្យចៅហេមស័យទៅរកចាប់ត្រីឯទន្លេ យកមកធ្វើអាហារអាស្រ័យ ចៅហេម-ស័យក៏ទៅតាមពាក្យនាងម៉ូះៗ អរណាស់គិតថា មេម៉ាលាឯងមួយជាន់ហ្នឹងហើយធ្វើជាសើចក្អាកក្អាយ មុខញញឹមប៉ប្រិមនិយាយទៅនាងម៉ាលាថា ណ្ហើយ ការដែលយើងប្រកែកគ្នាពីថ្ងៃម្សិល គោងលែងប្រកាន់ទៅ កុំខឹងនាំខុសហើយខាតផង នៅវិះនេះមានស្រីតែពីរនាក់គួរតែយើងស្រឡាញ់គ្នា អញ្ជើញអ្នកពិសាស្លា ចាំខ្ញុំទៅយកនំចំណីមកជូនអ្នកទៀត នាងម៉ូះចូលទៅយកនំប្រកប់ដោយថ្នាំពិសបំពុលឲ្យនាងម៉ាលាបរិភោគ ។

នាងម៉ាលីជាស្ត្រីអ្នកមានប្រាជ្ញាឆ្លាតវៃ ពិចារណាដឹងដល់ដើមទងទំនងទឹកចិត្តនាងម្ទិះ ទើបនិយាយទៅថា ហេតុខ្ញាមពីថ្ងៃម្សិលខ្ញុំក៏ឈប់នឹកនា ធ្វើម្តេចអ្នកអើយ បុរសនឹងស្ត្រីតែស្រឡាញ់គ្នាខ្ជាប់ខ្ជួនហើយរមែងមានសេចក្តីប្រចណ្ឌស្ទើរតែគប់គ្នា ឯចំណីអស់នេះខ្ញុំពុំហ៊ានអាស្រ័យឡើយ ចាំប្តីខ្ញុំមកដល់វិញពីព្រោះខ្ញុំពុំចេះបរិភោគរបស់អ្វីមុនប្តីខ្ញុំឡើយ ។

ម្ទិះ – អ្នកកុំព្រួយ ប្តីអ្នកគាត់ពិសារួចស្រេចពីម្សិលមិញហើយ ចាំគាត់ឯណាបាន ដល់ជិតថ្ងៃត្រង់បានគាត់ត្រឡប់មកមុខជានំចំណីអស់នេះផ្អូមខូចអស់ទទេ ។

នាងម៉ាលីសង្កេតឃើញសត្វរុយដែលមកទំលើចំណីអស់នោះដល់ហើរចេញទៅធ្លាក់ស្លាប់រណែលរលើក្តារមានចិត្តមួម៉ៅយោរយៅ តែខំអត់ចាំប្តីមកទើបប្រាប់ ធ្វើពើជាសួរនាងម្ទិះថា នំអ្នកច្បាស់ជាឆ្ញាញ់ណាស់ហើយមើលទៅ បានជាសត្វរុយគ្រាន់តែមកពេមបន្តិច គេចទៅជាបែកពោះស្លាប់អស់ នំនេះគេហៅនំអីអ្នក ។

ម្ទិះ-យី អ្នកឯងពុំស្គាល់ទេ នំនេះឆ្ញាញ់ពិសាណាស់ គេហៅថានំអន្ទរ អ្នកពិសាទៅកុំបង្អង់យូរក្រែងខូច ។

ស្រីទាំងពីរនាក់កំពុងតែជជែកគ្នា ចៅហេមស័យមកដល់ក៏សួរថាមានរឿងអីទៀតហើយ ។

ម៉ាលា — បងអើយមើលចុះ ខ្ញុំក្នុងខណៈនេះអត់លែងបានទៀតហើយ អ្នកម្ទិះចិត្តខ្មៅអាក្រក់ណាស់ គាត់ហ៊ានយកចំណីដាក់សុទ្ធតែថ្នាំពុលមកឲ្យខ្ញុំអាស្រ័យ ។

ចៅហេមស័យប្រឹងកកាយនំមើល ឃើញសុទ្ធតែថ្នាំពុលបង្កប់នៅក្នុង ហើយនិយាយពោលពាក្យត្មះតិះដៀលនាងម្ទិះ ជាអនេកបរិយាយ នាងម្ទិះមានសេចក្ដីទោសៈកើតឡើងក្នុងវេលានោះ អៀនខ្មាសមុខឡើងជាំខ្មៅដោយខ្លួនប្រព្រឹត្តអំពើលាមក ក៏បេះតែយំហើយស្រែកដេរនាងម៉ាលា ៗ នឹងចៅហេមស័យខឹងណាស់ នាំប្ដីប្រពន្ធ ចាប់នាងម្ទិះចងជាប់នៅសសរផ្ទះមិនឲ្យបម្រះរួច ហើយនាំគ្នាយកចបទៅជីកយកទ្រព្យរបស់គ្រឿងមាស — ប្រាក់កប់ក្នុងដី ដែលចោរប្ដីនាងម្ទិះប្លន់បានទាំងប៉ុន្មានរៀបធ្វើជាសំពាយស្ពាយរត់ត្រឡប់ទៅស្រុកអាត្មាវិញ ។

នាងម្ទិះនៅក្នុងផ្ទះតែម្នាក់ឯង ស្រែកយំស្រែកដេរ ទឹកស្ដាយចៅហេមស័យណាស់ មិនដឹងធ្វើដូចម្ដេច បម្រះក៏មិនរួចផង ប្រឹងទាំកគេរបំណងក៏ពុំជាប់ឡើយ ម្ល៉ោះហើយពឹតតែពីស្រែករកគេជួយស្រាយ ដល់ជិតពាក់កណ្ដាលយប់មេចោរជាប្ដីនាងម្ទិះ ត្រឡប់មកដល់ផ្ទះវិញ ឃើញប្រពន្ធគេចងជាប់នៅសសរហើយសង្ស័យណាស់ ក៏សួរថា ហេតុដូចម្ដេចបានជាប្អូនឯងមកជាប់នៅសសរផ្ទះដូច្នេះ ។

នាងម្ទិះ - បងអើយកាលព្រឹកមិញនេះមានពួកចោរពីរនាក់ឡើងមកលើផ្ទះយើង វាច្របាច់កខ្ញុំឲ្យប្រាប់កន្លែងទ្រព្យសម្បត្តិរបស់យើង ខ្ញុំក៏ពុំហ៊ាននៅស្ងៀមបាន ខ្លាចក្រែងវាសម្លាប់ខានឃើញមុខបងតទៅទៀត វាប្រឹងទៅកកាយយករបស់ដែលកប់នៅក្នុងដីទាំងប៉ុន្មាន រួចវានាំគ្នាចងខ្ញុំជាប់នៅសសរនេះ ហើយរត់បាត់អស់ទៅ ខ្ញុំប្រឹងស្រែកអើយស្រែកហៅគេជួយ តែគ្មានអ្នកណាមួយមកសោះ អត់បាយតាំងតែពីព្រឹករហូតមកដល់វេលានេះ ។

មេចោរឮដូច្នោះហើយ ក៏យកកាំបិតទៅកាត់ចំណងស្រាយប្រពន្ធចេញហើយក៏ស្រែកថា អើមួយជាន់នេះអបរាជ័យអស់ហើយ ទៅឯនោះរកគ្មានអ្វីសោះ គេដេញតាមទាន់ដណ្ដើមយករបស់គេទៅវិញ ថែមទាំងសម្លាប់អស់ចោរបីនាក់ទៅទៀត មកឯនេះប្រពន្ធគេចងជាប់នៅសសរ ទ្រព្យមានប៉ុន្មាន គេប្លន់យកពីឯងអស់រលីងទៅទៀត នេះបំជាកាលកណ្ណីធំ ប្រាក់ក៏បង់ថង់ក៏ដាច ឱអញអើយ តាំងពីថ្ងៃនេះទៅហើយ សមជារងទុក្ខវេទនាលំបាកដោយការរកចិញ្ចឹមជីវិតបានដោយក្រណាស់ មេ-ចោរចូលទៅដេកសន្ធឹកសន្ធៃ ភ្នែករំពៃគន់មើលរបស់នៅក្នុងផ្ទះ ឃើញខោអាវសារុងប្លែកក្លិន ខ្នើយដែលខ្លួនដេកក៏ខុសពីដើមទៀត សង្ស័យណាស់ក៏សួរទៅប្រពន្ធថា ខោអាវសារុងអស់នេះប្អូនបានពីណាមក ទំដំ-ណេកធុំក្លិនប្លែក សមជាមានអ្នកណាមកដេកមកនៅទីនេះមិនខាន ។

ម៉ុះ- គ្មានអ្នកណាទេ មានតែអាពីរនាក់ព្រឹកមិញវាស៊ីដេកលើគ្រែនេះ នាំគ្នាមើលមុខខ្ញុំស្រេច ឯងយំវាស្រេច ខោអាវនោះគឺរបស់វាទាំងអស់ បងកុំបារម្ភឲ្យសោះ ខ្ញុំមិនស្រីផ្តេសផ្តាសឡើយ បើខ្ញុំមានពុតមាយាខអាក្រក់ ខ្ញុំរត់ចោលបងបាត់ទៅហើយ ។

មេចោរជឿប្រពន្ធខ្លួនពេកណាស់ ថាល្ហើយរបស់ទ្រព្យប៉ុណ្ណឹងខូចខាតចោលទៅចុះ កុំឲ្យតែខូចខាតខ្លួនបងអូនឯង ។

## ឈុតទី ៧

### ចៅហេមស័យនឹងនាងម៉ាល៉ាបានសេចក្តីសុខ

ចៅហេមស័យនាងម៉ាល៉ាដើរយ៉ាងរហ័សចូលទៅក្នុងព្រៃ គាត់ដំរង់ទៅស្រុកខ្លួន ដល់ទីមួយស្ងាត់ពុំតែម្រឹគបក្សាបក្សីយំទ្រហឹងអឺងកងរំពង ខ្លះចឹកផ្លែឈើស៊ីលេងសប្បាយ ខ្លះហើរលោតលើមែកព្រឹក្សា ចៅហេមស័យនឹងម៉ាល៉ាដាក់សំពាយប្រះខ្លួនដេកក្រោមម្លប់ឈើ វាយោផាត់វាយត្រជាក់ជ្រួតជ្រាបពេញសព៌ាង្គកាយរហូតដល់ដួងហឫទ័យ ជនទាំងពីរនាក់ស្រើបស្រាលដោយកាមតណ្ហា ដេកប្រកៀកប្រទុបគ្នាកណ្តាលព្រៃ ។

ចៅហេមស័យ និយាយទៅប្រពន្ធថា យើងបានជួបគ្នាម្តងនេះហាក់ដូចជាបានរស់ឡើងវិញជាថ្មីទៀត ប្អូនមើលចុះដើមឈើខ្លះជ្រុះស្លឹកអស់

រលើង នេះដូចខ្លួនយើងកាលមានទុក្ខវេទនាពិបាកគោកយ៉ាកស្ទើរនឹងក្ស័យជីពជន្ម នឹមើលដើមរុក្ខាខ្លះកំពុងតែលូតលាស់សន្ធឹកជាថ្មីវិញទៀត នេះដូចរូបយើងទាំងពីរនាក់ បានជួបមុខឃើញគ្នាបានសេចក្តីសុខស្រួលឡើងវិញ ឱប្អូនអើយ យើងនៅដើរចំនួនមួយថ្ងៃទៀតបានដល់គេហស្ថានយើង សមជាមាតាបិតាញាតិសាលោហិតយើងអរណាស់ សូមប្អូនខំដើរបន្តិចទៅ បើដើរពុំរួចឲ្យបងពក៏ពដែរ ៗ

នាងម៉ាល៉ា-បងមើលសត្វរមាំងឈ្មោលញីទាំងគូ ស៊ីស្មៅរួចបោលពេញព្រឹក្សា នេះដូចខ្លួនយើងនាំគ្នាដើរកាត់វាលចូលព្រៃទាំងថ្ងៃទាំងយប់គួរឲ្យកំសត់កម្រនឹងគ្នាណាស់ កម្លាំងប្អូនកុំថាតែដើរត្រឹមមួយថ្ងៃ ដប់ថ្ងៃទៀតក៏បានដែរ តែបើដើរជាមួយនឹងបង បើដើរជាមួយនឹងអ្នកដទៃតែមួយថ្ងៃច្បាស់ជាពុំរួចឡើយ ៗ

ចៅហេមស័យ ស្តាប់ហើយលើកបីត្រកងប្រពន្ធថា យីប្អូនឯងខ្លាំងណាស់តើ រួចក៏នាំនាងម៉ាល៉ាត្រេចគោចរតាមជន់ព្រៃរហូតដល់ដើមភូមិមនុស្សអ្នកស្រុកទាំងអស់គ្នាផ្អើលគោឡោ ខ្លះស្រែកថា ចៅហេមស័យនឹងនាងម៉ាល៉ាបណ្តើរគ្នាមកពីណាវិញ ៖ យើងស្មានថាវាស្លាប់បាត់អស់ទៅហើយ ពីព្រោះគ្មានដំណឹងអ្វីសោះចំនួនកន្លះឆ្នាំ អើនេះចំជាគូព្រេងរបស់គេ ៗ

ចៅស៊ីណាទឹងនាងបូផាផាន់អង្គុយនៅក្បាលដំណេក ក្រឡេកទៅឃើញកូនទាំងពីរ ប្រឹងលោតតាំងតែពីលើផ្ទះរត់ទៅឱបថើបនាងម៉ាលា អង្អែលក្បាលចៅហោមស័យ សួរសោកអំពីកាលដែលលិចលង់ទឹកបែបដូចម្ដេចខ្លះ នាងម៉ាលាជំរាបម្ដាយសព្វគ្រប់ប្រការគ្មានខ្វះ ចៅស៊ី-ណានិយាយប្រាប់ចៅហោមស័យជាកូនប្រសាថា ឪពុកជាគិតខុសទៅហើយ បានជាឪប្រឹងបង្ខំនាងម៉ាលាឲ្យយកប្ដីទៀតមកពីជឿពាក្យអាចារ្យតាំគាត់ថាកូនឯងស្លាប់ទៅហើយ ឥឡូវនេះចៅសត្វាក៏លោតពីលើដើមគគីរសម្លាប់ខ្លួនទៅដោយសេចក្ដីសោកស្ដាយនាងម៉ាលាណាស់ កូនឯងទាំងពីរនាក់សំណាងខ្ពស់ណាស់គ្មានអ្នកណាស្មើទេក្នុងទីនេះ ។

ចៅហោមស័យទឹងនាងម៉ាលា ឡើងទៅលើផ្ទះហើយស្រាយសំពាយយកទ្រព្យមកចែកជូនឪពុកម្ដាយទាំងពីរខាងស្មើគ្នា ឪពុកម្ដាយត្រេកអរណាស់ ចៅស៊ីណាលាន់មាត់ថា អញស្មានខុសថាតែក៏មិនកើត ឥឡូវនេះទៅបាត់តែកន្ទះឆ្នាំគេបានរបស់សន្ធឹកយកមកចែកបាយឲ្យឯង នេះចំជាកូនព្រេងកូនសំណាងអំពីអតីតមក ។

បូផាផាន់-ម្ដេចខ្ញុំថាខុសប្ដីត្រូវ ឥឡូវដូចម្ដេចទៅកូនយើងទៅបាត់តែកន្ទះឆ្នាំ គេបានគ្រឿងមាសប្រាក់ពីរសំពាយ យកឲ្យយើងដេកស៊ីទាល់តែស្លាប់មិនអស់ផង ។

ស័ណា- បុរាណគេថា បើវេញពាន់កុំឲ្យដាច់កែង បង់បាទជាតិគត ខុសទៅហើយលែងនឹកនារឿងនេះទៀត ។

ចៅហេមស័យនៅជាសុខសាន្តនឹងប្រពន្ធ-ឪពុកម្តាយបងប្អូន មាន ពេលមួយបុរសនេះមកសញ្ជឹងគិតក្នុងខ្លួនថា ប្រពន្ធអញក្តី កេរ្តិ៍ឈ្មោះ អញក្តី បានរងទុក្ខវេទនាអាប់អួនមកតែពីតាអាចារ្យគាំគាត់សមណធម៌ អញគោរពប្តឹងតុលាការ ឲ្យប្រដៅតានេះ កុំឲ្យគាត់ចេះតែប្រព្រឹត្តអំពើ នេះតទៅទៀត ដល់ព្រឹកចៅហេមស័យ កន្ត្រាក់យកក្រដាសធ្វើពាក្យ ប្តឹងក្រសួងតុលាការ ដូចមានសេចក្តីយការណ៍ខាងក្រោមនេះថា :

សូមទានខ្ញុំប្របាទម្ចាស់ឈ្មោះហេមស័យជាតិជាខ្មែរអាយុ ២៥ ឆ្នាំ នៅភូមិអង្គរ ខេត្តអង្គរ សូមក្រាបប្រណិប័តន៍ចូលមកលោកចៅក្រមនឹង ចាងហ្វាងក្រសួងតុលាការខេត្តអង្គរសូមទានជ្រាប ។

ដ្បិតកាលពីប្រាំមួយខែមុននេះ ខ្ញុំប្របាទម្ចាស់បាននាំប្រពន្ធឈ្មោះ នាងម៉ាលា ទៅងូតទឹកលេងនៅមាត់ទន្លេសាប ជាបាបគ្រោះរបស់ខ្ញុំ ប្របាទម្ចាស់ ។ ហែលពុំរួចអណ្តែតខ្លួនទៅតាមខ្សែទឹកហូតដល់ចុងទន្លេ នោះ- ឯនាងម៉ាលាជាប្រពន្ធខ្ញុំប្របាទម្ចាស់ ស្មានថាខ្ញុំប្របាទម្ចាស់ ស្លាប់បាត់ក្នុងទឹកទៅហើយ ក៏ទៅពឹងលោកតាអាចារ្យគាំ ផ្ទះនៅ ភូមិជាមួយគ្នា ឲ្យអង្គុយធម៌តាមមើលព្រលឹងខ្ញុំប្របាទម្ចាស់តើនៅទីណា

លោកតាអាចារ្យគាំបង្គាប់ឲ្យនាងម៉ាល៉ារកសំពត់សដល់ដប់ហត្ថ ប្រាក់ដល់កន្លះណែន ទើបអង្គុយធម៌ឲ្យ នាងម៉ាល៉ាក៏ព្រមធ្វើតាម អាងខាននាងបូជាជាន់ម្ដាយក្មេកខ្ញុំប្របាទម្ចាស់ជាសាក្សីឲ្យបានដឹងបានឮផង ដល់បានគ្រឿងសក្ការបូជានេះសព្វគ្រប់ហើយ តាអាចារ្យគាំសំដែងវិធីតាំងឈានទៅឃើញថារូបខ្ញុំប្របាទម្ចាស់នេះនៅក្នុងសត្វក្រពើមួយ នាងម៉ាល៉ាប្រឹងសោកសង្រេងអត់បាយក្រហាយទឹកដោយសារជឿពាក្យតាគាំ មិនតែប៉ុណ្ណោះសោត កាលពីខែមុននេះ លោកសេនាវិជ័យស្មានថា ប្រពន្ធខ្ញុំប្របាទម្ចាស់មេម៉ាយពិត លោកបាត់ចែងបណ្ណាការមកដណ្ដឹងនាងម៉ាល៉ាឲ្យជាគូនឹងចៅសត្ថាជាកូនលោក ប្រពន្ធខ្ញុំប្របាទម្ចាស់ដែលមានចិត្តស្លូតត្រង់នឹងប្ដី មិនចង់ឲ្យប្រុសមកកន្ទងខ្លួនបានច្រើននាក់ ក៏លួចរត់ទៅលោតទឹកប្រាថ្នានឹងសម្លាប់ខ្លួន ក្នុងវេលាថ្ងៃរៀបអាពាហ៍ពិពាហ៍មង្គលការ ចៅសត្ថាបានដឹងថា នាងប្រព្រឹត្តបែបនេះហើយ ហេតុតែស្រឡាញ់នាងនេះខ្លាំងណាស់ ក៏ឡើងទៅលើចុងគគីរមួយដើមលោតទំលាក់ខ្លួនមកស្លាប់មួយរំពេចទៅ ។

ឯចំណែកនាងម៉ាល៉ា អណ្ដែតខ្លួនទៅជួបនឹងខ្ញុំប្របាទម្ចាស់កំពុងតែជិះទូកក្នុងទន្លេ ។

រឿងរ៉ាវអស់នេះ ប្រហែលព្រះតេជព្រះគុណម្ចាស់បានជ្រាបខ្លះហើយមិនខាន ឯចៅសត្ថាក្ដី នាងម៉ាល៉ាក្ដី គិតប្រហារជីវិតខ្លួននេះ មក

តែពីពាក្យទំនាយលោកតាអាចារ្យគាំ ក្តីឈ្មោះខ្ញុំប្របាទម្ចាស់សាយអសោចពេញភូមិក៏មកពីតានេះដែរ ។

ហេតុនេះសូមព្រះតេជព្រះគុណម្ចាស់ មេត្តាហៅឈ្មោះតាគាំនេះមកជំនុំជំរះតាម ទោសានុទោសប្រដៅកុំឲ្យគាត់ប្រព្រឹត្តអំពើទុច្ចរិតនេះទៀត ទើបខ្ញុំប្របាទម្ចាស់បានសុខចិត្តតរៀងទៅ ។

សេចក្តីគួរពុំគួរសូមមេត្តាខមាទោស

ស៊ីញ៉េឈ្មោះ ហេមស័យ

លោកចាងហ្វាងសាលាបានទទួលពាក្យបណ្តឹងនេះហើយក៏យកឲ្យសុភាចារបុរេសពិនិត្យ ចាត់ឲ្យក្រឡាបញ្ជីធ្វើដីកាកោះខ្លួនតាគាំមកសួរចម្លើយ ។

តាគាំ វេលាដែលបានទទួលសំបុត្រដីកាកោះមានចិត្តងឿងឆ្ងល់ណាស់ថា អញតាំងពីក្មេងរហូតមកដល់ចាស់ប៉ុណ្ណេះមិនដែលកើតខ្មាមអ្វីឡើងសាលាម្តង ទើបតែថ្ងៃនេះអញមានទាស់ហេតុអីនឹងអ្នកណា តាគាំយកវ៉ែនតាមកពាក់ប្រឹងពិនិត្យមើលសេចក្តីនៅក្នុងដីកាកោះថា មានចៅហេមស័យចោទប្រកាន់ជាបទឧក្រិដ្ឋ តាគាំស្រែកហៅនាងម៉ុកជាប្រពន្ធថា ម៉ុកអើយមកអាយ អញមួយជាន់នេះមានរឿងធំណាស់ហ៊ើយ ។

នាងម៉ុក — ស្អីតា ៗ ថាអី ។

តាគាំ — មានរឿងធំណាស់ ។

នាងម៉ុក — រឿងអី ។

តាគាំ — រឿងឧក្រិដ្ឋ ។

នាងម៉ុក — ស្អី-រឿងឧក្រិដ្ឋ ។

តាគាំ — អញថាឧក្រិដ្ឋៗ ហើយកុំសួរច្រើន មួយជាន់នេះ បើមិនស្តាប់ក៏រស់ បើមិនខ្លោះគង់តែឃ្លាន បើមិនឃ្លាន គង់តែប្រាក់ ។

នាងម៉ុក — ស្អី ឧក្រិដ្ឋស្តាប់រស់ ខ្លោះឃ្លានប្រាក់ខ្ញុំមិនយល់ទេ ។

តាគាំ — នាងឯងនៅសប្បាយតែម្នាក់ឯងចុះ ធ្វើខ្លួនឲ្យយ៉ាងហ៊ឺរកកំឡោះទៅ ។

នាងម៉ុក — តាឯងថាអី តាឯងទៅណា ។

តាគាំ — យើ អញថា អញឧក្រិដ្ឋហើយ ។

នាងម៉ុក — (មិនយល់ពាក្យឧក្រិដ្ឋ ស្រែកថា) តាឯងអុកក្តិតពីកាលណា ។

តាគាំ — យើ នាងនេះ ឯងថាឧក្រិដ្ឋ រាថាអុកក្តិត អញជាប់ទោទបទឧក្រិដ្ឋ គឺថាទោសធំណាស់ មានតែគុកនឹងប្រាក់ដឹងឬទេ នែស្អែកដល់ថ្ងៃត្រង់បើពុំឃើញអញត្រឡប់មកពីសាលាវិញ ឯងទៅលប

មើលអញផង អាណិតយកបាយឲ្យអញស៊ីកុំខាន ។

នាងម៉ុក - តាឯងមានខុសអីបានជាមានទោសដល់ទីនេះ ។

តាគាំ - ឈ្មោះហោមស័យក៏ប្តឹងពីអញ ។

នាងម៉ុក – ស្តាប់ហើយតាអើយតា ច្បាស់ជារឿងសមណធម៌ហើយ គ្មានអីទេ ។

ដល់ព្រឹកឡើងតាគាំស្លៀកសំពត់សពានាស ស្ពាយថង់យាមដៃឆ្វេងកាន់តម្រាមួយ ដៃស្តាំកាន់ឈើច្រត់ដើរទៅសាលា នាងម៉ុកស្រែកថា ជយោតាគាំ ជយោតាគាំ តាគាំទៅដល់សាលាយកដីកាកោះឲ្យទៅសុភាចារបុរសៗ ក៏សូត្រពាក្យចោទឲ្យស្តាប់ហើយសួរថា :

សុភា — តាគាំឯងបានសមណធម៌តាមមើលព្រលឹងចៅហោមស័យមែនឬទេ ។

តាគាំ — ប្របាទម្ចាស់ មែនពិតហើយ ។

សុភា — អន្ទ័យសមណធម៌ម្តងៗ ប្រហែលចំនួនកន្លះម៉ោង ហេតុដូចម្តេចបានជាថ្លៃច្រើនដល់ម្ល៉េះ ។

តាគាំ — ទានប្រោស នេះគឺបណ្តាំរបស់គ្រូខ្ញុំប្របាទបង្គាប់ឲ្យទារថៃបហ្នឹង ទើបបានឆាប់រួចសោហ៊ុយបង់ខាតកាលដែលសិក្សារៀនសមណធម៌នេះ លាក់បាំងថ្វីកាលខ្ញុំប្របាទ អស់ប្រាក់ចំនួនម្ភៃណែន ចំណាយទិញត្រៃចីវរទៀនធូបតែស្លាបូជាគ្រូទើបបានចេះប៉ុណ្ណឹង ។

សុភា — តើពឹងឲ្យតាឯងសមណធម៌ប៉ុន្មាននាក់ហើយ រកស៊ីបែបនេះប៉ុន្មានឆ្នាំហើយ ។

តាគាំ — បាទប្រុស គេរកខ្ញុំប្របាទឲ្យសមណធម៌តិចណាស់ត្រឹមមួយរយនាក់ដែរ ក្នុងរវាងតែកន្លះឆ្នាំនេះទេ ពីព្រោះខ្ញុំប្របាទទើបនឹងសឹកកាលចេញវស្សានេះ ។

សុភា — ណ្ហើយថាត្រឹមតែមួយរយនាក់ចុះ តាឯងបានឈ្នួលហាសិបណែនទៅហើយ នេះបានចំជារកស៊ីចូរ តាឯងដែលអង្គុយធម៌ តាមចំណាំតាឯងនិមិត្តដែលតាឯង ឃើញប៉ុន្មានតើយកការប្រមាណបានឬទេ ។

តាគាំ — បាទប្រុស ជាការពិតល្អណាស់ ឯនាងម៉ាណៃដែលមកឲ្យខ្ញុំប្របាទម្ចាស់មើលនេះ វេលានោះខ្ញុំប្របាទម្ចាស់អស់កំឡាំងពន់ពេក កំពុងតែតារនោក៏ដេកលក់ទៅ ទើបកើតនិមិត្តផ្តេសផ្តាសខុសទទេស្អាត ។

សុភា — អើបើតាឯងដឹងខ្លួនថា ដេកលក់ហើយយល់សប្តិទេ ហេតុដូចម្តេចបានជាហ៊ានប្រាប់គេថា ប្តីស្លាប់ក្រពើលេប ថែមទាំងយកប្រាក់កំណល់កន្ទះណែនរបស់គេទៀត តាឯងធ្វើនេះខុសច្បាប់ធំណាស់ត្រូវមានទោសពីរប្រការ ១ គឺឆបោក ២ គឺធ្វើជីវិតគេឲ្យវិនាសដោយមានប្រាថ្នាចង់បានលាភសក្ការៈ ទោសទាំងពីរនេះត្រូវយកទោសដែលធំមកកាត់

គឺទោសទី ២ តាមច្បាប់សម្រាប់ព្រះនគរមាត្រា ១៥០ នេះត្រូវដាក់គុកតាឯងចំនួន ១០ ឆ្នាំ ហើយត្រូវតាឯងបង់ជម្ងឺចិត្ត ចំនួនប្រាក់ ៥០ ណែន ឲ្យឈ្មោះហេមស័យ ឯប្រាក់នេះត្រូវតាតាំកម្រាស់ឯងយកមកដាក់សា-លាវេលាស្អែកព្រឹកម៉ោង ៨ កុំខាន បើមិនសុខចិត្តតាឯងឧទ្ធរណ៍ទៀតចុះ ៗ

តាតាំ- លើកដៃសំពះទៅក្រមញ្ញរថា ទានប្រោសខ្ញុំប្របាទអាយុជាងហុកសិបឆ្នាំទៅហើយ បើជាប់ទោស ១០ ឆ្នាំទៀតច្បាស់ជាស្លាប់ក្នុងគុកមិនខានឡើយ ណ្ហើយខ្ញុំប្របាទម្ចាស់មិនចាំបាច់ឧទ្ធរណ៍ទៀតទេ ឲ្យតែលោកអនុញ្ញាតឲ្យនាងម៉ុកជាប្រពន្ធខ្ញុំប្របាទមកនៅក្នុងគុកជាមួយផងបានឬទេ ៗ

សុភា- មិនដែលមាន នាងម៉ុកមានទោសអី ៗ

តាតាំ- ទានប្រោសមាន មកតែពីរ បានជាខ្ញុំប្របាទប្រឹងស-មណធមិចិញ្ចឹម ព្រះតេជព្រះគុណអើយ វែទ ប្រពន្ធខ្ញុំប្របាទអាយុទើបតែ ២០ ឆ្នាំ សាច់នៅខ្ចីល្អ ថ្ពាល់នៅទ្រមមៗ កានៅតែម្នាក់កាឯណាបាន បើព្រះតេជព្រះគុណមិនព្រមខ្ញុំប្របាទម្ចាស់ជាប់ដង្ហើមឥឡូវហ្នឹង ៗ

សុភា- អើតាឯងមានប្រពន្ធក្រមុំផង នេះចំជាចាស់អ្នកលេងរេច ៗ

ចាងហ្វាង- ណ្ហើយចុះតា ឯច្បាប់តែងមានត្រាប្រណី ណ្ហើយទោស

គុកជាប់ឆ្នាំខ្ញុំលើកទោលចេញ  តាឯងត្រូវតែបង់ប្រាក់ចំនួន ៥០ ណែនឲ្យ ទៅហោមស័យប៉ុណ្ណឹងបានហើយ  តាឯងរកបានទេប្រាក់ ៥០ ណែន ។

តាគាំ - ឱព្រះគុណធ្ងន់អើយ  លោកមានមេត្តាខ្ញុំប្របាទម្ចាស់ណាស់ ប្រាក់ ៥០ ណែនខ្ញុំប្របាទម្ចាស់រកបាន ចាំខ្ញុំប្របាទម្ចាស់ទៅយកពីប្រពន្ធខ្ញុំប្របាទ  មកជូនលោកវេលាថ្ងៃស្អែកនេះពុំហ៊ានខាន ។

តាគាំក៏លាទៅក្រមត្រឡប់មកផ្ទះវិញ  ឃើញប្រពន្ធកំពុងតែដេកឱបប្រុសកំលោះម្នាក់  តាគាំខឹងណាស់យកឈើច្រត់សំពងនាងម៉ុកហើយស្រែកដេរថា  មេចោរអប្រិយ  ឯងចុះគ្រូសារក្រែស  នេះបំផាស្រីពេស្យាកាកី  ប្រទះអាណាយកអាទឹង នុពុទ្ធោ ៗ អើយ  គ្រាន់តែឯងមានរឿងបន្តិចមិនទាន់ទៅជាអីផង  ក៏ក្បត់ចិត្តឯងទៅហើយ  ទំរាំតែឯងជាប់ទោសទៅទៀត  មួយយប់រាំនាំប្រុសតិចណាស់ត្រឹមជាប់មកលើផ្ទះនេះ  មើលមីខ្ញកឯង  ខ្ញកទាំងអស់  ខ្ញកទាំងគេក៏ទាំងខ្ញាស  យកប្រាក់ឲ្យអញ ៥០ ណែនឆាប់  អញត្រូវការយកទៅដាក់សាលា ។

នាងម៉ុក  ទញ់ទាល់គំនិត  ខ្មាសតាគាំក្រៃក្រាស់ក៏ឆ្លើយថា  ប្រាក់មានពីណា  ខ្ញុំចាយស៊ីអស់ទៅហើយ  នៅសល់តែជាប់ណែននៅក្នុងហិប ។

តាគាំ - ច្បាស់ជាបណ្ដោះឲ្យទៅសហាយរាំចាយស៊ីខ្លះហើយ  អញវេលានេះធ្លាក់ខ្លួនវិនាសធំ  មកពីមានប្រពន្ធក្រមុំ  បានជាមានទុក្ខបែប

នេះ ល្មមហើយស្រឡាញ់គេបន់ចិត្ត អញមិនគួរនៅឲ្យឃើញមុខមីនេះសោះ ឯណាគ្មានប្រាក់យកទៅដាក់សាលា ៗ គេនឹងធ្វើទោសមិនខាន ៗ

តាគាំ – កន្ត្រាក់យកបានប្រាក់ ១០ ណែន ដើរកាត់ទៅផ្សារទិញត្រីបីរនឹងគ្រឿងបរិក្ខារ មាននំមុងកន្ទួលខ្ទើយ បានរួចស្រេចក៏ប្រឹងដើរត្រចបូលក្នុងព្រៃ ទៅដល់ភ្នំដងរែកយកស្បង់ចីពរមកគ្រងបួសជាតាបសឥសី ចំរើនមេត្តាភាវនា កាត់ចិត្តលែងនឹកនាងម៉ុកទៀតឡើយ ឃើញបក្សាបក្សីទាំងឡាយ លោកតាគាំក្រហល់ក្រហាយក្នុងហឫទ័យគិតថា ឱកាមគុណមិនយាយីធ្វើបាបតែមនុស្សលោកទេ រហូតដល់សត្វតិរច្ឆានក៏តាមមកឱបរុំបង់ជាប់មិនឲ្យបន្ទោះរួចអំពីស្ថានណាមកពោលតីរច្ឆសង្សារនេះ អញអើយ កាលពីដើមបួសនៅស្រុកស្រូលល្អពេក មកឃើញមីម៉ុកក្រមុំចន្ទ្រែសិកពោលក្នុសភ្លាម ស្មានថាវាស្រឡាញ់ឯង ដូចឯងស្រឡាញ់វា ឱគួរសង្វេគដល់ចាស់ ៗ ដែលមានប្រពន្ធក្រមុំ ដោះក្រពុំដូចផ្លែទន្លាប់ស៊ូធ្វើការឲ្យទាល់ងាប់ផ្គាប់ចិត្តគេក៏មិនត្រូវថែមទៀត ហេតុនេះបានតែជាកម្មោះគូ ៗ នឹងក្រមុំ យាយ ៗ ចាស់ទុំគូនឹងតា ៗ ឯងមិនគិតដូច្នោះស្មានថា ក្រមុំបើបានមកតាប្អូកពាសង្ហាស្រឡាញ់ពល់ងាប់ មិនគួរឆោតល្ងង់បណ្ដោយឲ្យកាមគុណមករំបដាន់សោះឡើយ ៗ

ចៅហោមស័យនឹងនាងម៉ាលីបានប្រែកាយដោយនូវសេចក្ដីសុខអ្នកស្រុកស្រឡាញ់រាប់អានទុកជាមនុស្សត្រឹមត្រូវ កិច្ចការក្រ ទាំងឡាយ ចៅហោមស័យអាចជួយឈឺឆ្អាលយកអាសាគេទាំងអស់ ។

ថ្ងៃមួយ ចៅហោមស័យនិយាយទៅកាន់ប្រពន្ធថា កាលប្អូននៅក្មេងរូបល្អណាស់ ឥឡូវនេះខុសឆ្ងាយពីមុន នែប្អូន បុប្ផាទាំងឡាយកាលក្រពុំរីកឡើងល្អមើល ដល់ត្រូវកំដៅព្រះអាទិត្យផ្កាស្វយរុះអស់ទៅវិញ នេះដូចរូបយើងទាំងអស់គ្នា កាលនៅពីក្មេង មានរូបកាយល្អស្អាតដល់ចាស់ទៅសាច់ជ្រោកជ្រាកពព្រាជជីងមរណៈមកសង្កត់សង្កិនដូចជាផ្កាដែលត្រូវកំដៅព្រះសុរិយាន ។

ជនទាំងពីរនាក់ស្រឡាញ់ប្ដីប្រពន្ធលើសលប់មិនដែលមានវិវាទនឹងគំនិត ចាំបែងចិត្តមួយសោះហូតដល់ពេលខ្លួនរៀងខ្លួនទៅ ។

ឱជីវិតសត្វលោកយើងអើយ វិនាសស្លាប់ដោយសារកាមគុណច្រើនណាស់តើ កាមគុណបើមានច្រើនដល់បុគ្គលណា បុគ្គលនោះរមែងតែងសោយទុក្ខច្រើនជាងសុខ អកុសលកម្មនេះនឹងលែងមកញាំញីសត្វសាមញ្ញក្រែងតែមានផ្កាបទុមដុះចេញពីបក្តិមក ត្រើងដែលដេះនៅកន្ទរកប្រែទៅជាត្រជាក់ ឬព្រះអាទិត្យរះឡើងពីទិសបស្ចិមវិញហោង ។

សង្ខេបតែប៉ុណ្ណេះ ។

# វេយ្យាករណ៍សំស្ក្រឹតភាគទី ៣
# របស់ព្រះវិសុទ្ធិវង្ស (គ)

## (៦១) ៣ នាមសព្ទជា ឦ- ឦ- ការន្ត

### देवी ទេវី ស្ត្រី. "នាងទេវី"

| | ឯក. | | ទ្វិ. | | ពហុ. | |
|---|---|---|---|---|---|---|
| ប្ឋ. | देवी | ទេវី | देव्यौ | ទេវ្យៅ | देव्यस् | ទេវ្យស៑ |
| ទុ. | देवीम् | ទេវីម៑ | देव्यौ | ទេវ្យៅ | देवीस् | ទេវីស៑ |
| ត. | देव्या | ទេវ្យា | देवीभ्याम् | ទេវីភ្យាម៑ | देवीभिस् | ទេវីភិស៑ |
| ច. | देव्यै | ទេវ្យៃ | देवीभ्याम् | ទេវីភ្យាម៑ | देवीभ्यस् | ទេវីភ្យស៑ |
| ប. | देव्यास् | ទេវ្យាស៑ | देवीभ्याम् | ទេវីភ្យាម៑ | देवीभ्यस् | ទេវីភ្យស៑ |
| ឆ. | देव्यास् | ទេវ្យាស៑ | देव्योस् | ទេវ្យោស៑ | देवीनाम् | ទេវីនាម៑ |
| ស. | देव्वाम् | ទេវ្យាម៑ | देव्योस् | ទេវ្យោស៑ | देवीसु | ទេវីសុ |
| សម្ពោ. | देवि | ទេវិ | देव्यौ | ទេវ្យៅ | देव्यस् | ទេវ្យស៑ |

សព្ទជា ឦ-ការន្ត ស្ត្រីលិង្គ មានប៉ុណ្ណោះជាដើម
ត្រូវបំបែកដូច ទេវី

| | | | | | |
|---|---|---|---|---|---|
| जननी | ជននី | មាតា | पेशी | បេឝី | ដុំសាច់ |
| तमस्विनी | តមស្វិនី | យប់ | मही | មហី | ដី |

| | | | | | |
|---|---|---|---|---|---|
| तरी | *តរី* | កញ៉ាល់, ទូក | रजनी | *រជនី* | យប់ |
| नदी | *នទី* | ស្ទឹង | वाणी | *វាណី* | សម្លេង |
| नारी | *នារី* | ស្រី | वापी | *វាបី* | បឹង |
| पत्नी | *បត្នី* | ប្រពន្ធ | व्याघ्री | *វ្យាឃ្រី* | ខ្លាធំញី |
| पृथिवी | *បឫថិវី* | ផែនដី | सखी | *សខី* | ស្រីជាសម្លាញ់ |

## वधू *វធូ*, ស្ត្រី. "ស្រីមានគូស្រករ, ប្រពន្ធកំមុំ"

| | ឯក. | | ទ្វេ. | | ពហុ. | |
|---|---|---|---|---|---|---|
| ប្រ. | वधूस् | *វធូស៑* | वध्वौ | *វធ្វៅ* | वध्वस् | *វធ្វស៑* |
| ទ្វិ. | वधूम् | *វធូម៑* | वध्वौ | *វធ្វៅ* | वधूस् | *វធូស៑* |
| ត្រ. | वध्वा | *វធ្វា* | वधूभ्याम् | *វធូភ្យាម៑* | वधूभिस् | *វធូភិស៑* |
| ច. | वध्वै | *វធ្វៃ* | वधूभ्याम् | *វធូភ្យាម៑* | वधूभ्यस् | *វធូភ្យស៑* |
| ប. | वध्वास् | *វធ្វាស៑* | वधूभ्याम् | *វធូភ្យាម៑* | वधूभ्यस् | *វធូភ្យស៑* |
| ឆ. | वध्वास् | *វធ្វាស៑* | वध्वोस् | *វធ្វោស៑* | वधूनाम् | *វធូនាម៑* |
| ស. | वध्वाम् | *វធ្វាម៑* | वध्वोस् | *វធ្វោស៑* | वधूषु | *វធូឞុ* |
| សម្ពោ. | वधु | *វធុ* | वध्वौ | *វធ្វៅ* | वध्वस् | *វធ្វស៑* |

# សព្ទជា ឧការន្ត ស្ត្រីលិង្គ មានប៉ុណ្ណោះជាដើម ត្រូវបំបែកដូច វធូ

ចមូ ចមូ សេនា, កងទ័ព    តនូ តនូ រាងកាយ

ជម្ពូ ជម្ពូ ជម្ពូ, ព្រីង    សស្សូ ស្វស្រូ ម្ដាយក្មេក

**ការផ្ទៀបវិភត្តិ** វិភត្តិដែលមានរបៀបទៀងទាត់ខាងដើមត្រង់លេខ ៤៨ បានធៀបមកនឹងវិភត្តិដែលភ្ជាប់មកនឹងនាមសព្ទជា អា-, ឥ-, ឧ-ការន្ត ស្ត្រីលិង្គ ដែលបំបែកខាងលើនេះ ឃើញត្រូវគ្នាខ្លះដូចតទៅនេះ:

ត្រង់ឯកវចនៈ: ប្រ. សិ មានតែត្រង់នាមសព្ទជា ឧ-ការន្ត ដូច វធូសិ ហើយនឹងពួកនាមសព្ទជា ឥ- ការន្ត បន្តិចបន្តួច ដូចជា លក្ស្មី "សំអ, ជាយារបស់ព្រះវិស្ណុ", តន្ត្រី "ខ្សែ" ប្រ. ឯក.: លក្ស្មីសិ, តន្ត្រីសិ; ទុ. មិ ឃើញមានគ្រប់ការន្ត ដូចជា កថាមិ, ទេវីមិ, វធូមិ; តូ. អា. ឃើញមានតែត្រង់ ឥ-ឧការន្ត ដូចជា ទេវ្យា, វធ្វា, ( < ទេវី + អា; វធូ + អា ) ។

ត្រង់ទ្វិវចនៈ: វិភត្តិទាំងអស់ដែលនៅទៀងជាប្រក្រតីឥតប្រែប្រួល ចំពោះតែត្រង់ ឥ-ឧ-ការន្ត: ទេវ្យៅ ( < ទេវី + អៅ ), ទេវីភ្យាម៍, ទេវ្យោសិ ( < ទេវី + អោសិ ); វធ្វៅ ( < វធូ + អៅ ), វធូភ្យាម៍, វធ្វោសិ ( < វធូ + អោសិ ) ។ ឯ អា-ការន្ត មានវិភត្តិត្រូវគ្នាតែត្រង់ តូ. ច. ប.: កថាភ្យាម៍ ។

ត្រង់ពហុវចនៈ : ប្រ. អស៑, ត្ឫ. ភិស៑, ច. ប. ភ្យស៑, ស. សុ វិភត្តិទាំងនេះ មានសាធារណ៍គ្រប់នាមសព្ទជា អា- ឦ- ឩ-ការន្ត; ឯវិភត្តិនៃ ទុ. អស៑ នេះមានតែត្រង់ អា-ការន្ត ដូច កថាស៑, (អា + អស៑) ឯត្រង់ ឦ-ឩ-ការន្ត គេលុប អ ចេញ ទុកឲ្យនៅតែ ស៑ : ទេវីស៑, វធូស៑ ។

## (៦៦) ៤ នាមសព្ទជា ឥ- ឧ- ការន្ត

कवि កវិ, បុំ. "កវី (អ្នកបេះកាព្យ)"

| | ឯក. | | ទ្វិ. | | ពហុ. | |
|---|---|---|---|---|---|---|
| ប្រ. | कविस् | កវិស៑ | कवी | កវី | कवयस् | កវយស៑ |
| ទុ. | कविम् | កវិម៑ | कवी | កវី | कवीन् | កវីន៑ |
| ត្ឫ. | कविना | កវិនា | कविभ्याम् | កវិភ្យាម៑ | कविभिस् | កវិភិស៑ |
| ច. | कवये | កវយេ | कविभ्याम् | កវិភ្យាម៑ | कविभ्यस् | កវិភ្យស៑ |
| ប. | कवेस् | កវេស៑ | कविभ्याम् | កវិភ្យាម៑ | कविभ्यस् | កវិភ្យស៑ |
| ឆ. | कवेस् | កវេស៑ | कव्योस् | កវ្យោស៑ | कवीनाम् | កវីនាម៑ |
| ស. | कवौ | កវៅ | कव्योस् | កវ្យោស៑ | कविषु | កវិឞុ |
| សម្ពោ. | कवे | កវេ | कवी | កវី | कवयस् | កវយស៑ |

## សព្ទជា ឥ-ការន្ត បុំលិង្គ មានប៉ុណ្ណោះជាដើម
## ត្រូវបំបែកដូច ករិ

| | | | | | |
|---|---|---|---|---|---|
| អគ្គិ | អគ្គិ | ភ្លើង | ពលិ | ពលិ | ការបូជា |
| អទ្រិ | អទ្រិ | ភ្នំ | មណិ | មណិ | កែវមណី |
| ឥសិ | ឫសិ | ឫសី | យតិ | យតិ | អ្នកប្រព្រឹត្តធម៌ |
| កបិ | កបិ | ស្វា | រស្មិ | រស្មិ | រស្មី |
| គិរិ | គិរិ | ភ្នំ | រាសិ | រាសិ | គំនរ |
| ញាតិ | ញាតិ | ញាតិ | វហ្និ | វហ្និ | ភ្លើង |
| ធូលិ | ធូលិ | ធូលី | វ្រីហិ | វ្រីហិ | ស្រូវ |
| និធិ | និធិ | កំណប់ | សខិ | សខិ | សម្លាញ់ |
| បត្តិ | បត្តិ | ពលថ្មើរជើង | សមាធិ | សមាធិ | កិរិយាដំកល់ចិត្តឲ្យល្អ |

### មតិ មតិ, ស្ត្រី. "ប្រាជ្ញា, ការត្រិះរិះ"

| | ឯក. | | ទ្វិ. | | ពហុ. | |
|---|---|---|---|---|---|---|
| ប. | មតិស៑ | មតិស៑ | មតី | មតី | មតយស៑ | មតយស៑ |
| ទុ. | មតិម៑ | មតិម៑ | មតី | មតី | មតីស៑ | មតីស៑ |
| ត. | មត្យា | មត្យា | មតិភ្យាម៑ | មតិភ្យាម៑ | មតិភិស៑ | មតិភិស៑ |

| | ឯក. | ទ្វិ. | ពហុ. |
|---|---|---|---|
| ច. | मतये, मत्यै | मतिभ्याम् | मतिभ्यस् |
| | មតយេ, មត្យៃ | មតិភ្យាម៑ | មតិភ្យស៑ |
| ប. | मतेस्, मत्यास् | मतिभ्याम् | मतिभ्यस् |
| | មតេស៑, មត្យាស៑ | មតិភ្យាម៑ | មតិភ្យស៑ |
| ឆ. | मतेस्, मत्यास् | मत्योस् | मतीनाम् |
| | មតេស៑ មត្យាស៑ | មត្យោស៑ | មតីនាម៑ |
| ស. | मतौ, मत्याम् | मत्योस् | मतिषु |
| | មតៅ, មត្យាម៑ | មត្យោស៑ | មតិឞុ |
| សម្ពោ. | मते មតេ | मती មតី | मतयस् មតយស៑ |

## សព្ទជា ឥការាន្ត ស្ត្រីលិង្គ មានប៉ុណ្ណោះជាដើម ត្រូវបំបែកដូច មតិ

| | | | | | |
|---|---|---|---|---|---|
| अङ्गुलि | អង្គុលិ | ម្រាមដៃ | नीति | នីតិ | មារយាទ, សេចក្ដីដឹកនាំ |
| आसक्ति | អាសក្តិ | កិរិយាជាប់ | प्रकृति | ប្រកូតិ | ប្រក្រតី |
| इष्टि | ឥដ្ឋិ | កិរិយាប្រាថ្នា | भक्ति | ភក្តិ | សេចក្ដីស្រឡាញ់, ភក្តី |
| उक्ति | ឧក្តិ | កិរិយាពោល, សំដី | मुक्ति | មុក្តិ | កិរិយារួច |
| कान्ति | កាន្តិ | សេចក្ដីស្រឡាញ់, សេចក្ដីប្រាថ្នា | यष्टि | យដ្ឋិ | ឈើច្រត់ |
| गति | គតិ | ដំណើរ | वृद्धि | វុឌ្ឍិ | សេចក្ដីចំរើន |

तुष्टि តុដ្ឋិ សេចក្ដីត្រេកអរ स्मृति ស្ម្ឫតិ ស្មារតី

दृष्टि ទ្ឫដ្ឋិ ការឃើញ हानि ហានិ សេចក្ដីវិនាស

## वारि វារិ, នបុំ. "ទឹក"

| | ឯក. | | ទ្វិ. | | ពហុ. | |
|---|---|---|---|---|---|---|
| ប្ឋ. | वारि | វារិ | वारिणी | វារិណី | वारीणि | វារីណិ |
| ទុ. | वारि | វារិ | वारिणी | វារិណី | वारीणि | វារីណិ |
| តូ. | वारिणा | វារិណា | वारिभ्याम् | វារិភ្យាម៑ | वारिभिस् | វារិភិស៑ |
| ច. | वारिणे | វារិណេ | वारिभ्याम् | វារិភ្យាម៑ | वारिभ्यस् | វារិភ្យស៑ |
| ប. | वारिणस् | វារិណស៑ | वारिभ्याम् | វារិភ្យាម៑ | वारिभ्यस् | វារិភ្យស៑ |
| ឆ. | वारिणस् | វារិណស៑ | वारिणोस् | វារិណោស៑ | वारीणाम् | វារីណាម៑ |
| ស. | वारिणि | វារិណិ | वारिणोस् | វារិណោស៑ | वारिषु | វារិឞុ |
| សម្ព. | वारे, वारि | វារេ, វារិ | वारिणी | វារិណី | वारीणि | វារីណិ |

សព្ទជា ឥការន្ត នបុំ. ដែលមានវិធីបំបែកដូចគ្នានឹង វារិ ខាងលើនេះ មានដោយកម្រណាស់ ដូចសព្ទ អក្សិ, នបុំ. "ភ្នែក", សព្ទនេះ មានការន្តដូចគ្នា មានលិង្គដូចគ្នានឹង វារិ ក៏ពិតមែន តែវិធីបំបែកមានទំនងត្រូវគ្នានឹង វារិ តែត្រង់ ប្ឋ. ទុ. ឯក.: អក្សិ: ប្ឋ. ទុ. ទ្វិ.: អក្សិណី; តូ. ច. ប. ទ្វិ.: អក្សិភ្យាម៑; ប្ឋ. ទុ. ពហុ.: អក្សីណិ; តូ. ពហុ.: អក្សិភិស៑; ច. ប. ពហុ.: អក្សិភ្យស៑; ស. ពហុ.: អក្សិឞុ ក្រៅពី

នោះត្រូវបំបែកដូច អក្សរ ទិ (មើលលេខ ៦៦ ត្រង់សេចក្ដីបំណាំ ល. ៥);
អស្ថិ, ឧបុំ. "ឆ្អឹង" មានទំនង់ដូច អក្សិ ។

## गुरु គុរុ, បុំ. "គ្រូ"

| | ឯក. | | ទ្វិ. | | ពហុ. | |
|---|---|---|---|---|---|---|
| ប្រ. | गुरुस् | គុរុស៑ | गुरू | គុរូ | गुरवस् | គុរវស៑ |
| ទុ. | गुरुम् | គុរុម៑ | गुरू | គុរូ | गुरून् | គុរូន៑ |
| ក. | गुरुणा | គុរុណា | गुरुभ्याम् | គុរុភ្យាម៑ | गुरुभिस् | គុរុភិស៑ |
| ច. | गुरवे | គុរវេ | गुरुभ्याम् | គុរុភ្យាម៑ | गुरुभ्यस् | គុរុភ្យស៑ |
| ប. | गुरोस् | គុរោស៑ | गुरुभ्याम् | គុរុភ្យាម៑ | गुरुभ्यस् | គុរុភ្យស៑ |
| ឆ. | गुरोस् | គុរោស៑ | गुर्वोस् | គុវ៌ោស៑ | गुरूणाम् | គុរូណាម៑ |
| ស. | गुरौ | គុរៅ | गुर्वोस् | គុវ៌ោស៑ | गुरुषु | គុរុឞុ |
| សម្ពោ. | गुरो | គុរោ | गुरू | គុរូ | गुरवस् | គុរវស៑ |

## សព្ទជា ឧការន្ត បុំលិង្គ មានប៉ុណ្ណោះជាដើម
## ត្រូវបំបែកដូច គុរុ

| | | | | | |
|---|---|---|---|---|---|
| अंशु | អំសុ | រស្មី | पशु | បសុ | សត្វចិញ្ចឹម |
| ऋतु | ឫតុ | រដូវ | पांशु | បាំសុ | ធូលី |
| कृशानु | ក្ឫសានុ | ភ្លើង | भिक्षु | ភិក្សុ | ភិក្ខុ |
| केतु | កេតុ | ទង់ | मृत्यु | ម្ឫត្យុ | សេចក្ដីស្លាប់ |

## धेनु ធេនុ, ស្ត្រី. "មេគោ"

| | ឯក. | | ទ្វិ. | | ពហុ. | |
|---|---|---|---|---|---|---|
| ប្រ. | धेनुस् | ធេនុស៑ | धेनू | ធេនូ | धेनवस् | ធេនវស៑ |
| ទុ. | धेनुम् | ធេនុម៑ | धेनू | ធេនូ | धेनूस् | ធេនូស៑ |
| ត្រ. | धेन्वा | ធេន្វា | धेनुभ्याम् | ធេនុភ្យាម៑ | धेनुभिस् | ធេនុភិស៑ |
| ច. | धेनवे, धेन्वै<br>ធេនវេ, ធេន្វៃ | | धेनुभ्याम्<br>ធេនុភ្យាម៑ | | धेनुभ्यस्<br>ធេនុភ្យស៑ | |
| ប. | धेनोस्, धेन्वास्<br>ធេនោស៑, ធេន្វាស៑ | | धेनुभ्याम्<br>ធេនុភ្យាម៑ | | धेनुभ्यस्<br>ធេនុភ្យស៑ | |
| ឆ. | धेनोस्, धेन्वास्<br>ធេនោស៑, ធេន្វាស៑ | | धेन्वोस्<br>ធេន្វោស៑ | | धेनूनाम्<br>ធេនូនាម៑ | |
| ស. | धेनौ, धेन्वाम्<br>ធេនៅ, ធេន្វាម៑ | | धेन्वोस्<br>ធេន្វោស៑ | | धेनुषु<br>ធេនុឞុ | |
| សម្ពោ. | धेनो | ធេនោ | धेनू | ធេនូ | धेनवस् | ធេនវស៑ |

## សព្ទជា ឧការន្ត ស្ត្រីលិង្គ មានប៉ុណ្ណោះជាដើម ត្រូវបំបែកដូច ធេនុ

| | | | | | |
|---|---|---|---|---|---|
| अलाबु | អលាពុ | ឃ្លោក | हनु | ហនុ | ចង្កា |
| असिधेनु | អសិធេនុ | កាំបិតស្នា | रज्जु | រជ្ជុ | ខ្សែ |
| तंतु | តន្តុ | ឆ្កាយ | इषु | ឥឞុ | ព្រួញ |

## មធុ មធុ, នបុំ. "ឃ្មុំ"

| | ឯក. | | ទ្វិ. | | ពហុ. | |
|---|---|---|---|---|---|---|
| ប្រ. | មធុ | មធុ | មធុនី | មធុនី | មធូនិ | មធូនិ |
| ទ្វិ. | មធុ | មធុ | មធុនី | មធុនី | មធូនិ | មធូនិ |
| ត្ឫ. | មធុនា | មធុនា | មធុភ្យាម៑ | មធុភ្យាម៑ | មធុភិស៑ | មធុភិស៑ |
| ច. | មធុនេ | មធុនេ | មធុភ្យាម៑ | មធុភ្យាម៑ | មធុភ្យស៑ | មធុភ្យស៑ |
| ប. | មធុនស៑ | មធុនស៑ | មធុភ្យាម៑ | មធុភ្យាម៑ | មធុភ្យស៑ | មធុភ្យស៑ |
| ឞ. | មធុនស៑ | មធុនស៑ | មធុនោស៑ | មធុនោស៑ | មធូនាម៑ | មធូនាម៑ |
| ស. | មធុនិ | មធុនិ | មធុនោស៑ | មធុនោស៑ | មធុឞុ | មធុឞុ |
| សម្ពោ. | មធោ, មធុ | មធោ, មធុ | មធុនី | មធុនី | មធូនិ | មធូនិ |

## សព្ទជា ឧការាន្ត នបុំសកលិង្គ មានប៉ុណ្ណោះជាដើម ត្រូវបំបែកដូច មធុ

| | | | | | |
|---|---|---|---|---|---|
| អម្ពុ | អម្ពុ | ទឹក | ទារុ | ទារុ | ឈើ |
| អស្រុ | អស្រុ | ទឹកភ្នែក | រេណុ | រេណុ | លំអងធូលី |
| អាយុ | អាយុ | អាយុ | វស្តុ | វស្តុ | កន្លែង, ទីលំនៅ |
| ជានុ | ជានុ | ជង្គង់ | ឝ្មឝ្រុ | ស្មស្រុ | ពុកចង្កា |

សព្ទ ទ្យុ, ស្ត្រី. “ទេវលោក, ថ្ងៃ” សព្ទនេះមានត្រូវការប្រើច្រើន តែវិធីបំបែក ឥតមានរបៀបទៀងទាត់ទេ គួរបំបែកសព្ទនេះក្នុងពួកសព្ទជាឧការន្តនេះជាមួយគ្នាតែម្តង វិធីបំបែកនោះ ត្រូវចំណាំ ត្រង់ដែលមិនសូវត្រូវការប្រើ នៅក្នុងរង្វង់ក្រចក ដូចមានតទៅនេះ

| | ឯក. | ទ្វិ. | ពហុ. |
|---|---|---|---|
| ប្រ. | ទ្យោស៑ | ទ្យាវៅ, (ទិវៅ) | ទ្យាវស៑, ទិវស៑ |
| ទុ. | ទ្យាម៑, ទិវម៑ | " ( " ) | (ទ្យាវស៑), ទិវស៑, ទ្យូន៑ |
| ត.ប្ប | (ទ្យវា), ទិវា | (ទ្យោភ្យាម៑, ទ្យុភ្យាម៑) | (ទ្យោភិស៑), ទ្យុភិស៑ |
| ច. | ទ្យវេ, ទិវេ | ( " , " ) | (ទ្យោភ្យស៑, ទ្យុភ្យស៑) |
| ប. | ទ្យោស៑, ទិវស៑ | ( " , " ) | ( " , " ) |
| ឆ. | ទ្យោស៑, ទិវស៑ | (ទ្យវោស៑, ទិវោស៑) | ( ទ្យវាម៑, ទិវាម៑ ) |
| ស. | ទ្យវិ, ទិវិ | ( " , " ) | ( ទ្យោឞុ, ទ្យុឞុ ) |

ការផ្ទៀបវិភត្តិ នាមសព្ទជា ឥ ឧ-ការន្ត ទបុំសកលិង្គ ដែលបំបែកខាងលើនេះ មានទំនងដូចគ្នានឹងព្យញ្ជនការន្តដោយច្រើន ព្រោះវិភត្តិគេគល់ទឹងមានរបៀបទៀងទាត់គ្រប់អន្លើ ៗ ឯនាមសព្ទជា ឥ, ឧ-ការន្ត បុំលិង្គនឹងស្ត្រីលិង្គ ដែលបំបែកខាងលើ, វិភត្តិដែលមានរបៀប

ទៀងទាត់យ៉ាងពេញទី មានតែត្រង់ទ្វិវចន ក្រៅពីនោះមានដោយបំណែក ៗ គឺត្រង់ ឯកវចនៈ ប្រថមា, ទ្វិតីយា តួតីយា និងត្រង់ពហុវចនៈ តួតីយា, ចតុត្ថី, បញ្ចមី, ឆដ្ឋី, សប្តមី ។

## (៦៣) ៥. នាមសព្ទ ដែលមានព្យាង្គតែ ១ ជាឦ-, ឩ-, ឮ-, ឰ-, ឳ- ការាន្ត

### श्री ស្រី, ស្ត្រ. “សិរី”

| | ឯក. | | ទ្វិ. | | ពហុ. | |
|---|---|---|---|---|---|---|
| ប្រ. | श्रीस् | ស្រីស៑ | श्रियौ | ស្រិយៅ | श्रियस् | ស្រិយស៑ |
| ទុ. | श्रियम् | ស្រិយម៑ | " | " | " | " |
| តួ. | श्रिया | ស្រិយា | श्रीभ्याम् | ស្រីភ្យាម៑ | श्रीभिस् | ស្រីភិស៑ |
| ច. | श्रिये, श्रियै | ស្រិយេ, ស្រិយៃ | " | " | श्रीभ्यस् | ស្រីភ្យស៑ |
| ប. | श्रियस्, श्रियास् | ស្រិយស៑, ស្រិយាស៑ | " | " | " | " |
| ឆ. | " | " | श्रियोस् | ស្រិយោស៑ | श्रियाम्, श्रीणाम् | ស្រិយាម៑, ស្រីណាម៑ |

| | ឯក. | ទ្វិ. | ពហុ. |
|---|---|---|---|
| ស. | श्रियि, श्रियाम् ស្រិយិ, ស្រិយាម៑ | श्रियोस् ស្រិយោស៑ | श्रीषु ស្រីឞុ |
| សម្ពោ. | श्रीस् ស្រីស៑ | श्रियौ ស្រិយៅ | श्रियस् ស្រិយស៑ |

## भू ភូ, ស្ត្រី. "ផែនដី"

| | ឯក. | | ទ្វិ. | | ពហុ. | |
|---|---|---|---|---|---|---|
| ប្រ. | भूस् | ភូស៑ | भुवौ | ភុវៅ | भुवस् | ភុវស៑ |
| ទុ. | भुवम् | ភុវម៑ | " | " | " | " |
| ត្រ. | भुवा | ភុវា | भूभ्याम् | ភូភ្យាម៑ | भूभिस् | ភូភិស៑ |
| ច. | भुवे, भुवै | ភុវេ, ភុវៃ | " | " | भूभ्यस् | ភូភ្យស៑ |
| ប. | भुवस्, भुवास् | ភុវស៑, ភុវាស៑ | " | " | " | " |
| ឆ. | " | " | भुवोस् | ភុវោស៑ | भुवाम्, भूनाम् | ភុវាម៑ ភូនាម៑, |
| ស. | भुवि, भुवाम् | ភុវិ, ភុវាម៑ | " | " | भूषु | ភូឞុ |
| សម្ពោ. | भूस् | ភូស៑ | भुवौ | ភុវៅ | भुवस् | ភុវស៑ |

## रै រៃ, ស្ត្រី. "ទ្រព្យសម្បត្តិ"

| | ឯក. | | ទ្វិ. | | ពហុ. | |
|---|---|---|---|---|---|---|
| ប្រ. | रास् | រាស៑ | रायौ | រាយៅ | रायस् | រាយស៑ |
| ទ្វិ. | रायम् | រាយម៑ | " | " | " | " |
| ត្ប. | राया | រាយា | राभ्याम् | រាភ្យាម៑ | राभिस् | រាភិស៑ |
| ច. | राये | រាយេ | " | " | राभ्यस् | រាភ្យស៑ |
| ប. | रायस् | រាយស៑ | " | " | " | " |
| ឆ. | " | " | रायोस् | រាយោស៑ | रायाम् | រាយាម៑ |
| ស. | रायि | រាយិ | " | " | रासु | រាសុ |
| សម្ពោ. | रास् | រាស៑ | रायौ | រាយៅ | रायस् | រាយស៑ |

## गो គោ, បុំ. ស្ត្រី. "គោ"

| | ឯក. | | ទ្វិ. | | ពហុ. | |
|---|---|---|---|---|---|---|
| ប្រ. | गौस् | គៅស៑ | गावौ | គាវៅ | गावस् | គាវស៑ |
| ទ្វិ. | गाम् | គាម៑ | " | " | गास् | គាស៑ |
| ត្ប. | गवा | គវា | गोभ्याम् | គោភ្យាម៑ | गोभिस् | គោភិស៑ |

| | ឯក. | | ទ្វិ. | | ពហុ. | |
|---|---|---|---|---|---|---|
| ច. | गवे | គវេ | गोभ्याम् | គោភ្យាម៑ | गोभ्यस् | គោភ្យស៑ |
| ប. | गोस् | គោស៑ | " | " | " | " |
| ឆ. | " | " | गवोस् | គវោស៑ | गवाम् | គវាម៑ |
| ស. | गवि | គវិ | " | " | गोषु | គោឞុ |
| សម្ពោ. | गौस् | គៅស៑ | गावौ | គាវៅ | गावस् | គាវស៑ |

## नौ នៅ, ស្ត្រី. "ទូក"

| | ឯក. | | ទ្វិ. | | ពហុ. | |
|---|---|---|---|---|---|---|
| ប្រ. | नौस् | នៅស៑ | नावौ | នាវៅ | नावस् | នាវស៑ |
| ទុ. | नावम् | នាវម៑ | " | " | " | " |
| តុ. | नावा | នាវា | नौभ्याम् | នៅភ្យាម៑ | नौभिस् | នៅភិស៑ |
| ច. | नावे | នាវេ | " | " | नौभ्यस् | នៅភ្យស៑ |
| ប. | नावस् | នាវស៑ | " | " | " | " |
| ឆ. | " | " | नावोस् | នាវោស៑ | नावाम् | នាវាម៑ |
| ស. | नावि | នាវិ | " | " | नौषु | នៅឞុ |
| សម្ពោ. | नौस् | នៅស៑ | नावौ | នាវៅ | नावस् | នាវស៑ |

សេចក្តីបំណាំ. នាមសព្ទ មានព្យាង្គមួយ ៗ ដែលបំបែកខាងលើនេះ មានទំនងប្រហែលដូចជាបំបែកនាមសព្ទជាវ្យញ្ជនការន្ត ដោយពេញលេញ ព្រោះវិភត្តិដែលភ្ជាប់នឹងនាមសព្ទទាំងនោះ ជាវិភត្តិមានរបៀបទៀងទាត់ ។

## (៦៤) វិធីបំបែកនាមសព្ទជាវ្យញ្ជនការន្ត.

ក្នុងវិធីបំបែកនាមសព្ទនេះ, ត្រង់បុំលិង្គនឹងស្ត្រីលិង្គ មានវិភត្តិដូចគ្នាគ្រប់អន្ទើ:

ឯកវចនៈ: ស៑, អម៑, អា, ឯ, អស៑, អស៑, ឥ

ទ្វិវចនៈ: អៅ, ភ្យាម៑, អោស៑

ពហុវចនៈ: អស៑, អស៑, ភិស៑, ភ្យស៑, ភ្យស៑, អាម៑, សុ.

ត្រង់ប្រថមា ឯកវចនៈ, វិភត្តិ ស៑ ត្រូវលុបបំបាត់ចេញ កុំឲ្យមាននៅទីបំផុតនៃវ្យញ្ជនឡើយ ។

ឯចំណែក នបុំសកលិង្គ ត្រង់ប្រថមា នឹង ទ្វិតីយា ឯកវចនៈ មិនមានវិភត្តិទេ, ត្រង់ប្រថមា នឹង ទ្វិតីយា ទ្វិវចនៈ មានវិភត្តិ ឦ ; ត្រង់ប្រថមា នឹង ទ្វិតីយា ពហុវចនៈ មានវិភត្តិ ឥ ។ វិភត្តិក្រៅពីនោះ ដូច

គ្នានឹងវិភត្តិដែលភ្ជាប់នឹងនាមសព្ទ បុំលិង្គ ។ វិភត្តិទាំងអស់នោះ ត្រូវគ្នានឹងតំរូវិភត្តិ ដែលមានរបៀបទៀងទាត់ត្រង់លេខ ៤៨ ខាងដើម ។

## (៦៤) ១. ធាតុ–នាមសព្ទ

ធាតុ–នាមសព្ទ នោះ គឺ ជួនកាលរូបធាតុ ត្រឡប់មកជានាមសព្ទ ក៏មាន ធ. បទ៑, "ទៅ"; ន. ស. បទ៑, បុំ. "ជើង"; ធ. ទិឝ៑, "បង្អុល, សំដែង"; ន. ស. ទិឝ៑, ស្ត្រី. "ទិស"; ធ. វច៑, "ពោល"; ន. ស. វាច៑ "វាចា, សំដី"; ជួនកាលរូបធាតុ ភ្ជាប់ទៅនឹងនាមសព្ទ ទៅជាសមាសនាម ឬ ជាកត្តុនាម ក៏មាន: ទ្វិបទ៑, ដែលមានជើងពីរ; ធ. ពុធ៑, "ដឹង"; ន. ស.: ធម៌ពុធ៑, ដែលដឹងនូវធម៌; ធ. ក្ឫ, "ធ្វើ"; ន. ស.: បាបក្ឫត៑ ដែលធ្វើនូវបាប ។

ឯបទសមាសទាំងនោះជាគុណសព្ទទាំងអស់ ត្រង់បុំលិង្គនឹងស្ត្រីលិង្គ មានរូបសព្ទដូចគ្នា ទាំងវិធីបំបែកក៏ដូចគ្នា ឯនបុំសកលិង្គ មានផ្សេងគ្នាបន្តិច តែត្រង់ប្រថមា ទ្វិតីយា ឯកវចន មានស្វរជាហ្រស្វ, ត្រង់ប្រ. ទ្វិ. ទ្វិវ. ជា ណ្ណី, ត្រង់ប្រ. ទ្វិ. ពហុ. ជា ឥ ។

## पद् បទ៑, បុំ. "ជើង"

| | ឯក. | | ទ្វិ. | | ពហុ. | |
|---|---|---|---|---|---|---|
| ប្រ. | पाद् | ផាទ៑ | पादौ | ផាទៅ | पादस् | ផាទស៑ |
| ទុ. | पादम् | ផាទម៑ | " | " | पदस् | បទស៑ |
| ត្ឫ. | पदा | បទា | पद्भ्याम् | បទ្ភ្យាម៑ | पद्भिस् | បទ្ភិស៑ |
| ច. | पदे | បទេ | " | " | पद्भ्यस् | បទ្ភ្យស៑ |
| ប. | पदस् | បទស៑ | " | " | " | " |
| ឆ. | " | " | पदोस् | បទោស៑ | पदाम् | បទាម៑ |
| ស. | पदि | បទិ | " | " | पत्सु | បត្សុ |
| សម្ពោ. | पाद् | ផាទ៑ | पादौ | ផាទៅ | पादस् | ផាទស៑ |

## द्विपद् ទ្វិបទ៑, គ. ស. បុំ. ស្ត្រី. "មានជើងពីរ"

| | ឯក. | | ទ្វិ. | | ពហុ. | |
|---|---|---|---|---|---|---|
| ប្រ. | द्विपाद् | ទ្វិផាទ៑ | द्विपादौ | ទ្វិផាទៅ | द्विपादस् | ទ្វិផាទស៑ |
| ទុ. | द्विपादम् | ទ្វិផាទម៑ | " | " | द्विपदस् | ទ្វិបទស៑ |
| ត្ឫ. | द्विपदा | ទ្វិបទា | द्विपद्भ्याम् | ទ្វិបទ្ភ្យាម៑ | द्विपद्भिस् | ទ្វិបទ្ភិស៑ |

| | ឯក. | | ទ្វិ. | | ពហុ. | |
|---|---|---|---|---|---|---|
| ច. | द्विपदे | ទ្វិបទេ | द्विपद्भ्याम् | ទ្វិបទ្ភ្យាម៑ | द्विपद्भ्यस् | ទ្វិបទ្ភ្យស៑ |
| ប. | द्विपदस् | ទ្វិបទស៑ | " | " | " | " |
| ឆ. | " | " | द्विपदोस् | ទ្វិបទោស៑ | द्विपदाम् | ទ្វិបទាម៑ |
| ស. | द्विपदि | ទ្វិបទិ | " | " | द्विपत्सु | ទ្វិបត្សុ |
| សម្ពោ. | द्विपाद् | ទ្វិបាទ៑ | द्विपादौ | ទ្វិបាទៅ | द्विपादस् | ទ្វិបាទស៑ |

ទ្វិបទ៑ ជានបុំសកលិង្គ ត្រង់ប្រ. ទុ. សម្ពោ. ឯក. ជា ទ្វិបទ៑;- ទ្វិ. ជា ទ្វិបទី;- ពហុ. ជា ទ្វិបាទិ ក្រៅពីនោះដូចគ្នានឹងបុំលិង្គ ។

ឯ ទ្វិបទ៑ ដែលជាស្ត្រីលិង្គខាងលើនេះ គេអាចធ្វើឲ្យជាស្ត្រីលិង្គ មានទ្រង់ដោយឡែកទៀតបាន គឺប្រកបដោយប្រត្យយ ឦ ថែមមក ទៀតជា ទ្វិបទី តែត្រូវបំបែកដូចទេវី (ម.ល. ៦១) ។

## សេចក្ដីបំណាំ:

១. ន. ស. វាចិ, ស្ត្រី. កើតមកពីធាតុ វចិ, "ពោល" ជានាមសព្ទ មានស្វរជាទីឃ "វាចិ" ដូចនេះគប់អន្ទើ ឥតមានផ្លាស់ប្តូរប្រែទៅ ជាហ្រស្វឡើយ ដូចខាងក្រោយនេះ

| | ឯក. | | ទ្វេ. | | ពហុ. | |
|---|---|---|---|---|---|---|
| ប្រ. | वाक् | វាក៑ | वाचौ | វាចៅ | वाचस् | វាចស៑ |
| ទុ. | वाचम् | វាចម៑ | " | " | " | " |
| ត្ប. | वाचा | វាចា | वाग्भ्याम् | វាគ្ភ្យាម៑ | वाग्भिस् | វាគ្ភិស៑ |
| ច. | वाचे | វាចេ | " | " | वाग्भ्यस् | វាគ្ភ្យស៑ |
| ប. | वाचस् | វាចស៑ | " | " | " | " |
| ឆ. | " | " | वाचोस् | វាចោស៑ | वाचाम् | វាចាម៑ |
| ស. | वाचि | វាចិ | " | " | वाक्षु | វាក្សុ |
| សម្ពោ. | वाक् | វាក៑ | वाचौ | វាចៅ | वाचस् | វាចស៑ |

២. ធាតុ ហន៑, "សម្លាប់" ភ្ជាប់ទីផនាមសព្ទ កើតទៅជាបទសមាស ដូច វ្ឫត្រហន៑, បុំ. "ព្រះឥន្ទ្រ" ត្រង់ប្រថមា ឯកវចន ជា វ្ឫត្រហា (តាមទំនង់នាមសព្ទជា អន៑-ការន្ត ម.ល. ៦៦) ក្រៅពីនោះ ត្រូវបំបែកតាមសមគួរដូចតទៅនេះ

| | ឯក. | ទ្វិ. | ពហុ. |
|---|---|---|---|
| ប្រ. | वृत्रहा<br>វ្ឫត្រហា | वृत्रहणौ<br>វ្ឫត្រហណៅ | वृत्रहणस्<br>វ្ឫត្រហណស៑ |
| ទុ. | वृत्रहनम् វ្ឫត្រហនម៑ | " | वृत्रघ्नस् វ្ឫត្រឃ្នស៑ |
| ត. | वृत्रघ्ना វ្ឫត្រឃ្នា | वृत्रहभ्याम् វ្ឫត្រហភ្យាម៑ | वृत्रहभिस् វ្ឫត្រហភិស៑ |
| ច. | वृत्रघ्ने វ្ឫត្រឃ្នេ | " " | वृत्रहभ्यस् វ្ឫត្រហភ្យស៑ |
| ប. | वृत्रघ्नस् វ្ឫត្រឃ្នស៑ | " " | " " |
| ឆ. | " " | वृत्रघ्नोस् វ្ឫត្រឃ្នោស៑ | वृत्रघ्नाम् វ្ឫត្រឃ្នាម៑ |
| ស. | वृत्रघ्नि, °हनि<br>វ្ឫត្រឃ្និ, °ហនិ | " " | वृत्रहसु<br>វ្ឫត្រហសុ |
| សម្ពោ. | वृत्रहन्<br>វ្ឫត្រហន៑ | वृत्रहणौ<br>វ្ឫត្រហណៅ | वृत्रहणस्<br>វ្ឫត្រហណស៑ |

៣. ធាតុ អញ្ចុ "ទៅ, ដើរវៀន" ប្រកបដោយឧបសគ្គផ្សេងៗ កើតទៅជាបទគុណសព្ទ: ប្រ + អញ្ចុ > ប្រាញ្ចុ "ខាងកើត"; ប្រតិ + អញ្ចុ > ប្រត្យញ្ចុ, "ខាងលិច" ។

## प्राञ्च् ប្រាញ្ច៍ បុ. “ខាងកើត”

| | ឯក. | | ទ្វិ. | | ពហុ. | |
|---|---|---|---|---|---|---|
| ប្រ. | प्राङ् | ប្រាង៑ | प्राञ्चौ | ប្រាញ្ចៅ | प्राञ्चस् | ប្រាញ្ចស៑ |
| ទុ. | प्राञ्चम् | ប្រាញ្ចម៑ | " | " | प्राचस् | ប្រាចស៑ |
| ត. | प्राचा | ប្រាចា | प्राग्भ्याम् | ប្រាគ្ភ្យាម៑ | प्राग्भिस् | ប្រាគ្ភិស៑ |
| ច. | प्राचे | ប្រាចេ | " | " | प्राग्भ्यस् | ប្រាគ្ភ្យស៑ |
| ប. | प्राचस् | ប្រាចស៑ | " | " | " | " |
| ឆ. | " | " | प्राचोस् | ប្រាចោស៑ | प्राचाम् | ប្រាចាម៑ |
| ស. | प्राचि | ប្រាចិ | " | " | प्राक्षु | ប្រាក្សុ |
| សម្ពោ. | प्राङ् | ប្រាង៑ | प्राञ्चौ | ប្រាញ្ចៅ | प्राञ्चस् | ប្រាញ្ចស៑ |

ប្រាញ្ច៍, នបុំ. ត្រង់ប្រ. ទុ. សម្ពោ. ឯក.: ប្រាក៑;- ទ្វិ.: ប្រាចី.- ពហុ.: ប្រាញ្ចិ ក្រៅពីនោះដូចគ្នានឹងបុំលិង្គ ។ បើជាស្ត្រីលិង្គ ត្រូវប្រែកប ដោយប្រត្យយ ឦ ជា ប្រាចី ត្រូវបំបែកដូច នទី (ម.ល. ៦១) ។

## प्रत्यञ्च् ប្រត្យញ្ច៑, នបុំ. "ខាងលិច"

| | ឯក. | ទ្វិ. | ពហុ. |
|---|---|---|---|
| ប្ឋ. | प्रत्यङ् ប្រត្យង៑ | प्रत्यञ्चौ ប្រត្យញ្ចៅ | प्रत्यञ्चस् ប្រត្យញ្ចស៑ |
| ទុ. | प्रत्यञ्चम् ប្រត្យញ្ចម៑ | " " | प्रतीचस् ប្រតីចស៑ |
| ត្ឫ. | प्रतीचा ប្រតីចា | प्रत्यग्भ्याम् ប្រត្យគ្ភ្យាម៑ | प्रत्यग्भिस् ប្រត្យគ្ភិស៑ |
| ច. | प्रतिचे ប្រតីចេ | " " | प्रत्यग्भ्यस् ប្រត្យគ្ភ្យស៑ |
| ប. | प्रतीचस् ប្រតីចស៑ | " " | " " |
| ឆ. | " " | प्रतीचोस् ប្រតីចោស៑ | प्रतीचाम् ប្រតីចាម៑ |
| ស. | प्रतीचि ប្រតីចិ | " " | प्रत्यक्षु ប្រត្យក្សុ |
| សម្ពោ. | प्रत्यङ् ប្រត្យង៑ | प्रत्यञ्चौ ប្រត្យញ្ចៅ | प्रत्यञ्चस् ប្រត្យញ្ចស៑ |

ប្រត្យញ្ច៑, នបុំ. ត្រង់ប្ឋ. ទុ. សម្ពោ. ឯក.: ប្រត្យក៑.- ទ្វិ.: ប្រតីចី.- ពហុ.: ប្រត្យញ្ចិ, ក្រៅពីនោះដូចគ្នានឹងបុំលិង្គ ។ បើជាស្ត្រីលិង្គ ត្រូវប្រែកបដោយប្រត្យយ ឦ ជា ប្រតីចី ត្រូវបំបែកដូច នទី (ម.ល. ៦១) ។

### (៦៦) ២. នាមសព្ទ ជា អន៑-ការាន្ត.

នាមសព្ទ ជាអន៑-ការាន្តទាំងអស់ សុទ្ធតែជាបុំលិង្គ នឹងនបុំសកលិង្គ បើបុំលិង្គ ត្រង់ប្ឋ.ឯក. ត្រូវលុបតួ ន៑ ចេញ ហើយទីឃ អ ជា អា

(មើលធាតុនាមសព្ទលេខ ៦៥ ត្រង់សេចក្ដីចំណាំលេខ ២ ); បើនបុំ-សកលិង្គ ត្រង់ប្រ. ឯក. ត្រូវលុបតែតួ ន៑ ចេញ មិនត្រូវទីឃៈឡើយ, ក្រៅពីនោះ ជួនកាលលុបស្រៈ អ ជួនកាលលុប ន៑ ចេញ តាមសមគួរដល់វិភត្តិដែលជាស្រៈនិងព្យញ្ជនៈ ។

## राजन् រាជន៑, បុំ. “ស្ដេច”

| | ឯក. | | ទ្វិ. | | ពហុ. | |
|---|---|---|---|---|---|---|
| ប្រ. | राजा | រាជា | राजानौ | រាជានៅ | राजानस् | រាជានស៑ |
| ទុ. | राजानम् | រាជានម៑ | " | " | राज्ञस् | រាជ្ញស៑ |
| ត្ឫ. | राज्ञा | រាជ្ញា | राजभ्याम् | រាជភ្យាម៑ | राजभिस् | រាជភិស៑ |
| ច. | राज्ञे | រាជ្ញេ | " | " | राजभ्यस् | រាជភ្យស៑ |
| ប. | राज्ञस् | រាជ្ញស៑ | " | " | " | " |
| ឆ. | " | " | राज्ञोस् | រាជ្ញោស៑ | राज्ञाम् | រាជ្ញាម៑ |
| ស. | राज्ञि, राजनि<br>រាជ្ញិ, រាជនិ | | " | " | राजसु | រាជសុ |
| សម្ពោ. | राजन् | រាជន៑ | राजानौ | រាជានៅ | राजानस् | រាជានស៑ |

បើជាស្រីលិង្គ ត្រូវបន្ថែមបច្ច័យ ई ភ្ជាប់មកទៀតធ្វើជា រាជ្ញី “ស្ដេចស្រី” ត្រូវបំបែកដូច ទេវី

## นามนฺ នាមន៑, នបុំ. “ឈ្មោះ”

| | ឯក. | ទ្វិ. | ពហុ. |
|---|---|---|---|
| ប្ប. | นาม នាម | นามฺนี, นามนี<br>នាម្នី, នាមនី | นามานิ នាមានិ |
| ទុ. | " " | " " | " " |
| ត្ប. | นามฺนา នាម្នា | นามภฺยามฺ នាមភ្យាម៑ | นามภิสฺ នាមភិស៑ |
| ច. | นามฺเน នាម្នេ | " " | นามภฺยสฺ នាមភ្យស៑ |
| ប. | นามฺนสฺ នាម្នស៑ | " " | " " |
| ឆ. | " " | นามฺโนสฺ នាម្នោស៑ | นามฺนามฺ នាម្នាម៑ |
| ស. | นามฺนิ, นามนิ<br>នាម្និ, នាមនិ | " " | นามสุ នាមសុ |
| សម្ពោ. | นามนฺ, นาม<br>នាមន៑, នាម | นามฺนี, นามนี<br>នាម្នី, នាមនី | นามานิ នាមានិ |

## សេចក្ដីបំណាំ:

១. នាមសព្ទជា អន៑·ការន្ត ឯទៀត ដែលមានព្យញ្ជនដម្រួតគ្នា, ត្រង់កន្លែងដែលលុបស្រៈអ ចេញ បែរទៅជាមិនលុបវិញក៏មាន ព្រោះកាលណាលុបស្រៈ អ ចេញ ព្យញ្ជនដែលសល់នៅបន្តរលើគ្នា សរសេរ

ក៏លំបាក អានក៏លំបាក ដូចសព្ទ អាត្មន៑, បុំ. "ចិត្ត, ខ្លួន" ត្រង់ចតុថី ឯកវចនៈ អាត្មនេ មិនមែនជា អាត្មេ ដូច្នេះឡើយ ។

៤. សព្ទ ឝ្វន៑ បុំ. "ឆ្កែ", យុវន៑, បុំ. "កំលោះ" មានវិធីបំបែក ត្រូវគ្នាខ្លះ ខុសគ្នាខ្លះ តាមសមគួរដល់រូបសព្ទ ដូចតទៅនេះ

## श्वन् ឝ្វន៑, បុំ. "ឆ្កែ"

| | ឯក. | | ទ្វិ. | | ពហុ. | |
|---|---|---|---|---|---|---|
| ប្រ. | श्वा | ឝ្វា | श्वानौ | ឝ្វានៅ | श्वानस् | ឝ្វានស៑ |
| ទុ. | श्वानम् | ឝ្វានម៑ | " | " | शुनस् | ឝុនស៑ |
| ត្ឫ. | शुना | ឝុនា | श्वभ्याम् | ឝ្វភ្យាម៑ | श्वभिस् | ឝ្វភិស |
| ច. | शुने | ឝុនេ | " | " | श्वभ्यस् | ឝ្វភ្យស៑ |
| ប. | शुनस् | ឝុនស៑ | " | " | " | " |
| ឆ. | " | " | शुनोस् | ឝុនោស៑ | शुनाम् | ឝុនាម៑ |
| ស. | शुनि, श्वनि | ឝុនិ, ឝ្វនិ | " | " | श्वसु | ឝ្វសុ |
| សម្ពោ. | श्वन् | ឝ្វន៑ | श्वानौ | ឝ្វានៅ | श्वानस् | ឝ្វានស៑ |

បើជាស្ត្រី. ឝុនី, "ឆ្កែញី" ត្រូវបំបែកដូច ទេវី

## युवन् យុវន៑, បុំ. "កំលោះ"

| | ឯក. | | ទ្វិ. | | ពហុ. | |
|---|---|---|---|---|---|---|
| ប្រ. | युवा | *យុវា* | युवानौ | *យុវានៅ* | युवानस् | *យុវានស៑* |
| ទុ. | युवानम् | *យុវានម៑* | " | " | यूनस् | *យូនស៑* |
| ត្ប. | यूना | *យូនា* | युवभ्याम् | *យុវភ្យាម៑* | युवभिस् | *យុវភិស៑* |
| ច. | यूने | *យូនេ* | " | " | युवभ्यस् | *យុវភ្យស៑* |
| ប. | यूनस् | *យូនស៑* | " | " | " | " |
| ឆ. | " | " | यूनोस् | *យូនោស៑* | यूनाम् | *យូនាម៑* |
| ស. | यूनि, युवनि | *យូនិ, យុវនិ* | " | " | युवसु | *យុវសុ* |
| សម្ពោ. | युवन् | *យុវន៑* | युवानौ | *យុវានៅ* | युवानस् | *យុវានស៑* |

*បើជាស្ត្រី: យុវតី, "ក្រមុំ" ត្រូវបំបែកដូច ទេវី*

*៣. សព្ទ បន្ថិន៑, បុំ. "ផ្លូវ" វិធីបំបែក ត្រង់ប្រ. ឯក.: បន្ថាស៑, ក្រៅពីនោះផ្សេងអំពីគ្នាបន្តិចបន្តួច ដូចតទៅនេះ*

| | ឯក. | | ទ្វិ. | | ពហុ. | |
|---|---|---|---|---|---|---|
| ប្រ. | पन्थास् | *បន្ថាស៑* | पन्थानौ | *បន្ថានៅ* | पन्थानस् | *បន្ថានស៑* |
| ទុ. | पन्थानम् | *បន្ថានម៑* | " | " | पथस् | *បថស៑* |

| | ឯក. | | ទ្វិ. | | ពហុ. | |
|---|---|---|---|---|---|---|
| ត្រ. | पथा | បថា | पथिभ्याम् | បថិភ្យាម៑ | पथिभिस् | បថិភិស៑ |
| ច. | पथे | បថេ | " | " | पथिभ्यस् | បថិភ្យស៑ |
| ប. | पथस् | បថស៑ | " | " | " | " |
| ឆ. | " | " | पथोस् | បថោស៑ | पथाम् | បថាម៑ |
| ស. | पथि | បថិ | " | " | पथिषु | បថិឞុ |

៦. សព្ទ អហន៑, នបុំ. "ថ្ងៃ" មានវិធីបំបែកដូចតទៅនេះ

| | ឯក. | | ទ្វិ. | | ពហុ. | |
|---|---|---|---|---|---|---|
| ប្រ. | अहर् | អហរ៑ | अह्नी, अहनी / អហ្នី, អហនី | | अहानि | អហានិ |
| ទុ. | " | " | ", | " | " | " |
| ត្រ. | अह्ना | អហ្នា | अहोभ्याम् | អហោភ្យាម៑ | अहोभिस् | អហោភិស៑ |
| ច. | अह्ने | អហ្នេ | " | " | अहोभ्यस् | អហោភ្យស៑ |
| ប. | अह्नस् | អហ្នស៑ | " | " | " | " |
| ឆ. | " | " | अह्नोस् | អហ្នោស៑ | अह्नाम् | អហ្នាម៑ |
| ស. | अह्नि, अहनि / អហ្និ, អហនិ | | " | " | अहःसु | អហះសុ |

៤. សព្ទ អក្សិ, នបុំ. "ភ្នែក", អស្ថិ, នបុំ. "ឆ្អឹង" សព្ទទាំងពីរនេះមានវិធីបំបែកដូចគ្នានឹង អក្សិ, អស្ថិ ខ្លះ (ម. ឥការន្តត្រង់លេខ ៦៤) ផ្សេងខុសពីគ្នាខ្លះ ដូចតទៅនេះ

## អក្សិ, នបុំ. "ភ្នែក"

| | ឯក. | | ទ្វិ. | | ពហុ. | |
|---|---|---|---|---|---|---|
| ប្រ. | अक्षि | អក្សិ | अक्षिणी | អក្សិណី | अक्षीणि | អក្សីណិ |
| ទុ. | " | " | " | " | " | " |
| ករ. | अक्ष्णा | អក្ស្ណា | अक्षिभ्याम् | អក្សិភ្យាម៑ | अक्षिभिस् | អក្សិភិស៑ |
| ច. | अक्ष्णे | អក្ស្ណេ | " | " | अक्षिभ्यस् | អក្សិភ្យស៑ |
| ប. | अक्ष्णस् | អក្ស្ណស៑ | " | " | " | " |
| ឆ. | " | " | अक्ष्णोस् | អក្ស្ណោស៑ | अक्ष्णाम् | អក្ស្ណាម៑ |
| ស. | अक्ष्णि, अक्षणि | អក្ស្ណិ, អក្សណិ | " | " | अक्षिषु | អក្សិឞុ |

## (៦៧) ៣. នាមសព្ទ ជា ឥន៑- ការន្ត

សព្ទទាំងឡាយដែលជា ឥន៑- ការន្ត គឺសព្ទដែលប្រកបដោយប្រត្យយ ឥន៑ ដូចជា ពល នឹង ឥន៑ ជា ពលិន៑, ទណ្ឌ នឹង ឥន៑ ជា

ទណ្ឌិន៑ ដូច្នេះជាដើម សុទ្ធតែជាគុណសព្ទទាំងអស់ សំគាល់សេចក្ដីប្រែថា "មាន": ពល "កម្លាំង", ពលិន៑ "មានកម្លាំង"; ទណ្ឌ "ដំបង", ទណ្ឌិន៑ "មានដំបង, មានឈើច្រត់" តែគុណសព្ទទាំងអស់នេះ បើប្រើជានាមសព្ទក៏បានដូចគ្នា ត្រូវប្រែថា ពលិន៑, ជនមានកម្លាំង, ទណ្ឌិន៑ ជនមានឈើច្រត់

## बलिन् ពលិន៑, បុំ.

| | ឯក. | | ទ្វិ. | | ពហុ. | |
|---|---|---|---|---|---|---|
| ប្រ. | बली | ពលី | बलिनौ | ពលិនៅ | बलिनस् | ពលិនស៑ |
| ទុ. | बलिनम् | ពលិនម៑ | " | " | " | " |
| ត. | बलिना | ពលិនា | बलिभ्याम् | ពលិភ្យាម៑ | बलिभिस् | ពលិភិស៑ |
| ច. | बलिने | ពលិនេ | " | " | बलिभ्यस् | ពលិភ្យស៑ |
| ប. | बलिनस् | ពលិនស៑ | " | " | " | " |
| ឆ. | " | " | बलिनोस् | ពលិនោស៑ | बलिनाम् | ពលិនាម៑ |
| ស. | बलिनि | ពលិនិ | " | " | बलिषु | ពលិឞុ |
| សម្ពោ. | बलिन् | ពលិន៑ | बलिनौ | ពលិនៅ | बलिनस् | ពលិនស៑ |

ពលិន៑, នបុំ. មានវិធីបំបែកដូចគ្នា ប្លែកបន្តិចតែត្រង់ ប្រ. ទុ. សម្ពោ. ត្រង់ ប្រ. ទុ. ឯក. ជា ពលិ; – ទ្វិ. ជា ពលិនី; – ពហុ. ជា

ពលីនិ ។ ត្រង់ សម្ពោ. ឯក. ជា ពលិនិ ឬ ពលិ;–ទុតិ. ទាំង ពហុ. ដូច ប្រ. ទុ. ដែលជា ទុតិ. ទាំង ពហុ. នោះដែរ ។

ពលិនិ, បើជាស្ត្រី. ត្រូវបន្ថែម ឦ បច្ច័យ ធ្វើជា ពលិនី, “(ស្រី) មានកម្លាំង” ត្រូវបំបែកដូច ទេវី ។

## (៦៨) ៤. សទ្ទ ជា អន្ត- ការន្ត

សទ្ទទាំងឡាយដែលជា អន្ត-ការន្ត គឺរូបធាតុ ដែលប្រកបដោយបច្ច័យ អន្ត ឬ អត សម្រេចជាគុណសទ្ទ ឬ ជាអព្ភន្តរកិរិយា ដូច ធាតុ តុទ “ចាក់”; ចរ “ចរទៅ” ប្រកបដោយបច្ច័យ អន្ត សម្រេចរូបជា តុទន្ត “កាលចាក់”; ចរន្ត “កាលចរទៅ”; បើរូបធាតុណា ដែលមានបទអព្ភាស ដូច ធាតុ ទា “ឲ្យ”; ហុ “បូជា”, ធាតុទាំងនេះ ត្រូវប្រកបដោយបច្ច័យ អត សម្រេចរូបជា ទទត, “កាលឲ្យ”; ជុហត “កាលបូជា” ។

### तुदन्त् តុទន្ត, បុំ.

| | ឯក. | | ទ្វិ. | | ពហុ. | |
|---|---|---|---|---|---|---|
| ប្រ. | तुदन् | តុទំ | तुदन्तौ | តុទន្តៅ | तुदन्तस् | តុទន្តសៈ |
| ទុ. | तुदन्तम् | តុទន្តំ | " | " | तुदतस् | តុទតសៈ |

| | ឯក. | | ទ្វិ. | | ពហ. | |
|---|---|---|---|---|---|---|
| ក. | तुदता | តុទតា | तुदद्भ्याम् | តុទទ្ភ្យាម៑ | तुदद्भिस् | តុទទ្ភិស៑ |
| ច. | तुदते | តុទតេ | " | " | तुदद्भ्यस् | តុទទ្ភ្យស៑ |
| ប. | तुदतस् | តុទតស៑ | " | " | " | " |
| ឆ. | " | " | तुदतोस् | តុទតោស៑ | तुदताम् | តុទតាម៑ |
| ស. | तुदति | តុទតិ | " | " | तुदत्सु | តុទត្សុ |
| សម្ពោ. | तुदन् | តុទន៑ | तुदन्तौ | តុទន្តៅ | तुदन्तस् | តុទន្តស៑ |

តុទន្ត៑ នេះ, បើជានបុំ. ត្រូវបំបែកដូចគ្នា ប្លែកតែត្រង់ ប្រ. ទ្វិ. សម្ពោ: ឯក. ជា តុទត៑; – ទ្វិ. ជា តុទន្តី ឬ តុទតី; – ពហុ. ជា តុទន្តិ ។ បើជាស្ត្រីលិង្គ: តុទន្តី ឬ តុទតី ត្រូវបំបែកដូច ទេវី ។

សព្ទទាំងឡាយឯទៀត ដែលប្រកបដោយប្រត្យយ វន្ត៑, មន្ត៑[១] សម្រេចជាគុណសព្ទ ត្រូវប្រែថា "មាន..." ដូច ភគវន្ត៑ "មានព្រះភាគ្យ", ពលវន្ត៑, "មានកម្លាំង", មធុមន្ត៑ "មានទឹកឃ្មុំ", ស្មតិមន្ត៑ "មានស្មារតី" សព្ទទាំងនេះ ត្រូវបំបែកដូចគ្នានឹង តុទន្ត៑ ប្លែកតែត្រង់ ប្រថមាឯកវចន ជា ភគវាន៑, ពលវាន៑, មធុមាន៑, ស្មតិមាន៑ ។

១ ប្រត្យយទាំង ២ នេះ ត្រូវគ្នានឹងបច្ចយក្នុងកច្ចាយនបាលី វន្តុ, មន្តុ ដែលសម្រាប់ប្រកបផ្សំនឹងនាមសព្ទ សម្រេចឲ្យជា អត្ថិតទ្ធិត ។

បើជាស្ត្រីលិង្គ: ភគវតី, ពលវតី, មធុមតី, សតិមតី ត្រូវបំបែក ដូច ទៅ ៗ

## ददत् ទទត៑, បុំ. "ការឲ្យ"

| | ឯក. | | ទ្វិ. | | ពហុ. | |
|---|---|---|---|---|---|---|
| ប្រ. | ददत् | ទទត៑ | ददतौ | ទទតៅ | ददतस् | ទទតស៑ |
| ទុ. | ददतम् | ទទតម៑ | " | " | " | " |
| តឫ. | ददता | ទទតា | ददद्भ्याम् | ទទទ្ភ្យាម៑ | ददद्भिस् | ទទទ្ភិស៑ |
| ច. | ददते | ទទតេ | " | " | ददद्भ्यस् | ទទទ្ភ្យស៑ |
| ប. | ददतस् | ទទតស៑ | " | " | " | " |
| ឆ. | " | " | ददतोस् | ទទតោស៑ | ददताम् | ទទតាម៑ |
| ស់. | ददति | ទទតិ | " | " | ददत्सु | ទទត្សុ |
| សម្ពោ. | ददत् | ទទត៑ | ददतौ | ទទតៅ | ददतस् | ទទតស៑ |

ទទត៑ នេះ, បើជានបុំ. ត្រូវបំបែកដូចគ្នា ប្លែកតែត្រង់ ប្រ. ទុ. សម្ពោ. ឯក. ជា ទទត៑;– ទ្វិ. ជា ទទតី; ពហុ. ជា ទទតិ ។ បើជាស្ត្រីលិង្គ: ទទតី ត្រូវបំបែកដូច ទៅ ៗ

ម្យ៉ាងទៀត, សព្ទ មហន្ត, គ.ស. "ធំ" មានវិធីបំបែកគេគល់ដូច

គ្នា ទាំងសព្ទជា អន្ត- ការាន្ត គ្រប់អន្ទើ ប្លែកបន្តិចតែត្រង់ ប្រ. ទុ. ឯក. ទ្វិ. ទាំង ប្រ. ពហុ. មានសូរជាទីឃៈ:

| | ឯក. | | ទ្វិ. | | ពហុ. | |
|---|---|---|---|---|---|---|
| ប្រ. | महान् | មហាន៑ | महान्तौ | មហាន្តៅ | महान्तः | មហាន្តះ |
| ទុ. | महान्तम् | មហាន្តម៑ | " | " | महतः | មហតះ |
| តតិ. | महता | មហតា | महद्भ्याम् | មហទ្ភ្យាម៑ | महद्भिः | មហទ្ភិះ |
| ច. | महते | មហតេ | " | " | महद्भ्यः | មហទ្ភ្យះ |
| ប. | महतः | មហតះ | " | " | " | " |
| ឆ. | " | " | महतोः | មហតោះ | महताम् | មហតាម៑ |
| ស. | महति | មហតិ | " | " | महत्सु | មហត្សុ |

បើជានបុំ. ត្រង់ ប្រ. ទុ. ឯក. ជា មហត៑;- ទ្វិ. ជា មហតី;- ពហុ. ជា មហាន្តិ ក្រៅពីនោះដូចគ្នាទាំងអស់ ។ បើជាស្ត្រី.: មហតី ត្រូវបំបែកដូច នទី ។

## (៦៩) ៥. នាមសព្ទ ជា អស៑-, ឥស៑-, ឧស៑- ការាន្ត.

នាមសព្ទដែលជា អស៑-, ឥស៑-, ឧស៑- ការាន្ត ទាំងអស់ ជា នបុំសកលិង្គ មានជោយច្រើនណាស់ ស្ទើរតែទាំងអស់ ដែលជាបុំលិង្គ និងជាស្ត្រីលិង្គ មានតែ ២-៣ សព្ទប៉ុណ្ណោះ ។ ប៉ុន្តែសព្ទទាំងនោះ

អាចធ្វើទីបំផុតសព្ទ ឲ្យកើតទៅជាត្រៃលិង្គបានខ្លះ នៅវេលាដែលធ្វើទៅជាបទសមាស ។. មនស៑, នបុំ. "ចិត្ត" សុ-មនស៑, គ. "មានចិត្តល្អ"; វចស៑, នបុំ. "ពាក្យ, សំដី"; ទុវចស៑, គ. "មានសំដីអាក្រក់"; ឯសុមនស៑ និង ទុវចស៑ មានវិធីបំបែកដូចនាមសព្ទជា អស៑-ការន្ត បុំលិង្គ ដែរ ។

នាមសព្ទ ជាបុំលិង្គ និងស្ត្រីលិង្គ មានវិធីបំបែកដូចគ្នា ចំពោះតែ នាមសព្ទដែលជា អស៑-ការន្ត, ត្រង់ប្រថមា ឯកវចន ត្រូវទីឃស្រៈ អ ជា អា ។ រីឯនាមសព្ទដែលជានបុំសកលិង្គ, ត្រង់ប្រថមា ទុតិយា, ពហុវចន អស៑ ធ្វើជា អាំសិ; ឥស៑ ធ្វើជា ឦំឞិ; ឧស៑ ធ្វើជា ឩំឞិ ។

## चन्द्रमस् ចន្ទ្រមស៑, បុំ. "ព្រះចន្ទ្រ"

| | ឯក. | ទ្វិ. | ពហុ. |
|---|---|---|---|
| ប្រ. | चन्द्रमास् ចន្ទ្រមាស៑ | चन्द्रमसौ ចន្ទ្រមសៅ | चन्द्रमसस् ចន្ទ្រមសស៑ |
| ទ្វិ. | चन्द्रमसम् ចន្ទ្រមសម៑ | " " | " " |
| តឫ. | चन्द्रमसा ចន្ទ្រមសា | चन्द्रमोभ्याम् ចន្ទ្រមោភ្យាម៑ | चन्द्रमोभिस् ចន្ទ្រមោភិស៑ |

| | ឯក. | ទ្វិ. | ពហុ. |
|---|---|---|---|
| ច. | चन्द्रमसे ចន្ទ្រមសេ | चन्द्रमोभ्याम् ចន្ទ្រមោភ្យាម៑ | चन्द्रमोभ्यस् ចន្ទ្រមោភ្យស៑ |
| ប. | चन्द्रमसस् ចន្ទ្រមសស៑ | " | " |
| ឆ. | " " | चन्द्रमसोस् ចន្ទ្រមសោស៑ | चन्द्रमसाम् ចន្ទ្រមសាម៑ |
| ស. | चन्द्रमसि ចន្ទ្រមសិ | " | चन्द्रमःसु ចន្ទ្រមៈសុ |
| សម្ពោ. | चन्द्रमस् ចន្ទ្រមស៑ | चन्द्रमसौ ចន្ទ្រមសៅ | चन्द्रमसस् ចន្ទ្រមសស៑ |

## सुमनस् សុមនស៑, គំ.

ឯកវចនៈ: ប. សុមនាស៑, ទុ. សុមនសម៑, ត្ត. សុមនសា, ច. សុមនសេ, ប. ឆ. សុមនសស៑, ស. សុមនសិ, សម្ពោ. សុមនស៑;

ទ្វិវចនៈ: ប. ទុ. សម្ពោ. សុមនសៅ, ត្ត. ច. ប. សុមនោភ្យាម៑, ឆ. ស. សុមនសោស៑;

ពហុវចនៈ: ប. ទុ. សម្ពោ. សុមនសស៑, ត្ត. សុមនោភិស៑, ច. ប. សុមនោភ្យស៑, ឆ. សុមនសាម៑, ស. សុមនៈសុ.

## मनस् មនស៑, នបុំ. "ចិត្ត"

| | ឯក. | | ទ្វិ. | | ពហុ. | |
|---|---|---|---|---|---|---|
| ប្រ. | मनस् | មនស៑ | मनसी | មនសី | मनांसि | មនាំសិ |
| ទុ. | " | " | " | " | " | " |
| ត្ត. | मनसा | មនសា | मनोभ्याम् | មនោភ្យាម៑ | मनोभिस् | មនោភិស៑ |
| ច. | मनसे | មនសេ | " | " | मनोभ्यस् | មនោភ្យស៑ |
| ប. | मनसस् | មនសស៑ | " | " | " | " |
| ឆ. | " | " | मनसोस् | មនសោស៑ | मनसाम् | មនសាម៑ |
| ស. | मनसि | មនសិ | " | " | मनःसु | មនះសុ |
| សម្ពោ. | मनस् | មនស៑ | मनसी | មនសី | मनांसि | មនាំសិ |

## हविस् ហវិស៑, នបុំ. "កិរិយាបូជា"

| | ឯក. | | ទ្វិ. | | ពហុ. | |
|---|---|---|---|---|---|---|
| ប្រ. | हविस् | ហវិស៑ | हविषी | ហវិឞី | हवींषि | ហវីំឞិ |
| ទុ. | " | " | " | " | " | " |
| ត្ត. | हविषा | ហវិឞា | हविर्भ्याम् | ហវិភ៌្យាម៑ | हविर्भिस् | ហវិភ៌ិស |
| ច. | हविषे | ហវិឞេ | " | " | हविर्भ्यस् | ហវិភ៌្យស៑ |
| ប. | हविषस् | ហវិឞស៑ | " | " | " | " |

| | ឯក. | ទ្វិ. | ពហុ. |
|---|---|---|---|
| ប. | ឝ្រេយសស៑ ស្រេយសស៑ | ឝ្រេយសោស៑ ស្រេយសោស៑ | ឝ្រេយសាម៑ ស្រេយសាម៑ |
| ស. | ឝ្រេយសិ ស្រេយសិ | " " | ឝ្រេយះសុ ស្រេយះសុ |
| សម្ពោ. | ឝ្រេយន៑ ស្រេយន៑ | ឝ្រេយាំសៅ ស្រេយាំសៅ | ឝ្រេយាំសស៑ ស្រេយាំសស៑ |

បើជា នបុំ. ត្រង់ ប្រ. ទ្វិ. សម្ពោ. ឯក. ជា ស្រេយស៑;- ទ្វិ. ជា ស្រេយសី;- ពហុ. ជា ស្រេយាំសិ ក្រៅពីនោះដូចគ្នានឹង ស្រេយស៑, បុំ. ដែលបំបែកខាងលើនេះ ។

បើជាស្ត្រី:- ស្រេយសី ត្រូវបំបែកដូច ទេវី ។

## (៧១) ពិ. នាមសព្ទ ជា វស៑-ការាន្ត

សព្ទជា វស៑- ការន្ត គឺធាតុដែលប្រកបដោយប្រត្យយ វស៑ កើតទៅជាក្ឫតនាមសព្ទ មានសេចក្ដីជាអតីតកាល ។ ប្រត្យយ វស៑ នេះ ភ្ជាប់ចំពោះទីងរូបធាតុតែម្ដង ឲ្យសំរេចជានាមសព្ទ ចាត់ជានាមនាមក៏បាន ជាគុណនាមក៏បាន ។ ធាតុ. វិទ៑, ដឹង + វស៑ > វិទ្វស៑ "ដែលបានដឹង ឬ អ្នកបានដឹង (អ្នកប្រាជ្ញ)"

## วิทฺวสฺ វិទ្វស៑, បុំ.

| | ឯក. | | ទ្វិ. | | ពហុ. | |
|---|---|---|---|---|---|---|
| ប្រ. | วิทฺวานฺ | វិទ្វាន៑ | วิทฺวำโส | វិទ្វាំសោ | วิทฺวำสสฺ | វិទ្វាំសស៑ |
| ទ្វិ. | วิทฺวำสมฺ | វិទ្វាំសម៑ | " | " | วิทุษสฺ | វិទុឞស៑ |
| ត្ឫ. | วิทุษา | វិទុឞា | วิทฺวทฺภฺยามฺ | វិទ្វទ្ភ្យាម៑ | วิทฺวทฺภิสฺ | វិទ្វទ្ភិស៑ |
| ច. | วิทุเษ | វិទុឞេ | " | " | วิทฺวทฺภฺยสฺ | វិទ្វទ្ភ្យស៑ |
| ប. | วิทุษสฺ | វិទុឞស៑ | " | " | " | " |
| ឆ. | " | " | วิทุโษสฺ | វិទុឞោស៑ | วิทุษามฺ | វិទុឞាម៑ |
| ស. | วิทุษิ | វិទុឞិ | " | " | วิทฺวตฺสุ | វិទ្វត្សុ |
| សម្ពោ. | วิทฺวนฺ | វិទ្វន៑ | วิทฺวำโส | វិទ្វាំសោ | วิทฺวำสสฺ | វិទ្វាំសស៑ |

បើជានបុំ. ត្រង់ ប្រ. ទ្វិ. សម្ពោ. ឯក. ជា វិទ្វត៑; – ទ្វិ. ជា វិទុឞី; – ពហុ. ជា វិទ្វាំសិ ។

បើជា ស្ត្រី.: វិទុឞី ត្រូវបំបែកដូច នទី ។

## (៧២) ៨. នាមសព្ទ ជា អរ៑-, តរ៑- ការាន្ត

នាមសព្ទពួកនេះ បែកចេញជា ២ យ៉ាង គឺ:

១. ការក-នាមសព្ទ[១]ជា តរ៑-ការាន្ត ជាសព្ទកើតអំពីរូបធាតុ ដែល

---

១ នាមសព្ទពោលចំពោះ មនុស្ស ឬសត្វ ដែលជាអ្នកធ្វើ ឬ ជាអ្នកសំរេចនូវអំពើណាមួយ (ភាសាបារាំង: nom d'agent) ។

ផ្សំជាមួយនឹងប្រត្យយ តរ៑ សុទ្ធតែជាបុំលិង្គទាំងអស់ៈ ធាតុ ទា "ឲ្យ"ៈ ទាតរ៑ អ្នកឲ្យ; ករ៑ "ធ្វើ"ៈ កត៌រ៑ "អ្នកធ្វើ; នី "នាំ"ៈ នេតរ៑ "អ្នកនាំ" គមិ "ទៅ"ៈ គន្តរ៑ "អ្នកទៅ, អ្នកដើរ"; វចិ "ពោល"ៈ វក្តរ៑ "អ្នកពោល, អ្នកនិយាយ"; បើជាស្ត្រីលិង្គ ត្រូវចុះឦប្រត្យយ ធ្វើជា ទាត្រី, ស្រីអ្នកឲ្យ; កត្រី, ស្រីអ្នកធ្វើ; នេត្រី, ស្រីអ្នកនាំ; គន្ត្រី, ស្រីអ្នកដើរ; វក្ត្រី ស្រីអ្នកពោល ។

២. ពន្ធុ-នាមសព្ទ(១) ជា អរ៑-ការាន្ត ឬជា តរ៑-ការាន្ត មានជាបុំលិង្គខ្លះ, ជាស្ត្រីលិង្គខ្លះ, តែក្នុងពួកសព្ទនេះ ត្រូវបញ្ចូលសព្ទ នរ៑, បុំ. "ប្រុស" មកជាមួយផង ។

ក). បុំលិង្គៈ បិតរ៑, "បិតា"; ភាតរ៑, "បងប្អូនប្រុស"; ទេវរ៑, "បងប្អូនថ្លៃប្រុស"; នប្តរ៑, "ចៅប្រុស" ។

ខ). ស្ត្រីលិង្គៈ មាតរ៑, "មាតា", ស្វសរ៑, "បងប្អូនស្រី"; ទុហិតរ៑, "កូនស្រី"; យាតរ៑, "បងប្អូនថ្លៃស្រី" ។

---

១ នាមសព្ទ ពោលចំពោះជនជាផៅពង្ស រាប់តាំងពីមាតាបិតាចុះមក (ភាសាបារាំងៈ nom de parenté) ។

## दातर् ទាតរ៑, បុំ.

| | ឯក. | | ទ្វិ. | | ពហុ. | |
|---|---|---|---|---|---|---|
| ប្រ. | दाता | ទាតា | दातारौ | ទាតារៅ | दातारस् | ទាតារស៑ |
| ទ្វិ. | दातारम् | ទាតារម៑ | " | " | दातॄन् | ទាតៜន៑ |
| ត្ឫ. | दात्रा | ទាត្រា | दातृभ्याम् | ទាតឫភ្យាម៑ | दातृभिस् | ទាតឫភិស៑ |
| ច. | दात्रे | ទាត្រេ | " | " | दातृभ्यस् | ទាតឫភ្យស៑ |
| ប. | दातुर् | ទាតុរ៑ | " | " | " | " |
| ឆ. | " | " | दात्रोस् | ទាត្រោស៑ | दतॄणाम् | ទាតៜណាម៑ |
| ស. | दातरि | ទាតរិ | " | " | दातृषु | ទាតឫឞុ |
| សម្ពោ. | दातर् | ទាតរ៑ | दातारौ | ទាតារៅ | दातारस् | ទាតារស៑ |

## पितर् បិតរ៑, បុំ.

| | ឯក. | | ទ្វិ. | | ពហុ. | |
|---|---|---|---|---|---|---|
| ប្រ. | पिता | បិតា | पितरौ | បិតរៅ | पितरस् | បិតរស៑ |
| ទ្វិ. | पितरम् | បិតរម៑ | " | " | पितॄन् | បិតៜន៑ |
| ត្ឫ. | पित्रा | បិត្រា | पितृभ्याम् | បិតឫភ្យាម៑ | पितृभिस् | បិតឫភិស៑ |
| ច. | पित्रे | បិត្រេ | " | " | पितृभ्यस् | បិតឫភ្យស៑ |
| ប. | पितुर् | បិតុរ៑ | " | " | " | " |

| | ឯក. | | ទ្វិ. | | ពហុ. | |
|---|---|---|---|---|---|---|
| ប. | पितुर् | *បិតុរ៑* | पित्रोस् | *បិត្រោស៑* | पितॄणाम् | *បិត្ឫណាម៑* |
| ស. | पितरि | *បិតរិ* | " | " | पितृषु | *បិត្ឫឞុ* |
| សម្ពោ. | पितर् | *បិតរ៑* | पितरौ | *បិតរៅ* | पितरस् | *បិតរស៑* |

*ការក-នាមសព្ទ ដែលជាបុំលិង្គទាំងអស់ ត្រូវបំបែកដូច ទាតរ៑;-ដែលជាស្ត្រីលិង្គ មាន ទាត្រី ជាដើម ត្រូវបំបែកដូច ទេវី (ម.ល.៦១) ។*

*ឯពន្ធុ-នាមសព្ទ ដែលជាបុំលិង្គ មាន ភ្រាតរ៑, ទេវរ៑, នប្តរ៑ ជាដើម ត្រូវបំបែកដូច បិតរ៑;-ដែលជាស្ត្រីលិង្គ មាន មាតរ៑, ទុហិតរ៑, យាតរ៑ ជាដើម ក៏ត្រូវបំបែកដូច បិតរ៑ ដែរ ប្លែកតែត្រង់ ទ្វិ. ពហុ. ត្រូវធ្វើជា មាត្ឫស៑, ទុហិត្ឫស៑, យាត្ឫស៑ វៀរលែងតែ ស្វសរ៑ ១ នេះចេញ ត្រូវបំបែកដូចការកនាមសព្ទ ទាតរ៑ គ្រប់អន្លើ ប្លែកបន្តិចតែត្រង់ ទ្វិ. ពហុ. ជា ស្វស្ឫស៑ ។*

## *គុណសព្ទ*

## (៧៣) បែបយ៉ាងនិងវិធីបំបែកវិភត្តិនៃគុណសព្ទ ជាបុំលិង្គ នបុំសកលិង្គ និងស្ត្រីលិង្គ

*១. គុណសព្ទ ជា អការន្ត, បុំលិង្គនិងនបុំសកលិង្គ មានទ្រង់*

ដូចគ្នា បើជាស្ត្រីលិង្គ មានទ្រង់ផ្សេងពីគ្នា គឺជា អាការន្ត ឬ ឦការន្ត (ឥតមានច្បាប់ឲ្យទៀងទាត់ឡើយ)

កណ្ហ, "ខ្មៅ" បុំលិង្គ ត្រូវបំបែកដូច ទេវ; នបុំសកលិង្គ-ដូច ចិត្ត (ម. ល. ៥៩); ស្ត្រីលិង្គ: កណ្ហា ត្រូវបំបែកដូច កថា (ម. ល. ៦០)

បាប, "លាមក, អាក្រក់" បុំលិង្គនឹងនបុំសកលិង្គ ត្រូវបំបែកដូច ទេវ នឹង ចិត្ត; ស្ត្រីលិង្គ: បាបា ឬ បាបី ត្រូវបំបែកដូច កថា ឬ ទេវី ។

២. គុណសព្ទ ជា ឥ-នឹង ឧ ការន្ត ដូចគ្នានឹងនាមសព្ទ ជា ឥ-នឹង ឧ-ការន្ត ដែលជាបុំលិង្គ នឹង នបុំសកលិង្គដែរ:

សុចិ, "ស្អាត" បើបុំ. ត្រូវបំបែកដូច កវិ; បើនបុំ.-ដូច វារិ; បើស្ត្រី. ដូច មតិ (ម. ល. ៦២)

តនុ, "ស្តើង" បើបុំ. ត្រូវបំបែកដូច គរុ; បើនបុំ. ដូច មធុ; បើស្ត្រី. ដូច ធេនុ (ម. ល. ៦២) ។ ឯ តនុ, នបុំ. ក្តីរមែងបំ-បែកគុណសព្ទនេះ ត្រូវបំបែកដូច នាមសព្ទ ជាឧការន្តបុំលិង្គដូច្នេះ: ប. ឯក. តនុនេ, ឬ តន្វេ; ប. ឆ. ឯក. តនុនស្ស ឬ តនោស្ស ។ល។

គុណសព្ទ ជា ឧការន្ត ណាមួយ ដែលមានព្យញ្ជនតែមួយគួ ទៅពីខាងលើស្រៈ ។ គុណសព្ទនោះ អាចធ្វើជាស្ត្រីលិង្គ ដោយចុះប្រត្យយ ឦ ភ្ជាប់មកក្នុងទីបំផុតនៃសព្ទ ។ ឧ. តនុ, "ស្តើង" + ី > តន្វី; គុរុ, "ធ្ងន់" + ី > គុរ្វី; បុថុ "ទូលាយ" + ី > បុថ្វី; លឃុ, "ស្រាល" + ី > លឃ្វី ។ ល ។ ត្រូវបំបែកដូច ទេវី ។

៣ គុណសព្ទ ជាព្យញ្ជនការន្ត: ជាគុនាមសព្ទ បទ, "ជើង" ដែលធ្វើជាបទ ពហុព្វីហិសមាស ត្រឡប់ទៅជាគុណសព្ទ ជាត្រៃលិង្គ ទៅបាន ។ ឧ. ទ្វិបទ, បុំ. នបុំ. ស្ត្រី. "មានជើងពីរ"; តែឯស្ត្រីលិង្គ គេអាចធ្វើឲ្យមានទ្រង់ដោយឡែកទៀតបាន គឺបន្ថែមប្រត្យយ ឦ ជា ទ្វិបទី (ម. ល. ៦៥ ខាងដើម) ។

គុណសព្ទ ជា អន–ការន្ត, ឥន–ការន្ត ដែលជា បុំ. នបុំ. មានទ្រង់ដូចគ្នា កាលដែលធ្វើទៅជាស្ត្រីលិង្គ ត្រូវបន្ថែមប្រត្យយ ឦ ភ្ជាប់មកទៀត (ម. ល. ៦៦–៦៧):

ពហុមូធន, "មានក្បាលច្រើន", ស្ត្រី.: ពហុមូធ្នី (ស្រី) "មានក្បាលច្រើន";

ទុណ៌ាមិន៑ "មានឈ្មោះអាក្រក់", ស្ត្រ.: ទុណ៌ាម្នី (ស្រី) "មានឈ្មោះអាក្រក់";

ពលិន៑ "មានកំលាំង", ស្ត្រ.: ពលិនី, (ស្រី) "មានកំលាំង";

តបស្វិន៑ "មានតបៈ", ស្ត្រ.: តបស្វិនី, (ស្រី) "មានតបៈ"

គុណសព្ទដែលប្រកបដោយប្រត្យយ អន្ត៑, នបុំ. ជា អត៑, ស្ត្រ. ជា អន្តី ឬ អតី ។ គុណសព្ទដែលប្រកបដោយប្រត្យយ វន្ត៑, មន្ត៑, នបុំ. ជា វត៑, មត៑, ស្ត្រ. ជា វតី, មតី (ម.ល. ៦៨):

ភវន្ត៑, បុំ. "កាលនាំទៅ"; ភវត៑, នបុំ. ភវន្តី, ស្ត្រ.

ពិភ្រត៑, បុំ. "កាលនាំទៅ"; ពិភ្រត៑, នបុំ. ពិភ្រតី, ស្ត្រ.

ភគវន្ត៑, បុំ. "មានជោគ, មានភាគ"; ភគវត៑, នបុំ. ភគវតី, ស្ត្រ.

មហន្ត៑, បុំ. "ធំ"; មហត៑, នបុំ. មហតី, ស្ត្រ.

គុណសព្ទទាំងឡាយ ជា អស៑-, ឥស៑-, ឧស៑-, យស៑-, វស៑-គាពន្តមិនបាច់នាំយកមកពោលក្នុងទីនេះទៀតទេ ព្រោះបានពោលដោយសង្ខេបខ្លះហើយត្រង់លេខ ៦៩-៧០-៧១ ខាងដើម ។

## (៧៤) លំដាប់ថ្នាក់នៃគុណសព្ទ

សព្ទដែលសំដែងអំពីលក្ខណៈរបស់នាមសព្ទ ឲ្យដឹងថាល្អ, អាក្រក់, ខ្មៅ, ស ជាដើម ហៅថាគុណសព្ទៗនេះ បើចែកតាមលំដាប់ថ្នាក់ ខ្ពស់ទាប ជាងគ្នា ឬ លើស ឬ អន់ថយ ជាងគ្នា មាន ៣ យ៉ាង គឺ:

១. ប្រកតិ — គុណសព្ទ គឺសព្ទដែលតាំងនៅតាមទំនងភាព របស់ខ្លួន ឥតមានប្រកបដោយប្រត្យយណាមួយ ដែលអាចធ្វើសេចក្ដីឲ្យប្លែកពីប្រកតីឡើយ ឧ. កណ្ហ, "ខ្មៅ"; ស្វេត, "ស": ពលវន្ត, "មានកំលាំង", មហន្ត, "ធំ" ជាដើម ។

២. វិសេស — គុណសព្ទ គឺសព្ទដែលប្រកបដោយប្រត្យយ តរ, យស ឬ ឦយស (បើជាស្ត្រីលិង្គ: តរា, យសី, ឬ ឦយសី) ជាប្រត្យយអាចធ្វើសេចក្ដីឲ្យប្លែកពីប្រកតី ពីធម្មតា គឺជាធ្វើឲ្យល្អប្លែកជាងប្រកតី ឬ អាក្រក់ប្លែកជាងប្រកតី មិនមែនឲ្យដល់ថ្នាក់ល្អបំផុត, អាក្រក់បំផុត នោះទេ. ឧ កណ្ហ-តរ, ខ្មៅវិសេស, ខ្មៅប្លែក, ខ្មៅជាង; ស្វេត-តរ, សប្លែក, សជាង; ពលវន្តរ, មានកំលាំងប្លែក, មានកំលាំងជាង; មហន្តរ, ធំប្លែក, ធំជាង; មហិយស ធំប្លែក, ធំជាង ។ល។

៣— **អតិវិសេស—គុណសព្ទ** គឺសព្ទដែលប្រកបដោយប្រត្យយ តម, ឥដ្ឋ ឬ ឥស្សិក (បើជាស្ត្រីលិង្គ: តមា, ឥដ្ឋា ឬ ឥស្សិកា) ជាប្រត្យយអាចធ្វើសេចក្តីឲ្យប្លែកបំផុត ប្លែកណាស់ពីប្រក្រតី ពីធម្មតា គឺជាធ្វើឲ្យល្អបំផុត អាក្រក់បំផុត ខ្ពស់បំផុត ទាបបំផុត.

ឧ. កណ្ហ-តម, ខ្មៅបំផុត, ខ្មៅណាស់; ពលវន្តតម, មានកំលាំងខ្លាំងបំផុត, ខ្លាំងណាស់; មហិដ្ឋ, ធំណាស់, ធំបំផុត[១] ។ល។

## សេចក្តីចំណាំ:

១: ប្រត្យយ តរ របស់វិសេសគុណសព្ទ និង តម របស់អតិវិសេសគុណសព្ទ ទាំង ២ នេះ អាចភ្ជាប់ទៅនឹងគុណសព្ទទាំងអស់បាន ឥតវៀរគុណសព្ទណាមួយឡើយ ដូចជា គរុ, "ធ្ងន់"; លហុ, "ស្រាល", ទីឃ, "វែង", ជាដើម កាលដែលប្រកបដោយប្រត្យយទាំងពីរ ទៅជា គរុតរ, គរុតម; លហុតរ, លហុតម; ទីឃតរ, ទីឃតម ។ មិនមែនតែត្រឹមគុណសព្ទឡើយ ទាំងនាមសព្ទក៏ប្រកបភ្ជាប់ដោយបច្ច័យទាំងពីរនេះ បានដោយច្រើន នរ, "ប្រុស":

---

១. គុណសព្ទទាំង ៣ យ៉ាងនេះ មិនផ្សេងគ្នាអំពីរបៀបគុណសព្ទក្នុងភាសាបាឡីឡើយ ហេតុនោះមិនបានពោលដោយពិស្តារក្នុងទីនេះទេ បើត្រូវការចង់ដឹងដោយពិស្តារ គួរមើលក្នុងកច្ចាយនូបត្ថម្ភកភាគទី ១ ត្រង់លេខ ៣៩-៤០-៤១-៤២ នោះចុះ ។

ទុត្តម "បុរសឧត្តម, បុរសខ្ពង់ខ្ពស់" ជាដើម ។ ជួនកាលប្រត្យយទាំងនេះ អាចភ្ជាប់ទៅនឹងអតិវិសេសគុណសព្ទក៏បានខ្លះ: ស្រេឞ្ឋ–តរ "ប្រសើរជាង"; ស្រេឞ្ឋ–តម, "ប្រសើរបំផុត" ។

២. ប្រត្យយ យស៑ ឬ ឦយស៑ របស់វិសេសគុណសព្ទ ឞ្ឋ ឬ ឥឞ្ឋ របស់អតិវិសេសគុណសព្ទ ទាំង ២ ពួកនេះ ភ្ជាប់ទៅនឹងគុណ-សព្ទបានតែបន្តិចបន្តួច មិនអាចភ្ជាប់សាធារណ៍គ្រប់គុណសព្ទឡើយតែទោះបីបន្តិចបន្តួចក្តី ក៏ជាគុណសព្ទដែលត្រូវប្រើញឹកញាប់ជាង ។ ប្រត្យយទាំងនេះ, ជួនកាលភ្ជាប់ចំពោះទៅនឹងរូបធាតុក៏មាន. ឧ. ធាតុ ស្រី: ស្រេយស៑,-"ប្រសើរប្លែក, ប្រសើរជាង"; ស្រេឞ្ឋ, "ប្រសើរបំផុត" ។ ធាតុ ជ្យា: ជ្យាយស៑, "ធំជាង." (បង គឺបងលើពីរនាក់); ជ្យេឞ្ឋ, "ធំបំផុត (បងបង្អស់, បងបំផុត គឺបងលើគេទាំងអស់) ។

៣. អតិវិសេសគុណសព្ទ មិនមែនសម្រេចដោយសារតែប្រត្យយ តម, ឞ្ឋ. ឬ ឥឞ្ឋ ប៉ុណ្ណោះឡើយ ទោះបីឧបសគ្គជាបុព្វបទដូច អតិ "ក្រៃពេក, កន្លង" នេះ ដែលប្រកបផ្សំពីខាងដើមនៃសព្ទណាមួយ ក៏អាចធ្វើសព្ទនោះឲ្យកើតទៅជា អតិវិសេសគុណសព្ទបាន: អតិ-កាល, "ខ្មៅណាស់"; អតិ-ស្វេត, "សណាស់"; អតិ-រមណីយ, ជាទីគួររីករាយក្រៃពេក ។ល។

# ធម្មទេសនា

របស់

# ព្រះវិន័យធម្ម អ៊ុប វត្តបទុមវតី

## ជាបំរើសម្តេចព្រះមង្គលទេពាចារ្យសង្ឃនាយក

## សំដែងនៅកណ្តាលទីសន្និបាតក្នុងខែត្រស្វាយរៀង

*កាលនៅថ្ងៃ២៨ យូកាំងដល់ ១០ ស៊ិយេក*

ឆ្នាំ ១៩៣៨

# សំនាំធម៌ទេសនានៅខេត្រស្វាយរៀង

កាលនៅថ្ងៃមួយកើតខែអាសាឍឆ្នាំខាលសំរិទ្ធិស័ក ព. ស. ២៤៨១

គឺថ្ងៃ ២៨ ខែយូអាំង ឆ្នាំ ១៩៣៨

បានធ្វើដំណើរចេញទៅពីភ្នំពេញ ក្នុងពេលម៉ោង ៧ ព្រឹក ទៅដល់ស្វាយរៀងម៉ោង ៩ បានជួបនឹងលោកចៅហ្វាយខេត្រ ដែលចាំទទួលនៅមន្ទីរគេហស្ថានរបស់លោកបានបដិសណ្ឋារគួរសម រួចលោកក៏នាំទៅគួរសមនឹងលោករេស៊ីដង់រួមខេត្រ តពីនោះទើបចេញដំណើរទៅកាន់វត្តជម្ពូព្រឹក្សា ជាវត្តមេគណស្រុករំដួល នៅទីនោះមានលោកមន្ត្រីខេត្រ មន្ត្រីឃុំ ភិក្ខុ សាមណេរ នឹងឧបាសក ឧបាសិកាចាំទទួលជាច្រើនខ្នាន់ខ្នាប់ ដោយស្មានទៅប្រហែលជា ១០០០ ប្លាយនាក់ លុះធ្វើភត្តកិច្ចរួចស្រេច លោករេស៊ីដង់រួមខេត្រ បានតាមទៅគួរសមដល់អាត្មាភាពទាំងបីរូបនៅទីនោះទៀត លុះដល់រសៀលម៉ោង ១ បានសន្និ-បាតប្រជុំនៅលើសាលា ឧបាសកឧបាសិកាសមាទានសីលរួចស្រេច អាចារ្យសូត្រព្រហ្ម អារាធនាឲ្យទេសនាទាំងបីរូបតាមលំដាប់គ្នា អាត្មាភាពក៏បានប្រារព្ធផ្ដើមធម៌ទេសនាជាដំបូងថា:

អាត្មាភាពសូមចំរើនពរដល់លោក- អ្នកទាំងឡាយសូមជ្រាប ដ្បិតអាត្មាភាពនឹងសូមដំកបបញ្ជាក់ តាមដំណឹងដែលដឹងពីចាស់បុរាណលោក

បានដំណាលទុកតៗ មកថា កាលដើមឡើយ នគរក្រុងកម្ពុជាធិបតីយើងទាំងមូលនេះមនុស្សជាតិខ្មែរទាំងអស់ ធ្លាប់គប់អានកាន់ព្រះពុទ្ធសាសនាជាយូរយារអង្វែងឆ្នាំណាស់ហើយ លុះដល់រាជការប្រូតិកតូរ៉ាត់ លោកចូលមកជួយទំនុកបម្រុងក្នុងស្រុកយើងទៀតសោត លោកក៏មិនបានកាត់បំបាត់បដិសេធពុទ្ធសាសនាចោលដែរ ចេះតែនាំគ្នាប្រតិបត្តិបានសេចក្តីរុងរឿងឥតវិបរិតដរាបទល់នឹងសព្វថ្ងៃ ទើបតែឥឡូវនេះ បានដំណឹងថា មានស្រុកមួយ តាំងនៅខាងទិសអគ្នេយ៍ តដែននឹងស្រុកកូស័ង-ស៊ីន គឺខេត្តស្វាយរៀងនេះ មានជនជាតិខ្មែរខ្លះ ទាំងគ្រហស្ថនឹងបព្វជិត មានគំនិតវៀចវេរគេបកែទៅកាន់លទ្ធិសាសនាដទៃ ដោយកូម៉ិដោយអន្ទើ ហើយលះបោលពុទ្ធសាសនា ដែលមានគោលចារឹកខ្លឹមសារជារបស់ដើមបង្អស់ ហេតុដូច្នោះ ទើបសម្តេចសង្ឃនាយកទាំងពីរគណៈមួយអន្ទើនឹងលោកចាងហ្វាងសាលាបាលី ព្រមទាំងអស់លោកកុងស៊ីយេសេនាបតី បានបង្គាប់អាត្មាភាពទាំង ៣ រូប ឲ្យមកដើម្បីពន្យល់ផ្លូវពុទ្ធសាសនា ដល់លោក-អ្នកពលគ្នាឲ្យភ្លឺច្បាស់ សេចក្តីដូចម្តេចនឹងមានរៀបរាប់ជាប់តទៅនេះ ៗ

នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស

សូមប្រុងចាំស្តាប់ៗ ធម្មទេសនាពេលនេះនឹងលើកយកបុរាណកា-

សិតមួយម៉ាត់មកសំដែង ដើម្បីបញ្ជាក់សេចក្តី ក្នុងឱកាសបើកទីប្រជុំថ្មីនេះ ពាក្យពេចន៍កាសិតចាស់លោកប្រឌិតទុកមកជាយូរលង់ សឹងមានក្នុងសាស្ត្រគេកាលថា :

"កូនអើយកេរ្តិ៍មេបា ឲ្យរក្សាគន់គិតគ្រង ថែទាំចាំរំរង ប្រុងប្រយ័ត្ន ប្រយោជន៍យូរ'' ។

# អត្ថាធិប្បាយថា

កេរ្តិ៍មេបានោះ បានដល់ជាតិ ១ សាសនា ១ មហាក្សត្រ ១ ពជ-ការប្រតិកត្តុភ័ត ១ ទាំង ៤ នេះហើយជាកេរ្តិ៍មេបារបស់យើងៗ លោកទាំងឡាយត្រូវនាំគ្នាស្រឡាញ់ជាតិកុំភ្លេចកំណើត ត្រូវមានមានះថាជាតិខ្មែរនេះជាជាតិប្រសើរ ១ ហើយជាព្រះមហានគរ ១ ដំប្រសើរ សឹងមានគោលចារិកដែលជាតឹកតាងស្នាដៃខ្មែរ នៅនគរវត្តដ៏ស្កប់ស្កែងអស្ចារ្យ ឲ្យទាំងលោកស្រាប់ ហើយកាលដំនាន់ក្រុងនគរវត្តនោះមានអាណាខេត្ត ខាងលិចដល់ក្រុងបាងកក ខាងកើតដល់ក្រុងចម្ប៉ា ខាងជើងទល់នឹងស្រុកចិន ខាងត្បូងទល់នឹងទឹកសមុទ្រ, ឃើញថាធំទូលាយណាស់ ឥឡូវនេះរួញតែជិតមកតូចទាំងម៉្លេះ មិនមកអំពីអ្វី មកតែអំពីយើងទាំងអស់គ្នាមិនបានស្រឡាញ់ជាតិ ដោយស្មោះត្រង់ មិនបានសិក្សាបំណេះវិជ្ជាឲ្យចេះដឹង ប្រឹងតែដេកធ្មេចភ្នែកល្ងង់ បានជាស្រុកលិចលង់ផុងនៅ

លើកណ្ដាប់ដៃរបស់គេអស់ សមដូចជាពាក្យបុរាណថា "គង់យឺតដោយសារគក់ ស្រុកយឺតដោយសារខ្លៅ" សព្វសព្វថ្ងៃនេះ... 

ហើយចេះឯង គោងអាស្រ័យការប្រឹងប្រែងស្វែងរករៀន ទើបបានចេះ ទាំងទ្រព្យសម្បត្តិដែលនឹងមានសម្បូណ៌សោត ក៏មិនមែនមានដោយសារតែដេកលេងផ្សេងព្រៃងក់សនា ឬទេវតាណាជញ្ជូនយកមកឲ្យដែរ គោងអាស្រ័យការប្រឹងរកទើបមានបាន សមដូចពាក្យបុរាណថា "ចេះពីរៀនមានពីរក"; សត្វកជសីហ៍បើដេកនៅតែស្ងៀម ហាមាត់ចង្រ្កង ធ្វើម្ដេចសត្វម្រឹគនឹងរត់ចូលមាត់ឲ្យស៊ីដោយងាយ ?; អ្នកណាតែខ្ជិលច្រអូស មិនរៀនមិនសូត្រសោះ អ្នកនោះរកប្រើនបានតិច គោង អាស្រ័យកំឡាំងកាយយកទៅប៉ះ មិនប្លែកអីនឹងសត្វគោក្របី ដែលជាសត្វពលិព័ទ្ធនោះឡើយ ។

ម្យ៉ាងទៀត សុំលោកមើលតែសត្វដំរី ដែលជាសត្វធំ ឥតសត្វអ្វីជាគូប្រៀបផ្ទឹមឲ្យត្រឹមស្មើបាន ទាំងកំឡាំងប្រាណក៏សោត ក៏ខ្លាំងក្លាជាងមនុស្សជាច្រើនភាគ តែអាស្រ័យជាសត្វកំឡៅ ក៏ត្រឡប់ទៅជាចាញ់ប្រៀបមនុស្សយ៉ាងងាយតែម្ដង គោងមនុស្សចាប់យកមកជិះជាពាហនទៅវិញ នេះយ៉ាងណាមិញ មនុស្សដែលល្ងង់ខ្លៅក៏គោងចាញ់ប្រៀប

អ្នកដែលមានប្រាជ្ញា មានវិជ្ជាក៏ដូច្នោះដែរ, កាលបើបានឮពាក្យមនុស្ស ដទៃ ដែលបញ្ចោតឲ្យជឿអ្វីក៏ចេះតែជឿ ៗ ទៅដោយងាយ ៗ សូម្បី គេនិយាយថា "បើអ្នកណាមិនជឿនឹងស្លាប់ អ្នកណាជឿនឹងរួចពី សេចក្ដីស្លាប់" យ៉ាងនេះក៏ចេះតែជឿទៅ មិនពិចារណាត្រូវខុស បាប បុណ្យ គុណទោស ជាមុនសោះ មនុស្សយើងអ្នកណាកើតមក ហើយមិនស្លាប់នោះគ្មាន បើទុកណាជាជឿព្រះយេស៊ូ ព្រះឥស្សូរ ព្រះនារាយណ៍ ឬជឿព្រះពុទ្ធសាសនា ក៏ត្រូវការតែទទួលសេចក្ដី ស្លាប់រៀងខ្លួន ខានមិនបាន សមដូចព្រះពុទ្ធដីកាដែលទូន្មានទុកមកថា "សព្វេ សត្តា មរិស្សន្តិ មរណន្តំ ហិ ជីវិតំ" សត្វទាំងឡាយ សុទ្ធសឹងតែ ស្លាប់ឥតស្រណោះ ជីវិតសត្វទាំងអស់ មានស្លាប់ជាទីបំផុត" បើទុកជា ទំប្រឹងរត់បោលចូលទៅជឿសាសនាឯណា ក៏ត្រូវការតែស្លាប់មិនខាន ៗ

ក៏ការដែលចេះតែជឿ ៗ ទៅ មិនបានពិចារណាឲ្យគួរការជាមុនសិន ដូចយ៉ាងគេនិយាយថា "សត្វចៀបកប្បាសពាំក្របី ទៅទំដើមក្របៅ" ក៏ជឿដែរ ឬឮថា "ទន្សាយដុះស្នែង, ត្រដេវរិចទំពុងឈើ" ក៏ចេះតែល្ងើ ជឿទៅដែរ ដែលចេះតែជឿរបស់មិនពិតដូច្នេះ ក៏បណ្ដាលមកតែពី សេចក្ដីល្ងង់ខ្លៅ ជាហេតុ ទើបគេបញ្ចោតឲ្យជឿ ហើយគេគន់ប្រើឲ្យធ្វើ ការនឿយហត់ លំបាកលំបិនយ៉ាងណា ក៏ចេះតែធ្វើបាន ៗ

ក៏លោក- អ្នកទាំងឡាយ សុទ្ធសឹងជាអ្នកស្រឡាញ់សេចក្ដីសុខស្រណុកចិត្តកើតមកមួយជាតិ ស្អប់ខ្ពើមឆ្អើមទុក្ខទាំងអស់គ្នា ដូច្នេះត្រូវតែខំប្រឹងប្រែងស្វែងរៀនវិជ្ជា ទុកជាប្រទីបសម្រាប់ត្រាចលបំភ្លឺផ្លូវចំរើនផ្លូវវិនាស ផ្លូវស្រណុកលំបាកទុកជាក់ក្នុងខ្លួនឲ្យមួនមាំចុះ ព្រោះមានពុទ្ធភាសិតថា "នត្ថិ វិជ្ជា សមំ ធនំ" សព្វធនធានទាំងអស់ មិនថ្លៃថ្លាស្មើនឹងវិជ្ជា វិជ្ជាជាទ្រព្យកាត់ថ្លៃមិនបាន បើមានវិជ្ជាក្នុងសន្ដានហើយទ្រព្យដទៃ ៗ នឹងហូរចូលមកដោយងាយ ៗ

ក៏សព្វវិជ្ជាទាំងអស់ក្នុងលោកនេះ ច្រើនបែបច្រើនក្បួន នឹងត្រាចំនួនឲ្យសព្វគ្រប់មិនបាន សូម្បីមានព្យាយាមរៀនតាំងពីក្មេងដល់ចាស់ស្លាប់ ក៏មិនចេះចប់សព្វមុខផង តែសរុបសេចក្ដីឲ្យខ្លីទៅថា វិជ្ជាឯណាដែលឆ្ពោយប្រយោជន៍ឲ្យប្រាសចាកទោស ក៏គួរតែរៀនវិជ្ជានោះទៅចុះ ពីព្រោះវិជ្ជាខ្លះ យ៉ាងវិជ្ជាមន្តសណ្ដំ ស្នាំបំពុល លួចប្លន់ជាដើម វិជ្ជាទាំងនោះ ជារបស់នាំវិនាសមកឲ្យ ឯវិជ្ជាចំពួកខ្លះ យ៉ាងវិជ្ជាជួញប្រែ ធ្វើស្រែចំការ តាមផ្លូវសម្មាអាជីវៈ ហើយបានជាចៅកែសេដ្ឋី ឬធ្វើនាហ្មឺនមុខមន្ត្រីជាដើម វិជ្ជាទាំងនោះ នឹងនាំចំរើនមកឲ្យ; ដូច្នេះ គួរតែជ្រើសរើសរៀនវិជ្ជាណាដែលល្អ ៗ កុំរៀនវិជ្ជាអាក្រក់ឲ្យសោះ ព្រោះព្រះសម្ពុទ្ធទ្រង់ត្រាស់ទុកក្នុងបកកវសូត្រថា "សុវិជ្ជោ ភវំ ហោតិ

ធុរិដ្ឋាដោ បរាភវោ" អ្នកចេះវិជ្ជាល្អ រមែងចំរើន, អ្នកចេះវិជ្ជាអាក្រក់ រមែងវិនាស ដូច្នេះ ។

ហេតុដូច្នោះ ត្រូវខំរកស៊ី ប្តូររៀនសូត្រទន្ទេញ កុំបណ្តោយឲ្យខ្ជិលចូលពេញខ្លួនពេក តែខ្ជិលច្រអូសធ្វេសប្រហែសហើយ សេចក្តីចេះដឹងនឹងធនធាន ក៏វិនាសបាត់បង់ទៅមិនខាន សមនឹងពាក្យបុរាណថា "ប្រហែសបាត់ប្រយ័ត្នគង់" យើងនាំគ្នាធ្វេសប្រហែស មិនស្រឡាញ់ទំនុកបម្រុងជាតិ ចេះតែរេតចិត្ត បានជាចំណេះវិជ្ជាសាបសូន្យបាត់ទៅ យ៉ាងចំណេះឆ្លាក់ថ្មនៅនគរវត្តជាដើម ក៏សុទ្ធសឹងជាស្នាដៃខ្មែរ តែវិជ្ជាទាំងនោះវិញរលីហើយ ជាតិក៏ចេះតែវិញដោយលំដាប់គ្នា បើជាតិវិញហើយនឹងថែទាំសាសនាដែលជាគោលដើមរបស់ជាតិដូចម្តេចបាន? ក៏រមែងជ្រួសកាន់ប្រឡៃទៅជឿសាសនាដទៃទៅវិញ មកតែពីសេចក្តីល្ងង់ ល្ងង់មកពីមិនរៀន មិនរៀនមកពីខ្ជិល តែខ្ជិលហើយគ្មានបានការអ្វីទាំងអស់ សមគ្នានឹងភាសិតថា :

"អលសស្ស កុតោ សិប្បំ អសិប្បស្ស កុតោ ធនំ" ជាដើមថា តែខ្ជិលហើយគ្មានចំណេះ បើមិនចេះមុខជាគ្មានទ្រព្យ ៗ គ្មានមិត្ត ៗ ឥតសុខ ៗ គ្មានបុណ្យ ៗ គ្មានរកផ្លូវសួគ៌និព្វានឃើញទេ តែគ្មានផ្លូវសួគ៌និព្វាន ត្រូវសន្និដ្ឋានថា "នុះមិនមែនជាពាក្យពុទ្ធសាសនា ដែលជាតិខ្មែរកាប់អានថាជារបស់ឯកក្នុងលោក នោះឡើយ" ។

ឯព្រះមហាក្សត្រ នឹងរាជការប្រតិកក្បត់ ដែលចាត់ថាជាកេរ្តិ៍ ឬជាមេបានោះ ព្រោះថាលោកជាទីពឹងពាក់ពំនាក់ផ្អែក លោកពទុបក្រសោបគ្រប់គ្រងព្រះនគរ នឹងអាណាប្រជានុរាស្ត្រ បើគ្មានមហាក្សត្រ មនុស្សគ្មានសុខ ដូចភូមិស្រុកដែលគ្មានរបង ឬផ្ទះ ១ ខ្នងដែលគ្មានជញ្ជាំង ជាទីនាំឲ្យមានឱកាសដល់ខ្មាំងសត្រូវមើលងាយ បៀតបៀនបានជានិច្ច ។

មិនតែប៉ុណ្ណោះ យ៉ាងរាជការ នឹងព្រះករុណាជាម្ចាស់ជីវិតសព្វថ្ងៃ លោកជាសាសនូបត្ថម្ភ ទំនុកបម្រុងសាសនា នឹងយើងកល់គ្នាឲ្យបានសុខផង បណ្តុះឲ្យចំរើនលូតលាស់ដោយវិជ្ជាផង ទាំងផ្លូវលោក នឹងផ្លូវធម៌ យ៉ាងដូចជាតាំងសាលាបាឡីប្រែព្រះត្រៃបិដក តាំងសាលាឲ្យកុមាររៀនសូត្រសព្វខេត្តជម្រុំជនបទ វត្តអារាម នឹងបង្កើតរោងរោគាភិបាលរក្សារោគគ្រប់យ៉ាង ព្រមទាំងតាំងទីការពារភ័យអន្តរាយផ្សេងៗ ដើម្បីពង្រីកជាតិខ្មែរឲ្យធំទូលាយឡើងវិញ ជាដើម ដូច្នេះ ត្រូវតែតាំងចិត្តគិតថានឹងជួយ ដោយថ្វាយសួយសាអាកររាល់ៗឆ្នាំ ចំពោះលោក កុំគេចវេះវៀសខ្លួនឲ្យសោះ ទើបឈ្មោះថាជាអ្នករក្សាកេរ្តិ៍ ឬរក្សាមេបារបស់យើង ដោយសេចក្តីកតញ្ញូស្មោះត្រង់មែន ដូចបានអធិប្បាយមកនេះ ។

ហេតុនោះ នៅអវសានវចនៈទីបំផុតនេះ សូមដាស់តឿនក្រើនរំឭក

លោក-អ្នកទាំងអស់ តោងថែទាំរក្សាទុកកេរ្តិ៍មេបា កុំឲ្យរាត់រាយ គឺត្រូវស្រឡាញ់ជាតិ សាសនា-ព្រះមហាក្សត្រនិងរាជការប្រតិកតូរ៉ាត៍ បើទុកណាជាមានគេមកប្រហារដល់ជីវិត ក៏មិនត្រូវគិតគេចកែប្រែទៅកាន់លទ្ធិសាសនាដទៃ វិស័យផ្តាស ហើយប្រាសយ្ឃាតរាំងចិត្តក្បត់គិតដល់ជាតិនិងសាសនារបស់ខ្លួននោះឡើយ បើអ្នកឯណាក្បត់កេរ្តិ៍ដំណែលដែលដីដូនជីតា មាតាបិតារបស់ខ្លួនចែកឲ្យហើយ អ្នកនោះ ទុកជាជាមនុស្សអកតញ្ញូ ក្បត់ជាតិមិនស្គាល់កំណើតរបស់ខ្លួន ហាក់ដូចជាទំលាក់ចោលកេរ្តិ៍មរដក មានដីស្រែចំការដ៏មានដីជាតិជាដើម ដែលលោករំលែកចែកទុកឲ្យ បើលោក-អ្នកឯណាជាអ្នកស្រឡាញ់សាសនារបស់ខ្លួន និងស្រឡាញ់ជាតិមិនរវេតចិត្តចូលកាន់សាសនាដទៃ លោក-អ្នកនោះទុកជាជាអ្នកបានរក្សាកេរ្តិ៍ដំណែល ដែលម្តាយឪពុកចែកទុកឲ្យផង ឈ្មោះថាជាអ្នកបានធ្វើតាមពាក្យបណ្តាំរបស់លោកផង សមតាមពាក្យបណ្តាំដែលបានប្រឌិតប្រារព្ធទុកខាងដើមថា “កូនអើយកេរ្តិ៍មេបា ចូររក្សាគន់គិតត្រង-ថែទាំចាំរះរង ប្រុងប្រយ័ត្នប្រយោជន៍យូរ” ដូចពណ៌នាមកជាសុទ្ធិត្តកថា “សុភេទ្ធបេន សម្មតា” សន្មតថាចប់ធម៌ទេសនា សមគួរតាមពេលវេលា ឯវំ ៗ

ព្រះវិន័យធម្ម

អ៊ុប

ហិតោបទេស ភាគទី ១

«ការបង់មិត្រ»

ឧកញ៉ាទេពពិទូរ ក្រសេម គន្ធរបនបណ្ឌិត

ប្រែនិងរៀបរៀង (គ)

លុះព្រឹកព្រានឡើង ក្អែកឃើញក្សេត្របតីកាន់ឈើដើរត្រង់មក កាន់ទីនោះ ទើបប្រាប់ (ឧបាយឲ្យប្រើស) ថា "សំឡាញ់! អ្នកចូរដេកស្មៀម ធ្វើហាក់ដូចជាស្លាប់ បំប៉ោងពោះឲ្យឡើងត្រប៉ស សណ្ដូកជើងរឹងត្អឹង; បើខ្ញុំឲ្យសញ្ញា "ក្រែក" កាលណា ចូរក្រោកឡើងរត់ទៅកាលនោះ មួយរំពេច". ប្រើសក៏ធ្វើតាមបណ្ដាំក្អែក ។ លុះម្ចាស់ស្រែដើរមកឃើញក៏បើកភ្នែកគ្រលួងសំឡឹងទៅប្រើស ដោយចិត្តត្រេកអរ កាលឃើញប្រើសមានអាការដូចពោលហើយក៏បញ្ចេញវាចាថា "អេ៎! ប្រើសនេះស្លាប់ឯង", ហើយក្សេត្របតីក៏ដោះជង់ចេញ លុះក្សេត្របតីឃ្លាតចេញបន្តិច ប្រើសបានឮសំឡេងក្អែក ក៏ម្ហូមក្រោករត់ទៅ ក្សេត្របតីក្រឡេកទៅឃើញដូច្នោះក៏ពោលកំណាត់ឈើទៅ (ដោយពេញទំហឹង) ក៏ទទួលទៅត្រូវចចកស្លាប់ លោកទើបថា:

៨៥ បុណ្យបាបដែលធ្វើទុកយ៉ាងខ្លាំងក្នុងលោកនេះទីងស្នង
ផល (យ៉ាងយូរ) ត្រឹម ៣ ឆ្នាំចុះមកត្រឹម ៣ ខែ ឬក៏ ៣ បក្ខ
រហ័សមកទៀតត្រឹម ៣ ថ្ងៃ ។

ព្រោះហេតុនោះៗ យើង (ហិរញ្ញក:) ទើបថា "ការចងស្ពានមេត្រីក្នុងរវាងម្ខាងជាអាហារ ម្ខាងទៀតជាអ្នកស៊ី រមែងនាំមកនូវសេចក្តីវិបត្តិ ដោយពិត (៨៦) ។

ក្អែកតបថា —

៨៦ ម្នាលអ្នកដ៏មិនឲ្យទុក្ខ (ដល់អ្នកណា) ដូចចិត្តត្រី:, ទោះខ្ញុំត្រូវការអ្នកជាអាហារ ក៏មិនល្មមនឹងពោះខ្ញុំ; កាលអ្នកមានជីវិតរស់នៅ ខ្ញុំក៏មានជីវិតរស់នៅផង ។

៨៧ ការដែលនឹងទុកចិត្តគ្នា សូម្បីក្នុងពពួកតិរច្ឆានក៏អាចឃើញបាន កាលសេចក្ដីប្រព្រឹត្តិនៃអ្នកទាំងសងខាងបរិសុទ្ធនឹងជាប់ខាត; ដោយអំណាចនិស្ស័យដ៏ប្រសើររបស់សាធុជនគុណសម្បត្តិដ៏មាននៅជាសភាពហើយនឹងបានប្រែប្រួលទៅក៏ទេ ។

៨៨ ទឹកចិត្តរបស់សប្បុរស ទោះបីខឹងក្រោធ ក៏មិនបានប្រែផ្លាស់ឲ្យវិកល, គប់ភ្លើងនឹងធ្វើទឹកក្នុងទន្លេឲ្យក្ដៅមិនបាន ។

ហិរណ្យក: (បានស្ដាប់ដូច្នោះហើយ) ថា អ្នកឯងជាសត្វមាននិស្ស័យត្រឡប់ត្រឡិន; យើងមិនគួរចងមិត្តភាពនឹងអ្នកមាននិស្ស័យត្រឡប់ត្រឡិនជាដាច់ខាត ព្រោះលោកថា:

៨៩ ឆ្មា ១ ក្របី ១ ចៀម ១ ក្អែក ១ មនុស្សអាក្រក់ ១ អំបាលនោះដែលនឹងបានល្អព្រោះគេទុកចិត្ត, តែមិនគួរនឹងប្រគល់សេចក្ដីទុកចិត្តក្នុងពួកអំបាលនេះ ។

ប្រការ១ទៀត ខ្លួនអ្នកក៏នៅក្នុងពួកសត្វរបស់យើង, លោកពោលទុកថា:

៩០ ឈ្មោះថាសត្វ មិនគួរអ្នកណានឹងចង់ជាមិត្តផង ដោយហោចទៅ តែសេចក្ដីស្និទ្ធស្នាល ក៏កុំអាលឲ្យមាន, ទឹកដែលកំពុងពុះខ្ជោល គេអាចធ្វើឲ្យឈប់បាន ។

៩១ ឯទុរជន ទោះជាមានចំណេះវិជ្ជាជាអំពរណ៍ ក៏ត្រូវតែចៀសឲ្យផុត; អសិរពិសទោះប្រដាប់ដោយពេជ្រ នឹងទុកចិត្តបានឬថា វានឹងមិនធ្វើអន្តរាយ? ។

៩២ របស់ដែលមិនប្រុងនឹងកើត ក៏មិនអាចកើតបាន, របស់ដែលនឹងកើតបាន ទើបអាចកើតបាន, រទេះនឹងឲ្យទៅក្នុងទឹកក៏មិនបាន ទូកនឹងឲ្យទៅលើគោកក៏មិនបាន ។

៩៣ អ្នកណាប្រមាទជឿកំលាំងទ្រព្យថាមានច្រើន, ទុកចិត្តសត្វប្តូរកិរិយាដែលមិនស្លូតត្រង់, ជីវិតអ្នកនោះក៏ដុតខែត្រប៉ុណ្ណោះឯង ។

ក្អែក លឃុបតនកៈតបថា " ខ្ញុំធ្លាប់បានស្ដាប់រឿងដូច្នេះមកហើយទាំងអស់ ទោះបីដូច្នោះខ្ញុំមានសេចក្ដីតាំងចិត្តមែនៗ ដែលនឹងចង់ជាមិត្តមួយអន្លើនឹងអ្នក បើមិនបានដូច្នោះ ខ្ញុំនឹងអត់អាហារឲ្យស្លាប់នៅមាត់ទ្វាររបស់អ្នក ។

៩៤ អ្នកអាក្រក់ប្រៀបដូចឆ្នាំងដី បែកងាយ ផ្សាឡើងវិញមិនកើត; តែអ្នកល្អប្រៀបដូចឆ្នាំងស្ពាន់ កម្រនឹងបែក ៗ ហើយងាយនឹងផ្សាឡើងវិញ ។

៩៥ សេចក្តីរួបរួមជាមួយគ្នា ដែលនឹងមានដល់លោហធាតុទាំងពួង ក៏ព្រោះវាមានលក្ខណៈរលាយ (ចូលគ្នាបាន) នឹងមានដល់សត្វចតុប្បាទ, ទ្វេបាទទាំងពួង ក៏ព្រោះរូបលក្ខណៈ នឹងមានដល់ពួកអ្នកល្ងង់ខ្លៅ ក៏ព្រោះសេចក្តីខ្លាច នឹងសេចក្តីលោភ, នឹងមានដល់ពួកសប្បុរស ក៏ព្រោះទស្សនប្រិជា ។

៩៦ មនុស្សល្អរមែងមានអាការបីដូចជាផ្លែដូង អ្នកដទៃក្រៅអំពីនោះ ក៏ប្រហែលនៃផលពទ្រិកា (ផ្លែពុទ្រា[១]) មុខគួរស្រឡាញ់តែខាងក្រៅ កាលយល់ខនេះហើយ ក៏គប្បីប្រាថ្នាសមាគមនឹងមនុស្សល្អ ព្រោះ–

៩៧ សារសៃមេត្រីរបស់សាធុជន ទោះនឹងឈប់ចប់ចុះក្នុងរវាងពាក់កណ្តាល តែគុណសម្បត្តិមិនបានប្រែប្រួល; ទងឈូក ទោះបីកាច់ផ្តាច់ពីគ្នាហើយ ក៏នៅមានសរសៃជាប់នៅ ។

៩៨ សេចក្តីមានចិត្តស្អាតល្អ មានចិត្តសទ្ធា មានចិត្តដាច់

១ សេចក្តីធៀបនេះឃើញប្លែក យើងធ្លាប់ឃើញតែធៀបនឹងផ្លែល្វា ។

មានចិត្តខ្ជាប់ខ្ជួន ក្នុងវេលាសុខនិងទុក្ខ, សេចក្ដីអើពើ, សេចក្ដីមេត្តាករុណា សេចក្ដីស័ត្យ' គុណសម្បត្តិអំបាលនេះ ជាអង្គរបស់មិត្រ ៗ .

ខ្ញុំនឹងរកមិត្រដ៏ប្រកបដោយគុណសម្បត្តិដូច្នេះ អំពីណាបាន ក្រៅអំពីអ្នក ៗ

ហិរណ្យក: ពុំអ្នកពោលដូច្នេះ ទើបចេញអំពីរន្ធ និយាយថា ខ្ញុំត្រជាក់ចិត្តនឹងសំដីរបស់អ្នកហាក់ដូចបានក្រេបទឹកអម្ឫត. សមដូចលោកថា:

៩៩ ទឹកត្រជាក់ដែលត្រជាក់, ពាក់ខ្សែមុក្តា, លាបប្រេងចន្ទន៍ រមែងធ្វើឲ្យបុគ្គលបាត់ទុក្ខ បាត់ក្ដៅក្រហល់ក្រហាយ; (តែទោះបីដូច្នោះ) ក៏មិនមានអំណាចនឹងធ្វើចិត្តរបស់អ្នកទ្រទ្រង់នូវសេចក្ដីបរិសុទ្ធឲ្យរីកពាយស្មើដូចសន្ទនានឹងសប្បុរស អ្នកប្រ-កប ដោយគុណលក្ខណៈដ៏ល្អ ដ៏វិហាន ស្នេហ៍ទន់ទាញឲ្យទៅរកបានឡើយ ៗ

១០០ សាយកាយសេចក្ដីកំបាំង ចិត្តរហ័សមិនត្រិះរិះ, ទ្រគោះអាស្រូវពេះ, ចិត្តត្រឡប់ត្រឡិន, ច្រើនក្រោធ, ឥតពាក្យសត្យ, និងអំពល់ក្នុងរន្ធាល់; ទោសអំបាលនេះ គឺជាសេចក្ដីសាបសូន្យរបស់ការជាមិត្រ ៗ

តាមសេចក្ដីដែលអ្នកសន្មតា តាំងអំពីដើមរហូតមកមិនប្រទះឃើញសេចក្ដីទាស់កន្លងខ្លួនអ្នក សូម្បីបន្តិចបន្តួចឡើយ ព្រោះ-

១០១ សំដីពិរោះ ឬពាក្យសត្យរបស់បុគ្គលទីងពិសោធឲ្យឃើញបាន លុះតែប្រាស្រ័យគ្នា ចំណែកឯក់ចាមិនរឹងរូសឬមិនឡេះឡោះក៏ទីងឃើញស្ដែងកន្លងវេលាដែលបានសង្កេតមើល ៗ

១០២ មេត្រីរបស់អ្នកមានចិត្តមិនបរិសុទ្ធ រមែងប្រព្រឹត្តទៅ ១ យ៉ាង ចំណែកឯក់ចារបស់អ្នកមានចិត្តត្រឡប់ត្រឡិនរមែងប្រព្រឹត្តទៅ ១ យ៉ាងទៀត ៗ

◎ មនុស្សអាក្រក់ ចិត្តគិតទៅ ១ យ៉ាង មាត់និយាយទៅ ១ យ៉ាង កិរិយាដែលប្រព្រឹត្តផ្សេងទៅ ១ យ៉ាងទៀត; ឯសេចក្ដីគិត និងសំដី ទាំងសេចក្ដីប្រព្រឹត្តរបស់មហាត្មន (អ្នកចិត្តជា) រមែងដូចគ្នាទាំងអស់ ៗ

ហេតុនោះក៏ឲ្យប្រព្រឹត្តទៅតាមសេចក្ដីបំណងរបស់អ្នកទៅចុះ ថាហើយហិរញ្ញកៈ ក៏ចងស្ពានមេត្រីជាមិត្រនឹងក្អែក ៗ កាលលៀងលោមគ្នាដោយអាហារ ១ យ៉ាងតាមពិធីហើយ, ស្ដេចកណ្ដុរក៏ត្រឡប់ចូលរន្ធ, ក្អែកក៏ត្រឡប់ទៅទីលំនៅរបស់ខ្លួន ៗ ចាប់ដើមអំពីនោះសត្វទាំងពីរ

បានជាមិត្រស្និទ្ធស្នាលនឹងគ្នា  តែងទៅមករកគ្នាតែងចែកចាយអាហារដល់គ្នាទូវគ្នា នឹងសួរសុខទុក្ខទៅវិញទៅមក រៀងមកអស់កាលដ៏លង់ ។ នាថ្ងៃមួយ ក្អែកប្រឹក្សានឹងហរិណ្យកៈថា "នែសំឡាញ់ ទីនេះមិនជាទីទំនួលសម្រាប់ក្អែក លំបាកដោយអាហារណាស់ ហេតុនោះខ្ញុំចង់លះបង់ទីនេះទៅរកទីដទៃ ១ នោះ" ។

# រឿងព្រេង — បុរសកាស ៣០

និយាយពីរឿងបុរសម្នាក់មាននាមនឹងស្រុកមិនប្រាកដ អាពុកម្តាយស្លាប់អស់ទៅនៅកំព្រាតែម្នាក់ឯង ហើយក្រលំបាកណាស់គ្មានទ្រព្យសម្បត្តិអ្វីទេ មានតែកាស ៣០ ប្រកក្នុងថៅឡើងក្រវាត់ជាប់នៅចង្កេះជានិច្ច បុរសនោះគិតពិចារណាថា អញទៅទីពឹងអ្នកឯណា ទើងបានសេចក្តីសុខ គិតឃើញថា គួរអញទៅនៅជ្រកកោនទឹងលោកក្រឡាហោមចុះ គិតហើយក៏ដើរចេញពីផ្ទះទៅ លុះដល់ក្រាបសំពះតាមសមគួរ លោកក្រឡា-ហោមសួរថា ដីឯងមកពីស្រុកណាមក មានការអី បុរសនោះជំរាបថា ខ្ញុំព្របាទមកពីស្រុកឆ្ងាយ អាពុកម្តាយស្លាប់អស់នៅកំព្រាតែម្នាក់ឯង ខ្ញុំព្របាទមកនេះសូមជ្រកកោននៅបំរើជាកូនក្មួយតទៅ សូមព្រះតេជព្រះគុណមេត្តា លោកនោះសួរថា ដីឯងចេះសរសេរអក្សរល្មមធ្វើជាស្មៀនបានឬទេ ជំរាបថា អក្សរខ្ញុំព្របាទមិនចេះទេ លោកក្រឡាហោមប្រាប់ថា យើងទទួលឲ្យនៅ តែឲ្យដីឯងបោសសម្រាមក្រោមផ្ទះយើងរៀងរាល់ថ្ងៃកុំខាន ។

បុរសនោះក៏នៅបំរើបោសក្រោមផ្ទះរៀងរាល់ថ្ងៃ ដល់ចំនួនបីឆ្នាំ ថ្ងៃមួយនោះបុរសកាស ៣០ ជំរាបសួរមាតាលោកក្រឡាហោមថា លោកយាយ លោកក្រឡាហោមជាកូនកើតឆ្នាំខែថ្ងៃអី លោកក៏មានបុណ្យមាន

ទ្រព្យសម្បត្តិច្រើនម៉្លេះ លោកយាយនោះប្រាប់ឆ្នាំខែថ្ងៃនិងពេលដែលកើតសព្វគ្រប់ បុរសនោះបានស្ដាប់ចាំជាក់ប្រាកដ ក៏ពិចារណាថា គួរអញកត់ឆ្នាំខែថ្ងៃនិងវេលាលោកនេះហើយដាក់ក្នុងថៅឡឹងឲ្យជាប់ គិតហើយ ក៏យកកំណាត់សំពត់សចាស់កត់ឆ្នាំខែថ្ងៃពេលដែលលោកនោះកើតរួចស្រេចហើយដាក់ក្នុងថៅឡឹងមិនឲ្យអ្នកឯណាដឹងឃើញឡើយ ។

ថ្ងៃក្រោយលោកក្រឡាហោមសួរបុរសកាស ៣០ថា ដឹងឯងមកនៅនិងយើងយូរឆ្នាំហើយពុំទាន់បានធ្លើកជការអ្វីនឹងគេ ខ្លួនដឹងឯងតើកើតឆ្នាំខែថ្ងៃអ្វី បុរសនោះជំរាបថា ខ្ញុំប្របាទមិនចាំ តែកាលអាពុកម្ដាយខ្ញុំប្របាទនៅបានឲ្យកំណាត់កត់ទឹងកំណាត់សំពត់សមកខ្ញុំប្របាទ ៗ ក៏ទុកនៅសព្វថ្ងៃ តែមិនដឹងជារឿងអ្វីពីព្រោះខ្ញុំប្របាទមិនចេះអក្សរ លោកក្រឡា-ហោមថា បើដូច្នោះដឹងឯងឲ្យកំណាត់នោះមកអញ បុរសនោះក៏ជូនកំណាត់ទៅលោក ៗ មើលឃើញកើតឆ្នាំខែថ្ងៃពេលដូចលោក ៗ គិតក្នុងចិត្តថា ចៅនេះកើតឆ្នាំខែថ្ងៃដូចអញ គន់មើលទៅរូបពង់ឫកពារក៏សមសួន ចៅនេះនឹងបានធ្វើជានាហ្មឺនធំដូចអញមិនខាន ហើយកាន់កំណាត់នោះចូលទៅក្នុងបង្ហាញខ្សឹបនិយាយប្រាប់ភរិយាថា គេហ៍ អាដែងបុរសម្នាក់ជាកូនក្មួយយើងដែលបោសសម្រាមក្រោមផ្ទះសព្វថ្ងៃនេះវាកើតឆ្នាំខែថ្ងៃដូចអញ មើលទៅឫកពាសាច់ឈាមវាក៏សមសួនផង ទៅមុខវានឹងបានធ្វើជាសេនា-

បតីដូចយើង ហើយលោកនោះប្រឹក្សានឹងប្រពន្ធថា កូនស្រីយើងមួយនេះ គួរឲ្យទៅរកធ្វើជាភរិយាចុះ ខ្លួនរកនឹងបានធ្វើជានាហ្មឺនធំតរៀងយើង ភរិយាក៏យល់ព្រម លោកនោះចេញមកវិញប្រាប់បុរសនោះថា ពីថ្ងៃនេះតទៅឯងឈប់បោសសម្រាមក្រោមផ្ទះចុះ ត្រូវខ្លួនឯងឡើងមកបោសខាងលើផ្ទះវិញ ។

លុះកន្លងមក ១ ខែលោកក្រឡាហោមរៀបរករកហមង្គលការផ្សំផ្គុំកូនស្រីនឹងបុរសកាស ៣០ ជាស្វាមីភរិយារួចស្រេច លោកក្រឡាហោមក៏បង្ហាត់បង្ហាញកូនប្រសាឲ្យធ្វើកផការជាមួយចូលគាល់បំរើស្តេចរៀងរាល់ថ្ងៃដរាបមក ។

លុះកន្លងមកបីខែ មានគេដំណឹងថា កូនប្រសាលោកមិនមែនកើតឆ្នាំខែថ្ងៃដូចលោកទេ រឿងនេះគឺបុរសនោះសួរលោកយាយជាមាតាអំពីឆ្នាំខែថ្ងៃលោក លោកយាយក៏ប្រាប់សព្វគ្រប់ កូនប្រសាលោកបានស្តាប់ក៏សរសេរចុះកន្ទក់កំណាត់សំពត់សទុក លុះលោកសួរឆ្នាំខែថ្ងៃក៏ជូនកំណាត់នោះមក លោកមើលឃើញថា កើតឆ្នាំខែថ្ងៃដូចលោក ៗ ក៏ឲ្យកូនក្រមុំធ្វើជាភរិយា រឿងនេះមិនមែនដូច្នោះទេ គឺក្លែងសរសេរទុកប្រាកដ លោកក្រឡាហោមក៏ជឿជាក់ឥតសង្ស័យ ហើយមានចិត្តខោមនស្សជាខ្លាំង គិតថាមិនគួរនឹងទាញប្រាជ្ញាអាមនុស្សកំសត់នេះ ក៏គិតរកឧបាយនឹងផ្តាច់កូនបណ្តេញចោលចេញ ។

ក្រោយនោះមានទ័ពចោរបះបោរនៅខែត្រក្រៅច្រើន ស្ដេចផ្ដាច ទ្រង់ត្រាស់ប្រើលោកក្រឡាហោមឲ្យនាំសេនាទាហានទៅបង្ក្រាបទ័ពចោរ មិនរាបទាប ក៏លើកទ័ពត្រឡប់មកក្រាបបង្គំទូលតាមរឿងវិញ ស្ដេច ត្រាស់ប្រើឲ្យនាំសេនាទាហានទៅបង្ក្រាបទ័ពចោរទៀត ក៏មិនរាបទាប ហើយលើកទ័ពត្រឡប់មកយកសេចក្ដីក្រាបបង្គំទូលថា ទូលព្រះបង្គំជា ខ្ញុំលើកទ័ពទៅបង្ក្រាបទ័ពចោរពីរដងមិនឈ្នះវា ពីព្រោះសេនាទាហាន វាច្រើនហើយពូកែណាស់ផង ។

ទូលព្រះបង្គំជាខ្ញុំនឹងនាំសេនាទាហានទៅទៀតពុំបាន ដ្បិតមានជម្ងឺ កង្វល់ច្រើន សូមទ្រង់ចាត់មន្ត្រីណាមួយដែលមានស្វាហិចស្វាហាប់ឲ្យ នាំសេនាទាហានទៅបង្ក្រាបទ័ពចោរទាំងនោះជាដាច់ តែទូលព្រះបង្គំ ជាខ្ញុំមានកូនប្រសាប្រុសម្នាក់ ជាមនុស្សមានចិត្តទាហានហានក្លាចំណេះ វិជ្ជាកង្វល់ក៏មានច្រើន បើទ្រង់ចាត់វាឲ្យទៅវាហ៊ានទៅមិនខ្លាច ដែល លោកក្រឡាហោមទូលស្ដេចនេះ គឺឧបាយដោយស្អប់កូនប្រសានោះ ណាស់ បើវាលើកទ័ពទៅហើយ ទ័ពចោរទាំងនោះនឹងសំឡាប់មិនខាន ស្ដេចទ្រង់ព្រះសណ្ដាប់ក៏ឲ្យហៅកូនប្រសានោះមក ទ្រង់មានព្រះរាជឱង្ការ ប្រាប់ថា ៖ ខែត្រក្រៅមានទ័ពចោរបះបោរច្រើន ឥឡូវយើងប្រើអ្នក ឯងឲ្យនាំសេនាទាហានទៅបង្ក្រាបទ័ពចោរទាំងនោះហ៊ានទៅឬយ៉ាងណា បើហ៊ានទៅហើយឈ្នះវាផង យើងឲ្យរង្វាន់ ។

បុរសនោះទូលថា ទូលព្រះបង្គំជាខ្ញុំបាទទៅទទួលធ្វើរាជការថ្វាយ ទ្រង់មានព្រះរាជឱង្ការថា បើដូច្នោះអ្នកឯងនាំសេនាទាហានទៅជាឆាប់ ហើយថ្វាយបង្គំលាមកផ្ទះវិញជំរាបលោកក្រឡាហោមជាបិតាក្មេកតាមរឿងគ្រប់ប្រការរួចលើកទ័ពចេញទៅ ទ័ពចោរបានដឹងក៏លើកទ័ពមកទទួលតតាំងច្បាំងគ្នាជាមាំមួន ទ័ពចោរទ្រាំពុំបានក៏បរាជ័យបាក់បបខ្ចប ខ្ចាបរត់ខ្ចាត់ខ្ចាយវិនាសអស់ ហើយលើកទ័ពបង្ក្រាបរាបគ្រប់អន្លើ រួចនាំសេនាទាហានត្រឡប់មកវិញក្រាបបង្គំគាល់ទូលពីរឿងច្បាំងនឹងទ័ពចោរគ្រប់សេចក្តី ស្តេចជ្រាបទ្រង់ព្រះអំណរពន់ប្រមាណ ។

ឯលោកក្រឡាហោមជ្រាបថា កូនប្រសាលើកទ័ពទៅបង្ក្រាបទ័ពចោររាបទាបអស់ហើយមានចិត្តទោមនស្សរឹតតែខ្លាំងឡើង ពីព្រោះគិតថាដែលឲ្យវាទៅបង្ក្រាបទ័ពចោរ ដើម្បីឲ្យពួកចោរសំឡាប់អាដែងនេះ ឥឡូវវាមានជ័យជំនះវិញ រោគលោកក្រឡាហោមក៏រឹងរឹតតែខ្លាំងឡើង ពេទ្យមើលពុំជាក៏មរណភាពទៅ ស្តេចជ្រាបទ្រង់ព្រះចិន្តាថា នឹងឲ្យឈ្មោះណាធ្វើទីក្រឡាហោម ទ្រង់ព្រះចិន្តាឃើញតែបុរសដែលលើកទ័ពទៅវាយទ័ពចោររាបទាបមានគុណបំណាច់នឹងរាជការគួរល្មមឲ្យធ្វើទីក្រឡាហោមបាន ទ្រង់ព្រះចិន្តាដូច្នោះហើយត្រាស់ឲ្យហៅបុរសនោះមកគាល់ ហើយទ្រង់ព្រះមេត្តាប្រោសតាំងឲ្យធ្វើទីក្រឡាហោមជំនួសបិតាក្មេកទៅ ។

រឿងបុរសកាស ៣០ ចប់តែប៉ុណ្ណេះ ។

ឧកញ៉ាប្រាជ្ញាធិបតី - ជាងហ្វាង (យិន) តែង ។

## លទ្ធិទំនៀមខ្មែរ

# សែនខ្មោចមេបាចាស់ទុំ

# ក្នុងវេលាមានជម្ងឺឈឺ ដោយហេតុមានពួកញាតិ

# ទាស់គ្នា

អ្នកមើលរឿងនេះបើឃើញខាស់ខុសត្រង់ណា សុំឡូអធិប្បាយជូនទៅ

ព្រះរាជបណ្ណាល័យ ៗ សូមអំណរគុណជាមុន ។

# ទំនៀមសែនខ្មោចមេបាចាស់ទុំ

## ក្នុងវេលាមានជម្ងឺ ដោយហេតុមានពួកញាតិចាស់ៗ

កាលមានអ្នកណាមួយ ទោះចាស់ក្តី ក្មេងក្តី ឈឺបែបគ្រុំគ្រើយ អ្នកម្ចាស់ជម្ងឺបានព្យាយាមរក្សាដាក់ថ្នាំដូច្នេះ ដូច្នោះទៅហើយមិនត្រូវ គេរមែងរកគ្រូ ឬ ហោរឲ្យគន់គូរមើលឲ្យ បើមើលទៅថា ត្រូវខ្មោចមេបាចាស់ទុំធ្វើ ដោយហេតុមានពួកញាតិចាស់ខែងគ្នា នោះគេក៏រៀបសែនទៅតាមទំនៀម ។

ក៏ខ្មោចដំពួកណា ដែលបានឈ្មោះថា ខ្មោចមេបា ? ។ តាមសេចក្តីយល់របស់ចាស់ទុំដែលធ្លាប់កាប់ការខ្មោចប្រេតទេនេះ លោកអធិប្បាយថា បាននឹងខ្មោចបុព្វបុរសបុព្វស្ត្រី គឺ ខ្មោចជីដូន ជីតា ម្តាយឪពុក ម្តាយធំ អាពុកធំ មីង មា រៀងមកដល់បងប្រុស-ស្រី របស់យើងគ្រប់រូប ឈ្មោះថា ខ្មោចមេបា ។

កាលបានទទួលពាក្យតមកដូច្នេះហើយឲ្យនឹកឆ្ងល់ថា ពួកញាតិសន្តានរបស់យើងចំពួកជេដ្ឋកបុគ្គល (គឺបុគ្គលអ្នកធំ) មានជីដូន ជីតាជាដើម វេលាស្លាប់ទៅហើយ សុទ្ធតែទៅកើតជាខ្មោចនៅចាំថែរក្សាកូនចៅ ទីងនៅចាំធ្វើកូនចៅឲ្យឈឺ ឲ្យស្លាប់ក្នុងវេលាចាស់ចិត្តរបស់ខ្លួនដូច្នោះឬ? មិនបាន ទៅកើតជាទេវតា មនុស្ស ឬ តិរច្ឆានដទៃទៀតទេឬ? ។

សូមគបថា មិនដូច្នោះទេ តាមគតិព្រះពុទ្ធសាសនាសំដែងថា កំណើតរបស់សត្វមិនមានទៀងទាត់ប្រាកដកើតជាអ្វីម្យ៉ាង ៗ ទេ ជួនកាលកើតជានេះ ជួនកាលកើតជានោះ តាមកំលាំងអំពើកុសល និងអកុសលដែលខ្លួនធ្វើទុកមក អ្នកធ្វើល្អ ស្លាប់ហើយរមែងបានទៅកើតជាទេវតា ជាមនុស្ស ៗ អ្នកធ្វើអាក្រក់ ស្លាប់ហើយរមែងទៅកើតក្នុងកំណើតអាក្រក់ គឺនរក ខ្មោចប្រេតអសុរកាយផ្សេង ៗ និងតិរច្ឆាន ។ ក៏ក្នុងវង្សត្រកូលរបស់យើង តាំងពីត្រកូលប្រៀងលានមក គង់ជាមានអ្នកធ្វើអំពើអាក្រក់ ស្លាប់ហើយទៅកើតជាខ្មោចខ្វះមិនខាន កាលកើតជាខ្មោចហើយរមែងមកថែរក្សា និងធ្វើកូនចៅញាតិសន្តានឲ្យឈឺ ឲ្យស្លាប់ ដូចដែលចាស់ទុំពោលមកនោះមែន ដោយហេតុខ្មែរយើងមានទំនៀមទម្លាប់ទឹកនាគេខ្មោចមកកប់ពាន់ដូរបុគ្គលមកហើយ ពួកខ្មោចបានឱកាសដូច្នេះ ក៏ចូលមកសំដែងខ្លួនថាជាខ្មោចមេបាចាស់ទុំរបស់ត្រកូលនោះ ៗ ទៅ ចូរមើលរឿងខ្មោចព្រះវរទឹងដំទាវម៉ៅ មិនមែនជាខ្មោចមេបាខ្មែរយើងគ្រប់ខេត្តគ្រប់ស្រុកនោះទេ តែខ្មែរយើងគ្រប់ស្រុករមែងកប់អានព្រះវរទឹងដំទាវម៉ៅថាជាខ្មោចមេបាឬជាខ្មោចអារក្សរបស់ខ្លួន ៗ នេះជាតួយ៉ាងនៃសេចក្តីកប់អានខ្មោចមេបា ៗ ទំនៀមកប់អានខ្មោចមេបាជាដើមនេះមិនចំពោះមានតែប្រទេសកម្ពុជាទេ ប្រទេសទាំងឡាយដែល

នៅជិតខាងមានប្រទេសលាវជាដើម ក៏មានសេចក្ដីរាប់អានទំនងប្រហែលគ្នានឹងខ្មែរដែរ ។

ខ្មោចមេបានោះ ចំណាំតែធ្វើក្នុងវេលាមានពួកញាតិទាស់ទែងគ្នា ១ យ៉ាង. ក្នុងវេលាដែលមានកំឡោះក្រមុំសហាយស្មន់នឹងគ្នា ១ យ៉ាង ។ អំពីនេះនឹងពណ៌នារឿងពីរបៀបសែនខ្មោចមេបា ក្នុងវេលាមានជម្ងឺឈឺដោយហេតុមានពួកញាតិទាស់គ្នា ។ កាលគេដឹងទំនងថាត្រូវខ្មោចមេបាធ្វើហើយ គេក៏រៀបរបៀបសែនព្រេនដូច្នេះ គឺ:

ចំអាប ១ ស្លក បង្អែម ១ ស្លក

ទំនមាន់ស្ងោរ ក្បាលជ្រូកស្ងោរ

ស្រា, បាយ, ស្លា ១ ជើងពាន បារី ១ ជើងពាន,

ដល់វេលាក៏អញ្ជើញពួកញាតិទាំងអ្នកដែលទាស់ទែងគ្នា. ទាំងអ្នកដែលមិនទាស់ទែងគ្នា មកជួបជុំព្រមនៅទីផ្ទះអ្នកជម្ងឺ ស្រេចហើយយកទៀនធូបអុជដោតនៅហ៊ុង ទឹងនៅគ្រឿងចំអាប-បង្អែម នាំគ្នានិយាយបន់ស្រន់ដល់ខ្មោចមេបាអំបាលនោះថា តានេះ យាយនោះ ឪនេះ ម៉ែនោះ ធំនេះ ពូនោះ ដកបដល់ពួកញាតិទាំង ៧ សន្ដានដែលបែកឋានទៅ ក្រែងមានបើទឹងសំបាទេនបណ្ដាអស់យើងខ្ញុំជាកូនជាចៅថា មិនរាប់អានគ្នា ឥឡូវនេះយើងខ្ញុំដឹងទោសខ្លួនហើយ បាន

[stamp] COMMISSION DES MŒURS & COUTUMES



មកជួបជុំព្រមនៅទីនោះដើម្បីសារភាពទោសនឹងអស់លោកមេបា សូមកុំឲ្យអស់លោកមេបាប្រកាន់ថាជាប្រការអ្វីឡើយ សូមយកក្រយាបូជា ហើយឲ្យជម្ងឺនេះសះជាស្បើយស្បើយពីថ្ងៃនេះទៅ ឲ្យសែនជាដូច្នេះ ៣ ដង រួចយកស្រាចាក់ច្រួចទៅក្នុងពែង សន្មតថាឲ្យខ្មោចសេពសោយ ។ រួចចាប់បាយមហូបចំណីពីក្នុងសំពត្តបន្តិច ។ គ្រប់មុខមកដាក់ក្នុងចាន ១ ទឹកដាក់ស្រា ១ ម៉ាត់ បារី ១ អុជធូប ១ សរសៃដោតនៅចាននោះ និយាយសែនឲ្យតាហ៊ានតាក្លូវដែលជាដើមអង្រឹងស្នែងហែហាមដីជូនជីតាយើងមក ឥឡូវនេះយើងក៏រៀបឲ្យសេពសោយ កុំឲ្យខឹងសំបារថាយើងមិនរាប់អានដល់ឡើយ រួចយកទៅចាក់ចោលក្រោមដើមជណ្ដើរផ្ទះ ។ លំដាប់នោះគេក៏យកគ្រឿងសំណែនដែលសល់នោះមកនាំគ្នាបរិភោគ បើត្រូវក្រោយនោះទើបឃើញអ្នកជម្ងឺនោះគ្រាន់បើឡើង ក្រោកឡើងបរិភោគបាយទឹក និងសំនិយាយជាប្រក្រតីឡើងវិញ ។ តែដែលមិនជា ដោយហេតុខ្មោចនោះធ្វើធ្ងន់ដៃពេកទៅ គេរកមិនឃើញ ស្លាប់ទៅក៏មាន ។

(ចប់)

ក្រុមជំនុំទំនៀមទម្លាប់
COMMISSION DES MŒURS & COUTUMES

# បញ្ជីរឿង

ទំព័រ

១ — សុន្ទរកថារបស់លោកភិក្ខុលោកនាថ (គនឹងចប់) ឧកញ៉ាទេពពិទូរ ក្រសេម ប្រែចេញពីសៀវភៅពុទ្ធសាសនាសៀម . . . . . . . . . . . . ១៣៥

២ — គរិយសច្ចកថាសង្ខេប របស់លោកគ្រូអាចារ្យ ហ៊ាយ . . . . . . . . . . ១៤៩

៣ — ហិតោបទេស ភាគទី ១ (ត) របស់ឧកញ៉ាទេពពិទូរ ក្រសេម . . . . . ១៦៥

៤ — រឿងព្រេង-បុរសរៀនសិល្ប របស់ឧកញ៉ាប្រាជ្ញាធិបតី (យិន) . . . . . . ១៧៥

" " -បុរសមានប្រពន្ធល្អ " " ១៧៩

៥ — លទ្ធិទំនៀមទម្លាប់ខ្មែរ-សែនខ្មោចមេបាចាស់ទុំក្នុងវេលាមានជម្ងឺ ដោយមានក្រមុំកំឡោះសហាយគ្នា របស់ឧកញ៉ាទេពពិទូរ ក្រសេម . . . . . . ១៨៣

៦ — ការទទួលអំណរដល់ពួកស្ត្រីថៃប្រកាសនីយបត្រ នៅក្រសួងពុទ្ធសាសនបណ្ឌិត្យ របស់ខេមររង្សី . . . . . . . . . . . . . . . . ១៨៩

## រូបក្រៅរឿង

រូបគណៈស្ត្រីប្រកាសនីយបត្រនៃមហាវិទ្យាល័យ (សៀម) ថតរួមជាមួយនឹងពួកយុវសាសិស្តខ្មែរនៅមាត់ជណ្ដើរព្រះរាជបណ្ណាល័យខាងជើង កាលពីថ្ងៃ ២៤ ខែអ៊ូត ឆ្នាំ ១៩៣៩ . . . . . . . . . . . . . . . . ១៣៣

# TABLE DES MATIÈRES


Pages

1° Causerie sur la doctrine bouddhique par Bhikhu Lokanatha traduit de la revue Buddhasâsanâ Thai par Moha Krasèm. 135

2° Ariyasaccakathâ par le Vénérable Heay.................. 149

3° Hitopadésa 1re partie (suite)......................... 165

4° Contes populaires cambodgiens inédits:

L'homme qui s'instruit............................. 175

L'homme qui a une jolie femme................ 179

5° Mœurs et coutumes cambodgiennes:

Offrandes faites aux ancêtres à la suite de l'union secrète d'un jeune homme et d'une jeune fille par Maha Krasèm. 183

6° Visite des diplomées thaies à l'Institut Bouddhique par Khemararansi........................ 189

HORS TEXTE:

Les Diplomées thaies et les Yuvasalistes à l'escalier de la Bibliothèque Royale le 24 Août 1939............. 133



រូបគណៈស្ត្រីប្រកាសនីយបត្រនៃមហាវិទ្យាល័យ (សៀម) ថតរូមជាមួយ
នឹងពួកយុវសាលិស្ត្រីខ្មែរនៅមាត់ជណ្តើរព្រះរាជបណ្ណាល័យខាងជើង
កាលពីថ្ងៃ ២៤ អ៊ូតឆ្នាំ ១៩៣៩ ។

សុន្ទរកថា

# របស់ព្រះភិក្ខុលោកនាថ ពុទ្ធបព្វជិត ជាតិឥតាលី

# នៅក្នុងឥណ្ឌៀ

## ច្បាប់ទី ២

ឧកញ៉ាទេពពិទូរ ក្រសេម គន្ថរចនបណ្ឌិត

ប្រែចេញពីសៀវភៅពុទ្ធសាសនចក្រ

របស់សៀម

# ពាក្យថ្លែងការណ៍

សេចក្ដីដូចមានខាងក្រោមនេះ ជាសុន្ទរកថារបស់ព្រះភិក្ខុលោកនាថ ពុទ្ធបព្វជិត ជាតិឥតាលី បានថ្លែងចំពោះនឹងបណ្ឌិត យ. នេហរូ ហើយនឹងចុះផ្សាយក្នុងសៀវភៅពុទ្ធសាសនចក្រ របស់គណៈមហាពោធិសមាគម ក្នុងឥណ្ឌា ដូចដែលយើងថ្លែងក្នុងច្បាប់ទី ១ នោះហើយ ។

យើងឃើញថា រឿងនេះមានប្រយោជន៍ដល់អ្នកមើល អ្នកស្ដាប់ច្រើន ទើបប្រែចុះក្នុងកម្ពុជសុរិយា របស់យើង ដើម្បីផ្សាយដំណឹងដល់ពួកយើង ឲ្យបានដឹងពល់គ្នាផង ។ តែពួកយើងគួរសង្កេតមើលសេចក្ដីចេះដឹងធម៌អាថ៌របស់ភិក្ខុលោកនាថ ដែលជាអ្នកទើបនឹងមកកាន់ពុទ្ធសាសនាថ្មី ៗ នេះឯង ហើយមានសេចក្ដីយល់ក្នុងពុទ្ធសាសនាដល់ម្ល៉េះ ពួកយើងដែលធ្លាប់កាន់តាំងពីដូនតាមកហើយ បើមិនប្រឹងប្រៀបឈានជើងឲ្យវែងបន្តិចឡើង អាចនឹងធ្លាក់ទៅជាកូនសិស្សរបស់ពួកឌុរុបក៏សឹងបាន ។

ឧកញ៉ាទេពពិទូរ ក្រសេម គន្ថរចនបណ្ឌិត

## សុន្ទរកថា

បណ្ឌិត យូរ៉ៃល នេហ្រូ អាត្មាភាពសូមចំរើនពរដល់លោក អាត្មាសង្ឃឹមថា លោកគង់សុខសប្បាយជាទេ ។

យេរុសាលេម ធ្លាក់នៅក្នុងកណ្ដាប់ដៃគ្រិស្ដាំង, មេគកៈ ក៏នៅក្នុងកណ្ដាប់ដៃរបស់ពួកឥណ្ឌូ , ម្ដេចឡើយពុទ្ធគយា ជាបូជនីយស្ថានក្នុងពុទ្ធ-សាសនា ពួកពុទ្ធសាសនិកជនត្រូវការពុទ្ធគយា តែរដ្ឋបាលឥណ្ឌៀបដិ-សេធការដែលនឹងលើកប្រគល់ឲ្យពុទ្ធសាសនិកដ៏ជាម្ចាស់ដើមមែន ។ នោះវិញ អ្វីជាដើមហេតុនៃរឿងនេះ? ចិត្តនៃពួកពុទ្ធសាសនិកចំនួន ៥០០ លាននាក់ រមែងឈឺចាប់ជានិច្ចកាល រហូតវេលាដែលពុទ្ធគយា នៅក្រៅកណ្ដាប់ដៃរបស់គេ ពុទ្ធសាសនិកនឹងឥណ្ឌូសាសនិកក្លាយទៅជាអ្នកសោះអង្គើយគ្នា មកពីហេតុដណ្ដើមពុទ្ធគយា ហើយពួកឥណ្ឌូខូចបង់សេចក្ដីជួយជ្រោមជ្រែង ដែលគួរបានអំពីពួកពុទ្ធសាសនិក ៥០០ លាននាក់នោះទៅផង ហេតុនោះ សូមឲ្យពួកឥណ្ឌូ ចូលមកជាពុទ្ធសាសនិកចុះ សូមឲ្យពួកហរិជន ចូរនាំផ្លូវ ដោយចុះចូលជាពុទ្ធសាសនិកជាដំបូង អំពីនោះមហាពុទ្ធគយាវិហារ ក៏នឹងត្រឡប់បានមកជាសម្បត្តិរបស់ពុទ្ធសាស-និក ដែលជាម្ចាស់ដើមស្រាប់នោះវិញ ។ នេះជាវិធី ១ ដែលនឹងផ្ដើមញ៉ូប្រមូលយកការសេចក្ដីជួយជ្រោមជ្រែងរបស់លោកនៅពុទ្ធសាសនិក

ទាំងអស់មកបាន ហើយនេះជាសេចក្តីគាប់ប្រសើរបស់ពួកឥណ្ឌូ ដែលជាពួកជាប់ត្រូវសង្កត់សង្កិន (សំដៅពួកហរិជន) ។

ឥឡូវនេះ ឥណ្ឌៀកំពុងខ្សោយកំលាំង ព្រោះបែកខ្ញែកជាពួក ៗ ដែលសុទ្ធតែកប់អានលទ្ធិសាសនាសឹងជាបរប័ក្ខនឹងគ្នា ចេះតែផ្តិលផ្តាច់កំលាំងគ្នាទូវគ្នា ។ ពួកឥណ្ឌូបដិសេធសេចក្តីដែលនឹងក្លាយជាមហាម័ត ពួកមហាម័តក៏មិនព្រមក្លាយជាឥណ្ឌូ ព្រោះហេតុនោះ សូមឲ្យគេទាំងពីរពួកធ្វើសន្យាគ្នា ដើរផ្លូវមករកគ្នាពាក់កណ្តាលម្នាក់ចុះ គឺសូមឲ្យមហាម័តនឹងឥណ្ឌូទាំងពីរពួក ចូរនាំគ្នាទទួលកប់អានព្រះពុទ្ធសាសនា, អំពីនោះសេចក្តីជំពាក់ទើសទាក់ទាំងឡាយ ក៏នឹងក្លាយទៅជារបស់ដែលត្រូវស្អិតស្អាងស្រេចរៀបរយក្នុងខ្លួនតែម្តង ។

កាលពួកឥណ្ឌៀទាំងអស់ នាំគ្នាចូលជាពុទ្ធសាសនិកហើយ មិនមែនត្រឹមតែគេទាំងឡាយបានសេរីភាពប៉ុណ្ណោះ គេទាំងនោះនឹងធ្វើឲ្យលោកទាំងមូលញ័ររំប្រប់តែម្តង ការដែលមនុស្ស ៤០០ លាននាក់ នាំគ្នាផ្តួបចូលជាពុទ្ធសាសនិកក្នុងឥណ្ឌៀ ហើយបានទទួលសេចក្តីជ្រោមជ្រែងអំពីពុទ្ធសាសនិកក្រៅប្រទេសឥណ្ឌៀ ចំនួន ៥០០ លាននាក់មកទៀតនោះ ក៏ល្មមអង្រួនលោកទាំងមូលឲ្យរញ្ជួយបានហើយ ។

ចូរងាកទៅមើលថ្ងៃយប់ដ៏រុងរឿង របស់ព្រះបាទអសោកមហារាជ ក្នុងសម័យដែលឥណ្ឌៀទាំងអស់រួបរួមមិត្រមូលជាមួយគ្នា ក្រោមការ

គ្រប់គ្រងរបស់មហាចក្រពត្តិ ដ៏ជាពុទ្ធសាសនិក ។ ពុទ្ធសាសនាជាសាសនានៃសេចក្ដីពិត ដែលអាចនឹងបោសបក់សេចក្ដីជំពាក់ពក់រិនរៃលទ្ធិការមិនសមាគមគប់គ្នាក្នុងវង់ជនផ្សេងជាន់ ផ្សេងវណ្ណៈបានមែន ។, ពុទ្ធសាសនាជាសាសនានៃការុណ្យភាពដែលមិនមានប្រមាណ ការុណ្យភាពរមែងធ្វើឲ្យរួមចិត្តគ្នាបាន, ក្នុងពួកដែលរួមចិត្តគ្នា រមែងមានកំលាំង, ព្រះពុទ្ធសាសនាតែងឲ្យកំលាំងដោយការុណ្យភាព ហើយសេចក្ដីដែលរួមគ្នាបាននឹងបានជាឯកភាព ។

ពុទ្ធសាសនាជាមហាវិទ្យាល័យដ៏ធំបំផុតរបស់លោក ដែលប្រដៅឲ្យដឹងឥស្សរភាពខាងក្នុងឥស្សរភាពខាងក្រៅ នឹងឥស្សរភាពដោយជុំវិញខ្លួន ចូរកេប់អានព្រះពុទ្ធសាសនាចុះ អំពីនោះលទ្ធិប្រកាន់វណ្ណៈខ្ពស់ទាបក៏នឹងរលុបរលាយទៅឯង ការមកបានកប់ប្រសព្វនឹស្គាល់ពុទ្ធសាសនានេះឯង ជាវិធីដែលនឹងរំលាយលទ្ធិប្រកាន់ថ្នាក់វណ្ណៈ[១] ។

សឹងជារបស់ពិតបំផុតនៅក្នុងខ្លួនឯង ងាយបំផុត មានហេតុផលបំផុត វិធីឯទៃ ៗ ទាំងអស់ស៊ូមិនបាន ពុទ្ធសាសនាប្រដៅការរួមគ្នាជាសួន្យតែ ១ នឹងសាមគ្គីធម៌ ពុទ្ធសាសនាជាសាសនាមួយប៉ុណ្ណោះដែលសាងឲ្យមានព្រះចៅសិរីធម្មាសោកកជនឹងសិរីអាណាចក្ររបស់ព្រះអង្គ ។

---

១ វណ្ណៈ ៤ គឺ ក្សត្រិយ៍ ព្រាហ្មណ៍ វេស្ស សុទ្រ ។

បណ្ឌិត យ. នេហរូ ពុទ្ធសាសនាជាបណ្ណាការដែលល្អបំផុត ដែលយើងអាចនឹងជូនលោកនឹងឥណ្ឌា ពុទ្ធសាសនាជារបស់សំណប់របស់ភូមាដែលនឹងជូនដល់លោក នឹងឥណ្ឌាទាំងមូល «សព្វទានំ ធម្មទានំ ជិនាតិ» ព្រះពុទ្ធជាម្ចាស់ត្រាស់ថា ការឲ្យធម្មទានឈ្នះទានទាំងពួង លោកចូរទទួលយកពុទ្ធសាសនា ដែលជាសិរីមង្គលដ៏ធំបំផុតជាងសិរីមង្គលទាំងពួង ៗ

កាលអ្នកជម្ងឺមិនប្រាថ្នានឹងបរិភោគថ្នាំ ពេទ្យក៏រមែងមិនយកចិត្តទុកដាក់នឹងគេនោះ អាចបោះបង់ចោលគេទៅបាន បើឥណ្ឌាមិនព្រមទទួលពុទ្ធសាសនា ភូមានឹងបោះបង់ចោលឥណ្ឌា ហើយគង់ជាបែកខ្ញែកទីទៃពីគ្នាទៅ បណ្ដាប្រទេសទាំងឡាយក្នុងទ្វីបអាស៊ីដែលកាន់ពុទ្ធសាសនា ក៏នឹងមិនជួយឈឺឆ្អាលឥណ្ឌា ដរាបណាដែលឥណ្ឌានៅបដិសេធមិនទទួលរាប់អានពុទ្ធសាសនា សូមឥណ្ឌាចូលមកជាពុទ្ធសាសនិក អំពីនោះពុទ្ធគយាវិហារក៏នឹងធ្លាក់មកក្នុងកណ្ដាប់ដៃនៃពុទ្ធសាសនិកទាំងឡាយដោយខ្លួនឯង សូមឲ្យពុទ្ធគយាវិហារធ្លាក់មកក្នុងកណ្ដាប់ដៃនៃពុទ្ធសាសនិកទាំងឡាយចុះ លំដាប់នោះអាស៊ីទាំងអស់នឹងរួបរួមចូលគ្នាបាន ជាមហាភាតរភាព នៃពុទ្ធសាសនិកជាមួយគ្នា សូមឲ្យអាស៊ីទាំងមូលរួបរួមគ្នាឲ្យបានជាមហាភាតរភាពនៃពុទ្ធសាសនិកជាមួយគ្នាចុះ កាលដូច្នេះ

ហើយអ្នកណា នឹងអាចមកបង្ខំចិត្តវណ្ណៈបាន វណ្ណៈដែលជាពុទ្ធសាសនិកក៏នឹងប្ដូរចេញជាវណ្ណៈទាបបានក្នុងខ្លួនឯង ក្នុងនោះដែលជាពុទ្ធសាសនិក ក៏នឹងវិលមករកវណ្ណៈ ដែលជាពុទ្ធសាសនិកហើយនោះទៀត ហើយលោកម្ចាស់ពួកពុទ្ធ ក៏នឹងត្រេកអរសោមនស្សក្រៃពេកការដែលបានកូនពុទ្ធរបស់ខ្លួនសឹងត្រាត់ប្រាសទៅជាយូរ ត្រឡប់មកវិញ ។

ពួកយើង គោរពបានទុក្ខលំបាកក្នុងគ្រានេះ ក៏ព្រោះគេនាំគ្នាលះបង់សាសនាដែលល្អ គឺព្រះយេស៊ូវគ្រិស្តបង់ ហើយមកកាន់សាសនាដទៃ ៗ ដែលថយថោកជាង ទើបសូមឲ្យពួកវណ្ណៈត្រឡប់ចូលរកព្រះពុទ្ធអង្គដ៏ជាព្រះសាស្ដាល្អឯកបំផុតនោះចុះ អំពីនោះគេនឹងនៅជាសុខអស់កាលជាអង្វែង ។

អាត្មាភាពស្រឡាញ់ប្រទេសវណ្ណៈជាងប្រទេសដទៃ ៗ ខ្លួនអាត្មាជាវតាលី ចិត្តអាត្មាជាវណ្ណៈ វណ្ណៈជាដែនដីរបស់ព្រះបិតាខាងចំណែកដួងវិញ្ញាណអាត្មា ព្រះបិតាអាត្មា គឺព្រះពុទ្ធអង្គ អាត្មាជា «ពុទ្ធបុត្រ» បុត្ររបស់ព្រះពុទ្ធអង្គ ។

ព្រះពុទ្ធអង្គជាបរមគ្រូនៃលោក បានប្រកាសសច្ចធម៌ថា "សភាវៈគ្រប់យ៉ាងជារបស់មិនទៀង សភាវៈគ្រប់យ៉ាងជារបស់ប្រកបដោយទុក្ខ សភាវៈគ្រប់យ៉ាងជារបស់ឬគនរទេ ពួកដែលព្រមទទួល

ទុក្ខដ៏ថ្លៃថ្លានេះ ក៏នឹងបានទទួលទុក្ខទណ្ឌានទៅមុខវែងឆ្ងាយតទៅទៀត អ្នកបដិសេធក៏នឹងជា "មនុស្សស្លាប់" គឺជាត្រូវទំលាយនឹងបោះបង់ចោលទាល់រៀរពេល ពួកដែលបដិសេធការទទួលយកសច្ចធម៌ សេចក្តីស្លាប់របស់ដួងចិត្ត ជារបស់អប្រិយជាងការស្លាប់របស់កាយ ពុទ្ធសាសនាជាសាសនាមួយ ដែលអាចជួយមនុស្សស្លាប់ឲ្យត្រឡប់រស់មកវិញបាន ឥណ្ឌៀបានស្លាប់ទៅហើយក្នុងសព្វថ្ងៃនេះ ហើយនឹងមិនត្រឡប់រស់មកវិញបាន លុះដរាបណាដែលគេព្រមទទួលយកពុទ្ធសាសនា ដែលជាឧសថដ៏ប្រសើរបំផុតក្នុងលោកនេះ ។ ក្នុងព្រះពុទ្ធសាសនាគ្មានការអវតារ (បែងភាគឲ្យអន្ទោលកើត) ពួកព្រាហ្មណ៍មេកលមាយាច្រើនបានពោលបង្អាប់យកព្រះពុទ្ធអង្គទៅជាព្រះអវតារ ១ គ្រា ក្នុងសាសនាឥណ្ឌូនោះ សឹងជាគួបិសាចដ៏កំណាចសល់ ព្រះពុទ្ធអង្គមិនដែលត្រាស់ថា ព្រះអង្គជាព្រះអវតារគ្រាឯណានិមួយសោះឡើយ ហេតុអ្វីពួកឥណ្ឌៀទើបថាព្រះអង្គជាព្រះអវតាររបស់ខ្លួន ហេតុម្តេចគេទើបផ្គុំរឿងដែលព្រះអង្គមិនដែលត្រាស់សោះឡើយឡើងជារូបដូច្នេះ ព្រះពុទ្ធសាសនាបរិសុទ្ធផូរផង់ក្នុងខ្លួនឯងស្រាប់គ្រប់គ្រាន់ហើយ មិនត្រូវការសេចក្តីជួយបន្ថែមរបស់ពួកឥណ្ឌូទេ អវតារគឺការអន្ទោលកើត ស្រីក្ឫស្ណៈបានពោលនឹងអរជុនថា កាលណាសេចក្តីសទ្ធាជ្រះថ្លាខ្សោយចុះ ហើយសេចក្តីមិន

សង្ហាជ្រះថ្លាត្រឡប់មានគ្រាស់ឡើង យើងគោរពសាសនាខ្លួនឯងឡើងកាលនោះ (កត់តែ គីតា 47) តែព្រះពុទ្ធអង្គទ្រង់ព្រះនាម គោតម បានទ្រង់លុះដល់អនុត្តរនិព្វាន ក្នុងសង្សារៈមិនកើតទៀត ដូច្នោះពួកឥណ្ឌាទាំងអាចនៅថាព្រះពុទ្ធអង្គជា អវតារ ១ គ្រាដែរ បើការអវតារជាការកើតថ្មី ឯព្រះពុទ្ធអង្គជាឯកបុគ្គលមិនកើតទៀតទេ នេះបង្អុលឲ្យឃើញថា "ទ្រឹស្ដីរឿងអវតារ" ត្រូវផ្ដុំឡើងមកសំរាប់បង្កាប់យកព្រះពុទ្ធសាសនាទៅជារបស់ខ្លួនប៉ុណ្ណោះ សេចក្ដីមិនពិតមិនអាចតទល់ក្ដល់មុខនឹងសេចក្ដីពិត ពួកព្រាហ្មណ៍អ្នកលេងស្លោកក្រោកបានគិតរកឧបាយបញ្ចូលយកព្រះពុទ្ធជាអវតារ ១ ផងរបស់ឥណ្ឌូ ហើយដោយកលវិធីត្រឡប់ត្រឡិននេះ គេបានបរព្រះពុទ្ធសាសនាឲ្យឆ្ងាយចេញទៅក្រៅប្រទេសឥណ្ឌា (ដោយសេចក្ដីប្រាថ្នាដ៏ខ្លាំងក្លាដើម្បីក្បោលទ្ធិប្រកាន់វណ្ណៈ ទុកឲ្យបាន ដែលធ្វើឲ្យពួកខ្លួនបានខ្ពង់ខ្ពស់លើវណ្ណៈដទៃ ១) ដោយបាបកម្មដ៏មហន្តនឹងមុខគួរស្ញែងនេះ ពួកគេគោរពនេះទៅក្នុងនរកអស់កាលដ៏យូរ ៗ

បណ្ឌិត យ. នេហរូ ខណាដែលអាក្រក់ជាងគេ គឺខដែលធ្លាក់ទៅជាខ្ញុំនៃឥន្ទ្រិយ ៦ មិនដែលធ្លាក់នៅក្រោមអំណាចនៃប្រទេសដទៃ។ - ខដែលធ្លាក់ជាខ្ញុំឥន្ទ្រិយ ៦ ជាសេចក្ដីធ្លាក់ដ៏ថោកទាបបំផុត កាលបើដូច្នេះហេតុម្ដេចទើបមិនដំណើរការគិតគូរជកសេចក្ដីធ្លាក់ជាខ្ញុំឥន្ទ្រិយ ៦ ចេញពី

ដំបូង។ ម្ដេចទើបមកកង្វល់ក្នុងរឿងអំណាចនៃតាន់ប្រទេស? ចាំបាច់រកើប ពួកនុរុបថ្មី ព្រោះពួកនោះធ្លាក់ទៅជាខ្ញុំនៃឥន្ទ្រិយ ៦ ដូចយើងដែរ? ព្រះពុទ្ធជាម្ចាស់របស់យើងត្រាស់ថា "ខ្លួនជានាយរបស់ខ្លួន" ពល់រូបបេះតែធ្វើខ្លួនឲ្យទៅជាខ្ញុំរបស់ខ្លួន គ្មានអ្នកណាដែលអាចធ្វើអ្នកដទៃឲ្យធ្លាក់មកជាខ្ញុំបានទេ កាលបើដូច្នេះ ហេតុម្ដេចលោកទើបមកកង្វល់រឿងអង់គ្លេសច្រើនដល់ម្ល៉េះ? ចូរកង្វល់ក្នុងរឿងខ្លួនឯងវិញ, ចូរផ្ដើមដើរចេញអំពីខាងក្នុង, ចូរទំលាយសម្ពន្ធភាពនៃឥន្ទ្រិយ ៦, កាលលោកជាឥស្សរៈខាងក្នុង ហើយលោកដ៏ជាឥស្សរៈខាងក្រៅបានក្នុងខ្លួនឯង គ្មានអ្នកណាអាចធ្វើបុរសអ្នកអស់កិលេសហើយឲ្យធ្លាក់មកជាខ្ញុំបាន? គ្មានអ្នកណាអាចធ្វើព្រះពុទ្ធអង្គឲ្យធ្លាក់មកជាខ្ញុំបាន ហេតុនោះ បណ្ឌិត យ. នេហរូ លោកចូលព្យាយាមយ៉ាងមាំមួនទាល់តែដល់អរហន្តភាព លោកក៏នឹងបានប្រសព្វសេរីភាព យ៉ាងសន្ធោរជានិច្ចកាលរៀងទៅ ។

មនុស្សក្អកខ្វាក់មិនអាចដឹកដៃមនុស្សខ្វាក់ដូចគ្នាទៅបាន បើដឹកនឹងនាំគ្នាធ្លាក់គប់កក់ទាំងពីរ ហេតុនោះ បណ្ឌិត យ. នេហរូ ចូរទំលាយសេចក្ដីខ្វាក់ងងឹតរបស់ខ្លួនឯងជាដំបូងចេញសិន ហើយសឹមគិតនាំអ្នកដទៃតទៅ ខ្ញុំគេមិនអាចដោះអ្នកខ្ញុំគេដូចគ្នាឲ្យរួចជាអ្នកជាបាន, ហេតុនោះ បណ្ឌិត យ. នេហរូ ចូរធ្វើខ្លួនឯងឲ្យជាឥស្សរៈសិន អំពីនោះលោកនឹងសង្ឃឹមបាន ក្នុងការដែលនឹងធ្វើអ្នកដទៃឲ្យជាឥស្សរៈ? អ្នកលង់ទឹកមិន

អាចស្រង់អ្នកលង់ទឹកផងគ្នាបាន, ចូររៀនហែលទឹកឲ្យបេះស្មាត់សិនមុន ដែលនឹងព្យាយាមជួយស្រោចស្រង់អ្នកដទៃ ។

បណ្ឌិត យ. នេហរូ លោកមកក្នុងទីនេះ ដើម្បីសួរយកកូមាត្រ-ឡប់ចូលទៅកាន់ឥណ្ឌៀ ល្អណាស់។ តែលោកចូរប្រាប់ឲ្យឥណ្ឌៀព្រមទទួលកាន់ពុទ្ធសាសនាទៅសិន, លោកចូររំគាយកូន ដោយការព្រមទ-ទួលកាន់ពុទ្ធសាសនាដោយខ្លួនឯង ក្នុងកាលឥឡូវនេះតែម្តងចុះ។ វាជាការផុតវិស័យ ក្នុងការដែលនឹងសួរយកពួកពុទ្ធបរិស័ទ្យទៅចូលពួកដែលមិនមែនជាពុទ្ធបរិស័ទ្យ ព្រះពុទ្ធអង្គត្រាស់ថា "បើអ្នកមិនបានមិត្តដែលស្មើនឹងខ្លួនឬថ្លៃថ្លាជាងខ្លួន ក៏ចូរត្រេចទៅតែម្នាក់ឯង" កូមាស្ម័គ្រដើរម្នាក់ឯង ព្រោះឥណ្ឌៀបដិសេធមិនទទួលរាប់អានព្រះពុទ្ធសាសនា បណ្ឌិត យ. នេហរូ លោកយល់ក្នុងបឋមហេតុដូចពោលនេះហើយ ផលល្អក៏នឹងមានដល់លោក, ដល់ឥណ្ឌៀ នឹងដល់លោកទាំងមូល ។

អ្វីជាវត្ថុដែលប៉ុនប៉ងរបស់ការរស់នៅ? សេចក្តីសុខ សេចក្តីផុតរលត់ចាកសេចក្តីរស់នៅ ។ មនុស្សយើងនឹងផុតរលត់ចាកសេចក្តីរស់នៅដោយការស្រែកទេសបានឬ? មិនបានឡើយ ការស្រែកទេសសង្កត់យើងឲ្យលិចចុះទៅក្នុងសេចក្តីរស់នៅ នឹងសេចក្តីទុក្ខវេទនា ។

លោកពោលថា "ខ្លួនលោកមិនសូវអំពល់រឿងសាសនាណាស់ទេ លោកយកចិត្តទុកដាក់តែក្នុងការស្រែកទេសច្រើនជាង" បុគហ្គាយប្បាប់

ដំបូងដែលអាត្មាសរសេរមកដល់លោក អាត្មាពោលថា "ការស្រែកទេសធ្វើក្រពះឲ្យពេញ, សាសនាធ្វើចិត្តឲ្យពេញ" ការស្រែកទេសដំណើរខ្លួនទៅដោយលោកដ៏ប្រែប្រួល ពុទ្ធសាសនាដំណើរខ្លួនទៅដោយនិព្វាន មិនមានប្រែប្រួល, ការស្រែកទេសដំណើរកិច្ចការទៅដោយសេចក្តីកុតករ, ពុទ្ធសាសនាដំណើរកិច្ចការដោយសេចក្តីពិត, ការស្រែកទេសបំពោកសេចក្តីចំណង់ឲ្យក្លា កឲ្យកើតសេចក្តីទុក្ខកាយទុក្ខចិត្ត, ពុទ្ធ-សាសនាផ្តិលផ្តាច់សេចក្តីចំណង់អំណោយសេចក្តីត្រជាក់ត្រជំ និងសាន្តិសុខ ហេតុនោះ បណ្ឌិត យ. នេហរូ លោកជាអ្នកយកចិត្តទុកដាក់ក្នុងការស្រែកទេស ដែលមានសេចក្តីទុក្ខសោកជាចំណុចដែលប៉ុនប៉ង ហើយលោកមិនអើពើនឹងសាសនា ដែលមានសេចក្តីសុខសម្រាន្តជាចំណុចដែលប៉ុនប៉ង ការស្រែកទេស មិនចេះមានសេចក្តីអស់ហើយ ព្រោះសេចក្តីចំណង់នាំទៅកាន់សេចក្តីចំណង់ដ៏ធំក្រៃលែងទៅទៀត ក្នុងព្រះពុទ្ធសាសនាមានគំរែតទីបំផុត ព្រោះសេចក្តីអស់តណ្ហាដោយឯកទេសរមែងនាំទៅកាន់សេចក្តីអស់តណ្ហាដោយអស់ជើង ដែលមិនមានតណ្ហាតទៅរហូតកាល ព្រោះហេតុនោះ បណ្ឌិត យ. នេហរូ លោកចូរប្រឡាញ់សាសនា ដែលជារបស់មានព្រះនិព្វានជាចំណុចដែលប៉ុនប៉ង និងចូរស្អប់ការស្រែកទេស ដែលមាននរកជាចំណុចដែលប៉ុនប៉ង ។

(នៅមានត)

អរិយសច្ចកថាសង្ខេប

ព្រះអាចារ្យ ហាយ (សុវិជ្ជាញាណ) វត្តឧណ្ណាលោម

ក្រុងភ្នំពេញ

ក្រុមជំនុំព្រះត្រៃបិដក ក្នុងពុទ្ធសាសនបណ្ឌិត្យ

នៅព្រះរាជបណ្ណាល័យ កម្ពុជា

ប្រែរៀបរៀងអធិប្បាយជារបៀបទេសនា

# អរិយសច្ចកថា

នមត្ថុ រតនត្តយស្ស ។

ទុក្ខមេវ ហិ ន កោចិ ទុក្ខិតោ

ការកោ ន កិរិយាវ វិជ្ជតិ

អត្ថិ និព្វុតិ ន និព្វុតោ បុមា

មគ្គមត្ថិ គមកោ ន វិជ្ជតិ

ឥឡូវនេះនឹងសំដែងចំពោះអរិយសច្ច ៤ ប្រការ តាមគាថា ដែលបានលើកមកតាំងទុកខាងដើមនេះ ។ អរិយសច្ចធម៌ ដែលព្រះសម្ពុទ្ធទ្រង់ប្រកាសទុកមកជាគោលធំនៃពុទ្ធសាសនា ហៅថា សាមុក្កំសិកា ទេសនា គឺព្រះអង្គទ្រង់លើកឡើងសំដែងដោយព្រះអង្គឯង ជាធម៌មានអត្ថដ៏សុខុម បេញសេចក្ដីយ៉ាងពិស្ដារក្រៃលែង តែក្នុងទីនេះនឹងអធិប្បាយជាសេចក្ដីសង្ខេបល្មមជាសណ្ដាប់នៃសប្បុរសទាំងឡាយ ដូចតទៅនេះ ។

មនុស្សក្នុងលោកទាំងអស់ សុទ្ធតែជាអ្នកឈមមុខទៅរកសេចក្ដីសុខគ្រប់ៗគ្នា ឥតមាននរណាមួយ បដិសេធសេចក្ដីសុខចេញឡើយ ។ ពួកមនុស្សអ្នកខំប្រឹងប្រែងប្រកបការងារណាមួយ ក៏សុទ្ធតែប្រាថ្នារកសេចក្ដីសុខទាំងអស់ គឺថាប្រកបការងារ ដើម្បីចៀសវាងសេចក្ដីទុក្ខ បម្រុងស្ទាក់រកសេចក្ដីសុខប៉ុណ្ណោះឯង ។ ការងារដែលមនុស្សប្រកបនោះមាន

ច្រើនយ៉ាងគឺ កិច្ចការខ្លះក្រ ខ្លះងាយ ខ្លះធ្ងន់ ខ្លះស្រាល ខ្លះច្រើន ខ្លះតិច តាមធម្មតា ការងាររបស់មនុស្ស ក្នុងស្រុកនីមួយ ៗ ។

ការងារទាំងអស់នោះ បើបំប្រួញឲ្យខ្លីមក មានកំណត់ត្រឹម ២ យ៉ាងគឺ ការងារ ដែលប្រកបដោយទោស មានសម្លាប់សត្វឬក្រគួនបៀតបៀនមនុស្សសត្វជាដើម ឲ្យគេបានទុក្ខលំបាក ហៅថា សាវជ្ជកម្ម ១ ការងារ ដែលប្រាសចាកទោស មានវៀរចាកសម្លាប់សត្វជាដើម ហៅថា អនវជ្ជកម្ម ១ ។ បណ្ដាការងារទាំង ២ យ៉ាងនេះ មនុស្សគ្រប់ចំពូកដែលត្រូវការចង់បានសេចក្ដីសុខយ៉ាងវិសេសនោះ គួរប្រកបការងារជាអនវជ្ជកម្ម គួរវៀរសាវជ្ជកម្មឲ្យស្រឡះចេញ ។

មនុស្សអ្នកដែលចុះដៃចាប់ធ្វើការងារប្រកបដោយទោសនោះច្រើន តែដឹងថា អំពើនេះៗ ជាទោសដែរ តែដោយមានសេចក្ដីប្រកាន់លោភ ធ្វើទាំងបំពានទៅក៏មាន ដោយចាល់ផ្លូវក៏មាន មនុស្សខ្លះមិនដឹងថា អំពើនោះៗ ជាទោសសោះ ដោយពាលភាព គឺជាមនុស្សល្ងង់ខ្លៅទាំងស្រុងក៏មាន ដោយទំនៀមទំលាប់ដែលធ្លាប់ធ្វើមកក៏មាន ហើយក៏ធ្វើទៅតាមទំនើងមោហចិត្ត របស់ខ្លួនយ៉ាងស្អិត ឥតញញើត ។ បាបកម្មគឺអំពើអាក្រក់មានច្រើនយ៉ាង តែងកើតឡើងដោយអំណាចកំឡាំងឧបក្កិលេសទាំង ១៦ ឬអកុសលចេតសិក ១៤ ប្រការ ព្រោះថា ឧបក្កិលេស នឹងអកុសលចេតសិកទាំងនេះតែងបណ្ដាលដឹកនាំមនុស្សឲ្យធ្វើអំពើអាក្រក់

គឺនាំឲ្យប្រព្រឹត្តល្មើស នាំឲ្យច្រួលច្រាល់អន្ទះសា ឲ្យប្រាថ្នាធំហួសហេតុ ដរាបដល់តែសំដែងអាការចេញមកក្រៅ ដល់ភ្នែកត្រចៀកអ្នកឯទៀត ដូចយ៉ាងអាការដែលអ្នកអាងលើកដំកើងខ្លួនឯង ឬលំអៀងដោយអគតិ យោគយល់ពួករបស់ខ្លួន បន្តុះបង្អាប់គេ ប៉ុណ្ណោះជាដើម លោកហៅថាជាដំណើរបាបកម្មទាំងអស់ ៗ កម្មទាំងនេះ តែងនាំមកនូវទុក្ខភ័យឬសេចក្តីក្តៅក្រហាយ មិនមែនជាដំណើរនាំមកនូវសេចក្តីសុខ ក្សេមក្សាន្តត្រជាក់ចិត្តឡើយ ៗ បាបកម្មដែលបុគ្គលណាធ្វើហើយតែងផុះផុលអណ្តែតឡើងកើតជាផលអាក្រក់ វិលធ្លាក់ស្រោចទៅលើបុគ្គលនោះវិញ ដូចស្រមោល គង់នឹងបានទទួលទុក្ខភ័យ សេចក្តីរអៀសខ្មាសមុខឬក្តៅក្រហាយចិត្តគង់ពេលណាមួយមិនខាន ទោះនឹងចូលទៅកាន់ទីប្រជុំបរិស័ទណា ក៏តែងមានសេចក្តីរអៀសរអើលខ្លួនឯង ដូចគោដំបៅខ្នងរអើលនឹងក្អែកដែលហើរពីលើដរាប បាបកម្មសុទ្ធតែជាមូលហេតុនៃទុក្ខភ័យទាំងអស់តាំងអំពីលោកនេះ រហូតដល់បរលោក ៗ ចំណែកខាងកល្យាណកម្មគឺអំពើសុចរិតទៀងត្រង់ល្អ ជាមូលហេតុហូរមកនៃសេចក្តីសុខ ក្សេមក្សាន្តគ្រប់កាលទាំងពួង ព្រោះហេតុនោះសាធុជនទាំងឡាយអ្នកប្រាថ្នាសេចក្តីសុខដ៏ទូលាយនោះ គួរប្រយ័ត្នរាំងមើលកម្មគឺអំពើដែលខ្លួនត្រូវធ្វើនោះឲ្យរឿយ ៗ កុំបីភ្លេចស្មារតីឡើយ ព្រោះថាកម្មនេះជាមេបណ្តាលឬថាជាដើមផ្លូវនៃសេចក្តីសុខ-ទុក្ខគ្រប់យ៉ាង ៗ

សេចក្តីសុខ ដែលមនុស្សសត្វតែងប្រាថ្នានោះសោត ក៏មានច្រើនស្ថាន ដូចសេចក្តីសុខចំពោះខ្លួនចំពោះរូបមួយ ៗ របស់មនុស្ស ដោយសារមិនមានជម្ងឺដំកាត់ក្តី ដោយសារត្រកូលខ្ពង់ខ្ពស់ក្តី ដោយសារសម្បូណ៌ភោគសម្បត្តិក្តី ឬដោយសារប្រាជ្ញាស្មារតីការបេះដូងក្តី ទាំងនេះក៏ហៅថា សុខ តាមចំណែកកល់ ៗ រូប ៗ មួយទៀត សត្វដែលមកយកកំណើតជាមនុស្សនេះ ក៏រាប់ថាជាសុខវិសេស គ្រាន់បើជាងសត្វតិរច្ឆាន ប៉ុន្តែជម្នាមនុស្សបុថុជ្ជន ដែលបានសេចក្តីសុខប៉ុណ្ណោះហើយ ច្រើនតែត្រេកត្រអាលភ្លេចខ្លួនលង់ទៅក្នុងអំពើអាក្រក់ផ្សេង ៗ រហូតទាល់តែប្រែក្លាយធ្លាក់ខ្លួនទៅប្រទះនឹងសេចក្តីទុក្ខវិញក៏មាន សេចក្តីសុខ ដែលប្រកបដោយអាមិសនៅប្រែប្រួលនេះ លោកពោលថាជាសាមិសសុខគឺសុខនៅមានគូគ្នានឹងទុក្ខតែងប្រែក្លាយទៅជាទុក្ខខ្លះ សុខខ្លះម្តង ៗ មិនទាន់រាប់ថាជាសុខសុទ្ធសូម្បមាំមួន សូម្បីសុខក្នុងសួគ៌ទេវលោក ដែលជាទិព្វសុខស្តុកស្តម្ភដោយអាយុពណ៌សម្បុរភោគសម្បត្តិ ក៏លោករាប់ថាជាសាមិសសុខដូចគ្នា ព្រោះនៅវិលត្រឡប់មកកាន់កំណើត មកប្រទះសេចក្តីទុក្ខផ្សេង ៗ ជាដដែលវិញ ប៉ុន្តែសុខក្នុងសួគ៌ទេវលោកនោះឃើញថាវិសេសជាងសុខក្នុងមនុស្សលោក សេចក្តីសុខនេះបើពោលដោយរួបរួមមាន ៣ យ៉ាង គឺសុខក្នុងមនុស្ស ១ សុខក្នុងសួគ៌ទេវលោក ១ សុខក្នុង

ព្រះនិព្វាន ១ ៗ សុខពីរខាងដើមរាប់បញ្ចូលនៅក្នុងសាមិសសុខ ឬកាម-សុខ គឺសុខនៅក្នុងចំណោមនៃទុក្ខសន្និបាត ជាសុខឈ្លួសទៅដោយអារម្មណ៍ មានរូបារម្មណ៍ជាដើម ដែលជាទីត្រេកអរ ជាទីប្រាថ្នាពេញចិត្តរបស់បុថុជ្ជន មិនជាទីត្រេកអររបស់ព្រះអរិយឡើយ ៗ សុខក្នុងព្រះនិព្វានលោកចាត់ថាជានិរាមិសសុខ គឺសុខប្រាសចាកអាមិស មិនលាយច្រឡំដោយទុក្ខ មិនវិបរិតប្រែប្រួលក្លាយត្រឡប់វិញ ព្រះនិព្វានឈ្មោះថាឯកន្តសុខ ជាសុខដាច់ចំណោមអំពីទុក្ខ ឬហៅថាសន្តិសុខ ជាសុខស្ងប់ស្ងាត់ចាកអារម្មណ៍ ស្ងប់ស្ងាត់ចាកឧបធិអន្តរាយគ្រប់យ៉ាង ៗ

ព្រះសម្មាសម្ពុទ្ធ កាលនៅជាពោធិសត្វនៅឡើយ ព្រះអង្គបានត្រេចរង្គាត់តាប់កំណើតក្នុងភពតូចធំ បានជួបប្រសព្វនឹងសេចក្ដីសុខគ្រប់អន្លើ បណ្ដាសេចក្ដីសុខទាំងអស់ដែលជាប់ទាក់ទិនក្នុងភពសុទ្ធតែជាសុខមានវេទនាផ្លាស់ប្ដូរទៅនឹងទុក្ខទោសផ្សេងៗ សូម្បីសុខណាមួយក្នុងភពទាំង ៣ គឺ កាមភព, រូបភព, អរូបភព ក៏ព្រះអង្គបានជួបប្រទះ បានជ្រាបច្បាស់ទាំងអស់ ឥតកំបាំងសោះឡើយ ព្រះអង្គបានពិចារណាលៃលកស៊ើបដំណើរចំណាំមើលក្នុងលោកទាំងមូល ដោយប្រាជ្ញាដ៏វិសេសគ្រប់ៗជាតិនឹងឃើញមានសេចក្ដីសុខណាមួយ ឲ្យប្រសើរវិសេសដល់នូវទីបំផុតទុក្ខដូចសុខក្នុងព្រះនិព្វាននោះគ្មានឡើយ ព្រោះហេតុនោះ បានជាព្រះ

ពោធិសត្វខំកសាងបំពេញបារមីធម៌អស់ច្រើនជាតិ ដើម្បីលះបង់ចៀសវាងនូវគំនរទុក្ខទោស ដែលបន្ទំនៅក្នុងសាមិសសុខ ព្រោះព្រះអង្គបានឃើញច្បាស់នូវសេចក្តីសុខទុក្ខគ្រប់យ៉ាង ហើយទើបទ្រង់បែរព្រះហឫទ័យឆ្ពោះទៅរកសន្តិសុខតែម្យ៉ាង ឯផ្លូវដែលធ្វើដំណើរសេចក្តីប្រតិបត្តិ ឲ្យត្រង់លឿនទៅរកសន្តិសុខ គឺព្រះនិព្វាននោះសម្រេចមកអំពីការសង្រួមប្រយ័ត្នកាយវាចា ដោយការឲ្យទានរក្សាសីល ធ្វើចិត្តឲ្យបរិសុទ្ធ ដោយការចំរើនសមថកម្មដ្ឋាន ធ្វើបញ្ញាឲ្យចាស់ក្លា ឲ្យភ្លឺច្បាស់ចំពោះសង្ខារ ដោយការសេពគប់បណ្ឌិតនិងចំរើនវិបស្សនាកម្មដ្ឋាន ។ បុគ្គលដែលបានប្រព្រឹត្តតាមពិធីទាំងនេះមុខជានឹងបានដល់នូវសុខដូចសេចក្តីប្រាថ្នាមិនខាន អ្នកដែលមិនបានប្រតិបត្តិតាមគន្លងបែបនោះ កុំបាច់សង្ឃឹមថា បានដល់នូវសុខក្សេមក្សាន្តក្នុងបរលោកទៀតឡើយ ។ មួយទៀត បុគ្គលអ្នកពិចារណាឃើញបានតែត្រឹមកាមសុខគឺសុខក្នុងមនុស្សលោកនិងទេវលោកប៉ុណ្ណោះ មិនបានឃើញខាងសេចក្តីទុក្ខនិងសេចក្តីវិនាសផងទេ នឹងសង្ឃឹមថាខ្លួនរួចចាកទុក្ខក៏មិនបាន សមដូចព្រះពុទ្ធដីកាថា: យោ ទុក្ខំ ន បជានាតិ ន សោ ទុក្ខា បរិមុច្ចតិ សេចក្តីថា : បុគ្គលឯណាមិនស្គាល់ទុក្ខ បុគ្គលនោះមិនរួចស្រឡះចាកទុក្ខឡើយ ។ សេចក្តីនេះបំភ្លឺឲ្យឃើញថា បុគ្គលដែលចេះព្យាយាមសន្សំបុណ្យ ពីព្រោះគេស្គាល់បាប

គេបានចួបប្រទះនឹងសុខ ពីព្រោះគេស្គាល់ទុក្ខ ប្រទះនឹងសេចក្ដីចំរើន ពីព្រោះគេស្គាល់ខានផ្លូវវិនាស ប្រទះនឹងម្លប់ត្រជាក់ ពីព្រោះគេស្គាល់ដីឯងជាក្ដៅ ទៀងទៅជាអ្នកចេះដឹងបាន ពីព្រោះគេដឹងខ្លួនថាល្ងង់ខ្លៅ ព្រោះហេតុនោះ បុគ្គលអ្នកត្រូវការប្រាថ្នា សេចក្ដីសុខសេចក្ដីចំរើន ត្រូវតែស្គាល់ដើមកំណើតនៃសេចក្ដីសុខសេចក្ដីចំរើន នឹងសេចក្ដីទុក្ខ សេចក្ដីវិនាស ដែលជាធម្មជាតគូៗនឹងគ្នា ទើបចៀសវាងអំពីសេចក្ដីទុក្ខសេចក្ដីវិនាសបាន សមដូចពុទ្ធគាថាដែលបានលើកមកទុកក្នុងបទខាងដើមត្រង់បទទី ១.- ទុក្ខមេវ ហិ ន កោចិ ទុក្ខិតោ សេចក្ដីទុក្ខ មានពិតប្រាកដ តែគ្មាននរណាមួយដល់នូវទុក្ខ ។

ទី ២ — ការកោ ន កិរិយា វ វិជ្ជតិ អ្នកធ្វើគឺតណ្ហា មានពិតប្រាកដ តែកិរិយាគឺអំពើរមែងមិនមាន ។

ទី ៣- អត្ថិ និព្វុតិ ន និព្វុតោ ពុមា សេចក្ដីរលត់គឺព្រះនិព្វាន មានពិតប្រាកដ តែបុរសបុគ្គលអ្នកដល់នូវសេចក្ដីរលត់ រមែងមិនមាន ។

ទី ៤- មគ្គមត្ថិ គមកោ ន វិជ្ជតិ មគ្គមានពិតប្រាកដ តែគ្មានបុគ្គលអ្នកដើរ ។ នឹងអធិប្បាយតាមលំដាប់អរិយសច្ចដោយសង្ខេបដូចតទៅ ពាក្យថា ទុក្ខ ១ ជាធម្មជាតមួយគ្រាន់តែជានាមធម៌ គឺមានតែឈ្មោះឥតមានរូប ពណ៌ សណ្ឋាន ឬក្លិនយ៉ាងណាៗទេ នឹងមើល

ដោយភ្នែក ឬស្ទាបពាល់ដោយដៃ ក៏មិនឃើញមិនប្រែះ តែជារបស់មានពិសដ៏ក្លាខ្លាំងបំផុត អាចរុកទន្ទ្រានរឹបជាន់ យាយីបំផ្លាញ ពួកមនុស្សសត្វឲ្យប្រែះវេទនាខ្លោចផ្សាទន្ទឹះផ្អុកផ្អះពល់ៗជាតិ ។

ទុក្ខំ នេះ មកអំពីស័ព្ទដើមថា ទុ ប្រែថា គួរខ្ពើម គួរធុញទ្រាន់ គួរស្អប់ ឬថា អាក្រក់ ខំ ប្រែថា ទទេ ថាសូន្យ រួមទៅជា ទុខំ ដម្រួត អក្សរ ក មកទៀត ទៅជា ទុក្ខំ ប្រែរួបរួមថា គួរខ្ពើមរបស់ដែលទទេ ឬថាទទេសោះ តែជារបស់គួរខ្ពើម គឺរបស់អាក្រក់នេះ ស្រាប់តែធ្លាក់មកប៉ះពាល់ដល់កាយនិងចិត្តតែម្តង នឹងចាប់កើបចេញក៏មិនកើត មួយទៀត ទុក្ខំ នេះ ប្រែថា អត់ធន់បានដោយលំបាក អត់ទ្រាំបានដោយក្រ ឬថា ដកគាស់ចេញបានដោយលំបាក ថាគេចវៀះចេញបានដោយក្រ ។ ទុក្ខំ នេះតែងកើតលូតលាស់នៅក្នុងបញ្ចក្ខន្ធជាធម្មតា មានបញ្ចក្ខន្ធជាដែនកើតនៃទុក្ខ ដូចផែនដីជាដែនកើតនៃរុក្ខជាតិ ។

សេចក្តីទុក្ខនេះ មានន័យច្រើនយ៉ាង ចួនកាល លោកសំដែងអំពីទុក្ខ ៤ កង ចួនកាល ១២ កង ចួនកាល ៧ កង ក្នុងទីនេះនឹងសំដែងចំពោះទុក្ខ ៧ កង គឺ

ទី ១– ទុក្ខទុក្ខំ ទុក្ខយ៉ាងក្រៃលែងគឺទុក្ខត្រួតលើទុក្ខ ដូចរូបកាយដែលកើតមកនេះរាប់ថាជាទុក្ខមួយហើយ ៗ ថែមទាំងវិកលវិការមានខ្វាក់ខ្វិនជាដើម ឬកើតរោគបួសបមតមរមាស់ ក្អក រីងរៃ ក្នុងកាយថែមទៀត ។

ទី ២ – វិបរិណាមទុក្ខំ ទុក្ខព្រោះព្រាត់ប្រាសនិរាសចាកមាតាបិតា មិត្តសំឡាញ់ សត្វសង្ខារ ជាទីស្រឡាញ់ ជាទីពេញចិត្តគ្រប់ហើង ។

ទី ៣ – សង្ខារទុក្ខំ ទុក្ខព្រោះសង្ខារដែលត្រូវទទួលគ្រោះថ្នាក់ម្ដងៗ ដោយអំណាចផលកម្មបុណ្យបាប តិចច្រើន របស់មនុស្សសត្វ ។

ទី ៤ – បដិច្ឆន្នទុក្ខំ ទុក្ខដែលកំបាំងអំពីភ្នែកត្រចៀកអ្នកឯទៀត គឺទុក្ខដែលស្ថិតនៅក្នុងចិត្ត គ្រាន់តែក្ដួលក្ដៅ ធំនៅខាងក្នុងសន្ដាន ។

ទី ៥ – អប្បដិច្ឆន្នទុក្ខំ ទុក្ខដែលមិនកំបាំង បានដល់ទុក្ខដែលឃើញធ្លុះចេញមកប្រាកដដល់អាការខាងក្រៅ មិនបាច់សួរក៏អាចដឹងបាន ។

ទី ៦ – បរិយាយទុក្ខំ ទុក្ខដែលស្រាលៗកើតអំពីសម្ផ្លានពេកផ្សេងៗនៅល្មមព្យាបាលដោយថ្នាំ ឲ្យជាសះស្បើយទៅបាន ។

ទី ៧ – និប្បរិយាយទុក្ខំ ទុក្ខដែលធ្ងន់ធ្ងរជាបន្ទាំង ផុតផ្លូវព្យាបាល ទោះបីរកគ្រូពេទ្យពូកែមកកែខៃដាក់ថ្នាំឱសថវិសេសយ៉ាងណា ក៏មិនអាចនឹងធូរស្រាកស្រាន្ត ជាឡើងបាន ។

បណ្ដាទុក្ខទាំងនេះ ទុក្ខណាមួយ រមែងមានពិតប្រាកដដល់ពួកសត្វ ។ ត្រង់ដែលថា គ្មាននរណាមួយដល់នូវទុក្ខ នោះគឺថាមិនសូវមានអ្នកណាដឹងច្បាស់ ឃើញច្បាស់ ដោយបញ្ញាចក្ខុឡើយ ។ អធិប្បាយនេះជាទុក្ខសច្ច ។

ពាក្យថា តណ្ហា ប្រែថា ប្រាថ្នាជាប់មិនដាច់ ថាញាប់ញ័រ ថាអន្ទះសា ថា ធ្ងធ្ងាសស្ទើតស្ទក់ ថារទះរទោតកាតអាត ថាត្រអាលទៅក្នុងអារម្មណ៍ ៗ ធម្មជាតិតណ្ហានេះតែងផ្សាយចេញទៅប៉ះពាល់នឹងអាយតនខាងក្រៅមានរូបាយតនជាដើមជារឿយ ៗ តណ្ហានេះកាលកើតឡើងព្រោះអាស្រ័យរូប ហៅថា រូបតណ្ហា គ្រប់អាយតនទាំង ៦ ព្រោះថា អាយតនខាងក្រៅនោះឯងជាឈ្នួន នាំឲ្យតណ្ហាមានកំឡាំងក្លៀវក្លា ៗ តណ្ហាបើប្រមូលដោយខ្លីមាន ៣ យ៉ាងគឺ កាមតណ្ហា ប្រាថ្នាត្រអាលទៅក្នុងកាមភពដោយអំណាចកិលេសកាម គឺ រាគ លោភ ឥច្ឆា ឥស្សា អរតិ អសន្តុដ្ឋិ ត្រអាលទៅក្នុងវត្ថុកាម គឺរូប សទ្ទ គន្ធ រស ផោដ្ឋព្វ ១ ភវតណ្ហា ត្រអាលទៅក្នុងរូបភពដោយអំណាចរូបាវចរចេតនា ១ វិភវតណ្ហា ត្រអាលទៅក្នុងអរូបភព ដោយអំណាចអរូបាវចរចេតនា ១ ៗ តណ្ហាទាំងនេះ តែងដឹកនាំសត្វឲ្យអន្ទោលយោនយកកំណើតក្នុងភពថ្មី ប្រកបដោយនន្ទិរាគ ត្រេកត្រអាលទៅក្នុងអារម្មណ៍នោះ ៗ ជាធម្មតា ជាមូលហេតុជាដែនកើតនៃទុក្ខ ៗ តណ្ហាមានពិតប្រាកដក្នុងសន្តានសត្វ ៗ កិលេសធម៌ទាំងឡាយរមែងកើតឡើងព្រោះមានតណ្ហានេះ ជាឫសគល់ ដូចក្នុង នវកង្គុត្តរនិបាត មានសំដែងថា ឫសគល់នៃតណ្ហានេះ មាន ៩ យ៉ាង គឺ តណ្ហាជាបច្ច័យឲ្យស្វះស្វែងរក ១ ការស្វះស្វែងរកជាបច្ច័យ

ឲ្យបានលាភ ១ ការបានលាភជាបច្ច័យឲ្យរិះគិត ១ ការរិះគិតជាបច្ច័យឲ្យកើតឆន្ទរាគ ១ កើតឆន្ទរាគឡើងជាបច្ច័យឲ្យស្រវឹងជ្រុលជ្រប់ ១ ការស្រវឹងជ្រប់ជាបច្ច័យឲ្យហួងហែងទុក ១ ការហួងហែងទុកជាបច្ច័យឲ្យមានសេចក្ដីកំណាញ់ ១ សេចក្ដីកំណាញ់ជាបច្ច័យឲ្យកើតអធិករណ៍ ព្រោះការរក្សាទុកជាហេតុ ១ ពួកអកុសលដ៏លាមក មានកាន់ដម្បងសស្ត្រាវុធឈ្លោះទាស់ទែងញុះញង់ថាអញឯង ក៏រមែងកើតឡើងព្រម ១ ។ ត្រង់ដែលថា កិរិយាគឺអំពើ រមែងមិនមាននោះបានសេចក្ដីថា មិនសូវមានអ្នកណាព្យាយាមធ្វើវត្តប្រតិបត្តិឲ្យតឹងយ៉ាងៗក្រិដ្ឋ ដើម្បីលះបង់តណ្ហានោះចេញ ច្រើនតែបណ្ដោយឲ្យតណ្ហាគ្របសង្កត់ សុខចិត្តឲ្យខ្លួនជាប់នៅជាទាសកម្មករបំរើរបស់តណ្ហាជាធម្មតា ។ អធិប្បាយនេះជាសមុទយសច្ច ។

ពាក្យថា និព្វាន ប្រែថា អស់គ្រឿងជាក់ដោត ថាអស់គ្រឿងរួបរឹត ឬថារលត់កិលេសនិងទុក្ខសូន្យឈឹង ត្រង់ដែលថាសេចក្ដីរលត់គឺព្រះនិព្វាន មានពិតប្រាកដ តែគ្មានបុរសបុគ្គលអ្នកដល់នូវសេចក្ដីរលត់ទុក្ខនោះ បានសេចក្ដីថាបណ្ដាមនុស្សបុថុជ្ជនដែលកើតមករស់នៅមីដេរដាស មិនសូវមានអ្នកណាស្គាល់ច្បាស់ឃើញច្បាស់នូវព្រះនិព្វានដោយប្រាជ្ញាដ៏វិសេសឡើយ ច្រើនតែរស់នៅដោយសេចក្ដីប្រមាទ ។ ព្រះនិព្វានជាគុណជាតស្ងប់ស្ងាត់ចាកទុក្ខភ័យគ្រប់យ៉ាង ព្រះនិព្វានជា

សុខយ៉ាងវិសេសគ្មានសេចក្ដីសុខដទៃប្រៀបផ្ទឹមបាន ជាធម៌ស្ងាត់កំបាំងអំពីគំនិតប្រាជ្ញារបស់មនុស្សសាមញ្ញ នឹងមើលដោយមំសចក្ខុក៏មិនឃើញ ឬនឹងពិចារណាមើលដោយបញ្ញាចក្ខុជាលោកិយ ក៏កម្រនឹងឃើញច្បាស់បាន ។ មនុស្សអ្នកមានប្រាជ្ញាថ្លៃថ្លាដែលពិចារណាឃើញច្បាស់ ធ្វើឲ្យជាក់ច្បាស់បានចូលទៅកាន់ព្រះនិព្វាននោះ ក៏មានប្រមាណតិចណាស់ មនុស្សសត្វដែលសល់នៅជាពាលភាព បុថុជ្ជននោះច្រើនក្រៃលែង ។ អធិប្បាយនេះ ជានិរោធសច្ច ។

ពាក្យថា មគ្គ ប្រែថា ផ្លូវ (ដែលសម្រាប់ដើរដោយជើងក៏បាន ផ្លូវធម៌ផ្លូវវិន័យក៏បាន) តែក្នុងទីនេះ សំដៅយកផ្លូវធម៌វិន័យ មួយទៀត មគ្គ នេះ ប្រែថា ឧបាយសម្រាប់សម្លាប់កិលេស ឬថា ឧបាយសម្រាប់ស្វែងរកផ្លូវព្រះនិព្វាន រួមសេចក្ដីក៏គឺអដ្ឋង្គិកមគ្គ (មគ្គប្រកបដោយអង្គ ៨ ប្រការ) មានសម្មាទិដ្ឋិជាដើមនោះឯង ។

ត្រង់ដែលថា មគ្គ មានពិតប្រាកដ តែគ្មានបុគ្គលណាដើរនោះសេចក្ដីថា អដ្ឋង្គិកមគ្គជាផ្លូវប្រតិបត្តិយ៉ាងកណ្ដាល ធ្វើដំណើរឲ្យលឿនត្រង់ទៅកាន់ព្រះនិព្វាននោះ មាននៅប្រាកដដូចដើម ឥតមានសាបសូន្យបាត់បង់ទៅណាឡើយ ទាស់តែមិនសូវមានមនុស្សអ្នកប្រតិបត្តិឲ្យត្រូវតាមគំរិត គ្រប់គ្រាន់តាមលំដាប់ធម៌នោះៗ ។ អដ្ឋង្គិកមគ្គនេះ ជាមូលហេតុជាដែនហូរមកនៃព្រះនិព្វាន ។ អធិប្បាយនេះជាមគ្គសច្ច ។

អរិយសច្ច ៤ ប្រការដែលព្រះសម្ពុទ្ធត្រាស់ទេសនាមកក្នុងគម្ពីរផ្សេងៗ នោះមានសេចក្ដីដ៏វិចិត្រពិស្ដារជាអនេក ធម៌នេះជាគុណសម្បត្តិយ៉ាងខ្ពស់បំផុត ឬជាជាសារៈយ៉ាងមាំមួន របស់ពុទ្ធសាសនា គឺថាពុទ្ធសាសនានេះឯង មានអរិយសច្ចធម៌ជាគោលធំបណ្ដាច់ ដូចមហាសមុទ្រជាប្រធានរបស់ស្ទឹងបឹងផ្សេងៗ ដែលមាននៅក្នុងលោក ។ ឯសាសនាដទៃៗ ក្រៅពីពុទ្ធសាសនាក៏មិនសូវមាននិយាយអំពីអរិយសច្ចនេះឡើយ ធម៌នេះមានប្រាកដតែក្នុងព្រះពុទ្ធសាសនា ។ អរិយសច្ចធម៌នេះ ព្រះអង្គតែងទេសនាជាញឹកញាប់ជាងធម៌ឯទៀតៗ តាំងអំពីបឋមពោធិកាលទ្រង់សំដែងប្រោសបញ្ចវគ្គិយភិក្ខុជាដើម រហូតដល់មជ្ឈិមពោធិកាល បច្ឆិមពោធិកាល ទោះបីទេសនាធម៌ណាមួយ ក្រៅពីនេះ លុះដល់ទីបំផុតខាងចុងជិតបញ្ចប់ ក៏ច្រើនតែលើកយកអរិយសច្ចធម៌មកប្រកាសទេសនាបន្ថែមសម្រេចជាខាងក្រោយមិនដែលខាន ។

ពណ៌នាអំពីពុទ្ធគាថាប្រកាសអរិយសច្ច សន្មតថាចប់ដោយសង្ខេបប៉ុណ្ណេះ ។

អាចារ្យ ហាយ (សុវណ្ណញាណ) ក្រុមជំនុំព្រះត្រៃបិដក

ក្នុងពុទ្ធសាសនបណ្ឌិត្យ ព្រះរាជបណ្ណាល័យ ក្រុងភ្នំពេញ

ប្រែនឹងរៀបរៀងជាសេចក្ដីអធិប្បាយ ។

ព. ស. ២៤៨១ ។

ហិតោបទេស ភាគទី ១

# “ការបងមិត្រ”

ឧកញ៉ាទេពពិទូរ ក្រសេម គន្ធរបតបណ្ឌិត

ប្រែនិងរៀបរៀង (ត)-

ហារណ្យកៈ អភិប្រាយថា -

១០៤ ធ្មេញ សក់ ក្រចក និងមនុស្ស ត្រូវដកចេញ ចាកទីដ៏សមគួរហើយ មិនល្អ ; អ្នកប្រាជ្ញជ្រាបខនេះជាក់ច្បាស់ហើយ ទើបមិនគួរលះបង់ទីលំនៅរបស់ខ្លួន ។

ក្អែកបដិសេធថា សំឡាញ់អើយ ! ហ្នឹងជាពាក្យរបស់មនុស្ស កំសាក ព្រោះ -

១០៥ ធម្មតា កេសររាជសីហ៍, សប្បុរសនិងដំរីសារ រមែងលះបង់ទីលំនៅ (ដែលមិនស្រួលដល់ខ្លួន) ទៅនៅទីដទៃ ; ចំពូកសត្វក្អែក អ្នកខ្លាចច្រើន ម្រឹគឈ្លោល ច្រើន នៅឲ្យស្លាប់ក្នុងទីមួយកន្លែងនោះឯង ។

១០៦ អ្នកក្លាហាន មានចិត្តដាច់ ទោះនៅក្នុងប្រទេសរបស់ខ្លួន ឬក្នុងប្រទេសណា ក៏ឥតមានប្លែកអ្វី, ព្រោះនឹងទៅប្រទេសណា នឹងនៅជាប់ក្នុងប្រទេសនោះក៏បាន ដោយអំណាចកំលាំងរបស់ខ្លួន, រាជសីហ៍នៅក្នុងព្រៃណាក៏ប្រើចង្កូម ក្រចក និងកន្ទុយជាគ្រឿងអាវុធអាចស្រូបលោហិតដំរីសារដែលខ្លាចចំប្រប់ កែសេចក្តីស្រេកឃ្លានបានដោយងាយដោយប្រការដូចគ្នានោះ ។

ហិរណ្យកៈសួរថា "យើងនឹងទៅក្នុងទីណា ស្រួល ? ព្រោះលោកថា

១០៧ អ្នកគំនិតល្អិត នឹងឈានដើរទៅ ក៏ឈានតែជើង
ម្ខាងទៅសិន ម្ខាងទៀតជាន់ទុកនៅទីដើម កាលមិនទាន់
បានត្រួតត្រាមើលទីដទៃ (ឲ្យសព្វគ្រប់) ក៏មិនហ៊ានលះទី
ដើមនៅតែម្ដង ។

ក្អែកតបថា សំឡាញ់ មានទីដែលបានពិនិត្យរួចហើយ ១ កន្លែង ខ្ញុំជានាំនឹងនាំទៅ ។ ហិរណ្យកៈបញ្ជាក់ថា តំបន់ដែលនិយាយនេះនៅឯណា ? ក្អែកដំណាលប្រាប់ថា នៅព្រៃទណ្ឌកៈមានបឹងឈ្មោះករបូរគោរៈ នៅទីជិតបឹងនោះ អណ្ដើកឈ្មោះមន្ថរៈ សំឡាញ់ចាស់របស់ខ្ញុំអាស្រ័យនៅជាអ្នកប្រព្រឹត្តក្នុងធម៌ជាប្រក្រតី ព្រោះ–

១០៨ ការប្រដៅតាមគោលអ្នកប្រាជ្ញឲ្យអ្នកដទៃជាការងាយ
ពល់រូប តែត្រង់ប្រព្រឹត្តធម៌ដោយខ្លួនឯងបាន មានតែ
អ្នកជាមហាត្ម័ខមន្ថរៈសំឡាញ់របស់ខ្ញុំគង់ទទួលរ៉ាប់រងយ៉ាង
ស្រួល ដោយអាហារយ៉ាងឆ្ងាញ់ពីសា ។

ហិរណ្យកៈថា សំឡាញ់ កាលបើដូច្នោះខ្ញុំនឹងទៅដូចម្ដេចបាន ព្រោះ–

១០៩ ប្រទេសណាខ្វះទីពឹងអាង ខ្វះផ្លូវប្រកបការអា-
ជីវៈ ឬខ្វះមិត្រសំឡាញ់ ឬខ្វះវិជ្ជាគម (សេចក្តីចំរើន
ក្នុងវិជ្ជា) បុគ្គលគួរវៀរប្រទេសនោះបង់ ។

១១០ អង្គគុណ ៥ ប្រការ គឺ អ្នកមានទ្រព្យសម្បូណ៌ ១
ជីព្រាហ្មណ៍ ១ ព្រះរាជា ១ មេទឹក ១ នឹងពេទ្យ ១ ទាំង ៥ នេះ
គ្មានក្នុងទីណា មិនគួរនឹងតាំងគេហស្ថាននៅទីនោះ ។

១១១ ទីណា ខ្វះសម្បត្តិ ៥ ប្រការ គឺ ការរកស៊ី ១ ទី
កោតក្រែង ១ ទីអៀនខ្មាស ១ សេចក្តីមានចិត្ត ១ សេចក្តី
អើពើចែកចាយ ១ ក្នុងទីនោះបុគ្គលមិនគួរតាំងភូមិលំនៅ
នៅទេ ។

១១២ អ្នកឲ្យខ្ចី ១ ពេទ្យ ១ ជីព្រាហ្មណ៍ ១ មេទឹក
ដែលមានទឹកសាបល្អ ១ ទាំង ៤ នេះ ក្នុងទីណាខ្វះមិន
គួរសំណាក់នៅក្នុងទីនោះជាដាច់ខាត ហេតុនេះសំឡាញ់
ត្រូវនាំខ្ញុំទៅផង ។

ក្អែកតបថា “បាន” ហើយក៏នាំផ្លូវចេញជាមួយនឹងសំឡាញ់ ដើរ
បណ្តើរ និយាយសន្ទនាគ្នាបណ្តើរដោយរឿងផ្សេងៗ យ៉ាងសម្រាន្តចិត្ត
ដរាបមកដល់ជិតបឹង ។ ចំណែកអណ្តើកមន្ថរៈឃើញក្អែកអំពីចម្ងាយ

ក៏ចេញទៅអញ្ជើញក្អែកតាមឋានដ៏គួរ នឹងទទួលបដិសណ្ឋារៈតាមមុខការ នៃអ្នកម្ចាស់លំនៅផង ព្រោះ-

១១៣ អគ្គិ ជាគ្រូរបស់ទ្វិជាតិ (ព្រាហ្មណ) ព្រាហ្មណ៍ជាគ្រូរបស់វណ្ណៈទាំងឡាយ ស្វាមីជាគ្រូរបស់ភរិយា តែថាភ្ញៀវដែលមកនេះជាគិត្តិយសដោយឡែក ព្រោះថាមូសិកពជឈ្មោះហិរណ្យកៈ ជារតនាករអន្ទង់សមុទ្រនៃសេចក្តីករុណា ជាកំពូលអ្នកប្រព្រឹត្តការបុណ្យ សូម្បីស្តេចនាគពជដែលមានអណ្តាតដល់ទៅ ២.០០០ នឹងពោលសរសើរគុណនៃអ្នកនេះមិនអស់" ពោលដូច្នេះទើបនិយាយដំណាលរឿងចិត្រគ្រីវៈស្តេចព្រាបឲ្យស្តាប់ ។

មន្ថរៈក៏សំដែងសេចក្តីគោរពហិរណ្យកៈយ៉ាងខ្ពស់, ដណ្តឹងសួរថា ម្នាលអ្នកដ៏ចំរើន សូមប្រាប់ខ្ញុំឲ្យបានដឹង ហេតុម្តេចអ្នកទើបអាស្រ័យនៅក្នុងព្រៃស្ងាត់កណ្តៀងកណ្តោចដូច្នេះ,, ។

ហិរណ្យកៈតបថា ខ្ញុំនឹងសំដែងហេតុ សុំឲ្យអ្នកស្តាប់ដូចមានតទៅនេះ:

## រឿងទី ៥

បរិព្វាជកមួយពួកនៅក្នុងនគរចម្បកៈ បរិព្វាជកម្នាក់ឈ្មោះចូឌាកណ៌ អាស្រ័យនៅក្នុងនគរនោះ កាលបរិព្វាជកនោះត្រេចភិក្ខាចារបានអាហារ

មកបរិភោគរួចហើយ ក៏លើកបាត្រព្រះនៅដៃកែវ ហើយក៏ចូលដេកជារៀងរាល់ថ្ងៃ ខ្ញុំឯងធ្លាប់លោភទៀងទៅស៊ីអាហារជានិច្ច នាថ្ងៃមួយមានបរិញ្ញាជកម្នាក់ឈ្មោះវីណាកណ្ណិ ជាមិត្រសំឡាញមកសួរសុខទុក្ខ វេលាដែលកំពុងសន្ទនាគ្នាដោយរឿងផ្សេងៗ ចូឡាកណ្ណិតែងយកឈើគោះដីជាដកបបំណងនឹងឲ្យខ្ញុំខ្លាចរត់ទៅ ។ កាលវីណាកណ្ណិ ឃើញកិរិយាចូឡា-កណ្ណិនៅមិនសុខទើបសួរថា "សំឡាញ់" ហេតុម្ដេចអ្នកមិនតាំងចិត្តស្ដាប់ពាក្យដែលខ្ញុំនិយាយ? មើលទៅដូចជាមានកន្ទួល់អ្វីមួយយ៉ាងព្រោះ —

១១៤ មានមុខញញឹមញញែម នឹងដួងចក្ខុថ្លាស្រឡះ, តាំងចិត្តស្ដាប់ពាក្យសន្ទនា, ពចាពិពេក, ចិត្តអើពើអស់កល, តាំងយកនេមើលជាដកប, អំបាលនេះជាគ្រឿងសំគាល់របស់អ្នកដែលតាំងចិត្តគប់គ្នា ។

១១៥ ធ្វើឲ្យអន់ចិត្ត, រមិលគុណ, ប្រាសចាកសេចក្ដីកប់អាន, ចែចូវសេចក្ដីអាក្រក់, ក្លែបខ្ទូនកាលវេលាសន្ទនាគ្នា អំបាលនេះជាគ្រឿងសំគាល់ នៃអ្នកដែលមិនប្រងនឹងគប់"

ចូឡាកណ្ណិបានស្ដាប់ក៏សំដែងហេតុថា "ម្ដេចខ្ញុំមិនចង់ស្ដាប់អ្នក, មិនឃើញទេឬ? កណ្ដុរនេះវាធ្វើសេចក្ដីវិនាសដល់ខ្ញុំ លួចស៊ីអាហារដែលសល់នៅក្នុងបាត្រជានិច្ច ។

វីណាកណ្ណិ ទើបចូលទៅពិចារណាមើលទីដៃកែវ ក្នាន់និយាយ (ដោយសេចក្តីអស្ចារ្យក្នុងចិត្ត) ថា កណ្តុរតូចមួយប៉ុណ្ណេះ ម្តេចទើបហ៊ានលោតឡើងខ្ពស់ដល់ម្ល៉េះ គង់មានហេតុអ្វីនៅនោះ ព្រោះលោកតែងអាចថា —

១១៦ ករិយាក្រមុំធ្វើកិរិយាថៃថើប ប្រួតសក់, ឱបតែនូវស្វាមីចាស់ជរា មាន ឡើងក្នុងកាលណា រមែងមានហេតុនិមួយក្នុង នោះជាប្រាកដ ។

ចូឡាកណ្ណិសួរថា ដែលនិយាយនេះមានរឿងមកដូចម្តេច?" វីណាកណ្ណិទើបដំណាលថា :

## រឿងទី ៦

ក្នុងប្រទេសគៅឌី (វង្គប្រទេស) មាននគរឈ្មោះគៅសាម្ពី មានសេដ្ឋីម្នាក់ឈ្មោះចន្ទទាសនៅក្នុងនគរនេះ មានអាយុចាស់ចូលក្នុងបច្ឆិមវ័យ តែជាអ្នកលោភក្នុងកាមគុណ អាស្រ័យហេតុដែលមានសម្បត្តិ ទើបបាននាងក្រមុំលីលាវតីបុត្រីពាណិជម្នាក់ជាភរិយា, តែនាងលីលាវតីកំពុងពេញក្រមុំដូចទង់របស់កាមទេព(១) (ព្រោះហេតុនោះ) កាលមកបានប្តីជរា ទើបមិនមានសេចក្តីពេញចិត្ត, ព្រោះ —

(១) ល្អ ។

១១៧ ពន្លឺព្រះចន្ទមិនជាទីត្រេកអររបស់អ្នករងា, រស្មីព្រះអាទិត្យ មិនជាទីត្រេកអររបស់អ្នកក្តៅ, ស្វាមីដែលមានឥន្ទ្រិយគ្រាំគ្រាដោយជរាភាព រមែងមិនជាទីត្រេកអររបស់ស្ត្រី ។

១១៨ ប្រុសដែលមានសក់ស្កូវប្រាកដឡើងហើយ សេចក្តីស្រឡាញ់របស់ស្ត្រី (ដ៏ជាភរិយា) ក៏នឹងមានមួយប៉ុន្មាន, ព្រោះស្ត្រីដែលមានចិត្តប៉ុនប៉ងនូវប្រុសដទៃហើយ ត្រឡប់ឃើញស្វាមីរបស់ខ្លួនបីដូចជាភេសជ្ជៈ (កាលមិនទាន់ទំនាល់មែនទែន អ្នកណាខ្វះនឹងចង់សេព) ។

តែជួយគ្នាទៅវិញ ចំណែកប្តីចាស់រមែងស្រឡាញ់ប្រពន្ធក្មេងយ៉ាងបំផុតចិត្ត ព្រោះ –

១១៩ សេចក្តីប៉ងសម្បត្តិ នឹងសេចក្តីប៉ងក្នុងជីវិតជារបស់សំខាន់ រមែងមានគ្រប់រូប, តែឯប្រពន្ធក្មេងជារបស់សំខាន់របស់ប្តីចាស់ក្រៃលែងជីវិត ។

# រឿងព្រេង - អំពីបុរសទៅរៀនសិល្ប

មាននិទានមួយថាមានបុរសបួននាក់ទៅរករៀនសិល្បសាស្ត្រដល់តក្កសិលាមហានគរ រៀនសិល្បសាស្ត្រនោះហើយលាគ្រូដើរមកដល់កណ្ដាលផ្លូវបុរសទាំងបួននោះយល់ទឹកល្អពុំដឹងជាទឹកនោះមានពិសឡើយ បុរសទាំងបួនក៏យកទឹកនោះលុបមុខមាត់ បុរសទាំងបួននោះក៏ខ្វាក់ភ្នែកអស់ទឹងដើរក៏ពុំបានដល់ទៅលំនៅអាត្មាឯងទីទៃ ៗ ឡើយ ឯបុរសមួយថាយើងងងឹតអស់ទាំងបួននាក់ហើយតើ ធ្វើម្ដេចក៏នឹងបានអាហារស៊ី ឯបុរសមួយឆ្លើយថា នាកាលអញក្ដីអញយល់ព្រះច្បារឧទ្យាន របស់អ្នកស្ដេចមួយអន្លើនោះមានស្វាយផ្លែ ឯបុរសមួយថាបើទៅដឹងព្រះច្បារឧទ្យាននៅត្រង់ឯណាជាក់ហើយ យើងនាំគ្នាសំដៅទៅត្រង់នោះ ឯបុរសមួយឆ្លើយថា បើទៅយល់ស្វាយនោះ អញសោតបានយល់ស្វាយនោះផង មានផ្លែតែមែកមួយ ឯបុរសមួយឆ្លើយវិញថា បើទៅយល់មែកស្វាយមានផ្លែមែនពិតទុកងារអញនឹងពោលឲ្យជ្រុះផ្លែស្វាយនោះចុះ ឯបុរសមួយឆ្លើយឡើងថា លែងតែទៅពោលឲ្យជ្រុះចុះ អញនឹងទទួលផ្លែស្វាយនោះឲ្យបាន បុរសខ្វាក់ទាំងបួននោះសឹងគិតចូលចិត្តព្រមគ្នាទៅវិញទៅមកហើយបណ្ដើរគ្នាទៅរក ឃើញស្វាយនោះក្នុងឧទ្យានសម្ដេចព្រះមហាក្សត្រនោះមែនហើយ ទើបបុរសមួយពោលឡើង ត្រូវ

ផ្លែស្វាយជ្រុះចុះ ឯបុរសមួយទទួលចាប់បានផ្លែស្វាយនោះពុំឲ្យជ្រុះដល់ដីឡើយ ម៉្លោះហើយទឹកស្វាយខ្លាយត្រូវបុរសទាំងបួននោះពិសក៏ជ្រុះស្រឡះចេញអំពីក្អកៗបុរសទាំងបួននោះប្រែជាក្អួដូចប្រក្រតី កាលខ្លួនកំឡោះហោង ។ បុរសទាំងបួនក៏ក្អកបានយល់ផ្លែស្វាយនោះហើយ ទើបបុរសនោះដណ្ដើមផ្លែស្វាយគ្នា ទើបនាំគ្នាទៅប្ដឹងចៅក្រមដោយដំណើរទើងៗ ចៅក្រមទឹងពិចារណាកាត់អាស្រេចក្តីឲ្យបុរសទាំងបួននោះពុំបានឡើយ ទើបចៅក្រមនាំបុរសទាំងបួនឡើងក្រាបទូលសម្ដេចព្រះមហាក្សត្រទូលដោយនូវដំណើរសេចក្ដី ទើបព្រះអង្គទ្រង់ព្រះចិន្ដាពិចារណាដោយព្រះប្រាជ្ញាឈ្វេងយល់គន្ធព្រះរាជហឫទ័យ ទើបព្រះអង្គមានព្រះបន្ទូលត្រាស់ថា នាប្រែស្តុងទទួលផ្លែស្វាយបាននោះឲ្យមួយចម្អៀង ឯប្រែស្ដុងទាំងបីនោះដ្បិតពុំបានទទួលផ្លែស្វាយនោះឲ្យបានមួយចម្អៀងបីនាក់ នាបុរសបានមួយចម្អៀងម្នាក់ឯងនោះហេតុតែទទួលចាប់បានផ្លែស្វាយនោះហោង រីឯបុរសទាំងបួនចូលចិត្តហើយ ព្រមគ្នាទទូលព្រះបន្ទូលមហាក្សត្រទ្រង់បង្គាប់ បានយកផ្លែស្វាយស៊ីស្រេចហើយ ក្រាបលាព្រះមហាក្សត្រដើរទៅ ។ បុរសមួយឃើញកំណប់មាសទើបនាំគ្នាជីកកំណប់នោះទាំងបួននាក់បានហើយស្រដីប្រកែកគ្នាថា អញជីកលើសទៅទាំងបី បុរសមួយថា

អញតើមិនព្រមផង ឯបុរសថារឹងទៅចៅទាំងបី ឯអញសោកសឹងព្រម ផងគ្នាដូចដែល ឯបុរសមួយឆ្លើយថា ព្រមនោះក៏អញព្រមលើស ដ្បិតអ្វី អញថាដូច្នេះនោះ អញយល់កំណប់នោះជាដើមហើយអញព្រមជួយជីក យកមាសនេះផងគួរអញបានលើស ៗ បុរសទាំងបួនស្រដីរកទទឹងគ្នាពុំ ហើយពាក្យប្រកែកនោះឡើយ ទើបនាំគ្នាទៅដល់ចៅក្រមប្តឹងដោយនូវ ដំណើរទាំង ៗ នោះនឹងបង្គាប់ចែកឲ្យបានដូចចិត្តព្រមនឹងគ្នានោះយល់ជា ពុំបានឡើយ ទើបចៅក្រមនាំបុរសទាំងបួនឡើងទៅក្រាបទូលព្រះមហា-ក្សត្រាធិរាជដោយនូវដំណើរ ទើបទ្រង់ព្រះចិន្តាពិចារណាឈ្វេងយល់ ដោយដំណើរសេចក្តីបុរសទាំងបួននោះហើយ ទើបព្រះអង្គមានព្រះបន្ទូល ឲ្យចែកមាសនោះជាបីភាគមួយភាគឲ្យបានអ្នកដ៏យល់ ដ្បិតអ្នកនោះស្លូត សុភាពពុំលាក់នឹងគ្នាឡើយ ឯភាគពីរនោះព្រះអង្គឲ្យចែកបានទៅបុរស ទាំងបីស្មើគ្នាហោង ៗ ឯបុរសទាំងបួននោះចូលចិត្តព្រមទទួលយក ចំណែកមាសនោះដូចព្រះបន្ទូលព្រះមហាក្សត្របង្គាប់ហើយក្រាបលាទៅ លំនៅអាត្មាទាំង ៗ ហោង ៗ ៖ ៚—

# រឿងព្រេង-អំពីបុរសម្នាក់ប្រពន្ធល្អ

ថាមានបុរសម្នាក់មានប្រពន្ធល្អ ទើបនឹងរៀបការថ្មីបណ្ដើរគ្នាទៅ មានកំឡោះពីរនាក់វាឃើញហើយវាស្រឡាញ់ចង់បាន វាគិតថា ធ្វើម្ដេចនឹងបានអេះ ទើបចៅម្នាក់នោះឆ្លើយឡើងថា ងាយទេ ឯងគិតតែទៅរកខ្ចីរទេះគោមកបរ ប៉ុន្តែឯងកុំធ្វើជាស្គាល់អញ បើអញសួរឯងកុំប្រាប់ថារទេះ ឯងប្រាប់ថាចន្ទោលថាទឹមទៅវិញ ទើបបុរសម្នាក់ដើរទៅខ្ចីរទេះគោមកបរ ចួនជាបុរសនោះបណ្ដើរប្រពន្ធដើរមកដល់ ៗ ចៅម្នាក់នោះវាសួរថា អ្នកអញ្ជើញមកអាយ ឈប់និយាយគ្នាលេងបន្តិចសិន បុរសនោះក៏ចូលទៅអង្គុយលេង ដល់ចៅម្នាក់នោះបររទេះមកដល់ វាធ្វើជាសួរថា នេះគេហៅអីអ្នក ៗ បុរសប្ដីប្រពន្ធឆ្លើយប្រាប់មកថា គេហៅរទេះ ថាមែនឬអ្នក បុរសនោះថាមែន បើមែនអ្នកហ៊ានភ្នាល់នឹងយើង ចៅនោះវាថា បើខ្ញុំចាញ់ខ្ញុំព្រមជាខ្ញុំអ្នក បើខ្ញុំឈ្នះអ្នកវិញខ្ញុំសុំតែប្រពន្ធពីអ្នក បុរសនោះគិតថា ប្រាកដជាគេហៅថារទេះមែន នឹងខ្លាចអ្វីក៏ព្រមភ្នាល់នឹងគេ ទើបចៅនោះសួរទៅអ្នកបររទេះ ចង្អុលសួរទៅចន្ទោល ចៅនោះប្រាប់ថា នេះគេហៅចន្ទោល ចង្អុលសួរទៅទឹមថា នេះគេហៅទឹម នេះគេហៅទូក នេះគេហៅទ្រាយ នេះគេហៅប្រែក នេះគេហៅកង់ នេះគេហៅធ្នង់ នេះគេហៅត្រពង ដល់ឆ្លើយរួចសព្វគ្រប់ ៗ បុរសនោះសួរទៅបុរសប្ដីនឹង

ប្រពន្ធនោះថា ឥឡូវគេថា មិនមែនហៅរេះទេ បើដូច្នេះតើអ្នកឯងនឹងព្រមចាញ់យើងឲ្យប្រពន្ធមកយើងប្ដូរម្ដេច បុរសប្ដីប្រពន្ធនោះមិនព្រមដល់ប្រកែកទៅមិនឈ្នះគេ ៗ ដណ្ដើមយកប្រពន្ធទៅបាន បុរសនោះមិនសុខចិត្តទៅប្ដឹងចៅក្រម ៗ ឲ្យទៅកោះហៅទាំងពីរនាក់នោះមកជំនុំ ហៅទាំងពីរនាក់នោះរសួកចៅក្រម ទើបចៅក្រមកាត់សេចក្ដីថា ត្រូវចាញ់គេហើយ ត្រូវឲ្យប្រពន្ធនោះទៅគេ ៗ ឯបុរសនោះខឹងណាស់ ដ្បិតគេយកប្រពន្ធទៅបាន ដើរធ្ងន់យំផងទៅបន្តិចទៅប្រទះនឹងសុភាទន្សាយ សុភាទន្សាយសួរថា រាជីក៏យំបង បុរសនោះឆ្លើយប្រាប់តាមដំណើរសព្វគ្រប់ សុភាទន្សាយថា បើដូច្នោះបងឯងកុំភ័យរកតែចេកឲ្យយើងស៊ី យើងទៅជួយជំនុំឲ្យបានប្រពន្ធមកវិញ ចៅនោះអរណាស់ ខំទៅរកចេកមកឲ្យសុភាទន្សាយ ៗ ស៊ីចេករួចហើយដើរទៅជាមួយនឹងបុរសនោះ ទៅដល់សួរទៅចៅក្រម ៗ ឆ្លើយប្រាប់តាមដំណើរសព្វគ្រប់ ទើបសុភាទន្សាយថាលោកកាត់សេចក្ដីនេះមិនទាន់អស់ទេ បើដូច្នេះខ្ញុំសូមកាត់សេចក្ដីនេះផងឲ្យសុខចិត្តទាំងសងខាង ទើបសុភាទន្សាយសួរទៅបុរសដែលយកប្រពន្ធគេទៅនោះថា អ្នកឯងទាំងពីរនាក់ កាលភ្នាល់គ្នាថាដាក់អ្វី ទើបចៅនោះឆ្លើយឡើងថា ដាក់ប្រពន្ធ សុភាទន្សាយសួរទៅត្រង់ណាហៅប្រពន្ធបើអ្នកឯងរកឃើញយកទៅចុះ បើរកមិនឃើញទេឲ្យទាំងនោះមកគេវិញ

ឯបុរសនោះចាប់ទៅត្រង់ដៃ សុភាទន្សាយប្រាប់ថា នេះគេហៅដៃទេ ចាប់ទៅជើង នេះគេហៅជើងទេ ចាប់ត្រង់ណោះ ថាមិនមែន ត្រង់ណោះ ថាមិនមែន ថាទាំងអស់នេះឯងគេហៅប្រពន្ធ សុភាទន្សាយថា រវេះក៏ដូចគ្នា គេហៅចន្ទោលទឹមទូកទ្រាយ ប្រែកន្ទង់កង់ត្រពងទាំងអស់នេះ ថារវេះ ឯងយកប្រពន្ធគេមិនបានទេ ឲ្យមកគេវិញ សុភាទន្សាយឲ្យចៅនោះយកប្រពន្ធមកវិញ សុភាទន្សាយថា លោកចៅក្រមកាត់សេចក្ដីស៊ីតែសំណូកគេ កាត់សេចក្ដីគ្មានត្រង់តាមព្រះច្បាប់ ឯចៅនោះបានប្រពន្ធមកវិញក៏អរណាស់ លើកដៃសំពះទៅសុភាទន្សាយថា លោកកាត់សេចក្ដីនេះពេញហៅត្រង់ សូមឲ្យមានបុណ្យសក្ដិអាយុយឺន ។

ចប់រឿងនេះតែប៉ុណ្ណោះហោង ។

លទ្ធិទំនៀមខ្មែរ

# ពិធីសែនខ្មោចមេបាចាស់ទុំ

# ក្នុងវេលាមានជម្ងឺឈឺ ដោយហេតុមានកំលោះក្រមុំ

# សហាយគ្នា

អស់លោកអ្នកមើល បើឃើញទាស់ខុស

សូមអធិប្បាយបំពេញ ហើយបញ្ជូនទៅឲ្យព្រះរាជបណ្ណាល័យផង

សូមអំណរគុណទុកជាមុន

# ទំនៀមសែនខ្មោចមេបាចាស់ទុំ

ក្នុងវេលាមានជំងឺ ដោយហេតុមានកំណោះក្រមុំសហាយគ្នា ។

ខ្មោចមេបានេះទោះខ្លួនទៅជាខ្មោចដូច្នេះហើយ ក៏នៅកាន់តាមទំនៀមទម្លាប់របស់មនុស្សទៀត គឺកាលមានកំលោះក្រមុំ ប្រព្រឹត្តកន្លងចិត្តមាតាបិតា ទៅមានសហាយស្មន់នឹងគ្នា ដោយលួចលាក់ក្តី ឬក៏ស្រីដែលមានប្តីហើយ ប្រព្រឹត្តផិតប្តីទៅមានសហាយស្មន់ក្តី ខ្មោចមេបានឹងខឹងហើយធ្វើឲ្យអ្នកឯណាទីមួយក្នុងវង្សញាតិ ឬធ្វើអ្នកសាមីខ្លួនស្រីនោះឲ្យឈឺឲ្យស្លាប់ទៅក៏មាន ៗ ក្នុងរឿងនេះគេហៅដោយខ្លីថា «មេបាកំលោះក្រមុំ» តែបើស្រីផិតប្តីមានឈ្មោះហៅ ១ យ៉ាងទៀតថា “មេបាព្រនាក់បំពង់” ។ បើស្រីក្រមុំមានសហាយស្មន់ហើយខ្មោចមេបាធ្វើលើរូបនាងនោះឲ្យឈឺ គេហៅថា “មេបាផ្កាប់មុខ” ។

កាលមានជម្ងឺឈឺឡើងហើយគេមិនបានដឹងហេតុជម្ងឺជាក់ច្បាស់ គេរមែងរកគ្រូ-ហោរគន់គូរមើលដូចពោលហើយក្នុងរឿងលៀងអារក្ស តែជួនកាលខ្មោចនោះឯងមកចូលអ្នកជម្ងឺ ប្រាប់ត្រង់ ៗ មកថា អ្នកនេះ នាងនោះសហាយស្មន់នឹងគ្នា ឲ្យទៅយកខ្លួនមកសែនមេបាចាស់ទុំ ។ បើមិនទាន់ដឹងច្បាស់ជារូបណាធ្វើខុសនឹងខ្មោចមេបាទេ នោះអ្នកម្ចាស់ជម្ងឺត្រូវលើកទ្រនឹបផ្សងរកខ្លួនអ្នកធ្វើខុសគឺ :

ស្រូវ ១ កូនល្អី  អង្ករ ១ ចាន  ទៀនស្នែងក្របី ១
ពងមាន់ ១  ខ្សែបំណង ១ ។
តែក្បួនខ្លះថា  ស្រូវ ១ កញ្ជើ  អង្ករ ១ ចាន
ទៀន ១ ធូប ១ ខ្សុក  សំពត់ស ១ អាវ
កន្ទុះក្របី ១  កូនពាងតូច ១  ចង្កឹះ១ សម្រាប់
កាំបិត ១ នឹងធ្វើបជ្រូក ១ ។

ឲ្យដាក់សំរែកព្យួរនៅជញ្ជាំងខាងដំណេកអ្នកជម្ងឺ  ហើយបន់សុំឲ្យជម្ងឺនោះបានសះស្បើយទៅ  ៣ ថ្ងៃទៀតទើបបានរៀបសែនមេបាថ្វាយតាមទំនៀម ។ តែកាលទើបបន់នោះ ត្រូវឲ្យបញ្ចេញឈ្មោះប្រុសស្រីដែលខ្លួនសង្ស័យថា សហាយស្មន់នឹងគ្នានោះ បើត្រូវលើឈ្មោះនោះមែន ជម្ងឺទើបបានស្បើយពីថ្ងៃនោះទៅ បើជម្ងឺមិនស្បើយទេ ឲ្យគប្បីនឹករកឈ្មោះដទៃ ៗ ហើយបន់ដូចគ្នានេះតទៅទៀត ត្រាតែជម្ងឺនោះបានគ្រាន់បើ ។

កាលជម្ងឺគ្រាន់បើហើយ ត្រូវរៀបគ្រឿងសំណែនខ្មោចមេបាតទៅ គឺក្បាលជ្រូក ១ មាន់ស្ងោរ ១ គូ ទាស្ងោរ ១ គូ បំអប ១ ចាស បង្អែម ១ ចាស ស្លាត្រួយ ១ ស្លាបារី ៣ ដើមពាន ទឹក ១ ផ្តិល រៀបចំដាក់ថ្វាយ ។

ដល់ថ្ងៃដែលសែន ត្រូវហៅប្រុសស្រីអ្នកសាមីខ្លួន នឹងអញ្ជើញពួកញាតិជិតខាង ៦-៧ នាក់មកជួបជុំផង  អ្នកដើមការយកទៀនធូបអុជទៅ

ហឹង នឹងនៅគ្រឿងចំណាប បន្ថែមអំបាលនោះ ឲ្យប្រុស-ស្រីសាមីខ្លួន ក្រាបសំពះទន្ទឹមគ្នា សូមលន់តួទោសនឹងខ្មោចមេបា ៣ ដង ស្រេចហើយមេបាឬអាណាព្យាបាលខាងស្រី សួរបញ្ជាក់ប្រុសសាមីខ្លួនថា អ្នកសំពះចូលឬសំពះចេញ ខាងប្រុសបើសុខចិត្តយកនាងនោះជាប្រពន្ធគេទៅក៏នឹងតបថា សំពះចូល ៗ បើមិនសុខចិត្តយកក៏នឹងតបថា សំពះចេញ បើគេតបថា សំពះចូល អ្នកខ្លះគេក៏រៀបសែនផ្ដាប់ខ្មោចឲ្យយកគ្នាជាប្ដីប្រពន្ធក្នុងខណៈនោះតែម្ដង អ្នកខ្លះគេបង្គាប់ឲ្យប្រុសរៀបគ្រឿងបណ្ណា-ការរៀបការជាថ្មីទៅថ្ងៃក្រោយក៏មាន ៗ

រឿងខ្មោចមេបានេះបើគេឃើញជម្ងឺនោះអាចជាទៅបាន បើគេមិនឃើញអាចនឹងស្លាប់ក៏បាន ៗ

# ការទទួលអំណរដ៏ពន្លឹក
# បំពោះគណៈស្ត្រីថៃ (សៀម)
# នៅព្រះរាជបណ្ណាល័យ ក្រុងភ្នំពេញ

កាលពីថ្ងៃ ២៤ អ៊ូតឆ្នាំ ១៩៣៩ នេះ បណ្ដាខ្ញុំរាជការនៃព្រះរាជ-បណ្ណាល័យនិងគណៈយុវសាលា បានរៀបចំមន្ទីរព្រះរាជបណ្ណាល័យ ជាឧឡារិក ដើម្បីទទួលអំណរដល់គណៈស្ត្រីថៃមួយពួកដែលមានប្រកាស-នីយប័ត្រចេញអំពីមហាវិទ្យាល័យ នាំគ្នាធ្វើដំណើរមកលេងស្រុកខ្មែរនិងស្រុកយួន ជាការសំដែងមេត្រីចិត្តមិត្តភាពដល់គ្នារវាងគណៈស្ត្រីថៃនិងស្ត្រីនៃក្រុងកម្ពុជា ។ ការទទួលអំណរនៅព្រះរាជបណ្ណាល័យនេះមានពីរលើក គឺលើកដំបូងវេលាព្រឹកទទួលនៅបន្ទប់ក្រមជំនុំព្រះត្រៃបិដក ដោយគណៈស្ត្រីថៃពួកនេះដែលធ្វើដំណើរមកលេងស្រុកអាយមានបំណងនឹងធ្វើការកុសលមួយដល់ព្រះសង្ឃក្រុងកម្ពុជា ទើបដាក់បបំណងរបស់ខ្លួនដល់លោកស្រីការប៉ឺឡែស ៗ ក៏បង្គាប់ទៅពួកខ្ញុំរាជការព្រះរាជបណ្ណាល័យឲ្យចាត់ចែងនិមន្តព្រះសង្ឃទាំងធម្មយុត្តិទាំងមហានិកាយចំនួន៤៣រូប តាមចំ-នួនស្ត្រីថៃមានចំនួន ៤៣ នាក់ទើបមានការរៀបចំក្រាលព្រំបាំងរាំងននជាដើម សម្រាប់ជាអាសនៈសង្ឃគង់ទទួលចង្ហាន់ ៗ លុះដល់ម៉ោង ១០ព្រឹក ព្រះសង្ឃដែលនិមន្តពីវត្តផ្សេង ៗ ក៏បាននិមន្តទៅដល់ព្រះរាជបណ្ណាល័យ

ដល់ម៉ោង ១១ ទើបគណៈស្ត្រីថៃទៅដល់ ហើយនាំគ្នាចាត់ចែងគេនចង្ហាន់សង្ឃដោយពួកក្រុមព្រះរាជបណ្ណាល័យជួយធុរៈឲ្យបានស្រួលសព្វគ្រប់ ។ លុះព្រះសង្ឃធ្វើភត្តកិច្ចរួចហើយអនុមោទនា គណៈស្ត្រីថៃក៏មានចិត្តត្រេកអរកែកយកលុះគ្នាថ្វាយបង្គំលាត្រឡប់ទៅកាន់ទីសំណាក់ឯហោតិលធំវត្តភ្នំវិញ ។

ដល់ម៉ោង ៤ ល្ងាចមានការទទួលជានុឡាកែម្តងទៀតនៅកន្លែងមើលសៀវភៅរបស់ព្រះរាជបណ្ណាល័យ ជាដំណាងនាមនៃគណៈយុវសាលានិងក្រុមព្រះរាជបណ្ណាល័យ ។ យើងបានសង្កេតមើលក្នុងខណៈនោះ នៅល្វែងធំនៃព្រះរាជបណ្ណាល័យមានរៀបចំតុកៅអីជាចំនួនច្រើន ពេញទាំងមន្ទីរនិងភ្ញៀវនានា មានតុមួយធំមូលចែងជាប់ផ្កាស្បៃរៀងរបេនាជារូបអក្សរបាក់ង នៅត្រង់កណ្តាលមានសេចក្តីថា "ពុទ្ធសាសនបណ្ឌិត្យក្រុងកម្ពុជា" ហើយនៅជុំវិញតុមានសេចក្តីថា "សូមទទួលអំណរចំពោះពួកស្ត្រីថៃដែលមានប្រកាសនីយប័ត្រអំពីមហាវិទ្យាល័យ" ។

តាំងពីពេលម៉ោង ៤ ថ្ងៃទៅ ពួកគណៈយុវសាលាទាំងប្រុសស្រី – ក្មេង – ចាស់នាំគ្នាមកកាន់ព្រះរាជបណ្ណាល័យមិនដាច់ ទាំងភ្ញៀវដែលព្រះរាជបណ្ណាល័យបានអញ្ជើញនិងមិនបានអញ្ជើញក៏នាំគ្នាមកហែ ៗដែរ ត្រាតែពេញមន្ទីរព្រះរាជបណ្ណាល័យ ដែលគ្មានកៅអីគោងឈរ

ក៏មានចំនួនជាច្រើន ៗ បណ្ដាភ្ញៀវធំ ៗ ដែលយើងបានឃើញក្នុងខណៈនោះ គឺសម្ដេចក្រុមព្រះវរចក្ររណរិទ្ធ (សុត្ថាសនពេក្តម) និងសម្ដេចជាអគ្គជាយា ព្រះរាជបុត្រីព្រមទាំងព្រះអង្គម្ចាស់ក្សត្រីឯទៀត ៗ ផងឯមន្ត្រីធំៗ គឺសម្ដេចចៅហ្វាវាំងវរវៀងជ័យ លោកអគ្គមហាសេនា លោកតេជះ លោកពិទូរដីម៉ុងតេរូជាដើម គណៈមន្ត្រីបារាំងក៏មានទៅជួបជុំនៅឱកាសនោះខ្លះដែរ ៗ ក្រៅពីនេះនៅមានពួកខ្មែរ ចិន យួនដទៃទៀតដែលមកឈរចាំមើលស្ដ្រីសៀមនៅមុខសាលា និងខាងសាលា ជាចំនួនច្រើន ៗ កាលបើបូករួមទាំងអស់មានអ្នកមកទទួលអំណរនឹងចាំមើលជាចំ-នួនជាងពាន់នាក់ ៗ

លុះដល់ម៉ោង ៩ កន្លះ គណៈស្ដ្រីថៃក៏ធ្វើដំណើរមកដល់ហើយចៅនាទីយុវសាលា ក៏នាំស្ដ្រីអស់នោះទៅអង្គុយនៅកៅអីដែលបំរុងទុកដោយឡែក ៗ លុះស្ដ្រីអស់នោះអង្គុយស្ងប់ស្ងួនហើយ ទើបគណៈយុវសាលានាំគ្នាលើកទឹកតែនឹងនំដប់លៀងជូនគណៈស្ដ្រីថៃនឹងបណ្ដាភ្ញៀវទាំងពួងដែលបានអញ្ជើញមកជួបជុំក្នុងខណៈនោះគ្រប់រូប រួចលោកស្រីការប៉ុ-ឡែស ទូលអញ្ជើញសម្ដេចក្រុមព្រះវរចក្ររណរិទ្ធអធិបតីពុទ្ធសាសន-បណ្ឌិត្យ ឲ្យទ្រង់មានព្រះបន្ទូលសំដែងមេត្រីចិត្តជាភាសាសៀមទៅនឹងស្ដ្រីអស់នោះ រួចសម្ដេចចៅហ្វាវាំងថ្លែងសុន្ទរកថាមាត់ទទេជាភាសាបារាំងសែស ហើយលោកស្រីការប៉ុឡែសសារសេចក្ដីថ្លែងពីគណៈ

យុវសាលាដែលបានមកជួបជុំទទួលអំណរ ដោយមេត្រីចិត្តនឹងស្រុះស្រួលគ្នាជាពន្ទឹក ចប់ហើយទើបគ្រូពេទ្យស្រីម្នាក់ឈ្មោះដុកតៀរកៀនជាអធិបតីនៃគណៈស្ត្រីដែលមកនោះ ថ្លែងទទួលអំណរតបជាភាសាសៀមជាសេចក្តីខ្លី ៗ ថា ពួកយើង (សៀម) ដែលនាំគ្នាធ្វើដំណើរមកនេះមិននឹកនាថានឹងបានទទួលអំណរយ៉ាងសម្បើមដូច្នេះទេ សូមសំដែងមេត្រីសេចក្តីត្រេកអរដ៏ពន្ទឹកគបដល់អស់លោកដែលចាត់ចែងទទួល . . . . . . . ។

កាលចប់សុន្ទរកថាទីមួយ ៗ មានការទះដៃទ្រហឹងអឹងកង យើងសំគាល់ឃើញទឹកមុខរបស់បណ្ដាភ្ញៀវនឹងគណៈស្ត្រីថៃក្នុងខណៈនោះ សឹងមានសេចក្តីសប្បាយរីករាយគ្រប់គ្នា ។

បន្ទាប់អំពីនោះមក ដុកតៀរកៀនបង្គាប់ឲ្យស្ត្រីអស់នោះក្រោកឡើងស្រែក "ជយោ ៗ" បីដង ថ្វាយដល់ព្រះចៅផែនដីក្រុងកម្ពុជា ហើយឲ្យស្រែកថា "ជយោ ៗ" បីដងទៀត ជូនដល់ប្រជាជនជាតិខ្មែរ ដើម្បីសំដែងមេត្រីចិត្តនឹងអរគុណតប ៗ តអំពីនោះមកទើបលោកស្រីការប៊ីឡែសឲ្យគណៈយុវសាលាច្រៀងទទួលអំណរចំពោះគណៈស្រីថៃជាភាសាខ្មែរផង ភាសាបារាំងផង ៗ យើងបានសំគាល់ឃើញពួកយុវសាលាក្នុងខណៈនោះទាំងប្រុសទាំងស្រីប្រឹងខ្លួនតាំងចិត្តច្រៀងយ៉ាងស្រុះស្រួលព្រមព្រៀងគ្នាជាបំផុត ឯបទចំរៀងពីរយ៉ាងនោះ បទចំរៀងជាភាសាខ្មែរដូច្នេះ

## បទយុភកិរម្យ

ពួកយើងគណៈ    ជាយុវជន
<u>ស្រុះស្រួលលើសលន់ទាំងប្រុសទាំងស្រី</u>[១]
ចូលយុវសាលា    ដែលទើបកើតថ្មី
ប្រយោជន៍ដើម្បីជួយជ្រោមជ្រែងគ្នា ។
ឲ្យបានបងបាច់    ជាក្រុមមិត្រភក្តិ
<u>ស្រឡាញ់រួមរក្សាសមគ្គា</u>
សាមគ្គីទាំងជាតិយើងផងនានា
មេត្រីគប់គ្នាជាសុខក្សេមក្សាន្ត ។
គួរជួយអ្នកខ្សត់    ឲ្យបានចេញទៅ
<u>ដើរមើលលំនៅសព្វទីភូមិស្ថាន</u>
ឃើញស្រែចំការ    ទីងប្បារឧទ្យាន
កិច្ចការប៉ុន្មាន    គោងប្រឹងខ្វល់ខ្វាយ ។
គួរខំឧស្សាហ៍    នូវសេដ្ឋកិច្ច
<u>យោបល់បើចគេផងទាំងឡាយ</u>

---

១ ត្រង់ដែលមានគំនូសនៅខាងក្រោមនោះ ទុកឲ្យស្រីច្រៀងតែម្ខាង ក្រៅអំពីនោះទាំងប្រុសទាំងស្រីច្រៀងទាំងអស់គ្នា ។

នាំមកប្រែកបតាមកលឧបាយ
ឬកែប្រែផ្សាយតាមបែបសណ្ឋាន ៗ
វិជ្ជាអាជីព នៃយើងកល់គ្នា
ត្រូវយើងឧស្សាហ៍ត្រងត្រាប់គ្រប់ប្រាណ

ទើបនឹងចំរើន បានដោយធនធាន
ជាតិយើងថ្កើងថ្កានបានខ្ពស់ឧត្តម ៗ
នឹងឃើញអស់ទាំង ទីព្រៃព្រឹក្សា
ដែនដងបព្វតានឹងគុហាភ្នំ

សមុទ្រទន្លេទឹងបឹងតូចធំ
ធម្មតានិយមឲ្យកើតឡើងអើយ ៗ

លុះចប់ចំរៀងនេះ បណ្ដាគណៈស្ត្រីថៃនឹងភ្ញៀវទាំងអស់ទះដៃទ្រហឹងអឹងកង ហើយសរសើរថា ទំនុកច្រៀងនេះពីរោះណាស់ ៗ ហើយគណៈយុវសាលាក៏នាំគ្នាច្រៀងជាភាសាបារាំងតទៅទៀត ចប់មានការទះដៃដូចមុនទៀត តែទំនុកច្រៀងជាភាសាបារាំងនោះ យើងមិនបានស្រង់យកមកដាក់ក្នុងទីនេះទេ ដោយយល់ថា អ្នកមើលទស្សនាវដ្ដីរបស់យើងសុទ្ធតែជាខ្មែរ បើស្រង់យកទំនុកបារាំងមកដាក់គង់មិនសូវមានប្រយោជន៍ប៉ុន្មានទេ ៗ តពីពេលទះដៃសំដែងត្រេកអរ ដុកតៀរកៀនឲ្យគណៈស្ត្រីថៃក្រោកឈរឡើង នាំគ្នាច្រៀងទំនុកសៀមជាទំនុកទំនើបថ្មី

មាន ២ បទហៅថាបទលឿតស៊ុផាន់ ១ បទដួងច័ន្ទ ១ បទក្នុងពេលចប់ ១ បទ ៗ មានទះដៃទទួលអឹកធឹកដែរ ៗ ហើយលោកស្រីការប៉ុឡែសនាំគណៈស្ត្រីថៃនឹងយុវសាលាទៅថតរូបរួមគ្នានៅមាត់ដណ្ដើរព្រះរាជបណ្ណា-ល័យខាងជើង ។

បន្ទាប់ពីពេលនោះមក ចាប់ផ្ដើមសន្ទនាប្រាស្រ័យកាន់គ្នាទៅវិញទៅមកយ៉ាងស្និទ្ធស្នាល គណៈស្ត្រីថៃក៏ពាក់ទាក់នឹងពួកស្ត្រីខ្មែរ ៗ ដែលជាកូនសិស្សសាលាក៏មាន អ្នកធ្វើការហើយក៏មាន មានស្វាមីហើយក៏មាន ។ ឯគ្រឿងប្រដាប់ស្លៀកពាក់នឹងរូបឆោមក៏មិនចាញ់ស្ត្រីមកពីស្រុកនាយឡើយ ស្ត្រីទាំងពីរពួកមានសេចក្ដីមេត្រីកាន់គ្នាជាចំឡែក ហាក់ដូចជាញាតិមិត្ត ក្រៅពីនេះនៅមានពួកយុវសាលាដែលស្ម័គ្រចិត្តចង់និ-យាយចងស្ពានមេត្រីនឹងពួកស្ត្រីថៃ ក៏នាំគ្នាឈូឆរទៅតាមរកសុំកត់ឈ្មោះ ស៊ីកាតវិស៊ិតប្ដូរគ្នាទៅវិញទៅមក សឹងសំដែងឲ្យឃើញសេច-ក្ដីមេត្រីរីករាយក្រេមក្សាន្តទាំងអស់គ្នា តែមុខគួរឲ្យស្ដាយណាស់ ខណៈដែលពួកយុវសាលាទាំងប្រុសទាំងស្រី សំដែងមេត្រីចិត្តសន្ទនាកាន់គ្នាជាទីក្រេមក្សាន្តទាំងសងខាងនោះ ចួនជាដល់ពេលត្រឡប់ទៅទីសំណាក់នៃគណៈស្ត្រីថៃ ។ ឯពួកយុវសាលាក៏នាំគ្នាឈូឆរតាមទៅជូនរហូតដល់រថយន្ត តែស្ត្រីអស់នោះមិនទាន់ឡើងរថយន្តភ្លាមទេ នាំគ្នាទៅឡើងលេង

លើផ្ទះលោកស្រីការប៉ីឡែស ដែលនៅខាងត្បូងក្បែរព្រះរាជបណ្ណាល័យបន្តិច រួចនាំគ្នាមកឡើងរថយន្តចេញដំណើរទៅ ឯពួកយុវសាលាក៏នាំគ្នាស្រែកថា . ស៊ូតឌី ៗ (សួស្តីតាមសំនៀងសៀមថាស៊ូតឌី) ទ្រហ៊ឹងអឺងកងទៀត ឯពួកស្ត្រីថៃក៏ចាប់កន្សែងជូតមុខចេញពីបន្ទោះរថយន្តបក់លោស់លាវិច ៗ ហើយស្រែកស៊ូតឌីតប ៗ កិច្ចការប្រព្រឹត្តទៅដោយរៀបរយជាទីរីករាយសប្បាយទាំងអស់គ្នា ។

នៅទីបំផុតនេះ យើងមានសេចក្តីសង្ឃឹមទុកថា អំណោះតទៅមុខគណៈស្ត្រីថៃនិងគណៈស្ត្រីក្រុងកម្ពុជា នឹងមានស្ពានមេត្រីកាន់គ្នាដោយជិតស្និទ្ធមិនខាន ព្រមទាំងប្រទេសជាតិក៏កាន់តែមានសាមគ្គីស្រុះស្រួលមូលមិត្តគ្នាល្អដែរ គណៈទស្សនាវដ្តីសូមជូនដំណើរគណៈស្ត្រីថៃដែលធ្វើដំណើរមកមើលប្រទេសឥណ្ឌូស៊ីននេះ ប៉ូប្រែកបដោយសេចក្តីសុខសួស្តីដករាបត្រឡប់ទៅដល់ក្រុងបាងកកវិញ ។

សួស្តី - ជំយោ

ខេមរៈរង្សី

# បញ្ជីរឿង

១ — ពិធីបំរើនពុទ្ធមន្តដល់មហានគរបាំងសែស នៅមន្ទីរពុទ្ធសាសនបណ្ឌិត្យ របស់ខេមរៈរង្សី . . . . . . . . . . . . . . . . . . . . . ២០៣

២ — ដំណឹងផ្សេង ៗ របស់ខេមរៈរង្សី . . . . . . . . . . . . . . . ២០៩

៣ — គុណសម្បទា របស់លោកគ្រូអាចារ្យហ៊ែម . . . . . . . . . . . . ២១៥

៤ — សុន្ទរកថា របស់ភិក្ខុលោកនាថ (តនឹងចប់) . . . . . . . . . . . . ២៣១

៥ — ប្រជុំពាក្យ ភាគទី ៣ របស់ពួកស្រ្តីក្នុងព្រះរាជវាំង (ត) . . . . . . . . . ២៤៥

៦ — ហិតោបទេស ភាគទី ១ (ត) . . . . . . . . . . . . . . . . . ២៦១

៧ — ភរិយា ៧ ប្រការ របស់អាចារ្យ ហ. ឈា . . . . . . . . . . . . ២៧១

៨ — រឿងព្រេងខ្មែរ-ច្បាប់កំណត់កន្ត្រៃ . . . . . . . . . . . . . . . ២៨៣

## រូបក្រោយរឿង

រូបព្រះសង្ឃចំរើនជយបរិត្តដល់មហានគរបាំងសែស នៅមន្ទីរព្រះរាជបណ្ណាល័យ កាលពីថ្ងៃ ១០ សេបតមប្រ៍ ១៩៣៩ . . . . . . . . . . . . ២០១

ក្រុមជំនុំទំនៀមទម្លាប់
COMMISSION DES MŒURS & COUTUMES

# TABLE DES MATIÈRES

Pages.

1° Récitation de prières pour la France à l'Institut Bouddhique par Khemararansi.... 203

2° Informations diverses par Khemararansi.... 209

3° Gunasampadâ par l'Achar Himm.... 215

4° Causerie sur la doctrine Bouddhique par Bhikkhu Lokanatha (suite et fin).... 231

5° Recueil des Poèmes cambodgiens par la famille royale 3e partie (suite).... 245

6° Hitopadésa 1re partie (suite).... 261

7° Les sept catégories de femmes par l'Achar H. Chhéa.... 271

8° Contes populaires cambodgiens inédits:

L'enseignement du savant Keng-Kantray.... 283

HORS TEXTE :

Les vénérables à la cérémonie de récitation des prières pour la France à l'Institut Bouddhique.... 201



រូបព្រះសង្ឃបំរើឧបរិត្តជូនដល់មហាឧត្តរបាភាំងសែស នៅមន្ទីរ
ព្រះរាជបណ្ណាល័យ កាលពីថ្ងៃ ១០ សេបតមប្រ ១៩៣៩

# ពិធីសូត្រព្រះមន្តចំរើនជ័យបរិត្ត
# នៅមន្ទីរព្រះរាជបណ្ណាល័យ ក្រុងភ្នំពេញ

កាលពីថ្ងៃអាទិត្យ ១០ សេបតមប្រ៍ ១៩៣៩ វេលាម៉ោង ៥ ល្ងាច មានរៀបពិធីសូត្រមន្តមួយយ៉ាងធំនៅព្រះរាជបណ្ណាល័យ ដើម្បីចំរើនសិរីសួស្តីជយមង្គលដល់មហានគរបារាំងសែសនឹងសកលលោកព្រមទាំងប្រទេសឥណ្ឌូចិន មានចំនួនព្រះសង្ឃចំរើនព្រះបរិត្ត ២០០ អង្គ ។ ព្រះតេជព្រះគុណព្រះសិរីសម្មតិវង្ស ចាងហ្វាងសាលាបាលីជាន់ខ្ពស់ ផ្តួចផ្តើមធ្វើឡើងជាដំបូងរួមជាមួយនឹងព្រះរាជបណ្ណាល័យ ។

នៅឱកាសនេះ មានអស់លោកមន្ត្រីបារាំងខ្មែរ ទាំងខាងរាជការអាណាព្យាបាល នឹងរាជការព្រះករុណា បានទៅជួបជុំជាច្រើន ព្រមទាំងឧបាសកឧបាសិកាដទៃទៀតផង ។ លុះព្រះសង្ឃនឹងបណ្ដាក្រៀវមកជួបជុំព្រមហើយ ទើបព្រះតេជព្រះគុណព្រះសិរីសម្មតិវង្ស សូត្រសុន្ទរកថានៅចំពោះមុខមន្ត្រីបារាំងខ្មែរអស់នោះ ។

## សច្ចកថា

សុវត្ថិ ហោតុ សព្វទា សូមសួស្តីមានសព្វកាល

វុឌ្ឍិ ភវតុ សកលលោកស្ស សូមសេចក្តីចំរើនកើតមានដល់សកលលោក

សូមចំរើនពរលោកឡឺរេស៊ីដង់ស៊ុបេរីយើរ

លោកឡឺរេស៊ីដង់ខ្មែរ

សូមថ្វាយព្រះពរទ្រង់ ព្រះករុណា គ្រប់ព្រះអង្គ

សូមចំរើនពរសម្តេច ព្រះតេជព្រះគុណ អស់លោកកុងស៊ុយ សេនាបតី នូវអស់លោកទាំងឡាយ ។

អាត្មាភាពជាអ្នកដំណាងនាមព្រះសង្ឃ ក្រុមសាលាបាលីជាន់ខ្ពស់ ក្រុមជំនុំព្រះត្រៃបិដកក្នុងពុទ្ធសាសនបណ្ឌិត្យ សាលាបាលីរងទាំងឡាយ នឹងព្រះសង្ឃគ្រប់វត្តព្រមទាំងពុទ្ធិកសមាគមកម្ពុជរដ្ឋ សូមថ្លែងសេចក្តីសង្ខេប អំពីអធ្យាស្រ័យរបស់ព្រះសង្ឃពុទ្ធសាសនិក ដូចមានសេចក្តីតទៅនេះ

តាំងពីយូរឆ្នាំណាស់មកហើយ កម្ពុជរដ្ឋរបស់យើង តាំងពីបានមហានគរបារាំងសែសមកជួយទំនុកបម្រុង ក៏មានសេចក្តីស្ងប់ សុខស្រួលព្រមទាំងសេចក្តីចំរើនរឿយ ៗ តាមលំដាប់ ។ ព្រះពុទ្ធសាសនាដែលជាដួងចិត្តរបស់យើង ក៏រុងរឿងឥតមានអាក់ដកបមកដល់សម្រេចកិច្ចការប្រែព្រះត្រៃបិដកបោះពុម្ពផ្សាយ ដែលជាមុខការយ៉ាងធំសម្បើមរបស់ព្រះពុទ្ធសាសនា តាំងពីកាលណាមកក៏មិនដែលមានប្រទេសណាធ្វើកើតដល់ទីនេះ គួរឲ្យនានាប្រទេសនឹកស្ញើប ព្រមទាំងពេញចិត្តគិតយក

ដម្រាប់តាមផង ។ ការបានស្រួលបានចំរើនទាំងនេះ កើតមកអំពីសេចក្ដីទំនុកបំរុងរបស់មហានគរបារាំងសែស ដែលយើងពេញចិត្តកក់ក្ដៅទឹកសន្សឹមជានិច្ច ជាជាមហាអាណាព្យាបាលរបស់កម្ពុជរដ្ឋ ។

ឥឡូវនេះ យើងទាំងអស់គ្នាមានសេចក្ដីទុក្ខព្រួយជាទម្ងន់ចំពោះទៅលើមហានគរជាអាណាព្យាបាលរបស់យើង ដែលកំពុងចំប្រឹងលត់ភ្លើងគឺសេចក្ដីឃោរឃៅពុះពារមកទាំងស្រែង ទាំងកំពេលឲ្យរលត់ ឲ្យកើតសន្ដិភាពដល់សកលលោក ។ ក៏ព្រះពុទ្ធសាសនាដែលជាជំនឿរបស់យើង, តែងស្រោចស្រង់សត្វ តែងឲ្យនូវសន្ដិភាព ការទំនុកបំរុងព្រះពុទ្ធ-សាសនា តែងមានផលានិសង្សឲ្យសេចក្ដីសុខឃើញជាក់ស្ដែង ការបោះពុម្ពព្រះត្រៃបិដក ដែលរាជការអាណាព្យាបាលបារាំងសែសបានធ្វើហើយនោះមានដំឡៃច្រើនណាស់ មានផលរាប់មិនបាន មានអាយុវែងកំណត់ពុំបាន, គ្មានកំឡាំងអ្វីខាំងពូកែស្មើ ប្រសើរលើសលប់ជាងអ្វីៗទាំងអស់ក្នុងលោក ។ នេះជាសម្បត្តិ, ជាគុណភាព, ជាកំឡាំង ជាមហា-អំណាច របស់រាជការអាណាព្យាបាលបារាំងសែស ។ មែនពិតណាស់ សូមលោកឡឺរេស៊ីដង់ស៊ុបេរីយើរ, លោកឡឺរេស៊ីដង់ខ្មែរ ទាំងអស់លោកជឿ ព្រមទាំងសន្សឹមចុះ ថាមហានគរបារាំងសែសនឹងចេះតែមានសិរីសួស្ដីនឹងសេចក្ដីចំរើនរុងរឿងតរៀងទៅឥតអាក់ ជាប្រាកដ ។

លុះបញ្ចប់សេចក្ដីថ្លែងនេះស្រេចហើយ អាត្មាភាពទាំងអស់គ្នា សូមចំរើនព្រះបរិត្តពុទ្ធមន្ត ផ្សាយសេចក្ដីសុខ, ចំរើន, ដល់មហានគរបាកំងសែសជាអាណាព្យាបាលរបស់យើង ។

សូមអស់លោកស្ដាប់ដោយគោរព ដោយអំណាចសច្ចវាចានេះ

សូមសកលលោកបានសន្តិភាព

សូមមហានគរបាកំងសែសមានតេជានុភាព

សូមប្រទេសឥណ្ឌូស៊ីន បានសុខ, ចំរើន.

លុះចប់សច្ចកថានេះហើយ ទើបលោកអាចារ្យ ប៉ាង-ខាត់ ស៊ុត្រ ប្រែជាភាសាបាកំងតទៅទៀត ចប់ហើយទើបលោកជីឡង់ជាជំណាងលោករេស៊ីដង់ស៊ុប៉េរីយើរ ថ្លែងសេចក្ដីអរគុណ ជាជំណាងកពុំការអាណាព្យាបាល ហើយលោកមានប្រសាសន៍តទៅទៀតថា មហានគរបាកំងសែសប្រាថ្នាសន្តិភាពជាបំផុត សូមព្រះសង្ឃជូនដំណឹងដល់ពួកឧបាសកឧបាសិកាថា កុំបីកិតភ័យនឹងហេតុដែលកើតឡើងនៅទ្វីបឧរុបសព្វថ្ងៃនេះ កុំឲ្យជឿពាក្យនិយាយផ្ដេសផ្ដាស ត្រូវគិតតែចំរើនរកស៊ីដូចសព្វដងរៀងមក ឯប្រទេសឥណ្ឌូស៊ីននេះមិនមានហេតុកេងអ្វីទេ កុំបីអ្នកពល់គ្នាព្រួយបារម្ភឡើយ ។ល។ បន្ទាប់ពីនោះមក សម្ដេចចៅហ្វាកំងវរៈវៀងជ័យ ថ្លែងសេចក្ដីអរគុណជាជំណាងព្រះករុណាជាម្ចាស់ជីវិត ហើយពោលរំឭកជាស់តឿននឹងពន្យល់តាមសមគួរ ។

# ចំរើនជយបរិត្ត

បណ្ដាព្រះសង្ឃដែលមកប្រជុំសូត្រជយបរិត្តនេះ សឹងតាត់និមន្តមកពីអាកមផ្សេងៗក្នុងក្រុងភ្នំពេញ ទាំងប៉ែកខាងធម្មយុត្តិ ទាំងប៉ែកខាងមហានិកាយ ចំនួន ២០០ អង្គ ។ ព្រះតេជព្រះគុណព្រះសិរីសម្មតិវង្ស អែម. អុជទៀន-ធូបបូជាព្រះរត្នត្រ័យ ចំពោះនៅមុខព្រះពុទ្ធរូប ហើយព្រះសង្ឃទាំង ២០០ អង្គសូត្រពុទ្ធជយមង្គលគាថា គឺពាហុំ ព្រមគ្នាហូតដល់ចប់ដោយស្រួះស្រួលព្រមព្រៀង ។

លុះសូត្រធម៌ពុទ្ធជយមង្គលចប់ហើយ, ព្រះតេជព្រះគុណព្រះសាសនសោភ័ណ ជួន-ណាត បានប្រកាសសេចក្ដីដល់ព្រះភិក្ខុសង្ឃទាំងអស់ដែលនិមន្តមកប្រជុំក្នុងមន្ទីរព្រះរាជបណ្ណាល័យនេះថា ធម៌ពុទ្ធជយ-មង្គលដែលយើងបានសូត្រអំបាញ់មិញនេះ ជាធម៌មានអានុភាពកើតសេចក្ដីសុខចំរើនទឹងជយានុភាពគ្រប់យ៉ាង ។

ចាប់ដើមតាំងពីវេលានេះរៀងទៅ, សូមព្រះភិក្ខុសង្ឃគ្រប់អង្គតាំងចិត្តផ្សាយមេត្តាកល់ថ្លៃចំពោះទៅកែសកលលោក សូមឲ្យបានសេចក្ដីស្ងប់ យើងជាពួកបព្វជិត មិនត្រូវតាំងចិត្តព្យាបាទទេ ។ អាណាចក្រពុទ្ធចក្រក្នុងកម្ពុជរដ្ឋ ដែលបានសុខ ចំរើនទាំងនេះ មកអំពីមានពរជការអាណា-ព្យាបាលបារាំងសែសជាមួបជាបន្ទុករបស់យើង ។ ការបោះពុម្ពព្រះត្រៃ-

បិដកទាំងបាលីទាំងសម្រាយ ដែលពជការបារាំងសែសបានបង្កើតឡើង ឲ្យប្រាកដដល់ភ្នែកនឹងដួងចិត្តនៃសកលលោកក្នុងវេលានេះ ជាការសំខាន់បំផុត ឥតមានកិច្ចការណាដទៃរំលងឡើយ មានអានិសង្សខ្ពង់ខ្ពស់ត្រដឹមត្រៃផត មានអំណាចអាចឲ្យអ្នកដែលផ្ដើមបាត់ការ មានតេជានុភាពដ៏ពន្ទឹក ។

មួយយ៉ាងទៀត បណ្ដាជាតិមនុស្សក្នុងលោក នឹងរកជាតិមនុស្សណា ឲ្យមានអធ្យាស្រ័យសុភាពទន់ភ្លន់ជាងបារាំងសែសទៅទៀតគ្មានទេ ។ សូមឲ្យព្រះភិក្ខុសង្ឃពល់អង្គខំយកចិត្តទុកដាក់ ជួយនិយាយពន្យល់គ្នាត ៗ ទៅថា ឲ្យនាំគ្នាស្ងប់កុំជ្រួលច្របល់ដោយការឥតប្រ-យោជន៍; ឲ្យគិតតែពីខំប្រឹងរៀន ខំប្រឹងរក ខំប្រឹងប្រព្រឹត្តសុចរិតរាល់គ្នាទៅ ខ្លួនយើងត្រូវពឹងខ្លួនឯង, ពឹងគំនិតល្អរបស់ឯង ត្រូវជឿតែការដែលពិតកុំជឿពាក្យភូតភរ ត្រូវស្រឡាញ់មូប់កំពុងជ្រកបង្អែកដែលកំពុងផ្អែក; ត្រូវថែទាំផ្ទាំងបាយរបស់ខ្លួនកុំឲ្យបែក, គ្រាន់តែឮផ្គរលាន់កុំបាក់ទឹកចោល ត្រូវប្រើគំនិតឲ្យល្អិត, ទើបពេញជាអ្នកស្គាល់ប្រយោជន៍ជាក់ច្បាស់មិនភាន់ច្រឡំ ។

ដំណឹងផ្សេងៗ

# អំពីការរកឃើញព្រះពុទ្ធរូប សំរិទ្ធិជាន់ចាស់ក្នុងស្រុកម៉ាឡាយូ

មានអ្នកប្រាជ្ញជាតិអង់គ្លេសម្នាក់ ឈ្មោះលោកការិតវ៉ាល័ (Quaritch Vales) ត្រូវសមាគមអ្នកប្រាជ្ញមួយបញ្ជូនខ្លួនលោកទៅស្រុកម៉ាឡាយូ នៅខែត្រកេដា (Kedah) និងខែត្រប៉េរ៉ាក់ (Perak) ដើម្បីស្រាវជ្រាវរកស៊ីវិ-ល្ស៍របស់ឥណ្ឌាជាន់ចាស់ដែលមាននៅក្នុងចំណោមខែត្រអស់នោះ ។

លោកអ្នកប្រាជ្ញនេះបានបោះពុម្ពផ្សាយកិច្ចការរបស់លោក មានរូបយ៉ាងល្អ ជារូបភាពពុទ្ធសាសនាបែបហីនយាន និងមហាយាន ដើម្បីឲ្យមហាជនបានដឹងច្បាស់អំពីការស្វះស្វែងរុករកបោរាណវត្ថុរបស់លោក ។

ពួកដែលតាំងលំនៅនៅតាមប្រទេលពជឥណ្ឌាជាដំបូងនោះ បានចេញទៅតាំងភូមិលំនៅក្នុងស្រុកម៉ាឡាយូ ក្បែរមាត់ស្ទឹងមួយនៅកន្លែងនោះ សព្វថ្ងៃនេះគេកំពុងរើសកកាយយកសំណប៉ាហាំង ៗ ដោយសារតែពួកអ្នកជីកលោហធាតុមានបញ្ញាឈ្លាសវៃចំពួកខ្លះ ទើបគេបានរកឃើញស្លាមក្រុងចាស់របស់ប្រទេសពជឥណ្ឌាជាន់ដើម ហើយក្នុងខណៈនោះ បានប្រទះឃើញរូបសំរិទ្ធិជាច្រើន ៗ រូបដែលធ្វើពីសំរិទ្ធិជាដំបូងដែលគេបានឃើញនោះ ជាព្រះពុទ្ធរូបទ្រង់ស្ថិតឈរមានទ្រង់ទ្រាយល្អបំណាប់

របស់ពួកអ្នកកាន់ពុទ្ធសាសនាប៉ែកខាងហ៊ីនយាន ចាប់តាំងមកប្រហែល ជាក្នុងពុទ្ធសករាជ ១.០០០ ឆ្នាំ ទុកស្មើការចារិកអក្សរដែលគេរកឃើញ ក្នុងជាន់នោះដែរ ។ មានរូបសំរិទ្ធិដទៃ ១ទៀតដែលបានរកឃើញជារបស់ ជំណាន់ប៉ែកខាងពុទ្ធសាសនាមហាយាន ដែលជាសាសនាមានអំណាច គ្របដណ្តប់ក្នុងដែនដីមាឡាយូ ក្នុងសម័យនោះ ។ កាលពីឆ្នាំទៅទៀត ត្រង់កន្លែងធ្វើការយកលោហធាតុ គេបានប្រទះឃើញរូបពោធិសត្វ អវលោកិតស្វរៈ មានទំនងដូចរូបពោធិសត្វ ដែលបានឃើញនៅប្រាសាទ បាយ័នទីងដូចជារូបឯទៀត ។ បែបសាសនាមហាយាននៅប្រាសាទអង្គរ ដែរ ។

នៅវេលាគ្រាក្រោយបង្អស់ គេបានរកឃើញរូបពោធិសត្វអវលោកិតស្វរៈ មានព្រះហស្ត ៤ ទ្រង់ពរ ។ រូបនោះជារបស់កូលីម្នាក់ដែល នៅធ្វើជំរួញក្នុងស្រុកមាឡាយូ ហើយគាត់គោរពបូជារូបនេះ ដូចជារូប ព្រះវិស្ណុ (ព្រះនារាយណ៍) ដែលគាត់ធ្លាប់កាប់គាន តាំងអំពីគាត់បានរូប នេះមកគាត់មានសេចក្តីចំរើនសុខសប្បាយឡើងច្រើន គាត់មិនទឹកនាថាគេបំ-កសពង្រាត់រូបនោះយកទៅទុកពិពិធភណ្ឌស្ថានសោះ ។

ក្នុងទីបំផុត លោកអ្នករៀបរៀងរឿងនេះកត់សំគាល់សេចក្តីថា ពួក រូបសំរិទ្ធិមាឡាយូអស់នេះ មានបែបភាពដូចរូបដែលរកឃើញនៅស្រុក ឥណ្ឌៀ ស្រុកសៀមខែត្រឆៃយា មួយវិញទៀត គេមិនអាចឃាត់ឃោ-

បល់ដែលយល់ថា ដែនដីម៉ាឡាយូ, ជ្វា មានបទបែបស៊ីវិល្បស៍ឥណ្ឌា ជាច្រើន ដែលគេមិនទឹកជឿថាមានក្នុងសាវតារ តាំងអំពីពុទ្ធសករាជ ១.៤០០ ឆ្នាំមក ។ រូបអស់នោះមានរូបប្រហែល ៗ គ្នាជាច្រើនដែលគេរកឃើញនៅស្រុកជ្វា នឹងស្រុកសុម៉ាត្រា ដែលមានកំណើតកើតឡើងក្នុងសម័យនោះដែរ ហេតុនេះសូមជូនរឿងនេះជូនអ្នកតែងពង្សាវតារដែលខំសិក្សាពីដែនដីឥណ្ឌា ព្រមទាំងអានុភាពនៃពុទ្ធសាសនាដែលផ្សាយចូលនៅក្នុងស្រុកសៀម ស្រុកម៉ាឡាយូ, ស្រុកជ្វា, ស្រុកសុម៉ាត្រា សឹងសំឡឹងឃើញច្បាស់ អំពីអំណាចពុទ្ធសាសនាមហាយានដែលរកចូលមក តាំងផ្សាយលទ្ធិពុទ្ធសាសនា នៅដែនដីជាចំណែកឈូងសមុទ្របេង្គ័ល (Bengale) ហើយបែកសាយភាយចេញទៅនៅលើដែនដីជាចំណែកទិសខាងត្បូងឆៀងឯកើត (អាគ្នេយ៍) នៃទ្វីបអាស៊ី ។

✲ ✲

✲

# អំពីការគាស់កកាយរុករកបោរាណវត្ថុ

នៅស្រុកអាហ្វឃានិស្តង (Afghanistang gandhara) នៃពួកអ្នកប្រាជ្ញ
បោរាណវត្ថុជាតិបារាំងសែស កាលពីឆ្នាំ ១៩៣៦ ដល់ឆ្នាំ ១៩៣៧ ។

មានអ្នកប្រាជ្ញជាតិបារាំងសែសមួយក្រុម បានចេញទៅគាស់កកាយរុករកនៅស្រុកមួយដែលហៅថាស្រុកគន្ធារៈ នៅស្រុកឥណ្ឌា ខាង-

ដើង ៗ តាំងអំពីព្រះសម្មាសម្ពុទ្ធបរិនិព្វានមក រហូតមកដល់រវាងពុទ្ធ-សករាជ ៨០០ ឆ្នាំ ស្រុកនេះជាស្រុកកាន់ព្រះពុទ្ធសាសនាមាំមួនមួយដែរ (កាលអំពីដើមមក) ។ ដល់មកសព្វថ្ងៃនេះគេរកឃើញទីវត្តវិហារដែលបាក់បែកទៅ នឹងចេតិយស្ថាន មានក្បាច់នឹងគំនូរពន្យល់អំពីពុទ្ធប្រវត្តិ ហើយមានរូបបងប្អូន ៣ នាក់ ជាកស្សបគោត្រ (ឧរុវេលកស្សប, នទីកស្សប, គយាកស្សប?) ធ្វើអញ្ជលីកម្មចំពោះព្រះសម្មាសម្ពុទ្ធជាម្ចាស់ ឃើញមានរូបព្រះពោធិសត្វមេត្តេយ្យ ១ អង្គ ។ ឃើញមានអនុស្សាវរីយ ជាដំណាងរូបអន្តេវាសិកកំឡោះជាតិព្រាហ្មណ៍ម្នាក់ឈ្មោះ មេឃ: ជួបនឹងព្រះពុទ្ធទីបង្ករ: ។

កាលបើគេពិនិត្យមើលឲ្យជាក់ច្បាស់ អំពីក្បាច់ក្បូរបែបពុទ្ធសាសនា នឹងឃើញថា រចនាបែបគន្ធារ: ក៏សំបើមអស្ចារ្យប្រហែលនឹងរចនាបែបចិនដែលមានក្នុងរវាងពុទ្ធសករាជ ១.០០០ ឆ្នាំនោះដែរ មានគំនូរមួយល្អចំណាប់ ជារូបដែលគេគូរដំណាងព្រះពោធិសត្វអរិយមេត្តេយ្យមានព្រះហស្តកាន់ផ្កាឈូកខៀវ (ផ្កាលំចង់?) ។

ដល់មកសម័យបច្ចុប្បន្ននេះ ប្រទេសគន្ធារ:ជាប្រទេសកាន់សាសនាមោហម៉ុទ ។ បណ្ដាបូរាណវត្ថុដែលបាក់បែកទាំងប៉ុន្មានសំដែងឲ្យឃើញថា ប្រទេសនេះជាប្រទេសស្តុកស្តម្ភមាំមួន ក្នុងសម័យដែលកាន់ព្រះពុទ្ធ-

សាសនា សព្វថ្ងៃប្រទះឃើញតែកន្លែងដែលគេបោះបង់ចោលទៅនោះជាច្រើនៗ

# អំពីអល្បណាៈ

ព្រះរាជបណ្ណាល័យបានទទួលសៀវភៅទស្សនាវដ្តីបារាំងសែសមួយល្អចំណាប់ ដែលសុទ្ធតែបោះពុម្ពផ្សាយរឿងល្អៗ បានបោះពុម្ពរូបជាចំ-នួនច្រើនជាគ្រឿងប្រដាប់លំអរបស់សៀវភៅទស្សនាវដ្តីនោះទៀតផងៗ

ទស្សនាវដ្តីដែលចេញលើកក្រោយបំផុតយើងឃើញមានរឿងដែលជាប្រយោជន៍ដល់ស្រុកខ្មែរនេះ ហៅថា "អល្បណា:" ជាទំនៀមទម្លាប់មួយនៅស្រុកឥណ្ឌា អល្បណា: នេះជារូបគំនូរមួយដ៏ស្អាតកំបាំងដែលគេតែងគូរនៅឱកាសពិធីបុណ្យខ្លះខាងមុខវិហារ ឬនៅខាងមុខផ្ទះរាល់ៗ វេលាព្រឹកៗ រូបគំនូរដែលល្អបំផុតដែលធ្វើនៅក្នុងខែត្រទាំងពីរសព្វថ្ងៃនេះ គឺនៅខាងកើតស្រុកបេងគាល់ (Bengale) និងនៅខាងត្បូងស្រុកមទ្រាដ្ឋ (Madras) នៅក្នុងឃុំអ្នកទីទាល់ក្រណាស់នៅក្នុងក្រុងនោះ តាំងអំពីពេលព្រះអាទិត្យរះឡើង គេតែងធ្វើសក្ការបូជាដល់ទេវរូបព្រាហ្មណ៍នៅខាងមុខទេវសនៈតូចមួយ (un petit autel) ស្រីមេផ្ទះតែងប្រញាប់តាក់តែងគូររូប "អល្បណា:" នៅនឹងមាត់ទ្វារផ្ទះៗ ឯការគូរនេះគេប្រើគួរ

ដោយក្រឹសតូចធ្វើពីឈើ នៅទឹនដីថ្មល់គេក៏គូរដោយក្រឹសបែបនេះដែរ ប៉ុន្តែនៅខែត្រមទ្រដ្ឋ គេគូរគំនូរនៅលើដីដែលយកម្សៅម្ចុដីសពងយ៉ាន ផង់ល្អិតទៅពេលយពាសពេញហើយ ទើបគេគូរឲ្យឃើញរូបគំនូរអល្បណៈ ចេញមក ។

គំនូរអស់នេះគេបណ្ដោយឲ្យស្រី ៗ គូរទើបឃើញសុទ្ធតែជាស្នាដៃស្រី ៗ រូបដែលគូរទាំងនោះ ជារូបដែលគេគូរជាបណ្ដាំអាសន្នទាំងអស់ ព្រោះភ្ញៀវតែចូលមកដល់ផ្ទះនោះជាដំបូងក៏ដើរជាន់លុបលើគំនូរអស់នោះទៅ ។ នៅស្រុកបេងគ័ល (Bengal) គេយកគ្រាប់អង្ករមានពណ៌ផ្សេង ៗ មកធ្វើដូចជាព្រំមានក្រឡាពណ៌ផ្សេង ៗ ចំណែកឯស្រុកមទ្រដ្ឋគេមិនប្រើក្រឹសនោះទេ គឺគេយកម្រាមដៃជ្រលក់ទៅក្នុងទឹកអង្ករ (ម្សៅ) ហើយទើបគេគូររូបអល្បណៈនោះ ។

ពេលដែលធ្វើបុណ្យក្នុងគ្រួសារ (នៅទឹនផ្ទះ) គោងកេប្បុកក្ខុតកាស ប្រូនប្រៀបរៀបចំ “អល្បណៈ” នេះគ្រប់ ៗ ពេលធ្វើបុណ្យ ។

កុសលសម្បទា

របស់អាចារ្យ ហឹម

ក្រុមជំនុំព្រះត្រៃបិដក

ខត្តិយោ សេដ្ឋោ ជនេតស្មឹ
យេ គោត្តប្បដិសារិនោ
វិជ្ជាចរណសម្បន្នោ
សោ សេដ្ឋោ ទេវមានុសេតិ ។

រឿងដែលកើតឡើង ឲ្យបានព្រះដ៏មានព្រះភាគទ្រង់ត្រាស់សរសើរគាថានេះ ព្រោះពាក្យពួកព្រាហ្មណ៍ជេរប្រទេច វាសេដ្ឋៈនិងភារទ្វាជសាមណេរ ដែលចេញចាកត្រកូលព្រាហ្មណ៍ មកបួសក្នុងសំណាក់ព្រះដ៏មានព្រះភាគ ។ ពាក្យពួកព្រាហ្មណ៍នោះនិយាយថា មានតែព្រាហ្មណ៍ទើបជាវណ្ណៈប្រសើរបំផុត ពួកជនឯទៀតជាវណ្ណៈថយថោក មានតែពួកព្រាហ្មណ៍ទើបជាវណ្ណៈស ពួកជនឯទៀតជាវណ្ណៈខ្មៅ មានតែពួកព្រាហ្មណ៍ទើបបរិសុទ្ធ ពួកជនឯទៀតមិនមែនព្រាហ្មណ៍មិនបរិសុទ្ធទេ ពួកព្រាហ្មណ៍ជាបុត្តជាឱរសរបស់ព្រហ្ម កើតអំពីព្រះឱស្ឋព្រហ្ម កើតមកអំពីព្រហ្ម ព្រហ្មបានតាក់តែងមក ជាទាយាទរបស់ព្រហ្ម ឯវាសេដ្ឋៈនិងភារទ្វាជៈកើតក្នុងត្រកូលព្រាហ្មណ៍ជាវណ្ណៈប្រសើរ ក៏លះបង់វណ្ណៈប្រសើរចេញហើយ ចូលទៅបួសក្នុងសំណាក់សមណៈត្រងោល ជាគហបតីវណ្ណៈខ្មៅជាពួកនៃមារ កើតមកអំពីព្រះបាទព្រហ្ម ជាវណ្ណៈថយថោក យ៉ាងនេះពុំសមគួរឡើយ ។

ព្រះដ៏មានព្រះភាគទ្រង់ជ្រាបពាក្យនេះហើយទ្រង់ត្រាស់ថា ម្នាល វាសេដ្ឋៈនិងភារទ្វាជៈ ពួកព្រាហ្មណ៍របស់អ្នកទាំងឡាយ មិនបានដឹងដើមកំណើតសត្វលោកតាំងអំពីបឋមកប្ប បានជានិយាយខុសតាំងមូល ចុះនាងព្រាហ្មណី មានរដូវ មានគភ៌ សម្រាលកូន អង្រួយបំបៅកូនសិងមានប្រាកដ ពួកព្រាហ្មណ៍ទាំងនោះសុទ្ធតែកើតអំពីយោនីនាងព្រាហ្មណី ហេតុអ្វីក៏បានជានិយាយថា ពួកខ្លួនជាបុត្តឱរសរបស់ព្រហ្មទៅវិញ ពាក្យនិយាយយ៉ាងនេះជាពាក្យនិយាយបង្អាប់ព្រហ្មផង កុហកផង រមែងសោយទុក្ខបាបច្រើន ។

វណ្ណៈទាំងឡាយមាន ៤ គឺខត្តិយ ១ ព្រាហ្មណ៍ ១ វេស្សៈ ១ សុទ្ទៈ ១ វណ្ណៈទាំង ៤ ឯណានីមួយក្នុងលោកនេះ ជាអ្នកសម្លាប់សត្វ លួចទ្រព្យគេ ប្រព្រឹត្តខុសក្នុងកាមទាំងឡាយ និយាយពាក្យកុហក និយាយពាក្យបំបែកមិត្តគេ និយាយពាក្យទ្រគោះខ្លាំង និយាយពាក្យឥតប្រយោជន៍ មានសេចក្តីលោភមានចិត្តព្យាបាទ និងមានសេចក្តីយល់ខុស អកុសលធម៌ទាំងនេះជាធម៌ឲ្យផលអាក្រក់ គឺផលទុក្ខផលអាក្រក់ ។

ពួកខ្លះក្នុងលោកនេះ ជាអ្នកមិនសម្លាប់សត្វ មិនលួចទ្រព្យគេ មិនប្រព្រឹត្តខុសក្នុងកាមទាំងឡាយ និយាយតែពាក្យពិត និយាយតែពាក្យផ្សះផ្សាឲ្យព្រមព្រៀង និយាយតែពាក្យផ្អែមពីរោះ និយាយតែពាក្យ

ក្នុងធម៌វិន័យ មិនមានសេចក្ដីលោភ មិនមានចិត្តគំគួនមនុស្សទាំងសត្វ ទាំងមានសេចក្ដីយល់ត្រូវ កុសលធម៌ទាំងនេះជាធម៌ឲ្យផលស គឺឲ្យផលសុខផលល្អ ។

វណ្ណៈទាំងឡាយប្រព្រឹត្តធម៌ពីរពួក ជាអកុសលខ្លះ ជាកុសលខ្លះ យ៉ាងនេះ ដូចជាពួកព្រាហ្មណ៍កំពុងតែប្រព្រឹត្តធម៌ប្រឡូកប្រឡំគឺធម៌ខ្មៅទាំងធម៌សហើយ អួតថា ពួកខ្លួនមានវណ្ណៈសបរិសុទ្ធប្រសើរ ថាពួកឯទៀតមិនមែនព្រាហ្មណ៍ មានវណ្ណៈខ្មៅសៅហ្មងថយថោកយ៉ាងនេះ វិញ្ញូជនធ្វើម្ដេចនឹងយល់ព្រមតាមបាន ។

បើវណ្ណៈណាមួយទៀតណា យកធម៌របស់ខ្លួន ភៀសចេញចាកគេហរបស់ខ្លួនបួសជាភិក្ខុ ឆ្ងាយចាកកិលេសអស់អាសវៈ ប្រព្រឹត្តព្រហ្មចារ្យរួចស្រេចហើយ បានធ្វើសោឡសកិច្ចរួចហើយ មានភារៈគឺកិលេសទាំងខន្ធដាក់ចុះហើយ បានសម្រេចប្រយោជន៍របស់ខ្លួនតាមលំដាប់ហើយ មានតណ្ហាជាគ្រឿងចងក្នុងភពអស់រលីងហើយ មានចិត្តរួចផុតស្រឡះហើយ ព្រោះបានគុណសម្បទាគឺវិជ្ជាទាំងចរណៈដោយប្រពៃហើយ យ៉ាងនេះទើបប្រាកដជាប្រសើរលើសវណ្ណៈទាំងនោះដោយធម៌ពិត ព្រោះថាធម៌ជាគុណដ៏ប្រសើរបំផុតក្នុងប្រជុំជនទាំងបច្ចុប្បន្នទាំងបរលោក ។

ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ថា ម្នាលវាសេដ្ឋៈទាំងភារទ្វាជៈ កាលដែលលោកកំពុងវិនាសម្ដង ៗ មនុស្សខំបំពេញឈានចិត្ត បានទៅកើត

ក្នុងអាភស្សរព្រហ្មជាច្រើន លុះចក្រវាឡទាំងអស់រលាយទៅជាទឹកអ័ព្ទ ងងឹតសូន្យសុង ព្រះអាទិត្យព្រះចន្ទនក្ខត្តឫក្សមិនប្រាកដថ្ងៃយប់មួយខែកន្លះខែឆ្នាំនិងរដូវក៏មិនប្រាកដ គ្រាកាលកន្លងយូរអង្វែងទៅ កាលលោកកំពុងតែចំរើនមានផែនដីដុះឡើងជាដម្បូង សត្វទាំងឡាយច្យុតចាកអាភស្សរព្រហ្មបានភាពជាមនុស្សនៅលើផែនដីថ្មីនោះ សត្វទាំងនោះមានបីតិជាអាហារ មានរស្មីភ្លឺចេញឯង ត្រេចទៅក្នុងអាកាសបាន ។

សត្វទាំងនោះប្រព្រឹត្តនៅយូរទៅ មានរសផែនដីអណ្តែតលើទឹកសដូចទឹកដោះ មានសត្វខ្លះជាសត្វឡេះឡោះយកចង្អុលដៃទៅផ្តិតហើយយកមកលិទ្ធភ្លក់ ដឹងថាមានរសជាតិឆ្ងាញ់ដូចទឹកឃ្មុំនិងក្រូឃ្មុំ ក៏តាមគ្នាគៀរយករសផែនដីនោះជាពំនូតបរិភោគជាអាហារគ្រប់ពេលទៅ កាលបើសត្វទាំងនោះមានរសផែនដីជាអាហារ ពន្លឺដែលភ្លឺចេញឯងក៏សាបសូន្យទៅ លុះពន្លឺបាត់ទៅហើយ ព្រះអាទិត្យព្រះចន្ទនក្ខត្តឫក្ស ថ្ងៃយប់មួយខែកន្លះខែឆ្នាំនិងរដូវក៏ប្រាកដឡើង បណ្តាសត្វទាំងនោះបរិភោគរសផែនដីជាយូរអង្វែង កាយក៏កាន់តែរឹងប៉ឹង គ្រាកាលសត្វបរិភោគរសផែនដីជាអាហារ ពួកខ្លះមានសម្បុរល្អ ពួកខ្លះមានសម្បុរអាក្រក់ ពួកដែលមានសម្បុរល្អប្រកាន់ខ្លួនថាល្អ មើលងាយពួកសម្បុរអាក្រក់ ទោសដែលប្រកាន់ខ្លួននឹងមើលងាយគេនោះជាបច្ច័យ បណ្តាលឲ្យរសផែនដីអន្តរធានអស់ទៅ ។

លំដាប់អំពីនោះមានក្រមរផែនដីកើតឡើង សណ្ឋានដូចផ្សិតក្បាលពស់ មានរសជាតិល្អជាអាហារ ពួកសត្វទាំងនោះបរិភោគក្រមរផែនដីនោះឯងជាអង្វែងទៅ កាយក៏កាន់តែមាំមួនឡើង ទោសកើតពីប្រកាន់និងមើលងាយ ក្រមរផែនដីក៏អន្តរាយអស់ទៅទៀត ។

លំដាប់អំពីនោះកើតបទាលតា មានសណ្ឋានដូចវល្លិត្រកួន មានរសឆ្ងាញ់ពីសា បណ្តាសត្វទាំងនោះបរិភោគបទាលតានោះជាអាហារយូរអង្វែងទៅ កាយក៏កាន់តែសំណំសំនួនឡើង ទោសកើតពីប្រកាន់និងមើលងាយ បទាលតាក៏ពាយអស់ទៅទៀត ។

លំដាប់អំពីនោះកើតស្រូវសាលីដេរដាស ស្រូវនោះមានអង្ករផ្អិនស្រាប់ ឥតកន្ទក់ឥតអង្កាម បើបេះបូតព្រឹកកាត់ថ្ងៃនេះថ្ងៃស្អែកកើតវិញដូចដែល បណ្តាសត្វទាំងនោះបរិភោគអង្ករស្រូវសាលីជាអាហារ កាយក៏កាន់តែក្រៀវក្រា មិនគ្រាន់តែក្រៀវក្រាប៉ុណ្ណោះ មានភេទបែកធ្លាយជាស្ត្រីខ្លះជាបុរសខ្លះក្នុងកាលនោះ ស្ត្រីនិងបុរសនោះចេះតែសំឡឹងមើលគ្នាទៅវិញទៅមកហួសកំណត់ ទាល់តែសេចក្តីដម្រេកកើតឡើងដល់សេពមេថុនធម្ម កាលបើសត្វទាំងនោះកំពុងសេពមេថុន សត្វដទៃបានឃើញហើយដៀលត្មះប្រាសឆ្អុះថាចង្រៃ ខ្លះយកដេះ ខ្លះយកអាចម៍ដីបាចបោះហើយចៀសចេញទៅ សត្វដែលសេពនោះលុះតែកន្លងទៅ ១ ខែ ២ ខែទើបហ៊ានចូលមកកាន់ទីប្រជុំ ចាប់ដើមតាំងពីសត្វចេះសេពមេថុន

បណ្តាលឲ្យសត្វធ្វើអំពើលាមកច្រើនបែប បានសម័យមួយសត្វមួយរូប ទៅយកអង្ករស្រូវសាលីឲ្យល្មមគ្រាន់ព្រឹកល្ងាច ដំណឹងនោះដឹងដល់សត្វដទៃ ក៏ធ្វើត្រាប់តាមគ្នា ខ្លះយកឲ្យល្មមគ្រាន់ ២ ថ្ងៃ ឲ្យល្មមគ្រាន់ ៣ ថ្ងៃ ខ្លះប្រមែប្រមូលដាក់ទុក ចាប់ដើមតាំងពីសេចក្តីល្មោភកើតឡើង ស្រូវសាលីថយផលគឺកន្លែងដែលបេះបូតច្រូតកាត់ម្តងហើយលែងកើតទៀត ដល់កន្លងកាលយូរអង្វែងទៅ ពួកសត្វអស់ទាំងនោះកើតហួងហែងដល់ចែកប៉ាន់គ្នារៀងខ្លួន មានសត្វដែលល្មោភមិនបេះបូតចំណែករបស់ខ្លួន មានចិត្តលួចលួចបេះបូតចំណែករបស់គេ ហេតុនេះទេះតែកើតកើតឡើងការលួច ការតិះដៀល ពាក្យកុហក នឹងដាក់អាជ្ញាជាញឹកញយមិនមានស្រាក ។

សត្វទាំងឡាយនោះជំនុំគ្នា រើសរកសត្វដែលនឹងត្រូវត្រាច្បាប់អធិករណ៍ រើសរកទៅបានមហាបុរសដែលមានរូបល្អមានសក្តិធំប្រគល់អំណាចថា សត្វណាគួរបន្ទោសត្រូវឲ្យបន្ទោស សត្វណាគួរតិះដៀលត្រូវឲ្យតិះដៀល សត្វណាគួរបណ្តេញត្រូវឲ្យបណ្តេញ ចាំយើងទាំងឡាយជូនចំណែកស្រូវស្រែ មហាបុរសបានទទួលការសន្មតិហើយ បាននាមបញ្ញត្តិថា សម្មតិ ដល់បានជាអធិបតីត្រួតត្រាស្រែបាននាមថា ខត្តិយៈ បានញុំាងសត្វឲ្យពេញចិត្តតាមធម៌បាននាមថា រាជា ម្ចាស រាសេដ្ឋៈ នឹងការទោជៈ ខត្តិយៈកើតតាំងពីកាលនោះឯង ។

បណ្ដាសត្វទាំងឡាយសត្វពួកមួយគិតគ្នាថា ធម៌ដ៏លាមកទាំងឡាយ គឺការលួចទ្រព្យ ពាក្យតិះដៀល ពាក្យកុហក ការដាក់អាជ្ញា ការបណ្ដេញ កើតប្រាកដដល់ពួកសត្វ បើដូច្នោះពួកយើងគួរតែបន្សាត់នូវធម៌ដ៏លាមកនោះចេញ ពួកសត្វទាំងនោះនៅក្នុងជម្រំប្រក់ស្លឹកសម្ងំនូវអារម្មណ៍ ដោយកិច្ចមិនមានភ្លើងផ្សែងមិនមានត្បាល់អង្រែ ស្វែងរកអាហារព្រឹកបរិភោគព្រឹក ល្ងាចបរិភោគល្ងាច សត្វទាំងនោះបាននាមប្រាកដថាព្រាហ្មណ៍ ម្នាលវាសេដ្ឋៈនិងភារទ្វាជៈ ពួកព្រាហ្មណ៍កើតឡើងយ៉ាងនេះឯង ។

សត្វពួកមួយទៀតជាសត្វរាប់អានមេថុន ជាអ្នកមានខ្វល់ខ្វាយនឹងការសន្សំទ្រព្យសម្បត្តិ (ប្រកបការងារលក់ចេញទិញចូល) សត្វពួកនោះបាននាមថា វេស្សៈ (អ្នកជំនួញ) ម្នាលវាសេដ្ឋៈ និងភារទ្វាជៈ ពួកវេស្សៈកើតឡើងយ៉ាងនេះឯង ។

សត្វពួកមួយទៀតជាអ្នករាប់អានមេថុនដូចគ្នា (ជាអ្នកមានខ្ជះខ្ជែងសន្សំទ្រព្យសម្បត្តិដូចគ្នា ប៉ុន្តែបើនឹងប្រកបការងារច្រើនអាងកំឡាំងរបស់ខ្លួន) សត្វពួកនោះបាននាមថា សុទ្ទៈ (អ្នកក្រ) ម្នាលវាសេដ្ឋៈ និងភារទ្វាជៈ ពួកសុទ្ទៈកើតឡើងយ៉ាងនេះឯង ។

ពួកខត្តិយៈខ្លះ ពួកព្រាហ្មណ៍ខ្លះ ពួកវេស្សៈខ្លះ ពួកសុទ្ទៈខ្លះ ជាអ្នកធុញទ្រាន់នឹងធម៌របស់ខ្លួន ភៀសចេញចាកកេតរបស់ខ្លួនទៅបួសជាភិក្ខុ

ប្រព្រឹត្តស្ងប់ស្ងាត់ចាកកាមគុណទាំងឡាយ ពួកនេះបាននាមបញ្ញត្តិថា សមណៈ ម្នាលវាសេដ្ឋៈនិងភារទ្វាជៈ ពួកសមណៈកើតឡើងយ៉ាងនេះឯង ។

រឿងនេះខ្ញុំរៀបរាប់សង្ខេបខ្លី ជាសេចក្ដីត្រាន់តែនឹងបង្ហាញបញ្ជាក់ដើមកំណើតសត្វជាដំបូងតែមួយក្រុមហើយបែកបានជា ខត្តិយៈ ព្រាហ្មណ៍ វេស្សៈ សុទ្ទៈ និងសមណៈ ក៏នៅតែពីពួកមួយប៉ុណ្ណោះ បើលោកអ្នកចង់ដឹងឲ្យពិស្ដារជាងនេះ សូមឲ្យមើលក្នុងអគ្គញ្ញសូត្រ ។ ទី ៤ នៃគម្ពីរទីឃនិកាយបាដិកវគ្គឯណោះ ។

សេចក្ដីយល់របស់ខ្ញុំថា សេចក្ដីបរិសុទ្ធប្រសើរមិនមែនប្រព្រឹត្តទៅតាមជាតិតាមពួកឬតាមពូជ ដែលធ្លាប់ប្រសើរក៏បេះតែប្រសើរតកូនតទៅទៅដូច្នោះឡើយ សេចក្ដីបរិសុទ្ធប្រសើរនោះបំពោះត្រង់តែបុគ្គលដែលបានគុណសម្បត្តិ គឺវិជ្ជានិងចរណៈសេចក្ដីចេះដឹងនិងកិរិយាដែលបុគ្គលគប្បីប្រព្រឹត្តឯណោះ ទើបសមនឹងភាសិតដែលព្រះដ៏មានព្រះភាគទ្រង់ត្រាស់សរសើរគាថានេះថា

ខត្តិយោ សេដ្ឋោ ជនេតស្មឹ
យេ គោត្តប្បដិសារិនោ
វិជ្ជាចរណសម្បន្នោ
សោ សេដ្ឋោ ទេវមានុសេតិ ។

គាថានេះគឺព្រហ្មឈ្មោះសនង្កុមារសំដែងហើយ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់សរសើរថា គាថានេះពីរោះ គាថានេះល្អ គាថានេះប្រកបដោយប្រយោជន៍ គថាគតយល់ព្រមតាមថា

ក្សត្រប្រសើរបំផុតក្នុងប្រជុំជន ជាអ្នករឭកនូវគោត្រ បុគ្គលដែលប្រកបដោយវិជ្ជានិងចរណៈ ប្រសើរបំផុតក្នុងទេវតានិងមនុស្ស ៗ

ម្នាលអំពស្ឋៈ និងការឡាជៈ ព្រះបាទបសេនទិកោសលព្រះអង្គទ្រង់ជ្រាបថា តថាគតចេញចាកសក្យត្រកូលមកទ្រង់ព្រះផ្នួស ជាព្រះអរហន្តសម្មាសម្ពុទ្ធ ក៏មានសេចក្តីគោរពថ្វាយបង្គំក្រោកទទួលចំពោះតថាគត ប៉ុនអម្បាលពួកសក្យៈក៏គង់មានសេចក្តីគោរពថ្វាយបង្គំក្រោកទទួលចំពោះព្រះបាទបសេនទិកោសល បើតាមបរិយាយយ៉ាងនេះអ្នកត្រូវដឹងថា ធម៌ជាគុណប្រសើរបំផុតក្នុងប្រជុំជនទាំងបច្ចុប្បន្ននិងបរលោក ៗ

ព្រះដ៏មានព្រះភាគទ្រង់សំដែងក្នុងអម្ពដ្ឋសូត្រដូច្នេះថា បុគ្គលដែលមិនបានសម្រេចគុណសម្បទាគឺវិជ្ជានិងចរណៈ ទោះបីប្រតិបត្តិតាំងតែងយ៉ាងណាក៏នៅតែជាអ្នកបំរើ របស់បុគ្គលដែលបានសម្រេចគុណសម្បទាគឺវិជ្ជានិងចរណៈនោះឯង ទ្រង់ត្រាស់សំដែងប្រធាននៃសេចក្តីសាបសូន្យនៃគុណសម្បទាមាន ៤ ប្រការយ៉ាងនេះថា សមណព្រាហ្មណ៍ដទៃពួកខ្លះ រៀបគ្រឿងបរិក្ខារជាក់ក្នុងអម្រែករែកចូលទៅសម្ងំក្នុងព្រៃ តាំងចិត្តថា

អញ្ញបរិភោគតែផ្លែឈើដែលទុំជ្រុះឯង យ៉ាងនេះជាប្រធាននៃសេចក្ដីសាបសូន្យនៃគុណសម្បទាទី ១ ហើយជាអ្នកបំរើរបស់បុគ្គលដែលបានគុណសម្បទា សមណព្រាហ្មណ៍ដទៃពួកខ្លះមិនបានផ្លែឈើទុំជ្រុះឯង សម្ងំក្នុងព្រៃមានជ្រីកទឹងប្រែងបរិភោគតែមើមដម្លូងនិងផ្លែឈើទុំ យ៉ាងនេះជាប្រធាននៃសេចក្ដីសាបសូន្យនៃគុណសម្បទាទី ២ ហើយជាអ្នកបំរើនៃបុគ្គលដែលបានគុណសម្បទា សមណព្រាហ្មណ៍ដទៃពួកខ្លះមិនមានជ្រីកទឹងប្រែង ធ្វើរោងជិតស្រុកជិតនិគមសម្ងំបូជាភ្លើងក្នុងរោងនោះ យ៉ាងនេះក៏ជាប្រធាននៃសេចក្ដីសាបសូន្យនៃគុណសម្បទាទី ៣ ហើយជាអ្នកបំរើរបស់បុគ្គលបានគុណសម្បទា សមណព្រាហ្មណ៍ដទៃពួកខ្លះមិនបានបូជាភ្លើង សង់រោងធំក្នុងផ្លូវប្រជុំ ៤ បើកទ្វារទាំង ៤ ទិសតាំងចិត្តថា សមណព្រាហ្មណ៍ដទៃក្ដី ខរណាក្ដី មកកាន់ទីនេះ អញនឹងបូជាតាមកំឡាំងតាមមាន យ៉ាងនេះក៏ជាប្រធាននៃសេចក្ដីសាបសូន្យនៃគុណសម្បទាទី ៤ ហើយនៅជាអ្នកបំរើរបស់បុគ្គលដែលបានគុណសម្បទា គឺវិជ្ជាចរណៈនោះឯង ៗ

សង្កេតតាមពុទ្ធភាសិតទៅឃើញថា បុគ្គលដែលបានគុណសម្បទា គឺវិជ្ជាចរណៈ ប្រសើរបំផុតក្នុងប្រជុំជនទាំងបច្ចុប្បន្ននិងបរលោក អ្នកកាន់ព្រះពុទ្ធសាសនាគួរប្រាថ្នាក្រៃពេក ៗ

មានក្នុងគោវិន្ទសូត្រសេចក្ដីថា កាលជាតិបាលមាណពបានឡើង

ពេញទីជាបុរោហិត · បាននាមប្រាកដថា គោវិន្ទព្រាហ្មណ៍ ហើយគោវិន្ទ បានជួបនឹងព្រាហ្មណ៍ឈ្មោះសនង្កុមារ ដោយប្រធានយ៉ាងធំ បានស្តាប់ធម៌ ១៤ បទមានគុណពុល គឺព្រហ្មឈ្មោះសនង្កុមារសំដែង ហើយមានសេចក្តីតក់ស្លុតគិតគៀសគេទៅបួសសាងព្រត្ត ឲ្យផុតស្រឡះចាកគុណពុល ដល់បានអនុញ្ញាតអំពីសំណាក់ក្សត្រទាំង ៧ នគរ ពីព្រាហ្មណមហាសាលទាំង ៧ ពីខ្ទាន់ព្រះគេសទាំង ៧០០ នឹងអំពីភរិយាទាំង ៤០ រូបស្រេចហើយ គោវិន្ទព្រាហ្មណ៍ចេញបួសកាលណា កាលនោះក្សត្រព្រាហ្មណមហាសាលខ្ទាន់ព្រះគេសនឹងភរិយា ក៏ចេញបួសតាមទាំងអស់ មិនតែប៉ុណ្ណោះ អ្នកនគរមានសេចក្តីជ្រះថ្លាចេញបួសតាមជាច្រើន ៗ

តាំងអំពីបញ្ចសិខគន្ធព្វបុត្តក្រាបទូលយ៉ាងនេះថា គោវិន្ទនោះប្រព្រឹត្តធម៌ជាអស្ចារ្យ ចេញបួសហើយញុំាងជនច្រើនមានក្សត្រជាដើមឲ្យជ្រះថ្លាចេញបួសតាមហើយ អ្នកបួសទាំងនោះប្រតិបត្តិមិនសៀបប្រៀបប្រហែលជាមានប្រយោជន៍ទាំងអស់ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ថា ម្នាលបញ្ចសិខគន្ធព្វបុត្ត គោវិន្ទព្រាហ្មណ៍នោះចេញបួសហើយញុំាងជនច្រើនមានក្សត្រជាដើមឲ្យជ្រះថ្លាចេញបួសតាមហើយ អ្នកបួសទាំងអាចារ្យនឹងសិស្សនោះ ចំរើនបានឈាននឹងអភិញ្ញាជាច្រើនអស្ចារ្យដែរ ប៉ុន្តែព្រហ្មចារ្យរបស់គោវិន្ទ មិនដើម្បីនឿយណាយ មិនដើម្បីប្រាស

ចាកតម្រេក មិនដើម្បីរលត់ទុក្ខ មិនដើម្បីស្ងប់រម្ងាប់ មិនដើម្បីត្រាស់ដឹង មិនដើម្បីដល់ព្រះនិព្វាន ព្រហ្មចារ្យនោះប្រព្រឹត្តទៅបានត្រឹមតែស្ថានសួគ៌និងស្ថានព្រហ្មតែប៉ុណ្ណោះ មិនស្មើនឹងព្រហ្មចារ្យរបស់តថាគតដែលបានត្រាស់ដឹង ហើយបានសំដែងដល់ពួកបរិសទ្យនោះទេ ព្រហ្មចារ្យរបស់តថាគតនោះ ប្រព្រឹត្តទៅដើម្បីនឿយណាយ ដើម្បីប្រាសចាកតម្រេក ដើម្បីរលត់ទុក្ខ ដើម្បីស្ងប់រម្ងាប់ ដើម្បីត្រាស់ដឹង ដើម្បីដល់ព្រះនិព្វាន ម្នាលបញ្ចសិខគន្ធព្វបុត្ត ព្រហ្មចារ្យដែលតថាគតបានសំដែងហើយដល់ពួកបរិសទ្យនោះគឺ មជ្ឈិមាបដិបទា (ផ្លូវប្រតិបត្តិជាកណ្តាល) គឺអរិយមគ្គប្រកបដោយអង្គ ៨ អរិយមគ្គប្រកបដោយអង្គ ៨ នោះគឺ សម្មាទិដ្ឋិ យល់ត្រូវ ១ សម្មាសង្កប្បោ ត្រិះរិះត្រូវ ១ សម្មាវាចា ពាក្យសំដីត្រូវ ១ សម្មាកម្មន្តោ ធ្វើការងារត្រូវ ១ សម្មាអាជីវោ ចិញ្ចឹមជីវិតត្រូវ ១ សម្មាវាយាមោ ព្យាយាមត្រូវ ១ សម្មាសតិ រឭកត្រូវ ១ សម្មាសមាធិ ដម្កល់ចិត្តត្រូវ ១ ផ្លូវប្រសើរទាំង ៨ នេះ ប្រព្រឹត្តទៅដើម្បីនឿយណាយ ។បេ។ ប្រព្រឹត្តទៅដើម្បីដល់ព្រះនិព្វានដោយពិត ។

យើងជាអ្នកសិក្សាពិចារណាតាមពុទ្ធភាសិតនេះទៅ ឃើញពេញចិត្តណាស់ ព្រោះព្រះអរិយមគ្គទាំង ៨ នេះជាពុទ្ធសាសនាទាំងមូល

ជាផ្លូវត្រង់ជាដំណើររបស់ព្រះអរិយបុគ្គលទាំងឡាយ ព្រះអរិយមគ្គទាំង ៨ នេះជាផ្លូវប្រតិបត្តិដើម្បីបានគុណសម្បទា គឺវិជ្ជានិងចរណៈរហូតដល់បានសម្រេចនូវព្រះនិព្វានជាស្ថានក្សេមប្រសើរ ។

អ្នកកាន់ព្រះពុទ្ធសាសនាគួរប្រាថ្នាប្រតិបត្តិក្នុងព្រះអរិយមគ្គ ៨ នេះ ជាគុណដើម្បីឲ្យសម្រេចប្រយោជន៍របស់ខ្លួនផង ឲ្យរុងរឿងព្រះពុទ្ធ-សាសនាស្ថិតស្ថេរចិរកាលអង្វែងទៅផង អរិយមគ្គ ៨ នេះបើអស់លោកអ្នកប្រាថ្នាឲ្យឃើញអត្ថរសជាក់ច្បាស់ សូមឲ្យមើលសតិបដ្ឋានសូត្រ សូត្រទី ១០ ក្នុងគម្ពីរមជ្ឈិមនិកាយមូលបណ្ណាសកឯណោះ ពុំនោះសូមមើលមគ្គសំយុត្តក្នុងគម្ពីរសំយុត្តនិកាយនឹងបានចេះដឹងច្រើនឡើង ។

ខ្ញុំរៀបរាប់ក្នុងរឿងនេះមិនបានជាសេចក្តីពិស្តារទេ គ្រាន់តែជាសេចក្តីប្រួតកាត់ខ្លីៗ ឲ្យឃើញថា វិជ្ជានិងចរណៈនេះជាគុណប្រសើរបំផុត និងអរិយមគ្គទាំង ៨ ជាផ្លូវប្រតិបត្តិប្រសើរវិសេសថ្លៃថ្លា ព្រោះជាពុទ្ធសា-សនាទាំងមូល ដើម្បីបំបែរមុខសាសនិកជនឲ្យឈមទៅកាន់ផ្លូវប្រសើរនោះ សូមសន្មតតែប៉ុណ្ណោះ ។

សុន្ទរកថា

របស់ព្រះភិក្ខុលោកឆាប ពុទ្ធបណ្ឌិត

ជាតិឥតាលី ច្បាប់ទី ២

(តនឹងចប់)

ដែរ ប៉ាយ៉ិន បានបញ្ជូនសេចក្ដីអំពាលនេះមកដល់លោក ១- លទ្ធិវត្ថុនិយម (គឺការស្រុកទេស) ជាដើមហេតុនៃការប៉ះគ្នា នឹងការទទឹងទទែងគ្នា នឹងទៅជាយ៉ាងដទៃមិនមាន បំពេញបំពោកតែសេចក្ដីទោមនស្ស នឹងសេចក្ដីទុក្ខក្ដៅក្រហាយគ្មានទីបំផុត ក្រែនអុចអាលតែខាងសេចក្ដីថោកទាប ដូចយ៉ាងសេចក្ដីចងពៀរ សេចក្ដីក្រោធ សេចក្ដីលោភ សេចក្ដីឥច្ឆាឈ្នានីស នឹង ។ល។ ដោយពិត គឺជាការបើកផ្លូវទឹកនៃនរកឲ្យហូរចូលមក (ចូរមើលហេតុការណ៍របស់លោកក្នុងសម័យនេះ) រាជបល្ល័ង្កខាងប៉ែករូបធម៌ ជារបស់ដែលតែងប្រែទៅកាន់សេចក្ដីត្រាំត្រា ជីវិតរបស់អ្នកក្ដាប់អំណាចយ៉ាងលោក ៗ នេះរមែងខ្លី ២- លទ្ធិចិត្តនិយម (គឺពុទ្ធសាសនា) រមែងបណ្ដុះពូជនៃសេចក្ដីស្រឡាញ់ សន្តិសុខ សាមគ្គី មេត្រី នឹងសេចក្ដីសុខសម្រាន្ត រាជ-បល្ល័ង្កខាងប៉ែកចិត្តដូច្នេះ ឋិតថេរយូរ, ព្រះរាជាខាងប៉ែកចិត្តដូច្នេះ គឺព្រះពុទ្ធទាំងឡាយគ្រប់ ៗ ព្រះអង្គដែលបរិនិព្វានទៅហើយ ។

បណ្ឌិត យ. នេហ្រូ សេចក្ដីបំណងរបស់លោក គឺការទាមទារយកឥស្សរភាពខាងក្រៅ ដោយធ្វើការតស៊ូទទឹងទាស់នឹងអ្នកឈ្នះខាងក្រៅ សេចក្ដីបំណងរបស់ពួកអាត្មា គឺការទាមទារយកឥស្សរភាពខាងក្នុង ដោយធ្វើការតស៊ូនឹងអ្នកឈ្នះខាងក្នុង (គឺសេចក្ដីលោភ សេចក្ដីក្រោធ

សេចក្ដីវង្វេង ) ចូរសំឡឹងមើលឲ្យឃើញសេចក្ដីជាមោឃៈ (សោះទទេ) នៃបំណងនិងវិធីការរបស់លោក ចូរសំឡឹងមើលឲ្យឃើញសេចក្ដីមានផលកំរៃនៃបំណង និងវិធីការរបស់ពួកអាត្មា វិធីការរបស់យើងរហ័សហើយឥតភ័យទៀងទាត់និងខ្ជាប់ខ្ជួនល្អប្រាសចាកសេចក្ដីទុក្ខ គឺខាតទុនរបស់ខ្លួនយើងឬអ្នកដទៃ ចំណែករបស់លោកជួយគ្នានិងរបស់យើងសោះតែម្ដង ទ្រិសចង្អុលរបស់លោក គឺនរក ទ្រិសចង្អុលរបស់យើង គឺនិព្វាន ទ្រព្យខាងប៉ែកវត្ថុ ជារបស់ឥតប្រយោជន៍ ទ្រព្យខាងប៉ែកចិត្ត គឺអរិយទ្រព្យ ជារបស់ប្រសើរបំផុតហេតុម្ដេច? ហេតុថា អរិយទ្រព្យរមែងជាប់តាមទៅបាន ក្នុងវេលាដែលស្លាប់ទៅហើយ ទ្រព្យខាងប៉ែកវត្ថុ តោងបោះបង់ចោលនៅខាងក្រោយ ខ្លួនយើងត្រូវកប់ឬដុតទៅទទេ តើឲ្យផលល្អអ្វី-ត្រង់ណាខ្លះ ដល់បុរសអ្នកឧបយកលោកទាំងអស់បានហើយ ទៅនរក?" ។

បណ្ឌិត យ. នហារូ អ្វីជាបំណុចដែលប៉ុនប៉ង-ក្នុងជីវិតរបស់លោក គឺ ការលុះដល់សេចក្ដីសុខសម្រាន្ត ដោយការឃើញសច្ចធម៌យ៉ាងច្បាស់លាស់ ខ្ពល់ ៗ រូបរមែងស្រឡាញ់សច្ចធម៌ គ្មាននរណាស្អប់ខ្ពើមសច្ចធម៌ ដូច្នោះ ចូរទទួលកាន់ពុទ្ធសាសនា, ពុទ្ធសាសនា គឺ សច្ចធម៌ដែលខ្ពស់បំផុត ។

លោកបានមកកាន់ស្រុករបស់ពួកពុទ្ធបរិស័ទទាំងឥឡូវនេះ លោកកំពុងចូលទៅរកពុទ្ធបណ្ឌិតម្នាក់, ល្អណាស់!! ដោយមិនចាំបាច់ទៅរកបណ្ឌិតនៃគ្រិស្តាំង កាលនៅក្នុងប្រទេសដែលជាពុទ្ធសាសនិក, លោកនឹងឃើញសេចក្តីល្អរបស់គ្រិស្តបណ្ឌិត តែក្នុងវេលាដែលលោកទៅកាន់ក្រុងរោម, ឥឡូវនេះលោកនៅក្នុងស្រុកពុទ្ធបរិស័ទ លោកនឹងបានឃើញតែពុទ្ធបណ្ឌិតប៉ុណ្ណោះ, កាលលោកទៅកាន់ស្រុកដែលជាគ្រិស្តបរិស័ទ លោកនឹងបានឃើញគ្រិស្តបណ្ឌិត, តែនៅមិនបានជាការជួនល្មមក្នុងការដែលឃើញតែមុខមាត់ និងលក្ខណខាងក្រៅរបស់គេ, លោកតោងពិនិត្យឲ្យដឹងដល់សេចក្តីយល់ និងទឹកចិត្តរបស់គេ ដោយការទៅដល់វិហាររបស់គេ ហើយសាកសួរបញ្ហាផ្សេងៗ ក្នុងផ្លូវសាសនា ពាក្យតបរបស់គេនោះឯង នឹងបំភ្លឺឲ្យលោកជ្រាបថា "គេចេះដឹងអ្វីប៉ុន្មាន" ។

## ព្រះនិព្វានមិនមែនសេចក្តីសូន្យទេ!

លោកនេះមិនទៀង ប្រកបដោយទុក្ខ ទទេប្រាសចាកខ្លួនប្រាណ, ហេតុនេះ លោកនេះទើបជារបស់សូន្យទទេ, របស់ដែលសូន្យទទេ ក៏ចាត់ជាសភាវធម៌ ១ យ៉ាង សេចក្តីមិនមាននៃលោកដែលសូន្យទទេនោះឯង ជាសភាវធម៌យ៉ាងនោះគឺព្រះនិព្វាន ព្រះនិព្វានជាទីចូលទៅរំងាប់បង់ បំបាត់បង់នូវលោកដ៏សូន្យទទេនេះ, ព្រះនិព្វាន

ជាសភាវៈ ១ យ៉ាងដែលមាននៅ មិនមែនសេចក្តីសូន្យទេ, ព្រោះនិព្វានគឺសេចក្តីពិតដ៏ខ្ពង់ខ្ពស់បំផុត នៃសច្ចធម៌ដែលមិនចេះប្រែប្រួល, លោកនេះជាលោកនៃសេចក្តីយល់សប្តិ ដែលមនុស្សគ្រប់ៗ រូបតែងតែយល់សប្តិឃើញ, ហើយគ្មានអ្វីជារបស់ពិត ព្រោះនិព្វានជាទីភ្ញាក់ចាកយល់សប្តិ គ្មានការយល់សប្តិ ហើយគ្រប់យ៉ាងក្នុងនោះជារបស់ពិតទាំងអស់ ។

សេចក្តីទុក្ខវេទនា រមែងត្រូវរំលាយឲ្យអស់ចេញទៅបាន ដោយការឃើញសភាវធម៌ទាំងឡាយត្រូវតាមសេចក្តីពិត នុ៎ះគឺ មិនទៀងជាទុក្ខ ជាអនត្តា, ចូរមើលរូបកាយនេះជាតួយ៉ាងអ្នកណាជាម្ចាស់ អ្នក-សេចក្តីមិនទៀង អ្នក-សេចក្តីជាទុក្ខ អ្នក-ជាអនត្តា នេះឯង ជាម្ចាស់នៃរូបកាយនេះ ពួកយើងមិនមែនជាម្ចាស់ទេ ព្រោះហេតុនោះម្តេចមកកង្វល់ដោយនេះនោះថ្វីទៀត? ចោរប្រាថ្នានឹងសម្លាប់យើងៗ នឹងយំទៅថ្វី? យើងបានបង់ខាតអ្វីទៅហើយឬ? ត្រូវឲ្យអ្នក-សេចក្តីមិនទៀង-ជាទុក្ខ-ជាអនត្តានោះយំចុះ ព្រោះគេជាម្ចាស់ សុំពួកយើងកុំហាទទួលយកកាយចូលមកជារបស់ខ្លួន ការហាទទួលកាន់យកមកជារបស់យើងនោះ ចាត់ជាការលួច, ឯការលួចគេ ត្រូវបានទទួលទោសជាផលស្នងការលះសេចក្តីអាលោះអាល័យក្នុងកាយ ជាសេចក្តីគាប់តាមគន្លងធម៌

គួរបានសោយបរមសុខ, គោលនេះរមែងប្រើបាននឹងរូបក្ខន្ធ ឬអង្គនៃសេចក្ដីរស់នៅ អង្គដទៃៗបួនទៀត គឺ វេទនា សញ្ញា សង្ខារ វិញ្ញាណ ក៏មិនមែនជារបស់លោក ទាំងអស់នោះជារបស់សេចក្ដីមិនទៀង-ជាទុក្ខ-ជាអនត្តា ចូរលះបង់ ហើយតាំងនៅឲ្យគាប់តាមគន្លងធម៌ទើបជាការគួរបានទទួលសោយបរមសុខ ។

មនុស្សយើងជារបស់មិនទៀង ជាទុក្ខ ជាអនត្តា មនុស្សប្លុម រមែងត្រូវការសេចក្ដីសុខប្លុម របស់ដែលមិនទៀង រមែងត្រូវការរបស់ដែលមិនទៀង សេចក្ដីសោះសូន្យទទេ រមែងត្រូវការសេចក្ដីសោះសូន្យទទេ ល្ងង់អីដល់ម្ល៉េះ បណ្ឌិត នេហរូ លោកនឹងពួករបស់លោក កំ-ពុងរត់ទៅតាមលោកដែលសូន្យទទេ គ្មានអ្នកចូលចិត្តនឹងព្រះនិព្វានដែលជាសភាវៈ១ យ៉ាងសិងមាននៅ លោកតែងត្រេកអរទទួលនាឡិកាមាស ជំនួសសេចក្ដីទទេ ព្រះនិព្វានមិនជារបស់ខ្ពស់ថ្លៃថ្លាជាងនាឡិកាមាសទេឬ? ព្រះពុទ្ធអង្គទ្រង់ប្រគល់ព្រះនិព្វាន ដ៏គ្មានអ្វីប្រៀបស្មើ ឲ្យដល់លោកជំនួសសេចក្ដីទទេ ចុះហេតុម្ដេច លោកទើបមិនទទួលយក, ម្ដេចលោកមិនរលាស់លោក ដែលជារបស់សូន្យទទេនេះចោលចេញ ហើយទទួលយកព្រះនិព្វាន ដែលជារបស់មាននៅពិតប្រាកដ? ។

អវិជ្ជា (សេចក្ដីមិនដឹងស្គាល់របស់ពិត) ជារោគយង់ក្នុងចិត្ត នឹងរោគយង់ក្នុងកាយ ខាងណាមានពិសកំណាចអាក្រក់

ជាន់ខាងណា ? ពេលយំក្នុងដួងចិត្ត ជាពេលកំណាចបំផុត, បណ្ឌិត នេហរូ នឹងនៅជាសុខដូចម្តេចបាន ក្នុងកាលដែលលោកកំពុងទុក្ខ សោប់សេល់ដោយពេលដែលមុខគួរព្រឹមព្រើមដូច្នេះ ? លោកមិនប្រាថ្នានឹងយកពេលយំក្នុងកាយមកប្តូរយកពេលយំក្នុងចិត្តចេញទៅទេឬ ? លោកមិនប្រាថ្នានឹងទទួលពេលយំក្នុងកាយព្រមទាំងអរហត្តផលដ៏ខ្ពស់បំផុត ក្នុងខណៈជាមួយគ្នាទេឬ ? លោកជាមនុស្សខ្វាក់ក្នុងចំណែកនាមធម៌ សេចក្តីខ្វាក់ក្នុងចំណែកនាមធម៌ (គឺចិត្ត) ដូច្នេះ ជាសេចក្តីខ្វាក់ដែលអាក្រក់បំផុត លោកមានហេតុអន្តរាយដ៏ទាក់ទាមដោយភ្នែក, ចូរមកនេះចុះ ចូរឲ្យយើងកាត់ពក-កន្ទុយថ្លៃក្នុងភ្នែករបស់លោកចេញចុះ? យើងមិនគិតថ្លៃឡើយហត់ទេ ? យើងធ្វើការឲ្យដោយសេចក្តីមេត្តាករុណាដ៏បរិសុទ្ធ អញ្ជើញមកនេះចុះ កាលលោកឃើញសច្ចធម៌ហើយ លោកនឹងនៅជាសុខសម្រាន្តហូតនិរន្តរកាល ។

ធ្វើដូចម្តេចនឹងបានដល់ព្រះនិព្វានដោយឆាប់ ?·(តប) នឹងដល់ព្រះនិព្វានបាន ដោយការមិនថែមចំណីភ្លើង ឲ្យដល់គំនរភ្លើង គឺឥន្ទ្រិយទាំង ៦ ភ្នែកឆេះដង្គោលដោយភ្លើងរាគៈ ភ្លើងទោសៈ ភ្លើងមោហៈ ភ្លើងកំណើត-ចាស់-ឈឺ-ស្លាប់-សោក-បរិទេវៈ-ទុក្ខ-ទោមនស្ស-ឧបាយាស ឯត្រចៀក ច្រមុះ អណ្តាត កាយ នឹងចិត្តក៏ដូចគ្នានេះ ឆេះដង្គោលទៅដោយភ្លើង គឺ រាគៈ ទោសៈ មោហៈ ។ ល ។

ឧបាយាស សូមយើងកុំបន្ថែមឧសឲ្យដល់គំនរភ្លើងអំបាលនេះឡើយ សូមពួកយើងចូលគយឃាំប្រយ័ត្នឥន្ទ្រិយទាំង ៦ នេះ កុំឱបរឹតយឹតប្រកាន់សេចក្ដីស្រើបស្រាលនៃកាម ឥន្ទ្រិយ ៦ គឺមុខដំបៅនៃរោគឃ្លង់ យើងកុំអេះរោគឃ្លង់នេះឡើយ "ភ្នែកមិនដែលឆ្អែតដោយការមើល ត្រចៀកមិនដែលឆ្អែតដោយការស្ដាប់" កុំឱបរឹតសេចក្ដីស្រើបស្រាលក្នុងកាមឡើយ កុំផឹកទឹកប្រៃឡើយ ព្រោះថា រឹតផឹកណាស់ រឹតស្រេកក្រវល់ក្រាយណាស់ឡើង ដោយការមិនឱបក្រសោបសេចក្ដីស្រើបស្រាលក្នុងផ្លូវកាមទុក្ខនេះ គំនរភ្លើងទាំងឡាយ នឹងរលត់ទៅឯង ព្រោះវាត្រូវការគ្រឿងបញ្ឆេះទើបឆេះទៅបាន គួរលើកមហាសមុទ្រស្រោចលត់ភ្លើងអំបាលនោះបង់ ធ្វើដូចម្ដេច គឺលត់ដោយការហាត់បំរើន សមាធិភាវនា ចូរព្យាយាមដោយសេចក្ដីខ្មីឃ្មាតយ៉ាងខ្លាំងក្លា ចូរសិក្សាព្រះពុទ្ធពចន៍ដ៏រុងរឿងថ្លៃថ្លា ចូរធ្វើឲ្យច្រើន ឲ្យញយៗថែមឡើង ក្នុងសមាធិដែលរៀបរាប់នឹងឲ្យផលហើយ សឹងលោកបានយកចិត្តទុកដាក់ធ្វើមែនៗ ការបង្ហឹកសមាធិភាវនា ជាភ្នាក់ងាររលត់ភ្លើងដែលវិសេសបំផុត ចូរប្រគល់ឲ្យភ្នាក់ងាររលត់ភ្លើង ធ្វើមុខងាររបស់គេ ចូរព្យាយាមយ៉ាងប្រថុយរស់ប្រថុយស្លាប់តែម្ដង ចូរធ្វើការឲ្យសំរេចមុខគួរស្ញើ ចូរដុតបំផ្លាញបាបបន្តិចបន្តួចក្នុងគំនរភ្លើងគឺតបធម៌ដ៏ចាស់ក្លា ចូរឈ្នះភ្លើងដោយភ្លើង ចូរឲ្យភ្លើង

នៃតបធម៌ដ៏ចាស់ក្លា ឈ្មោះភ្លើងនៃកាមារម្មណ៍ កាលភ្លើងនៃកាមារម្មណ៍រលត់ទៅហើយ ក៏រលត់ជានិច្ចកាល នេះឯងគឺសេចក្ដីត្រជាក់ត្រជុំនៃព្រះនិព្វាន ជាទីដែលភ្លើងកិលេសទាំងពួង ចូលទៅរលត់មិនសល់ ។

ព្រះពុទ្ធអង្គរបស់យើងបានត្រាស់ថា មានសេចក្ដីសុខ ២ យ៉ាង: សេចក្ដីសុខនៃជីវិតដែលជារបស់លោកៗនេះ (លោកិយសុខ) នឹងសេចក្ដីសុខនៃការលះលោក (នេក្ខម្មសុខ) ក្នុងពីរយ៉ាងនេះ សេចក្ដីសុខនៃការលះលោក ជាសុខខ្ពស់បំផុត គ្មានមនុស្សណាដែលអាចរស់នៅបានដោយប្រាសចាកសេចក្ដីសុខ; យើងតោងមានយ៉ាងឯណានីមួយជាធម្មតា ដូច្នេះ សូមឲ្យយើងទទួលអំណរក្នុងសេចក្ដីសុខនៃការលះលោកចុះ! សេចក្ដីផ្អែមក្រអូប គឺសេចក្ដីសុខដោយការលះលោក សំគីពិនិត្យនៅក្នុងអនិច្ចំ, ឃើញអនិច្ចលក្ខណក្នុងរបស់គ្រប់មុខ, មិនមានខ្លួនប្រាណលើងទទេ! ចូរពិចារណាអនិច្ចលក្ខណឲ្យជាប់តគ្នាក្នុងសង្ខារធម៌ទាំងឡាយ ឲ្យឃើញនូវជីវិតនេះថាគ្រាន់តែអាការកើតបន្តគ្នារដឹកទៅ ឬជាអាការហូរដូចទឹក គ្មានទីហាមឃាត់កំណក ចូរឧស្សាហ៍ពិចារណាសេចក្ដីហូរវិលវល់នៃរបស់ទាំងពួង ចូរដឹងកថាមិនមានខ្លួនអំពីណា, តអំពីនោះទៅ យើងក៏នឹងមិនមានសេចក្ដីទុក្ខ មិនមានសេចក្ដីទោមនស្ស, នេះឯងគឺ សេចក្ដីសុខនៃការលះលោក ចូរលែងខ្លួនចូលទៅក្នុងភូមិដែលគ្មានសេចក្ដី

កើត! ចូរនៅជាសុខសម្រាន្តក្នុងភូមិដែលគ្មានសេចក្តីកើត គ្រានោះ លោកនឹងឃើញបានថា នេក្ខម្មសុខនេះ ជាសុខខ្ពស់បំផុតពិតប្រាកដ យ៉ាងណាហើយ កាលលោកភ្លក់រសនៃនេក្ខម្មសុខដែលកម្រសត្វនឹងភ្លក់បាន ដូច្នេះហើយ លោកនឹងផ្ដើម ប្រឆាម នឹងកត: ទោស: អស់កាលជានិច្ចទៅ មនុស្សយើង គឺ អណ្ដាតភ្លើងដែលឆេះដង្គោលបន្តឡើងមិនដាច់ពីគ្នា ហើយមិនមែនជាអណ្ដាតភ្លើងតែមួយដដែល ៗ សូម្បីសូនគ្នាត្រឹមពីរខណ: ក៏គ្មានឡើយ ជីវិតគ្រាន់តែជាលីលាសរបស់សេចក្តីក្លាយដែលប្រែប្រួលបន្តគ្នាទៅប៉ុណ្ណោះ អ្នកណាប្រកាន់ខ្ជាប់? អ្នកណាចង់? អ្នកណាប្រាថ្នាការស្រែកទេស? លីលាសនោះឯងប្រកាន់ខ្ជាប់ លីលាសនោះឯងចង់ លីលាសនោះឯងត្រូវការស្រែកទេស ៗល ៗ ហេតុនោះការដែលចូលទៅប្រកាន់ខ្ជាប់នូវអ្វី ៗ នោះមិនមែនជាសេចក្តីល្ងង់ខ្លៅទេឬ? អវិជ្ជារមែងកាន់យកខ្ជាប់ បញ្ញារមែងលែងបង់ មានសេចក្តីប្រកាន់ខ្ជាប់ តែគ្មានបុគ្គលអ្នកប្រកាន់ខ្ជាប់សោះឡើយ មានលីលាស តែគ្មានបុគ្គលអ្នកសំដែងលីលាសនោះ មានសេចក្តីទុក្ខ តែគ្មានបុគ្គលអ្នកទទួលទុក្ខសោះ អវិជ្ជាជាមូលហេតុនៃទុក្ខទាំងពួង បញ្ញាជាមូលហេតុនៃសុខទាំងពួង ចូរសំឡាប់អវិជ្ជាដោយបញ្ញា ចូរឃើញសង្ខារធម៌ទាំងឡាយ ឲ្យត្រង់តាមដែលពិតដូចម្ដេច អំពីនេះទៅលោកនឹងផុតរបូត

ចេញអំពីកងទុក្ខ ជីវិតជាសេចក្ដីយល់សប្ដិ ជារបស់មិនពិត ចូរក្រោកអំពីដេកលក់ដ៏យូរយ៉ាងនេះចុះ កុំយល់សប្ដិយូរពេកឡើយ ម្ដេចមកអំពល់នៅសោយទុក្ខដដែល ៗ នេះធ្វើអ្វី ? អ្នកដែលទល់ទុក្ខ គឺមនុស្សវិកលចរិត្ត អ្នកឈ្លាសវៃមែនមិនទល់ទុក្ខ ព្រោះហេតុនោះ បណ្ឌិត នេហរូ លោកចូរជាអ្នកឈ្លាស ហើយរបូតចេញពីកងទុក្ខចុះ កាលខ្លួនលោកជាអ្នកឈ្លាស ហើយលោកក៏អាចនាំអ្នកដទៃទៅបាន ដោយផ្លូវឥតមានភ័យ ។

សូមឲ្យលោកមកជាអ្នកឈ្លាសដោយរួសរាន់ចុះ សូមឲ្យលោកឃើញយ៉ាងជាក់ស្ដែងថា ជារបស់ដ៏ឧត្ដមជាងការស្រុកទេសជាច្រើនភាគណាស់ សូមឲ្យបើកពន្លឺអរុណជាថ្មីដោយរួសរាន់ចុះ កាលពុទ្ធសាសនាត្រឡប់មកជាសាសនារបស់ឥណ្ឌាវិញហើយ គ្រានោះសេចក្ដីរុងរឿងជាអាណាចក្ររបស់ព្រះបាទធម្មាសោករាជ ក៏នឹងត្រឡប់មកវិញដែរ នឹងបានឈ្នះសេចក្ដីនិយមរបស់លោកទាំងអស់បាន ជាយុគ ៗ ( គឺជាលើក ៗ ) ទៀត ហើយ កាលថ្ងៃនៃសេចក្ដីសម្រាន្តនោះមកដល់ ពុទ្ធសាសនាឥណ្ឌា ពុទ្ធសាសនាលង្កា ពុទ្ធសាសនាភូមា ក៏នឹងត្រឡប់រួមមកជាមួយគ្នា ដើម្បីករុបជាប្រទេសពុទ្ធសាសនិកជនមួយឡើងដ៏ធំក្រៃលែង ដែលអាចរួមយកទាំងអាស៊ីដែលសល់នៅ មកចូលរួមគ្នាជាមហាភាត្រភាពនៃពុទ្ធសាសនិកជាដុំកំភួនដ៏មាំមួនបាន ។

សូមសេចក្ដីប្រាថ្នាដ៏ប្រសើររបស់លោកទាំងអស់ចូរដុះដាលកើតជាផលពេញព្រៀបចុះ និងសូមឲ្យលោកសម្រេចព្រះនិព្វាន ដែលមិនមានអ្វីផ្ទឹមស្មើដោយឆាប់ចុះ សូមជូនពរដ៏ខ្ពស់បំផុត និងមេត្តាដែលគ្មានកំណត់ដល់លោក និងដល់ពួកសណ្ឋៀកល់ ៗ គ្នានិងដល់លោកទាំងអស់ ។

**លោកតាចិតុទូបញ្ញដិត**

**ជាតិឥតាលី**

**ចប់**

# ប្រជុំពាក្យកាព្យ

# ភាគទី ៣

# របស់ពួកស្រីក្នុងព្រះរាជវាំង

( តទី ៨ )

អហំសេដ្ឋោ

សេដ្ឋត្រេកសោ ព្រហ្មនោគយំ
តំទសគុលី ដលីតែងតាំង
តាមដោយសច្ចំ ពាក្យពិតសត្យា ៗ
ខ្ញុំកូនមន្ត្រី ឯកអគ្គសេនី
ជាខ្ញុំក្សត្រា ចាំពធីរៈ
ចមចក្រពជា ស្ថិតក្នុងភាព
ឥន្ទ្របត្តបុរី ៗ ក្រុងកម្ពុជា-
ធិបតីរដ្ឋា ថ្កើងព្រះបារមី
ឥស្សរសម្បត្តិ ពស្ត្ររដ្ឋច្រើនក្រៃ
ថ្កុំថ្កើងជាអយ្យ ឯកកជ្យក្សត្រា ៗ
ស្ដេចទ្រង់សន្ដោស មេត្តាប្រាណីប្រោស
ព្រះទ័យករុណា ប្រទានយសស័ក្តិ
អាណាក់ថ្លៃថ្លា លើកស័ក្តិបិតា
ខ្ញុំឡើងជាថ្មី ៗ ជាពញាតេជោ
សូរិវង្សវិពោ វរពដធរណី
តែងរិះកដគារ អាណាប្រក្រតី
បិតស្រុកនោះនៃ នាមកំពង់ស្វាយ ៗ

ទ័ពខ្មាំងក៏បះ　　លោកដកចាស់
វិលមកស្រុកអាយ　　ព្យាធិបៀតបិន
អង្គឥន្ទ្រីកាយ　　ខ្ញុំពុំសប្បាយ
កើតក្តីវេទនា ៗ　　មានចិត្តសង្វេគ
អនិច្ចារូបរោគ　　កើតកង្វល់ការ
គួរប្រែគួរប្រាស　　គួរលះចេញជា
គួរកុំស្នេហា　　ក្នុងសង្សារវដ្ត ៗ
ពាតែងសល់លេ　　ឲ្យកើតអំពល់
សិនជួបសិនព្រាត់　　ពាតែងបញ្ឆោត
បំពោតសព្វសត្វ　　គិតហើយគួរកោត
កុំសង្ស័យសោះ ៗ　　គួរយកព្រះធម៌
វិសេសមានអាថ៌　　ចាប់ចងគួរកោះ
ក្នុងដួងចិន្តា　　ឲ្យថ្លាក្សាយក្សស់
តាមបាលីព្រះ　　បន្ទូលទេសនា ៗ
រឿងអនិច្ចំ　　ជាទីកំបាំង
គ្មានទៀងត្រង់ណា　　សឹងតែប្រែស្រាយ
សព្វកាយមនុស្ស　　បទបាឡីថា

សំដីសោះសូន្យទេ ៗ    ទុក្ខកើតទុក្ខ
ពុំមានសាន្តសុខ    ហៅក្តីទំនេរ
ទុក្ខហើយទុក្ខទៀត    បង្អៀតធ្វេសទ្វេ
ពុំចេះល្ហើយល្ហែ    ទុក្ខតាល់ខ្លួនក្សៀយ ៗ
អនត្តាសូន្យសោះ    សូន្យរូបសូន្យឈ្មោះ
គួរកុំសង្ស័យ    អស់ទ្រព្យរបស់
អំរស់សព្វថ្ងៃ    គួរកុំអាល័យ
បែកពាយឲ្យទាន    ធ្វើបុណ្យសន្សំ
សាងសីលបទុំ    តាំងទុកជាស្ពាន
អាចឆ្លងដល់ត្រើយ    ល្ហែល្ហើយកុំមាន
ទុក្ខសោកលុះបាន    និព្វានសុខំ ៗ
ហេតុគេជគេជះ    ខ្ញុំអាចប្រែប្រាស
សាងសីលសន្សំ    ធ្វើបុណ្យឲ្យទាន
សង្វាតខិតខំ    ឲ្យខ្ញុំបានសំ-
រេចដូចប្រាថ្នា ៗ    មួយបើខ្ញុំបាន
ចុតពាកហ៊ាន    លែងជាតិមនុស្ស
ជារយសែនសល់    លុះដល់អនា-

គតក្ដីប្រាថ្នា ខ្ញុំពុំភ្លាំងភ្លេច ៗ
ពោះខ្ញុំយោនយក អន្ទោលទៅមក
ទាន់ព្រះសពេជ្ញ ឲ្យខ្ញុំបានជា
បុរសសំរេច ប្រាថ្នាស្រេចស្រេច
លើសលែងអ្នកផង ៗ ប្អូនខ្ញុំគិតរប់
ប្រាំពីរឆ្នាំគ្រប់ ដូចពាក្យផ្សំផ្សង
បានចូលសំណាក់ ចិត្តស្ម័គ្រស្រេង
ចិត្តចាប់គ្រាប់គ្រង សេព្រះធម៌ថ្ងៃ ៗ
ឲ្យខ្ញុំបានជា ឧបដ្ឋាកសាសនា
ចមកតដែនត្រ័យ ស្ងួនព្រះឧស្សា
នេត្រាសព្វថ្ងៃ ឃ្លាំងធម៌ប្រពៃ
ដូចខ្ញុំប្រណិធាន ៗ ខ្ញុំសូមប្រាថ្នា
ឲ្យបានចាប់មហា កំពូលព្រះនិព្វាន
មួយខ្ញុំផ្ដាត់ កងវដ្ដសង្សាន
សង្សារនេះបាន តាំងកអវិជ្ជា ៗ
ជួបចាប់កំណើត អន្ទោលមកកើត
កងកតដែនមហា កម្ពុជបុរី

សួស្តីវដ្ឋា ជាបុរេសា

ដូចចិត្តបំណង ៗ ឲ្យខ្ញុំបានរៀន

សិល្បសាស្ត្ររៀន ត្រៃបិដកផង

សំណាក់កម្មដ្ឋាន ឲ្យបានខ្ញុំសង

គុណព្រះគុរុឡោង នូវព្រះឧបជ្ឈាយ៍ ៗ

ទោះព្រៀងលានសាច់ មានគុណបំណោច

ទីងខ្ញុំក្ដីណា ឲ្យខ្ញុំបានស្នង

សងគុណថ្ងៃថ្វា កុំឲ្យអសារ

សោះគុណលោកឡើយ ៗ ទោះទ្រព្យធនធាន

អំបាលដែលមាន តិចច្រើនលោកអើយ

ឲ្យខ្ញុំចែកចាយ កុំស្ដាយសោះឡើយ

ទុកជាទានហើយ តាមចិត្តប្រាថ្នា ៗ

ទោះទ្រព្យថោកថ្លៃ កុំឲ្យសង្ស័យ

ចាប់ចិត្តចេតនា ឲ្យខ្ញុំស្មោះស្មាន

ទីងទានសីលា តាមទូន្មានមហា

ព្រះតថាគត ៗ ខ្ញុំសូមស្មាលា

ចិត្តទ្រើសឥទ្ធា ដូចជាតិស៊ុតទ្រុត

មច្ចុរ៉យំ ស្ទាំងកាំងវេទ្ធត់
ឮសីលទានវត់ ខ្លាចបង់ទ្រព្យ ៗ
ខ្ញុំសូមទៅកើត ជួបជាប់កំណើត
នៃឋានសួគ៌ ឋានតុសិតសម
ចួបជុំផងគ្នា មាតាបិតា
គ្រូឧបជ្ឈាយ៍ផង ៗ លែងជាត់ពីនោះ
ច្យុតចាកចុះ ចាប់បដិសន្ធិផង
កើតក្នុងត្រកូល កំពូលអ្នកផង
ឥតអ្នកណាហោង ផ្ទឹមត្រឹមខ្ញុំបាន ៗ
ឲ្យមានប្រាជ្ញា ប្រាជ្ញប្រសក្នុងនា
កម្ពុជពជឋាន ជាអ្នកប្រាជ្ញធំ
ឧត្ដមច្រើនឋាន ល្បីឮសព្វឋាន
ទូទិសនានា ៗ ទោះទេពទេវិន្ទ
សុកអម្រិន្ទ្រ បិតឋានសួគ៌
ឲ្យកងចាញ់ចាល ត្រអាលត្រប់គ្នា
ចុះចាកសួគ៌ មកថ្វាយស័ព្ទសា ៗ
–ធុតាវៃនអញ ខ្ញុំស្អាងបំពេញ

ដីនប្រុសប្រាជ្ញ   បានដូចប្រាថ្នា
ដោយនាអំណាច   សូមឲ្យខ្ញុំប្រាជ្ញ
ប្រុសដូចសត្វា ។

## បទព្រហ្មគីត

ទើបខ្ញុំនឹងថ្វាថ្លែង   តាយតាត់តែងតែងភាសា
ទំនងទំនងវោហារ   ដោយចិន្តាខ្ញុំគិតប៉ង ។
សូមទេវតាខ្ញុំទំព្យ   យល់ទាំងគ្រប់ដែនភពផង
ដួងចិត្តខ្ញុំសោកហោង   សឹងជាទំព្យកុំឃ្លាតឃ្លា ។
ខ្ញុំកើតមកជាតិនេះ   ពេករឹតអស់ទាំងអត្ថា
ព្យាធិមោមិតព្យា   បៀតបៀនបីនពុំស្រាកស្រាន្ត ។
ទ្រព្យធនទាំងស័ក្តិយស   មិនខ្ពង់ខ្ពស់តែសមប្រាណ
ដោយបុណ្យពីបុរាណ   បានសានមកពីបុព្វេ ។
តែកម្មអកុសល   ឲ្យអំពល់ពុំទំនេរ
វេសតែគិតគ្នាន់គ្នេរ   កុំកើតទីក្នុងមនុស្សនេះ ។
គួរលោះគួរសោលា   កុំប្រែក្លាគួរតែដោះ
តែពួនឲ្យបាត់សោះ   កុំចង់ចុះមកកើតវិញ ។
គួរទៅព្រៃពំនឹង   ជាទីពឹងទឹងលំគេញ

៙ស្រាហ៍សមាទានដេញ    ក្តីអកុសលកុំឲ្យជិត ៗ
សីល ៥ សីល ៨    សីលអដ្ឋមីស្អាតយប់ព្រឹក
តាមយ៉ាងសង្ឃប្រព្រឹត្ត    កុំរិះគិតអាល័យក្រោយ ៗ
ជាតិនេះខ្លួនមានកម្ម    ហើយចុះទ្រាំទៀតជិតដោយ
បើកើតទៅជាតិក្រោយ    តាំងអធិដ្ឋានទៅទៀត ៗ
ឲ្យខ្ញុំឈ្នះតណ្ហា    កិលេសាកាចបៀនបៀត
ជួលផ្ទះកាន់ទៅទៀត    រុះចោលចេញកុំសង្ស័យ ៗ
ចិត្តអើយកុំបន្ទន់    ប្រឹងរិះរង់ចាប់អាល័យ
ស្រុកនេះដូចព្រៃ    កុំអាឡៃដោះឲ្យដាច់ ៗ
មានខ្លាមានក្រពើ    សព្វសរពើតែងពួនផ្ទាប់
សឹកសៀតសព្វដោយសាច់    តេឲ្យគ្រូផ្កាប់មិនឈ្នះឡើយ ៗ
គួរខ្ពើមគួរអើម    គួរតែស្ញើមណាស់លោកអើយ
កុំត្រេកកុំអរឡើយ    កុំគិតស្តាយអាល័យរក ៗ
គួរស្អុះគួរស្អប់គេ    អាចារ្យមកជាពេទ្យ
ផ្តាលផ្តាញ់ឲ្យព្រៀក    កុំឲ្យរាមកកានទី ៗ
រត់រកទីដៃ    ទីងអាស្រ័យឲ្យណាយនិរ-
ទុក្ខសោកកើតភ័យរី    ចាប់រកទីបានឧត្តម ៗ

នគរនាមកែវឯក ព្រះបច្ចេកពោធិសំ-
ណាក់នៅឥតអារម្មណ៍ ឋិតនៅកំសាន្តសប្បាយ ។
គិតគ្រប់គួរវេទនា គួរស្មាលាចៀសឲ្យឆ្ងាយ
គំនិតនៅរូបកាយ នឹងរលាយលេតអន្ត ។
ឥតអ្នកណានឹងជួយ ខ្លួនតែមួយឥតគេស្រង់
សង្ឃឹមតែអានិសង្ស ជួយសង្គ្រោះដោះទុក្ខបាន ។
គេជះផលសីលា ខ្ញុំប្រាថ្នាចិត្តស្មោះស្មាន
ផលសីលនូវផលទាន ដែលខ្ញុំបានសាងសព្វជាតិ ។
សូមឲ្យអស់ទេវតា ឆកាមាមកជាអាទិ៍
ជួយឲ្យស័ព្ទសាសោទរ៍ ស្តាប់ខ្ញុំនឹងផ្សងប្រណិធាន ។
បើកើតទៅជាតិមុខ ចិត្តអាក្រក់ក្នុងសន្តាន
ចិត្តខ្ញុំកុំឲ្យមាន ប៉ុនចំរៀកសក់មួយឡើយ ។
ស្មាលាចិត្តលោភោ ពោលពាលោទ្រឿងឥតត្រើយ
លោភនោះណាលោកអើយ ជាធំលើសអកុសលផង ។
មានោចិត្តមានះ ទោសោនោះធំកន្លង
ឲ្យចៀសចេញឆ្ងាយហោង កុំចាប់ចងក្នុងចិន្តា ។
ឲ្យខ្ញុំបានត្រង់ត្រាប់ តាមសណ្តាប់ព្រះគាថា
សច្ចំខន្តីណា កតញ្ញូកតវេទិផង ។

ឲ្យបានឲ្យកាន់ខ្ជាប់ តាមដំកប់ព្រះធម៌ច្បង
ដោយដានដោយគន្លង តាមទំនងព្រះពុទ្ធអង្គ ។
កើតមកក្នុងជាតិនេះ ស្អប់អីម្ល៉េះខ្ញុំមិនចង់
តែងនាំចិត្តឲ្យរេ- រន្ធវិលវល់ក្នុងសង្សារ ។
ហេតុនេះខ្ញុំគិតដោះ ឲ្យឆ្ងាយសោះពីអវិជ្ជា
កុំស្រើបស្រួលទឹកក់ ជាអន្ទាក់ប្រាក់ចង ។
រឹតត្រួតខ្ញុំសព្វថ្ងៃ រួបជើងដៃនឹងចំណង
ក្តៅផ្សាសព្វថ្ងៃហោង ព្រោះចំណងកាចក្រៃ ។
នឹងគិតតែឲ្យរួច ឲ្យរបូតពីជើងដៃ
ចំណងកាចជាប់ក្រៃ ឥតប្រាស្រ័យអ្នកណាឡើយ ។
មានតែគុណព្រះពុទ្ធ ជាមកុដលើសិរហើយ
គុណព្រះធម៌ជាត្រើយ នូវគុណព្រះសង្ឃសីលទាន ។
នូវគុណវរបិតា វរមាតាជាប្រធាន
គុណព្រះអាចារ្យមាន តែងប្រដៅសិល្បសាស្ត្រផង ។

បទភុជង្គលីលា

ចាយវែងសំដែងសេចក្តី កំណើតជាស្រី
កើតក្នុងលោកា ។ មានស័ក្តិគ្មានលក្ខណា
កម្មបានជា ប្រកបទាំងគ្រប់ ។

ល្អអង្គល្អវង្សស្ងើតស្ងប់ គឺមោះឧបទ្រព
ពុំចៀសចេញឆ្ងាយ ៗ ដូចជិតរូបរឹតអង្គកាយ
ឲ្យជាចំណាយ អ្នកជនគ្រប់មាត់ ៗ
មានប្តីភក្តីប្រដិព័ទ្ធ ឃើញប្រុសទៀតទាត់
ចោលប្តីបង់សៀត ៗ ប្តីដឹងដំណឹងខំឆ្លៀត
លួចលបលាក់ទៀត ហើយស្បថបំពាន ៗ
ខ្ញុំសូមចៀសចាកពីសន្តាន ជាតិស្រីសាមាណ្យ
ដូចតាំងប្រាថ្នា ៗ ជាបុរសស្រេចស្រស់ថ្ងៃថ្លា
ក្នុងព្រះសាសនា ត្រើយត្រៃសរ.ពជ្ញ ៗ
ដល់បាននិព្វានសំរេច វិនាសក្តិលផ្តាច់
អស់អវិជ្ជាជង ៗ គួរក្ដួចចិន្តា[1] ?
គួរប្រាសគួរលះសង្សារ គួរកុំស្នេហា
វិលមកកើតទៀត ៗ ជាតិក្រោយក្រែងក្លាយបង់សៀត
វិលមកកើតទៀត ជាស្រីអប្បលក្ខណ៍ ៗ
ជាតិក្រោយស្អានកុំឲ្យអាក់ គេជះចិត្តអ្នក
ឲ្យដូចប្រាថ្នា ៗ កើតក្នុងលោកិយនេះមហា.

---

១ ពាក្យនេះ ហាក់ដូចជាលើស ឬបាត់ សេចក្ដីមិនជាប់ចុងចួនសោះ បើបាត់យើងនឹងបំពេញដូច្នេះ ក៏ល្មមបានសេចក្ដីដែរ គឺ: គួរក្ដួចចិន្តាប៉ុនប៉ង លះគ្រឿងសៅហ្មង សព្វគ្រប់ប្រការ ។

អប្បយសអាត្មា   គ្រប់សព្វសេចក្តី ។
ជាតិក្រោយកុំឆ្ងាយឡើយនៃ   បានជួបព្រះស្រី
បមកពរ័តន៍ត្រ័យ ។   គន់លើសំពៅមាសថ្លៃ
លឿនលន់ប្រៀបប្រែ   លើផលសាហាន ។
អណ្តែតត្រៃសែតហោន   កដហង្សមាសមាន
ហិចហោះនភី ។   ដល់ឋានដែនដានទិពទី
សត្តពោជ្ឈង្គមណី   បានព្រះពុទ្ធអង្គ ។
រលត់ទុក្ខជុំប្រាំពីរវង់   នាមសត្តពោជ្ឈង្គ
តែងផ្ទុកសត្វផង ។   សល់សែនសង្ខេយ្យាសោតហោង
ទីនាសទុក្ខផង   ពុំដែលជិតដល់ ។
ទីសោកទីកេតទុក្ខទល់   ទីក្តីអកុសល
សឹងសាបសូន្យសោះ ។   ដល់ត្រើយគួរកុំស្រណោះ
វដ្តសង្សារនោះ   កាតែងវិលវល់ ។
គួរខ្លាចអំណាចកសល់   គួរកុំអំពល់
ធៀងរកកកៀត ។   ក្រែងធ្លាយក្រក្រោយបង្អៀត
មាតុគ្រាមកសៀត   សិកសព្វកង្កាយ ។
គ្មានសុខតែទុក្ខអំបាយ   គួរបៀសឲ្យឆ្ងាយ

គួរកុំស្តាយសោះ ។ តាំងចិត្តប្រាថ្នាចំពោះ
សូមទេពទិសទស ជួយជាទិព្វញ្ញាណ ។

អ្នកម្នាងកុឡាប

ពាក្យនេះពុំបានជាឧត្តមប៉ុន្មានទេ តាំងសេចក្តីប្រាថ្នាសុំកើតជាបុរស សេចក្តីសារស័ព្ទឃើញជានឿយណាយក្នុងលោកនេះ សុំទៅកើតឯឋានសួគ៌ ហើយសុំឲ្យបានជាអ្នកប្រាជ្ញធំក្នុងក្រុងកម្ពុជា ។

តាំងសេចក្តីប្រាថ្នាវិលវល់ ដោយហេតុជាស្រីក្នុងព្រះបរមរាជវាំង បើទុកជាដូច្នោះក៏គួរគប្បីរក្សាសំនួនទុក ។

# ហិតោបទេស ភាគទី ១

## «ការបងមិត្រ»

ឧកញ៉ាទេពពិទូរ ក្រសេម គន្ធរបនបណ្ឌិត

ប្រែនឹងរៀបរៀង (ត)

១២០ ប្រុសជក ទោះបីមិនអាចសេពសន្ធៈបាន តែនឹងលះ បេញក៏មិនព្រមដែរ (ចូលចែប) សោណជាតិ (ថ្នក) សូម្បីធ្លេញបេរីលេ សុំឲ្យតែបានលិទ្ធផ្គងគម្រង់ប៉ុណ្ណោះ ក៏សប្បាយចិត្តហើយ ។

មិនយូរប៉ុន្មាន នាងលីលាវតី ជាស្រីក្រមុំ (កំពុងពេញជម្រែក) មិនបានគិតមុខក្រោយ ក៏ប្រព្រឹត្តកន្លងមារយាទកុលប្រវេណី លបស្រឡាញ់ប្រុសកំលោះកូនពាណិជម្នាក់ ព្រោះ-

១២១ ទៅតាមអំពើចិត្ត នៅក្នុងផ្ទះរបស់បិតា ដើរមើលហែហមនក្ខត្តឫក្ស សមាគមហួសប្រមាណនឹងប្រុសដែលទាក់ទាមជាញាតិ នៅក្នុងទីលំនៅផ្សេង បួកឡូកនឹងស្រីអាក្រក់ ខ្ជះខ្ជាយក្នុងការចាយទ្រព្យ សេចក្តីចាស់ជរារបស់ស្វាមី មានចិត្តឫស្សា ស្វាមីចេញទៅក្រៅទីលំនៅ អំពាលនេះជាហេតុឲ្យស្ត្រីដល់នូវសេចក្តីវិបត្តិ ។

១២២ ការសេពសុរាមេរ័យ បួកឡូកនឹងមនុស្សអាក្រក់ មិននៅផ្ទះប្តី ត្រេចដើរកាយមាយ ដេកប្រែន អាស្រ័យផ្ទះអ្នកដទៃ ៦ យ៉ាងនេះជាហេតុឲ្យស្ត្រីសាបសូន្យ ។

១២៣ ម្នាលលោកនារេ[១] គ្មានទឹកខ្មែង គ្មានទុកាស

---

១ ជាឈ្មោះឫស៊ីដ៏ល្បីឈ្មោះ ១ ។

គ្មានប្រុសមកសមាគមស្រឡាញ់ផង (កាលគ្មាន) ដូច្នេះ សេចក្ដីបរិសុទ្ធទើបកើតមានដល់ស្ត្រីបាន ។

១២៤ គង់មិនមានប្រុសណាជាទីពេញចិត្តជាប្រាកដ ឬមាន តែមិនជាទីកំណាន់ (របស់ស្ត្រី) ដូចយ៉ាងគោ ចូលចិត្តរកតែស្មៅថ្មី ៗ ស្រស់ ៗ តទៅ ។

១២៥ តាមពិត ស្ត្រីមានចិត្តប្រែប្រួលជានិច្ច ទោះនៅក្នុងប្រជុំទេវតាក៏នៅល្បីឈ្មោះ បុរសឯណារក្សានារីទុកបាន កប់ថា គេអំបាលនោះគ្រោះល្អបានសុខ ។

១២៦ ហេតុដែលស្ត្រីទ្រង់សេចក្ដីបរិសុទ្ធិនៅបានមិនមែនថា ពីព្រោះគេអៀនអន់ មានចរិយាសម្បត្តិ មានសេចក្ដីសុចរិតនឹងស្វាមី ឬមានសេចក្ដីកោតញញើត ក៏ទេដែរ តាមដោយពិតព្រោះខ្វះអ្នកប្រាថ្នាប៉ុណ្ណោះឯង ។

១២៧ នារីស្មើដូចថ្នាំងប្រេង បុរសស្មើដូចរងើកភ្លើង, ព្រោះហេតុនោះ អ្នកដែលដឹងហើយ ទើបមិនគួរនាំយកថ្នាំងប្រេងនឹងភ្លើងទៅទុកក្នុងទីជាមួយគ្នា ។

១២៨ បិតារក្សាក្នុងវ័យនៅក្មេង ភស្ដារក្សាក្នុងវេលាក្រមុំ បុត្ររក្សាក្នុងសម័យចាស់ជរា; ធម្មជាតិជាស្ត្រីនឹងរក្សាខ្លួនឯងមិនបានឡើយ ។

១២៩ បុរសមិនគួរនៅក្នុងទីកំបាំងជាមួយមាតាឬបងប្អូនក្រមុំ ឬកូនក្រមុំ, ព្រោះសេចក្ដីតម្រេក មានអំណាចអាចគ្របសង្កត់អ្នកដែលដឹងខ្សែងនឹតមុខបាន ។

នាថ្ងៃមួយ នាងលីលាវតីប្រដាប់ដោយគ្រឿងមាសពេជ្រផ្សេងៗ អង្គុយប្រឡែងលេងនឹងប្រុសសហាយបុត្រពាណិជនៅលើគ្រែយ៉ាងសប្បាយ, ក្រឡេកឃើញប្ដីដើរចូលមកដោយមិនទាន់ដឹងក៏ក្រោកឡើងភ្លាម ស្ទុះទៅទទួលមុខប្ដី ធ្វើកិរិយាញិកញាក់ផ្អកផ្ដិតឱបថើប ។ ចំណែកឯប្រុសសហាយបានឱកាសក៏ក្រោករត់ទៅបាន លោកទើបថា–

១៣០ ព្រះឧសនា(១) យល់ក្នុងកលសាស្ត្រឯណា ព្រះព្រហស្បតិ៍យល់ក្នុងកលសាស្ត្រឯណា កលសាស្ត្រនោះមានប្រចាំនៅយ៉ាងល្អក្នុងប្រាជ្ញស្ត្រី តាមសភាពមកហើយ ។

គ្រានោះ ស្រីពេស្យាម្នាក់ ដើរកាត់ទីនោះទៅ ឃើញនាងលីលាវតីឧបរតិប្ដី (ខុសធម្មតា) ទើបនឹកថា "គ្មានហេតុហើយនាងគង់មិនឧបរតិប្ដីដូច្នេះ" តែមិនយូរក៏ដឹងហេតុនោះបាន នាងលីលាវតី ក៏ត្រូវស្រីពេស្យាកំហែងយកប្រាក់យ៉ាងស្ងាត់ៗ ។

ព្រោះហេតុនោះ ខ្ញុំ (វិណាកណ៌) ទើបថា "កិរិយាក្រមុំធ្វើកិរិយាថៃថើប ប្ដូរសក់ ឧបរតិប្ដីជាដើម ។ល។ (១១៦) ។

---

១ ព្រះសុក្រ ។

ចំណែកកណ្តុរនេះគង់មានហេតុអ្វី ១ យ៉ាង ទើបធ្វើឲ្យមានកំឡាំងដល់ម្ល៉េះ,” បរិញ្ញាជកត្រិះរិះមួយស្របក់ហើយទើបនិយាយថា មើលទៅប្រហែលជាការមានទ្រព្យឧត្តមនេះឯង ជាដើមហេតុក្នុងនេះ ព្រោះ–

១៣១ ក្នុងលោកនេះ ក្នុងទីត្រង់ស្ថាន, ក្នុងសម័យសព្វកាល, បុគ្គលគ្រប់រូប មានទ្រព្យរាប់ថាមានកំឡាំង សូម្បីអំណាចស្តេច ក៏គោងកើតឡើងដោយទ្រព្យជាមូលហេតុ ។

លំដាប់នោះបរិញ្ញាជក (អ្នកបួសនោះ) កាន់យកចបទៅជីករន្ធដែលខ្ញុំ (ហិរណ្យក:) នៅ រែយកទ្រព្យដែលខ្ញុំសន្សំទុកមកយូរហើយទៅអស់ ។ ខ្ញុំអស់កំលាំងអស់សេចក្តីក្លាហាន ទឹងហោចសេចក្តីព្យាយាមចុះកល់ថ្ងៃ មិនអាចស្វែងរកអាហារដើម្បីខ្លួនបាន ទើបដើរត្រណាត់ត្រណែងវិលវល់ទៅមកតាមបរិវេណនោះ ចូឡាកណ៌ឃើញខ្ញុំក៏និយាយឡើងថា–

១៣២ ក្នុងលោកនេះ បុគ្គលដែលទឹងមានកំលាំងក៏ព្រោះ
ទ្រព្យ ទឹងជាបណ្ឌិតក៏ព្រោះទ្រព្យ ចូរមើលកណ្តុរនេះជា
គួយ៉ាង បានត្រឡប់សភាពទៅតាមភូមិភេទរបស់វាហើយ ។

១៣៣ បណ្តាកិច្ចរបស់បុរសអ្នកមានដំណឹងតិច អស់
ទ្រព្យធេងហើយ ក៏ទឹងរលំរលាយដូចកល់ទឹកត្រពាំងក្នុង
គិម្ហរដូវដូច្នោះ ។–

១៣៤ អ្នកមានទ្រព្យ ក៏មានមិត្រសំឡាញ់ អ្នកមានទ្រព្យ ក៏មានបក្ខពួកបងប្អូន អ្នកមានទ្រព្យរាប់ថាមានកេរ្តិ៍ឈ្មោះក្នុងលោកនេះ អ្នកមានទ្រព្យគេក៏ប្រកាន់ថាជាបណ្ឌិតទៅផង ។

១៣៥ ផ្ទះអ្នកដែលគ្មានបុត្រ ក៏ដូចជាផ្ទះទទេ ផ្ទះអ្នកដែលគ្មានមិត្រក៏ដូចគ្នា ទិសរបស់មនុស្សមិនឃើញស្រ-មោលអ្វីសោះឡើយ ក៏សូន្យទទេ អ្នកខ្សត់ទ្រព្យជាអ្នកសោះសូន្យទទេជាងទាំងអស់នេះ ។

១៣៦ ក្នុងសេចក្តីក្រនឹងសេចក្តីស្លាប់ទាំងពីរនេះ គេប្រកាន់ថា សេចក្តីពាល់ក្រ អាក្រក់ជាងសេចក្តីស្លាប់ឲ្យទុក្ខក៏តែក្នុងវេលាស្លាប់ ចំណែកសេចក្តីពាល់ក្ររមែងឲ្យទុក្ខវេទនានៅទុះឯងដរាបល្មុះអស់ជីវិត ។

១៣៧ ឥន្ទ្រិយនោះ ៗ មិនវិកលហើយ កេរ្តិ៍ឈ្មោះក៏គង់នៅ បញ្ញាមិនវិបរិតហើយ វាចាក៏មិនប្លែក រីឯបុរស (អ្នកមានឥន្ទ្រិយអំបាលនេះ) មករសាត់អស់ធាតុអ៊ុនពោលគឺទ្រព្យហើយ គេក៏ប្រែទៅមួយរំពេច មុខគួរអស្ចារ្យអីម៉្លេះហ្ន៎ធម្មជាតនេះ ។

កាលបានពុទ្ធដូច្នេះចប់ចុះហើយ ខ្ញុំរំពឹងថា អញនឹងនៅក្នុងទីនេះតទៅមិនគួរ ហើយនឹងដំណាលរឿងនេះឲ្យអ្នកដទៃស្តាប់ក៏មិនគួរដែរ ព្រោះ—

១៣៨ អ្នកចេះដឹងមិនគួរប្រកាសសេចក្ដីបង់ខាតទ្រព្យ (របស់ខ្លួន), សេចក្ដីទុក្ខព្រួយក្នុងចិត្ត, ការអពមង្គលក្នុងផ្ទះ, ការត្រូវបោកបញ្ឆោត, និងសេចក្ដីអាម៉ាស់មុខ (ដល់អ្នកក្រៅ) ។

១៣៩ លក្ខណៈគួរបិទបាំងឲ្យជិត ៩ ប្រការ គឺអាយុ, ទ្រព្យសម្បត្តិ, សេចក្ដីទុក្ខក្នុងចិត្ត, សេចក្ដីខ្ជីខ្ជាក្នុងផ្ទះ, មន្ត, មេថុន, ថ្នាំដែលបរិភោគ, តបៈកម្ម, សេចក្ដីចែកចាយ និងសេចក្ដីអាម៉ាស់មុខ ។

១៤០ កាលវាសនាមិនជួយ សេចក្ដីព្យាយាមរបស់បុរសក៏សូន្យប្រយោជន៍; ហេតុនេះ អ្នកមានបញ្ញា តែងធ្លាក់ក្រខ្សត់ហើយនឹងរកសេចក្ដីសុខក្នុងទីណាបានក្រៅអំពីព្រៃ ។

១៤១ មនុស្សចិត្តដាច់ព្រមស្លាប់ដោយស្រួល. តែមិនព្រមឲ្យក្រខ្សត់ អគ្គីពោះបីលត់ហើយ ក៏នៅមិនទាន់ដល់ភាវៈជាធាតុត្រជាក់ភ្លាមតែម្ដង ។

១៤២ សេចក្ដីប្រព្រឹត្តទៅរបស់បណ្ឌិត ប្រៀបដូចបង្កោមផ្កាដែលមានគតិជា ២ ស្ថាន គឺសម្រាប់ជនទាំងពួងសៀតប្រដាប់ក្បាល ឬមិនដូច្នោះក៏ស្វិតក្រៀមនៅក្នុងព្រៃ ។

កាលទឹងទ្រាំទល់ទុក្ខសុំទានគេនៅទីនោះ ក៏វេទនាណាស់ ព្រោះ–

១៤៣ ជីវិតរបស់អ្នកអស់ទ្រព្យ រត់ចូលគំនរភ្លើងឲ្យស្លាប់ទៅប្រសើរជាងទៅអង្វរសុំទានអ្នកកំណាញ់ដូជាតិ ។

១៤៤ សេចក្ដីទាល់ក្រ ធ្វើឲ្យបុគ្គលដល់នូវសេចក្ដីអប្បយស បានទទួលអប្បយសហើយ ក៏ដល់នូវសេចក្ដីថយតេជះ, សេចក្ដីថយតេជះធ្វើឲ្យជាទីស្អប់ខ្ពើម, សេចក្ដីត្រូវស្អប់ខ្ពើម, ធ្វើឲ្យត្រូវអាស្រ័យអ្នកដទៃ កាលជាអ្នកអាស្រ័យគេហើយ ក៏ពលរហូតដល់សេចក្ដីទុក្ខសោក, សោយទុក្ខសោកហើយ, បញ្ញាក៏អប្ប, អប្បបញ្ញាហើយ ក៏ធ្លាក់ដល់សេចក្ដីរលំរលាយសោះសូន្យ, អនិច្ចា ! សេចក្ដីខ្សត់ទ្រព្យជាមូលនៃវិបត្តិទាំងអស់ ទេតើ ។

១៤៥ ស៊ូទ្រាំស្ងៀមជាជាងនិយាយពាក្យអសត្យ ទ្រាំអត់សេចក្ដីពេលកលជាជាងសេពគប់ករិយាគេ, លះជីវិតបង់ជាជាងចូលចិត្តស្ដាប់ពាក្យសរសៀត, ជាយាចកជាជាងអាស្រ័យទ្រព្យគេបរិភោគ ។

ករិយា ៧ ប្រការ

# អាចារ្យ ហ. ឈា ក្រុមជំនុំព្រះត្រៃបិដក

# បានដកស្រង់ពីគម្ពីរ

# អង្គុត្តរនិកាយ សត្តកនិបាត

តែងជាពាក្យកាព្យ

បទកាកគតិ

ព. ស. ២៤៨១

# ភរិយា ៧ ប្រការគឺ

១ — វធកា ភរិយា

២ — ចោរ ភរិយា

៣ — អយ្យា ភរិយា

៤ — មាតា ភរិយា

៥ — ភគិនី ភរិយា

៦ — សខី ភរិយា

៧ — ទាសី ភរិយា

ខ្ញុំម្ចាស់សូមក្រាប សិរពេទន់ទាប
ប្រណម្យវន្ទា ឆ្ពោះរត្នទាំងបី
ដោយភក្តីសទ្ធា សូមមានជយា
សិរីសុខា ៗ រួចប្រែភាសិត
រិះដោយទំនិត តាមន័យគាថា
ចងជាពាក្យកាព្យ សម្រាប់បណ្ដា
ជនដែលសិក្សា រៀនមើលស្រួលមាត់ ៗ
តែចាំកាលណា ងាយអានងាយថា
មិនសូវជ្រួសភ្លាត់ ព្រោះពាក្យជួន ៗ
ឆ្លើយគ្នាតាមបទ ប្រាំពីរវគ្គគត់
ជាមួយល្បះឃ្លា ៗ ទឹងថ្លៃងពីស្រី
នៅក្នុងលោកិយ ចិត្តស្មើខុសគ្នា
ស្មើមួយគួរយក ស្មើមួយគួរលា
ស្មើមិនដូចគ្នា មានពីរចំណែក ៗ
ឯស្មើគួរយក ព្រោះចេះគិតរក
ប្រយោជន៍ថ្លៃក ៗ ជាមួយស្វាមី
ឥតបីប្រកែក បើប្ដីអស់ឯក

ខ្លួនឯងធ្វើមុន ៗ ឯស្នើគួរណា
ព្រោះចិត្តខ្លីខ្លា ប្រទុស្តនឹងគុណ
ប្រមាញទៅខុស បង្អស់ទ្រព្យធន
គ្មានគិតបាបបុណ្យ ចង់តែហឺហា ៗ
ឯស្រីមានខ្មាស ប្រាជ្ញក្នុងពុទ្ធសាសន៍
ប្រកាសប្រាប់ថា ខ្លួនមានពូជពង្ស
ត្រកូលថ្លៃថ្លា មិនត្រូវក្លៀវក្លា
គួរកាន់កេរ្តិ៍ខ្មាស ៗ ឯស្រីវេស្សា
ត្រូវតែងកាយា ហឺហាឲ្យណាស់
ទើបប្រុសអាចហ៊ាន ចូលរួមសង្វាស
តែកាន់កេរ្តិ៍ខ្មាស វិនាសមិនខាន ៗ
សុភាសិតនេះ ខ្ញុំបានត្រិះរិះ
តាមន័យបុរាណ សំស្ក្រឹតគាថា
ទុកជាលំអាន ន័យខ្លះឈប់ខាន
មិនបានតែងទេ ៗ ក្រែងលោកឯណា
គបដោយប្រាជ្ញា ឈ្លាសវៃជាងគេ
សូមទានបំពេញ ពាក្យពីបុរេ
ទុកឲ្យយើងគេ មើលទូន្មានប្រាណ ៗ

ន័យជាបន្ទាប់ ខ្ញុំសូមរៀបរាប់
ពីស្រីក្នុងស្ថាន ដែលជាភរិយា
បុរសគ្រប់ប្រាណ កំណត់ឈ្មោះបាន
ប្រាំពីរប្រការ ៗ ភរិយាទី ១
ចិត្តគ្មានគិតជួយ គិតតែឫស្យា
ប្រទុស្តស្វាមី ឥតក្តីករុណា
ដូចខ្មាំងមោហា ស្តីថាមិនស្តាប់ ៗ
ចូលចិត្តកែកាយ ពាព្រិតពព្រាយ
បូរស់បូរស្វាប់ នឹងប្រែសដៃ
ទោះបីយូរឆាប់ គិតតែសំឡាប់
ស្វាមីអាត្មា ៗ ភរិយាទី ២
លំបាកពេញទី នឹងថៃរក្សា
ព្រោះចិត្តគុំគួន ដូចចោរឫស្យា
គិតតែប្រាថ្នា លួចទ្រព្យសម្បត្តិ ៗ
ដែលប្តីស្វែងរក បានហើយយកមក
លាក់ទុកមិនស្វាត់ តែស្ងៀមក្បួចខ្លួន
ឆក់លួចបំបាត់ ដើម្បីទុកដាក់

ចាយតែម្នាក់ឯង ៗ ព្រោះចិត្តរំពឹង
រំពៃដញ្ញឹង គិតតែពីស្វែង
ស្ទុះទៅខាងក្រៅ រត់បោលគ្នាឯង
ឲ្យប្ដីចំបែង កើតទោសទុក្ខា ៗ

កិរិយាទី ៣ ឥតចិត្តមេត្រី
អាសូរកស្ដា គិតតែខាងខ្ជិល
ប្រអូសកាយា ខ្ជិលថែរក្សា
រៀបចំទុកដាក់ ៗ ចិត្តសោតតក់ម៉ក់
សំដីអាក្រក់ ប្រាសឆ្អេះឥតអាក់
កំហែងគំហក ដាក់ស្វាមីភក្ដិ
ឲ្យស្វែងរកប្រាក់ ចិញ្ចឹមអាត្មា ៗ

ដំកើងខ្លួនឯង មិនមានកោតក្រែង
ខ្លាចចិត្តកស្ដា ធ្វើបុកដូចម្ចាស់
ទៅហ្វាយទកញ៉ា បើប្ដីស្ដីថា
សំឡក់ក្រោធខឹង ៗ កិរិយាទី ៤
មារយាទខ្ជាប់ខ្លួន ចេះមានដំណឹង
ចេះទុកចេះដាក់ ទោះប្រាក់មួយស្លឹង
ចេះតែប្រឹតប្រៀង ស្លឹងមួយជាទ្វី ៗ

កើតឡើងជាមាន ព្រោះចិត្តមិនហ៊ាន
ខ្លះខ្លាយវក់វី ក្រែងចិត្តស្វាមី
ដោយភក្តីសាមគ្គី តាំងខ្លួនក្នុងទី
មេត្រីចិត្តមួយ ៗ ព្យាបាលរក្សា
ស្វាមីអាត្មា មិនឲ្យមានព្រួយ
ដូចម្តាយថែកូន លើកពបីស្ងួយ
ពិសេសត្រូវអ្វីមួយ ទាំកូនពុំបាន ៗ

ករិយាទី ៥ ខ្លាចបាបៈកម្ម
ត្រាំក្នុងសន្តាន ស្លូតត្រង់សុចរិត
គោរពកប់អាន ស្វាមីកល្យាណ
មិនឲ្យមានហ្មង ៗ ដូចជាប្អូនស្រី
មានចិត្តមេត្រី កោតខ្លាចប្រុសបង
ស្តីថាលើសខ្លះ មិនហ៊ានឆ្លើយឆ្លង
ខុសម្តងផ្គងម្តង ខំអត់សង្កត់ ៗ

ករិយាទី ៦ ជាមិត្រឥតព្រួយ
ទោះមានទោះខ្សត់ តែងតែរួមសុខ
រួមទុក្ខប្រាកដ បើប្តីនឿយហត់

ហ៊ានជួយក៏ប៉ុន្នេះ ៗ ចិត្តសោកជាល្អ
ប្រព្រឹត្តធមិស សាមគ្គីគប់គ្រង
មានវត្តប្រតិបត្តិ មិនឲ្យខុសឆ្គង
រីករាយបំព្រង ទៅរកស្វាមី ៗ
ដូចមិត្រសំឡាញ់ ពេញចិត្តឥតខ្ចាញ់
ជួបគ្នាថ្មី ៗ មិនដែលពោលពាក្យ
ទ្រគោះអប្រិយ ឲ្យបែកមេត្រី
សេចក្តីកប់អាន ៗ ករិយាទី ៧
ចិត្តមិនវៀចវិល ពីកស្តាប្រាណ
ទោះស្តីជេរថា យ៉ាងណាប៉ុន្មាន
អាចទប់ចិត្តបាន មិនតបតវិញ ៗ
ដូចជាទាសី ទោះម្ចាស់ជេរស្តី
ធ្វើទុក្ខបុកម្នេញ ក្រេវក្រោធឡូឡា
មិនតវ៉ាវិញ អត់ឱនបំពេញ
ចិត្តនាយទៅហ្វាយ ៗ ករិយាទាំងអស់
ខ្វះចិត្តសប្បុរស ខ្វះពាលក្លែងក្លាយ
បែកជាពីរផ្នែក តាមដោយបរិយាយ
អត្តាធិប្បាយ នៃព្រះសាស្តា ៗ

ទ្រង់ត្រាស់សំដែង ទេស្នាតាក់តែង
ដោយព្រះគាថា ចំពោះនាងស្រី
ឈ្មោះសុជាតា ជាកូនប្រសា
នៃមហាសេដ្ឋី[១] ៗ មានទ្រព្យស្តុកស្តម្ភ
ជាទីឧបត្ថម្ភ ដល់ជនប្រុសស្រី
ក្រផុតទីពឹង ដូចប្រែតអប្រិយ
ចូលដល់សេដ្ឋី បាត់ក្តីស្រែកឃ្លាន ៗ
ឯរឿងសេដ្ឋី ឈប់ស្ទេះកាត់ខ្វី
មិនបានទិទាន ទឹងសូមសំដែង
ថ្លែងតាមបទមាន កាលព្រះទ្រង់ញាណ
សំដែងថែកថា ៗ ស្រី ៣ ខាងដើម
លុះដាច់ដង្ហើម ស្លាប់ទៅកាលណា
ធ្លាក់ក្នុងអបាយ ក្រហាយខ្លោចផ្សា
ព្រោះទោសអាត្មា ប្រមាថស្វាមី ៗ
ស្រី ៤ ខាងចុង គំនិតបេះប្រុង
ប្រយ័ត្នស្មារតី កាន់ធម៌សុចរិត
ចិត្តស្មោះនឹងប្តី បើនិយាយស្តី

១ ឈ្មោះអនាថបិណ្ឌិក ។

សុភាពពកបសា ៗ ស្រី ៤ នេះឯង
ព្រះទ្រង់សំដែង ចង្អុលប្រាប់ថា
ស្លាប់ទៅសោយសុខ សម្បត្តិទេវតា
មានទេពកញ្ញា ហោមរោមប្រក្រតី ៗ
បើកើតជាមនុស្ស ត្រកូលក៏ខ្ពស់
គង់នាលោកិយ រូបសោតក៏ល្អ
សាច់សល្អិតខ្ចី ស្រស់លើសជាងស្រី
ព្រោះក្តីសុចរិត ៗ សូមលោកអ្នកប្រាជ្ញ
ប្រតិពលអង់អាច យល់ច្បាស់ភាសិត
ក្រែងពាក្យខ្ញុំតែង ខ្វែងទាស់ក្នុងចិត្ត
សូមទានប្រសិទ្ធិ ជួយកែជម្រូវ ៗ
សត្តៈគរុយោ ស្មេះឈប់ពណ៌នា
ពីការខុសត្រូវ សូរេចនិដ្ឋា
សង្ខេបទុកទៅ លែងតែងតទៅ
ព្រោះគ្មានវេលា ៗ សូមលោកអ្នកស្រី
ទោះចាស់ក្មេងក្តី កុំស្តីនិន្ទា
ដល់ខ្ញុំអ្នកតែង ក្រែងមានវេរ
គួរតែចាំគ្នា សិក្សាទៅហោង ៗ

# រឿងព្រេងខ្មែរ – ច្បាប់កឹងកន្ត្រៃ

នេះសាស្ត្រាកឹងកន្ត្រៃ ពោធិសត្វកាត់សេចក្ដីពុំឲ្យមានដេរដៀងលំអៀងដោយអគតិក្រែងមានបាបទៅនរកធ្លាក់ទៅអវិចិ ពុំហ៊ានករកូតឡើយ ហើយសូត្រសុភាពដកបងល់យារដីរំ មិនឲ្យខុសឆ្គងឲ្យជាសៅហ្មងនឹងចិត្តអ្នកផងទាំងឡាយ ឲ្យបានសុខសប្បាយ ឲ្យរាស្ត្រផងរំពៃខ្លាចបាបដកបជាអាចិន្ត្រៃប្រក្រតីស្រដីទៀងទាត់ ឲ្យមានពាក្យសត្យកុំឲ្យមានភ្លាត់ហោង ៗ

មានរឿងនិទានមួយថា

មានខ្លាពោលមួយទៅដេកលើរូងពស់វែក ពស់នោះលូនចេញមកលើកពពារកំសួលពិសចឹកខ្លានោះស្លាប់នៅមាត់រូង ថ្ងៃនោះជួនជាមហាឫសីមួយអគ្គគោចរទៅយល់ខ្លានោះស្លាប់គួរ ៗ មហាឫសីនោះអនិច្ចាករុណាខ្លានោះ មហាឫសីព្រោះខ្លានោះរស់ឡើងវិញ ហើយៈទើបខ្លានោះពោលថាអញដេកលក់ស្រណុកសប្បាយក្នុងព្រៃ ម្ដេចឡើយប្រស្ដូងកំរើកឲ្យអញភ្ញាក់ម៉្លះ អញខាំប្រស្ដូងពុំលែងឡើយ ៗ ទើបមហាឫសីឆ្លើយថា ប្រស្ដូងដេកលើរន្ធពស់វាចឹកកំសួលពិសស្លាប់ អញព្រោះប្រស្ដូងរស់ឡើងហើយគួរតែប្រស្ដូងសងគុណបុណ្យអញ ម្ដេចឡើយប្រស្ដូងនឹងខាំអញវិញ ម៉្លោះមហាឫសីនូវខ្លាប្រកែកជជែកគ្នា ពុំអស់ពុំហើយឡើយ ទើបមហាឫសីនូវខ្លានាំគ្នាទៅប្ដឹងចចកថ្លែងច្បាប់ដោយដំណើរទីទៃ ៗ ៗ ទើបចចកជញ្ជឹងក្នុងចិត្តថា អញនៅក្នុងព្រៃសព្វថ្ងៃពឹងពំនាក់

ដោយនូវអានុភាពខ្លា បើអញបង្គាប់សេចក្ដីនេះឲ្យខ្លាចាញ់ហើយសមអញពំនាក់ខ្លានៅនាព្រៃនេះពុំបានឡើយ កាលបើចចកគិតដូច្នោះហើយកាត់សេចក្ដីនេះឲ្យខ្លាស៊ីប្រស្ដែងមហាឫសីហោង ឯចចកបង្គាប់សេចក្ដីដូច្នេះនេះហៅឆន្ទាគតិ មហាឫសីពុំចូលចិត្តឡើយ ស្រដីប្រកែកគ្នាទៅវិញទៅមក ហើយនាំគ្នាទៅរកប្ដឹងគោឲ្យពិចារណា មហាឫសីនូវខ្លាថ្លែងប្រាប់ដោយដំណើរទើទៃ ៗ ហើយគោជញ្ជឹងក្នុងចិត្តថា បើអញបង្គាប់សេចក្ដីនេះឲ្យខ្លាចាញ់ហើយសមខ្លានេះក៏ស្អប់អញក៏ខាំអញហោង កាលបើគោគិតដូច្នោះហើយគោនោះកាត់សេចក្ដីឲ្យខ្លាសុំមហាឫសីហោង គោបង្គាប់សេចក្ដីដូច្នេះនេះហៅភយាគតិ ឯមហាឫសីពុំចូលចិត្តឡើយ ឯគោជាចៅក្រមកាត់សេចក្ដីដូច្នេះ លុះគោនោះស្លាប់ទៅនរកឧទុកបរិយន្តពន់ប្រមាណឥតឯសុំបានដល់តិចឡើយ ៗ

ទើបមហាឫសីនាំគ្នាទៅប្ដឹងស្វាឲ្យពិចារណា មហាឫសីនូវខ្លាប្រាប់ដោយដំណើរទើទៃ ៗ ហើយឯស្វាជញ្ជឹងក្នុងចិត្តថា កាលពីដីពុកអញធ្វើគុណនឹងបុរសមួយធ្លាក់ក្នុងអណ្ដូងដីពុកអញគាត់យកឡើងហើយ មានខ្លាមួយកន្ទឹងស៊ីបុរសនោះសោត ដីពុកអញគាត់លើកឡើងទុកលើឈើរួចអំពីភ័យហើយ បុរសនោះប្រែមកសម្លាប់ឯដីពុកអញវិញ ស្វានោះគិតរំពឹងដូច្នោះហើយ ទើបស្វានោះកាត់សេចក្ដីឲ្យខ្លាសុំហោង ឯមហាឫសីពុំចូលចិត្តឡើយ ទើបមហាឫសីនូវខ្លានាំគ្នាទៅប្ដឹងត្មាតឲ្យពិចារណា

មហាឫសីទូវខ្លាថ្លែងប្រាប់ដោយដំណើរទីទៃ ៗ ហើយឯគាត់រំពឹងដញ្ចឹង គិតក្នុងចិត្តថា សព្វថ្ងៃនេះអញបានរំពាដែលខ្លាជាអាហារបំណាំប្រក្រតីពុំដែលដាច់ បើអញបង្គាប់សេចក្ដីនេះឲ្យខ្លាចាញ់ហើយសូម្បីខ្លានេះរកខំនឹងទ្រឹង អញទៅម្ដេចនឹងបានស៊ីរំពាដែលខ្លានេះ កាលបើគាត់គិតដូច្នេះ គាត់ទើបកាត់សេចក្ដីដូច្នេះនេះហៅមោហាគតិ មហាឫសីពុំចូលចិត្តឡើយ ឯគាត់បង្គាប់សេចក្ដីពុំដោយសុចរិត ពុំពិតត្រង់ លុះដល់កាលណាគាត់នោះអស់អាយុស្លាប់អំពីនោះទៅ នឹងធ្លាក់ទៅនរកពុំលែងឡើយ ទើបមហា·ឫសីទូវខ្លានាំគ្នាទៅប្ដឹងទេព្រ័ក្យឲ្យពិចារណា មហាឫសីទូវខ្លាថ្លែងប្រាប់ដោយដំណើរទីទៃៗ ហើយទេព្រ័ក្សដញ្ចឹងគិតថា នាមនុស្សផងដើរព្រៃអាស្រ័យដោយម្លប់ឈើផងតាំងពួន សឹងតែកាច់មែកហែកសន្ទុកស្មោះសំបកធ្វើកកាត់ដើមគិតដូច្នោះហើយ កាត់សេចក្ដីឲ្យខ្លាស៊ីមហាឫសីហោង. ទេព្រ័ក្សបង្គាប់សេចក្ដីដូច្នោះនេះហៅមោហាគតិពុំទៀងត្រង់ឡើយ នោះមហាឫសីពុំចូលចិត្តឡើយ ៗ ទើបមហាឫសីទូវខ្លានាំគ្នាទៅប្ដឹងទន្សាយឲ្យពិចារណា មហាឫសីថានាប្រស្ដងខ្លានេះដេកលើរន្ធពស់វែក ពស់ចេញមកខាំប្រស្ដងនេះស្លាប់អញសែកមន្ដបោសពិសឲ្យរស់ អញគិតថាប្រស្ដងខ្លានេះយល់គុណអញ ឥឡូវនេះម្ដេចឡើយខ្លាក៏នឹងស៊ីអញវិញ ដូច្នេះតាម៉ែតប្រស្ដងទន្សាយពិចារណាឲ្យអញផង ទើបខ្លាប្ដឹងថាអញដេកលក់ស្រណុកសុខសប្បាយក្នុងព្រៃស្ថាននោះ ម្ដេចប្រស្ដងមហាឫសីឲ្យ

អញក្បាក់ដូច្នេះ អញខាំប្រើស្តូងឬសីនេះស៊ីពុំលែងឡើយ មហាឫសី
នាំអញទៅប្តឹងចចក ៗ បង្គាប់ឲ្យអញស៊ី ប្រើស្តូងឬសីនេះពុំស្រណុក
ចិត្តឡើយ ទើបនាំអញទៅប្តឹងគោ ៗ បង្គាប់ឲ្យអញស៊ីប្រើស្តូងឬសី ៗ ពុំ
ចូលចិត្តឡើយ ទើបអញទៅប្តឹងស្វា ៗ បង្គាប់ឲ្យអញស៊ីប្រើស្តូងឬសីប្រើ-
ស្តូងឬសីនោះពុំស្រណុកចិត្តឡើយ ទើបអញនាំទៅប្តឹងត្មាត ៗ បង្គាប់
អញឲ្យស៊ី ប្រើស្តូងឬសីនេះពុំស្រណុកចិត្តឡើយ ទើបអញនាំទៅប្តឹង
ទេព្រីក្ស ៗ បង្គាប់ឲ្យអញស៊ី ប្រើស្តូងឬសីពុំស្រណុកចិត្តឡើយ ទើប
អញនាំមកប្តឹងប្រើស្តូង តាមតែប្រើស្តូងទន្សាយពិចារណាឲ្យអញផង ៗ
ទន្សាយស្តាប់មហាឫសីនូវពាក្យខ្លាហើយ ពិចារណាដោយនូវប្រាជ្ញា
ឈ្លាសវៃឈ្វេងយល់អាថ៌សេចក្តីហើយទន្សាយបង្គាប់ថា បើដូច្នោះប្តូរ
មហាឫសីនូវបង់ខ្លានាំគ្នាទៅដល់ស្ថានដែលនៅនោះ ហើយឲ្យបង់ខ្លា
ដេកលក់ស្រណុកដូចអំពីដើមហើយឲ្យមហាឫសីចូលទៅដល់ដែលដេក
នោះ ឲ្យបានអញយល់នឹងពិចារណាដោយនូវប្រការនោះ កាលបើ
ដូច្នោះមហាឫសីនូវខ្លាបបួលគ្នានាំទាំងទន្សាយទៅដល់លំនៅហើយខ្លា
នៅស្ថានដដែលនោះ លុះយូរបន្តិចក្លូវពស់វែកចេញមកខាំខ្លាមិញស្លាប់
នៅមាត់ន្លេនោះហោង កាលបើខ្លានោះស្លាប់ហើយ ទន្សាយថា មហា-
ឫសីព្រះអង្គមើលខ្លានោះ ហេតុតែឥតធម៌ផ្ទើងក្តេចគុណគេ ឥឡូវនេះ
ពុំលែងនឹងវេកកម្មដំណអំពីនោះទៅមុខម្ចាស់កុំធ្វើគុណនឹងខ្លានេះហោង ។